ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ការប្រមូលឯកសារច្បាប់ស្តីពីការងារ

## ព្រះរាជក្រម

## អនុក្រឹត្យ

## ប្រកាស

## សារាចរ

## សេចក្តីជូនដំណឹង

២០០៦

ខ្ញុំបាទ តូ តក្តី សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងអង្គការILOដែលបានរៀបចំប្រមូលចងនូវឯកសារនេះឡើងដើម្បីធ្វើអោយមានលក្ខណៈកាន់តែងាយស្រួលចំពោះអ្នកស្រាវជ្រាវ ជាពិសេស និស្សិតច្បាប់ ។

ខ្ញុំបាទសូមគោរពជូនពរ សម្តេច ទ្រង់ឯកឧត្តម លោកជំទាវ លោកលោកស្រី ជាមន្ត្រីរាជការ បុគ្គលិកក្រុមប្រឹក្សាអាជ្ញាកណ្តាល និងបុគ្គលិកនៃអង្គការILO សូមមានសុខភាពល្អ និងប្រកបកិច្ចការងារទទួលជោគជ័យគ្រប់ពេលវេលា ។

PHEAKDEY.COM

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កម្រងឯកសារច្បាប់ស្តីពីការងារ

ព្រះរាជក្រម

អនុក្រឹត្យ

ប្រកាស

សារាចរ

សេចក្តីជូនដំណឹង

២០០៦

ខ្ញុំបាទ តូ តក្តី សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងអង្គការILOដែលបានរៀបចំប្រមូលចងនូវឯកសារនេះឡើងដើម្បីធ្វើអោយមានលក្ខណៈកាន់តែងាយស្រួលចំពោះអ្នកស្រាវជ្រាវ ជាពិសេស និស្សិតច្បាប់ ។

ខ្ញុំបាទសូមគោរពជូនពរ សម្តេច ទ្រង់ឯកឧត្តម លោកជំទាវ លោកលោកស្រី ជាមន្ត្រីរាជការ បុគ្គលិកក្រុមប្រឹក្សាអាជ្ញាកណ្តាល និងបុគ្គលិកនៃអង្គការILO សូមមានសុខភាពល្អ និងប្រកបកិច្ចការងារទទួលជោគជ័យគ្រប់ពេលវេលា ។

PHEAKDEY.COM

SOC L05

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កម្រងឯកសារច្បាប់ស្តីពីការងារ

## ព្រះរាជក្រម

## អនុក្រឹត្យ

## ប្រកាស

## សារាចរ

## សេចក្តីជូនដំណឹង

២០០៦

# កម្រងឯកសារច្បាប់ស្តីពីការងារ
# ព្រះរាជក្រម-អនុក្រឹត្យ-ប្រកាស-សារាចរ
# សេចក្តីជូនដំណឹង

# ក្រុមប្រឹក្សាអាជ្ញាកណ្តាល

បោះពុម្ពដោយមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល

រៀបរៀង និងចងក្រងដោយ
លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល
ថូ ម៉ុនថន
ពិនិត្យ និងវាយអត្ថបទដោយ
សាម សុវណ្ណឌី
លោកស្រី មូ ចន្ទ័វាសនា

p

កម្រងឯកសារច្បាប់ស្តីពីការងារ រួមមាន : ព្រះរាជក្រម អនុក្រឹត្យ ប្រកាស សារាចរ និង សេចក្តីជូនដំណឹង បានចម្លងតាមច្បាប់ដើមទាំងស្រុង

ថវិកាសម្រាប់ការបោះពុម្ពផ្សាយនេះត្រូវបានផ្តល់ដោយ ក្រសួងការងារនៃសហរដ្ឋអាមេរិក តាមរយៈគម្រោងដោះស្រាយវិវាទការងារនៅកម្ពុជា នៃអង្គការពលកម្មអន្តរជាតិ

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០០៦

# អារម្ភកថា

កម្រងឯកសារច្បាប់ស្តីពីការងារ ដែលលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានរៀបចំ និងចងក្រងឡើងនេះ គឺជាកម្រងឯកសារទាំងឡាយដែលបានមកពីក្រសួងទទួលបន្ទុកវិស័យការងារ រួមជាមួយក្រសួង-ស្ថាប័ន ពាក់ព័ន្ធមួយចំនួនទៀត ដែលបានខិតខំយកចិត្តទុកដាក់រៀបចំ និងតាក់តែងឡើងនូវបទប្បញ្ញត្តិពាក់ព័ន្ធ និងបទដ្ឋានការងារ ព្រមទាំងលិខិតគតិយុត្តិដទៃទៀត ដែលកំពុងស្ថិតនៅជាធរមានដូចជា ព្រះរាជក្រម ,អនុក្រឹត្យ ,ប្រកាស ,សារាចរ ,សេចក្តីជូនដំណឹង និងសេចក្តីណែនាំ ដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់ ការអនុវត្តច្បាប់ស្តីពីការងារ ដែលកំពុងតែអនុវត្តនាពេលសព្វថ្ងៃនេះ ។

គោលបំណងសំខាន់នៃកម្រងឯកសារច្បាប់ស្តីពីការងារនេះគឺ ដើម្បីធ្វើឱ្យកាន់តែមានភាពងាយស្រួលថែមទៀតក្នុងការស្វែងរក និងប្រើប្រាស់នូវឯកសារច្បាប់នេះ ជាពិសេសងាយស្រួលក្នុងការអនុវត្តការងារជាប្រចាំសំរាប់អ្នកធ្វើការនៅតាមសហគ្រាស គ្រឹះស្ថាននានា ព្រមទាំងសំរាប់ជួយដល់អ្នកសិក្សាស្រាវជ្រាវបានយល់នូវនីតិវិធីនៃការអនុវត្តច្បាប់ស្តីពីការងារនេះផងដែរ ។

សៀវភៅ "**កម្រងឯកសារច្បាប់ស្តីពីការងារ**" ដែលបានរៀបចំឡើងនេះ យើងខ្ញុំបានចម្លងយកតាមច្បាប់ដើមទាំងស្រុង ដោយពុំមានធ្វើការកែសម្រួលនូវពាក្យពេចន៍ ឬឃ្លាប្រយោគអ្វីឡើយ ។

យើងខ្ញុំសង្ឃឹមថា កម្រងឯកសារច្បាប់ស្តីពីការងារនេះ ពិតជាបានផ្តល់នូវគំនិតល្អៗសំរាប់ធ្វើការត្រិះរិះពិចារណា ដែលនេះជាប្រយោជន៍មួយសំរាប់ការអភិវឌ្ឍន៍ធនធានមនុស្សផង និងការអភិវឌ្ឍន៍សង្គមផង ព្រោះថា នេះជាសមិទ្ធិផលដែលបានមកពីការសិក្សាស្រាវជ្រាវ ប្រមែប្រមូលនូវរាល់ឯកសារទាំងឡាយដែលពាក់ព័ន្ធ និងការអនុវត្តច្បាប់ស្តីពីការងារ ដែលបានអនុវត្តនៅព្រះរាជាណាចក្រកម្ពុជាយើងនេះ ។ ជាពិសេស កម្រងឯកសារច្បាប់ស្តីពីការងារនេះ ពិតជាអាចធ្វើជាជំនួយដល់អស់លោកអ្នកជាពុំខានឡើយ ។

យើងខ្ញុំក៏សូមស្វាគមន៍នូវរាល់ការរិះគន់ ការទិតៀន និងសំណូមពរផ្សេងៗ ពីសំណាក់អ្នកសិក្សាគ្រប់មជ្ឈដ្ឋានទូទៅផងដែរ ។

**សូមអរគុណ !**

## មាតិកា

**ផ្នែកទី១: ព្រះរាជក្រម** **ទំព័រ**


០១-ព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥

ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ---------------- ០១-០២


**ផ្នែកទី២: អនុក្រឹត្យ**


០១-អនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥

ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និង បណ្តុះបណ្តាល

វិជ្ជាជីវៈ------------------------------------------------០៣-១៨

០២-អនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៦

ស្តីពីសមាសភាព និងការប្រព្រឹត្តទៅនៃគណៈកម្មការប្រឹក្សាការងារ --------- ១៩-២៤

០៣-អនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៥

ស្តីពីការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស -------------------- ២៥-២៩


**ផ្នែកទី៣: ប្រកាស**


០១-ប្រកាសរួមលេខ ០៨ សកអ/៩៤ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៤

p

ស្តីពីការចាត់តាំងបណ្តាញពេទ្យការងារ ----------------------------៣០-៣៣

០២-ប្រកាសរួមលេខ ០៩ សកអ/៩៤ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៩៤

ស្តីពីការពិនិត្យកាយសម្បទា សំរាប់ជនកម្ពុជា និងជនបរទេស

ដែលប្រកបមុខរបរ នៅព្រះរាជាណាចក្រកម្ពុជា -------------------- ៣៤-៣៥

០៣-ប្រកាសរួមលេខ ៨៦ សកអ. ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៩៧

ស្តីពីប្រាក់ឈ្នួលយោងប្រចាំថ្ងៃ --------------------------------------៣៦

០៤-ប្រកាសលេខ ១០ សកបយ. ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៩

ស្តីពីប្រាក់បំណាច់នៃការងារ ដែលបានធ្វើក្នុងឱកាសថ្ងៃឈប់បុណ្យ

ដែលត្រូវមានប្រាក់ឈ្នួល --------------------------------៣៧-៣៨

០៥-ប្រកាសលេខ ៨០ សកបយ. ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ១៩៩៩

ស្តីពីការធ្វើការបន្ថែមម៉ោងក្រៅពីថិរវេលាធ្វើការធម្មតា ---------------- ៣៩-៤១

០៦-ប្រកាសលេខ ០០៤ សកបយ. ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០០
ស្តីពីការហ្វឹកហ្វឺនកូនជាង ---------------------------------------- ៤២-៤៦
០៧-ប្រកាសលេខ ០៥២ សកបយ. ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០០
ស្តីពីការរៀបចំបង្គន់អនាម័យ ------------------------------------- ៤៧-៤៨
០៨-ប្រកាសលេខ ០៥៣ សកបយ. ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០០
ស្តីពីកៅអីអង្គុយនៅប៉ុស្តិ៍ការងារ ---------------------------------- ៤៩-៥០
០៩-ប្រកាសលេខ ០៥៤ សកបយ. ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០០
ស្តីពីការផ្តល់ភេសជ្ជៈអនាម័យ ------------------------------------- ៥១-៥២
១០-ប្រកាសលេខ ០៨១ សកបយ. ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០០០
ស្តីពីការដាក់លក្ខខណ្ឌការងារសំរាប់វិជ្ជាជីវៈដែលមិនទាន់មានអនុសញ្ញារួម ---- ៥៣-៥៤
១១-ប្រកាសលេខ ២៦៨ សកបយ. ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០០
ស្តីពីការផ្តល់វិញ្ញាបនប័ត្រអនុវត្តច្បាប់ស្តីពីការងារចំពោះសហគ្រាស គ្រឹះស្ថាន -- ៥៥-៥៦
១២-ប្រកាសលេខ ៣១៣ សកបយ. ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០០
ស្តីពីតួនាទី ភារកិច្ចរបស់ប្រតិភូបុគ្គលិក និងសហជីព ------------------- ៥៧-៥៨
១៣-ប្រកាសរួមលេខ ៣៣០ សកបយ. ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០០
ស្តីពីការរៀបចំគិលានដ្ឋានសហគ្រាស ------------------------------ ៥៩-៦៣
១៤-ប្រកាសរួមលេខ ៥៦ សកបយ. ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១
ស្តីពីអាករប័ណ្ណការងារ និងសៀវភៅការងារ ------------------------ ៦៤-៦៥
១៥-ប្រកាសលេខ ១២៤ សកបយ. ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០១
ស្តីពីការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្ម ------------------------ ៦៦-៦៨
១៦-ប្រកាសលេខ ១២៥ សកបយ. ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០១
ស្តីពីការបញ្ចេញបញ្ចូលខ្យល់ និងការសំអាតបរិយាកាសក្នុងទីកន្លែងធ្វើការ ---- ៦៩-៧០
១៧-ប្រកាសរួមលេខ ១៣៩ សកបយ. ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០១
ស្តីពីលក្ខខណ្ឌ និងបេសកម្មសេវាពេទ្យសហគ្រាស --------------------- ៧១-៧៤
១៨-ប្រកាសលេខ ១៦១ សកបយ. ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០១
ស្តីពីការប្រើប្រាស់ហត្ថពលកម្មបរទេស ----------------------------- ៧៥-៧៦
១៩-ប្រកាសលេខ ២៣៧ សកបយ. ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០១
ស្តីពីការបង្កើតប៉ុស្តិ៍អធិការកិច្ចការងារនៅតាមខណ្ឌនានានៃរាជធានីភ្នំពេញ ---- ៧៧-៨០

២០-ប្រកាសលេខ ២៦៧ សកបយ. ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១
ស្តីពីការឈប់សំរាកពិសេស ------------------------------------ ៨១-៨២
២១-ប្រកាសលេខ ២៦៨ សកបយ. ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១
ស្តីពីសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន -------------------------------- ៨៣-៨៧
២២-ប្រកាសលេខ ២៦៩ សកបយ. ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០០១
ស្តីពីការបង្កើតសៀវភៅបើកប្រាក់ ------------------------------- ៨៨-៩២
២៣-ប្រកាសលេខ ២៨៦ សកបយ. ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០១
ស្តីពីប្រតិភូបុគ្គលិកនៅក្នុងសហគ្រាស គ្រឹះស្ថាន --------------------- ៩៣-៩៦
២៤-ប្រកាសលេខ ២៨៧ សកបយ. ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០១
ស្តីពីបែបបទចុះបញ្ជិកា ការផ្សព្វផ្សាយ និងការត្រួតពិនិត្យការអនុវត្ត
អនុសញ្ញារួម ----------------------------------------------៩៧-៩៩
២៥-ប្រកាសលេខ ២៨៨ សកបយ. ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០១
ស្តីពីសេចក្តីប្រកាសជូនដំណឹងបើក និងបិទសហគ្រាស គ្រឹះស្ថាន ---------១០០-១០៤
២៦-ប្រកាសលេខ ៣០៥ សកបយ. ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១
ស្តីពីភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិតនៅថ្នាក់
សហគ្រាស គ្រឹះស្ថាន និងសិទ្ធក្នុងការចរចាជាសមូហភាព ដើម្បីចុះ
អនុសញ្ញារួមនៅថ្នាក់សហគ្រាស គ្រឹះស្ថាន --------------------- ១០៥-១១៣
២៧-ប្រកាសលេខ ៣១៥ សកបយ. ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០១
ស្តីពីរបៀបគិតអតីតភាពការងារដើម្បីកំណត់ថិរវេលា ដែលត្រូវឱ្យដំណឹងមុន
សំរាប់កម្មករនិយោជិតដែលមិនធ្វើការប្រចាំខែ ------------------ ១១៤-១១៥
២៨-ប្រកាសលេខ ៣១៦ សកបយ. ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០១
ស្តីពីការប្រើប្រាស់កម្មករនិយោជិតប្រភេទខ្លះខុសពីម៉ោងធ្វើការរួម ------ ១១៦-១១៧
២៩-ប្រកាសលេខ ៣១៧ សកបយ. ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០១
ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទការងាររួម ------------------- ១១៨-១២០
៣០-ប្រកាសលេខ ៣១៨ សកបយ. ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០១
ស្តីពីនីតិវិធីនៃការដោះស្រាយវិវាទការងារបុគ្គល ----------------- ១២១-១២៣
៣១-ប្រកាសលេខ ៣២៨ សកបយ. ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០១
ស្តីពីការតែងតាំងសមាជិកនៃគណៈកម្មការប្រឹក្សាការងារ----------- ១២៤-១២៦

៣២-ប្រកាសលេខ ១០០ សកបយ. ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០០២

ស្តីពីការព្យួរការសំរាកប្រចាំសប្តាហ៍ ---------------------------- ១២៧-១២៩

៣៣-ប្រកាសលេខ ១៤២ សកបយ. ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២

ស្តីពីការបែងចែកម៉ោងធ្វើការក្នុងសប្តាហ៍ដើម្បីឱ្យបានឈប់សំរាក

បន្ថែមនារសៀលថ្ងៃសៅរ៍ -------------------------------- ១៣០-១៣១

៣៤-ប្រកាសលេខ ១៤៣ សកបយ. ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២

ស្តីពីការបែងចែកម៉ោងធ្វើការក្នុងរយៈពេលក្រៅពីសប្តាហ៍ធម្មតា

ដោយគិតជាមធ្យមចំនួន១២សប្តាហ៍បន្តបន្ទាប់ ------------------- ១៣២-១៣៣

៣៥-ប្រកាសលេខ ១៤៤ សកបយ. ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២

ស្តីពីបដិប្បញ្ញត្តិចំពោះការហាមឃាត់មិនឱ្យប្រើក្មេងធ្វើការពេលយប់ -----១៣៤-១៣៥

៣៦-ប្រកាសលេខ ១៤៥ សកបយ. ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០២

ស្តីពីការហ្វឹកហ្វឺនវិជ្ជាជីវៈដល់ក្មេងសំរាប់ធ្វើការក្រោមដី ------------- ១៣៦-១៣៧

៣៧-ប្រកាសលេខ ១៤៧ សកបយ. ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០២

ស្តីពីបរិយាកាសណ៍កំដៅក្នុងទីកន្លែងធ្វើការ ------------------------១៣៨-១៣៩

៣៨-ប្រកាសលេខ ២៤៣ សកបយ. ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ ២០០២

ស្តីពីការជូនដំណឹងគ្រោះថ្នាក់ការងារ របៀបផ្តល់តាវកាលិក

និង អត្រាបាត់បង់សមត្ថភាពការងារ ------------------------- ១៤០-១៦៥

៣៩-ប្រកាសលេខ ០៩៦ សកបយ. ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៣

ស្តីពីការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល ---------------------- ១៦៦-១៦៨

៤០-ប្រកាសលេខ ១៣៨ សកបយ. ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៣

ស្តីពីសំឡេងក្នុងទីកន្លែងធ្វើការ ------------------------------ ១៦៩-១៧០

៤១-ប្រកាសលេខ ១៣៩ សកបយ. ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៣

ស្តីពីការងារក្នុងមណ្ឌលហប់---------------------------------- ១៧១-១៧៣

៤២-ប្រកាសលេខ ១៧៤ សកបយ. ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៣

ស្តីពីការបង្កើតលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ----------- ១៧៤-១៧៥

៤៣-ប្រកាសលេខ ៤៣៧ សកបយ. ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៣

ស្តីពីការផ្លាស់ប្តូរសមាសភាពសមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល--------១៧៦-១៧៧

៤៤-ប្រកាសលេខ ៤៨៤ សកបយ. ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០០៣
ស្តីពីពន្លឺ និងការបំភ្លឺ ----------------------------------------១៧៨-១៨៤

៤៥-ប្រកាសលេខ ០២៩ សកបយ. ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០៤
ស្តីពីការផ្លាស់ប្តូរសមាសភាពសមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល -------១៨៥-១៨៦

៤៦-ប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤
ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ---------------------------------១៨៧-២០៥

៤៧-ប្រកាសលេខ ១០៣ សកបយ. ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៤
ស្តីពីការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល ------------------------២០៦-២០៨

៤៨-ប្រកាសលេខ ១០៦ សកបយ. ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៤
ស្តីពីការហាមឃាត់កុមារធ្វើការនៅកន្លែងការងារ
ប្រកបដោយគ្រោះថ្នាក់-------------------------------------២០៩-២១៥

៤៩-ប្រកាសលេខ ២៦៥ សកបយ. ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤
ស្តីពីការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល ---------------------- ២១៦-២១៨

៥០-ប្រកាសលេខ ៤១៦ កកបវ. ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤
ស្តីពីការបង្កើតគណៈកម្មការប្រឹក្សាគម្រោងតាមឃ្លាំមើលលក្ខខណ្ឌការងារ
នៅក្នុងវិស័យវាយនភណ្ឌ និងសំលៀកបំពាក់នៅកម្ពុជា-------------- ២១៩-២២១

៥១-ប្រកាសលេខ ៤៥៣ កកបវ. ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៤
ស្តីពីការបង្កើតគណៈកម្មការប្រឹក្សាគម្រោងដោះស្រាយវិវាទការងារ
នៅកម្ពុជា------------------------------------------------ ២២២-២២៤

៥២-ប្រកាសលេខ ៤១៣ កកបវ. ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៥
ស្តីពីប័ណ្ណការងារ និងសៀវភៅការងារជនបរទេស ------------------២២៥-២២៨

៥៣-ប្រកាសលេខ ៤១៤ កកបវ. ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៥
ស្តីពីសៀវភៅការងារកម្មករនិយោជិតខ្មែរ ---------------------- ២២៩-២៣១

៥៤-ប្រកាសលេខ ៥១៣ កកបវ. ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៥
ស្តីពីការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល ----------------------២៣២-២៣៥

៥៥-ប្រកាសលេខ ១៨៨៦ កកបវ. ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៥
ស្តីពីការឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួលប្រចាំឆ្នាំ ២០០៦ ---------២៣៦-២៣៨

៥៦-ប្រកាសលេខ ០២១ កកបវ/ប្រក. ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៦
ស្តីពីការចុះបញ្ជិកានៃអង្គការវិជ្ជាជីវៈ -------------------------២៣៩-២៤១
៥៧-ប្រកាសលេខ ០៩៩ កកបវ. ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៦
ស្តីពីការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល --------------------- ២៤២-២៤៥

## ផ្នែកទី៤: សារាចរ

០១-សារាចរលេខ ០១ សកអ. ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ១៩៩៧
ស្តីពីសន្តិសុខ និងអនាម័យការងារចំពោះកម្មករនិយោជិត
ការគោរពសិទ្ធិ កិត្តិយសរបស់កម្មករនិយោជិត ------------------- ២៤៦-២៤៨
០២-សារាចរលេខ ៤០ សកអ. ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ១៩៩៨
អំពីការបិទផ្សាយលិខិតបទដ្ឋាននានា ---------------------------២៤៩-២៥០
០៣-សារាចរលេខ ០២១ សកបយ. ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៩
ស្តីពីការចាត់តាំងបុគ្គលិកទំនាក់ទំនងនៅតាមរោងចក្រ
សហគ្រាស កាត់ដេរ ------------------------------------ ២៥១-២៥២
០៤-សារាចរលេខ ០២៤ សកបយ. ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៩
ស្តីពីប្រាក់ឈ្នួលនៃការងារពេលយប់ -------------------------- ២៥៣-២៥៤
០៥-សារាចរលេខ ០០៥ សកបយ. ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០០០
ស្តីពីសិទ្ធិធ្វើកូដកម្ម ------------------------------------ ២៥៥-២៥៦
០៦-សារាចរលេខ ០១២ សកបយ. ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០០០
ស្តីពីការអនុវត្តវិធានការអនាម័យ និងសន្តិសុខការងារ
នៅតាមគ្រឹះស្ថានផលិតផជួ -------------------------------- ២៥៧-២៥៨
០៧-សារាចរលេខ ១២ សកបយ. ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០២
ស្តីពីការដោះស្រាយវិវាទការងារ ---------------------------- ២៥៩-២៦០

## ផ្នែកទី៥: សេចក្តីជូនដំណឹង

០១-សេចក្តីជូនដំណឹងអន្តរក្រសួង ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៦ -------២៦១-២៦៣
០២-សេចក្តីជូនដំណឹងលេខ ០៦ សកអ. ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៧----- ២៦៤-២៦៦

០៣- សេចក្តីជូនដំណឹងលេខ ១២ សកអ. ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៩៧

ស្តីពីបណ្ណ័ការងារ និងសៀវភៅការងារជនបរទេស ------------------២៦៧-២៦៨

០៤- សេចក្តីជូនដំណឹងលេខ ១៣ សកអ. ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៩៧

ស្តីពីសៀវភៅការងាររបស់និយោជិត-កម្មករខ្មែរ -------------------២៦៩-២៧០

០៥-សេចក្តីជូនដំណឹងលេខ ០១៤ សកបយ. ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៩ ---- ២៧១-២៧២

០៦-សេចក្តីជូនដំណឹងលេខ ១៥ សកបយ. ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០០ --- ២៧៣-២៧៤

០៧-សេចក្តីជូនដំណឹងលេខ ០១៧ សកបយ. ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ --- ២៧៥-២៧៧

០៨-សេចក្តីជូនដំណឹងលេខ ២០ សកបយ. ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០០----------២៧៨

០៩-សេចក្តីណែនាំលេខ ២៦ សកបយ. ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០០

ស្តីពីការផ្តល់ដំណឹងអំពីកន្លែងធ្វើការទំនេរ ------------------------២៧៩-២៨១

១០-សេចក្តីជូនដំណឹងលេខ ២៧ សកបយ. ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០០

ស្តីពីសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក (កម្មករនិយោជិត) ----- ២៨២-២៨៣

១១-សេចក្តីណែនាំលេខ ០០៣ សកបយ. ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០១

ស្តីពីនីតិវិធីក្នុងការអនុវត្តន៍ប្រកាសលេខ ០០៤ សកបយ ចុះថ្ងៃទី០៥

ខែមករា ឆ្នាំ២០០០ ស្តីពីការហ្វឹកហ្វឺនកូនជាង --------------------២៨៤-២៨៦

១២-សេចក្តីជូនដំណឹងលេខ ១៤ សកបយ. ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០១ ----២៨៧-២៨៩

១៣-សេចក្តីជូនដំណឹងលេខ ៣២ សកបយ. ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០១-------២៩០-២៩១

១៤-សេចក្តីជូនដំណឹងលេខ ០៣ សកបយ. ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០២ ---------២៩២

១៥-សេចក្តីជូនដំណឹងលេខ ០៧ សកបយ. ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០២

ការបន្តអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង និងការធ្វើតេស្តលើ

កម្មករចាស់ ចំពោះសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ដែលពុំទាន់

បានចាប់ផ្តើមអនុវត្តក្នុងឆ្នាំ ២០០១ ---------------------------២៩៣-២៩៥

១៦-សេចក្តីជូនដំណឹងលេខ ១៤ សកបយ. ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០២

ស្តីពីការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស គ្រឹះស្ថាន ------------- ២៩៦-២៩៩

១៧-សេចក្តីជូនដំណឹងលេខ ១៦ សកបយ. ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០២

ស្តីពីការចុះបញ្ជិកាអង្គការវិជ្ជាជីវៈ និងការបញ្ជាក់ភាពជាតំណាង

របស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត ------------------------៣០០-៣០៤

១៨-សេចក្តីជូនដំណឹងលេខ ០១ សកបយ. ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០០៣ --- ៣០៥-៣០៧

១៩-សេចក្តីណែនាំ ០៨ សកបយ. ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០០៣ --- ៣០៨-៣០៩

២០-សេចក្តីជូនដំណឹងលេខ ១១ សកបយ. ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៣ --- ៣១០-៣១១

២១-សេចក្តីជូនដំណឹងលេខ ០១៦ សកបយ. ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០០៣ -----------៣១២

២២-សេចក្តីជូនដំណឹងលេខ ០០៣ សកបយ. ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៤---- ៣១៣-៣១៤

២៣-សេចក្តីជូនដំណឹងលេខ ០១៣ សកបយ. ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៤
ស្តីពីបទប្បញ្ញត្តិទូទៅ និងនីតិវិធីនៃការរៀបចំការបោះឆ្នោតសំរេច
ភាពជាតំណាងបំផុតរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិតនៅ
ថ្នាក់សហគ្រាស គ្រឹះស្ថាន------------------------------------៣១៥-៣១៨

**ផ្នែកទី៦: ប្រកាសថ្មី**

០១-ប្រកាសលេខ ១៣៨ កកបវ/ប្រក. ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៦
ស្តីពីការតែងតាំងគណៈកម្មការប្រឹក្សាការងារ-------------------- ៣១៩-៣២២

ဢ ဢ ဢ ❖ ဣ ဣ ဣ

p

# ព្រះរាជក្រម

p

# ព្រះរាជក្រម

នស/រកម/០១០៥/០០៣

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី
ចូល លេខ: 4482 ថ្ងៃទី 24/11/04 ម៉ោង.......

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
ចូល លេខ: 218 ថ្ងៃទី 21/01/05 ម៉ោង

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស /រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញតាមសេចក្តីសម្រេចលេខ ០៦៦/០០៨/២០០៤ កបធ.ច ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

Coml/Kram 4

# ច្បាប់
# ស្តីពី
# ការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**មាត្រា ១.-**

ត្រូវបានបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចំណុះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានសមត្ថកិច្ចដឹកនាំនិងគ្រប់គ្រងលើវិស័យការងារ និងវិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវបានដឹកនាំដោយរដ្ឋមន្ត្រីមួយរូប ដែលអមដោយរដ្ឋលេខាធិការ និង/ឬអនុរដ្ឋលេខាធិការតាមការចាំបាច់ ។

**មាត្រា ៤.-**

ការរៀបចំរចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦.-**

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ. ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

ពរល.០៥០១.០១៦ នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

លេខ ១៧ ច.ល
[illegible]
រាជធានីភ្នំពេញ. ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible]

# អនុក្រឹត្យ

## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តទៅ

## របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៥

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់ការរៀបចំបណ្ដាអង្គភាពនៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងកំណត់បេសកកម្មរបស់ក្រសួង និងមុខការនៃបណ្ដាអគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន នាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួង ។

## ជំពូកទី ២
## បេសកកម្ម និងរចនាសម្ព័ន្ធ

**មាត្រា ២.-**

ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈត្រូវបានរាជរដ្ឋាភិបាលកម្ពុជាប្រគល់បេសកកម្មឱ្យដឹកនាំ និងគ្រប់គ្រងវិស័យការងារ និងវិស័យបណ្ដុះបណ្ដាលវិជ្ជាជីវៈ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣.-**

ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈមានមុខងារ និងភារកិច្ច ជាអាទិ៍ដូចតទៅ ៖

*ក- វិស័យការងារ ៖*

- អនុវត្តច្បាប់ស្ដីពីការងារ សំដៅធានា កែលំអអនាម័យនិងសុវត្ថិភាពការងារ សុខភាពរបស់កម្មករនិយោជិត និងលក្ខខណ្ឌធ្វើការងារនៅក្នុងសហគ្រាស គ្រឹះស្ថាន
- ធ្វើអធិការកិច្ចតាមសហគ្រាស គ្រឹះស្ថាន តាមការកំណត់នៃបទប្បញ្ញត្តិស្ដីពីរដ្ឋបាលការងារ
- តាមដានការអនុវត្តច្បាប់ស្ដីពីការងារ និងបទប្បញ្ញត្តិពាក់ព័ន្ធទៅនឹងបទដ្ឋានការងារ លក្ខខណ្ឌការងារ អនាម័យ និងសុវត្ថិភាពការងារ និងការការពារសុខភាពកម្មករនិយោជិត
- ជួយការពារ និងសម្របសម្រួលទំនាក់ទំនងរវាងបណ្ដាអង្គការតំណាងរបស់កម្មករនិយោជិត និងសមាគមនិយោជក និងបណ្ដាការងារនៃសេដ្ឋកិច្ចមិនរៀបរយ
- ធ្វើការសម្របសម្រួលរាល់ទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន អង្គការនានា ក្នុងតំបន់ និងលើសកលលោក ដើម្បី ជំរុញវិស័យការងារ ដោយសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ដំណើរការតាមនីតិវិធីនូវការដោះស្រាយវិវាទការងាររួម និងបុគ្គល
- គ្រប់គ្រងការងារប្រើប្រាស់ពលកម្មកម្ពុជាទាំងក្នុង និងក្រៅប្រទេស និងសហការក្នុងការគ្រប់គ្រងជនបរទេស ដែលចូលមកប្រកបមុខរបរនៅក្នុងប្រទេស
- សិក្សា និងរៀបចំគោលនយោបាយជាតិស្ដីពីការគ្រប់គ្រងមុខរបរ និងហត្ថពលកម្ម
- ដាក់ឱ្យអនុវត្តច្បាប់ស្ដីពីរបបសន្តិសុខសង្គម សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់

ស្តីពីការងារ និងដំណើរការបេឡាជាតិរបបសន្តិសុខសង្គម

- អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិដែលពាក់ព័ន្ធនឹងពលកម្មកុមារ ។

*ខ- វិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ ៖*

- សិក្សា និងរៀបចំគោលនយោបាយជាតិស្តីពីមុខរបរ ដើម្បីធ្វើការប្តូរសរុបសេចក្តីត្រូវការនៃទីផ្សារការងារ។
- ដាក់តែង និងអភិវឌ្ឍនយោបាយស្តីពីមុខរបរ ដោយឈរលើនយោបាយជាតិសម្រាប់ការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ដាក់តែង និងអភិវឌ្ឍគោលនយោបាយជាតិសម្រាប់ការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ដាក់តែងគោលការណ៍ និងគ្រប់គ្រងប្រព័ន្ធអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ពិនិត្យសំណើសុំបង្កើត ទទួលស្គាល់ គ្រឹះស្ថាន មជ្ឈមណ្ឌល ថ្នាក់រៀនអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈគ្រប់ប្រភេទ ។
- គ្រប់គ្រង ត្រួតពិនិត្យ និងវាយតម្លៃគ្រឹះស្ថានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈ និងឯកជន ,
- ធ្វើការសម្របសម្រួលរាល់ទំនាក់ទំនងជាមួយក្រសួង ស្ថាប័ន អង្គការនានា ក្នុងតំបន់ និងពិភពលោក ដើម្បីជំរុញការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ,
- សហការជាមួយសហគ្រាស គ្រឹះស្ថាន ដើម្បីពង្រីង និងលើកកំពស់ការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ដាក់តែង និងអភិវឌ្ឍស្តង់ដារមុខរបរស្របតាមសេចក្តីត្រូវការទីផ្សារការងារក្នុង និងក្រៅប្រទេស ,
- រៀបចំ និងគ្រប់គ្រងការធ្វើតេស្តអំពីវិជ្ជាជីវៈ គ្រប់ប្រភេទមុខរបរ និងធ្វើការផ្តល់ ឬដកហូតប័ណ្ណទទួលស្គាល់វិជ្ជាជីវៈ ដោយយោងតាមលទ្ធផលនៃការធ្វើតេស្ត ,
- គ្រប់គ្រងការងារហ្វឹកហ្វឺនកូនជាង និងយន្តការនៃការហ្វឹកហ្វឺនកូនជាង តាមច្បាប់ស្តីពីការងារ ។

មាត្រា ៤.-

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានរចនាសម្ព័ន្ធដូចតទៅ ៖

១- ថ្នាក់កណ្តាល ៖

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុមាន ៖

- នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក
- នាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម
- នាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ
- នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ។

អគ្គនាយកដ្ឋានការងាររួមមាន ៖

- នាយកដ្ឋានអធិការកិច្ចការងារ
- នាយកដ្ឋានវិវាទការងារ
- នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម
- នាយកដ្ឋានសន្តិសុខសង្គម
- នាយកដ្ឋានការងារកុមារ
- នាយកដ្ឋានពេទ្យការងារ ។

អគ្គនាយកដ្ឋានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរួមមាន ៖

- នាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- នាយកដ្ឋានស្តង់ដាជាតិសមត្ថភាព
- នាយកដ្ឋានព័ត៌មានទីផ្សារការងារ ។

អគ្គាធិការដ្ឋាន

នាយកដ្ឋានសវនកម្មផ្ទៃក្នុង

ខុទ្ទកាល័យរដ្ឋមន្ត្រី

២- អង្គភាពមូលដ្ឋាន

- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ក្រុង
- ការិយាល័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈស្រុក ខ័ណ្ឌ ។

៣- គ្រឹះស្ថានសាធារណៈក្រោមអាណាព្យាបាល

អង្គការលេខរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

## ជំពូកទី ៣
p
## អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

**មាត្រា ៥.-**

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុទទួលបន្ទុកការងារទំនាក់ទំនង សម្របសម្រួល គ្រប់គ្រងកិច្ចការរដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋ ផែនការ ស្ថិតិ នីតិកម្ម និងសហប្រតិបត្តិការអន្តរជាតិ ។

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុដឹកនាំដោយអគ្គនាយកមួយរូប និងអគ្គនាយករងជាជំនួយការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុមាននាយកដ្ឋានចំនួន ០៤ ដូចមានចែងក្នុងមាត្រាខាងក្រោម ៖

មាត្រា ៦.-

**នាយកដ្ឋានរដ្ឋបាល និងបុគ្គលិកទទួលបន្ទុក ៖**

- សម្របសម្រួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋានដោយសហការជាមួយអគ្គនាយកដ្ឋានដទៃទៀត ក្រោមឱវាទក្រសួង
- គ្រប់គ្រង និងចរាចរណ៍ឯកសាររបស់ក្រសួង
- ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងគ្រប់គ្រងការងារសង្គមរបស់ក្រសួង
- ណែនាំរបៀបរបបធ្វើការងាររដ្ឋបាលដល់អង្គភាពក្រោមឱវាទក្រសួង
- ធ្វើរបាយការណ៍ការងារ និងកំណត់ហេតុផ្សេងៗ របស់ថ្នាក់ដឹកនាំក្រសួង
- គ្រប់គ្រងផ្នែករដ្ឋបាលចំពោះមន្ត្រីរាជការរបស់ក្រសួង ដោយទំនាក់ទំនងជាមួយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- រៀបចំរាល់លិខិតរដ្ឋបាលពាក់ព័ន្ធបុគ្គលិករបស់ក្រសួង សម្រាប់ការគ្រប់គ្រងអាជីព
- ធ្វើកម្មវិធីតំណែងឯកទេស និងធនធានមនុស្សរបស់ក្រសួង
- វាយតម្លៃតម្រូវការ រៀបចំគោលនយោបាយ និងកម្មវិធីបណ្តុះបណ្តាលវិក្រឹត្យការមន្ត្រីរាជការក្នុងក្រសួង
- រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងព័ត៌មានប្រតិបត្តិ
- វាយតម្លៃ តម្លើងឋានៈ ឬលើកទឹកចិត្តដល់អង្គភាព ឬបុគ្គលដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួង ដោយសហការជាមួយអង្គភាពពាក់ព័ន្ធ
- រៀបចំការងារបៀវត្សរ៍ពលកម្ម ប្រាក់កំរៃ និងរបបឧបត្ថម្ភគោលនយោបាយសង្គម
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានរដ្ឋបាល និងបុគ្គលិកដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់ ។

មាត្រា ៧.-

**នាយកដ្ឋានផែនការ ស្ថិតិ និងទីតិកម្មទទួលបន្ទុក ៖**

- កសាងផែនការគោល និងសហការជាមួយផ្នែកជំនាញដែលពាក់ព័ន្ធរបស់ក្រសួង កសាងផែនការសកម្មភាពតាមបណ្តាផ្នែក
- សម្របសម្រួល រៀបចំកម្មវិធីសហប្រតិបត្តិការក្នុង និងក្រៅប្រទេស ដោយសហការជាមួយផ្នែកជំនាញ សហការជាមួយផ្នែកជំនាញនានា រៀបចំលិខិតស្នាម និងផែនការអភិវឌ្ឍន៍របស់ក្រសួង
- ប្រមូល និងរៀបចំស្ថិតិរបស់មុខសញ្ញាដែលក្រសួងទទួលបន្ទុក ។ រៀបចំ គ្រប់គ្រងទិន្នន័យ និងសិក្សាចំណោលស្ថិតិទាំងនោះ ក្នុងគោលដៅរៀបចំយុទ្ធសាស្ត្រ កំណត់កម្មវិធីសកម្មភាព និងធ្វើគម្រោងផែនការសកម្មភាព និងទិសដៅអនាគតរបស់វិស័យការងារ និងវិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ
- គ្រប់គ្រងព័ត៌មានវិទ្យា និងបណ្ណាល័យរបស់ក្រសួង
- ណែនាំរបៀបរបប និងធ្វើរបាយការណ៍សរុបអំពីសកម្មភាព និងលទ្ធផលការងាររបស់ក្រសួងប្រចាំខែត្រីមាស ឆមាស និងប្រចាំឆ្នាំ

- ក្តាប់ និងប្រមូលសភាពការណ៍ជាក់ស្តែងពាក់ព័ន្ធវិស័យការងារ និងវិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ
- ពិនិត្យវាយតម្លៃបរិមាណ គុណភាពរបស់រដ្ឋបាល និងសមិទ្ធផលវិស័យការងារ និងវិស័យបណ្តុះបណ្តាលវិជ្ជាជីវៈ
- សម្របសម្រួល និងពិនិត្យសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋាននានារបស់ក្រសួង
- តាមដានការងារអនុវត្ត អនុសញ្ញា ច្បាប់ លិខិតបទដ្ឋាននានាទាក់ទងទៅនឹងការងាររបស់ក្រសួង
- ស្រាវជ្រាវ ដកស្រង់ ចងក្រងអត្ថបទច្បាប់ បទប្បញ្ញត្តិ សន្ធិសញ្ញានានាទាក់ទងទៅនឹងការងាររបស់ក្រសួង និងគ្រប់គ្រងឯកសារទាំងអស់នោះ
- ជាអ្នកជំនួយការច្បាប់ទាក់ទងទៅនឹងរាល់ការងារនីតិកម្មរបស់ក្រសួង
- អនុវត្តការកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់ ។

មាត្រា ៨.-

**នាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋទទួលបន្ទុក ៖**

- រៀបចំគម្រោងថវិកាក្រសួង និងតាមដានរំលឹកពីការប្រតិបត្តិ
- គ្រប់គ្រងចំណូលឱ្យបានសមស្របតាមច្បាប់ហិរញ្ញវត្ថុ បង់ចូលថវិការដ្ឋ
- គ្រប់គ្រង និងសម្របសម្រួលជំពូកថវិកា
- គ្រប់គ្រង និងពិនិត្យគណនីពិសេស
- គ្រប់គ្រង និងសម្របសម្រួលរាល់ចំណូល ចំណាយរបស់ក្រសួង
- គ្រប់គ្រងបន្ទុកគណនីនៃការអនុវត្តលទ្ធកម្មសាធារណៈ
- សហការជាមួយអង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ក្នុងការងារត្រួតពិនិត្យចំណូល ចំណាយរបស់ក្រសួង
- ប្រមូលផ្តុំតម្រូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំផ្គត់ផ្គង់សម្ភារៈ និងបរិក្ខាររបស់ក្រសួង
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិ សម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- គ្រប់គ្រងយានយន្តរបស់រដ្ឋ ដែលប្រគល់ឱ្យក្រសួង ព្រមទាំងធ្វើកម្មវិធីចំណាយ និងបែងចែក ប្រេងឥន្ធនៈ គ្រឿងបន្លាស់ និងជួសជុល ដាក់ជូនប្រធានស្ថាប័នពិនិត្យ និងសំរេច
- ទទួល និងបែងចែកបរិក្ខារជូនដល់បណ្តាអង្គភាពក្រោមឱវាទក្រសួង
- គ្រប់គ្រងការប្រើប្រាស់ឧបករណ៍ព័ត៌មានវិទ្យានៃសកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី
- ត្រួតពិនិត្យបច្ចេកទេសនៃការប្រតិបត្តិលទ្ធកម្មសាធារណៈ
- អនុវត្តការកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់ ។

មាត្រា ៩.-

**នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ទទួលបន្ទុក ៖**

- ធ្វើការសម្របសម្រួលរាល់ទំនាក់ទំនងការងារជាមួយផ្នែកជំនាញរបស់ក្រសួង ស្ថាប័ន អង្គការនានា និងបណ្តាប្រទេសក្នុងតំបន់ និងលើសកលលោក ដើម្បីអភិវឌ្ឍការងារគ្រប់វិស័យរបស់ក្រសួង ដោយសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- រៀបចំពិធីការ និងឯកសារនានាសម្រាប់ថ្នាក់ដឹកនាំក្រសួង ក្នុងការទទួលភ្ញៀវអន្តរជាតិ សម្រាប់កិច្ចប្រជុំ និងពិធីនានារបស់ក្រសួង
- រៀបចំអនុស្សរណៈ ឬកិច្ចព្រមព្រៀងរវាងក្រសួងជាមួយក្រសួង ស្ថាប័ន អង្គការនានា និងបណ្តាប្រទេសក្នុងតំបន់ និងលើសកលលោក និងតាមដានរាល់លទ្ធផលការងារអនុវត្ត ហើយរាយការណ៍ជូនថ្នាក់ដឹកនាំ
- តាមដាន និងបូកសរុបរាល់សកម្មភាពសហប្រតិបត្តិការអន្តរជាតិ និងអាស៊ានដែលក្រសួងបានចុះអនុស្សរណៈ ឬកិច្ចព្រមព្រៀង
- សម្រួលលិខិតស្នាម ដូចជា លិខិតឆ្លងដែន ទិដ្ឋាការរបស់មន្ត្រីរាជការក្រោមឱវាទក្រសួងដែលត្រូវបំពេញបេសកកម្មនៅក្រៅប្រទេស តាមការចាត់តាំងរបស់ក្រសួង និងបណ្តាជនបរទេសដែលមកបំពេញការងារជាមួយក្រសួង
- សរុបសភាពការណ៍អន្តរជាតិ បទពិសោធន៍របស់បណ្តាប្រទេសក្នុងតំបន់ និងសកលលោក ហើយធ្វើការផ្សព្វផ្សាយព័ត៌មានដល់ផ្នែកជំនាញដែលពាក់ព័ន្ធ
- រៀបចំគម្រោងសហប្រតិបត្តិការទ្វេភាគី និងពហុភាគីជាមួយអង្គការ ស្ថាប័នជាតិ អន្តរជាតិ និងអាស៊ាន
- អនុវត្តការកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី ៤

## អគ្គនាយកដ្ឋានការងារ

មាត្រា ១០.-

អគ្គនាយកដ្ឋានការងារទទួលបន្ទុកការងារទំនាក់ទំនង សម្របសម្រួល គ្រប់គ្រងកិច្ចការអធិការកិច្ចការងារ វិវាទការងារ មុខរបរ និងពលកម្ម សន្តិសុខសង្គម ការងារកុមារ និងពេទ្យការងារ ។

អគ្គនាយកដ្ឋានការងារដឹកនាំដោយអគ្គនាយកមួយរូប និងអគ្គនាយករងជាជំនួយការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានការងារមាននាយកដ្ឋានចំនួន ០៦ ដូចបានចែងក្នុងមាត្រាខាងក្រោម ។

មាត្រា ១១.-

**នាយកដ្ឋានអធិការកិច្ចការងារទទួលបន្ទុក ៖**

- ពាក់ព្រៀងបទប្បញ្ញត្តិ និងបទបញ្ជាដែលទាក់ទងនឹងល័ក្ខខ័ណ្ឌការងារ
- ត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិច្បាប់ និងបទបញ្ជាដែលទាក់ទងនឹងល័ក្ខខ័ណ្ឌទូទៅនៃការងារ អនាម័យ

និងសន្តិសុខការងារ

- ពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ និងអនុសញ្ញាអន្តរជាតិនានាស្តីពីការងារ ដែលទាក់ទងនឹងល័ក្ខខ័ណ្ឌទូទៅនៃការងារ អនាម័យ និងសន្តិសុខការងារ សិទ្ធិការងារ
- ធ្វើការអប់រំ ផ្សព្វផ្សាយចំពោះនិយោជក និងកម្មករនិយោជិត ដើម្បីគោរពបទប្បញ្ញត្តិច្បាប់ស្តីពីការងារ
- ផ្តល់ព័ត៌មានទៅអាជ្ញាធរមានសមត្ថកិច្ចនូវករណីមិនប្រក្រតី និងការរំលោភផ្សេងៗ ដែលពាក់ព័ន្ធនឹងវិស័យការងារ
- ផ្តល់យោបល់អំពីបញ្ហាទាក់ទងនឹងការរៀបចំ ឬកែប្រែសហគ្រាស គ្រឹះស្ថាន និងអង្គការចាត់តាំងដែលបានអនុញ្ញាតអំពីអាជ្ញាធររដ្ឋបាល ហើយដែលមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារ
- ត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិ និងបទបញ្ជាដែលទាក់ទងនឹងល័ក្ខខ័ណ្ឌជីវភាពនៃកម្មករនិយោជិត និងគ្រួសារនៃជនទាំងនោះ
- ចាត់តាំង និងគ្រប់គ្រងភ្នាក់ងារចុះធ្វើអធិការកិច្ចការងារតាមសហគ្រាស គ្រឹះស្ថាន និងត្រួតពិនិត្យសកម្មភាពអធិការកិច្ចការងារ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានអធិការកិច្ចការងារដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់ ។

## មាត្រា ១២.-

**នាយកដ្ឋានវិវាទការងារទទួលបន្ទុក ៖**

- តាក់តែងបទប្បញ្ញត្តិ និងបទបញ្ជាដែលទាក់ទងនឹងការការពារសិទ្ធិ និងផលប្រយោជន៍របស់កម្មករនិយោជិត ក្នុងពេលប្រកបវិជ្ជាជីវៈរបស់ខ្លួន ,
- ពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ អនុសញ្ញាអន្តរជាតិនានាស្តីពីការងារ អំពីសិទ្ធិនៃការបង្កើតអង្គការវិជ្ជាជីវៈ
- ជួយការពារដល់បណ្តាអង្គការតំណាងរបស់កម្មករនិយោជិត និងនិយោជក នៅក្នុងសហគ្រាស គ្រឹះស្ថាន
- ដាក់ឱ្យដំណើរការនូវនីតិវិធីសម្រាប់ដោះស្រាយវិវាទការងារ
- ដោះស្រាយរាល់វិវាទការងារ
- តាមដាន និងជំរុញការចរចាជាសមូហភាព និងសំវាទសង្គម ព្រមទាំងពិនិត្យ និងចុះបញ្ជិកាអង្គការវិជ្ជាជីវៈ និងអនុសញ្ញារួម ព្រមទាំងផ្តល់វិញ្ញាប័នប័ត្របញ្ជាក់ភាពជាតំណាងនៃអង្គការសហជីពកម្មករ
- ទទួលបន្ទុកកិច្ចការលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល
- ទទួលបន្ទុកកិច្ចការលេខាធិការដ្ឋានគណៈកម្មការប្រឹក្សាការងារ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានវិវាទការងារដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់ ។

មាត្រា ១៣.-

**នាយកដ្ឋានមុខរបរ និងហត្ថពលកម្មទទួលបន្ទុក ៖**

- សិក្សា និងលើកវិធានការសម្រាប់អភិវឌ្ឍន៍ និងការការពារមុខរបរ
- គ្រប់គ្រង ចេញប័ណ្ណការងារ សៀវភៅការងារ និងផ្តល់ទិដ្ឋាការការងារ ដល់កម្មករនិយោជិតខ្មែរដែលធ្វើការនៅក្នុង និងក្រៅប្រទេស
- ត្រួតពិនិត្យ និងផ្តល់ប័ណ្ណការងារ សៀវភៅការងារដល់ជនបរទេសដែលមកប្រកបមុខរបរ នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- រៀបចំក្របខ័ណ្ឌគតិយុត្តិពីវិធានការទាំងអស់ ដាក់ឱ្យអនុវត្តវិធានការ និងតាមដានការអនុវត្ត
- រៀបចំឱ្យមានការិយាល័យរកការងារធ្វើ នៅតាមមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ក្រុង
- កសាងស្ថិតិមុខរបរ និងហត្ថពលកម្មក្នុង និងក្រៅប្រទេស ទៅតាមលំដាប់ថ្នាក់សកម្មភាពសេដ្ឋកិច្ច
- តាក់តែងបទប្បញ្ញត្តិ និងបទបញ្ជាស្តីពីការគ្រប់គ្រងជនបរទេស ដែលមកប្រកបមុខរបរនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងស្តីពីការគ្រប់គ្រងកម្លាំងពលកម្ម និងពលករខ្មែរទៅធ្វើការនៅក្រៅប្រទេស
- គ្រប់គ្រងជនបរទេសដែលមកប្រកបរបរក្នុងព្រះរាជាណាចក្រកម្ពុជា និងពលករខ្មែរទៅធ្វើការនៅក្រៅប្រទេស ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងករណីដែលមានពលករខ្មែរច្រើន អាចស្នើសុំបង្កើតអនុពន្ធការងារ
- ស្វែងរកទីផ្សារការងារជូនពលករខ្មែរទៅធ្វើការនៅក្រៅប្រទេស
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានមុខរបរ និងហត្ថពលកម្មដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់ ។

មាត្រា ១៤.-

**នាយកដ្ឋានសន្តិសុខសង្គមទទួលបន្ទុក ៖**

- រៀបចំបទប្បញ្ញត្តិ ដើម្បីអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- រៀបចំដំណើរការសេវាកម្មផ្តល់តាវកាលិកហានិភ័យការងារដល់កម្មករនិយោជិតផ្នែកឯកជន
- រៀបចំដំណើរការសេវាកម្មផ្តល់តាវកាលិកជរាភាព ទុព្វលភាព និងមរណភាពដល់កម្មករនិយោជិតផ្នែកឯកជន
- រៀបចំដំណើរការសេវាកម្មធានារ៉ាប់រងសុខភាពសម្រាប់កម្មករនិយោជិតផ្នែកឯកជន
- ត្រួតពិនិត្យ និងតាមដានការអនុវត្តរបបសន្តិសុខសង្គម
- រៀបចំគោលនយោបាយជាតិស្តីពីរបបសន្តិសុខសង្គម
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានសន្តិសុខសង្គម ដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់ ។

**មាត្រា ១៥.-**

**នាយកដ្ឋានការងារកុមារទទួលបន្ទុក ៖**

- តាក់តែង និងអភិវឌ្ឍគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងពលកម្មកុមារ
- អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល អនុសញ្ញា និងសន្ធិសញ្ញាអន្តរជាតិដែលពាក់ព័ន្ធនឹងពលកម្មកុមារ ជាពិសេសទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- តាមដាន ត្រួតពិនិត្យការអនុវត្តផែនការសកម្មភាពជាតិ អនុសញ្ញាដែលពាក់ព័ន្ធទៅនឹងពលកម្មកុមារ
- បង្កើនកិច្ចសហប្រតិបត្តិការ សម្របសម្រួលជាមួយក្រសួង ស្ថាប័ន អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ ដើម្បីដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹងពលកម្មកុមារ
- សហការ អនុវត្ត និងវាយតម្លៃការអនុវត្តគោលការណ៍ គម្រោង កម្មវិធីនានា ដែលពាក់ព័ន្ធនឹងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារជាមួយដៃគូ ក្រសួង ស្ថាប័ន អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិនានា
- ធ្វើអន្តរាគមន៍ ដើម្បីដោះស្រាយរាល់បញ្ហាពាក់ព័ន្ធនឹងការទប់ស្កាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ
- រៀបចំទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ ខែមិថុនា ជារៀងរាល់ឆ្នាំ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានការងារកុមារដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់ ។

**មាត្រា ១៦.-**

**នាយកដ្ឋានពេទ្យការងារទទួលបន្ទុក ៖**

- តាក់តែងអត្ថបទច្បាប់ និងបទបញ្ជាការងារពាក់ព័ន្ធដល់អនាម័យការងារ និងបច្ចេកទេសសន្តិសុខការងារក្នុងការការពារទប់ស្កាត់រាល់ហានិភ័យវិជ្ជាជីវៈរបស់កម្មករនិយោជិត
- ចងក្រងឯកសារបច្ចេកទេសក្នុងវិស័យអនាម័យនិងសន្តិសុខការងារ ធ្វើការផ្សព្វផ្សាយ អប់រំជាប្រចាំដល់កម្មករនិយោជិតដែលកំពុងធ្វើការនៅតាមសហគ្រាស គ្រឹះស្ថាន
- ឃ្លាំមើលជាប្រចាំអំពីសុខភាពកម្មករនិយោជិត ដែលប៉ះពាល់ ឬខូចខាតដោយសារប្រកបការងារ
- រៀបចំ ត្រួតពិនិត្យ វាយតម្លៃ និងទាក់ទងជាប្រចាំនូវរាល់សកម្មភាពរបស់អង្គភាពពេទ្យការងារ និងគ្រូពេទ្យ នៅតាមសហគ្រាស គ្រឹះស្ថាន ពិសេសគ្រប់គ្រងលើការងារសីលធម៌វិជ្ជាជីវៈពេទ្យ
- ទាក់ទងជាមួយបណ្តាប្រទេសក្នុងតំបន់ និងប្រទេសជឿនលឿនក្នុងការស្រាវជ្រាវអំពីនយោបាយ និងបច្ចេកទេសខាងអនាម័យនិងសន្តិសុខការងារ
- ពិនិត្យសុខភាពកម្មករនិយោជិតមុនចូលធ្វើការ ជាកាលិក ឬសារជាថ្មី ទៅតាមសំណូមពរចាំបាច់ និងរៀបចំទុកដាក់ឯកសារសុខភាព ឱ្យបានត្រឹមត្រូវ
- ជំរុញ លើកទឹកចិត្ត និងគាំទ្រខាងហិរញ្ញវត្ថុ ចំពោះការសិក្សាវិស័យសុខាភិបាលពាក់ព័ន្ធដល់សុខភាព សុវត្ថិភាពក្នុងការងាររបស់កម្មករនិយោជិត
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានពេទ្យការងារដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី ៥
## អគ្គនាយកដ្ឋានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ

**មាត្រា ១៧.-**

អគ្គនាយកដ្ឋានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ទទួលបន្ទុកការងារ តាក់តែង និងរៀបចំគោលនយោបាយសម្រាប់អភិវឌ្ឍប្រព័ន្ធអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងគ្រប់គ្រងលើការងារអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ការអនុវត្តកាតព្វកិច្ចហិរញ្ញប្បទានកូនជាងតាមច្បាប់ស្តីពីការងារ និងព័ត៌មានទីផ្សារការងារក្នុង និងក្រៅប្រទេស ។

អគ្គនាយកដ្ឋានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដឹកនាំដោយអគ្គនាយកមួយរូប និងអគ្គនាយករង ជាជំនួយការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មាននាយកដ្ឋានចំនួន ០៣ ដូចបានចែងក្នុងមាត្រាខាងក្រោម ។

**មាត្រា ១៨.-**

**នាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ** ទទួលបន្ទុក ៖

- រៀបចំ តាក់តែងអត្ថបទច្បាប់ និងលិខិតបទដ្ឋាននានាសម្រាប់ការគ្រប់គ្រង គ្រឹះស្ថានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈ ឯកជន អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ
- គ្រប់គ្រងគ្រឹះស្ថានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឬថ្នាក់បណ្តុះបណ្តាលវិជ្ជាជីវៈ សាធារណៈ ឯកជន អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ
- សម្របសម្រួល គ្រប់គ្រងសកម្មភាពការងារអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៃគ្រឹះស្ថានសិក្សាសាធារណៈ ឬថ្នាក់បណ្តុះបណ្តាលវិជ្ជាជីវៈ ដែលស្ថិតក្រោមឱវាទក្រសួងនានា
- ប្រមូលទិន្នន័យ រៀបចំស្ថិតិ សម្រាប់ការងារអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- កសាងផែនការសម្រាប់អភិវឌ្ឍប្រព័ន្ធអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- ត្រួតពិនិត្យ និងវាយតម្លៃគុណភាពការងារអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៃគ្រឹះស្ថានសិក្សាសាធារណៈ ឯកជន អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ
- ពិនិត្យ និងសំរេចលើសំណើសុំបង្កើតគ្រឹះស្ថានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឬថ្នាក់បណ្តុះបណ្តាលវិជ្ជាជីវៈសាធារណៈ ឯកជន អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ
- អភិវឌ្ឍគោលនយោបាយសម្រាប់មូលនិធិជាតិបណ្តុះបណ្តាល
- សិក្សា ស្រាវជ្រាវលើមុខរបរដែលត្រូវធ្វើការបណ្តុះបណ្តាល ឱ្យសមស្របតាមតម្រូវការជាក់ស្តែង ក្នុងតំបន់នីមួយៗ ពិសេសតម្រូវការទីផ្សារការងារក្នុង និងក្រៅប្រទេស
- រៀបចំផែនការផ្តល់មូលនិធិជាតិបណ្តុះបណ្តាលដល់ស្ថាប័នសាធារណៈ ឯកជន អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ ដែលធ្វើការបណ្តុះបណ្តាល
- ត្រួតពិនិត្យ និងវាយតម្លៃលើគម្រោងស្នើសុំរបស់ស្ថាប័នសាធារណៈ ឯកជន អង្គការក្រៅរដ្ឋាភិបាល និង

អង្គការអន្តរជាតិ ដែលធ្វើការបណ្តុះបណ្តាល

- ផ្តល់ឥណទានដល់សហគមន៍ជនក្រីក្រ ដែលបានទទួលការបណ្តុះបណ្តាលរួច ដើម្បីប្រកបមុខរបរដោយខ្លួនឯង
- តាមដាន និងវាយតម្លៃលើសកម្មភាពបណ្តុះបណ្តាល និងឥណទានដែលបានផ្តល់ជូន
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់ ។

**មាត្រា ១៩.-**

**នាយកដ្ឋានស្តង់ដាជាតិសមត្ថភាព** ទទួលបន្ទុក ៖

- រៀបចំគោលនយោបាយសម្រាប់អភិវឌ្ឍន៍ប្រព័ន្ធស្តង់ដាជាតិសមត្ថភាព
- រៀបចំបញ្ជីអាទិភាពនៃតម្រូវការមុខរបរ និងវិភាគមុខរបរ
- រៀបចំ និងអភិវឌ្ឍក្របខ័ណ្ឌគុណវុឌ្ឍិជាតិ និងក្របខ័ណ្ឌស្តង់ដាជាតិសមត្ថភាព
- អភិវឌ្ឍស្តង់ដាជាតិសមត្ថភាព
- អភិវឌ្ឍកម្មវិធីសិក្សាផ្អែកលើសមត្ថភាព
- ពង្រឹង និងពង្រីកសហប្រតិបត្តិការរវាងរោងចក្រ សហគ្រាស ឧស្សាហកម្ម ស្ថាប័នសាធារណៈ ស្ថាប័នបណ្តុះបណ្តាលសាធារណៈ ឯកជន អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ
- អភិវឌ្ឍគោលនយោបាយជាតិ និងផែនការយុទ្ធសាស្ត្រស្តីពី ការធ្វើតេស្តបញ្ជាក់សមត្ថភាពជំនាញរបស់ពលករ និងទទួលស្គាល់កម្មវិធីបណ្តុះបណ្តាល ឬគ្រឹះស្ថានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- អភិវឌ្ឍវិញ្ញាសារសម្រាប់ការអនុវត្ត ក្នុងការធ្វើតេស្តបញ្ជាក់សមត្ថភាពជំនាញ ក្នុងប្រព័ន្ធអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- អភិវឌ្ឍលក្ខណៈវិនិច្ឆ័យ សម្រាប់ការទទួលស្គាល់កម្មវិធីបណ្តុះបណ្តាល គ្រឹះស្ថានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- បង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់ទទួលស្គាល់មជ្ឈមណ្ឌលធ្វើតេស្ត និងសមត្ថភាពមេប្រយោគធ្វើតេស្ត
- វាយតម្លៃសញ្ញាប័ត្រ ឬវិញ្ញាបនប័ត្រទៅតាមគ្រឹះស្ថានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈ ឯកជន អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ
- ធ្វើតេស្តបញ្ជាក់សមត្ថភាពជំនាញ និងផ្តល់សញ្ញាប័ត្រ ឬវិញ្ញាបនប័ត្រជាតិបញ្ជាក់សមត្ថភាព
- វាយតម្លៃទទួលស្គាល់គុណភាពកម្មវិធីបណ្តុះបណ្តាល ឬគ្រឹះស្ថានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
- រៀបចំ ចាត់ចែងការចូលរួមប្រឡងមុខជំនាញអាស៊ាន និងអូឡាំពិក ដើម្បីវាស់វែងសមត្ថភាពជំនាញរបស់ពលករបច្ចេកទេស
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានស្តង់ដាជាតិសមត្ថភាពដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់ ។

មាត្រា ២០.-

**នាយកដ្ឋានព័ត៌មានទីផ្សារការងារទទួលបន្ទុក ៖**

- រៀបចំគោលនយោបាយ កម្មវិធី និងគ្រប់គ្រងការងារអប់រំបណ្តុះបណ្តាលពិសេស ដូចជា ការហ្វឹកហ្វឺនកូនជាង ការបណ្តុះបណ្តាលតាមប្រពៃណីក្នុងគ្រួសារ ការសិក្សាពីចម្ងាយ ការសិក្សាបន្ត ការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក និងការសិក្សាបច្ចេកវិទ្យាដែលទើបចេញថ្មី
- រៀបចំបទប្បញ្ញត្តិគតិយុត្តិស្តីពីការហ្វឹកហ្វឺនកូនជាង ការធ្វើតេស្តិ៍កម្មករនិយោជិត ការត្រួតពិនិត្យការហ្វឹកហ្វឺនកូនជាង កំណត់កម្មវិធីតាមមុខរបរនីមួយៗ ការប្រឡងបញ្ចប់វគ្គ និងវិធីជ្រើសតាំងគណៈមេប្រយោគនៅតាមសហគ្រាស គ្រឹះស្ថាននានា
- រៀបចំ សម្របសម្រួលសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីអនុវត្តការអប់រំបណ្តុះបណ្តាលពិសេស
- រៀបចំកម្មវិធី និងគ្រប់គ្រងការអប់រំ បណ្តុះបណ្តាលពិសេស សម្រាប់ធានាសមធម៌ ក្នុងការទទួលអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដល់ក្រុមមុខសញ្ញាពិសេស ដូចជា ជនពិការ ជនជួបការលំបាកជាងគេ នារីភេទ និងជនជាតិភាគតិច
- អប់រំសុខភាព និងអនាម័យដល់សហគមន៍
- សិក្សាស្រាវជ្រាវ អង្កេតមុខរបរជាអាទិភាព តាមសហគ្រាស គ្រឹះស្ថាន តាមតំបន់នីមួយៗ ដើម្បីរៀបចំចងក្រងជាប្រព័ន្ធព័ត៌មានទីផ្សារការងារ
- ប្រមូលទិន្នន័យអំពីតម្រូវការនៃទីផ្សារការងារ ដើម្បីរៀបចំឱ្យមានតុល្យភាពរវាងការបណ្តុះបណ្តាល ផ្គត់ផ្គង់ និងតម្រូវការកម្លាំងពលកម្មឱ្យបានសមស្របតាមទីផ្សារការងារទាំងក្នុង និងក្រៅប្រទេស
- កសាងស្ថិតិការងារដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គភាពក្រោមឱវាទក្រសួង
- រៀបចំសេវាផ្តល់ព័ត៌មានអំពីទីផ្សារការងារដល់សហគ្រាស គ្រឹះស្ថាន អ្នកវិនិយោគទុនជាតិ អន្តរជាតិ គ្រឹះស្ថានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ កម្មករនិយោជិត ពលរដ្ឋទាំងពីរភេទ ដែលមានបំណងសិក្សា មុខជំនាញវិជ្ជាជីវៈ និងរកការងារធ្វើ តាមតម្រូវការទីផ្សារការងារទាំងក្នុង និងក្រៅប្រទេស
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

នាយកដ្ឋានព័ត៌មានទីផ្សារការងារដឹកនាំដោយប្រធានមួយរូប និងអនុប្រធានជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី ៦
## អធិការដ្ឋាន

មាត្រា ២១.-

អធិការដ្ឋានទទួលបន្ទុក ៖

- ធ្វើអធិការកិច្ចជាប្រចាំ លើគ្រប់អង្គភាពក្រោមឱវាទរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ពិនិត្យ សម្រុះសម្រួល និងដោះស្រាយវិវាទរដ្ឋបាល ដែលពាក់ព័ន្ធដល់សមត្ថកិច្ច និងសកម្មភាពរបស់មន្ត្រី និងភ្នាក់ងាររបស់ក្រសួង
- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី អំពីការប្រព្រឹត្តទៅរបស់អង្គភាព ដែលបានធ្វើអធិការកិច្ចហើយនោះ និងពីវិធានការកែលំអការប្រព្រឹត្តទៅរបស់អង្គភាពទាំងនោះ

- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលក្រសួងប្រគល់ជូន ។

អគ្គាធិការដ្ឋានដឹកនាំដោយអគ្គាធិការមួយរូប និងមានអគ្គាធិការរងជាជំនួយការតាមការចាំបាច់ ។

## ជំពូកទី ៧

## នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**មាត្រា ២២.-**

**នាយកដ្ឋានសវនកម្មផ្ទៃក្នុង** ទទួលបន្ទុកអនុវត្តភារកិច្ចតាមអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ ។

## ជំពូកទី ៨

## ខុទ្ទកាល័យរដ្ឋមន្ត្រី

**មាត្រា ២៣.-**

ខុទ្ទកាល័យរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មទាំងឡាយ ដែលកំណត់តាមបទប្បញ្ញត្តិនៃអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ដូចមានយោងក្នុងមូលបទខាងលើស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

## ជំពូកទី ៩

## អង្គភាពមូលដ្ឋាន

**មាត្រា ២៤.-**

នៅតាមខេត្ត ក្រុងនីមួយៗ មានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ក្រុងមួយ ដែលទទួលបន្ទុកអនុវត្ត និងសម្របសម្រួលសកម្មភាពនានារបស់ក្រសួង ។

នៅតាមស្រុក ខណ្ឌ មានការិយាល័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលទទួលបន្ទុកអនុវត្ត និងសម្របសម្រួលសកម្មភាពនានារបស់ក្រសួង និងតាមបទបញ្ជារបស់មន្ទីរ ។

## ជំពូកទី ១០

## គ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមអាណាព្យាបាល

**មាត្រា ២៥.-**

គ្រឹះស្ថានសាធារណៈរដ្ឋបាលនានា ដែលស្ថិតក្រោមអាណាព្យាបាលរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវកំណត់ដោយអនុក្រឹត្យមួយដោយឡែក ។

## ជំពូកទី ១១

## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា ២៦.-**

អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុត្រូវបានបង្កើតឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌនៃបទបញ្ជាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកា ក្នុងបណ្តាក្រសួង ។

## ជំពូកទី ១២

## អវសានបញ្ញត្តិ

**មាត្រា ២៧.-**

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ និងថ្នាក់ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**មាត្រា ២៨.-**

ភារកិច្ចទាំងឡាយណា ដែលពាក់ព័ន្ធនិងសមត្ថកិច្ចរបស់ស្ថាប័នដទៃ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងប្រធានស្ថាប័ននៃស្ថាប័នដទៃទាំងនោះត្រូវសហការគ្នា ដើម្បីបែងចែកការទទួលខុសត្រូវ និងអនុវត្តការងារទាំងនោះ តាមរយៈប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងប្រធានស្ថាប័នទាំងនោះ ។

**មាត្រា ២៩.-**

អនុក្រឹត្យ និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៣០
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ០៣ ២០០៥

## អង្គការលេខរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:....៤៧....អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## សមាសភាព និងការប្រព្រឹត្តទៅនៃគណៈកម្មការប្រឹក្សាការងារ

****

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១០ ខែមិនា ឆ្នាំ២០០៦ ស.ក.

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះកំណត់សមាសភាព និងការប្រព្រឹត្តទៅនៃគណៈកម្មការប្រឹក្សាការងារ ដែលត្រូវបាន បង្កើតឡើងដោយមាត្រា៣៩២ នៃច្បាប់ស្តីពីការងារ និងដែលមានបេសកកម្មជាអាទិ៍ សិក្សាស្រាវជ្រាវរាល់បញ្ហាដែលទាក់ទងនឹងការងារមុខរបរនៃកម្មករនិយោជិត ប្រាក់ឈ្នួល ការអប់រំវិជ្ជាជីវៈ ចលនាកម្លាំងពលកម្មក្នុងប្រទេស ទេសន្តរប្រវេសន៍ ការរៀបចំអោយរឹតតែប្រសើរឡើងនូវល័ក្ខខ័ណ្ឌខាងសម្ភារៈ និងខាងស្មារតី នៃកម្មករនិយោជិត ហើយនិងបញ្ហាអនាម័យ និងសន្តិសុខការងារ ។

គណៈកម្មការប្រឹក្សាការងារមានភារកិច្ចជាអាទិ៍ដូចតទៅ ÷

- លើកយោបល់ណែនាំអំពីអត្រាប្រៀវត្សអប្បបរមា ដែលត្រូវធានា
- ផ្តល់យោបល់ជាមុន ដើម្បីពង្រីកដែនអនុវត្តអនុសញ្ញារួម ឬក្នុងករណីដែលគ្មានអនុសញ្ញារួមទេ ផ្តល់យោបល់ជាយថាហេតុជាមុន ចំពោះបទបញ្ជានៃល័ក្ខខ័ណ្ឌមុខរបរនៅក្នុងវិជ្ជាជីវៈមួយ ឬក្នុងវិស័យសកម្មភាពណាមួយជាក់លាក់ ។

## ជំពូកទី ២

## សមាសភាពនៃគណៈកម្មការប្រឹក្សាការងារ

p

**មាត្រា ២.-**

គណៈកម្មការប្រឹក្សាការងារមានសមាសភាពដូចតទៅ ÷

- រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬតំណាង មួយ(០១) រូប ជាប្រធាន
- តំណាងអង្គការសហជីពកម្មករនិយោជិតដែលមានភាពជាតំណាងជាងគេបំផុតក្នុងថ្នាក់ជាតិ មួយ(០១) រូប ជាអនុប្រធាន
- តំណាងអង្គការនិយោជកដែលមានភាពជាតំណាងជាងគេបំផុតក្នុងថ្នាក់ជាតិ មួយ(០១) រូប ជាអនុប្រធាន
- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មួយ(០១) រូប ជាសមាជិក
- តំណាងក្រសួងពាណិជ្ជកម្ម មួយ(០១) រូប ជាសមាជិក ៕.

- តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មួយ(០១) រូប ជាសមាជិក
- តំណាងក្រសួងសុខាភិបាល មួយ(០១) រូប ជាសមាជិក
- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មួយ(០១) រូប ជាសមាជិក
- តំណាងក្រសួងកិច្ចការនារី មួយ(០១) រូប ជាសមាជិក
- តំណាងក្រសួងបរិស្ថាន មួយ(០១) រូប ជាសមាជិក
- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន មួយ(០១) រូប ជាសមាជិក
- តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មួយ(០១) រូប ជាសមាជិក
- តំណាងក្រសួងមហាផ្ទៃ មួយ(០១) រូប ជាសមាជិក
- តំណាងក្រសួងទេសចរណ៍ មួយ(០១) រូប ជាសមាជិក
- តំណាងក្រសួងយុត្តិធម៌ មួយ(០១) រូប ជាសមាជិក
- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មួយ(០១) រូប ជាសមាជិក
- តំណាងអង្គការសហជីពកម្មករនិយោជិតដែលមានភាពជាតំណាងជាងគេបំផុតក្នុងថ្នាក់ជាតិចំនួន ប្រាំមួយ(០៦) រូប ជាសមាជិក
- តំណាងអង្គការនិយោជកដែលមានភាពជាតំណាងជាងគេបំផុតក្នុងថ្នាក់ជាតិចំនួន ប្រាំមួយ(០៦) រូប ជាសមាជិក ។

គណៈកម្មការនេះ ត្រូវបោះឆ្នោតជ្រើសរើសអនុប្រធានពីររូប គឺម្នាក់ក្នុងចំណោម ៧នាក់ ដែលជាតំណាងនៃអង្គការសហជីពកម្មករនិយោជិត ដែលមានភាពជាតំណាងជាងគេបំផុតក្នុងថ្នាក់ជាតិ និងម្នាក់ទៀតក្នុងចំណោម ៧នាក់ ដែលតំណាងអង្គការនិយោជកដែលមានភាពជាតំណាងជាងគេបំផុតក្នុងថ្នាក់ជាតិ ។

នីតិវិធីនៃការបោះឆ្នោតជ្រើសរើសអនុប្រធានគណៈកម្មការប្រឹក្សាការងារត្រូវអនុវត្តដូចតទៅ ៖

-ដោយបានទទួលសិទ្ធិពីគណៈកម្មការប្រឹក្សាការងារក្នុងកិច្ចប្រជុំ សមាជិកទាំង៧រូប នៃភាគីតំណាងអង្គការសហជីពកម្មករនិយោជិត ដែលមានភាពជាតំណាងជាងគេបំផុតក្នុងថ្នាក់ជាតិ បោះឆ្នោតជ្រើសរើសអនុប្រធានមួយរូបនៃគណៈកម្មការប្រឹក្សាការងារ ។

-ដោយបានទទួលសិទ្ធិពីគណៈកម្មការប្រឹក្សាការងារក្នុងកិច្ចប្រជុំ សមាជិកទាំង៧រូប នៃភាគីតំណាងអង្គការនិយោជកដែលមាន ភាពជាតំណាងជាងគេបំផុតក្នុងថ្នាក់ជាតិ បោះឆ្នោតជ្រើសរើសអនុប្រធានមួយរូបនៃគណៈកម្មការប្រឹក្សាការងារ ។

គណៈកម្មការប្រឹក្សាការងារត្រូវមានសមាជិកបម្រុងដែលមានចំនួនស្មើនឹងចំនួនសមាជិកពេញសិទ្ធិ ។៚

## មាត្រា ៣.-

ឈ្មោះសមាជិកពេញសិទ្ធិ និងឈ្មោះសមាជិកបម្រុងរបស់គណៈកម្មការប្រឹក្សាការងារ ដែលឧទ្ទេសនាម ដោយក្រសួងពាក់ព័ន្ធ ដោយអង្គការសហជីពកម្មករនិយោជិត និងដោយអង្គការនិយោជក ត្រូវកំណត់ដោយ ប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

## ជំពូកទី ៣
## ការប្រព្រឹត្តទៅនៃគណៈកម្មការប្រឹក្សាការងារ

## មាត្រា ៤.-

លើកលែងតែប្រធានគណៈកម្មការដែលជារដ្ឋមន្ត្រី សមាជិកគណៈកម្មការប្រឹក្សាការងារមានអាណត្តិមួយ ឆ្នាំ ហើយអាចបន្តទៀតបានតាមការចាត់តាំងពីក្រសួង ស្ថាប័ន ឬអង្គការពាក់ព័ន្ធ ដូចមានចែងក្នុងមាត្រា២ នៃ អនុក្រឹត្យនេះ ។ គណៈកម្មការប្រឹក្សាការងារត្រូវដំណើរការការងារនៅក្នុងអាណត្តិរបស់ខ្លួន រហូតដល់មានការ ប្រកាសតែងតាំងសមាសភាពនៃគណៈកម្មការនេះសម្រាប់អាណត្តិថ្មីមកជំនួស ។

## មាត្រា ៥.-

ករណីដែលសមាជិកពេញសិទ្ធិទទួលមរណៈភាព លាឈប់ ត្រូវបានដកហូត ឬផ្លាស់ប្តូរពីតំណែង ដោយ ប្រការណាមួយ ដោយក្រសួង ស្ថាប័ន ឬអង្គការពាក់ព័ន្ធ សមាជិកបម្រុងដែលមកពីក្រសួង ស្ថាប័ន ឬអង្គការ ពាក់ព័ន្ធនោះនឹងក្លាយជាសមាជិកពេញសិទ្ធិដោយស្វ័យប្រវត្តិរហូតដល់ចប់អាណត្តិ ។ ក្នុងរយៈពេលនេះ ក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អាចស្នើអោយក្រសួង ឬអង្គការពាក់ព័ន្ធ ឧទ្ទេសនាមបេក្ខជនថ្មីជំនួសសមាជិក បម្រុងមុនបើពិនិត្យឃើញថាចាំបាច់ ។

## មាត្រា ៦.-

គណៈកម្មការប្រឹក្សាការងារត្រូវរួមប្រជុំពីរដងយ៉ាងតិច ក្នុងមួយឆ្នាំ ។ ប្រធានគណៈកម្មការប្រឹក្សា ការងារអាចកោះប្រជុំគណៈកម្មការនេះបានគ្រប់ពេល ទៅតាមការយល់ឃើញរបស់ខ្លួន ឬទៅតាមសំណើរបស់ អនុប្រធានណាមួយ ។ សំណើនេះត្រូវបញ្ជាក់ពីហេតុផលសមស្រប និងការចាំបាច់ ។ ក្នុងករណីឯកភាព ប្រធាន គណៈកម្មការត្រូវរៀបចំរបៀបវារៈនៃសម័យប្រជុំ ដោយពិគ្រោះយោបល់ជាមួយអនុប្រធានទាំងពីរ ។ ការប្រជុំ ត្រូវធ្វើក្នុងអំឡុង ៣០(សាមសិប)ថ្ងៃ យ៉ាងយូរ ក្រោយការរៀបចំរបៀបវារៈ ។ ក្នុងករណីដែលសមាជិកពេញ សិទ្ធិអវត្តមាន សមាជិកបម្រុងត្រូវចូលរួមប្រជុំជំនួស ។៚

លិខិតអញ្ជើញចូលរួមប្រជុំ និងឯកសារត្រៀមត្រូវផ្ញើជូនសមាជិកពេញសិទ្ធិ និងសមាជិកបម្រុងយ៉ាងយឺតបំផុត ១៥ (ដប់ប្រាំ) ថ្ងៃមុនសម័យប្រជុំ ។

**មាត្រា ៧.-**

ការបោះឆ្នោតត្រូវធ្វើឡើងតាមបទបញ្ជាស្តីពីការបញ្ចេញមតិ និងនីតិវិធីនៃការបោះឆ្នោតរបស់គណៈកម្មការប្រឹក្សាការងារ ។ ការសម្រេចរបស់គណៈកម្មការប្រឹក្សាការងារ ត្រូវធ្វើឡើងដោយយកតាមសម្លេងភាគច្រើននៃចំនួនសមាជិកដែលបានបោះឆ្នោត ។ ករណីទទួលបានសម្លេងស្មើគ្នា សម្លេងប្រធានមានឧត្តមានុភាព ។

**មាត្រា ៨.-**

កំណត់ហេតុនៃការប្រជុំត្រូវចុះហត្ថលេខាដោយប្រធាន និងអនុប្រធានគណៈកម្មការ ហើយត្រូវផ្ញើជូនសមាជិកពេញសិទ្ធិ និងសមាជិកបម្រុងទាំងអស់ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយថ្ងៃប្រជុំ ។

**មាត្រា ៩.-**

គណៈកម្មការប្រឹក្សាការងារមានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលរ៉ាប់រងដោយនាយកដ្ឋានវិវាទការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ១០.-**

អនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៨ ស្តីពីសមាសភាព និងការប្រព្រឹត្តទៅនៃគណៈកម្មការប្រឹក្សាការងារ អនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៨ ស្តីពីសមាសភាព និងការប្រព្រឹត្តទៅនៃគណៈកម្មការប្រឹក្សាការងារ អនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៩៨ និងអនុក្រឹត្យ ៣៧ អនក្រ.បក ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីសមាសភាព និងការប្រព្រឹត្តទៅនៃគណៈកម្មការប្រឹក្សាការងារ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។៚

**មាត្រា ១១.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួងស្ថាប័នពាក់ព័ន្ធ និងគ្រប់អង្គភាពវិជ្ជាជីវៈពាក់ព័ន្ធដូចមានចែងក្នុងមាត្រា២ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ល។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែឧសភា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ១១
- ឯកសារ - កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៥៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស

### រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញច្បាប់ការងារដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ៥៩ក្រ ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៩២
-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តមសីហនុវរ្ម័នព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តមសីហនុវរ្ម័នព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
-តាមសំណើរបស់រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ។

### សំរេច

**មាត្រា១.-** ដើម្បីដោះស្រាយជីវភាព និងបង្កើនមុខជំនាញវិជ្ជាជីវៈ រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស ដែលទីផ្សារការងារក្នុងប្រទេសមិនទាន់មានលទ្ធភាពទទួលយកអ្នកគ្មានការងារធ្វើ និងអ្នកដែលមានការងារធ្វើមិនពេញលេញបានអស់ និងរកប្រាក់ចំណូលចូលថវិកាជាតិ ។

**មាត្រា២.-** ការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស និងការគ្រប់គ្រងពលករទាំងនេះ ជាសមត្ថកិច្ចរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ។

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន អាចអនុញ្ញាតតាមប្រកាសរបស់ក្រសួងឱ្យក្រុមហ៊ុនណាមួយបញ្ជូនពលករខ្មែរណាមួយទៅធ្វើការនៅបរទេសបាន ។

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ត្រូវចេញសារាចរណែនាំអនុវត្តបន្ថែមទៀតក្នុងករណីចាំបាច់ ។

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ត្រូវសហការជាមួយក្រសួងមហាផ្ទៃ ក្នុងការធ្វើទំរង់បែបបទ ដូចជាលិខិតឆ្លងដែនជាដើម ដើម្បីបញ្ជូនពលករទៅបរទេស ហើយត្រូវសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិក្នុងការគ្រប់គ្រងពលករខ្មែរ ដែលធ្វើការនៅបរទេស ។

**មាត្រា៣.-** ត្រូវបានចាត់ទុកជាបេក្ខជនសំរាប់ជ្រើសរើសបញ្ជូនឱ្យទៅធ្វើការនៅបរទេស ពលករខ្មែរទាំងពីរភេទមានអាយុចាប់ពី ១៨ ឆ្នាំ ឡើងទៅដែលបានដាក់ពាក្យសុំរកការងារធ្វើនៅក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ។

**មាត្រា៤.-** ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ហៅថា ភាគីផ្តល់ពលករ ។ ក្រុមហ៊ុនដែលស្នើសុំជ្រើសរើសពលករហៅថា ភាគីទទួលពលករ ។

**មាត្រា៥.-** រាល់សំណើពីភាគីទទួលពលករ ត្រូវបញ្ជាក់ឱ្យច្បាស់លាស់អំពីល័ក្ខខ័ណ្ឌសំខាន់ៗ ជាអាទិ៍ :-

-កាលបរិច្ឆេទចាប់ផ្តើមអនុវត្ត និងបញ្ចប់ការងារ

-ប្រភេទការងារ

-ទីកន្លែងទៅធ្វើការងារ

-ចំនួន និងមុខជំនាញរបស់ពលករ

-ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ ដោយគិតទាំងការស្នាក់នៅ ហូបចុក ស្លៀកពាក់ ព្យាបាល ព្រមទាំងបញ្ហាផ្សេងៗទៀតក្នុងជីវភាពប្រចាំថ្ងៃ

-ការដឹកជញ្ជូនពលករទៅ និងមក ។

ក្រោយពីបានទទួលសំណើភាគីផ្តល់ពលករ ត្រូវឆ្លើយទៅភាគីទទួលពលករវិញ យ៉ាងយូរបំផុត ៤៥ថ្ងៃដោយត្រូវបញ្ជាក់ថា តើអាចផ្តល់ពលករបានកំរិតណា ឬមិនបាន ឬត្រូវពិភាក្សាគ្នាបន្ថែមទៀត ។

ភាគីទទួលពលករ ត្រូវឆ្លើយមកភាគីផ្តល់ពលករវិញយ៉ាងយូរ ៣០ថ្ងៃ ថាតើ ត្រូវការពលករទាំងអស់នោះឬទេ ឬត្រូវការតែកំរិតណាមួយនោះ ដោយត្រូវចូលមកពិភាក្សានៅពេលជាមួយគ្នានេះដែរ ។ ហួសរយៈពេល ៣០ថ្ងៃ ហើយបើគ្មានចម្លើយ និងមិនឃើញចូលមកពិភាក្សាទេ ភាគីផ្តល់ពលករកំណត់ថា ភាគីទទួលពលករមិនត្រូវការពលករទាំងនោះទេ ។

**មាត្រា៦.-** ការបញ្ជូនពលករទៅបរទេសអាចអនុវត្តបានលុះត្រាតែ មានការអនុញ្ញាតពីភាគីផ្តល់ពលករ និងត្រូវមានកិច្ចសន្យាការងាររវាងពលករជាមួយភាគីទទួលពលករ ។

**មាត្រា៧.-** ក្រោយពេលទទួលការអនុញ្ញាតិជាផ្លូវការរយៈពេល ០៧ថ្ងៃយ៉ាងយូរ ភាគីទទួលពលករ ត្រូវតំកល់ប្រាក់ធានាចំនួនមួយរយពាន់ដុល្លារអាមេរិក នៅក្នុងគណនីរបស់ភាគីផ្តល់ពលករ ។ បើភាគីពលករមិនបានបង់ប្រាក់ធានានោះទេ ការអនុញ្ញាតិនេះនឹងត្រូវចាត់ទុកជាមោឃៈ ។

ប្រាក់តំកល់នេះ សំរាប់ឱ្យភាគីផ្តល់ពលករបើកឱ្យពលករជំនួសភាគីទទួលពលករ ក្នុងករណីដែលភាគីមិនបានគោរពលក្ខខណ្ឌណាមួយដែលមានចែងក្នុងកិច្ចសន្យាការងារ ។

ក្នុងពេលអនុវត្តកិច្ចសន្យាការងារ បើប្រាក់តំកល់នេះត្រូវបានដកខ្លះដើម្បីឱ្យពលករ ភាគីទទួលពលករត្រូវបង់បំពេញឱ្យបានគ្រប់ចំនួនឡើងវិញ ។

ភាគីទទួលពលករ អាចដកប្រាក់តំកល់នេះទៅវិញបាន នៅពេលចប់កិច្ចសន្យាការងារជាស្ថាពរជាមួយពលករទាំងអស់ ។

ប្រាក់តំកល់ក្នុងមាត្រានេះ អាចបន្ធូរបន្ថយបានចំពោះនិយោជកដែលត្រូវការជ្រើសរើសពលករខ្មែរតែបន្តិចបន្តួចដោយផ្ទាល់ ដើម្បីយកមកធ្វើការក្នុងរោងជាង ឬរោងជាងសិប្បកម្មរបស់ខ្លួន ប៉ុន្តែនិយោជកនោះចាំបាច់ត្រូវពិភាក្សាជាមួយក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ដើម្បីធ្វើកិច្ចសន្យាឯកត្តភូតជាមួយពលករទាំងនោះ ។

**មាត្រា៨.-** ភាគីទទួលពលករត្រូវបង់សោហ៊ុយសេវា និងការរៀបចំឯសារផ្សេងៗ ជូនភាគីផ្តល់ពលករតាមការឯកភាពគ្នាដែលមានកំណត់ក្នុងកិច្ចសន្យា ។

**មាត្រា៩.-** កិច្ចសន្យាការងារ ត្រូវបញ្ជាក់ឱ្យច្បាស់ជាអាទិ៍ :-

-ឈ្មោះ និងអាសយដ្ឋានរបស់ភាគីនីមួយៗ

-កាលបរិច្ឆេទនៃការចាប់ផ្តើម និងបញ្ចប់កិច្ចសន្យា

-ទីកន្លែង និងប្រភេទការងារជាក់ស្តែង

-មុខជំនាញពលករ

-ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗ

-ភាគបៀវត្ស និងប្រាក់បំណាច់ផ្សេងៗដែលត្រូវបញ្ជូនមកគ្រួសារ

-ពេលម៉ោងធ្វើការ និងថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ ប្រចាំឆ្នាំ

-ការស្នាក់នៅ ហូបចុក ស្លៀកពាក់ ព្យាបាល

-ការបង់ប្រាក់ធានារ៉ាប់រងចំពោះពលករម្នាក់ៗ

-ការប្រគល់ និងទទួលពលករពេលទៅ និងពេលត្រឡប់មកវិញ

-សោហ៊ុយដឹកជញ្ជូនពលករទៅ និងមក

-ករណីដែលត្រូវបញ្ជូនពលករមកមាតុប្រទេសវិញមុនកាលកំណត់ក្នុងកិច្ចសន្យាការងារ ។

**មាត្រា១០.-** ពលករទាំងអស់ ត្រូវមានសិទ្ធិឈប់សំរាកប្រចាំឆ្នាំ ដោយមានប្រាក់ឈ្នួលដែលភាគីទទួលពលករត្រូវចេញឱ្យ ។ ឯចំនួនថ្ងៃឈប់សំរាកនេះ ត្រូវគិតជាថ្ងៃធ្វើការធម្មតាមួយថ្ងៃកន្លះយ៉ាងតិចក្នុងរយៈពេលធ្វើការមួយខែជាប់ ។

**មាត្រា១១.-** កិច្ចសន្យាការងារត្រូវធ្វើជាពីរភាសា ដែលមានតំលៃស្មើគ្នា គឺជាភាសាខ្មែរ និងភាសាបារាំង ឬ អង់គ្លេស ។ រយៈពេលនៃកិច្ចសន្យាការងារមិនត្រូវឱ្យលើសពីពីរឆ្នាំឡើយ ។

នៅពេលចប់អាណត្តិនៃកិច្ចសន្យាការងារ ភាគីទាំងពីរអាចពិភាក្សាគ្នាបន្តអនុវត្តកិច្ចសន្យាទៅទៀតបាន ឬមួយធ្វើកិច្ចសន្យាសាថ្មី ។ កិច្ចសន្យាបន្តការងារតទៅទៀត ឬធ្វើសាជាថ្មីក៏ត្រូវមានការចុះទិដ្ឋាការសាថ្មីពីក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនដែរ ។

**មាត្រា១២.-** ភាគីផ្តល់ពលករ ជាអ្នកជ្រើសរើសពលករតាមមុខជំនាញនីមួយៗ ឱ្យបានគ្រប់ចំនួនដែលបានកំណត់ក្នុងកិច្ចសន្យាការងារ ។

កិច្ចសន្យាការងារ ដែលពលករចុះហត្ថលេខាជាមួយភាគីទទួលពលករ ត្រូវមានចុះទិដ្ឋាការរបស់អធិការការងារមានសមត្ថកិច្ច ។

**មាត្រា១៣.-** នៅពេលចុះកិច្ចសន្យាការងារ ពលករម្នាក់ៗត្រូវផ្តល់:

| | |
|---|---|
| -ជីវប្រវត្តិសង្ខេបរបស់សាមីជនមានបិទរូបថត ៤ x ៦ ស.ម | ០២ សន្លឹក |
| -សំបុត្រថ្កោលទោស | ០២ ច្បាប់ |
| -លិខិតបញ្ជាក់សុខភាពដែលចេញឱ្យដោយនាយកដ្ឋានពេទ្យការងារ | ០២ ច្បាប់ |
| -សេចក្តីចម្លងសញ្ញាប័ត្រ ឬលិខិតបញ្ជាក់មុខជំនាញ "បើសិនមាន" | ០២ ច្បាប់ |
| -សេចក្តីចម្លងលិខិតឆ្លងដែនរបស់សាមីជន | ០២ ច្បាប់ |
| -ប័ណ្ណសុំការងារ | ០២ ច្បាប់ |

**មាត្រា១៤.-** មុនពេលចេញដំណើរទៅបរទេស ភាគីផ្តល់ពលករ និងទទួលពលករ ត្រូវទទួលបន្ទុករៀបចំធ្វើកម្មសិក្សាអំពីរបៀបរបបធ្វើការងារ របៀបរបបរស់នៅ ទំនៀមទំលាប់ប្រពៃណី និងច្បាប់ទំលាប់ជាចាំបាច់របស់ប្រទេសទទួលពលករ ។

**មាត្រា១៥.-** ប្រាក់បៀវត្សរបស់ពលករម្នាក់ៗត្រូវជាប់ពន្ធតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា១៦.-** ភាគីទទួលពលករ ត្រូវរ៉ាប់រងចេញសោហ៊ុយចំណាយឱ្យមន្ត្រីរបស់ប្រទេសផ្តល់ពលករ ទៅបំពេញបេសកកម្ម ដើម្បីជូនពលករទៅដល់ប្រទេសទទួលពលករ ត្រួតពិនិត្យល័ក្ខខ័ណ្ឌការងារ ទីកន្លែងធ្វើការងារ និងទីស្នាក់អាស្រ័យរបស់ពលករដែលបានកំណត់ក្នុងកិច្ចសន្យា ។

ភាគីផ្តល់ពលករ ត្រូវបញ្ជូនមន្ត្រីទៅពិនិត្យការអនុវត្តន៍កិច្ចសន្យាការងារដល់ទីកន្លែងក្នុងរយៈដែលចាំបាច់ ។

**មាត្រា១៧.** បើមានវិវាទការងារកើតឡើង ភាគីទទួលពលករត្រូវពិភាក្សា និងដោះស្រាយជាមួយពលករភ្លាម ដោយផ្អែកលើកិច្ចសន្យាការងារ ។ បើការពិភាក្សាគ្នាមិនអាចសំរុះសំរួលគ្នាបានទេ នោះគេត្រូវផ្តល់ពត៌មានភ្លាម ទៅស្ថានឯកអគ្គរាជទូត ឬបេសកកម្មរបស់ព្រះរាជាណាចក្រកម្ពុជា ប្រចាំប្រទេសនោះ ដើម្បីចូលរួមដោះស្រាយ ។

**មាត្រា១៨.** ភាគីទទួលពលករត្រូវផ្តល់ពត៌មានដល់ភាគីផ្តល់ពលករឱ្យបាន ៤៥ថ្ងៃ មុនកាលបរិច្ឆេទនៃការត្រឡប់មកមាតុប្រទេសវិញ ពិតប្រាកដរបស់ពលករ ។

ភាគីទទួលពលករ និងភាគីផ្តល់ពលករ ត្រូវរៀបចំរួមគ្នាអំពីប្រតិទិន នៃការធ្វើមាតុភូមិនិវត្តន៍របស់ពលករ ។

**មាត្រា១៩.** ការបាត់ខ្លួនរបស់ពលករនៅក្នុងរយៈពេលអនុវត្តកិច្ចសន្យាការងារ ភាគីទទួលពលករ ត្រូវផ្តល់ពត៌មានជាបន្ទាន់ ដល់ស្ថានឯកអគ្គរាជទូត ឬបេសកកម្មទូតរបស់ព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនោះ និងមកក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជននៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា២០.** ជនណាដែលបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស ដោយល្មើសនឹងបទប្បញ្ញត្តិទាំងឡាយក្នុងអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**មាត្រា២១.** បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា២២.** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និងចុះហត្ថលេខាតទៅ ។ p

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៥

**នាយករដ្ឋមន្ត្រីទី១** — **នាយករដ្ឋមន្ត្រីទី២**

**នរោត្តម រណឫទ្ធិ** — **ហ៊ុន សែន**

# ប្រកាស

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
និងអតីតយុទ្ធជន
លេខ: ០៨ សកអ/៩៤

រាជធានីភ្នំពេញ ,ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៤

# ប្រកាសរួម
## ស្តីពី
## ការចាត់តាំងបណ្ណាញពេទ្យការងារ

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**
**រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន**

-បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញ ព្រះរាជក្រឹត្យ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
-បានឃើញច្បាប់ការងារដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ៩៩ ក្រ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៩២

## សំរេច

**ប្រការ១.-** គ្រប់រោងចក្រ សហគ្រាស គ្រឹះស្ថាន ឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សិប្បកម្ម កសិកម្ម សេវាកម្ម សហគ្រាសដឹកជញ្ជូន តាមផ្លូវថ្នល់ ឬតាមទន្លេ ទោះជាប្រយោជន៍សាធារណៈ ពាក់កណ្តាលសាធារណៈ ឬឯកជន ក្រៅសាសនា ឬក្នុងសាសនាក៏ដោយ ទោះបីជាមានលក្ខណៈជាការបង្រៀនវិជ្ជាជីវៈ ជាការកុសលក៏ដោយ ត្រូវរៀបចំចាត់តាំងបណ្តាញពេទ្យការងារ ដើម្បីធានាសន្តិសុខការងារ អនាម័យការងារ និងសុខភាពរបស់និយោជិត និងកម្មកររបស់ខ្លួន ។ ក៏ប៉ុន្តែមិនត្រូវអនុវត្តបទប្បញ្ញត្តិនេះ ចំពោះរោងជាងទាំងឡាយណា ដែលមានប្រើតែនិយោជិតជាសមាជិកគ្រួសារ ដែលឋិតនៅក្រោមការគ្រប់គ្រងរបស់ឪពុកម្តាយ ឬអ្នកអាណាព្យាបាលប៉ុណ្ណោះ លើកលែងតែការងារប្រព្រឹត្តទៅដោយឡចំហាយ ឬគ្រឿងយន្ត ឬអគ្គីសនី ឬក៏ឧស្សាហកម្ម នោះជាគ្រឹះស្ថានដែលអាចមានគ្រោះថ្នាក់ ឬខូចសុខភាព ។

សហគ្រាស និងគ្រឹះស្ថានដែលអង្គុលក្នុងមាត្រា១ នៃច្បាប់ការងារ ត្រូវឱ្យមានព្យាបាលជម្ងឺដោយឥតគិតថ្លៃ សំរាប់អ្នកស៊ីឈ្នួលទៀងទាត់របស់ខ្លួន និងគ្រួសារអ្នកស៊ីឈ្នួលទាំងនោះ។

**ប្រការ២.-** គ្រប់រោងចក្រ សហគ្រាស និងក្រុមហ៊ុនដែលបានចែងក្នុងប្រការ១ ហើយដែលមានប្រើអ្នកស៊ីឈ្នួលយ៉ាងតិច ៥០នាក់ ត្រូវរៀបចំគិលានដ្ឋានអចិន្ត្រៃយ៍មួយឱ្យបានសមរម្យ តាមលក្ខខណ្ឌខាងក្រោម :

- មានទំហំសមស្របទៅតាមចំនួនបុគ្គលិក កម្មករ ប៉ុន្តែយ៉ាងតូចបំផុតឱ្យមានទំហំផ្ទៃ ១៦ ម៉ែត្រក្រឡា ។
- មានភាពងាយស្រួលដល់អ្នកជម្ងឺចេញ-ចូល
- មានពន្លឺ និងខ្យល់អាកាសចេញ-ចូលគ្រប់គ្រាន់
- នៅឆ្ងាយពីសម្លេង ធូលី ផ្សែង កាកសំណល់ផ្សេងៗ

កាលណាសហគ្រាសមានសាខា ឬការដ្ឋានមួយ ឬច្រើនដែលមានប្រើអ្នកស៊ីឈ្នួលយ៉ាងតិច ៥០នាក់ ហើយស្ថិតនៅចម្ងាយលើសពី ៥ គីឡូម៉ែត្រ (៥ គ.ម) ពីការដ្ឋានធំ និយោជកត្រូវតែផ្តល់ចំពោះសាខា ឬការដ្ឋានទាំងនោះ ឱ្យដូចជាការដ្ឋានធំដែរ នូវមធ្យោបាយសង្គ្រោះ និងព្យាបាលអ្នកស៊ីឈ្នួលខ្លួន ឱ្យបានសព្វគ្រប់ដូចជាបុគ្គលិកពេទ្យ សំណង់ សំភារៈវត្ថុរំរបួស និងថ្នាំ ព្យាបាល ។

**ប្រការ៣.-** គ្រប់រោងចក្រ សហគ្រាស ក្រុមហ៊ុនផ្សេងៗ ដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវមានបុគ្គលិកធ្វើការក្នុងគិលានដ្ឋានរបស់ខ្លួនជាប្រចាំដូចតទៅ :

- គ្រូពេទ្យមធ្យម ០១នាក់ និងគិលានុប្បដ្ឋាក ឬគិលានុប្បដ្ឋាយិកា ០១នាក់ សំរាប់បុគ្គលិកកម្មករចាប់ពី ៥០នាក់ ទៅ ២០០នាក់ ។
- គ្រូពេទ្យមធ្យម ០១នាក់ និងគិលានុប្បដ្ឋាក ឬគិលានុប្បដ្ឋាយិកា ០២នាក់ សំរាប់បុគ្គលិកកម្មករចាប់ពី ៤០០នាក់ឡើងទៅ ។
- ក្នុងករណីពិសេស ត្រូវមានវេជ្ជបណ្ឌិត ០១នាក់ និងគិលានុប្បដ្ឋាក ឬគិលានុប្បដ្ឋាយិកា ០១នាក់ ឬ ០២នាក់ ធ្វើការជាប្រចាំផងដែរ ដោយពុំគិតចំនួនបុគ្គលិក កម្មករឡើយ ចំពោះរោងចក្រ សហគ្រាស ឬក្រុមហ៊ុនណាដែលប្រកបដោយហានិភ័យខ្ពស់ ឬក្នុងករណីដែលក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន យល់ឃើញថា ចាំបាច់ត្រូវមានវេជ្ជបណ្ឌិត ធ្វើការជាប្រចាំ ។
- ចំពោះសហគ្រាសដែលមានចែកម៉ោងធ្វើការទាំងថ្ងៃទាំងយប់ ត្រូវមានគិលានុប្បដ្ឋាក ឬគិលានុប្បដ្ឋាយិកាយ៉ាងតិច ០១ នាក់ យាមប្រចាំការជាអចិន្ត្រៃយ៍ ។

**ប្រការ៤.-** - ចំពោះរោងចក្រ សហគ្រាស ឬក្រុមហ៊ុនផ្សេងៗណា ដែលមានអ្នកស៊ីឈ្នួលតិចជាង ២០នាក់ ត្រូវមានអ្នកជំនួយសង្គ្រោះ ០១ នាក់ និងប្រអប់សង្គ្រោះមួយ ។

- ចំពោះរោងចក្រ សហគ្រាស ឬ ក្រុមហ៊ុនផ្សេងៗណា ដែលមានអ្នកស៊ីឈ្នួលចាប់ពី ២០ នាក់ ទៅ ៥០នាក់ ត្រូវមានបន្ទប់រុំរបួសមួយ និងគិលានុប្បដ្ឋាក ឬគិលានុប្បដ្ឋាយិកា ០១នាក់។

- ចំពោះសហគ្រាស ដែលមានអ្នកស៊ីឈ្នួលមិនគ្រប់ចំនួននឹងត្រូវបង្កើតគិលានដ្ឋានអចិន្ត្រៃយ៍មួយ សហគ្រាសទាំងនោះ អាចរួមសហការជាមួយសហគ្រាសផ្សេងដ៏ទៃទៀតដែលស្ថិតនៅជិតគ្នា ដើម្បីបង្កើតជាគិលានដ្ឋានអចិន្ត្រៃយ៍មួយ ហៅថា គិលានដ្ឋានអន្តរៈសហគ្រាស ។

**ប្រការ៥.-**

**ក-ប្រអប់សង្គ្រោះត្រូវមានជាចាំបាច់:**

- សំភារៈរុំរបួស
- សំភារៈសម្រាប់ឃាត់ឈាម ឱសថផ្សេងៗ ដូចជាថ្នាំបំបាត់ការឈឺចាប់
- ថ្នាំបញ្ចុះកំដៅ ថ្នាំទប់ទល់នឹងការរាគរូស ក្អួត ថ្នាំប្រឆាំងនឹងការរលាកភ្លើង
- ប្រេងខ្យល់ ប្រេងកូឡា ជាដើម ។

**ខ-បន្ទប់រុំរបួសត្រូវមានជាចាំបាច់នូវ:**

- ប្រអប់សង្គ្រោះមួយ
- គ្រែរុំរបួសមួយ
- តុ កៅអី
- ភ្លើងបំភ្លឺ

**គ-គិលានដ្ឋាន:**

ក្នុងគិលានដ្ឋាននីមួយៗ ត្រូវមានគ្រែ ០២ យ៉ាងតិច " គ្រែមួយសំរាប់ព្យាបាលជម្ងឺ គ្រែមួយទៀតសំរាប់សង្គ្រោះបន្ទាន់ " ។ p

កាលណាចំនួនអ្នកស៊ីឈ្នួលមានច្រើនជាង ៤០០នាក់ ក្រៅពីគ្រឿងរុំរបួស គិលានដ្ឋាន ត្រូវមានកន្លែងសំរាប់ឱ្យអ្នករបួស និងអ្នកជំងឺសំរាក មុននឹងបញ្ជូនទៅមន្ទីរពេទ្យធំ ឬសំរាប់ដាក់អ្នកជម្ងឺឱ្យសំរាកនៅឆ្ងាយពីគេ កាលណាត្រូវការ ។ ទីកន្លែងទាំងនោះត្រូវមានលទ្ធភាពដាក់អ្នកជម្ងឺសំរាកឱ្យបាន ០២ភាគរយ នៃអ្នកស៊ីឈ្នួលដែលប្រើក្នុងការដ្ឋាន ។

ក្រៅពីវិធានការដែលចែងខាងលើ និយោជកត្រូវតែចាត់ចែងដោយចេញសោហ៊ុយខ្លួនឯងនូវ :

១- ក្រុមគីមីញ៉ូ បង្ការរោគនៅក្នុងការដ្ឋានខ្លួន

២- ការចាក់ថ្នាំការពារជម្ងឺឆ្លងទាំងឡាយ ដោយប្រើស៊ីរ៉ាំង និងម្ជុលចាក់ម្តងចោល ។

**ប្រការ៦.-** សោហ៊ុយចំណាយក្នុងការរៀបចំគិលានដ្ឋាន និងការប្រព្រឹត្តិទៅនៃក្រុមពេទ្យការងារ ទាំងការព្យាបាល ថែទាំ និងអាហារនៃអ្នករបួស និងអ្នកជម្ងឺសំរាកក្នុងគិលានដ្ឋានសហគ្រាស ត្រូវនៅក្នុងបន្ទុកនិយោជក។

**ប្រការ៧.-** ការប្រព្រឹត្តិល្មើស ឬមិនអនុវត្តតាមបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យជាប្រាក់ ឬ ទទួលទោសដូចមានចែងក្នុងមាត្រា ២៨៦ ២៨៧ និង ២៨៩ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៨.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីពេលចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **រដ្ឋមន្ត្រី ក្រសួងសុខាភិបាល** | **រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន** |
| **ហត្ថលេខា និង ត្រា** | **ហត្ថលេខា និង ត្រា** |
| **វេជ្ជ. ឈា ថាំង** | **ស៊ុយ សែម** |

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
និងអតីតយុទ្ធជន

លេខ: ០៩ សកអ/៩៤

រាជធានីភ្នំពេញ ,ថ្ងៃទី ១៩ ខែ មករា ឆ្នាំ១៩៩៤

# ប្រកាសរួម
## ស្តីពី
## ការពិនិត្យកាយសម្បទាសំរាប់ជនកម្ពុជា និងជនបរទេស ដែលប្រកបមុខរបរ នៅព្រះរាជាណាចក្រកម្ពុជា

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន**

-បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញ ព្រះរាជក្រឹត្យ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
-បានឃើញច្បាប់ការងារដែលប្រកាសអោយប្រើតាមក្រិត្យលេខ ៩៩ ក្រ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៩២

## សំរេច

**ប្រការ១.-** ជនកម្ពុជា និងជនបរទេសទាំងពីរភេទ ដែលប្រកបមុខរបរណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ចាំបាច់ត្រូវឆ្លងការពិនិត្យកាយសម្បទា ។

**ប្រការ២.-** នាយកដ្ឋានពេទ្យការងារនៃក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន មានភារកិច្ចពិនិត្យកាយសម្បទា និងកំណត់បែបបទ និងលក្ខណៈបច្ចេកទេសនៃការពិនិត្យកាយសម្បទា ។

**ប្រការ៣.-** មុនពេលប្រកបមុខរបរ ជនកម្ពុជា និងបរទេសទាំងនោះ ត្រូវទៅពិនិត្យកាយសម្បទាជាចាំបាច់នៅនាយកដ្ឋានពេទ្យការងារ ដែលស្ថិតនៅអគារលេខ៤៨២ ផ្លូវជាតិលេខ២ សង្កាត់ចាក់អង្រែ ខណ្ឌ មានជ័យ រាជធានីភ្នំពេញ ។

**ប្រការ៤.-** ចំពោះជនកម្ពុជា និងជនបរទេស ដែលបានចូលធ្វើការរួចហើយមុនប្រកាសរួមនេះចេញផ្សាយ ក៏ត្រូវពិនិត្យកាយសម្បទា នៅនាយកដ្ឋានពេទ្យការងារនេះដែរ ។

ប្រការ៥.- ការពិនិត្យកាយសម្បទា អាចមានការពិនិត្យជាលក្ខណៈពិសេសថែមទៀត តាមមុខជំនាញវិជ្ជាជីវៈជាក់ស្តែង ។

ប្រការ៦.- ក្រោយពីពេលធ្វើការពិនិត្យកាយសម្បទា បានសព្វគ្រប់ត្រឹមត្រូវហើយនោះ ទើបនាយកដ្ឋានពេទ្យការងារចេញវិញ្ញាបនប័ត្របញ្ជាក់ការពិនិត្យកាយសម្បទានេះ ជូនសាមីជន ដើម្បីប្រើប្រាស់ជាផ្លូវការ ។

ប្រការ៧.- ម្ចាស់សហគ្រាស ត្រូវបង់ថ្លៃឈ្នួលសំរាប់ការពិនិត្យកាយសម្បទានៃនិយោជិតរបស់ខ្លួន ដែលបានកំណត់ក្នុងប្រការ ៥ ខាងលើ ទៅតាមករណីនីមួយៗ ។

ប្រការ៨.- ការប្រព្រឹត្តិល្មើស ឬមិនអនុវត្តតាម បទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោស ដូចមានចែងក្នុងមាត្រា ២៨៦ និង ២៨៨ នៃច្បាប់ស្តីពីការងារ ។

ប្រការ៨.- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីពេលចុះហត្ថលេខា តទៅ ។

| | |
|---|---|
| **រដ្ឋមន្ត្រី ក្រសួងសុខាភិបាល** | **រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន** |
| **ហត្ថលេខា និង ត្រា** | **ហត្ថលេខា និង ត្រា** |
| **វេជ្ជ. ឈា ថាំង** | **ស៊ុយ សែម** |

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
និងអតីតយុទ្ធជន

លេខ : ៨៦ សកអ.

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩៧

# ប្រកាសរួម
## ស្តីពី
## ប្រាក់ឈ្នួលយោងប្រចាំថ្ងៃ

**ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញច្បាប់ការងារ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស.រកម ០៣៩៧/១០ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១.០៩៤-៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១.០៩៤-៩០ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ p

## សំរេច

**ប្រការ១.-** កំណត់ប្រាក់ឈ្នួលយោងប្រចាំថ្ងៃ ស្មើនឹងប្រាំបីពាន់រៀល (៨.០០០៛.០០) ។

**ប្រការ២.-** ប្រាក់ឈ្នួលយោងប្រចាំថ្ងៃ នៃប្រការ១ នេះគឺជាកំរិតកំណត់សំរាប់គណនាការដាក់ពិន័យទៅតាមទោសបញ្ញត្តិក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៣.-** ប្រកាសរួមនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងយុត្តិធម៌** | **រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន** |
| **ហត្ថលេខា និង ត្រា** | **ហត្ថលេខា និង ត្រា** |
| **ចែម ស្ងួន** | **ស៊ុយ សែម** |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ: ១០ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ១៩៩៩

# ប្រកាស
# ស្តីពី
# ប្រាក់បំណាច់នៃការងារដែលបានធ្វើក្នុងឱកាស ថ្ងៃឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួល

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## សំ រេ ច

**ប្រការ១.-** ម្ចាស់ ឬនាយកគ្រឹះស្ថាន សហគ្រាស ដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារត្រូវអនុញ្ញាតអោយកម្មករនិយោជិតរបស់ខ្លួនបានឈប់សំរាក ដោយមានប្រាក់ឈ្នួលក្នុងឱកាសថ្ងៃឈប់បុណ្យដែលកំណត់ជារៀងរាល់ឆ្នាំដោយប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

**ប្រការ២.-** ក្នុងករណីចាំបាច់ដែលគ្រឹះស្ថាន ឬសហគ្រាស មិនអាចបញ្ឈប់សកម្មភាពរបស់ខ្លួនបាន ក្នុងឱកាសថ្ងៃឈប់បុណ្យដូចមានចែងក្នុងប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ

និងយុវនីតិសម្បទា ម្ចាស់ ឬនាយកគ្រឹះស្ថាន សហគ្រាស អាចសំរបសំរួលជាមួយកម្មករនិយោជិតរបស់ខ្លួនអោយធ្វើការនៅថ្ងៃឈប់បុណ្យទាំងនេះបាន ។

**ប្រការ៣.-** ការធ្វើការថ្ងៃបុណ្យ ត្រូវមានការស្ម័គ្រចិត្តពីកម្មករនិយោជិត ។

**ប្រការ៤.-** កម្មករនិយោជិតដែលធ្វើការថ្ងៃឈប់បុណ្យមានសិទ្ធិទទួលនូវប្រាក់បំណាច់មួយ ដែលមានចំនួនស្មើនឹងប្រាក់ឈ្នួលថ្ងៃធ្វើការធម្មតា ។

**ឧទាហរណ៍:** ១-និយោជិតម្នាក់មានប្រាក់ឈ្នួលសុទ្ធសាធប្រចាំខែ ៥២ ដុល្លារ ក្នុងមួយខែ។ នៅថ្ងៃ០៨ មីនា ជាថ្ងៃឈប់បុណ្យមានប្រាក់ឈ្នួល និយោជិតនោះស្ម័គ្រចិត្តមកធ្វើការតាមសំណូមពររបស់និយោជកពេញមួយថ្ងៃធ្វើការ ។ ក្នុងករណីនេះដល់ពេលបើកប្រាក់ឈ្នួលគាត់ត្រូវទទួលបាន:

$$= 52\,\$ + \left(\frac{52\,\$}{26} \text{ x } 1\right) = 54\,\$$$

**ឧទាហរណ៍:** ២-និយោជិតម្នាក់ទៀតមានប្រាក់ឈ្នួលសុទ្ធសាធ ៥២ ដុល្លារ ក្នុងមួយខែ ។ នៅថ្ងៃ ៨ មីនា ជាថ្ងៃឈប់បុណ្យមានប្រាក់ឈ្នួល និយោជិតនោះគាត់ស្ម័គ្រចិត្តមកធ្វើការចំនួន ៤ ម៉ោង តាមសំណូមពររបស់និយោជក ។ ថិរវេលាធ្វើការរបស់សហគ្រាសគឺ ៤៨ ម៉ោង ក្នុងមួយសប្តាហ៍។ ក្នុងករណីនេះនៅពេលបើកប្រាក់ឈ្នួលគាត់ត្រូវទទួលបាន:

$$= 52\,\$ + \left[\left(\frac{52\,\$ \text{ x } 12}{52 \text{ x } 48}\right) \text{X } 4\right] = 53\,\$$$

**ប្រការ៥.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ៧៧សកអ. ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

MOSALVY

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខៈ ៨០ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ មីនា ឆ្នាំ១៩៩៩

# ប្រកាស
# ស្តីពី
# ការធ្វើការបន្ថែមម៉ោង ក្រៅពីថិរវេលាធ្វើការធម្មតា

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## សំរេច

**ប្រការ១.-** ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារ អាចស្នើសុំការអនុញ្ញាតិពីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីធ្វើការបន្ថែមម៉ោងលើសពីថិរវេលាធ្វើការធម្មតារបស់សហគ្រាស គ្រឹះស្ថានរបស់ខ្លួននៅក្នុងករណីដូចតទៅៈ

ក-ដើម្បីអោយការងារពិសេសប្រព្រឹត្តទៅបានដូចជា ការធ្វើបញ្ជីសារពើភ័ណ្ឌ និងតុល្យការ ការដាក់កំណត់ពេលវេលាការជំរះបញ្ជី និងការបញ្ឈប់គណនេយ្យ ។

ខ-ដើម្បីអោយសហគ្រាសអាចទប់ទល់ និងការងារ ដែលមានច្រើនខុសធម្មតាបណ្តាលមកពីកាលៈទេសៈប្លែកៗដោយមិនអាចរង់ចាំនិយោជករកវិធានការដទៃទៀត ។

**ប្រការ២.-** សំណុំលិខិតនៃការស្នើសុំធ្វើការបន្ថែមម៉ោងមានដូចតទៅៈ-

១-លិខិតស្នើសុំរបស់សហគ្រាស គ្រឹះស្ថានចំនួន ០១ ច្បាប់

២-លិខិតបញ្ជាក់អំពីយោបល់ឯកភាពរបស់ប្រតិភូពេញសិទ្ធិ គ្រប់រូបរបស់សហគ្រាសគ្រឹះស្ថាន ឬការឯកភាពពីចំនួនពាក់កណ្ដាលនៃកម្មករនិយោជិត បើសហគ្រាស គ្រឹះស្ថានមិនទាន់មានប្រតិភូបុគ្គលិកចំនួន ០១ ច្បាប់ ។

**ប្រការ៣.-** សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលមានទីតាំងនៅរាជធានីភ្នំពេញ ត្រូវបញ្ជូនសំណុំលិខិតទៅស្នើសុំធ្វើការបន្ថែមម៉ោងនៅ នាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដែលស្ថិតនៅអគារលេខ២៨ វិថីសម្ដេចព្រះធម្មលិខិតអ៊ុក (ផ្លូវលេខ ១៨៤) សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។ ចំណែកសហគ្រាស គ្រឹះស្ថាន ដែលមានទីតាំងនៅតាមខេត្ត-ក្រុង ដទៃទៀតត្រូវបញ្ជូនសំណុំលិខិតទៅអធិការដ្ឋានសង្គមកិច្ចខេត្ត-ក្រុង នៃមូលដ្ឋានខ្លួន ។

សំណុំលិខិតនៃការស្នើសុំធ្វើការបន្ថែមម៉ោង ត្រូវបញ្ជូនទៅនាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្នុងរយៈពេលយ៉ាងតិច ១៥ថ្ងៃ មុនការចាប់ផ្ដើមធ្វើការបន្ថែមម៉ោង ។ ចំពោះខេត្ត-ក្រុងដទៃទៀត ក្រៅពីរាជធានីភ្នំពេញ ក៏ត្រូវអនុវត្តកាលកំណត់នេះដូចគ្នាដែរ ។

**ប្រការ៤.-** ការរៀបចំធ្វើការបន្ថែមម៉ោងនេះ ត្រូវផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត ពោលគឺម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន មិនត្រូវបង្ខិតបង្ខំ ឬដាក់វិន័យផ្សេងៗ ចំពោះកម្មករនិយោជិតដែលមិនស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងឡើយ ។ p

**ប្រការ៥.-** ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវផ្ដល់ប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោងជូនកម្មករនិយោជិតដូចតទៅ :-

ក-ស្មើនឹង ១៥០% (ឬមួយដងកន្លះ) នៃប្រាក់ឈ្នួលពេលធ្វើការធម្មតា ចំពោះការធ្វើការបន្ថែមម៉ោងនៅពេលថ្ងៃនៃថ្ងៃធ្វើការធម្មតា ។

ខ-ស្មើនឹង ២០០% (ឬពីរដង) នៃប្រាក់ឈ្នួលពេលធ្វើការធម្មតា ចំពោះការធ្វើការបន្ថែមម៉ោងនៅពេលយប់ (ពីម៉ោង២២:០០ ទៅម៉ោង ៥:០០ព្រឹក) ។

**ប្រការ៦.-** ចំពោះសហគ្រាសដែលមានកម្មករនិយោជិតធ្វើការពេលយប់ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវផ្ដល់ទីកន្លែងសំរាកទទួលទានដំណេកឱ្យបានសមរម្យដល់កម្មករនិយោជិត ដែលចេញពីធ្វើការនៅពេលយប់ ពុំនោះសោតទេ ត្រូវផ្ដល់មធ្យោបាយសំរាប់ដឹកជញ្ជូនកម្មករនិយោជិតទៅដល់លំនៅដ្ឋានរៀងៗខ្លួនវិញប្រកបដោយសុវត្ថិភាព នៅពេលចប់ម៉ោងធ្វើការពេលយប់ ។

**ប្រការ៧.-** រាល់ការប្រព្រឹត្តិល្មើសនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវពិន័យ ឬផ្តន្ទាទោសតាមច្បាប់ដូចមានចែងក្នុងជំពូកទី ១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៨.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខៈ ០០៤ សគបយ.

រាជធានីភ្នំពេញ . ថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០០០

# ប្រកាស
# ស្តីពី
# ការហ្វឹកហ្វឺនកូនជាង

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## សំរេច

**ប្រការ១.-** សហគ្រាស គ្រឹះស្ថាន រោងចក្រទាំងអស់ ដែលមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវហ្វឹកហ្វឺនកូនជាងឱ្យបានពេញលេញស្របតាមលក្ខណៈបច្ចេកទេសនៃមុខរបរ និងប្រភេទការងាររបស់សហគ្រាស គ្រឹះស្ថាន រោងចក្រទាំងនោះ ។

កូនជាង គឺជាជនដែលបានចុះកិច្ចសន្យាសិក្សាវិជ្ជាជីវៈជាមួយនឹងនិយោជក ឬសិប្បករណាម្នាក់ ដែលបានចុះកិច្ចសន្យានឹងគ្នាថា និយោជកត្រូវបង្រៀនវិជ្ជាជីវៈខ្លួន ហើយកូនជាងត្រូវធ្វើការឱ្យនិយោជកតែតាមលក្ខខណ្ឌ និងក្នុងរយៈពេលនៃកិច្ចសន្យា ។

**ប្រការ២.-** ការហ្វឹកហ្វឺនកូនជាង តំរូវឱ្យមានកិច្ចសន្យាជាលាយលក្ខណ៍អក្សរច្បាស់លាស់ ដែលមានឈ្មោះថា " កិច្ចសន្យាស្តីពីការហ្វឹកហ្វឺនកូនជាង" ។ កិច្ចសន្យានេះមានថិរវេលាមិនលើសពី ២ ឆ្នាំឡើយ ។

ការហ្វឹកហ្វឺនកូនជាង គឺការអប់រំវិជ្ជាជីវៈជាមួយនឹងនិយោជក ឱ្យបានពេញលេញ និងតាមរបៀបបច្ចេកទេស ដល់បុគ្គលិកដែលបានចុះកិច្ចសន្យាថា នឹងជួយធ្វើការក្នុងឋានៈជាកូនជាង ។

**ប្រការ៣.-** សហគ្រាស គ្រឹះស្ថាន រោងចក្រទាំងឡាយ ដែលមានប្រើប្រាស់កម្មករនិយោជិតច្រើនជាង ៦០ (ហុកសិប) នាក់ ត្រូវមានកូនជាងតាមការកំណត់ខាងក្រោម :-

ក- ១០% ( ដប់ភាគរយ ) ចំពោះសហគ្រាស ដែលមានកម្មករនិយោជិតចាប់ពី ៦១ នាក់ ដល់ ២០០ នាក់

ខ- ៨% ( ប្រាំបីភាគរយ ) ចំពោះសហគ្រាស ដែលមានកម្មករនិយោជិតចាប់ពី ២០១ នាក់ ដល់ ៥០០ នាក់

គ- បន្ថែម៤% ( បួនភាគរយ ) រាល់ពេលដែលមានចំនួនកម្មករនិយោជិត ៥០០ នាក់បន្ថែមទៀត ចំពោះសហគ្រាស ដែលមានកម្មករនិយោជិត ចាប់ពី ៥០១ នាក់ ឡើងទៅ

ឃ- ចំនួនអតិបរមានៃកូនជាង ត្រូវធ្វើការហ្វឹកហ្វឺនកំណត់ត្រឹម ១១០(មួយរយដប់)នាក់ក្នុង ១ឆ្នាំ ទោះជាសហគ្រាស គ្រឹះស្ថាន រោងចក្រនោះមានកម្មករនិយោជិតចំនួនច្រើនយ៉ាងណាក៏ដោយ ។

**ប្រការ៤.-** នៅទីបញ្ចប់នៃការហ្វឹកហ្វឺន កូនជាងត្រូវឆ្លងកាត់ការប្រឡងបញ្ជាក់សមត្ថភាព ដើម្បីឈានទៅទទួលបាននូវវិញ្ញាបនប័ត្រ ដោយមានការបញ្ជាក់ពីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល-វិជ្ជាជីវៈ និងយុវនីតិសម្បទា ។

**ប្រការ៥.-** គ្រប់សហគ្រាស គ្រឹះស្ថាន រោងចក្រទាំងអស់ ត្រូវរៀបចំការហ្វឹកហ្វឺនកូនជាងយ៉ាងយូរបំផុត ៣ (បី) ខែ ក្រោយថ្ងៃដែលប្រកាសនេះបានចូលជាធរមាន ។ ចំពោះសហគ្រាស គ្រឹះស្ថានរោងចក្រ ដែលបើកថ្មី ត្រូវអនុវត្តការហ្វឹកហ្វឺនយ៉ាងយូរបំផុតនៅ៣ ( បី )ខែ ក្រោយថ្ងៃសហគ្រាស គ្រឹះស្ថាន រោងចក្រ ចាប់ផ្តើមដំណើរជាផ្លូវការ ។

**ប្រការ៦.-** ដើម្បីធានាគុណភាពនៃការហ្វឹកហ្វឺនកូនជាងសហគ្រាស គ្រឹះស្ថាន រោងចក្រទាំងអស់ ត្រូវរៀបចំចាត់តាំង :-

**ក.ការត្រួតពិនិត្យការហ្វឹកហ្វឺនៈ**

- ត្រូវឱ្យមានជាប្រចាំនូវការត្រួតពិនិត្យជារៀងរាល់ខែ ត្រីមាស ឆមាស និងការប្រលងបញ្ចប់វគ្គ ដោយមានរបាយការណ៍ជាលាយលក្ខណ៍អក្សរច្បាស់លាស់ ។ ការត្រួតពិនិត្យនេះត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នូវរាល់ការរីកចំរើន ការប្រែប្រួលរបស់កូនជាង ទាំងផ្នែកទ្រឹស្តី និងការប្រតិបត្តិផ្ទាល់ ។

- គណៈកម្មការត្រួតពិនិត្យ ត្រូវមានសមាសភាព :-

១-តំណាងរបស់សហគ្រាស

២-តំណាងកម្មករដែលមានមុខជំនាញ មុខរបរ និងការងារដូចគ្នា

៣-តំណាងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

**ខ-ការប្រលងបញ្ចប់វគ្គ:**

- ដើម្បីធានាគុណភាពកូនជាង និងអព្យាក្រឹត្យភាព នៅក្នុងពេលប្រលងបញ្ចប់វគ្គ សហគ្រាសត្រូវរៀបចំគណៈមេប្រយោគអព្យាក្រឹត្យមួយឱ្យទទួលខុសត្រូវ និងអនុវត្ត ។

- គណៈមេប្រយោគនេះត្រូវមានសមាសភាព :-

១-គ្រូបង្វឹក និងតំណាងម្ចាស់សហគ្រាស

២-តំណាងកម្មករ ដែលមានមុខជំនាញ មុខរបរ និងការងារដូចគ្នា

៣-តំណាងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាចូលរួម

**ប្រការ៧.-** គ្រប់សហគ្រាស ដែលមានការហ្វឹកហ្វឺនកូនជាង ត្រូវអនុវត្តតាមបទបញ្ជាផ្ទៃក្នុងស្តីពីការហ្វឹកហ្វឺនកូនជាង ដូចមានក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ ។

**ប្រការ៨.-** សហគ្រាស គ្រឹះស្ថាន រោងចក្រទាំងឡាយណា ដែលគ្មានលទ្ធភាព និងរៀបចំការហ្វឹកហ្វឺនកូនជាងបាននោះ ត្រូវធ្វើសំណើមកក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិ-សម្បទា ដើម្បីធ្វើការសុំបង់ពន្ធអាករហ្វឹកហ្វឺនកូនជាងជំនួសវិញ។ ពន្ធអាករត្រូវបង់តាមអត្រាកំណត់ចំនួន ១%(មួយភាគរយ) លើប្រាក់ឈ្នួលប្រចាំឆ្នាំ នៃចំនួនសរុបរបស់កម្មករនិយោជិតទាំងអស់របស់សហគ្រាសជារៀងរាល់ឆ្នាំ ។

ការបង់ពន្ធហ្វឹកហ្វឺនកូនជាង ត្រូវធ្វើឱ្យបានមុនថ្ងៃបំណាច់ត្រីមាសនីមួយៗជារៀងរាល់ឆ្នាំ ឬអាចបង់មុនជាសរុបប្រចាំឆ្នាំតែម្តងក៏បាន ។

ប្រាក់ពន្ធអាករហ្វឹកហ្វឺនកូនជាងនេះ ត្រូវបញ្ចូនទៅក្នុងបេឡាបណ្តុះបណ្តាលវិជ្ជាជីវៈរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងជូនដំណឹងទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងស្ថាប័នពាក់ពន្ធ័ ។ បេឡាបណ្តុះបណ្តាលវិជ្ជាជីវៈ និងត្រូវកំណត់ដោយប្រកាសដោយឡែក ។

**ប្រការ៩.-** ការមិនព្រមបង់ពន្ធអាករហ្វឹកហ្វឺនកូនជាងនេះ នឹងត្រូវទទួលការផាកពិន័យ ដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ១០.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

ឧបសម្ព័ន្ធនៃប្រកាសលេខៈ ០០៤ សកបយ.
ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០០០

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## បទបញ្ជាផ្ទៃក្នុង
## ស្តីពី
## ការហ្វឹកហ្វឺនកូនជាង

**ប្រការ១: កូនជាងមានសិទ្ធិ**

-ទទួលការហ្វឹកហ្វឺនមុខជំនាញការងារសមស្របតាមកិច្ចសន្យាស្តីពីការហ្វឹកហ្វឺនកូនជាង

-បញ្ចេញយោបល់ដើម្បីផលប្រយោជន៍រួម ។

**ប្រការ២: កូនជាងមានភារកិច្ច**

-ខិតខំយកចិត្តទុកដាក់ក្នុងការហ្វឹកហ្វឺន

-អនុវត្តតាមកាលវិភាគនៃការហ្វឹកហ្វឺន

-គោរព និងអនុវត្តតាមវិធានការផ្នែកអនាម័យ និងសុវត្ថិភាព ការបង្ការគ្រោះថ្នាក់ការងារ និងជម្ងឺវិជ្ជាជីវៈក្នុងសហគ្រាស ។

**ប្រការ៣: កាលវិភាគនៃការហ្វឹកហ្វឺន**

-ពីថ្ងៃ ចន្ទ័ រហូតដល់ថ្ងៃសុក្រ រៀងរាល់សប្តាហ៍

-ពេលព្រឹកពីម៉ោង ៨:០០ ដល់ម៉ោង ១១:០០ ស្មើ ៣ ម៉ោង

-ពេលល្ងាចពីម៉ោង ១៤:០០ ដល់ម៉ោង ១៧:០០ ស្មើ ៣ ម៉ោងសរុប ៦ ម៉ោងក្នុង១ ថ្ងៃ

-មួយសប្តាហ៍ត្រូវហ្វឹកហ្វឺន ៣០ ម៉ោង ។

**ប្រការ៤: វិន័យ និងចរិយាធម៌របស់កូនជាង**

-ត្រូវគោរពពេលម៉ោងហ្វឹកហ្វឺនអោយបានទៀងទាត់តាមការកំណត់

-ត្រូវស្លៀកពាក់សមរម្យនៅក្នុងទីតាំងហ្វឹកហាត់

-ហាមយកអាវុធតាមខ្លួន ជក់បារី និងសេពគ្រឿងស្រវឹងនៅក្នុងពេលហ្វឹកហ្វឺន

-ត្រូវមានគំនិតមាយាទល្អ មានចរិតថ្លៃថ្នូរត្រឹមត្រូវ ចេះគោរពចាស់ទុំ ស្រឡាញ់រាប់អានមិត្តភក្តិ

-មិនត្រូវប្រព្រឹត្តិអំពើហឹង្សា បង្កអោយមានអសន្តិសុខផ្សេងៗ ដែលធ្វើអោយខូចសណ្តាប់ធ្នាប់ក្នុងទីកន្លែងហ្វឹកហ្វឺនឡើយ

-ត្រូវរក្សាសុជីវធម៌ល្អ មិនរំខានអ្នកដទៃក្នុងពេលហ្វឹកហ្វឺន ទោះតាមរូបភាពណាក៏ដោយ ។

**ប្រការ៥:** កូនជាងដែលប្រព្រឹត្តិខុសឆ្គង ឬមិនអនុវត្តតាមបទបញ្ជាផ្ទៃក្នុង ស្តីពីការហ្វឹកហ្វឺនកូនជាង ត្រូវទទួលការអប់រំ ឬអាចទទួលការអនុវត្តន៍វិន័យយោងទៅលើអំពើប្រព្រឹត្តិជាក់ស្តែង ។

ធ្វើនៅថ្ងៃទី .............. ខែ ............... ឆ្នាំ .............

ម្ចាស់ ឬនាយក ....................................

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខៈ ០៥២ សកបយ.

រាជធានីភ្នំពេញ . ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០០០

# ប្រកាស
# ស្តីពី
# ការរៀបចំបង្គន់អនាម័យ

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## <u>សំរេច</u>

**ប្រការ១.-** និយោជកនៃសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវរៀបចំឱ្យមាននៅក្នុងបរិវេណសហគ្រាស គ្រឹះស្ថានរបស់ខ្លួននូវបង្គន់សំរាប់ឱ្យកម្មករនិយោជិត បានប្រើប្រាស់ដោយសមរម្យ និងមានអនាម័យល្អ ។

**ប្រការ២.-** ចំនួនបង្គន់ត្រូវរៀបចំឱ្យមានសំរាប់ភេទប្រុស និងស្រី ដាច់ផ្សេងពីគ្នាទៅតាមចំនួនកម្មករនិយោជិត ដូចតារាងខាងក្រោមនេះ:-

| ចំនួនកម្មករនិយោជិត (ប្រុស ឬ ស្រី) | ចំនួនបង្គន់ |
| --- | --- |
| ១ នាក់ - ១៥ នាក់ | ១ |
| ១៦ នាក់ - ៣៥ នាក់ | ២ |
| ៣៦ នាក់ - ៥៥ នាក់ | ៣ |
| ៥៦ នាក់ - ៨០ នាក់ | ៤ |
| ៨១ នាក់ - ១១០ នាក់ | ៥ |
| ១១១ នាក់ - ១៥០ នាក់ | ៦ |
| ១៥១ នាក់ - ១000 នាក់ | ថែម ១ សំរាប់ ៥០ នាក់ |
| លើសពី ១.000 នាក់ | ថែម ១ សំរាប់៧០ នាក់ |

**ប្រការ៣.-** ការសាងសង់ត្រូវធ្វើអោយបានដូចខាងក្រោម:-

- កំរាលក្រោម និងជញ្ជាំងមិនជ្រាបទឹក
- ទ្វារជិត និងមានគន្លឹះសំរាប់ខ្ទាស់ពីក្នុង
- ជញ្ជាំងត្រូវលាបពណ៌ភ្លឺ
- មានពន្លឺល្អ
- មានតាក តភ្ជាប់ពីកន្លែងធ្វើការទៅបង្គន់ ដើម្បីការពារទឹកភ្លៀង ។ ក្នុងករណីមិនអាចធ្វើតាមបាន និយោជកត្រូវផ្តល់មធ្យោបាយផ្សេងទៀត ដើម្បីការពារទឹកភ្លៀង ។

**ប្រការ៤.-** ត្រូវរៀបចំយ៉ាងណាឱ្យទឹកដែលបង្ហូរចេញពីបង្គន់ ស្របតាមក្បួនអនាម័យ ។

**ប្រការ៥.-** ចំពោះសហគ្រាស គ្រឹះស្ថាន ដែលមានប្រើកម្មករនិយោជិតជាស្ត្រីភេទពីមួយរយនាក់ឡើងទៅ ត្រូវធ្វើបង្គន់ខ្ពស់ ដែលអាចអង្គុយផ្ទាល់ពីលើបាន បន្ថែមមួយសំរាប់ស្ត្រីហាសិបនាក់ ។

**ប្រការ៦.-** ទឹកសំរាប់ប្រើប្រាស់នៅតាមបង្គន់ត្រូវឱ្យបានគ្រប់គ្រាន់ មានសភាពស្អាត និងថ្លា ។ សាប៊ូក៏ត្រូវមានគ្រប់គ្រាន់នៅតាមបង្គន់នីមួយៗ ។ បង្គន់ទាំងអស់ត្រូវបានទទួលការសំអាត ថែទាំ ដុសលាងយ៉ាងហោចបានម្តងក្នុងមួយថ្ងៃ ។

**ប្រការ៧.-** អ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោស ដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៨.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ: ០៥៣ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០០០

# ប្រកាស
# ស្តីពី
# កៅអីអង្គុយនៅប៉ុស្តិ៍ការងារ

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## សំរេច

**ប្រការ១.-** និយោជកនៃសហគ្រាស គ្រឹះស្ថានដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារ ត្រូវរៀបចំនៅតាមប៉ុស្តិ៍ការងារនីមួយៗ ឱ្យមានកៅអីដ៏សមរម្យសំរាប់ប្រើប្រាស់តាមបំណងកម្មករនិយោជិត កាលណាការងាររបស់គេត្រូវនឹងឥរិយាបទអង្គុយ ឬឥរិយាបទអង្គុយម្តងម្កាល ។

**ប្រការ២.-** ទោះក្នុងករណីណាក៏ដោយ និង ទោះបីការងារមិនតម្រូវឱ្យមានឥរិយាបទអង្គុយក៏ដោយ និយោជកក៏ត្រូវរៀបចំឱ្យមានកៅអីគ្រប់គ្រាន់នៅមិនឆ្ងាយពីប៉ុស្តិ៍ការងារ សំរាប់កម្មករនិយោជិតប្រើប្រាស់នៅពេលចាំបាច់ ។

**ប្រការ៣.-** បទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស គ្រឹះស្ថាន អាចមានការបញ្ជាក់ ឬកំណត់ពីការប្រើប្រាស់កៅអីអង្គុយ ។

**ប្រការ៤.-** អ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោស ដូចមានចែងក្នុងជំពូកទី ១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៥.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ: ០៥៤ សកបយ.

រាជធានីភ្នំពេញ . ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ២០០០

# ប្រកាស
## ស្តីពី
## ការផ្តល់ភេសជ្ជៈអនាម័យ

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## សំរេច

**ប្រការ១.-** និយោជកនៃសហគ្រាស គ្រឹះស្ថានដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារ ត្រូវផ្តល់ភេសជ្ជៈអនាម័យឱ្យបានគ្រប់គ្រាន់ដល់កម្មករនិយោជិតរបស់ខ្លួន ។

**ប្រការ២.-** ដើម្បីរក្សាឱ្យមានភាពអនាម័យ ភេសជ្ជៈអនាម័យនេះ ត្រូវដាក់ក្នុងធុងដែលមានគម្របបិទជិត និងមានចំពួយសំរាប់បង្ហូរពីខាងក្រោម ។

**ប្រការ៣.-** ទីតាំងដាក់ធុងភេសជ្ជៈអនាម័យ ត្រូវស្ថិតនៅជិតកន្លែងធ្វើការ ។ បទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស គ្រឹះស្ថាន អាចកំណត់ពីទីតាំងដាក់ធុងភេសជ្ជៈអនាម័យពីរបៀបផ្តល់ភេសជ្ជៈអនាម័យ ឬពីប្រការទាំងឡាយ ដែលរក្សាអនាម័យ និងរបៀបរៀបរយ ។

**ប្រការ៤.**- និយោជក ត្រូវរៀបចំឱ្យមានកែវទឹក ឬមធ្យោបាយណាផ្សេងទៀត ប្រកបដោយលក្ខណៈអនាម័យ សំរាប់កម្មករនិយោជិតប្រើប្រាស់ ។

**ប្រការ៥.**- ភេសជ្ជៈមានជាតិស្រវឹង ត្រូវហាមមិនឱ្យជនណាយកចូលការដ្ឋាន ឬផ្តល់ឱ្យកម្មករនិយោជិតក្នុងម៉ោងធ្វើការ ។

**ប្រការ៦.**- អ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោស ដូចមានចែងក្នុងជំពូកទី ១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៧.**- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ: ០៨១ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ២០០០

# ប្រកាស
# ស្តីពី
# ការដាក់លក្ខខណ្ឌការងារសំរាប់វិជ្ជាជីវៈដែលមិនទាន់មានអនុសញ្ញារួម

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

# សំ រេ ច

**ប្រការ១.-** នៅពេលមិនទាន់មានអនុសញ្ញារួមនៅក្នុងផ្នែកវិជ្ជាជីវៈណាមួយ ឬនៅក្នុងក្របខ័ណ្ឌភូមិសាស្ត្រណាមួយ ការដាក់ឱ្យអនុវត្តលក្ខខណ្ឌការងារមួយចំនួនសំរាប់វិជ្ជាជីវៈ ឬសំរាប់ក្របខ័ណ្ឌភូមិសាស្ត្រនោះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិ-សម្បទា ។

**ប្រការ២.-** ការកំណត់លក្ខខណ្ឌការងារសំរាប់ផ្នែកវិជ្ជាជីវៈ ឬក្របខណ្ឌ័ភូមិសាស្ត្រខាងលើ ត្រូវផ្អែកលើបទប្បញ្ញត្តិនៃអនុសញ្ញារួម ដែលអនុវត្តនៅក្នុងផ្នែកវិជ្ជាជីវៈ ឬក្របខណ្ឌ័ភូមិសាស្ត្រប្រហាក់ប្រហែលគ្នា ដែលមានលក្ខខណ្ឌសេដ្ឋកិច្ចស្រដៀងគ្នា ។

**ប្រការ៣.-** ក្នុងអំឡុងពេល ១៥ថ្ងៃយ៉ាងតិចបន្ទាប់ពីថ្ងៃផ្ញើសេចក្តីព្រាងប្រកាសជូនសមាជិកគណៈកម្មការប្រឹក្សាការងារមក ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នឹងធ្វើការកោះប្រជុំគណៈកម្មការប្រឹក្សាការងារ ដើម្បីពិនិត្យពិភាក្សាលើការសំរេចដាក់ឱ្យអនុវត្តលក្ខខណ្ឌការងារសំរាប់វិជ្ជាជីវៈណាមួយ ឬក្របខណ្ឌភូមិសាស្ត្រណាមួយនោះ ។

**ប្រការ៤.-** ក្រោយពេលពិគ្រោះពិភាក្សា ដោយឯកភាពយោបល់ជាមួយគណៈកម្មការប្រឹក្សាការងារ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចេញប្រកាសផ្សព្វផ្សាយឱ្យអនុវត្តលក្ខខណ្ឌការងារសំរាប់ផ្នែកវិជ្ជាជីវៈ ឬក្របខណ្ឌភូមិសាស្ត្រនោះ ។ លក្ខខណ្ឌការងារដែលបានកំណត់ខាងលើ ត្រូវមានប្រសិទ្ធិភាពអនុវត្តតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

**ប្រការ៥.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ: ២៦៨ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០០

# ប្រកាស
# ស្តីពី
# ការផ្តល់វិញ្ញាបនបត្រអនុវត្តច្បាប់ស្តីពីការងារ ចំពោះសហគ្រាស គ្រឹះស្ថាន

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## ស ំ រេ ច

**ប្រការ១.**- រៀងរាល់ដំណាច់ឆ្នាំនីមួយៗ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នឹងចេញប្រកាសសំរេចអំពីការផ្តល់វិញ្ញាបនបត្រអនុវត្តច្បាប់ស្តីពីការងារ ចំពោះសហគ្រាស គ្រឹះស្ថានទាំងឡាយ ដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារ ដែលសហគ្រាស គ្រឹះស្ថានទាំងនោះបានខិតខំអនុវត្តច្បាប់ស្តីពីការងារបានល្អប្រសើរ ។

**ប្រការ២.**- លក្ខណៈវិនិច្ឆ័យសំរាប់ការពិនិត្យ និងសំរេចផ្តល់វិញ្ញាបនបត្រនោះ មានដូចតទៅ:-

- ការអនុវត្តលក្ខខណ្ឌការងារបានត្រឹមត្រូវតាមការកំណត់ជាធរមានអំពីថិរវេលាធ្វើការ ប្រាក់ឈ្នួល ការឈប់សំរាក ។ល។ ឬបានល្អប្រសើរជាង ។

- ទំនាក់ទំនងវិជ្ជាជីវៈល្អ រវាងនិយោជក និង តំណាងកម្មករនិយោជិត និងការអនុវត្តសេរីភាពសហជីពបានល្អ
- ការអនុវត្តវិធានអនាម័យ និង សន្តិសុខការងារបានល្អ
- ការបំពេញបែបបទសហគ្រាសបានល្អត្រឹមត្រូវ ។

**ប្រការ៣.-** គណៈកម្មការមួយរបស់ក្រសួង ដែលមានអគ្គនាយកការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬតំណាងជាប្រធាន ត្រូវពិនិត្យលក្ខណៈវិនិច្ឆ័យទាំងនេះឱ្យបានហ្មត់ចត់ និងត្រឹមត្រូវ ដោយផ្អែកតាមរបាយការណ៍អធិការកិច្ចការងាររបស់នាយកដ្ឋានជំនាញ និងមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាល-វិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុងទាំងឡាយរបស់ក្រសួង ឬសំណើរបស់សហគ្រាស គ្រឹះស្ថាន ដើម្បីស្នើសុំសេចក្តីសំរេចរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិ-សម្បទា ។

**ប្រការ៤.-** ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នឹងចេញផ្សាយជាសាធារណៈនូវបញ្ជីរាយឈ្មោះសហគ្រាស គ្រឹះស្ថានដែលបានទទួលវិញ្ញាបនប័ត្រនេះ ។

**ប្រការ៥.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

p **អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខៈ ៣១៣ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០០០

# ប្រកាស
# ស្តីពី
# តួនាទី ភារកិច្ចរបស់ប្រតិភូបុគ្គលិក និង សហជីព

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## សំរេច

**ប្រការ១.-** ប្រតិភូបុគ្គលិក គឺជាតំណាងរបស់កម្មករនិយោជិតនៅក្នុងសហគ្រាស គ្រឹះស្ថាន ស្របទៅតាមជំពូកទី១១ ផ្នែកទី៣ នៃច្បាប់ស្តីពីការងារ ។

**ប្រការ២.-** សហជីព ជាអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត ស្របទៅតាមមាត្រា២៦៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៣.-** ប្រតិភូបុគ្គលិក មានបេសកកម្មដូចមានចែងក្នុងមាត្រា២៨៤ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៤.-** តំណាងសហជីព ក៏អាចផ្តល់ពត៌មាន និងសំណើបានដែរ ចំពោះនិយោជក អំពីបញ្ហាដូចមានចែងក្នុងប្រការ៣ ខាងលើ បើសិនជាបញ្ហានោះមានការទាក់ទងចំពោះសមាជិករបស់ខ្លួន ។

**ប្រការ៥.-** ប្រតិភូបុគ្គលិក ត្រូវបានគេពិគ្រោះពិភាក្សា និងត្រូវផ្តល់យោបល់ជាលាយលក្ខណ៍អក្សរដូចមានចែងក្នុងមាត្រា២៨៤ កថាខណ្ឌពីរចុងក្រោយ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៦.-** តំណាងសហជីព ត្រូវបានគេពិគ្រោះពិភាក្សា និងត្រូវផ្តល់យោបល់ជាលាយលក្ខណ៍អក្សរផងដែរទៅលើបញ្ហាដែលមានចែងក្នុងប្រការ៥ ខាងលើ ។

**ប្រការ៧.-** អ្នកដឹកនាំសហជីពសំខាន់ ០៣រូបនៅក្នុងសហគ្រាស គ្រឹះស្ថាន តាមធម្មតារួមមាន ប្រធាន អនុប្រធានទី១ និងលេខាធិការទី១ ដែលបានចុះបញ្ជិកានៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា ត្រូវទទួលបានការការពារពីការបញ្ឈប់ពីការងារដូចប្រតិភូបុគ្គលិកដែរ។

**ប្រការ៨.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខៈ ៣៣០ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ២០០០

# ប្រកាសរួម
## ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងក្រសួងសុខាភិបាល
## ស្តីពី
## ការរៀបចំគិលានដ្ឋានសហគ្រាស

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ/បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសុខាភិបាល ។

## ស ម្រេ ច

**ប្រការ១.-** និយោជកនៃសហគ្រាស គ្រឹះស្ថានដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ហើយដែលមានកម្មករនិយោជិតចាប់ពី ៥០ នាក់ឡើងទៅ ត្រូវរៀបចំឱ្យមានគិលានដ្ឋានអចិន្ត្រៃយ៍មួយនៅក្នុងសហគ្រាសរបស់ខ្លួន ។

គិលានដ្ឋានអចិន្ត្រៃយ៍នេះ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់នាយកដ្ឋានពេទ្យការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

គិលានដ្ឋានអចិន្ត្រៃយ៍នេះ ត្រូវបានកំណត់តាមលក្ខខណ្ឌនៃទីតាំង និងទំហំ ចំនួន និងគុណភាពបុគ្គលិកសុខាភិបាល ហើយនិងសំភារៈ បរិក្ខារពេទ្យ ព្រមទាំងឱសថ ។

**ប្រការ២.-** អំពីទីតាំង និងទំហំ

គិលានដ្ឋានត្រូវស្ថិតនៅជិតកន្លែងធ្វើការ មានភាពងាយស្រួលដល់អ្នកជំងឺចេញ-ចូល មានពន្លឺគ្រប់គ្រាន់ មានខ្យល់អាកាសល្អ នៅឆ្ងាយពីសម្លេងលាន់ឮខ្លាំង ឆ្ងាយពីទីតាំងដាក់កាកសំណល់ គ្មានធូលី គ្មានផ្សែង គ្មានក្លិន និងត្រូវមានទំហំសមស្របទៅតាមចំនួនកម្មករនិយោជិត ប៉ុន្តែយ៉ាងតូចបំផុតឱ្យមានផ្ទៃ ២០ ម៉ែត្រក្រឡា ។

**ប្រការ៣.-** អំពីចំនួន និងគុណភាពបុគ្គលិកសុខាភិបាល

ចំនួន និងគុណភាពនៃបុគ្គលិកសុខាភិបាល ត្រូវបានកំណត់ស្របតាមចំនួនកម្មករនិយោជិតនៃសហគ្រាស គ្រឹះស្ថាន ដូចមានក្នុងតារាងខាងក្រោមនេះ :-

| ចំនួនកម្មករនិយោជិត ក្នុងសហគ្រាស | ចំនួនគិលានុប្បដ្ឋាក ឬគិលានុប្បដ្ឋាយិកា | ចំនួនគ្រូពេទ្យ | វត្តមានអប្បបរមារបស់គ្រូពេទ្យ សំរាប់មួយថ្ងៃ៨ ម៉ោង |
|---|---|---|---|
| ៥០ - ៣០០ នាក់ | ១ នាក់ ប្រចាំការ | វេជ្ជបណ្ឌិត១ នាក់ ឬគ្រូពេទ្យមធ្យម១ នាក់ | ២ ម៉ោង |
| ៣០១ - ៦០០ នាក់ | ១ នាក់ ប្រចាំការ | វេជ្ជបណ្ឌិត១ នាក់ | ២ ម៉ោង |
| ៦០១ - ៩០០ នាក់ | ២ នាក់ ប្រចាំការ | វេជ្ជបណ្ឌិត១ នាក់ | ៣ ម៉ោង |
| ៩០១ - ១៤០០ នាក់ | ២ នាក់ ប្រចាំការ | វេជ្ជបណ្ឌិត១ នាក់ | ៤ ម៉ោង |
| ១៤០១ - ២០០០ នាក់ | ២ នាក់ ប្រចាំការ | វេជ្ជបណ្ឌិត១ នាក់ | ៦ ម៉ោង |
| លើសពី ២០០០ នាក់ | ៣ នាក់ ប្រចាំការ | វេជ្ជបណ្ឌិត១ នាក់ | ៨ ម៉ោង |

កាលណាសហគ្រាស គ្រឹះស្ថាន មានធ្វើការបន្ថែមម៉ោង បុគ្គលិកនៃគិលានដ្ឋាន ត្រូវមានគិលានុប្បដ្ឋាយិកា និងគ្រូពេទ្យប្រចាំការក្នុងរយៈពេលធ្វើការបន្ថែមម៉ោងនេះ ។

**ប្រការ៤.-** អំពីសំភារៈ បរិក្ខារ និងឱសថ

សំភារៈជាគ្រឿងសង្ហារឹមត្រូវមានជាអប្បបរមាគឺ :-

- តុធ្វើការមួយ
- កៅអីអង្គុយមានបង្អែកបី

-ទូសំរាប់ទុកដាក់ឯកសារមួយ

- ទូសំរាប់ដាក់តាំងឱសថមួយ

- គ្រែពីរមានពូក និងកំរាល

- បរិធានសំរាប់រំងាប់មេរោគមួយ (STERILISATEUR )

បរិក្ខារពេទ្យ និងឱសថ ត្រូវមានជាចាំបាច់ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ៥.-** ចំពោះសហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតលើសពី ២០០នាក់ ត្រូវរៀបចំឱ្យមានគ្រែសំរាប់អោយអ្នករបួស និងអ្នកជំងឺសំរាក នៅជិតគិលានដ្ឋានទៅតាមអត្រាពីរភាគរយនៃចំនួនកម្មករនិយោជិតក្នុងសហគ្រាស គ្រឹះស្ថានរហូតដល់ចំនួន ២០គ្រែ ជាអតិបរមា ។

**ប្រការ៦.-** កាលណាសហគ្រាស គ្រឹះស្ថាន មានសាខា ឬការដ្ឋានមួយ ឬច្រើនដែលមានកម្មករនិយោជិតចាប់ពី ៥០នាក់ឡើងទៅ ហើយដែលស្ថិតនៅចំងាយលើសពី ប្រាំគីឡូម៉ែត្រពីការដ្ឋានធំ និយោជកត្រូវតែផ្តល់ចំពោះសាខា ឬការដ្ឋានទាំងនោះ ឱ្យដូចជាចំពោះការដ្ឋានធំដែរ នូវមធ្យោបាយសង្គ្រោះនិងព្យាបាលកម្មករនិយោជិតខ្លួនឱ្យបានសព្វគ្រប់ដូចជា បុគ្គលិកពេទ្យ សំណង់ សំភារៈ វត្ថុរុំរបួសនិងឱសថព្យាបាល ។

**ប្រការ៧.-** ចំពោះសហគ្រាស គ្រឹះស្ថាន ដែលមានកម្មករនិយោជិតមិនដល់ ៥០នាក់ ត្រូវមានមធ្យោបាយសង្គ្រោះដូចខាងក្រោមនេះ :-

- កម្មករនិយោជិតក្រោម២០នាក់ ត្រូវមានប្រអប់សង្គ្រោះមួយ និងអ្នកជំនួយសង្គ្រោះម្នាក់ ។
- កម្មករនិយោជិតពី២០ នាក់ដល់ ៤៩នាក់ ត្រូវមានបន្ទប់រុំរបួសមួយ និងគិលានុប្បដ្ឋាក ឬគិលានុប្បដ្ឋាយិកាម្នាក់ ។ p

គ្រឿងសង្ហារិម បរិក្ខារពេទ្យ និងឱសថ ដែលមានជាចាំបាច់ ដូចមានកំណត់ក្នុងតារាងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ៨.-** អ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោសដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៩.-** ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| **ក្រសួងសុខាភិបាល** | **ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា** |
| **ហត្ថលេខា និង ត្រា** | **ហត្ថលេខា និង ត្រា** |
| **វេជ្ជ. ហុង ស៊ុនហួត** | **អ៊ិត សំហេង** |

តារាងឧបសម្ព័ន្ធ នៃប្រកាសរួមលេខ ៣៣០ សកបយ.

ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ២០០០

**១-ប្រអប់សង្គ្រោះ :**

| | | | |
|---|---|---|---|
| -កន្ត្រៃអ៊ីណុក ១ | -បង់ស្អិតរមូរ ១ | -កំប្រេស ១០ | -Alcool Iodé 200ml |
| -ដង្កៀបអ៊ីណុក ២ | -បង់ស្បៃរមូរ ៥ | -សំឡីជក់ទឹក ១០០ក្រ. | - Eau Oxygéné200ml |
| -ស្រោមដៃ ២០ | -បង់យឺតរមូរ ៥ | -ប្រេងខ្យល់ ១ដប | -Ether 50ml |
| -សាប៊ូដុំ ១ | -ក្រណាត់សបីជ្រុង៤ | -ប្រេងកូឡា ១ ដប | -Analgésiques<br>- Anti-diarrhéiques |

**២-បន្ទប់រំរបួស :**

| គ្រឿងសង្ហារឹម | បរិក្ខារពេទ្យ | ឱសថ |
|---|---|---|
| -គ្រែមានពូក និងកំរាល ១ | -Trousse pour petite chirurgie | -Antihémorragique |
| -តុធ្វើការ ១ | -Tensiomètre + stétoscope | -Analgésiques |
| -កៅអីអង្គុយមានបង្អែក ៣ | -Eau Oxygénée-Alcool Iodé | -Antispasmodiques |
| -ទូរដាក់សំភារះបរិក្ខារ និងឱសថមួយ | -Ether | -Anti-infectieuses |

**៣-គិលានដ្ឋាន :**

<u>**បរិក្ខារពេទ្យ**</u> p

-Trousse pour petite chirurgie
-Tensiomètre + Stétoscope bi-auriculaire
-Chronomètre à secondes
-Marteau à réflexes
-Abaisse-langue
-Otoscope
-Spéculum nasal
-Thermomètre médical
-Thermomètre d'ambiance
-Vaccinostyles
-Nécessaires pour petits pansements
-Seringues en plastiques (divers numéros )
-Gants

**ឱសថ :**

1- Les Anti-infecteuses :
   A. Anti-bactériennes
   B. Antifugiques
   C. Antihelminthiques
2- Les Analgésiques
3- Les Anti-inflammatoires non stéroïdes (AINS)
4- Les Anesthésiques locaux
5- Les Antihistaminiques
6- Les Corticoïdes
7- Les Anti-asthmatiques
8- Les Antitussifs
9- Les Anti-migraineux
10- Les Anti-diarrhéiques
11- Les Diurétiques
12- Les Vitamines
13- Les Sels minéraux
14- Les Médicaments utilisés en cardio-angiologie :
   A. Tonicardiaque
   B. Anti-hypertenseur
15- Les Médicaments utilisés en gastro-entérologie
16- Les Anti-anémiques
17- Les Antihémorragiques
18- Les Antiseptiques externes, Cicatrisants percutanés
19- Les Coollyres
20- Les Sérums

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ: ៥៦ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០០១

# ប្រកាសរួម
# ស្តីពី
# អាករបណ្ណការងារ និងសៀវភៅការងារ

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។
-បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-បានឃើញប្រកាសរួមលេខ ៣០២ សកអ/៩៧ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៧ របស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីអាករប័ណ្ណការងារ និងសៀវភៅការងារ
-បានឃើញការចាំបាច់របស់ក្រសួង

## **សំរេច**

**ប្រការ១.-** កំណត់អាករប័ណ្ណការងារ និងសៀវភៅការងារ ដូចខាងក្រោម :-

១-អាករសៀវភៅការងារកម្មករនិយោជិតខ្មែរ :

-អាករសៀវភៅការងារកម្មករនិយោជិតខ្មែរម្នាក់ៗ ត្រូវបានកំណត់ ១.៥០០ រៀល (មួយពាន់ប្រាំរយរៀលគត់) ។ អាករនេះត្រូវបានកំណត់អោយបង់តែម្តងគត់ ។

២-អាករប្រចាំឆ្នាំនៃប័ណ្ណការងារ និងសៀវភៅការងារជនបរទេស ៖

ក-អាករប្រចាំឆ្នាំប្រតិទិននៃសៀវភៅការងារ និងប័ណ្ណការងារជនបរទេសម្នាក់ៗដែលចូលមកស្នាក់នៅ ឬប្រកបមុខរបរអ្វីមួយ ឬធ្វើការអ្វីមួយយកប្រាក់ឈ្នួលមានរយៈពេលកំណត់ត្រូវបានកំណត់ចំនួន ១០០ដុល្លារអាមេរិក (មួយរយដុល្លារអាមេរិក) ។

ខ-អាករប្រចាំឆ្នាំប្រតិទិននៃសៀវភៅការងារ និងប័ណ្ណការងារជនបរទេសម្នាក់ៗ ដែលរស់នៅអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ចាប់ពីអាយុ ១៨ឆ្នាំឡើងទៅ ត្រូវបានកំណត់ចំនួន ៥០ដុល្លារអាមេរិក (ហាសិបដុល្លារអាមេរិក) ។

**ប្រការ២.-** សាមីជនបរទេស ត្រូវបង់អាករនេះឱ្យបានមុនដំណាច់ខែមីនា ជារៀងរាល់ឆ្នាំ ចូលថវិកាជាតិដោយត្រូវមានចេញបង្កាន់ដៃទៅតាមហិរញ្ញវត្ថុជូនដល់អ្នកបង់ ។

នៅរាជធានីភ្នំពេញរដ្ឋទេយ្យករចំណូលនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវយកចំណូលនេះទៅបង់ជូនរតនាគារជាតិ ។

ចំពោះនៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត-ក្រុងនានា ចំណូលនេះ ត្រូវយកទៅបង់ជូនរតនាគារខេត្ត-ក្រុងរៀងៗខ្លួន ។

**ប្រការ៣.-** នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត-ក្រុង នៃក្រសួងសង្គមសង្គមកិច្ច ការងារ បណ្តុះ-បណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋានថវិកានីយកម្ម និងហិរញ្ញកិច្ចនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសរួមនេះ តាមភារកិច្ចរៀងៗខ្លួន ។ p

**ប្រការ៤.-** ជនដែលបានបាត់បង់អាករទៅតាមការកំណត់ខាងលើនេះ ត្រូវផ្តន្ទាទោសទៅតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៥.-** ប្រកាសរួមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ៣០២ សកអ/៩៧ ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ១៩៩៧ ស្តីពីអាករប័ណ្ណការងារ និងសៀវភៅការងារ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦.-** ប្រកាសនេះមានសុពលភាពចាប់ពីថ្ងៃដែលបានចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **ទេសរដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា** |
| **ហត្ថលេខា និង ត្រា** | **ហត្ថលេខា និង ត្រា** |
| **គាត ឈុន** | **អ៊ិត សំហេង** |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ: ១២៤ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០១

# ប្រកាស
# ស្តីពី
# ការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្ម

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## <u>ស ម្រេ ច</u>

**ប្រការ១.-** និយោជកនៃសហគ្រាស គ្រឹះស្ថាន ដូចមានចែងនៅក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវយកចិត្តទុកដាក់រិះរកមធ្យោបាយចាំបាច់ ដើម្បីចៀសវាងកុំឱ្យការលើកដាក់ទម្ងន់មានគ្រោះថ្នាក់ដល់សុខភាពកម្មករនិយោជិត ពិសេសកុំឱ្យមានការប៉ះពាល់ដល់ឆ្អឹងខ្នង ។

ក្នុងករណីដែលការលើកដាក់ទម្ងន់ ដោយកំលាំងពលកម្មផ្ទាល់មិនអាចចៀសវាងបានទេ ត្រូវធ្វើយ៉ាងណា កុំឱ្យការងារទាំងនោះបង្កគ្រោះថ្នាក់ដល់សុខភាពកម្មករនិយោជិត ។ ការលើកដាក់ទម្ងន់ សំរាប់កម្មករនិយោជិតម្នាក់ ឬច្រើននាក់ ជាអាទិ៍ :-

- ការលើក
- ការដឹកនាំ

- ការដាក់ចុះ

- ការរុញ

- ការអូសទាញ

- ការរំកិលវត្ថុដែលមានទម្ងន់ដោយបញ្ចេញកម្លាំងពលកម្មផ្ទាល់ ។

**ប្រការ២.‐** ដើម្បីជាវិធានការល្អក្នុងការលើកដាក់ទម្ងន់ដោយកំលាំងពលកម្មផ្ទាល់នេះ និយោជកត្រូវ :-

- រៀបចំកញ្ចប់ទម្ងន់នីមួយៗកុំឱ្យវែងទទឹង និងមិនលើសពី ៥០គីឡូក្រាម
- រៀបចំផ្លូវឆ្លងកាត់ឱ្យបានជិតបំផុត និងមិនឱ្យយាប់ធ្វើដំណើរ
- រៀបចំកម្មករនិយោជិត ដែលចូលរួមធ្វើការលើកដាក់ទម្ងន់ដោយមិនបង្ខិតបង្ខំ
- រិះរកមធ្យោបាយបច្ចេកទេសជំនួយក្នុងការលើកដាក់ទម្ងន់
- ផ្ដល់ដល់កម្មករនិយោជិតនូវការអប់រំពីបច្ចេកទេសលើកដាក់ទម្ងន់ ។

**ប្រការ៣.‐** ស្ត្រីមានផ្ទៃពោះ ឬស្ត្រីទើបចូលធ្វើការឡើងវិញបន្ទាប់ពីសំរាលកូន ឬរលូតកូន ឬរំលូតកូនក្នុងរយៈពេល ២ខែដំបូង មិនអនុញ្ញាតឱ្យលើកទម្ងន់លើសពី ៥គីឡូក្រាម ។

**ប្រការ៤.‐** កម្មករនិយោជិតម្នាក់មិនអនុញ្ញាតឱ្យ លើក ដាក់ អូស ទាញ រុញ ឬរំកិលទម្ងន់ ដោយកម្លាំងពលកម្មផ្ទាល់ ដែលមានចំនួនលើសពីទម្ងន់ ដែលមានបង្ហាញក្នុងតារាងខាងក្រោមនេះ :-

| **សណ្ឋាននៃទម្ងន់** | **បុរស** | | **ស្ត្រី** | |
|---|---|---|---|---|
| | **ចាប់ពី១៥ ឆ្នាំ** | **ចាប់ពី១៨ ឆ្នាំ** p | **ចាប់ពី១៥ ឆ្នាំ** | **ចាប់ពី១៨ ឆ្នាំ** |
| លើកដាក់ទម្ងន់ផ្ទាល់ | ១២ គីឡូក្រាម | ៥០ គីឡូក្រាម | ០៦ គីឡូក្រាម | ២៥ គីឡូក្រាម |
| រទេះរុញកង់១ ផ្លូវក្នុងការដ្ឋាន | ៣២ គីឡូក្រាម | ៨០ គីឡូក្រាម | ហាម | ៤០ គីឡូក្រាម |
| រទេះរុញកង់៣ ឬ ៤ ផ្លូវក្នុងការដ្ឋាន | ៤៨ គីឡូក្រាម | ១២០ គីឡូក្រាម | ២៤ គីឡូក្រាម | ៦០ គីឡូក្រាម |

**ប្រការ៥.‐** បទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស គ្រឹះស្ថាន អាចបញ្ជាក់ពីសេចក្ដីច្បាស់លាស់នៃការរៀបចំការងារលើកដាក់ទម្ងន់ ។ ក៏ប៉ុន្តែសេចក្ដីបញ្ជាក់នៃបទបញ្ជាផ្ទៃក្នុងនេះ មិនអាចផ្ទុយពីប្រការទាំងឡាយនៃប្រកាសនេះឡើយ ។

**ប្រការ៦.**- ការមិនអនុវត្តតាមបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោស ដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៧.**- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខៈ ១២៥ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០១

# ប្រកាស
## ស្តីពី
## ការបញ្ចេញបញ្ចូលខ្យល់ និង ការសំអាតបរិយាកាសក្នុងទីកន្លែងធ្វើការ

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## សំរេច

**ប្រការ១.-** និយោជកនៃសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវរៀបចំយ៉ាងណាឱ្យទីកន្លែងធ្វើការមានបរិយាកាសស្អាតល្អ ដើម្បីរក្សាសុវត្ថិភាព និងសុខភាពកម្មករនិយោជិត ។ បរិយាកាសនេះ ត្រូវគ្មានភាពក្រខ្វក់ គ្មានក្លិន ដែលនាំឱ្យមានគ្រោះថ្នាក់ ឬនាំឱ្យខានដល់ការងារដូចជា ចំហាយ ឧស្មន័ ធូលី ជាដើម ។

**ប្រការ២.-** - ការបញ្ចេញបញ្ចូលខ្យល់ក្នុងទីកន្លែងធ្វើការ ដែលគ្មានបរិយាកាសក្រខ្វក់ ត្រូវធ្វើដោយការបក់បញ្ចូលខ្យល់តាមធម្មជាតិ ឬដោយសិប្បនិម្មិត ។

- ការបក់បញ្ចូលខ្យល់តាមធម្មជាតិអាចធានាបាន ដោយការធ្វើទ្វារ បង្អួច ឬរន្ធខ្យល់ផ្សេងៗ ហើយផ្ទៃក្រឡានៃទ្វារ បង្អួច រន្ធខ្យល់ទាំងអស់សរុបគ្នា មិនត្រូវឱ្យទាបជាង មួយភាគបួននៃផ្ទៃក្រឡាអគារ ឬរោងជាងឡើយ ។

- ការបក់បញ្ចូលខ្យល់ដោយសិប្បនិម្មិត ដោយឧបករណ៍គ្រឿងយន្តដែលអាចស្រូបបញ្ចេញខ្យល់ចាស់ ។ ទ្វារ បង្អួច និងរន្ធខ្យល់ដទៃទៀត ត្រូវមានក្រឡាផ្ទៃសរុប មិនត្រូវឱ្យទាបជាង មួយភាគបួននៃផ្ទៃក្រឡាអគារ ឬរោងជាងឡើយ ។

**ប្រការ៣.-** ការប្រើប្រាស់វត្ថុធាតុមិនបង្កគ្រោះថ្នាក់ ឬការប្រើបច្ចេកទេស ដើម្បីលុបបំបាត់ការសាយភាយនៅក្នុងបរិយាកាសក្រោមរូបភាពជា ឧស្ម័ន ចំហាយ ឬធូលី ដែលបង្កគ្រោះថ្នាក់ គឺជាឯកសិទ្ធិនៃការផលិត ។ ក្នុងករណីដែលមិនអាចលុបបំបាត់វត្ថុធាតុមានគ្រោះថ្នាក់ក្នុងបរិយាកាស និយោជកត្រូវរកវិធីចាប់យកវត្ថុធាតុទាំងនោះជាបណ្តើរៗតាំងពីប្រភពដើមនៃការផលិត ហើយបញ្ចេញចោលមកក្រៅឱ្យស្របតាមច្បាប់ការពារបរិស្ថាន ។ អគារ ឬរោងជាងដែលមានបរិយាកាសបំពុលដោយវត្ថុធាតុមានគ្រោះថ្នាក់ ត្រូវខ័ណ្ឌដាច់ពីគេ ។

**ប្រការ៤.-** ប្រសិនបើវិធីសាស្ត្របច្ចេកទេស មិនអាចលុបបំបាត់វត្ថុធាតុមានគ្រោះថ្នាក់ក្នុងបរិយាកាសបានទេ និយោជកត្រូវផ្តល់នូវសំភារៈការពារបុគ្គលដ៏សមស្របដល់កម្មករនិយោជិតម្នាក់ៗ ដើម្បីការពារខ្លួន និងត្រូវធានាដោយយកចិត្តទុកដាក់ថា សំភារៈការពារបុគ្គលទាំងនោះ ត្រូវបានប្រើប្រាស់ និងថែរក្សាដោយត្រឹមត្រូវ ។

**ប្រការ៥.-** អ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោស ដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ៕

**ប្រការ៦.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខៈ ១៣៩ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០០១

# ប្រកាសរួម

## ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងក្រសួងសុខាភិបាល

## ស្តីពី

## លក្ខខណ្ឌ និង បេសកកម្មសេវាពេទ្យសហគ្រាស

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ p
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ/បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសុខាភិបាល ។

## សំរេច

**ប្រការ១.-** គ្រូពេទ្យដែលអាចធ្វើការនៅក្នុងគិលានដ្ឋានសហគ្រាសបាន លុះត្រាតែបានបំពេញនូវលក្ខខណ្ឌដូចខាងក្រោមនេះ :-

- មានសញ្ជាតិខ្មែរ
- មានសញ្ញាប័ត្រវេជ្ជសាស្ត្រ ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល
- បានទទួលការអប់រំបន្ថែមអំពីអនាម័យការងារ និងបច្ចេកទេសសន្តិសុខការងារ នៅនាយកដ្ឋានពេទ្យការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានចុះឈ្មោះនៅក្នុងបញ្ជីសមាជិកគណៈគ្រូពេទ្យ
- មិនដែលមានទោសពីបទព្រហ្មទណ្ឌណាមួយ
- មានសុខភាពគ្រប់គ្រាន់អាចបំពេញការងារនេះបាន
- មានលិខិតអនុញ្ញាតប្រកបមុខរបរជាគ្រូពេទ្យសហគ្រាស ដែលចេញឱ្យពីរឆ្នាំម្តងដោយនាយកដ្ឋានពេទ្យការងារ ។

**ប្រការ២.-** គ្រូពេទ្យសហគ្រាសមានសិទ្ធិ និងកាតព្វកិច្ចមួយចំនួនដូចតទៅ :-

- ត្រូវមានកិច្ចសន្យាការងារមួយឆ្នាំម្តង ហើយចម្លងជូនទៅនាយកដ្ឋានពេទ្យការងារ
- ប្រាក់ឈ្នួលតាមកិច្ចសន្យាពីសហគ្រាស និង មានសិទ្ធិទទួលនូវការឧបត្ថម្ភ និងសិទ្ធិផ្សេងៗដទៃទៀត ដូចកម្មករនិយោជិតក្នុងសហគ្រាស
- មានសិទ្ធិប្រកបមុខវិជ្ជាជីវៈតាមលក្ខខណ្ឌបច្ចេកទេសរបស់ខ្លួន
- មានតួនាទីជាទីប្រឹក្សាផ្នែកអនាម័យ និង សន្តិសុខការងាររបស់សហគ្រាស។ ប្រសិនបើការផ្តល់យោបល់ដ៏ត្រឹមត្រូវ មិនបានទទួលស្គាល់ពីសហគ្រាស ត្រូវរាយការណ៍ជាបន្ទាន់ទៅអធិការពេទ្យការងារ ឬអធិការការងារ
- ត្រូវចេះរក្សាអាថ៌កំបាំងវិជ្ជាជីវៈពេទ្យ និង អាថ៌កំបាំងបច្ចេកទេស បែបផែនផលិតរបស់សហគ្រាស
- ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងសីលធម៌វិជ្ជាជីវៈនៃនាយកដ្ឋានពេទ្យការងារ ។

**ប្រការ៣.-** បេសកកម្មនៃគ្រូពេទ្យសហគ្រាសមានដូចតទៅ :-

១-ធ្វើការងារបង្កាសុខភាពកម្មករនិយោជិតឱ្យគេចផុតពីគ្រោះថ្នាក់ការងារ និងជម្ងឺវិជ្ជាជីវៈជាការងារចំបងរបស់គ្រូពេទ្យសហគ្រាស រួមមានជាអាទិ៍ :

- ពិនិត្យទីកន្លែងធ្វើការឱ្យបានទៀងទាត់ និងជាកាលិក ដើម្បីសិក្សាអំពីលក្ខខណ្ឌការងារ ប៉ុស្តិ៍ការងារ បច្ចេកទេសផលិត អំពីសារធាតុនានាដែលមានប្រើក្នុងផលិតកម្ម និងអំពីស្ថានភាព សុវត្ថិភាពគ្រឿងចក្រនានា

- ឃ្លាំមើលស្ថានភាព សុខភាពកម្មករនិយោជិត ដោយផ្ដល់ពត៌មាន ឬឱ្យដំបូន្មានដល់កម្មករនិយោជិត អំពីយថាហេតុនៃការថមថយកាយសម្បទារបស់គេ ឬយថាហេតុនៃគ្រោះថ្នាក់ការងារ និងជម្ងឺវិជ្ជាជីវៈ

- ឃ្លាំមើលបរិស្ថានជុំវិញ និង ស្ថានភាពនៃអនាម័យទូទៅរបស់សហគ្រាស នៅការិយាល័យ រោងជាង អាហារដ្ឋាន វាសនដ្ឋាន ។ល។

- ផ្ដល់សេវាសង្គ្រោះបន្ទាន់ដល់កម្មករនិយោជិត ដែលទទួលរងគ្រោះថ្នាក់ការងារ

- ពិនិត្យព្យាបាលបឋមដល់កម្មករនិយោជិត ដែលមានជម្ងឺផ្សេងៗ ។

២-ធ្វើការងាររដ្ឋបាលមួយចំនួនដែលចាំបាច់ដូចជា :-

- ត្រូវរក្សាការសម្ងាត់រាល់ឯកសារស្ដីពីសុខភាពរបស់កម្មករនិយោជិត

- រៀបចំសាលាកប័ត្រពេទ្យសំរាប់ផ្ដល់ឱ្យកម្មករនិយោជិត នៅពេលដែលគេចាកចេញពីសហគ្រាស

- ត្រូវរក្សាទុកដាក់ឱ្យមានសណ្ដាប់ធ្នាប់ រាល់សៀវភៅបញ្ជីផ្សេងៗរបស់គិលានដ្ឋាន (បញ្ជីប្រចាំថ្ងៃ បញ្ជីកម្មករនិយោជិត ដែលធ្វើការជាប់ និងគ្រោះថ្នាក់ បញ្ជីចាក់ថ្នាំបង្ការ ។ល។)

- ធ្វើសេចក្ដីជូនដំណឹងអំពីគ្រោះថ្នាក់ការងារ និងជម្ងឺវិជ្ជាជីវៈ អំពីជម្ងឺឆ្លងជាដើម ទៅផ្នែក និងស្ថាប័នពាក់ពន្ធ័ ។

- ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ទៅនាយកដ្ឋានពេទ្យការងារ។

៣-ធ្វើការទំនាក់ទំនងចាំបាច់នៅក្នុង និងក្រៅសហគ្រាស :-

- នៅក្នុងសហគ្រាស ត្រូវធ្វើទំនាក់ទំនងជាមួយទីចាត់ការផ្នែកផែនការផលិតកម្ម ប្រតិភូបុគ្គលិក និងសហជីព គណៈកម្មការអនាម័យ និងសន្ដិសុខសហគ្រាស ។ល។

- នៅក្រៅសហគ្រាស ត្រូវធ្វើទំនាក់ទំនងជាមួយគ្រូពេទ្យព្យាបាល នៅតាមមន្ទីរពេទ្យ អធិការពេទ្យការងារ អធិការការងារ ឬមន្ទីរពិសោធន៍ផ្សេងៗ ។

**ប្រការ៤.-** និយោជក ឬតំណាងនិយោជកត្រូវទុកឱកាស និងផ្ដល់សិទ្ធិចាំបាច់ឱ្យគ្រូពេទ្យសហគ្រាសអនុវត្តភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ ។

**ប្រការ៥.-** ការបញ្ឈប់គ្រូពេទ្យសហគ្រាស មុនកិច្ចសន្យាការងារផុតកំណត់ ត្រូវមានការពិគ្រោះយោបល់ជាមុនជាមួយអធិការពេទ្យការងារ ។

**ប្រការ៦.-** គ្រូពេទ្យសហគ្រាស ដែលបានបំពេញការងារនៅក្នុងសហគ្រាសមុនប្រកាសនេះចេញ ត្រូវមកបំពេញលក្ខខណ្ឌដូចមានចែងនៅក្នុងប្រការ១ នៃប្រកាសនេះ ។

**ប្រការ៧.-** ការមិនអនុវត្តតាមបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោស ដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៨.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ២០០១

| | |
|---|---|
| **ទេសរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| **ក្រសួងសុខាភិបាល** | **ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា** |
| **ហត្ថលេខា និង ត្រា** | **ហត្ថលេខា និង ត្រា** |
| **ហុង ស៊ុនហួត** | **អ៊ិត សំហេង** |

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខៈ ១៦១ សកបយ.

រាជធានីភ្នំពេញ . ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០១

# ប្រកាស
# ស្តីពី
# ការប្រើប្រាស់ហត្ថពលកម្មបរទេស

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## សំ រេ ច

**ប្រការ១.-** ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងឡាយ ដូចមានចែងក្នុងមាត្រា១នៃច្បាប់ស្តីពីការងារ នៅពេលដែលត្រូវការជ្រើសរើសកម្មករនិយោជិត ត្រូវធ្វើការជ្រើសរើសជនជាតិខ្មែរជាអាទិភាព ។

ក្នុងករណីដែលមិនអាចរកបាននូវជនជាតិខ្មែរ ដើម្បីបំពេញតាមសេចក្តីត្រូវការចាំបាច់ណាមួយ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន អាចធ្វើការជ្រើសរើសហត្ថពលកម្មបរទេស ដែលជាឯកទេស អ្នកបច្ចេកទេស ឬអ្នកមានជំនាញវិជ្ជាជីវៈ សំរាប់ចូលបំរើការងារនៅកន្លែងដែលរកហត្ថពលកម្មខ្មែរមិនបាននោះ ដោយត្រូវធ្វើសំណើជាលាយលក្ខណ៍អក្សរស្នើសុំការអនុញ្ញាតជាមុន មកក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

សំណើស្តីពីសេចក្តីត្រូវការហត្ថពលកម្មបរទេសសំរាប់ឆ្នាំបន្ត ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ដាច់ពីគ្នានូវចំនួនកម្មករនិយោជិតខ្មែរ និងបរទេសដែលមានបច្ចុប្បន្ន និងមូលហេតុចំបងដែលនាំឱ្យ

មានសេចក្តីត្រូវការហត្ថពលកម្មបរទេសនោះ ហើយត្រូវផ្ញើមកក្រសួងសង្គមកិច្ច ការងារ បណ្តុះ-បណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ឱ្យបានមុនដំណាច់ខែវិច្ឆិកា នៃឆ្នាំនីមួយៗ។

**ប្រការ២.-** ផ្អែកតាមសំណើរបស់ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាននីមួយៗ ជាទូទៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងអនុញ្ញាតឱ្យប្រើប្រាស់ហត្ថពលកម្មបរទេស មិនលើសពី ១០ភាគរយ នៃចំនួនកម្មករនិយោជិតខ្មែរសរុបទេ ។

អត្រាកំណត់អតិបរមា ១០ភាគរយនេះ បែងចែកទៅតាមប្រភេទនៃកម្មករនិយោជិត ដូចខាងក្រោម :-

| | |
|---|---|
| - និយោជិតការិយាល័យ | ៣ ភាគរយ |
| - និយោជិត ឬកម្មករឯកទេស | ៦ ភាគរយ |
| - និយោជិត ឬកម្មករគ្មានឯកទេស | ១ ភាគរយ |

ក្នុងករណីដែលសេចក្តីត្រូវការប្រើប្រាស់ហត្ថពលកម្មបរទេសលើសពីអត្រា១០ភាគរយ សំណើសុំការអនុញ្ញាតិនេះ ត្រូវបញ្ជាក់ឱ្យបានលំអិត និងច្បាស់លាស់ អំពីមុខងារ មុខវិជ្ជាឯកទេស ឬមុខជំនាញវិជ្ជាជីវៈនៃជនបរទេសម្នាក់ៗ ដែលត្រូវធ្វើការជ្រើសរើសចូលបំរើការងារ និងមូលហេតុជាក់ស្តែងដែលនាំឱ្យមានសេចក្តីត្រូវការប្រើប្រាស់ហត្ថពលកម្មបរទេសម្នាក់ៗ ដែលលើសអាត្រា ១០ភាគរយនោះផង ។

**ប្រការ៣.-** ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ដែលមានប្រើប្រាស់ជនបរទេស ត្រូវធ្វើសេចក្តីប្រកាសជូនដំណឹងជាលាយលក្ខណ៍អក្សរ ស្តីពីកិច្ចសន្យាការងារជនបរទេសទាំងនោះមកនាយកដ្ឋានមុខរបរ និងហត្ថពលកម្មនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចំពោះអ្នកនៅរាជធានីភ្នំពេញ និងមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត-ក្រុងនីមួយៗ ចំពោះអ្នកនៅខេត្ត-ក្រុង ។

**ប្រការ៤.-** អ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ នឹងត្រូវពិន័យ ឬទទួលទោសដូចមានចែងនៅក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៥.-** ប្រកាសលេខ ១៨៥សកអ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៩៧ ស្តីពីការប្រើប្រាស់ហត្ថពលកម្មបរទេសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ: ២៣៧ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០១

# ប្រកាស
## ស្តីពី
## ការបង្កើតប៉ុស្តិ៍អធិការកិច្ចការងារនៅតាមខណ្ឌនានានៃរាជធានីភ្នំពេញ

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## សំរេច

**ប្រការ១.-** បង្កើតប៉ុស្តិ៍អធិការកិច្ចការងារនៅតាមខណ្ឌ នៃរាជធានីភ្នំពេញ ។

**ប្រការ២.-** ប្រធានប៉ុស្តិ៍អធិការកិច្ចការងារនីមួយៗ មានថ្នាក់ចាប់ពីអនុប្រធានការិយាល័យ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ឡើងទៅ ។

**ប្រការ៣.-** ប៉ុស្តិ៍អធិការកិច្ចការងារទាំងអស់ ស្ថិតក្រោមចំណុះនាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។ ទីតាំងធ្វើការរបស់ប៉ុស្តិ៍អធិការកិច្ចការងារ ស្ថិតនៅតាមការិយាល័យសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខណ្ឌ ។

ប្រការ៤.៉   ប៉ុស្តិ៍អធិការកិច្ចការងារ មានតួនាទីភារៈកិច្ចដូចតទៅ :

ក-ចុះត្រួតពិនិត្យការអនុវត្តច្បាប់ស្តីពីការងារ នៅតាមសហគ្រាស គ្រឹះស្ថាននានា ដែលស្ថិតនៅក្នុងដែនសីមានៃខណ្ឌរបស់ខ្លួន ពិសេសត្រូវចុះត្រួតពិនិត្យសហគ្រាស គ្រឹះស្ថានកាត់ដេរ និងដេរស្បែកជើងឱ្យបានយ៉ាងតិចម្តងក្នុងមួយខែ ចំពោះសហគ្រាស គ្រឹះស្ថាននីមួយៗ ។ ក្នុងករណីចាំបាច់ក្រសួងនឹងចាត់តាំងប្រមូលកំលាំងឱ្យប៉ុស្តិ៍អធិការកិច្ចការងារមួយទៅជួយការងារប៉ុស្តិ៍អធិការកិច្ចការងារមួយទៀត ។

ខ-ដោះស្រាយវិវាទការងារ ដែលកើតមានឡើងនៅតាមសហគ្រាស គ្រឹះស្ថានទាំងអស់ដែលស្ថិតនៅក្នុងដែនសីមានៃខណ្ឌរបស់ខ្លួន ។ រាល់វិវាទបុគ្គល ត្រូវតែសាកសួរពតិមានឱ្យបានរួចរាល់នៅតាមប៉ុស្តិ៍ រួចហើយសាកល្បងធ្វើការផ្សះផ្សា ។ បើយល់ឃើញថា មិនអាចធ្វើការផ្សះផ្សានៅតាមប៉ុស្តិ៍បានទេ ត្រូវរាយការណ៍ជូននាយកដ្ឋានអធិការកិច្ចការងារភ្លាម ។ ចំពោះវិវាទបុគ្គលស្តីពីការបញ្ឈប់ប្រតិភូបុគ្គលិក ការបញ្ឈប់ប្រតិភូសហជីព ការបញ្ឈប់អ្នកដឹកនាំសហជីព (ប្រធាន អនុ-ប្រធានទី១ និងលេខាធិការទី១) ឬក៏វិវាទ ដែលអាចបណ្តាលឱ្យកើតមានជាបាតុកម្ម ឬកូដកម្មនោះត្រូវសាកសួរពិតមានឱ្យបានរួចរាល់នៅតាមប៉ុស្តិ៍អធិការកិច្ចការងារ រួចហើយត្រូវរាយការណ៍ភ្លាមជូននាយកដ្ឋានអធិការកិច្ចការងារ ។

គ-គ្រប់គ្រងសភាពការណ៍នៅតាមសហគ្រាស គ្រឹះស្ថាន ទាំងអស់ដែលស្ថិតក្នុងដែនសីមា នៃខណ្ឌរបស់ខ្លួន ពិសេសអំពីវិវាទការងាររួម ដែលបំរុងនឹងកើតមានឡើងនៅតាមសហគ្រាស គ្រឹះស្ថានកាត់ដេរ និងដេរស្បែកជើង ដោយត្រូវចាត់វិធានការដោះស្រាយជាបន្ទាន់ ។ ករណីមិនអាចដោះស្រាយបាន ត្រូវរាយការណ៍ភ្លាមជូននាយកដ្ឋានអធិការកិច្ចការងារ ។ ជំរុញការអនុវត្តន៍សារាចររបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាលេខ ០២១ សកបយ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៩ ស្តីពីការចាត់តាំងបុគ្គលិកទំនាក់ទំនងនៅតាមរោងចក្រ សហគ្រាសកាត់ដេរ ។ ប៉ុស្តិ៍អធិការកិច្ចការងារ ត្រូវសហការឱ្យបានល្អជាមួយបុគ្គលិកទំនាក់ទំនងនេះ ដើម្បីពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ នៅតាមរោងចក្រ សហគ្រាសកាត់ដេរទាំងអស់ ។

ឃ-ប្រធានប៉ុស្តិ៍ ត្រូវរៀបចំកម្មវិធីចុះអធិការកិច្ចការងារ ប្រចាំសប្តាហ៍ឱ្យបានទៀងទាត់តាមតារាងគំរូរបស់នាយកដ្ឋានអធិការកិច្ចការងារ រួចហើយផ្ញើកម្មវិធីនេះ ០១ច្បាប់ ទៅនាយកដ្ឋានអធិការកិច្ចការងារនៅរៀងរាល់ថ្ងៃព្រហស្បតិ៍នៃសប្តាហ៍នីមួយៗ យ៉ាងយូរ ។

ង-ការចុះធ្វើអធិការកិច្ចការងារ ត្រូវពិនិត្យគ្រប់ចំណុចទាំងអស់ដែលមានចែងក្នុងច្បាប់ និងបទបញ្ជាស្តីពីការងារ ពិសេសអំពីបែបបទស្តីពីសហគ្រាស បទបញ្ជាផ្ទៃក្នុងការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក ការធ្វើការបន្ថែមម៉ោង ការផ្តល់ប្រាក់ឈ្នួល ការឈប់សំរាក ព្រមទាំងលក្ខខណ្ឌ

ការងារផ្សេងទៀត ការងារសហជីព ការប្រើប្រាស់កុមារ អនាម័យ និងសន្តិសុខការងារ ។ មាតិកានៃការធ្វើអធិការកិច្ចការងារ មានលំអិតក្នុងគំរូរបាយការណ៍ស្តីពីអធិការកិច្ចការងារ ដែលជាឧប្បសម្ព័ន្ធនៃប្រកាសនេះ ។

ច-បែបបទនៃការចុះធ្វើអធិការកិច្ចការងារ ត្រូវអនុវត្តតាមគោលការណ៍ដែលធ្លាប់អនុវត្តកន្លងទៅ ដោយលើកដំបូង ត្រូវធ្វើរបាយការណ៍អធិការកិច្ចការងារសាមញ្ញ ឬរបាយការណ៍អធិការកិច្ចការងារពិសេស ដែលមានបញ្ជាក់នូវការកត់សំគាល់ ការផ្តល់ដំបូន្មាន ឬការដាក់កំហិតទៅតាមស្ថានភាពជាក់ស្តែង និងការប្រព្រឹត្តិល្មើសនៃសហគ្រាស គ្រឹះស្ថាននីមួយៗ ។ ចំពោះការដាក់កំហិតក្រៅពីសរសេរនៅក្នុងរបាយការណ៍អធិការកិច្ចការងារសាមញ្ញ ឬរបាយការណ៍អធិការកិច្ចការងារពិសេស ឬកំណត់ហេតុអធិការកិច្ចការងារពិសេស ត្រូវសរសេរជាលិខិតដាក់កំហិតជូនទៅសហគ្រាសគ្រឹះស្ថានបន្ថែមទៀត ។ បន្ទាប់មក គឺការធ្វើកំណត់ហេតុអធិការកិច្ចការងារ ពិសេសនៅពេលចុះពិនិត្យលើកទី២ ឬលើកបន្តបន្ទាប់ ដើម្បីត្រួតពិនិត្យការដាក់កំហិត ។

ទាំងរបាយការណ៍អធិការកិច្ចការងារសាមញ្ញ ទាំងរបាយការណ៍ ឬកំណត់ហេតុអធិការកិច្ចការងារពិសេស និងលិខិតដាក់កំហិតត្រូវតែផ្ញើជូននាយកដ្ឋានអធិការកិច្ចការងារមួយមុខ ០១ច្បាប់ៗ រៀងរាល់ថ្ងៃច័ន្ទនៃសប្តាហ៍នីមួយៗ ឱ្យបានទៀងទាត់ ។

ឆ-ករណីត្រូវចាត់វិធានការផ្សេងៗដូចជា ការផាកពិន័យជាដើម ចំពោះសហគ្រាស គ្រឹះស្ថានដែលប្រព្រឹត្តល្មើសខ្លាំង ឬចចេសរឹងរូសមិនព្រមគោរពប្រតិបត្តិច្បាប់ និងបទបញ្ជាស្តីពីការងារនោះត្រូវតែរាយការណ៍មកនាយកដ្ឋានអធិការកិច្ចការងារដើម្បីពិនិត្យ និងចាត់ការបន្ត។ ចំពោះបទល្មើសរបស់សហគ្រាស គ្រឹះស្ថានដែលទាក់ទងនឹងសមត្ថកិច្ចរបស់នាយកដ្ឋានអធិការកិច្ចការងារ នាយកដ្ឋាននេះ ត្រូវធ្វើសំណើសុំសេចក្តីសំរេចពីថ្នាក់ដឹកនាំក្រសួងដែលទទួលបន្ទុកផ្នែកនេះ ដើម្បីចាត់វិធានការបន្ត ។ រីឯបទល្មើសរបស់សហគ្រាស គ្រឹះស្ថានដែលទាក់ទងនឹងសមត្ថកិច្ចនាយកដ្ឋានផ្សេងទៀត នាយកដ្ឋានអធិការកិច្ចការងារ ត្រូវរាយការណ៍ទៅអគ្គនាយកការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីចាត់វិធានការបន្ត។

ជ-យ៉ាងយូរបំផុតនៅរៀងរាល់ថ្ងៃច័ន្ទនៃសប្តាហ៍នីមួយៗ ប្រធានប៉ុស្តិ៍ត្រូវតែយករបាយការណ៍សរុបការងារប្រចាំសប្តាហ៍ ទៅជូននាយកដ្ឋានអធិការកិច្ចការងារ។

ឈ-ក្នុងករណីចាំបាច់ ដូចជាមានកូដកម្ម ឬវិវាទការងាររួមផ្សេងទៀត គប្បីសហការឱ្យបានល្អប្រសើរជាមួយអាជ្ញាធរដែនដី និងស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយបានទាន់ពេល និងបង្កើនប្រសិទ្ធិភាពក្នុងការអនុវត្តច្បាប់ស្តីពីការងារ។

៧-ប៉ុស្តិ៍អធិការកិច្ចការងារ ត្រូវអនុវត្តតាមការណែនាំ ឬការប្រគល់ភារៈកិច្ចផ្សេងៗទៀត ក្នុងករណីចាំបាច់ពីនាយកដ្ឋានអធិការកិច្ចការងារ ។

**ប្រការ៥.-** មន្ត្រីរាជការទាំងអស់នៃប៉ុស្តិ៍អធិការកិច្ចការងារ ត្រូវរក្សាអាថ៌កំបាំងវិជ្ជាជីវៈ និងត្រូវទុកជាជាអាថ៌កំបាំងដាច់ខាតនូវប្រភពនៃពាក្យប្តឹងទាំងអស់ ដែលដាក់ឱ្យខ្លួនពិនិត្យ ស្តីពីកំហុសណាមួយក្នុងវបនកណ្ឌ ឬអំពើល្មើសនឹងបញ្ញត្តិច្បាប់ ហើយចៀសវាងមិនប្រាប់និយោជក ឬតំណាងនៃជននោះថា ការត្រួតពិនិត្យធ្វើឡើងដោយមានពាក្យប្តឹងសោះឡើយ ។

**ប្រការ៦.-** មន្ត្រីរាជការទាំងអស់ នៃប៉ុស្តិ៍អធិការកិច្ចការងារ ត្រូវខិតខំអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

**ប្រការ៧.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា លេខ ២៩៣ សកបយ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៩៩ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៨.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**
**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**
**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ: ២៦៧ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០១

# ប្រកាស
# ស្តីពី
# ការឈប់សំរាកពិសេស

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## សំរេច

**ប្រការ១.**- និយោជកនៃសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារមានសិទ្ធិអនុញ្ញាតឱ្យកម្មករនិយោជិតខ្លួន បានឈប់សំរាកពិសេសដោយមានប្រាក់ឈ្នួល ដែលមានចិរវេលាមិនលើសពីប្រាំពីរថ្ងៃក្នុងមួយឆ្នាំ ក្នុងឱកាសដែលកម្មករនិយោជិតមានធុរៈផ្ទាល់ខ្លួនឬ ក្នុងឱកាសមានព្រឹត្តិការណ៍ប៉ះពាល់ផ្ទាល់ដល់គ្រួសារនៃកម្មករនិយោជិតនោះ ដូចជា :-

-ការរៀបអាពាហ៍ពិពាហ៍ផ្ទាល់ខ្លួន

-ប្រពន្ធសំរាលកូន

-រៀបអាពាហ៍ពិពាហ៍កូន

-ប្តី ប្រពន្ធ កូន ឪពុក ម្តាយ មានជម្ងឺ ឬទទួលមរណភាព។

**ប្រការ២.-** និយោជកអាចធ្វើការកាត់កងការឈប់សំរាកពិសេសនេះពីការឈប់សំរាកប្រចាំឆ្នាំរបស់កម្មករនិយោជិត បើកម្មករនិយោជិតនោះមិនទាន់អនុវត្តការឈប់សំរាកប្រចាំឆ្នាំទាំងអស់របស់ខ្លួនទេ ឬអាចតំរូវឱ្យកម្មករនិយោជិតធ្វើការសងវិញ បើកម្មករនិយោជិតនោះបានអនុវត្តការឈប់សំរាកប្រចាំឆ្នាំទាំងអស់របស់ខ្លួនហើយ ។

**ប្រការ៣.-** ការធ្វើការសងអាចអនុវត្តបានតែក្នុងរយៈពេល ៩០ថ្ងៃ ក្រោយថ្ងៃឈប់សំរាកពិសេស ។ ការធ្វើការសងត្រូវអនុវត្តក្នុងថ្ងៃធ្វើការធម្មតា និងក្នុងល័ក្ខខ័ណ្ឌដែលថិរវេលាធ្វើការសរុបមិនលើសពី១០ម៉ោងក្នុងមួយថ្ងៃ ឬលើសពី ៥៤ម៉ោង ក្នុងមួយសប្តាហ៍ ។

**ប្រការ៤.-** ការធ្វើការសង ត្រូវឱ្យឈ្នួលតាមអត្រាពេលម៉ោងធ្វើការធម្មតា ។

**ប្រការ៥.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ ៧៦ សកអ. ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ: ២៦៨ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០១

# ប្រកាស
# ស្តីពី
# សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

# ស ម្រេ ច

**ប្រការ១.-** នាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវប្រើ និងរក្សាទុកឱ្យបានត្រឹមត្រូវនូវសៀវភៅបញ្ជីប្រចាំគ្រឹះស្ថានមួយ ដែលអធិការការងារបានចុះលេខរៀង និងចុះហត្ថលេខាសង្ខេប ។ គំរូសៀវភៅបញ្ជីប្រចាំគ្រឹះស្ថានមានក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ២.-** និយោជក ឬអ្នកតំណាង ត្រូវជូនសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាននេះ ទៅអធិការការងារ ឬអភិបាលការងារត្រួតពិនិត្យ និងធ្វើការសង្កេតធ្វើការផ្តល់ដំបូន្មាន ឬធ្វើការដាក់កំហិតផ្សេងៗនៅរាល់ពេលចុះត្រួតពិនិត្យ ។

**ប្រការ៣.-** សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន ដែលបានប្រើប្រាស់គ្រប់ទំព័រទាំងអស់ហើយ និយោជកត្រូវថែរក្សាទុកអោយគង់វង្សក្នុងរយៈពេល ៣ឆ្នាំ ។ អធិការការងារ និងអភិបាលការងារ អាចទាររកសៀវភៅបញ្ជីប្រចាំគ្រឹះស្ថាននោះ នៅគ្រប់ពេលវេលា ។

**ប្រការ៤.-** អ្នកប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលការពិន័យ ឬផ្តន្ទាទោសតាមច្បាប់ដូចមានចែងនៅក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៥.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ៩២ សកអ.ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ១៩៩៧ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

ឧបសម្ព័ន្ធ ប្រកាសលេខ ២៦៨ សកបយ.
ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០០១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅបញ្ជីប្រចាំគ្រឹះស្ថាន

p

រាជធានីភ្នំពេញ . ថ្ងៃទី ខែ ឆ្នាំ២០០

ទំហំ ២០ សម X ៣០ សម

-ឈ្មោះគ្រឹះស្ថានៈ------------------------------------------------------------

-ផ្នែកនៃសកម្មភាពសេដ្ឋកិច្ចៈ----------------------------------------------

-អាសយដ្ឋានៈ----------------------------------------------------------------

-នាម និងគោត្តនាមនិយោជកៈ------------------------------------------------

p

-កាលបរិច្ឆេទនៃការចេញសៀវភៅបញ្ជីៈ---------------------------------------

បោះត្រា និងហត្ថលេខា
របស់អធិការការងារ

លេខទំព័រ:------

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខៈ ២៦៩ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០១

# ប្រកាស
## ស្តីពី
## ការបង្កើតសៀវភៅបើកប្រាក់

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## <u>សំរេច</u>

**ប្រការ១.-** នាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវកាន់ដោយទៀងទាត់ជាដរាប នូវសៀវភៅបើកប្រាក់មួយ ដូចគំរូក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ២.-** សៀវភៅបើកប្រាក់នេះ នឹងទុកជាត្រឹមត្រូវបាន លុះត្រាមានចុះលេខទំព័រ និងចុះហត្ថលេខាសង្ខេបគ្រប់ទំព័រដោយអធិការការងារ ។ និយោជកនៃសហគ្រាស គ្រឹះស្ថានណាចង់ធ្វើសៀវភៅបើកប្រាក់តាមរបៀបផ្សេងពីគំរូដូចមានចែងក្នុងប្រការ១ ខាងលើ ប៉ុន្តែមានចុះពត៌មាន និងបែបបទត្រួតពិនិត្យដូចគ្នានោះ ត្រូវធ្វើពាក្យសុំទៅនាយកដ្ឋានអធិការកិច្ចការងារ (ចំពោះសហគ្រាស គ្រឹះស្ថាននៅរាជធានីភ្នំពេញ) និងនៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត-ក្រុងបាន (ចំពោះសហគ្រាស គ្រឹះស្ថាននៅខេត្ត- ក្រុងផ្សេងទៀត) ។

**ប្រការ៣.-** សៀវភៅបើកប្រាក់នេះ ត្រូវទុកនៅក្នុងការិយាល័យបេឡា ឬទីចាត់ការនៃសហគ្រាស គ្រឹះស្ថាន ដើម្បីងាយស្រួលដល់ការត្រួតពិនិត្យ ។ កាលណាប្រើសៀវភៅនេះគ្រប់ទំព័រហើយ និយោជក ត្រូវមានកាតព្វកិច្ចរក្សាទុកឱ្យគង់វង្សក្នុងរយៈពេល ៣ ឆ្នាំ ។ អធិការការងារ ឬអភិបាលការងារ អាចទាររកសៀវភៅនេះ នៅគ្រប់ពេលវេលា ។

**ប្រការ៤.-** អ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលការពិន័យ ឬផ្តន្ទាទោសតាមច្បាប់ ដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៥.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ៩៣ សកអ. ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៩៧ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

ឧបសម្ព័ន្ធ ប្រកាសលេខ ២៦៩ សកបយ.
ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០០១

# សៀវភៅបើកប្រាក់

# LE LIVRE DE PAYE

**គ្រឹះស្ថាន:**------------------------------------------------------------------------

ETABLISSEMENT-------------------------------------------------------------

**ផ្នែកនៃសកម្មភាពសេដ្ឋកិច្ច:**----------------------------------

BRANCHE D'ACTIVE ECONOMIQUE--------------------------

**អាសយដ្ឋាន:**------------------------------------------------

ADDRESSE ------------------------------------------------

p

ទំហំ ២៥ សម X ៣៥ សម

# សៀវភៅបើកប្រាក់

# LE LIVRE DE PAYE

គ្រឹះស្ថានៈ------------------------------------------------------------

ETABLISSEMENT------------------------------------------------------------

ផ្នែកសកម្មភាពសេដ្ឋកិច្ចៈ------------------------------------------

BRANCHE D'ACTIVE ECONOMIQUE------------------------------

p

អាសយដ្ឋានៈ--------------------------------------------------------------

ADDRESSE ---------------------------------------------------

ប្រចាំខែ..................ឆ្នាំ................ ទំព័រ................................

| ល.រ N° | នាមត្រកូល និង នាមខ្លួននៃ កម្មករនិយោជិត Nom et prénom du salarié | សញ្ជាតិ Natio-nalité | ថ្ងៃខែឆ្នាំ ចូលបំរើ ការងារ | មុខងារកាន់ កាប់ក្នុង សហគ្រាស Fontion occupée dans l'entreprise | ស្ថានភាព គ្រួសារ Situation de famille | | ប្រាក់ថ្ងៃ ឬប្រាក់ខែ Salaire journalier ou mensuel | វិភាជន៍ គ្រួសារ Allcca-tions famili-ales | ប្រាក់ម៉ោង ធ្វើការ បន្ថែម Indemnité pour heures supplé-mentaire | ប្រាក់ជូស ការឱ្យដំ-ណឹងមុន ឬប្រាក់ទូ-ទាត់ការ ឈប់ Preavis ou delai congé | ប្រាក់ ឈប់សំ-រាកប្រចាំ ឆ្នាំ Congé annuel payé | ប្រាក់ រង្វាន់ ផ្សេងៗ Autres Indem-nité ou primes | ចំនួនទឹក ប្រាក់ទាំង អស់ដែល ត្រូវបាន Total des sommes à payer | ប្រាក់ហូតទុក Retenues | | | | | ចំនួន ប្រាក់ ដែល កាត់ ទាំង អស់ Tota-l des rete-nues | ចំនួន ប្រាក់ ដែល ត្រូវ បើក Mon-tant net à pay-er | ហត្ថ-លេខា Emarg-ement | សេចក្តី ផ្សេងៗ Obser-vations |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ប្រពន្ធ Fem-me | កូន En-fant | | | | | | | | ចំនួនប្រាក់ ខ្ចី Montant des avan-ces acco-rdées | កាត់ ប្រាក់ខ្ចី Déduc-tion des avances | ប្រាក់ បន្ថយ ថ្ងៃ ឈប់ Déduc-tion des journéess de congé | ពន្ធ និង វិភាជន៍ Taxe et contribution — សន្តិសុខ សង្គម Sécurité sociale | ពន្ធ និង វិភាជន៍ Taxe et contribution — ពន្ធលើ ប្រាក់បៀវត្ស ITS | | | | |
| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤[១] | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០[២] | ២១[៣] | ២២ | ២៣ |
| | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | |

[១] ១៤ = ៨ + ៩ + ១០ + ១១ + ១២ + ១៣

[២] ២០ = ១៦ + ១៧ + ១៨ + ១៩

[៣] ២១ = ១៤ + ២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ: ២៨៦ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ ២០០១

# ប្រកាស
# ស្តីពី
# ប្រតិភូបុគ្គលិកនៅក្នុងសហគ្រាស គ្រឹះស្ថាន

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## សំរេច

**ប្រការ១.-** សហគ្រាស គ្រឹះស្ថានទាំងអស់ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ហើយដែលមានប្រើកម្មករនិយោជិតចាប់ពី ០៨ នាក់ឡើងទៅ ត្រូវបង្កើតឱ្យមានប្រតិភូបុគ្គលិក ។ ប្រតិភូពេញសិទ្ធិ (ឬប្រតិភូបុគ្គលិកពេញសិទ្ធិ) ម្នាក់ ត្រូវមានប្រតិភូជំនួយម្នាក់ ។

ប្រភេទសហគ្រាស គ្រឹះស្ថាន ដែលត្រូវឱ្យមានប្រតិភូបុគ្គលិកជាដាច់ខាត គឺសហគ្រាស គ្រឹះស្ថាន ឧស្សាហកម្ម ពាណិជ្ជកម្ម រ៉ែ សំណង់ សេវាកម្ម ធនាគារ កសិកម្ម កំពង់ផែ សណ្ឋាគារ ភោជនីយដ្ឋាន សាលាបង្រៀន និងផលិតកម្មផ្សេងៗទៀត ។ ប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយ ត្រូវបោះឆ្នោតជ្រើសរើសដោយកម្មករនិយោជិតសំរាប់អាណត្តិ ២ឆ្នាំ ។

ប្រការ២..  បែបបទនិងរបៀបបោះឆ្នោតជ្រើសរើសប្រតិភូពេញសិទ្ធិនិងប្រតិភូជំនួយត្រូវអនុវត្តដូចតទៅៈ

- សហជីពដែលមានភាពជាតំណាងនៅក្នុងសហគ្រាស គ្រឹះស្ថាន ជាអ្នកជ្រើសតាំងបេក្ខជនឈរឈ្មោះទៅតាមចំនួនអាសនៈនៃប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយ ។ និយោជកត្រូវពិភាក្សាជាមួយសហជីពទាំងនោះ ដើម្បីកំណត់បែបបទកាលបរិច្ឆេទនៃការបោះឆ្នោត និងចំនួនអាសនៈដែលត្រូវបែងចែកទៅឱ្យគណៈអ្នកបោះឆ្នោត ។

- នៅពេលដែលមិនទាន់មានសហជីពនៅក្នុងសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិតមានសិទ្ធិពេញលេញដោយស្ម័គ្រចិត្តចុះឈ្មោះក្នុងបញ្ជីបេក្ខជន ដើម្បីឱ្យគេបោះឆ្នោតជ្រើសរើសប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយ ។ និយោជកត្រូវអញ្ជើញតំណាងកម្មករនិយោជិត ដើម្បីពិភាក្សាគ្នាអំពីបែបបទចាត់តាំងកាលបរិច្ឆេទនៃការបោះឆ្នោត និងចំនួនអាសនៈដែលត្រូវបែងចែកទៅឱ្យគណៈអ្នកបោះឆ្នោត។

- ការបោះឆ្នោតជ្រើសរើសប្រតិភូពេញសិទ្ធិ និងប្រតិជំនួយ ត្រូវធ្វើតាមរបៀបតែមួយ ប៉ុន្តែត្រូវធ្វើដាច់ដោយឡែកពីគ្នា ។ ការបោះឆ្នោតត្រូវធ្វើដោយសំងាត់ ការបោះឆ្នោតត្រូវធ្វើក្នុងម៉ោងធ្វើការ ។

- សហគ្រាស គ្រឹះស្ថានណាមានកម្មករនិយោជិតចាប់ពី ៥១នាក់ (ហាសិបមួយនាក់) ឡើងទៅ ការបោះឆ្នោតជ្រើសរើសប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយ ត្រូវបែងចែកជាពីរគណៈដាច់ដោយឡែក ។ គណៈអ្នកបោះឆ្នោតទី១ គឺសំរាប់ការបោះឆ្នោតជ្រើសរើសប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយដែលតំណាងឱ្យកម្មករនិយោជិតធម្មតា ។ គណៈអ្នកបោះឆ្នោតទី២ គឺសំរាប់ការបោះឆ្នោតជ្រើសរើសប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយដែលតំណាងឱ្យអ្នកដឹកនាំ អ្នកគ្រប់គ្រង អ្នកមានសញ្ញាប័ត្រចាប់ពីថ្នាក់ឧត្តមសិក្សាឡើង និងអ្នកជំនាញជាន់ខ្ពស់ ។ ប៉ុន្តែបើចំនួនសរុបនៃអ្នកត្រូវបោះឆ្នោតក្នុងគណៈអ្នកបោះឆ្នោតទី២ មានតិចជាងប្រាំបីនាក់នោះ ការបោះឆ្នោតអាចប្រព្រឹត្តទៅតែមួយគណៈរួមគ្នាតែម្តង ។

- និយោជកត្រូវបិទផ្សាយបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត ព្រមទាំងបញ្ជីឈ្មោះបេក្ខជនឈរឈ្មោះជូនដល់កម្មករនិយោជិតបានជ្រាប យ៉ាងតិចក្នុងរយៈពេលបីថ្ងៃមុនថ្ងៃបោះឆ្នោត។

- អ្នកបោះឆ្នោតមានសិទ្ធិពេញលេញក្នុងការជ្រើសរើសបេក្ខជនដែលខ្លួនពេញចិត្ត ប៉ុន្តែត្រូវគោរពបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោតជាដាច់ខាត។

- ក្រោយពេលប្រកាសផ្សាយបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត ព្រមទាំងបញ្ជីឈ្មោះបេក្ខជនឈរឈ្មោះរួច មុននឹងចែកសន្លឹកឆ្នោតដល់កម្មករនិយោជិតធ្វើការបោះឆ្នោត អ្នកទទួលខុស

ត្រូវរៀបចំការបោះឆ្នោត ត្រូវអនុញ្ញាតឱ្យកម្មករនិយោជិតសម្រាករយៈពេលពីរម៉ោង ដើម្បីធ្វើការត្រិះរិះពិចារណាដោយសេរីទៅលើបេក្ខជនដែលខ្លួនពេញចិត្ត។

- ចំពោះសហគ្រាស គ្រឹះស្ថានដែលមានសាខាច្រើនហើយសាខានីមួយៗ មានកម្មករនិយោជិតចាប់ពីប្រាំបីនាក់ឡើងទៅ ត្រូវធ្វើការបោះឆ្នោតជ្រើសរើសប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយតាមសាខានីមួយៗដាច់ដោយឡែកពីគ្នា។

- ក្នុងករណីបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកអាណត្តិថ្មី ការបោះឆ្នោត ត្រូវប្រព្រឹត្តទៅក្នុងរយៈពេលដប់ប្រាំថ្ងៃមុនពេលបញ្ចប់អាណត្តិប្រតិភូបុគ្គលិក ។

- និយោជកត្រូវទទួលខុសត្រូវការរៀបចំបោះឆ្នោតនេះ ទាំងផ្នែកសំភារៈ ហិរញ្ញវត្ថុ និងស្មារតី។

**ប្រការ៣.-** ប្រតិភូបុគ្គលិកក្នុងនាមជាតំណាងស្របច្បាប់របស់កម្មករនិយោជិត ត្រូវបំពេញភារៈកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវ និងស្មោះត្រង់ ។ ប្រតិភូបុគ្គលិកមានបេសកកម្មជាអាទិ៍ :-

- នាំពាក្យប្រាប់និយោជកអំពីសេចក្តីតវ៉ារបស់កម្មករនិយោជិតម្នាក់ៗ ឬច្រើននាក់រួមគ្នា ដែលមិនសុខចិត្ត អំពីការអនុវត្តប្រាក់ឈ្នួល ការអនុវត្តនីតិក្រម និងបទបញ្ជាទូទៅនៃការងារ ហើយនឹងអនុសញ្ញារួមសំរាប់អនុវត្តនៅក្នុងសហគ្រាស គ្រឹះស្ថាន

- ជំរាបជូនអធិការការងារ នូវបណ្តឹងតវ៉ាមិនសុខចិត្ត និងការរិះគន់ផ្សេងៗ ពាក់ព័ន្ធដល់ការអនុវត្តបទប្បញ្ញត្តិច្បាប់ និងបទបញ្ជាការងារដែលអធិការការងារមានភារកិច្ចត្រួតពិនិត្យ

- មើលខុសត្រូវលើការអនុវត្តបទប្បញ្ញត្តិខាងអនាម័យ និងខាងសន្តិសុខការងារ

- លើកសំណូមពរនូវវិធានការដែលមានប្រយោជន៍ សំរាប់រួមចំណែកការពារសុខភាពកែលំអសន្តិសុខ និងល័ក្ខខ័ណ្ឌការងាររបស់កម្មករនិយោជិតដែលធ្វើការក្នុងសហគ្រាស គ្រឹះស្ថានពិសេស ក្នុងករណីមានគ្រោះថ្នាក់ការងារ ឬមានជំងឺវិជ្ជាជីវៈ។

- ជូនយោបល់ជាលាយលក្ខណ៍អក្សរលើសេចក្តីព្រាងបទបញ្ជាផ្ទៃក្នុង ឬលើគម្រោងនៃការសម្រួលបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស គ្រឹះស្ថានខ្លួន។

- ជូនយោបល់ជាលាយលក្ខណ៍អក្សរលើវិធានការដែលគេបានគ្រោងឡើង សំរាប់ការបញ្ឈប់កម្មករនិយោជិត ដោយសារកាត់បន្ថយសកម្មភាព ឬការរៀបចំផ្ទៃក្នុងរបស់សហគ្រាស គ្រឹះស្ថានខ្លួន។

**ប្រការ៤.-** និយោជកត្រូវធ្វើកំណត់ហេតុ នៅរាល់ពេលធ្វើការបោះឆ្នោតជ្រើសរើសប្រតិភូពេញសិទ្ធិ និងប្រតិភូជំនួយ ។ ចំពោះសហគ្រាស គ្រឹះស្ថាន ទាំងអស់នៅរាជធានីភ្នំពេញ ត្រូវធ្វើកំណត់ហេតុនេះមួយច្បាប់ ទៅនាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ

និងយុវនីតិសម្បទា ដែលស្ថិតនៅអគារលេខ ២៨ វិថីសម្តេចព្រះធម្មលិខិតអ៊ុក (ផ្លូវលេខ១៨៤) សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។ ចំពោះសហគ្រាស គ្រឹះស្ថាននៅតាមខេត្ត-ក្រុង ត្រូវធ្វើកំណត់ហេតុនេះមួយច្បាប់ទៅ មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិ-សម្បទាខេត្ត-ក្រុង នៃមូលដ្ឋានខ្លួន ។ កំណត់ហេតុនេះ ត្រូវធ្វើយ៉ាងយូរបំផុតក្នុងរយៈពេលប្រាំបីថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត ។

**ប្រការ៥.-** និយោជកត្រូវផ្តល់ឱ្យប្រតិភូបុគ្គលិក នូវទីកន្លែងធ្វើការ ទីកន្លែងប្រជុំ សំភារៈធ្វើការ និងទីកន្លែងសំរាប់ការបិទផ្សាយផ្សេងៗដ៏ស្រមស្រប ។

**ប្រការ៦.-** និយោជកត្រូវអនុញ្ញាតឱ្យប្រតិភូបុគ្គលិកម្នាក់ៗ នូវពេលវេលាពីរម៉ោងក្នុងមួយសប្តាហ៍ សំរាប់បំពេញការងាររបស់ខ្លួន ដោយរក្សាទុកប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំផ្សេងៗ ដែលធ្លាប់បានទទួលនៅដដែល ។ ក្នុងករណីពិសេស និងដោយមានការឯកភាពពីនិយោជកផង ប្រតិភូបុគ្គលិកម្នាក់ៗ អាចបំពេញការងាររបស់ខ្លួនលើសពីថិរវេលាកំណត់នេះ ។

**ប្រការ៧.-** កម្មករនិយោជិត អាចបណ្តេញប្រតិភូបុគ្គលិកពីតំណែង មុនពេលចប់អាណត្តិបានក្នុងករណីដែលប្រតិភូបុគ្គលិកនោះ មិនអាចបំពេញភារកិច្ចរបស់ខ្លួន ។ ការសំរេចស្តីពីការបណ្តេញចេញនេះ ត្រូវធ្វើឡើងតាមរបៀប និងបែបបទបោះឆ្នោត ដូចគ្នានឹងពេលជ្រើសរើសជននោះដែរ ។ កម្មករនិយោជិត ត្រូវជូនដំណឹងជាផ្លូវការទៅអធិការការងារក្នុងរយៈពេល ០៣ថ្ងៃ យ៉ាងយូរ ក្រោយពីការសំរេចបណ្តេញប្រតិភូបុគ្គលិកចេញពីតំណែង ។ ពេលប្រតិភូពេញសិទ្ធិ ត្រូវបណ្តេញចេញពីតំណែង ប្រតិភូជំនួយ នឹងទទួលការងារនេះជំនួស រហូតដល់ពេលមានការបោះឆ្នោតជ្រើសរើសប្រតិភូ-បុគ្គលិកសំរាប់អាណត្តិថ្មី ។ Replacement

**ប្រការ៨.-** ការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរបំផុត ០៦ ខែ ក្រោយពេលបើកសហគ្រាស គ្រឹះស្ថាន ។

**ប្រការ៩.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ៧០ ប្រក.អក ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ និង លេខ ១៤៦ សកអ. ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ១៩៩៧ និងលេខ ៦៥៩ សកអ. ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១០.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខៈ ២៨៧ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០១

# ប្រកាស
# ស្តីពី
# បែបបទចុះបញ្ជិកា ការផ្សព្វផ្សាយ និងការត្រួតពិនិត្យ
# ការអនុវត្តអនុសញ្ញារួម

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## សំរេច

**ប្រការ១.-** អនុសញ្ញារួម ត្រូវសរសេរជាភាសាខ្មែរ ។ អនុសញ្ញារួមអាចបកប្រែជាភាសាបរទេសបាន ប៉ុន្តែករណីមានវិវាទស្តីពីការបកស្រាយខ្លឹមសារនៃអនុសញ្ញារួម គឺយកភាសាខ្មែរជាផ្លូវការ ចំពោះមុខច្បាប់ ។

**ប្រការ២.-** អនុសញ្ញារួម ត្រូវបញ្ជាក់ច្បាស់អំពីដែនអនុវត្តរបស់ខ្លួន ។ ភាគីហត្ថលេខី ត្រូវខិតខំអស់ពីលទ្ធភាព ដើម្បីដាក់បញ្ចូលទៅក្នុងអនុសញ្ញារួមនូវនីតិវិធីទាំងឡាយ ដែលទាក់ទងនឹងការផ្សះផ្សាការដោះស្រាយវិវាទតាមរយៈអាជ្ញាកណ្តាល និងការបកស្រាយអនុសញ្ញារួម ។

**ប្រការ៣.-** លើកលែងតែមានបទបញ្ញត្តិច្បាប់ផ្ទុយពីនេះ អនុសញ្ញារួម ឧបសម្ព័ន្ធ និងកិច្ចសន្យាបន្ថែមរបស់អនុសញ្ញារួម មានប្រសិទ្ធិភាពអនុវត្តមួយថ្ងៃ បន្ទាប់ពីបានចុះបញ្ជិកានៅស្ថាប័នមានសមត្ថកិច្ច។ ជនដែលបានចុះហត្ថលេខា ឬជាសមាជិកនៃអង្គការហត្ថលេខី មានកាតព្វកិច្ចអនុវត្តអនុសញ្ញារួមនេះ ។ និយោជកដែលដកសមាជិកភាពចេញពីអង្គការហត្ថលេខី ក្រោយពេលដែលអនុសញ្ញារួមចូលជាធរមាន នៅតែមានកាតព្វកិច្ចអនុវត្តអនុសញ្ញារួមនេះ។

**ប្រការ៤.-** និយោជក ឬអង្គការរបស់និយោជក ត្រូវយកអនុសញ្ញារួម ព្រមទាំងឧបសម្ព័ន្ធ និងកិច្ចសន្យាបន្ថែមរបស់អនុសញ្ញារួម ទៅចុះបញ្ជិកានៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង បើអនុសញ្ញារួមបានចុះហត្ថលេខានៅខេត្ត-ក្រុង ឬនៅនាយកដ្ឋានអធិការកិច្ចការងារ បើអនុសញ្ញារួមបានចុះហត្ថលេខានៅភ្នំពេញ ។ សំណុំលិខិតស្នើសុំចុះបញ្ជិកាមានដូចតទៅ :-

- ពាក្យសុំចុះបញ្ជិកា........................................................................................ ០១ច្បាប់
- អនុសញ្ញារួម ឧបសម្ព័ន្ធ និងកិច្ចសន្យាបន្ថែមរបស់អនុសញ្ញារួម "បើមាន" ក្នុងមួយមុខ..........................................................................................០៥ច្បាប់។

**ប្រការ៥.-** បន្ទាប់ពីបានចុះបញ្ជិកាហើយ មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង ឬនាយកដ្ឋានអធិការកិច្ចការងារ ត្រូវបញ្ជូនអនុសញ្ញារួម ឧបសម្ព័ន្ធ និងកិច្ចសន្យាបន្ថែមរបស់អនុសញ្ញារួមមួយមុខ ០១ ច្បាប់ ទៅតំកល់ទុកនៅការិយាល័យក្រឡាបញ្ជីនៃតុលាការការងារ ឬការិយាល័យក្រឡាបញ្ជីនៃតុលាការខេត្ត-ក្រុង ក្នុងមូលដ្ឋានខ្លួនបើមិនទាន់មានតុលាការការងារ ។ p

**ប្រការ៦.-** និយោជកដែលជាប់ទាក់ទិននឹងអនុសញ្ញារួម ត្រូវផ្តល់សេចក្តីចម្លងនៃអនុសញ្ញារួម ឧបសម្ព័ន្ធ និងកិច្ចសន្យាបន្ថែមរបស់អនុសញ្ញារួម ដែលបានចុះបញ្ជិការួចហើយឱ្យប្រតិភូបុគ្គលិកមួយច្បាប់ម្នាក់ និងមួយច្បាប់ទៀតឱ្យការិយាល័យបុគ្គលិកនៃសហគ្រាស គ្រឹះស្ថាន សំរាប់ការស្វែងយល់របស់កម្មករនិយោជិតទាំងអស់ ។ ទន្ទឹមនេះ និយោជកត្រូវបិទផ្សាយសេចក្តីជូនដំណឹង អំពីការធ្វើអនុសញ្ញារួមនេះ នៅគ្រប់ទីកន្លែងធ្វើការរបស់កម្មករនិយោជិត និងកន្លែងផ្សព្វផ្សាយពតិមានដល់កម្មករនិយោជិត ។ ជនគ្រប់រូបអាចស្វែងយល់ដោយឥតគិតថ្លៃអំពីអនុសញ្ញារួម ឧបសម្ព័ន្ធ និងកិច្ចសន្យាបន្ថែមរបស់អនុសញ្ញារួម នៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង ឬនាយកដ្ឋានអធិការកិច្ចការងារ ។ ករណីចាំបាច់គេក៏អាចសុំសេចក្តីថតចម្លងនៃឯកសារទាំងអស់នេះបាន ដោយគ្រាន់តែបង់ថ្លៃចំពោះការថតចម្លងប៉ុណ្ណោះ។

**ប្រការ៧.-** អធិការការងារ អាចចុះទៅត្រួតពិនិត្យការអនុវត្តអនុសញ្ញារួម ដោយសាកសួរពត៌មានពីប្រតិភូបុគ្គលិក នាយកសហគ្រាស គ្រឹះស្ថាន ឬពីកម្មករនិយោជិតផ្ទាល់។

**ប្រការ៨.-** វាលវិវាទដែលទាក់ទងនឹងការអនុវត្តអនុសញ្ញារួម អាចឱ្យភាគីណាមួយប្តឹងទៅតុលាការការងារ ឬតុលាការខេត្ត-ក្រុង នៃមូលដ្ឋានដែលអនុសញ្ញារួមបានចុះហត្ថលេខា ។ តុលាការអាចសំរេចឱ្យផ្តល់សំណងជំងឺចិត្តដល់ភាគីដែលមានការខូចខាត ។ ប៉ុន្តែភាគីវិវាទអាចប្តឹងទៅអធិការការងារមានសមត្ថកិច្ចនៅទីកន្លែង ដែលភាគីកម្មករនិយោជិតធ្វើការ ដើម្បីធ្វើការផ្សះផ្សាជាមុនសិន ។

**ប្រការ៩.-** ការចូលរួមអនុវត្តអនុសញ្ញារួមពីសំណាក់និយោជក ឬអង្គការវិជ្ជាជីវៈផ្សេងទៀត ក្រៅពីភាគីហត្ថលេខី និងសមាជិក ក្រោយពេលដែលអនុសញ្ញារួមនេះបានចុះហត្ថលេខារួចហើយ ក៏ដូចជាការបដិសេធអនុសញ្ញារួម ត្រូវអនុវត្តបែបបទដូចគ្នានឹងការចុះបញ្ជិកា និងផ្សព្វផ្សាយអនុសញ្ញារួមដែរ។

**ប្រការ១០.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ២៤៩ សកអ. ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៩៧ និងលេខ ១៩៧ សកអ. ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១១.-** អនុសញ្ញារួម ដែលបានចុះហត្ថលេខារួចហើយ មុនការចេញផ្សាយនៃប្រកាសនេះ ក៏ត្រូវចុះបញ្ជិកា និងផ្សព្វផ្សាយឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃប្រកាសនេះផងដែរ។

**ប្រការ១២.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ: ២៨៨ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០១

# ប្រកាស
## ស្តីពី
## សេចក្តីប្រកាសជូនដំណឹងបើក និង បិទសហគ្រាស គ្រឹះស្ថាន

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## សំរេច

**ប្រការ១.-** នាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថានដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវធ្វើសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថាន ទៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នៅមុនពេលបើកសហគ្រាស គ្រឹះស្ថាន (ជាស្ថាពរ)។

**ប្រការ២.-** សំណុំលិខិតនៃសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថាន មានដូចតទៅ :-

១-សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថានយកតាមគំរូ ក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ ដោយមានបិទតែមប្រ៊ី ១.៥០០រៀល (មួយពាន់ប្រាំរយរៀល) ចំនួនពីរច្បាប់។

២-សេចក្តីប្រកាសជូនដំណឹងស្តីអំពីបុគ្គលិកយកតាមគំរូក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ ចំនួន ០៣ ច្បាប់ ។

ចំពោះសហគ្រាស គ្រឹះស្ថានទាំងអស់នៅក្នុងរាជធានីភ្នំពេញ ត្រូវបញ្ជូនសំណុំលិខិតនៃសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស គ្រឹះស្ថានខាងលើ ទៅនាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចំណែកសហគ្រាស គ្រឹះស្ថាន នៅតាមខេត្ត-ក្រុងផ្សេងទៀត ត្រូវបញ្ជូនទៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិ-សម្បទា ខេត្ត-ក្រុង នៃមូលដ្ឋានខ្លួន ។

**ប្រការ៣.-** សហគ្រាស គ្រឹះស្ថានទាំងអស់ដែលមានចង្អុលបង្ហាញក្នុងប្រការ១ ខាងលើ ត្រូវជូនដំណឹងមកនាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិ-សម្បទា ចំពោះសហគ្រាស គ្រឹះស្ថាន នៅរាជធានីភ្នំពេញ ឬមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត-ក្រុង នៃមូលដ្ឋានខ្លួននូវគ្រប់សកម្មភាពផ្លាស់ប្តូរទីតាំងការកែប្រែ-រចនាសម្ព័ន្ធផលិតកម្ម ការផ្លាស់ប្តូរម្ចាស់ និងការបិទ ឬបញ្ឈប់សកម្មភាពសហគ្រាសយ៉ាងយូរបំផុត ៣០ថ្ងៃ (សាមសិបថ្ងៃ) បន្ទាប់ពីថ្ងៃមានការផ្លាស់ប្តូរ ឬបន្ទាប់ពីថ្ងៃដែលបញ្ឈប់សកម្មភាពសហគ្រាស គ្រឹះស្ថាន ។

**ប្រការ៤.-** អ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលការពិន័យ ឬផ្តន្ទាទោសដូចមានចែងក្នុងជំពូកទី១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៥.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ១៤៧ សកអ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៩៧ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

p

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

ឧបសម្ព័ន្ធទី១ ប្រកាសលេខ ២៨៨ សកបយ.

ចុះថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០០១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្ដីប្រកាសជូនដំណឹងបើកសហគ្រាស

១- ឈ្មោះនៃសហគ្រាស:.................................................................................................

២- កាលបរិច្ឆេទនៃការបើកសហគ្រាស ថ្ងៃទី...................ខែ.....................ឆ្នាំ.................

៣- អាសយដ្ឋាននៃមន្ទីរចាត់ការសហគ្រាស លេខ.............ផ្លូវលេខ.............សង្កាត់..................ខណ្ឌ.....

................ក្រុង............................លេខទូរសព្ទ...................................លេខទូរសារ..............

-នាមម្ចាស់សហគ្រាស ............................................សញ្ជាតិ ..............................

-នាមនាយកសហគ្រាស ............................................សញ្ជាតិ ............................

៤- លក្ខន្តិកៈគតិយុត្តិរបស់សហគ្រាស ................................................................................

៥- ប្រភេទសហគ្រាស .......................................................................................................

៦- ទីតាំងនៃសហគ្រាស លេខ.............ផ្លូវលេខ.............សង្កាត់......................ខណ្ឌ..........................

ក្រុង.............................លេខទូរសព្ទ..........................លេខទូរសារ...................................

៧-ចំនួនកម្មករនិយោជិត សរុប ............... នាក់ ស្រី.............នាក់ ប្រុស .............. នាក់

ក្នុងនោះ:-

- កម្មករនិយោជិត អាយុពី ១៥ ទៅក្រោម ១៨ ឆ្នាំ ចំនួន ......នាក់ ស្រី ....នាក់ ប្រុស ....នាក់
- មានជនបរទេស ចំនួន .......... នាក់ ស្រី ................ នាក់ ប្រុស ................. នាក់ ។

៨- រយៈពេល និងប្រភេទការងារពេលយប់សំរាប់ស្ត្រី ឬក្មេងប្រសិនបើមានបដិប្បញ្ញត្តិ ...........................

..........................................................................................................................

....................................................................................................................... ។

៩- មានកម្មករនិយោជិតអាយុក្រោម ១៨ ឆ្នាំ ស្នាក់នៅក្នុងសហគ្រាស ចំនួន.......នាក់ ( ស្រី ......នាក់) ។

១០-ប្រភេទគ្រឿងចក្រ និងវិធីប្រើសំភារៈ វត្ថុធាតុដើមប្រកបដោយគ្រោះថ្នាក់ ....................................

............................................................................................................................ ។

១១- ថ្ងៃឈប់សំរាកប្រចាំសប្ដាហ៍ ............................................................................................ ។

រាជធានីភ្នំពេញ , ថ្ងៃទី ................ខែ ...............ឆ្នាំ២០០.........

**ហត្ថលេខា ម្ចាស់ ឬនាយកសហគ្រាស**

p

ឧបសម្ព័ន្ធទី១ ប្រកាសលេខ ២៨៨ សកបយ.

ចុះថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ២០០១

## សេចក្តីប្រកាសជូនដំណឹងស្តីពីបុគ្គលិក

| | | |
|---|---|---|
| យីហោ:.................................................................<br>អាសយដ្ឋានផ្ទះលេខ:...........ផ្លូវ..........សង្កាត់.................<br>ខណ្ឌ:.................ក្រុង:...............ទូរស័ព្ទ:....................<br>ឈ្មោះម្ចាស់គ្រឹះស្ថាន:..................សញ្ជាតិ:....................<br>ឈ្មោះនាយកគ្រឹះស្ថាន:.................សញ្ជាតិ:.................... | ផ្នែកសកម្មភាពសេដ្ឋកិច្ច:.............................................................<br>ផលិតផលសំខាន់ៗ:.....................................................................<br>លក្ខន្តិក:គតិយុត្តនៃសហគ្រាស:...................................................... | ចំនួនបុគ្គលិកសព្វថ្ងៃ:...........នាក់<br>ចំនួនបុគ្គលិកមធ្យម:(១)......នាក់<br>គិតត្រឹមថ្ងៃទី......ខែ........ឆ្នាំ....... |

| ល.រ | នាមត្រកូល និងនាមខ្លួន | ភេទ | សញ្ជាតិ | ថ្ងៃខែឆ្នាំកំណើត | លេខសៀវភៅការងារ | បៀវត្សប្រចាំខែ | របៀបបើកបៀវត្ស | ថ្ងៃខែឆ្នាំចូលធ្វើការ | មុខងារ | កំរិតវប្បធម៌ ឬកំរិតវិជ្ជាជីវៈ | ចំនួនម៉ោងធ្វើការក្នុងមួយអាទិត្យ | កំណត់សំគាល់របស់ការិយាល័យ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ |
| ១ | ក.អ្នកដឹកនាំ | | | | | | | | | | | | |
| ២ | ខ. និយោជិតការិយាល័យ | | | | | | | | | | | | |
| ៣ | គ.កម្មករជំនាញខ្ពស់ | | | | | | | | | | | | |
| ៤ | ឃ.កម្មករជំនាញ | | | | | | | | | | | | |
| ៥ | ង.កម្មករពាក់កណ្តាលជំនាញ | | | | | | | | | | | | |
| ៦ | ច ហត្ថករឯកទេស | | | | | | | | | | | | |
| ៧ | ឆ.ហត្ថករ | | | | | | | | | | | | |

<u>កំណត់សំគាល់:</u> - បើគ្មានពតិមានណាដែលត្រូវចុះ ត្រូវដាក់ក្នុងខ្ទង់ទី១ ថា " គ្មាន "

- (១) មធ្យមតាមខែគិតក្នុងប្រាំមួយខែ

រាជធានីភ្នំពេញ . ថ្ងៃទី..........ខែ...........ឆ្នាំ.............

ហត្ថលេខាម្ចាស់ ឬនាយកសហគ្រាស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ: ៣០៥ សកបយ.

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០១

# ប្រកាស

## ស្តីពី

## ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករ និយោជិត នៅថ្នាក់សហគ្រាស គ្រឹះស្ថាន និងសិទ្ធិក្នុងការចរចាជាសមូហភាព ដើម្បីចុះអនុសញ្ញារួម នៅថ្នាក់សហគ្រាស គ្រឹះស្ថាន

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## សំរេច

**ប្រការ១.-** ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត ត្រូវបានទទួលស្គាល់ក្នុងក្របខ័ណ្ឌភូមិសាស្ត្រ ឬវិជ្ជាជីវៈ ដូចខាងក្រោមនេះ :

**-ក្នុងក្របខ័ណ្ឌភូមិសាស្ត្រ**

- នៅថ្នាក់សហគ្រាស ឬគ្រឹះស្ថាន
- នៅថ្នាក់ខេត្ត ឬក្រុង
- នៅថ្នាក់ជាតិ។

- ក្នុងក្របខ័ណ្ឌវិជ្ជាជីវៈ

  - វិជ្ជាជីវៈមួយជាកំណត់
  - វិជ្ជាជីវៈច្រើនបញ្ចូលរួមគ្នា ឬប្រហាក់ប្រហែលគ្នា
  - សកម្មភាពសេដ្ឋកិច្ចមួយ ឬផ្នែកមួយនៃសកម្មភាពសេដ្ឋកិច្ចមួយជាកំណត់
  - សកម្មភាពសេដ្ឋកិច្ចច្រើន ឬផ្នែកច្រើននៃសកម្មភាពសេដ្ឋកិច្ច ។

**ប្រការ២.-** សហជីពថ្នាក់សហគ្រាស ឬគ្រឹះស្ថាន ត្រូវចុះបញ្ជិកានៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ស្របតាមប្រកាសលេខ ២៧៧ សកបយ ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០០ ។

**ប្រការ៣.-** លក្ខន្តិកៈសហជីពត្រូវកំណត់ថា តើសហជីពនេះមានគោលបំណងតំណាងឱ្យកម្មករនិយោជិតទាំងអស់របស់សហគ្រាស គ្រឹះស្ថាន ឬគ្រាន់តែតំណាងឱ្យប្រភេទមួយ ឬច្រើនដែល កំណត់ដោយលក្ខន្តិកៈ ។ ក្នុងករណីនេះ គឺមានតែកម្មករនិយោជិត ដែលស្ថិតក្នុងប្រភេទនោះ ឬប្រភេទទាំងឡាយនោះទេ ដែលអាចចូលជាសមាជិកសហជីព ។ ត្រូវហាមឃាត់មិនអោយបង្កើតសហជីព ឬសមាគមទាំងឡាយណា ដែលរួមបញ្ចូលនិយោជក និងកម្មករនិយោជិតនៅក្នុងសហជីព ឬសមាគម តែមួយជាមួយគ្នា ។

លក្ខន្តិកៈសហជីព ត្រូវកំណត់លក្ខខណ្ឌសំរាប់ជ្រើសរើសអ្នកដឹកនាំរបស់ខ្លួនតាមរយៈការបោះឆ្នោតជាសម្ងាត់ ។ ទោះជាយ៉ាងនេះក្តី អាណត្តិរបស់អ្នកដឹកនាំ មិនត្រូវលើសពីពីរឆ្នាំឡើយ ប៉ុន្តែគេអាចត្រូវបានបោះឆ្នោតជ្រើសរើសជាថ្មីបាន ។

កម្មករនិយោជិត ទាំងអស់ដែលជាបេក្ខជនសំរាប់ការបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព ទទួលបាននូវការការពារចំពោះការបញ្ឈប់ពីការងារដូចប្រតិភូបុគ្គលិកដែរ ។ ការការពារនេះមាន រយៈពេល ៤៥ថ្ងៃមុនការបោះឆ្នោត ហើយត្រូវបញ្ចប់ក្នុងរយៈពេល ៤៥ថ្ងៃ ក្រោយការបោះឆ្នោត ប្រសិនបើបេក្ខជនទាំងនេះមិនត្រូវបានជាប់ឆ្នោត ។ សហជីពត្រូវជូនដំណឹងទៅនិយោជកអំពីបេក្ខភាពនេះតាមគ្រប់មធ្យោបាយទាំងអស់ដែលទុកជាបានការ ។ និយោជកត្រូវអនុវត្តបទប្បញ្ញត្តិនេះតែម្តងគត់នៅរៀងរាល់ពេលបោះឆ្នោតជ្រើសរើសថ្នាក់ដឹកនាំសហជីព ។

អាណត្តិនៃអ្នកដឹកនាំសហជីពថ្នាក់សហគ្រាស គ្រឹះស្ថាន នឹងត្រូវបញ្ចប់ដោយសារការបញ្ចប់នៃកិច្ចសន្យាការងារតែក្នុងករណីដែលបញ្ហានេះបានចែងក្នុងលក្ខន្តិកៈសហជីព ។

អ្នកដឹកនាំសហជីពទាំងអស់ដែលត្រូវបានបញ្ឈប់ជាបណ្តោះអាសន្ន ឬអចិន្ត្រៃយ៍ ដោយហេតុផលសេដ្ឋកិច្ច ឬហេតុផលផ្សេងៗទៀតនៅតែមានសិទ្ធិចេញចូលក្នុងសហគ្រាស ដើម្បីបំពេញភារកិច្ច

ទទួលខុសត្រូវស្របតាមអាណត្តិសហជីពរបស់ខ្លួន ។ ថ្នាក់ដឹកនាំសហជីពណាម្នាក់ដែលបានប្រព្រឹត្តិខុស ហើយត្រូវបានបណ្តេញស្របច្បាប់ ត្រូវតែលាលែងពីសហជីព ។

**ប្រការ៤.-** ចាប់តាំងពីពេលដាក់ពាក្យសុំចុះបញ្ជិកាសហជីពកម្មករនិយោជិតទាំងអស់ ដែលជាស្ថាបនិក ឬកម្មករនិយោជិតដែលស្ម័គ្រចិត្តចូលជាសមាជិកសហជីពនេះ ក្នុងពេលកំពុងស្នើសុំចុះបញ្ជិកា ត្រូវបានការការពារដូចគ្នានឹងប្រតិភូបុគ្គលិកដែរ ។ ការការពារនេះមានរយៈពេលរហូតដល់ ៣០ថ្ងៃ ក្រោយកាលបរិច្ឆេទនៃការចុះបញ្ជិកាសហជីព។

ផុតរយៈពេលកំណត់ក្នុងកថាខ័ណ្ឌខាងលើ ការការពារនេះ ត្រូវបានផ្តល់ឱ្យអ្នកដឹកនាំសហជីព ០៣នាក់ក្នុងលក្ខខណ្ឌដូចមានចែងក្នុងមាត្រា២៨២ និង២៩៣ នៃច្បាប់ស្តីពីការងារ។ ចំពោះសហជីពដែលមានសមាជិកលើសពី ២០០នាក់ ការការពារនេះ ត្រូវផ្តល់ឱ្យសមាជិកសហជីពម្នាក់សំរាប់ភាគបន្ថែមនីមួយៗ ដែលមានសមាជិកសហជីព ១០០ នាក់ ។ ការការពារនេះ អាចផ្តល់កាន់តែច្រើនថែមទៀតដោយអនុសញ្ញារួម ។ ដើម្បីទទួលបាននូវការការពារនេះសហជីព ត្រូវជូនដំណឹងដល់និយោជកអំពីឈ្មោះអ្នកដែលត្រូវទទួលការការពារតាមគ្រប់មធ្យោបាយដែលទុកជាបានការ។ សេចក្តីចម្លងមួយច្បាប់នៃការជូនដំណឹងនេះ ត្រូវផ្ញើទៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

ក្នុងករណីដែលមានការតវ៉ាអំពីចំនួនសមាជិកសហជីព ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នឹងធ្វើការអង្កេត ។ ក្នុងករណីនេះ ភាគីដែលមានការពាក់ព័ន្ធជាពិសេសភាគីដែលជាកម្មវត្ថុនៃការអង្កេត ត្រូវផ្តល់ជូនក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នូវភស្តុតាងទាំងអស់ ដែលបញ្ជាក់អំពីភាពជាត្រឹមត្រូវរបស់ខ្លួន។

និយោជកណាដែលបញ្ឈប់ ឬបណ្តេញកម្មករនិយោជិតពីការងារ ដែលបានទទួលការការពារស្របតាមបទប្បញ្ញត្តិទាំងឡាយខាងលើ ដោយគ្មានការអនុញ្ញាតិជាមុនពីអធិការការងារ ឬក៏ធ្វើឱ្យមានការខូចខាតណាមួយដល់កម្មករនិយោជិតនោះ ត្រូវទទួលពិន័យស្របតាមមាត្រា៣៧៣ នៃច្បាប់ស្តីពីការងារ ។ វិធានការទាំងឡាយរបស់និយោជកដែលរំលោភលើបទប្បញ្ញត្តិខាងលើនេះ ត្រូវចាត់ទុកជាមោឃៈ និងគ្មានតំលៃអ្វីទាំងអស់ ។ ក្រសួងនឹងចាត់វិធានការទាំងអស់ នៅក្នុងសមត្ថកិច្ចរបស់ខ្លួនយ៉ាងម៉ឺងម៉ាត់ជាបន្ទាន់ ដើម្បីឱ្យកម្មករនិយោជិត ដែលត្រូវបានបណ្តេញចេញពីការងារ ឱ្យបានចូលធ្វើការវិញ (ទោះបីជារឿងក្តីនេះកំពុងរង់ចាំការជំនុំជំរះ នៅចំពោះមុខតុលាការមានសមត្ថកិច្ចក៏ដោយ) ។ វិធានការទាំងអស់នេះ រួមមានកិច្ចសហប្រតិបត្តិការជាមួយក្រសួងដទៃទៀតដូចមានចែងក្នុងប្រកាសអន្តរក្រសួងលេខ ២៥៨៨ ពណបអព.ប្រក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០០។

**ប្រការ៥.-** សហជីពទាំងអស់ដែលបានបង្កើតឡើងនៅថ្នាក់សហគ្រាស គ្រឹះស្ថានស្របតាមមាត្រា ២៦៨ នៃច្បាប់ស្តីពីការងារ មានសិទ្ធិតំណាងឱ្យផលប្រយោជន៍របស់សមាជិករបស់ខ្លួនតាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីការងារ ។

សិទ្ធិដូចគ្នានេះ ត្រូវបានផ្តល់ឱ្យសហជីពថ្នាក់ខ្ពស់ជាងសហគ្រាស គ្រឹះស្ថាន (ឧទាហរណ៍ៈ សហជីពដែលបង្កើតឡើងតាមសកម្មភាពសេដ្ឋកិច្ចមួយ ឬតាមផ្នែកមួយនៃសកម្មភាពសេដ្ឋកិច្ច ឬ សហជីពថ្នាក់ជាតិ) ប្រសិនបើសហជីពថ្នាក់ខ្ពស់ទាំងនោះ មានសមាជិករបស់ខ្លួននៅក្នុងសហគ្រាស ឬគ្រឹះស្ថាននោះ ។ សហជីពទាំងនេះ អាចចាត់តាំងតំណាងសហជីពម្នាក់ នៅថ្នាក់សហគ្រាស គ្រឹះស្ថាន តាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា២៧៨ នៃច្បាប់ស្តីពីការងារ ។ ចំនួនតំណាងសហជីពអាចច្រើនជាងនេះ ដោយការចរចាជាសមូហភាព ។

តំណាងសហជីព ដែលត្រូវបានចាត់តាំងស្របតាមកថាខ័ណ្ឌខាងលើនឹងទទួលបាននូវការការពារដូចមានចែងក្នុងមាត្រា២៩៣ នៃច្បាប់ស្តីពីការងារ ។

សហជីពទាំងអស់ ដែលបង្កើតឡើងក្នុងសហគ្រាស គ្រឹះស្ថាន ត្រូវតែផ្តល់ភស្តុតាងនៃភាពជាតំណាងរបស់ខ្លួន ។ ភស្តុតាងនេះ ត្រូវយកតាមលក្ខណៈវិនិច្ឆ័យទាំងឡាយដែលមានចែងក្នុងមាត្រា ២៧៧ នៃច្បាប់ស្តីពីការងារ ។

កម្មករនិយោជិតទាំងអស់ ដែលជាសមាជិកសហជីព អាចស្នើសុំជាលាយលក្ខណ៍អក្សរក្នុងរយៈពេលយ៉ាងតិច ១៥ថ្ងៃមុន ដើម្បីឱ្យនិយោជកកាត់ប្រាក់ឈ្នួលរបស់ខ្លួន ដើម្បីបង់ភាគទានសហជីព ដែលខ្លួនជាសមាជិកស្របតាមមាត្រា១២៩ នៃច្បាប់ស្តីពីការងារ ហើយនិយោជកត្រូវតែអនុវត្តឱ្យបានត្រឹមត្រូវតាមសំណើនេះ ។ តាមសំណើរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និយោជកត្រូវផ្តល់សេចក្តីបញ្ជាក់របស់ខ្លួនអំពីចំនួនកម្មករនិយោជិតដែលបានស្នើសុំកាត់ប្រាក់ឈ្នួលដើម្បីបង់ភាគទានសហជីព ប្រភព និងឈ្មោះសហជីព ឬសហជីពទាំងឡាយដែលបានទទួលផលពីនីតិវិធីនេះ ។ សេចក្តីបញ្ជាក់នេះ គឺជាភស្តុតាងបន្ថែមដើម្បីកំណត់ភាពជាតំណាងរបស់សហជីព ។

**ប្រការ៦.-** សហជីពណា ដែលសមាជិករបស់ខ្លួនមានចំនួនភាគច្រើនដាច់ខាត នៃចំនួនកម្មករនិយោជិតទាំងអស់ក្នុងសហគ្រាស គ្រឹះស្ថាន សហជីពនោះ មានសិទ្ធិតំណាងឱ្យកម្មករនិយោជិតទាំងមូលនៃសហគ្រាស គ្រឹះស្ថាននោះ ។ សហជីពណាដែលសមាជិករបស់ខ្លួនមានចំនួនភាគច្រើនដាច់ខាតនៃចំនួនកម្មករនិយោជិតប្រភេទណាមួយជាក់លាក់នៅក្នុងសហគ្រាស គ្រឹះស្ថាន សហជីពនោះមានសិទ្ធិតំណាងឱ្យតែកម្មករនិយោជិតនៃប្រភេទនោះតែប៉ុណ្ណោះ ។ ក្នុងករណីផ្ទុយពីនេះ សហជីពនីមួយៗមានសិទ្ធិតំណាងឱ្យតែសមាជិករបស់ខ្លួនតែប៉ុណ្ណោះ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បញ្ជាក់អំពីភាពជាតំណាងបំផុតនៃសហជីពតាមសេចក្តីស្នើសុំរបស់សហជីពនោះ ដែលសហជីពនោះត្រូវផ្តល់ជូនក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទានូវគ្រប់ភស្តុតាងដ៏សមស្របទាំងឡាយពិសេសភស្តុតាង ដូចមានចែងក្នុងមាត្រា២៧៧ នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែ មុននឹងផ្តល់សេចក្តីបញ្ជាក់នេះក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ស្នើឱ្យនិយោជក និងសហជីពដែលជាសមាជិកគណៈកម្មការប្រឹក្សាការងារ ផ្តល់នូវសេចក្តីសង្កេតរបស់ខ្លួន ឬសេចក្តីជំទាស់ជាយថាហេតុរបស់ខ្លួនក្នុងរយៈពេល ១៥ថ្ងៃគត់ ។ សេចក្តីស្នើនេះ ត្រូវធ្វើតាមរយៈសំបុត្រអនុសិដ្ឋ ឬលិខិតជូនផ្ទាល់ដៃដែលមានចុះហត្ថលេខាថា បានទទួលហើយ។ រូបវ័ន្តបុគ្គល ឬនីតិបុគ្គលដែលមានការពាក់ព័ន្ធ ក៏អាចផ្តល់នូវសេចក្តីសង្កេតរបស់ខ្លួន ឬសេចក្តីជំទាស់ជាយថាហេតុក្នុងរយៈពេលដូចគ្នានេះដែរ ។ ផុតកំណត់ពេលនេះ ប្រសិនបើគ្មានសេចក្តីជំទាស់ណាមួយទេ ទើបក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អាចចេញសេចក្តីបញ្ជាក់នេះបាន។

ករណីក្រសួងសំរេចមិនបញ្ជាក់ អំពីភាពជាតំណាងបំផុតរបស់សហជីព សហជីពអាចស្នើឱ្យក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រៀបចំការបោះឆ្នោតជាសម្ងាត់ដោយមានការចូលរួមរបស់កម្មករនិយោជិត ឬប្រភេទកម្មករនិយោជិតទាំងអស់ ដែលសហជីពនោះតំណាងក្នុងលក្ខខណ្ឌដូចមានចែងក្នុងបទប្បញ្ញត្តិនៃកថាខ័ណ្ឌ២ នៃប្រការ៧ ខាងក្រោម ។ ប្រសិនបើមានសហជីពច្រើន បានបង្ហាញភស្តុតាងជូនក្រសួងថា សហជីពទាំងនោះជាតំណាងកម្មករនិយោជិតនៅក្នុងសហគ្រាស គ្រឹះស្ថាន សហជីពទាំងនោះត្រូវតែបានចូលរួមក្នុងការបោះឆ្នោត។ សហជីពដែលទទួលបានសម្លេងភាគច្រើននៃសន្លឹកឆ្នោតបានការ ក្នុងពេលបោះឆ្នោតត្រូវបានទទួលស្គាល់ថា ជាសហជីពដែលមានភាពជាតំណាងបំផុត ។ ប្រសិនបើសហជីពណាមួយមិនបានទទួលសម្លេងភាគច្រើននៃសន្លឹកឆ្នោតបានការក្នុងពេលបោះឆ្នោតសហជីពនោះ ត្រូវបានទទួលស្គាល់ថា ជាសហជីពមានសមាជិកភាគតិច ។

សហជីពត្រូវបានទទួលស្គាល់ថា ជាសហជីពដែលមានភាពជាតំណាងបំផុតក្នុងរយៈពេល ២ឆ្នាំជាអប្បបរមា ។ ផុតរយៈពេលនេះ រូបវ័ន្តបុគ្គល ឬនីតិបុគ្គលដែលមានការពាក់ព័ន្ធអាចស្នើសុំឱ្យរៀបចំការបោះឆ្នោតជាថ្មី ក្នុងគោលបំណងបញ្ជាក់ថា សហជីពនេះនៅតែរក្សាបាននូវភាពជាតំណាងបំផុតរបស់ខ្លួន។

**ប្រការ៧.-** កាលបរិច្ឆេទ និងទីកន្លែងបោះឆ្នោត ត្រូវជូនដំណឹងដល់កម្មករនិយោជិតយ៉ាងតិចប្រាំពីរថ្ងៃគត់មុនការបោះឆ្នោត ។ និយោជកត្រូវអនុញ្ញាតឱ្យមន្ត្រីដែលចាត់តាំងដោយក្រសួងសង្គមកិច្ច ការងារ

បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ផ្តល់ដល់កម្មករនិយោជិតនូវពត៌មានទាំងឡាយដែលចាំបាច់សំរាប់ការបោះឆ្នោត ។ មន្ត្រីនេះត្រូវជូនដំណឹងដល់កម្មករនិយោជិតទាំងអស់ ដូចមានចែងក្នុងកថាខ័ណ្ឌ២ នៃប្រការ៧ នេះ ដើម្បីកម្មករនិយោជិតទាំងនោះអាចចូលរួមក្នុងការបោះឆ្នោត ។ មន្ត្រីដែលបានទទួលការចាត់តាំងពីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ធ្វើការសំរុះសំរួលទាំងឡាយជាក់ស្តែង ដើម្បីឱ្យការបោះឆ្នោតអាចប្រព្រឹត្តទៅបាន ដោយពិគ្រោះយោបល់ជាមួយនិយោជក និងសហជីព អំពីពេលម៉ោងបោះឆ្នោតការិយាល័យបោះឆ្នោតជាដើម ។

កម្មករនិយោជិតទាំងអស់ ដែលធ្វើការជាទៀងទាត់នៅក្នុងសហគ្រាស គ្រឹះស្ថានយ៉ាងតិចបីខែ ដោយគិតចាប់ពីថ្ងៃចូលសាកល្បងការងារ មានសិទ្ធិចូលរួមក្នុងការបោះឆ្នោត ។ ប្រសិនបើសហជីពតំណាងឱ្យតែប្រភេទមួយ ជាកំណត់នៃកម្មករនិយោជិត គឺមានតែកម្មករនិយោជិតដែលស្ថិតក្នុងប្រភេទនេះទេដែលអាចចូលរួមក្នុងការបោះឆ្នោតនេះបាន ។

សហជីពអាចធ្វើយុទ្ធនាការផ្តល់ពត៌មានចាំបាច់ទាំងអស់សំរាប់ការបោះឆ្នោត ដូចជាអំពីកាលបរិច្ឆេទទីកន្លែងនៃការបោះឆ្នោត ទំរង់សន្លឹកឆ្នោត នីតិវិធីនៃការបោះឆ្នោតជាដើម ។ ការធ្វើយុទ្ធនាការនេះ ត្រូវប្រព្រឹត្តទៅនៅក្រៅពេលម៉ោងធ្វើការ ឬក្នុងម៉ោងធ្វើការនៅក្នុងសហគ្រាស គ្រឹះស្ថាន ប្រសិនបើមានការយល់ព្រមពីនិយោជក និងស្របតាមបែបបទដែលនិយោជកបានយល់ព្រម ។

សន្លឹកឆ្នោតត្រូវរៀបចំយ៉ាងណាកុំឱ្យមានការច្រឡំ ។ បើអាចធ្វើទៅបាន សន្លឹកឆ្នោតមានតែសំនួរមួយគត់ដែលមានប្រអប់សំរាប់គូស (ឧទាហរណ៍ៈ តើអ្នកចង់ឱ្យសហជីព "ក" តំណាងឱ្យអ្នកឬទេ? ដោយមានប្រអប់សំរាប់គូសថា បាទ ចាំ ឬ ទេ) ។ ក្នុងករណីមានឈ្មោះសហជីពច្រើន នៅក្នុងសន្លឹកឆ្នោត ត្រូវមានប្រអប់សំរាប់គូសនៅជាប់ និងឈ្មោះសហជីពនីមួយៗ នៃសន្លឹកឆ្នោតនោះ ។ ជាអាទិ៍សន្លឹកឆ្នោតអាចដាក់រូបថតនៃអ្នកដឹកនាំសហជីព ឬសហជីពទាំងឡាយ ដោយមានឈ្មោះរបស់សហជីព និងដោយមានប្រអប់សំរាប់គូសនៅជិតរូបថត គឺធ្វើយ៉ាងនេះ ដើម្បីជួយកម្មករនិយោជិតដែលមិនអាចអានអក្សរបាន ធ្វើការជ្រើសរើស ។

ការបោះឆ្នោត ត្រូវធ្វើក្នុងពេលម៉ោងធ្វើការ ប្រសិនបើមានការយល់ព្រមពីនិយោជក ។ ការបោះឆ្នោត ត្រូវធ្វើនៅមុន ឬក្រោយពេលម៉ោងធ្វើការភ្លាមៗ ប្រសិនបើគ្មានការយល់ព្រមពីនិយោជកឱ្យធ្វើការបោះឆ្នោតក្នុងពេលម៉ោងធ្វើការទេ ។

ការបោះឆ្នោត ត្រូវធ្វើនៅកន្លែងធ្វើការ ប្រសិនបើមានការយល់ព្រមពីនិយោជក ឬនៅទីណាជិតកន្លែងធ្វើការ ប្រសិនបើគ្មានការយល់ព្រមពីនិយោជកទេ ។

ការបោះឆ្នោត ត្រូវស្ថិតក្រោមអធិបតីភាព នៃមន្ត្រីដែលតែងតាំងដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។ មន្ត្រីនេះនឹងចាត់តាំងមនុស្សម្នាក់ ឬច្រើននាក់

ផងដែរ ដើម្បីពិនិត្យមើលភាពត្រឹមត្រូវនៃការបោះឆ្នោត ។ តំណាងសហព័ន្ធសហជីពថ្នាក់ជាតិ អង្គការជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធ មានសិទ្ធិចូលរួមសង្កេតការណ៍ ដើម្បីពិនិត្យភាពត្រឹមត្រូវនៃការបោះឆ្នោត។

សហជីពទាំងអស់ដែលយកចិត្តទុកដាក់ចំពោះលទ្ធផលនៃការបោះឆ្នោត មានសិទ្ធិចាត់តាំងអ្នកជំនួយការពិនិត្យសន្លឹកឆ្នោតម្នាក់ ឬច្រើននាក់ ដើម្បីជួយមន្ត្រីដែលតែងតាំងដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្នុងការរាប់សន្លឹកឆ្នោត។

ដោយមានការព្រមព្រៀងពីភាគីទាំងអស់ដែលពាក់ព័ន្ធ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អាចប្រគល់ការរៀបចំ និងការត្រួតពិនិត្យការបោះឆ្នោតជូនតតិយជន ឬស្ថាប័នសាធារណៈ ឬឯកជនដែលទទួលបានទំនុកចិត្តក្នុងការបំពេញកិច្ចការនេះ។

ត្រូវធ្វើការរាប់សន្លឹកឆ្នោតជាសាធារណៈ បន្ទាប់ពីការបោះឆ្នោត ត្រូវបានបញ្ចប់ភ្លាម ។ លទ្ធផល ត្រូវប្រកាសដោយជនដែលទទួលបន្ទុកត្រួតពិនិត្យសន្លឹកឆ្នោត បន្ទាប់ពីការរាប់សន្លឹកឆ្នោតបានបញ្ចប់ ។

សហជីពដែលត្រូវបានទទួលស្គាល់ថា ជាសហជីពដែលមានភាពជាតំណាងបំផុតឆ្លងតាមការបោះឆ្នោតនេះទទួលបាននូវភាពជាតំណាងនេះ បន្ទាប់ពីលទ្ធផលនៃការបោះឆ្នោតត្រូវបានប្រកាសស្របតាមកថាខ័ណ្ឌខាងលើ។

រាល់ការធ្វើឧបាស្រ័យទាក់ទងដល់ភាពត្រឹមត្រូវនៃការបោះឆ្នោត ឬលទ្ធផលនៃការបោះឆ្នោត ត្រូវតែដាក់ជូនតុលាការមានសមត្ថកិច្ចក្នុងរយៈពេល ៨ថ្ងៃគត់ ដោយគិតចាប់ពីថ្ងៃប្រកាសលទ្ធផល។ ការធ្វើឧបាស្រ័យនេះមិនមានផលធ្វើឱ្យផ្អាកការអនុវត្តលទ្ធផលនៃការបោះឆ្នោតឡើយ។

**ប្រការ៨.-** ដោយមិនគិតដល់បទប្បញ្ញត្តិទាំងឡាយនៃកថាខ័ណ្ឌ១ នៃប្រការ៦ ខាងលើ សហជីពមានសមាជិកភាគតិច មានសិទ្ធិតំណាងឱ្យតែសមាជិករបស់ខ្លួនតែប៉ុណ្ណោះ។

សហជីពមានសមាជិកភាគតិច ក៏អាចចូលរួមក្នុងការតាក់តែងសេចក្តីព្រាងអនុសញ្ញារួមផងដែរ ប្រសិនបើសហជីពមានភាពជាតំណាង ឬតំណាងបំផុតអញ្ជើញឱ្យចូលរួម។

**ប្រការ៩.-** សហជីពដែលមានភាពជាតំណាងបំផុត មានសិទ្ធិស្នើសុំឱ្យនិយោជកធ្វើការចរចាអំពីអនុសញ្ញារួម ដែលអនុវត្តចំពោះកម្មករនិយោជិតទាំងអស់ ដែលសហជីពនោះតំណាងឱ្យ។ ក្នុងករណីនេះ និយោជកមានកាតព្វកិច្ច ត្រូវតែធ្វើការចរចាជាមួយសហជីព។

នៅក្នុងសហគ្រាស គ្រឹះស្ថានណា ដែលពុំទាន់មានសហជីពមានភាពជាតំណាងបំផុតនោះ សហជីពទាំងអស់ ឬសហជីពច្រើន ដែលមានសមាជិកនៅក្នុងសហគ្រាស គ្រឹះស្ថាននោះ អាចរួបរួមគ្នាដើម្បីលើកឡើងនូវសេចក្តីព្រាងរួមនៃអនុសញ្ញារួម ។ និយោជកមានកាតព្វកិច្ចត្រូវធ្វើការចរចា

ប្រសិនបើសហជីពទាំងនោះ តំណាងឱ្យកម្មករនិយោជិតភាគច្រើននៃសហគ្រាស គ្រឹះស្ថាន ឬ ប្រភេទកម្មករនិយោជិតដែលអនុសញ្ញារួមនោះគ្របដណ្តប់ ។ ក្នុងករណីមានការតវ៉ាអំពីភាពជាតំណាងឱ្យកម្មករនិយោជិតភាគច្រើននៃសហគ្រាស គ្រឹះស្ថាន ការបោះឆ្នោតស្របតាមវិធានដែលមានចែងក្នុងប្រការ៦ ខាងលើត្រូវតែយកមកអនុវត្ត ។

ក្នុងករណី ដែលសហជីពមានសមាជិកភាគតិចទាំងអស់រួមគ្នាទៅ មិនតំណាងឱ្យកម្មករនិយោជិតភាគច្រើននៅក្នុងសហគ្រាស គ្រឹះស្ថាន ឬប្រភេទនៃកម្មករនិយោជិត ដែលគ្របដណ្តប់ដោយអនុសញ្ញារួមនៃការងារនោះទេ និយោជកត្រូវមានកាតព្វកិច្ចធ្វើការចរចាជាមួយសហជីពទាំងនោះ ក្នុងនាមសមាជិកដែលសហជីពទាំងនោះតំណាងឱ្យតែប៉ុណ្ណោះ ។

សហជីពទាំងឡាយដែលមានសិទ្ធិចរចាជាសមូហភាពជាមួយនិយោជក អាចកំណត់ដោយសេរីនូវវិធានទាំងឡាយ ដើម្បីតាក់តែងសេចក្តីព្រាងអនុសញ្ញារួម និងដើម្បីរៀបចំសមាសភាពនៃគណៈកម្មការដែលទទួលបន្ទុកធ្វើការចរចា ។

ក្នុងករណីដែលសហជីពណាមួយ បានទទួលសម្លេងភាគច្រើនដាច់ខាតនៃការបោះឆ្នោតខាងលើ សហជីពនោះត្រូវបានទទួលស្គាល់ជាភ្នាក់ងារផ្តាច់មុខក្នុងការចរចា ដើម្បីតំណាងឱ្យកម្មករនិយោជិតទាំងអស់ដែលទាក់ទងនឹងការចរចានេះ ។

**ប្រការ១០.-** និយោជកដែលមានកាតព្វកិច្ចធ្វើការចរចាជាមួយសហជីព ត្រូវតែចូលរួមប្រជុំជាមួយតំណាងសហជីពដែលជាដៃគូ ។ ក្នុងអំឡុងពេលចរចានេះ តំណាងចរចាមិនត្រូវបានកាត់ប្រាក់ឈ្នួលប្រាក់រង្វាន់ និងផលប្រយោជន៍ផ្សេងៗឡើយ ។

**ប្រការ១១.-** កាតព្វកិច្ចរបស់គ្រប់ភាគីនៃការចរចាជាសមូហភាព ដើម្បីចុះអនុសញ្ញារួមមានជាអាទិ៍ :-

ក-កាតព្វកិច្ចសំរបសំរួលឱ្យមាននីតិវិធីនៃការចរចា ដែលមានលក្ខណៈរៀបរយអាចទទួលយកបាន ។

ខ-កាតព្វកិច្ចធ្វើសម្បទាន និងការជំទាស់ដោយមានការពិនិត្យពិចារណាសមហេតុសមផល ។

គ-កាតព្វកិច្ចរបស់និយោជកក្នុងការផ្តល់ដល់តំណាងសហជីព ឬសហជីពទាំងឡាយនូវមធ្យោបាយសំរាប់បង្កលក្ខណៈងាយស្រួលទាំងឡាយដ៏សមស្រប ដើម្បីអាចបំពេញបេសកកម្ម ក្នុងការចរចារបស់ខ្លួនបាន ។

ឃ-កាតព្វកិច្ចរបស់និយោជកក្នុងការផ្តល់នូវពត៌មានទាំងអស់ពាក់ព័ន្ធ និងការចរចា ដែលបានស្នើឡើងដោយសហជីព ដែលបានចូលរួមក្នុងដំណើរការចរចា ។

**ប្រការ១២.-** ភាគីនៃការចរចាជាសមូហភាពអាចកំណត់ដោយសេរីនូវកាលបរិច្ឆេទដែលត្រូវជួបគ្នា ដើម្បីធ្វើការចរចា ។ កាលបរិច្ឆេទនេះ មិនត្រូវមានថិរវេលាតិចជាង ៣០ថ្ងៃប្រតិទិនឡើយ ។

ការជូនដំណឹងគ្នាទៅវិញទៅមក អំពីកម្មវត្ថុ និងកាលបរិច្ឆេទនៃការចរចាជាសមូហភាព ត្រូវធ្វើតាមសំបុត្រអនុសិដ្ឋ ឬលិខិតជូនផ្ទាល់ដៃ ដែលមានចុះហត្ថលេខាថា បានទទួលហើយ ។

ផុតកាលបរិច្ឆេទដែលបានកំណត់ដំបូង ភាគីនៃការចរចាជាសមូហភាពអាចកំណត់កាលបរិច្ឆេទនេះជាថ្មីតាមបំណងរបស់ខ្លួន ប្រសិនបើគេមិនសំរេចបិទការចរចាគ្នាទេនោះ ។ ក្នុងករណីនេះ មុននឹងធ្វើកូដកម្ម ឬឡុកអៅ បណ្តាភាគីត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងជំពូកទី១២ ស្តីពីការដោះស្រាយវិវាទការងារ និងជំពូកទី១៣ ស្តីពីកូដកម្ម-ឡុកអៅ នៃច្បាប់ស្តីពីការងារ ។

**ប្រការ១៣.-** អនុសញ្ញារួមដែលបានធ្វើនៅថ្នាក់សហគ្រាស គ្រឹះស្ថានមានអានុភាពដូចមានចែងក្នុងជំពូកទី៥ នៃច្បាប់ស្តីពីការងារ ។

**ប្រការ១៤.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ: ៣១៥ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០១

# ប្រកាស
# ស្តីពី
# របៀបគិតអតីតភាពការងារ ដើម្បីកំណត់ចិរវេលាដែលត្រូវ អោយដំណឹងមុនសំរាប់កម្មករនិយោជិត ដែលមិនធ្វើការប្រចាំខែ

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## សំ រេ ច

**ប្រការ១.-** អតីតភាពការងារ ដើម្បីយកមកកំណត់ចិរវេលាដែលត្រូវឱ្យដំណឹងមុន នៅពេលបញ្ឈប់កម្មករនិយោជិត ដែលបានចុះកិច្ចសន្យាការងារមានចិរវេលាមិនកំណត់ និងដែលមិនធ្វើការប្រចាំខែ ត្រូវគិតស្មើនឹងរយៈពេល ដែលកម្មករនិយោជិតនោះជាប់កិច្ចសន្យាជាមួយនិយោជកខ្លួន ទោះបីការអនុវត្តកិច្ចសន្យានោះត្រូវបានព្យួរ ឬកាត់ផ្តាច់ម្តងម្កាលក៏ដោយ ពោលគឺអតីតភាពការងារនេះត្រូវគិតចាប់ពីថ្ងៃចូលធ្វើការដំបូងរហូតដល់ថ្ងៃបញ្ឈប់ពីការងារ ។

**ប្រការ២.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ២០៧ សកអ. ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៣.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ: ៣១៦ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០១

# ប្រកាស
# ស្តីពី
# ការប្រើប្រាស់កម្មករនិយោជិតប្រភេទខ្លះខុសពីម៉ោងធ្វើការរួម

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## សំរេច

**ប្រការ១.-** ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន មានសិទ្ធិប្រើប្រាស់កម្មករនិយោជិតរបស់ខ្លួនខុសពីម៉ោងធ្វើការដែលបានកំណត់ជារួម ។ កម្មករនិយោជិតប្រភេទនេះមានជាអាទិ៍:-

- អ្នកទទួលខុសត្រូវថែទាំគ្រឿងម៉ាស៊ីន និងឋបនភ័ណ្ឌ
- អ្នកទទួលខុសត្រូវបោសសំអាត បំរើភ្ញៀវ បើកបរ និងជួសជុលទីកន្លែងធ្វើការ
- អ្នកទទួលខុសត្រូវយាមកាមសហគ្រាស គ្រឹះស្ថាន ។

**ប្រការ២.-** ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវមានតារាងបញ្ជីឈ្មោះ និងម៉ោងធ្វើការដោយឡែករបស់កម្មករនិយោជិតប្រភេទដូចមានចែងក្នុងប្រការ១ ខាងលើ ដែលត្រូវរក្សាទុកជាប្រចាំសំរាប់ការត្រួតពិនិត្យជាយថាហេតុរបស់អធិការការងារ ។

**ប្រការ៣.-** កម្មករនិយោជិត ប្រភេទដូចមានចែងក្នុងប្រការ ១ ខាងលើ មានសិទ្ធិនឹងអនុវត្តដូចកម្មករនិយោជិតធម្មតាអំពី ថិរវេលាធ្វើការ ការចែកពេលធ្វើការប្រចាំថ្ងៃ ប្រាក់ឈ្នួលពេលធ្វើការបន្ថែមម៉ោង និងការទូទាត់ម៉ោងធ្វើការ ដែលខកខានមិនបានធ្វើ ។

**ប្រការ៤.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ ៩២ សកអ. ចុះថ្ងៃទី ០៦ ខែមីនា ឆ្នាំ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខៈ ៣១៧ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០០១

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការដោះស្រាយវិវាទការងាររួម

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## សំរេច

**ប្រការ១.-** ចំពោះការដោះស្រាយវិវាទការងាររួម បើក្នុងអនុសញ្ញារួម មិនបានគ្រោងនីតិវិធីសំរាប់ការដោះស្រាយទេ គ្រប់រឿងវិវាទត្រូវតែភាគីណាមួយប្តឹងទៅអធិការកិច្ចការងារ ។

នាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ស្ថិតនៅអគារលេខ ២៨ វិថី សម្តេចព្រះធម្មលិខិតអ៊ុក "ផ្លូវលេខ ១៨៤" សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ មានសមត្ថកិច្ចទទួលខុសត្រូវដោះស្រាយវិវាទការងាររួម ដែលកើតមាននៅរាជធានីភ្នំពេញ។

មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង ដទៃទៀត មានសមត្ថកិច្ចទទួលខុសត្រូវដោះស្រាយវិវាទការងាររួម ដែលកើតមាននៅខេត្ត-ក្រុងរៀងៗខ្លួន។

**ប្រការ២.-** ក្រោយពីបានទទួលបណ្តឹងរបស់ភាគីណាមួយ អធិការការងារ ត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីចាត់តាំងអ្នកផ្សះផ្សាម្នាក់ក្នុងរយៈពេល ៤៨ ម៉ោង ។ បន្ទាប់មកអ្នកផ្សះផ្សា ត្រូវធ្វើលិខិតអញ្ជើញទៅភាគីទាំងអស់មកផ្តល់នូវពត៌មាន និងឯកសារជាភស្តុតាងនានា ដើម្បីផ្សះផ្សាវិវាទឱ្យបានសមស្រប ។

ការសាកសួរពត៌មានបន្ថែម ត្រូវធ្វើឡើងមួយភាគីម្តង១ ដាច់ដោយឡែកពីគ្នា ។ គ្រប់ពេលសាកសួរពត៌មានបន្ថែម ត្រូវធ្វើកំណត់ហេតុទុកជាឯកសារ ដោយមានចុះហត្ថលេខាអ្នកផ្សះផ្សា និងភាគីដែលផ្តល់ពត៌មាននោះផង ។

ភាគីទាំងពីរ ត្រូវតែចូលរួមប្រជុំតាមការអញ្ជើញរបស់អ្នកផ្សះផ្សា ។

បើភាគីណាមួយមិនចូលរួមប្រជុំទេនោះ អ្នកផ្សះផ្សា ត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីចាត់វិធានការទៅតាមច្បាប់ស្តីពីការងារ ។

**ប្រការ៣.-** ក្នុងករណីដែលបានទទួលពត៌មានសព្វគ្រប់ពីភាគីទាំងអស់ហើយ អ្នកផ្សះផ្សា ត្រូវធ្វើលិខិតអញ្ជើញម្តងទៀតឱ្យភាគីដែលពាក់ព័ន្ធទាំងអស់ មកចូលរួមប្រជុំជាមួយគ្នា ដើម្បីធ្វើការផ្សះផ្សា ។

ការផ្សះផ្សាត្រូវធ្វើក្នុងរយៈពេល ១៥ថ្ងៃ គិតចាប់ពីពេលបានទទួលសេចក្តីបង្គាប់ពីរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។ ការផ្សះផ្សានេះអាចធ្វើឡើងវិញបាន តែតាមសំណូមពររួមនៃភាគីវិវាទ ។

ភាគីទាំងពីរត្រូវតែចូលរួមប្រជុំតាមការអញ្ជើញរបស់អ្នកផ្សះផ្សា ។ បើភាគីណាមួយមិនចូលរួមប្រជុំទេនោះ អ្នកផ្សះផ្សាត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល-វិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីចាត់វិធានការទៅតាមច្បាប់ស្តីពីការងារ ។

**ប្រការ៤.-** លិខិតអញ្ជើញដែលមានចែងក្នុងប្រការ២ និងប្រការ៣ ខាងលើ ត្រូវផ្ញើជូនភាគីវិវាទតាមសំបុត្រអនុសិដ្ឋ ដែលមានហត្ថលេខាបញ្ជាក់ថា បានទទួលហើយ ឬលិខិតជូនផ្ទាល់ដៃ ដោយមានចុះហត្ថលេខាថា បានទទួល ។

**ប្រការ៥.-** ភាគីវិវាទអាចឱ្យគេជួយអម ឬឱ្យគេតំណាងខ្លួនបាន ។ ជនទាំងឡាយដែលអាចជួយអម ឬធ្វើជាតំណាងរបស់ភាគីវិវាទបាន លុះត្រាតែជនទាំងនោះជាមនុស្សពេញវ័យ ដែលច្បាប់ទទួលស្គាល់ហើយអាចសំរេចកិច្ចការបានផង ។

**ប្រការ៦.-** ត្រូវធ្វើកំណត់ហេតុនៅរាល់ពេលប្រជុំផ្សះផ្សា ដោយមានបញ្ជាក់ច្បាស់លាស់ពីការយល់ព្រម ឬមិនយល់ព្រមសះជានិងគ្នា ។ កំណត់ហេតុនោះ ត្រូវចុះទិដ្ឋាការដោយអ្នកផ្សះផ្សា ព្រមទាំងហត្ថលេខារបស់ភាគីដែលពាក់ព័ន្ធ និងត្រូវចម្លងចែកភាគីទាំងអស់ ។

**ប្រការ៧.-** ការព្រមព្រៀងសះជា ដែលបានចុះហត្ថលេខាដោយភាគី និងបានចុះទិដ្ឋាការដោយអ្នកផ្សះផ្សា មានតម្លៃ និងអនុភាពដូចគ្នានឹងអនុសញ្ញារួមរវាងភាគី និងរវាងអ្នកដែលឱ្យគេតំណាងខ្លួន ។ ប៉ុន្តែ ប្រសិនបើភាគីតំណាងកម្មករនិយោជិត ពុំមែនជាអង្គការសហជីពវិជ្ជាជីវៈណាមួយទេ ការព្រមព្រៀង នេះ មិនជំទាស់ទាំងចំពោះអង្គការសហជីពនោះ ទាំងចំពោះកម្មករនិយោជិតដែលឱ្យគេតំណាងខ្លួន។

**ប្រការ៨.-** ចំពោះវិវាទការងាររួម ដែលភាគីពុំបានប្តឹង ឬឱ្យដំណឹងមកអធិការកិច្ចការងារទេនោះ រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អាចចាត់ការផ្សះផ្សាតាម នីតិវិធីដែលកំណត់ក្នុងប្រការ២ ប្រការ៣ ប្រការ៤ ប្រការ៥ និងប្រការ៦ ខាងលើ ក្រោយពីបាន ដំណឹងពីវិវាទនេះភ្លាម ។

**ប្រការ៩.-** វិវាទការងាររួមណា ដែលមានការប៉ះពាល់ ឬអាចបណ្តាលឱ្យប៉ះពាល់ដល់សន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈ អធិការកិច្ចការងារ ក្រោយពីបានទទួលដំណឹងស្តីពីវិវាទនេះ ត្រូវធ្វើរបាយ-ការណ៍ជាបន្ទាន់ ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីចាត់តាំងអ្នកផ្សះផ្សា និងចាត់ការធ្វើការផ្សះផ្សាភ្លាមៗ ចុះសាកសួរពត៌មាន និងធ្វើការផ្សះផ្សា ដល់ទីកន្លែងតែម្តង ។

**ប្រការ១០.-** បើមានអនុសញ្ញាបានគ្រោងពីនីតិវិធីច្បាស់លាស់សំរាប់ដោះស្រាយវិវាទការងាររួមហើយនោះ វិវាទការងាររួម ត្រូវតែដោះស្រាយតាមនីតិវិធីនៃអនុសញ្ញានេះ ។

**ប្រការ១១.-** ចំពោះវិវាទការងាររួមដែលផ្សះផ្សាមិនព្រមសះជា អ្នកផ្សះផ្សាត្រូវរាយការណ៍ជាបន្ទាន់ ជូន រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីមានវិធានការ ដោះស្រាយបន្ត។ p

**ប្រការ១២.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ៨៦២ សកអ ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ១៩៩៦ និង លេខ ១៤៤ សកអ. ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ១៩៩៧ ត្រូវចាត់ទុកជា និរាករណ៍ ។

**ប្រការ១៣.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខៈ ៣១៨ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០១

# ប្រកាស
# ស្តីពី
# នីតិវិធីនៃការដោះស្រាយវិវាទបុគ្គល

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## សំរេច

**ប្រការ១.-** ក្នុងការដោះស្រាយវិវាទបុគ្គល មុននឹងប្តឹងទៅតុលាការ ភាគីណាមួយអាចប្តឹងជាលាយលក្ខណ៍អក្សរ ទៅអធិការការងារ ដើម្បីធ្វើការផ្សះផ្សាជាមុនសិន។

នាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ស្ថិតនៅអគារលេខ ២៨ វិថីសម្តេចព្រះធម្មលិខិតអ៊ុក "ផ្លូវលេខ១៨៤" សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ មានសមត្ថកិច្ចទទួលខុសត្រូវផ្សះផ្សាវិវាទការងារនៅរាជធានីភ្នំពេញ ។ មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុងដទៃទៀត មានសមត្ថកិច្ចទទួលខុសត្រូវផ្សះផ្សាវិវាទការងារនៅខេត្ត-ក្រុងរៀង១ខ្លួន ។

**ប្រការ២.-** ក្រោយពីបានទទួលបណ្តឹងពីភាគីណាមួយ អធិការការងារ ត្រូវធ្វើលិខិតអញ្ជើញទៅភាគីទាំងអស់មកផ្តល់នូវពត៌មាន និងឯកសារជាភស្តុតាងនានាដែលខ្លួនចង់បាន ដើម្បីផ្សះផ្សាវិវាទឱ្យបានសមស្រប ។

ការសាកសួរពត៌មានបន្ថែមនេះ ត្រូវធ្វើឡើងមួយភាគីម្តងដាច់ដោយឡែកពីគ្នា ។ គ្រប់ពេលសាកសួរពត៌មានបន្ថែម ត្រូវធ្វើកំណត់ហេតុទុកជាឯកសារ ដោយមានចុះហត្ថលេខាអធិការការងារ និងភាគីដែលផ្តល់ពត៌មាននោះផង ។ កំណត់ហេតុនេះត្រូវផ្តល់ជូនភាគីដែលផ្តល់ពត៌មាន ១ ច្បាប់ផង ។

**ប្រការ៣.-** បើភាគីដើមចោទ ឬតំណាងនៃជននេះ មិនព្រមអញ្ជើញទៅផ្តល់ពត៌មានបន្ថែម ជូនអធិការការងារតាមកាលកំណត់ ឬក្នុងរយៈពេលបីថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃកំណត់ "គិតតែថ្ងៃធ្វើការ" ដោយគ្មានមូលហេតុសមស្របទេនោះ ពាក្យប្តឹងនោះត្រូវទុកជាមោឃៈ ។

បើភាគីចុងចោទ ឬតំណាងនៃជននេះ មិនព្រមចូលបង្ហាញខ្លួនតាមកាលកំណត់ ឬក្នុងរយៈពេលបីថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃកំណត់ "គិតតែថ្ងៃធ្វើការ" ដោយគ្មានមូលហេតុសមស្របទេនោះ រឿងវិវាទត្រូវចាត់ទុកថា មិនសះជា ហើយត្រូវចាត់ទុកថា ភាគីចុងចោទមានកំហុសដូចការចោទប្រកាន់របស់ភាគីដើមចោទទាំងស្រុង ។

**ប្រការ៤.-** បន្ទាប់ពីបានទទួលពត៌មានសព្វគ្រប់អស់ហើយ អធិការការងារត្រូវធ្វើលិខិតអញ្ជើញម្តងទៀតឱ្យភាគីទាំងសងខាងចូលរួមប្រជុំជាមួយគ្នា ដើម្បីធ្វើការផ្សះផ្សា ។

អធិការការងារ ត្រូវធ្វើការផ្សះផ្សាវិវាទបុគ្គលក្នុងរយៈពេលបីសប្តាហ៍យ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យប្តឹង ។

ភាគីវិវាទអាចឱ្យគេជួយអម ឬឱ្យគេតំណាងខ្លួនបាន ។

បើភាគីដើមចោទ ឬតំណាងនៃជននេះ មិនចូលរួមប្រជុំតាមការកំណត់ ហើយគ្មានបញ្ជាក់មូលហេតុសមស្របទេនោះ ពាក្យប្តឹងត្រូវចាត់ទុកជាមោឃៈ ។

បើភាគីចុងចោទ ឬតំណាងនៃជននេះ មិនចូលរួមប្រជុំតាមការកំណត់ ហើយគ្មានបញ្ជាក់មូលហេតុសមស្របទេនោះ រឿងវិវាទត្រូវចាត់ទុកថាមិនសះជា ហើយត្រូវចាត់ទុកថា ភាគីចុងចោទមានកំហុសដូចការចោទប្រកាន់របស់ភាគីដើមចោទទាំងស្រុង ។

**ប្រការ៥.-** លិខិតអញ្ជើញដែលមានចែងក្នុងប្រការ២ និងប្រការ៤ ខាងលើ ត្រូវផ្ញើជូនភាគីតាមសំបុត្រអនុសិដ្ឋ ឬលិខិតជូនផ្ទាល់ដៃ ដែលមានចុះហត្ថលេខាបញ្ជាក់ថា បានទទួលហើយ ។

**ប្រការ៦.-** ជនទាំងឡាយនឹងអាចជួយអម ឬធ្វើជាតំណាងរបស់ភាគីវិវាទបាន លុះត្រាតែជននោះជាមនុស្សពេញវ័យដែលច្បាប់ទទួលស្គាល់ ហើយអាចសំរេចកិច្ចការបានផង ។

**ប្រការ៧.-** ត្រូវធ្វើកំណត់ហេតុនៅរាល់ពេលប្រជុំផ្សះផ្សា ដោយមានបញ្ជាក់ច្បាស់លាស់ ពីការយល់ព្រម ឬមិនយល់ព្រមសះជានឹងគ្នា ។ កំណត់ហេតុនោះ ត្រូវចុះហត្ថលេខាដោយអធិការការងារព្រមទាំងហត្ថលេខារបស់ភាគីទាំងសងខាង និងត្រូវចម្លងចែកភាគីផង ។

**ប្រការ៨.-** ការព្រមព្រៀងដែលបានធ្វើនៅចំពោះមុខអធិការការងារ គឺជាការព្រមព្រៀងយកជាការបានចំពោះមុខច្បាប់ ។

**ប្រការ៩.-** ក្នុងករណីមិនសះជា ដោយរាប់ទាំងការមិនសះជា ដែលមានកំណត់ក្នុងប្រការ៣ និងប្រការ៤ ខាងលើផង អធិការការងារត្រូវជំរាបទៅភាគី អំពីសិទ្ធិរបស់ភាគីដើមចោទ ដែលអាចធ្វើពាក្យប្តឹងជាបន្តទៅតុលាការមានសមត្ថកិច្ចទៅតាមបែបបទដែលមានកំណត់ក្នុងច្បាប់ ។

**ប្រការ១០.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ២២ សកអ. ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ១៩៩៤ និងលេខ ១៤៥ សកអ. ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ១៩៩៧ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១១.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខៈ ៣២៨ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០១

# ប្រកាស
# ស្តីពី
# ការតែងតាំងសមាជិកនៃគណៈកម្មការប្រឹក្សាការងារ

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

# សំរេច

**ប្រការ១.-** តែងតាំងសមាជិកពេញសិទ្ធិនៃគណៈកម្មការប្រឹក្សាការងារ នៅអមក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដែលមានសមាសភាពដូចតទៅ :-

| | | |
|---|---|---|
| ១-ឯកឧត្តម អ៊ិត សំហេង | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា | ជាប្រធាន |
| ២-លោក លីវ ប៊ុនហៃ | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៣-លោក ឱក តារារិទ្ធិ | តំណាងក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| ៤-លោក គីម ទូច | តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ជាសមាជិក |
| ៥-លោកស្រីវេជ្ជ.ប្រាក់ ពិសិដ្ឋរង្សី | តំណាងក្រសួងសុខាភិបាល | ជាសមាជិក |

| | | |
|---|---|---|
| ៦-លោក ស៊ឹម ហង្ស | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| ៧-លោកជំទាវ កេត សំអាត | តំណាងក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | ជាសមាជិក |
| ៨-លោក ឡុញ ហ៊ាល | តំណាងក្រសួងបរិស្ថាន | ជាសមាជិក |
| ៩-លោក នួន សុខផល | តំណាងក្រសួងសារធារណៈការ និងដឹកជញ្ជូន | ជាសមាជិក |
| ១០-លោក ឡុង ពៅប្រាជ្ញា | តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ជាសមាជិក |
| ១១-លោក ជួន មុំថុល | តំណាងសហព័ន្ធសហជីពខ្មែរ | ជាសមាជិក |
| ១២-លោក សោម អូន | តំណាងសហព័ន្ធសហជីពកម្មករកម្ពុជា | ជាសមាជិក |
| ១៣-លោក ជា វិជ្ជា | តំណាងសហជីពសេរីកម្មករ | |
| | នៃព្រះរាជាណាចក្រកម្ពុជា | ជាសមាជិក |
| ១៤-លោក រស់ សុក | តំណាងសហព័ន្ធសហជីពឯករាជ្យកម្ពុជា | ជាសមាជិក |
| ១៥-អ្នកស្រី ម៉ម ញឹម | តំណាងសហព័ន្ធសហជីពជាតិ នៃឧស្សាហកម្ម | |
| | វាយនភ័ណ្ឌកាត់ដេរកម្ពុជា | ជាសមាជិក |
| ១៦-លោកប៉ាស្កាលប្រង់ហ្គញ៉ុង | តំណាងសហព័ន្ធពាណិជ្ជករ និង សមាគម | |
| | ពាណិជ្ជកម្មនៅកម្ពុជា | ជាសមាជិក |
| ១៧-លោក យ៉ាំ ស៊ុយសាំង | តំណាងសមាគមពាណិជ្ជកម្ម ហុងកុង ម៉ាកាវ | |
| | ប្រទេសចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា | ជាសមាជិក |
| ១៨-លោក ហ៊ិនរី កុងឈីភីន | តំណាងសមាគមឧស្សាហកម្មឈើកម្ពុជា | ជាសមាជិក |
| ១៩-លោក វ៉ាន់ ស៊ូអៀង | តំណាងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា | ជាសមាជិក |
| ២០-លោក វ៉ាង ស៊ីន | តំណាងសមាគមឧស្សាហកម្មស្បែក | |
| | ជើងនៅកម្ពុជា | ជាសមាជិក។ |

**ប្រការ២.-** តែងតាំងសមាជិកបំរុងនៃគណៈកម្មការប្រឹក្សាការងារ ដែលមានសមាសភាពដូចតទៅ :-

| | | |
|---|---|---|
| ១-លោក ម៉ា វឿន | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិកបំរុង |
| ២-លោក មាន សុភា | តំណាងក្រសួងពាណិជ្ជកម្ម | ជាសមាជិកបំរុង |
| ៣-លោក កែវ សុវត្ថិ | តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ជាសមាជិកបំរុង |
| ៤-លោកវេជ្ជ.ថាច វ៉ារ៉ិន | តំណាងក្រសួងសុខាភិបាល | ជាសមាជិកបំរុង |
| ៥-លោក វ៉ិន លឹម | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ | |
| | និងនេសាទ | ជាសមាជិកបំរុង |
| ៦-លោកស្រី ឯក វីរៈ | តំណាងក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | ជាសមាជិកបំរុង |

| | | |
|---|---|---|
| ៧-លោក ទា ជុប | តំណាងក្រសួងបរិស្ថាន | ជាសមាជិកបំរុង |
| ៨-លោក មាស ម៉ូនីកា | តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន | ជាសមាជិកបំរុង |
| ៩-លោក អន សូផាណារ៉ា | តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ជាសមាជិកបំរុង |
| ១០-លោក ចក់ យ៉ន | តំណាងសហព័ន្ធសហជីពខ្មែរ | ជាសមាជិកបំរុង |
| ១១-លោក លាង ស៊ុនហ៊ាង | តំណាងសហព័ន្ធសហជីពកម្មករកម្ពុជា | ជាសមាជិកបំរុង |
| ១២-លោក សយ សំអុន | តំណាងសហព័ន្ធសហជីពខ្មែរនៃកម្មករសំណង់ និងព្រៃឈើ | ជាសមាជិកបំរុង |
| ១៣-អ្នកស្រី ទេព គីមវណ្ណី | តំណាងសហព័ន្ធសហជីពឯករាជ្យកម្ពុជា | ជាសមាជិកបំរុង |
| ១៤-លោកស្រី កេន ឆេងឡាង | តំណាងសហព័ន្ធសហជីពជាតិនៃឧស្សាហកម្មវាយនភ័ណ្ឌកាត់ដេរកម្ពុជា | ជាសមាជិកបំរុង |
| ១៥-លោកស្រី ឡោ ហ្សូហ្សែត | តំណាងសហព័ន្ធពាណិជ្ជករ និងសមាគមពាណិជ្ជកម្មនៅកម្ពុជា | ជាសមាជិកបំរុង |
| ១៦-លោក លី ហួត | តំណាងសមាគមពាណិជ្ជកម្ម ហុងកុង ម៉ាកាវ ប្រទេសចិនប្រចាំព្រះរាជាណាចក្រកម្ពុជា | ជាសមាជិកបំរុង |
| ១៧-លោក Zhou Xiong Zhi | តំណាងសមាគមឧស្សាហកម្មឈើនៅកម្ពុជា | ជាសមាជិកបំរុង |
| ១៨-លោក គង់ សាង | តំណាងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា | ជាសមាជិកបំរុង |
| ១៩-លោក លីន យូហ៊្វន | តំណាងសមាគមឧស្សាហកម្មស្បែកជើងនៅកម្ពុជា | ជាសមាជិកបំរុង ។ |

**ប្រការ៣.-** ក្នុងករណីដែលឯកឧត្តមរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អវត្តមាន ឬជាប់រវល់កិច្ចការមមាញឹក លោកអាចផ្ទេរសិទ្ធិជូនឯកឧត្តមរដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ឬឯកឧត្តមអគ្គនាយកការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ទទួលភារកិច្ចជាប្រធានស្តីទីនៃគណៈកម្មការប្រឹក្សាការងារ ។

**ប្រការ៤.-** គណៈកម្មការប្រឹក្សាការងារ ត្រូវរួមប្រជុំតាមការកំណត់ និងការអញ្ជើញរបស់ប្រធាន ។

**ប្រការ៥.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខៈ ១០០ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០០២

# ប្រកាស
## ស្តីពី
## ការព្យួរការសំរាកប្រចាំសប្តាហ៍

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## សំរេច

**ប្រការ១.** ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ អាចព្យួរការឈប់សំរាកប្រចាំសប្តាហ៍របស់កម្មករនិយោជិតបាន ក្នុងករណីដូចមានចែងក្នុងមាត្រា១៥១ នៃច្បាប់ស្តីពីការងារ ។

**ប្រការ២.** នៅក្នុងសហគ្រាស គ្រឹះស្ថានខ្លះ និយោជកអាចកាត់បន្ថយការឈប់សំរាកប្រចាំសប្តាហ៍របស់កម្មករនិយោជិតចំនួន ២ថ្ងៃក្នុងមួយខែ ដើម្បីទូទាត់ថ្ងៃធ្វើការមិនកើតកន្លងទៅ ដែលបណ្តាលមកពីអាកាសធាតុមិនល្អ ។ សហគ្រាស គ្រឹះស្ថាន ប្រភេទនេះមានដូចតទៅ :-

- សហគ្រាស គ្រឹះស្ថាន បំរើការងារសាធារណៈដូចជា ការងារបោសសំអាត ឬប្រមូលសំរាម នៅតាមថ្នល់ ទីលានសាធារណៈ ការងារជួសជុលធ្វើថ្នល់ ឬលូទឹក
- សហគ្រាស គ្រឹះស្ថាន បំរើការងារជួសជុល ឬតបំពង់ទឹក ឬបំពង់ឧស្ម័ន ជួសជុល ឬប្រក់ដំបូលផ្ទះ ឬអគារ
- សហគ្រាស គ្រឹះស្ថាន សំណង់ ចំពោះការងារដែលប្រព្រឹត្តទៅនៅផ្នែកខាងក្រៅនៃអគារ
- សហគ្រាស គ្រឹះស្ថាន ឡឥដ្ឋ ចំពោះការងារដែលប្រព្រឹត្តទៅនៅកណ្ដាលវាល
- សហគ្រាស គ្រឹះស្ថាន កាយយករ៉ែ ចំពោះការងារដែលប្រព្រឹត្តទៅនៅកណ្ដាលវាល
- សហគ្រាស គ្រឹះស្ថាន ដឹកជញ្ជូនតាមផ្លូវទឹក
- ភោជនីយដ្ឋាន និងកន្លែងលក់ដូរដែលប្រព្រឹត្តទៅនៅកណ្ដាលវាល
- សហគ្រាស គ្រឹះស្ថាន បេះ ឬប្រមូលផ្លែឈើ ឬបន្លែ
- សហគ្រាស គ្រឹះស្ថាន ចិញ្ចឹមសត្វសន្ទានខ្សែ ខ្ចៅ ឬត្រី
- សហគ្រាស គ្រឹះស្ថាន ផលិតទឹកត្រី ឬអំបិល
- សហគ្រាស គ្រឹះស្ថាន ធ្វើប្រកកំប៉ុងនូវផ្លែឈើ បន្លែ ឬត្រី
- សហគ្រាស គ្រឹះស្ថាន លើកដាក់ផលិតផល ឬវត្ថុធាតុដែលឆាប់ខូច
- សហគ្រាស គ្រឹះស្ថាន កសិកម្ម និងនេសាទ ។

ការធ្វើការសងនៅថ្ងៃឈប់សំរាកប្រចាំសប្ដាហ៍ ចំពោះប្រភេទសហគ្រាស គ្រឹះស្ថាន ដូចបានរៀបរាប់ខាងលើ ត្រូវអនុវត្តក្នុងខែ បន្ទាប់ពីថ្ងៃធ្វើការមិនកើតដោយអាកាសធាតុមិនល្អ ។ ករណីត្រូវធ្វើការសងពីរថ្ងៃ ថ្ងៃទាំងពីរនេះ មិនត្រូវជាថ្ងៃឈប់សំរាកប្រចាំសប្ដាហ៍ពីរដែលជាប់គ្នាឡើយ ។

**ប្រការ៣.-** ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានដទៃទៀត ក៏អាចព្យួរការឈប់សំរាកប្រចាំសប្ដាហ៍របស់កម្មករនិយោជិតបានដែរ ។ ការព្យួរនេះ បើមានចំនួន ២ថ្ងៃក្នុងមួយខែ មិនត្រូវជាថ្ងៃឈប់សំរាកប្រចាំសប្ដាហ៍ពីរដែលជាប់គ្នាឡើយ ។

**ប្រការ៤.-** នៅមុនពេលដាក់ឱ្យកម្មករនិយោជិត ធ្វើការនៅថ្ងៃឈប់សំរាកប្រចាំសប្ដាហ៍ ដូចមានចែងក្នុងប្រការ១ ប្រការ២ ប្រការ៣ ខាងលើ និយោជកត្រូវស្នើសុំសេចក្ដីអនុញ្ញាតពីអធិការការងារ "ដោយបញ្ជាក់ពីមូលហេតុនៃការព្យួរការឈប់សំរាកប្រចាំសប្ដាហ៍នេះ កាលបរិច្ឆេទ និងថិរវេលានៃការព្យួរចំនួនកម្មករនិយោជិត ដែលមិនបានឈប់សំរាក ព្រមទាំងបែបបទនៃការឈប់សំរាកសងដោយទូទាត់វិញក្នុងរយៈពេល ៣០ថ្ងៃ" ។ អធិការការងារត្រូវជូនដំណឹងដល់និយោជក ដែលសុំការអនុញ្ញាតនោះ អំពីការសំរេចរបស់ខ្លួនក្នុងរយៈពេល ៤ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ បើមិនដូច្នេះទេ ពាក្យសុំការអនុញ្ញាតិ នឹងត្រូវចាត់ទុកថាបានយល់ព្រមហើយ ។

**ប្រការ៥.-** កម្មករនិយោជិតដែលធ្វើការនៅថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ ត្រូវបានប្រាក់ឈ្នួលស្មើនឹងពីរដង នៃប្រាក់ឈ្នួលថ្ងៃធ្វើការធម្មតា ។

**ប្រការ៦.-** ក្នុងករណីប្រធានស័ក្តិ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន អាចព្យួរការឈប់សំរាកប្រចាំសប្តាហ៍របស់កម្មករនិយោជិត ដោយពុំចាំបាច់ស្នើសុំការអនុញ្ញាតិជាមុនពីអធិការការងារឡើយ ។

**ប្រការ៧.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ៩១ សកអ. ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ១៩៩៨ និងលេខ ២០៩ សកអ. ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៨.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**
**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**
**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ: ១៤២ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០២

# ប្រកាស
# ស្តីពី
# ការបែងចែកម៉ោងធ្វើការក្នុងសប្តាហ៍ ដើម្បីអោយបានឈប់សំរាក បន្ថែមនារសៀលថ្ងៃសៅរ៍

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## ស ម្រ េ ច

**ប្រការ១.-** ដើម្បីឱ្យបានឈប់សំរាកនារសៀលថ្ងៃសៅរ៍ បន្ថែមលើការឈប់សំរាកប្រចាំសប្តាហ៍ជាធម្មតានៅថ្ងៃអាទិត្យ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ អាចរៀបចំឱ្យកម្មករនិយោជិតធ្វើការតែប្រាំថ្ងៃកន្លះក្នុងមួយសប្តាហ៍ ។ ក្នុងករណីនេះ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន អាចបង្កើនថិរវេលាធ្វើការពេញលេញរបស់កម្មករនិយោជិតដល់ប្រាំបួនម៉ោងជាអតិបរមាក្នុងមួយថ្ងៃ ។

**ប្រការ២.-** ក្នុងការបែងចែកម៉ោងធ្វើការថ្មីនេះ បើការងារក្នុងសហគ្រាស គ្រឹះស្ថានបានរៀបចំឡើងជាពីរវេនបន្តបន្ទាប់គ្នា វេនទីមួយត្រូវបានសំរាកបន្ថែមនារសៀលថ្ងៃសៅរ៍ ហើយវេនទីពីរត្រូវបានសំរាកបន្ថែមនាព្រឹកថ្ងៃចន្ទ័នៃសប្តាហ៍បន្ទាប់ ។

**ប្រការ៣.-** ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានដែលមានបំណងបែងចែកម៉ោងធ្វើការរបៀបខាងលើត្រូវមានការឯកភាពជាមុនជាមួយសហជីពដែលមានភាពជាតំណាង និងប្រតិភូបុគ្គលិក ឬជាមួយចំនួនពាក់កណ្តាលនៃកម្មករនិយោជិត តាមរយៈការបោះឆ្នោតជាសំងាត់ បើសហគ្រាស គ្រឹះស្ថានគ្មានប្រតិភូបុគ្គលិក និងសហជីព ។

**ប្រការ៤.-** បើមានការឯកភាពជាមួយសហជីព ដែលមានភាពជាតំណាង និងប្រតិភូបុគ្គលិក ឬកម្មករនិយោជិតរួចហើយ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន អាចអនុវត្តម៉ោងធ្វើការថ្មីមួយថ្ងៃ បន្ទាប់ពីបានបិទផ្សព្វផ្សាយការបែងចែកម៉ោងធ្វើការថ្មីនេះនៅក្នុងសហគ្រាស គ្រឹះស្ថាន ។ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវជូនដំណឹងដល់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិ-សម្បទា ខេត្ត-ក្រុងនៃមូលដ្ឋានខ្លួន ឬនាយកដ្ឋានអធិការកិច្ចការងារ បើសិនជាសហគ្រាស គ្រឹះស្ថាននោះស្ថិតនៅរាជធានីភ្នំពេញ នៅមុនពេលអនុវត្តម៉ោងធ្វើការថ្មីនេះ ។

**ប្រការ៥.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ៨៩ សកអ. ចុះថ្ងៃទី ០៦ ខែមីនា ឆ្នាំ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

p **រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ: ១៤៣ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០២

# ប្រកាស
# ស្តីពី
# ការបែងចែកម៉ោងធ្វើការក្នុងរយៈពេលក្រៅពីសប្តាហ៍ធម្មតា ដោយគិតជាមធ្យមចំនួន ១២ សប្តាហ៍បន្តបន្ទាប់

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## សំរេច

**ប្រការ១.-** ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួល ឬសេចក្តីត្រូវការជាចាំបាច់ក្នុងផលិតកម្ម ឬសេវាកម្ម ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ អាចបែងចែកម៉ោងធ្វើការក្នុងរយៈពេលក្រៅពីសប្តាហ៍ធម្មតា ដោយយកចំនួនជាមធ្យម ១២សប្តាហ៍បន្តបន្ទាប់មកគិត ។

**ប្រការ២.-** ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ដែលចង់បែងចែកម៉ោងធ្វើការតាមរបៀបខាងលើនេះ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោមនេះ :-

- ថិរវេលាធ្វើការគិតជាមធ្យមក្នុងរយៈពេល ១២ សប្តាហ៍បន្តបន្ទាប់មិនត្រូវលើសពី ៤៨ម៉ោងក្នុងមួយសប្តាហ៍

- ចិរវេលាធ្វើការប្រចាំថ្ងៃ មិនត្រូវលើសពីដប់ម៉ោង

- ការពន្យារចិរវេលាធ្វើការ មិនត្រូវឱ្យលើសពីមួយម៉ោងក្នុងមួយថ្ងៃ ។

**ប្រការ៣.-** ក្រៅពីលក្ខខណ្ឌដូចមានចែងក្នុងប្រការ២ខាងលើ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវៈ-

- ពិភាក្សាឯកភាពជាមុនជាមួយសហជីពដែលមានភាពជាតំណាង និងជាមួយប្រតិភូបុគ្គលិក ឬចំនួនពាក់កណ្តាលនៃកម្មករនិយោជិតយ៉ាងតិច ចំពោះសហគ្រាស គ្រឹះស្ថាន ដែលគ្មានប្រតិភូបុគ្គលិក និងសហជីព

- ធានាការដឹកជញ្ជូនកម្មករនិយោជិត ពីលំនៅដ្ឋាន ឬទីជិតខាងនៃលំនៅដ្ឋានរបស់កម្មករនិយោជិតទៅកន្លែងធ្វើការ និងត្រឡប់វិញ បើការធ្វើដំណើររបស់កម្មករនិយោជិតប្រព្រឹត្តទៅនៅពេលយប់

- ប្រើឧបករណ៍ស្វ័យប្រវត្តិ ដើម្បីចុចសលាកប័ត្រម៉ោងចេញ ចូលធ្វើការរបស់កម្មករនិយោជិតព្រមទាំងរក្សាទុកសលាកប័ត្រនេះរយៈពេលបីឆ្នាំ សំរាប់ការត្រួតពិនិត្យមើលជាយថាហេតុរបស់អធិការការងារ និងតុលាការការងារ ឬតុលាការអាជ្ញាកត្តិ បើមិនទាន់មានតុលាការការងារ

- បិទផ្សាយម៉ោងធ្វើការថ្មីនៅក្នុងសហគ្រាស គ្រឹះស្ថាន និងត្រូវជូនដំណឹងដល់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង នៃមូលដ្ឋានខ្លួន ឬនាយកដ្ឋានអធិការកិច្ចការងារ បើសហគ្រាស គ្រឹះស្ថានស្ថិតនៅរាជធានីភ្នំពេញ យ៉ាងហោចណាស់ប្រាំពីរថ្ងៃមុនការដាក់ឱ្យអនុវត្តម៉ោងធ្វើការថ្មីនេះ ។

**ប្រការ៤.-** ម៉ោងធ្វើការដែលលើសពី ៤៨ ម៉ោងក្នុងមួយសប្តាហ៍ ត្រូវផ្តល់ប្រាក់ឈ្នួលតាមអត្រាតម្លើងដែលបានកំណត់ដោយមាត្រា១៣៩ នៃច្បាប់ស្តីពីការងារ និងប្រកាសលេខ ៨០សកបយ. ចុះថ្ងៃទី០១ ខែ មីនា ឆ្នាំ១៩៩៩ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

**ប្រការ៥.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ ៩០សកអ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ: ១៤៤ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០២

# ប្រកាស
# ស្តីពី
# បដិប្បញ្ញត្តិចំពោះការហាមឃាត់មិនអោយប្រើក្មេងធ្វើការពេលយប់

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## សំរេច

**ប្រការ១.-** ក្មេងដែលមានអាយុពី ១៦ ឆ្នាំទៅក្រោម ១៨ ឆ្នាំ អាចប្រើអោយធ្វើការនៅពេលយប់បាននៅក្នុងរោងចក្រស្លដែក និងដែកថែប រោងចក្រធ្វើកែវ រោងចក្រធ្វើក្រដាស រោងចក្រធ្វើស្ករ និងរោងចក្របំបែករ៉ែមាស ដែលត្រូវដើរឥតឈប់ទាំងយប់ទាំងថ្ងៃ ។ ការប្រើក្មេងឱ្យធ្វើការពេលយប់នៅក្នុងរោងចក្រទាំងនេះមានគោលបំណងតែមួយគឺ ដើម្បីផ្តល់ការហ្វឹកហ្វឺន ឬបណ្តុះបណ្តាល-វិជ្ជាជីវៈ ដល់ក្មេងតែប៉ុណ្ណោះ ។

**ប្រការ២.-** ក្នុងគ្រប់ករណីទាំងអស់ថិរវេលាធ្វើការប្រចាំថ្ងៃរបស់ក្មេង មិនអាចលើសពី ៨ ម៉ោងក្នុងមួយថ្ងៃ ហើយការសំរាករបស់ក្មេងនៅចន្លោះពីម៉ោងធ្វើការមួយទៅម៉ោងធ្វើការមួយទៀត ត្រូវមានថិរវេលាយ៉ាងហោចណាស់ ១៣ ម៉ោងជាប់គ្នា ។

**ប្រការ៣.-** និយោជកដែលចង់ប្រើក្មេងពេលយប់ ត្រូវសុំការអនុញ្ញាតជាមុនពីអធិការការងារ ។ បន្ទាប់ពីបានទទួលពាក្យស្នើសុំហើយ អធិការការងារត្រូវធ្វើការសំរេច តាមករណីក្មេងនិមួយៗដោយផ្អែកតាមមូលហេតុនៃការប្រើក្មេង ថិរវេលាធ្វើការ និងការសំរាករបស់ក្មេង ព្រមទាំងវិញ្ញាបនប័ត្រកាយសម្បទារបស់ក្មេងដែលចេញដោយគ្រូពេទ្យការងារផង ។

**ប្រការ៤.-** នៅក្នុងគ្រឹះស្ថាន សហគ្រាសទាំងអស់ ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ និយោជកអាចប្រើក្មេងប្រុសអាយុពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ឱ្យធ្វើការនៅពេលយប់បាន ដើម្បីជួយបង្ការគ្រោះថ្នាក់ដែលអាចនឹងកើតមាន ឬដើម្បីជួសជុលគ្រឿងចក្រ បរិក្ខា ឬសម្ភារៈ ដែលខូចខាតបណ្តាលមកពីមានគ្រោះថ្នាក់កន្លងមកហើយ ។ និយោជកដែលចង់ប្រើក្មេងក្នុងគោលបំណងខាងលើ ត្រូវជូនដំណឹងឱ្យអធិការការងារបានដឹងជាមុនអំពីមូលហេតុនៃការធ្វើបដិប្បញ្ញត្តិនេះ ។

**ប្រការ៥.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ ២៩៨ សកអ. ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៦.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ: ១៤៥ សកបយ.

រាជធានីភ្នំពេញ . ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០២

# ប្រកាស
## ស្តីពី
## ការហ្វឹកហ្វឺនវិជ្ជាជីវៈដល់ក្មេងសំរាប់ធ្វើការក្រោមដី

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

p

## សំរេច

**ប្រការ១.-** ក្មេងអាយុពី១៦ ឆ្នាំ ទៅក្រោម ១៨ឆ្នាំ អាចប្រើឱ្យធ្វើការនៅអណ្តូងរ៉ែ ឬការយករ៉ែ ឬយកថ្មក្រោមដីបាន តែក្នុងគោលបំណងហ្វឹកហ្វឺនវិជ្ជាជីវៈ និង ជួយឱ្យក្មេងមានទម្លាប់ទៅនឹងមុខរបរនាពេលអនាគតរបស់ខ្លួនប៉ុណ្ណោះ ។ ការប្រើក្មេងក្នុងមុខរបរប្រភេទនេះ ត្រូវស្ថិតក្រោមលក្ខខណ្ឌយ៉ាងតឹងរឹង ដូចមានចែងក្នុងប្រការខាងក្រោម ។

**ប្រការ២.-** មុននឹងចូលធ្វើការ ក្មេងត្រូវទទួលការពិនិត្យកាយសម្បទាយ៉ាងម៉ត់ចត់ពីគ្រូពេទ្យការងារ រួមបញ្ចូលទាំងការថតសួតដោយវិទ្យុផង ។ ចំណាយលើការពិនិត្យកាយសម្បទាគឺជាបន្ទុករបស់និយោជក ។ វិញ្ញាបនប័ត្រកាយសម្បទាដែលចេញដោយគ្រូពេទ្យការងារ ត្រូវរក្សាទុកដោយនិយោជក និងត្រូវបង្ហាញជូនអធិការការងារ ឬអធិការពេទ្យការងារតាមសំណើ ។ ការពិនិត្យកាយសម្បទានេះ ត្រូវធ្វើឡើងវិញរៀងរាល់រយៈពេល ៦ ខែ ។

ប្រការ៣.- និយោជកត្រូវមានសៀវភៅបញ្ជីសំរាប់ក្មេងដោយឡែកដែលក្នុងនោះត្រូវបញ្ជាក់ច្បាស់អំពីៈ

- អាយុរបស់ក្មេង
- កាលបរិច្ឆេទនៃការចុះក្រោមដីលើកទីមួយ
- ថិរវេលាសំរាកប្រចាំសប្តាហ៍
- ថិរវេលាសំរាកប្រចាំឆ្នាំ ។

ប្រការ៤.- មុននឹងចុះទៅធ្វើការក្រោមដី ក្មេងត្រូវទទួលការបណ្តុះបណ្តាលពិសេសដោយគ្រូស្ទាត់ជំនាញ អំពីៈ-

- គ្រោះថ្នាក់ដែលអាចកើតមានចំពោះសុខភាព និងសន្តិសុខការងារនៅក្រោមដី
- ការសង្គ្រោះបន្ទាន់
- វិធានការការពារគ្រោះថ្នាក់ ការប្រើប្រាស់បរិក្ខាសុវត្ថិភាព និងសេចក្តីណែនាំអំពីសន្តិ-សុខការងារ ។

ប្រការ៥.- ក្មេងដែលធ្វើការក្រោមដី ត្រូវតែស្ថិតក្រោមការដឹកនាំរបស់គ្រូបង្ហាត់ដែលមានការទទួលខុសត្រូវខ្ពស់ ។ ក្នុងករណីនេះក្មេងអាចជួយការងារក្នុងក្រុម ដើម្បីឱ្យមានទម្លាប់ទៅនឹងមុខរបរនាពេលអនាគតរបស់ខ្លួន ប៉ុន្តែពេលវេលាហ្វឹកហ្វឺនពិតប្រាកដ យ៉ាងហោចណាស់ក៏ត្រូវស្មើនឹងពាក់កណ្តាលនៃពេលវេលាធ្វើការទាំងអស់របស់ក្មេងនៅក្រោមដីដែរ ។

ប្រការ៦.- ក្មេងដែលធ្វើការក្រោមដីមិនត្រូវទុកឱ្យធ្វើការដោយគ្មានការឃ្លាំមើលឡើយ ។ ហាមឃាត់មិនឱ្យប្រើក្មេងកាន់ឧបករណ៍គ្រឿងយន្តណា ឬប្រើប្រាស់នូវរបៀបធ្វើអាជីវកម្មណា ដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់ក្មេង ។

ប្រការ៧.- ក្មេងមិនអាចធ្វើការនៅក្រោមដីលើសពី ៤០ម៉ោងក្នុងមួយសប្តាហ៍ ឬ ៨ ម៉ោងក្នុងមួយថ្ងៃឡើយ ។

ប្រការ៨.- ក្មេងដែលធ្វើការក្រោមដីត្រូវបានឈប់សំរាកប្រចាំសប្តាហ៍ ដែលមានថិរវេលាយ៉ាងហោចណាស់ ៤៨ ម៉ោងជាប់ គិតរួមបញ្ចូលទាំងថ្ងៃអាទិត្យ និង មានសិទ្ធិឈប់សំរាកប្រចាំឆ្នាំចំនួន ២៤ ថ្ងៃ បើបានធ្វើការជាប់ក្នុងមួយឆ្នាំ ទោះបីជាការធ្វើការនៅក្រោមដីមានលក្ខណៈមិនពេញពេលក៏ដោយ ។

ប្រការ៩.- ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ២៩៧ សកអ. ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ១០.- ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ**
**និងយុវនីតិសម្បទា**

លេខៈ ១៤៧ សកបយ.

រាជធានីភ្នំពេញ . ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០២

# ប្រកាស
# ស្តីពី
# បរិយាកាសកំដៅក្នុងទីកន្លែងធ្វើការ

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## <u>សំរេច</u>

**ប្រការ១.-** និយោជកនៃសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវរៀបចំយ៉ាងណាឱ្យបរិយាកាសកំដៅក្នុងទីកន្លែងធ្វើការស្ថិតនៅក្នុងកំរិតដែលអាចទទួលយកបាន ។ បរិយាកាសកំដៅនេះ ត្រូវឱ្យសមស្របទៅនឹងសុខភាពនៃអ្នកធ្វើការ ហើយមិនបង្កឱ្យមានការរំខានដល់ការងាររបស់គេទាំងពួង ។ បរិយាកាសកំដៅនេះ ត្រូវបានត្រួតពិនិត្យដោយសីតុណ្ហមាត្រ "កែវស្ទង់កំដៅ" ដែលដាក់នៅកន្លែងធ្វើការ ។

**ប្រការ២.-** អគារ ឬរោងជាង ត្រូវឱ្យមានមាឌ ១០ ម៉ែត្រត្រីគុណយ៉ាងតិច ក្នុងលក្ខខណ្ឌធម្មតាសំរាប់កម្មករនិយោជិតម្នាក់ៗ ។ ទីកន្លែងធ្វើការត្រូវបង្ខាំងឱ្យដាច់ពីកំដៅខ្លាំងនៃពន្លឺព្រះអាទិត្យ ។ របៀប

ផលិតដែលមិនបញ្ចេញកំដៅ គួរទទួលយកជាឯកសិទ្ធិ ។ ប្រសិនបើការផលិតបញ្ចេញកំដៅខ្លាំង និយោជកត្រូវកាត់បន្ថយកំដៅនោះ ដោយ :-

- រុំភ្ជិត ឬបង្ខាំងបរិក្ខាការងារដែលបញ្ចេញកំដៅ ( ដូចជាប្រពន្ធ័នាំចំហាយជាដើម )
- ស្រូបយកកំដៅ និង បញ្ចេញសកំដៅតាំងពីដើមប្រភព ។

**ប្រការ៣.-** ក្នុងករណីដែលទីកន្លែងធ្វើការមានកំដៅឡើងខ្លាំង ធ្វើឱ្យប៉ះពាល់ដល់សុខភាព ឬធ្វើឱ្យទើសទាល់ដល់ការងាររបស់កម្មករនិយោជិត និយោជកត្រូវរកគ្រប់មធ្យោបាយដើម្បីធ្វើឱ្យទីកន្លែងធ្វើការបានត្រជាក់វិញ ដូចជាដាក់កង្ហារ ម៉ាស៊ីនស្រូបខ្យល់ ឬម៉ាស៊ីនត្រជាក់ជាដើម ។

**ប្រការ៤.-** កម្មករនិយោជិតដែលធ្វើការនៅទីកន្លែងដែលមានបរិយាកាសត្រជាក់ខ្លាំង ត្រូវមានសិទ្ធិទទួលបាននូវមធ្យោបាយទប់ទល់នឹងធាតុត្រជាក់ដូចជា ខោអាវក្រាស់ មួក ស្រោមដៃ ជាដើម ។

**ប្រការ៥.-** អ្នកប្រព្រឹត្តិល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោសដូចមានចែងក្នុងជំពូកទី ១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៦.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ: ២៤៣ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ២០០២

# ប្រកាស
# ស្តីពី
# ការជូនដំណឹងគ្រោះថ្នាក់ការងារ របៀបផ្តល់តាមកាលកំណត់ និង អត្រាបាត់បង់សមត្ថភាពការងារ

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## សំរេច

**ប្រការ១.-** នាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សិប្បកម្ម កសិកម្ម សេវាកម្ម សហគ្រាសដឹកជញ្ជូនតាមផ្លូវគោក ឬតាមផ្លូវទឹក ទោះជាប្រយោជន៍សាធារណៈ ពាក់កណ្តាលសាធារណៈ ឬឯកជន ក្រៅសាសនា ឬក្នុងសាសនា ទោះមានលក្ខណៈជាការបង្រៀនវិជ្ជាជីវៈ ឬជាការកុសល ព្រមទាំងវិជ្ជាជីវៈសេរីនៃសមាគម ឬក្រុមហ៊ុនប្រភេទណាក៏ដោយ ត្រូវប្រកាសជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីគ្រោះថ្នាក់ការងារ ដែលបានធ្លាក់លើរូបកាយកម្មករនិយោជិតរបស់ខ្លួន ។

ការប្រកាសជូនដំណឹងនេះ ត្រូវធ្វើទៅនាយកដ្ឋានសន្តិសុខសង្គម នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ប្រសិនបើសហគ្រាសនោះមានទីតាំងនៅក្នុងទីក្រុងភ្នំពេញ ។ ចំពោះសហគ្រាសដែលមានទីតាំងនៅក្នុងខេត្ត-ក្រុងដទៃផ្សេងទៀត និយោជក ឬម្ចាស់សហគ្រាសនោះ ត្រូវប្រកាសជូនដំណឹងអំពីគ្រោះថ្នាក់ការងារទៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះ-បណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទានៃខេត្ត-ក្រុង ដែលសហគ្រាសនោះតាំងនៅ ។

**ប្រការ២.-** ការប្រកាសជូនដំណឹងអំពីគ្រោះថ្នាក់ការងារ ត្រូវធ្វើតាមសំបុត្រអនុសិដ្ឋ ឬសំបុត្រជូនផ្ទាល់ដៃ ដោយមានបញ្ជាក់ថាបានទទួលហើយក្នុងរយៈពេលយ៉ាងយូរបំផុតសែសិបប្រាំបីម៉ោង បន្ទាប់ពីពេលមានគ្រោះថ្នាក់ដោយមិនគិតថ្ងៃឈប់សំរាក ឬថ្ងៃបុណ្យ ។

គំរូនៃសេចក្តីជូនដំណឹងអំពីគ្រោះថ្នាក់ការងារ មានកំណត់ក្នុងឧបសម្ព័ន្ធទី ១ នៃប្រកាសនេះ ។

**ប្រការ៣.-** កម្មករនិយោជិតដែលទទួលរងគ្រោះថ្នាក់ការងារក៏ត្រូវមានកាតព្វកិច្ចជូនដំណឹងដល់និយោជក ឬ អ្នកតំណាងពេញច្បាប់របស់និយោជកអំពីគ្រោះថ្នាក់ការងារដែលបានធ្លាក់មកលើខ្លួនក្នុងរយៈពេលយ៉ាងយូរបំផុតម្ភៃបួនម៉ោង បន្ទាប់ពីឧប្បត្តិហេតុកើតឡើង ។ ទោះជាយ៉ាងនេះក្តី កាតព្វកិច្ចនេះអាចលើកលែងបាន ក្នុងករណីប្រធានសក្តិ ឬករណីដែលខ្លួនខ្វះលទ្ធភាពទាំងស្រុង ដើម្បីធ្វើការជូនដំណឹង ឬក៏ការមានមូលហេតុសមហេតុសមផលណាមួយផ្សេងទៀត ។

ការជូនដំណឹងដែលតំណាងកម្មករនិយោជិត ប្រធានក្រុម និង កម្មករនិយោជិត ធ្វើជូនទៅនិយោជក ឬអ្នកតំណាងនិយោជករបស់ខ្លួននោះ ត្រូវចម្លងជូននាយកដ្ឋានសន្តិសុខសង្គម ឬមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុងផង ។

ក្នុងករណីដែលមិនអាចជូនដំណឹងដោយផ្ទាល់នៅនឹងកន្លែងកើតហេតុ ដូចជាក្នុងករណីគ្រោះថ្នាក់នៅពេលធ្វើដំណើរ ដែលច្បាប់បានកំណត់ថាជាគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ពេលបំពេញបេស-កកម្មជាដើម សេចក្តីជូនដំណឹងនេះអាចធ្វើបានតាមរយៈសំបុត្រអនុសិដ្ឋ ។

**ប្រការ៤.-** ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ដែលកើតឡើងដោយធ្វើការ ឬក្នុងពេលធ្វើការ ទោះដោយហេតុយ៉ាងណាក៏ដោយ ហើយទោះបីមានកំហុសមកពីកម្មករនិយោជិត ឬគ្មានក៏ដោយ គឺគ្រោះថ្នាក់ដែលធ្លាក់លើរូបកាយកម្មករនិយោជិតក្នុងពេលធ្វើការឱ្យនិយោជក ឬនាយកសហគ្រាស ឬធ្លាក់លើសិស្សវិជ្ជាជីវៈ មានឈ្នួលក្តី ឥតឈ្នួលក្តី កាន់មុខងារជាអ្វី នៅទីកន្លែងណាក៏ដោយ ។

ម្យ៉ាងទៀតត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារដែរ ចំពោះគ្រោះថ្នាក់ណាដែលធ្លាក់លើកម្មករនិយោជិតក្នុងពេលដែលសាមីខ្លួនធ្វើដំណើរពីលំនៅស្ថានខ្លួនត្រង់ឆ្ពោះទៅទីកន្លែងធ្វើការ ឬពីកន្លែងធ្វើការទៅកន្លែងបើកប្រាក់ឈ្នួល ឬវិលមកវិញដោយគ្មានឈប់ ឬវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ឬក្រៅពីការងារដែលគេតម្រូវឱ្យទៅ ។

ជំងឺបណ្ដាលមកពីវិជ្ជាជីវៈទាំងអស់ដូចមានកំណត់ក្នុងច្បាប់ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ ។

**ប្រការ៥.**~ នៅពេលមានគ្រោះថ្នាក់ការងារកើតឡើង និយោជក ម្ចាស់សហគ្រាស នាយកដ្ឋានសន្តិសុខសង្គម មន្ទីរសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត-ក្រុង ត្រូវមានភារកិច្ចចំពោះមុខដូចតទៅ :-

**ក~ចំពោះនិយោជក ឬម្ចាស់សហគ្រាសៈ**

- ចាត់ឱ្យមានការសង្គ្រោះជាបន្ទាន់ដល់ជនរងគ្រោះតាមគ្រប់មធ្យោបាយ
- ជូនដំណឹងទៅក្រសួងមានសមត្ថកិច្ច
- រក្សាសភាពដើមនៃទីកន្លែងកើតហេតុ "ចំពោះគ្រោះថ្នាក់ធ្ងន់ ឬគ្រោះថ្នាក់បណ្ដាលឱ្យស្លាប់មនុស្ស"
- ក្នុងករណីតម្រូវឱ្យមានការផ្លាស់ប្ដូរសភាពដើមនៃកន្លែងគ្រោះថ្នាក់ ដោយសារការសង្គ្រោះ ត្រូវធ្វើកំណត់ហេតុ និង ថតទុកជាឯកសារ
- ផ្ដល់ឯកសារដែលពាក់ព័ន្ធឱ្យបានគ្រប់គ្រាន់ដល់គណៈកម្មការអង្កេត
- បង្កលក្ខណៈងាយស្រួលដល់ជន ដែលបានដឹងអំពីហេតុការណ៍គ្រោះថ្នាក់ ដើម្បីជនទាំងនោះអាចរាយការណ៍ជូនគណៈកម្មការអង្កេត
- ធានារ៉ាប់រងគ្រប់ការចំណាយទាំងអស់នៃការអង្កេត ចំពោះតែការវិភាគបច្ចេកទេស
- អនុវត្តឱ្យបានត្រឹមត្រូវនូវវិធានការដែលបានចុះនៅក្នុងកំណត់ហេតុ ។

**ខ~ចំពោះនាយកដ្ឋានសន្តិសុខសង្គមៈ**

- ជូនដំណឹងជាបន្ទាន់ទៅនាយកដ្ឋានពេទ្យការងារ និង នាយកដ្ឋានអធិការកិច្ចការងារ ដើម្បីស្នើសុំមន្ត្រីមានសមត្ថភាពសំរាប់ចូលរួមក្នុងការអង្កេតគ្រោះថ្នាក់ ។
- ចាត់ចែងចុះពិនិត្យ អង្កេតដល់កន្លែងកើតហេតុផ្ទាល់ឱ្យបានឆាប់បំផុត ដែលអាចធ្វើបាន
- ស្នើសុំជំនួយពីអ្នកឯកទេសជំនាញ ក្នុងករណីគ្រោះថ្នាក់ដែលមានការពាក់ព័ន្ធនឹងលក្ខខណ្ឌបច្ចេកទេសស្មុគស្មាញ ។

**គ~ចំពោះមន្ទីរសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត~ក្រុងៈ**

- ចាត់ចែងចុះពិនិត្យ និង ធ្វើអង្កេតដល់កន្លែងកើតហេតុផ្ទាល់ឱ្យបានឆាប់បំផុត ដែលអាចធ្វើបាន ។
- ស្នើសុំជំនួយពីអ្នកឯកទេសជំនាញ ក្នុងករណីគ្រោះថ្នាក់ដែលមានការពាក់ព័ន្ធនឹងលក្ខខណ្ឌបច្ចេកទេសស្មុគស្មាញ ។

- ក្នុងករណីមានគ្រោះថ្នាក់ធ្ងន់ ឬដល់ស្លាប់ ត្រូវជូនដំណឹងជាបន្ទាន់មកនាយកដ្ឋានសន្តិសុខសង្គម ក្នុងរយៈពេលយ៉ាងយូរបំផុតចិតសិបពីរម៉ោង បន្ទាប់ពីបានទទួលដំណឹងពីសហគ្រាសដែលមានឧប្បត្តិហេតុ ។

រាល់ពេលចុះអង្កេតគ្រោះថ្នាក់ការងារ ត្រូវធ្វើកំណត់ហេតុបញ្ជាក់ឱ្យបានច្បាស់លាស់ អំពីថាតើគ្រោះថ្នាក់នោះ ពិតជាគ្រោះថ្នាក់ការងារឬទេ មូលហេតុនៃគ្រោះថ្នាក់ និងត្រូវកំណត់វិធីសាស្ត្រសំរាប់បង្ការគ្រោះថ្នាក់ដដែលនេះ កុំឱ្យកើតមានជាថ្មី ។ កំណត់ហេតុគ្រោះថ្នាក់ការងារត្រូវធ្វើតាមគំរូដូចមានចែងក្នុងឧបសម្ព័ន្ធទី ២ នៃប្រកាសនេះ ។

របាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំអំពីគ្រោះថ្នាក់ការងារ ត្រូវធ្វើតាមតារាងគំរូដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី ៣ និងទី ៤ នៃប្រកាសនេះ ។

**ប្រការ៦.-** ក្នុងពេលដែលបេឡាជាតិសន្តិសុខសង្គមមិនទាន់បង្កើត និយោជក ឬម្ចាស់សហគ្រាស ដូចមានចែងក្នុងប្រការ១ នៃប្រកាសនេះ ត្រូវមានកាតព្វកិច្ចផ្តល់តាវកាលិកសំរាប់ជួសជុលគ្រោះថ្នាក់ការងារបន្ថែមលើសោហ៊ុយសំរាប់ជួយសង្គ្រោះគ្រាដំបូង ។ តាវកាលិកសំរាប់ជួសជុលគ្រោះថ្នាក់ការងារមានជាអាទិ៍ដូចតទៅ :-

- ការជួយឧបត្ថម្ភសំរាប់ការព្យាបាល និង ថែរក្សាជំងឺ
- ប្រាក់បំណាច់ប្រចាំថ្ងៃ
- ធនលាភ
- សោហ៊ុយសំរាប់បូជាសព និង ធនលាភសំរាប់អ្នកនៅក្នុងបន្ទុករបស់អ្នករងគ្រោះ ។

ចំពោះគ្រោះថ្នាក់ចរាចរ ដែលមានលក្ខណៈជាគ្រោះថ្នាក់ការងារ ការជួសជុលដែលចេញឱ្យដោយភាគីទីបី ពោលគឺភាគីដែលបង្កឱ្យមានគ្រោះថ្នាក់ក៏ត្រូវចាត់ទុកជាតាវកាលិកគ្រោះថ្នាក់ការងារការងារដែរ ។ និយោជកមានសិទ្ធិប្តឹងទាមទារឱ្យភាគីទីបី ចេញតាវកាលិកគ្រោះថ្នាក់ប្រភេទនេះមកឱ្យខ្លួន ប្រសិនបើតាវកាលិកនេះសហគ្រាសបានសងទៅអ្នករងគ្រោះរួចហើយ ។

ទោះជាមានចែងដូច្នេះក្តី តាវកាលិកផ្នែកនេះត្រូវតែស្ថិតនៅក្នុងបន្ទុកនិយោជកជាអ្នកទទួលរ៉ាប់រង ពោលគឺនិយោជកត្រូវរ៉ាប់រងរាល់ការចំណាយទាំងអស់ជាមុនសិនរួចទើបដោះស្រាយជាមួយភាគីទីបីជាក្រោយ ។

អ្នករងគ្រោះដោយគ្រោះថ្នាក់ការងារ មានបុព្វសិទ្ធិពេញលេញក្នុងការទាមទារតាវកាលិករបស់ខ្លួន ក្នុងករណីដែលតុលាការចេញសាលក្រមបញ្ជាក់ថា សហគ្រាសក្ស័យធន ។

**ប្រការ៧.-** ការជួយឧបត្ថម្ភសំរាប់ការព្យាបាល និង ថែរក្សាអ្នករងគ្រោះ ក្នុងរយៈពេលសំរាកព្យាបាលនៅមន្ទីរពេទ្យរាប់ទាំងការព្យាបាលពេលរបួស ឬជំងឺរើឡើងវិញ និង ការជួយឧបត្ថម្ភផ្សេងៗបន្ទាប់ពីមុខ

របួសបានជាសះស្បើយ គឺជាកាតព្វកិច្ចរបស់និយោជក ចំពោះជនរងគ្រោះថ្នាក់ការងារ ដែលបណ្ដាលឱ្យបាត់បង់សមត្ថភាពការងារជាកាលិក ឬបាត់បង់សមត្ថភាពការងារជាអចិន្ត្រៃយ៍ដោយផ្នែក ឬទាំងស្រុង បន្ទាប់ពីមានការបញ្ជាក់យ៉ាងត្រឹមត្រូវពីគ្រូពេទ្យផ្លូវការ ដែលមានការយល់ព្រមពីក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។ តាវកាលិកផ្នែកនេះមានកំណត់ដូចតទៅៈ-

- ប្រាក់បំណាច់សំរាប់ការព្យាបាល ការព្យាបាលដោយវះកាត់ ការព្យាបាលខាងទន្តសាស្ត្រ ការពិនិត្យដោយវិទ្យុកាំរស្មីអ៊ិច ឬអេកូសាស្ត្រ ការពិនិត្យនៃមន្ទីរពិសោធន៍ និងរាល់ការវិភាគផ្សេងៗ ដែលគ្រូពេទ្យព្យាបាលតម្រូវឱ្យមាន
- ប្រាក់ចំណាយសំរាប់ទិញឱសថ និងគ្រឿងប្រើប្រាស់បន្ទាប់បន្សំទាក់ទងនឹងការព្យាបាល
- ប្រាក់ឧបត្ថម្ភសំរាប់អ្នកចាំថែរក្សាជំងឺនៅក្នុងមន្ទីរព្យាបាល ឬទីផ្សេងទៀតដែលមានលក្ខណៈជាកន្លែងសំរាប់ព្យាបាល
- ការផ្គត់ផ្គង់ ការជួសជុល ឬកែកុនជាថ្មីនូវអវៈយវៈសិប្បនិម្មិត ឈើច្រត់ រទេះសំរាប់មនុស្សពិការ
- សោហ៊ុយសំរាប់ដឹកអ្នករងគ្រោះពីកន្លែងគ្រោះថ្នាក់ទៅមន្ទីរពេទ្យឬទៅកាន់លំនៅស្ថាន
- ការឧបត្ថម្ភសំរាប់ការងារសំរបសំរួលមុខងារឡើងវិញ ឬការជួយបង្រៀនវិជ្ជាជីវៈឱ្យបានសមស្របតាមកាយសម្បទារបស់ជនរងគ្រោះ ។

ទោះបីមានការកំណត់ដូចខាងលើក្ដី ក៏អ្នករងគ្រោះអាចនឹងមានសិទ្ធិទទួលនូវអត្ថប្រយោជន៍ប្រសើរជាងនេះថែមទៀត។ p

**ប្រការ៨.-** ក្នុងករណីគ្រោះថ្នាក់ការងារ ដែលបណ្ដាលឱ្យបាត់បង់សមត្ថភាពការងារជាកាលិក ឬជាអចិន្ត្រៃយ៍ ដែលមានអត្រាតិចជាងម្ភៃភាគរយ ហើយមិនទាន់អាចចូលធ្វើការបាន ពោលគឺគ្រោះថ្នាក់ដែលបណ្ដាលឱ្យអាក់ខានធ្វើការមួយរយៈពេលក្រៅពីអត្ថប្រយោជន៍ ដូចមានចែងក្នុងប្រការ ៧ អ្នករងគ្រោះត្រូវមានសិទ្ធិទទួលនូវប្រាក់បំណាច់ប្រចាំថ្ងៃ ដែលនិយោជកត្រូវបើកឱ្យ ចាប់ពីថ្ងៃទីប្រាំនៃថ្ងៃដែលមានគ្រោះថ្នាក់នេះទៅរហូតដល់ជាសះស្បើយ ដោយមានលិខិតបញ្ជាក់ពីគ្រូពេទ្យផ្លូវការដែលទទួលស្គាល់ដោយក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

ប្រាក់បំណាច់ប្រចាំថ្ងៃត្រូវស្មើនឹងប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃរបស់អ្នករងគ្រោះ។

ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ គឺជាផលចែករវាងប្រាក់ឈ្នួលមូលដ្ឋានរបស់អ្នករងគ្រោះ នឹងចំនួនថ្ងៃធ្វើការនៃអ្នករងគ្រោះ។

ប្រាក់ឈ្នួលមូលដ្ឋាន គឺជាផលបូកនៃប្រាក់ឈ្នួលសុទ្ធសាធជាមួយអត្ថប្រយោជន៍ផ្សេងៗ ដូចជា ប្រាក់ម៉ោងបន្ថែម ប្រាក់ភារកិច្ច និង ប្រាក់បំណាច់មួយចំនួនដែលមានលក្ខណៈជាសោហ៊ុយ ដូចជា សោហ៊ុយធ្វើដំណើរ សោហ៊ុយវិជ្ជាជីវៈ សោហ៊ុយបេសកកម្មជាដើម លើកលែងតែប្រាក់វិភាជន៍គ្រួសារ ។

ចំនួនប្រាក់ឈ្នួលមូលដ្ឋានត្រូវកំណត់តាមល័ក្ខខ័ណ្ឌដូចខាងក្រោម :-

១- បើការបើកប្រាក់ឈ្នួលប្រព្រឹត្តទៅក្នុងមួយខែម្តង ចំនួនប្រាក់ឈ្នួលមូលដ្ឋានស្មើនឹងចំនួនប្រាក់ឈ្នួលសំរាប់ខែកន្លងទៅគឺ ខែមុនខែដែលមានគ្រោះថ្នាក់ ។

២- បើការបើកប្រាក់ឈ្នួលប្រព្រឹត្តទៅរៀងរាល់អឌ្ឍមាស ចំនួនប្រាក់ឈ្នួលមូលដ្ឋានស្មើនឹងចំនួនប្រាក់ឈ្នួលសំរាប់ពីរអឌ្ឍមាសបន្តបន្ទាប់មុនអឌ្ឍមាសដែលមានគ្រោះថ្នាក់ ។

៣- បើការបើកប្រាក់ឈ្នួលប្រព្រឹត្តទៅរៀងរាល់សប្តាហ៍ ចំនួនប្រាក់ឈ្នួលមូលដ្ឋានស្មើនឹងចំនួនប្រាក់ឈ្នួលសំរាប់បួនសប្តាហ៍បន្តបន្ទាប់មកទល់នឹងសប្តាហ៍ដែលមានគ្រោះថ្នាក់ ។

៤- បើការបើកប្រាក់ឈ្នួលប្រព្រឹត្តទៅជាប្រចាំថ្ងៃ ឬមិនទៀងទាត់ចំនួនប្រាក់ឈ្នួលមូលដ្ឋានស្មើនឹងចំនួនសរុបនៃប្រាក់ឈ្នួលប្រចាំថ្ងៃធ្វើការ និង ថ្ងៃសំរាកដោយមានប្រាក់ឈ្នួលក្នុងរយៈពេលមួយខែ គិតមកទល់នឹងថ្ងៃដែលអាក់ខានធ្វើការ ។

៥- បើការបើកប្រាក់ឈ្នួលប្រព្រឹត្តទៅក្នុងរយៈពេលលើសពីមួយខែ ប៉ុន្តែអាចបើកម្តងក្នុង ១ ត្រីមាស ចំនួនប្រាក់ឈ្នួលមូលដ្ឋានស្មើនឹងចំនួនសរុបនៃប្រាក់ឈ្នួលសំរាប់រយៈពេលបីខែ គិតមកទល់នឹងថ្ងៃអាក់ខានធ្វើការ ។

៦- បើអ្នករងគ្រោះធ្វើការក្នុងមុខរបរប្រចាំរដូវ ឬប្រកបមុខរបរមិនជាប់លាប់ចំនួនប្រាក់ឈ្នួលមូលដ្ឋានស្មើនឹង ចំនួនសរុបនៃប្រាក់ឈ្នួលសំរាប់រយៈពេលដប់ពីរខែ គិតមកទល់ថ្ងៃដែលអាក់ខានធ្វើការ ។

ប្រាក់ឈ្នួលមូលដ្ឋានត្រូវគិតដូចគ្នាតាមលក្ខខណ្ឌខាងលើ បើសិនជាក្នុងរយៈពេលសាមសិបថ្ងៃគិតមកទល់ថ្ងៃគ្រោះថ្នាក់ អ្នករងគ្រោះមានផ្អាកការងារដោយមូលហេតុ ឈឺគ្រោះថ្នាក់ធម្មតា ការសំរាលកូន ការឈប់សំរាកមានប្រាក់ឈ្នួល អវត្តមានដោយមានការអនុញ្ញាតិត្រឹមត្រូវ ឬជំងឺ ឬមុខរបួសដែលបណ្តាលមកពីគ្រោះថ្នាក់ការងារលាប់ឡើងវិញ ។

ក្រោយពីមានការបញ្ជាក់ពីនាយកដ្ឋានពេទ្យការងារថា បានជាសះស្បើយអាចចូលបំរើការងារបានហើយ ។

- បើសាមីជនមិនព្រមចូលបង្ហាញខ្លួនមកធ្វើការក្នុងរយៈពេល ៦ ថ្ងៃ (គិតតែថ្ងៃធ្វើការ) គិតពីថ្ងៃទទួលលិខិតបញ្ជាក់ខាងលើ ត្រូវចាត់ទុកថាបានបោះបង់ចោលការងារ ។

- និយោជកត្រូវយកចិត្តទុកដាក់ទទួលសាម៉ីជនឱ្យចូលធ្វើការវិញ ក្នុងករណីមិនអាចទទួលបានទេ ត្រូវផ្តល់ប្រាក់បំណាច់ជូនសាម៉ីជនស្មើនឹងប្រាក់មធ្យមប្រចាំថ្ងៃចំនួន ១២ ខែ ។

**ប្រការ៩.-** ចំពោះករណីគ្រោះថ្នាក់ការងារដែលបណ្តាលឱ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ចាប់ពីម្ភៃភាគរយឡើងទៅ ឬគ្រោះថ្នាក់ដល់ស្លាប់ និង ដោយមានសេចក្តីបញ្ជាក់យ៉ាងត្រឹមត្រូវពីគ្រូពេទ្យផ្លូវការ ដែលទទួលស្គាល់ដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាផងនោះ អ្នករងគ្រោះ ឬសិទ្ធិវន្ត មានសិទ្ធិពេញលេញក្នុងការទទួលបាននូវតាវកាលិកជាធនលាភ ។

ធនលាភ គឺជាអនុគមន៍នៃប្រាក់ឈ្នួលមូលដ្ឋានប្រចាំឆ្នាំ និង អត្រាបាត់បង់សមត្ថភាពការងាររបស់អ្នករងគ្រោះ ។ ធនលាភសំរាប់គ្រោះថ្នាក់ការងារ ត្រូវផ្តល់ឱ្យបន្ទាប់ពីមុខរបួសបានជាសះស្បើយ ។ នៅក្នុងរយៈពេលកំពុងព្យាបាលមុខរបួស ជនរងគ្រោះមានសិទ្ធិទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃដូចមានចែងក្នុងប្រការ ៨ ខាងលើ ។

ប្រាក់ឈ្នួលមូលដ្ឋានប្រចាំឆ្នាំរបស់អ្នករងគ្រោះ ត្រូវកំណត់តាមលក្ខខណ្ឌដូចខាងក្រោម :-

- ក្នុងលក្ខខណ្ឌធម្មតា ប្រាក់ឈ្នួលមូលដ្ឋានប្រចាំឆ្នាំ ស្មើនឹងចំនួនប្រាក់ឈ្នួលមូលដ្ឋានរបស់អ្នករងគ្រោះ ដូចមានកំណត់ក្នុងប្រការ៨ ខាងលើ ក្នុងរយៈពេលដប់ពីរខែ គិតមកទល់ថ្ងៃដែលអាក់ខានធ្វើការ ។

- ចំពោះអ្នករងគ្រោះ ដែលបំរើការក្នុងវិជ្ជាជីវៈណាមួយ ប៉ុន្តែមិនទាន់គ្រប់ដប់ពីរខែពេញលេញ បើគិតមកទល់ថ្ងៃអាក់ខានធ្វើការដោយសារគ្រោះថ្នាក់ការងារ ប្រាក់ឈ្នួលមូលដ្ឋាន ស្មើនឹងប្រាក់ឈ្នួលជាក់ស្តែងក្នុងរយៈពេលដែលបានធ្វើការមកទល់ថ្ងៃអាក់ខានធ្វើការនោះ ។ ទោះបីមាន ខបញ្ជាក់យ៉ាងនេះក៏ដោយ ក៏អ្នករងគ្រោះអាចមានសិទ្ធិទទួលអត្ថប្រយោជន៍ ដូចក្នុងកថាខ័ណ្ឌខាងលើ ឬប្រសើរជាងនេះ ។

- បើក្នុងចិរវេលាដប់ពីរខែ គិតមកទល់ថ្ងៃមានគ្រោះថ្នាក់ការងារ អ្នករងគ្រោះបានអាក់ខានធ្វើការដោយសារមានជំងឺ គ្រោះថ្នាក់ធម្មតា ការសំរាលកូន ការឈប់សំរាកដោយមានប្រាក់ឈ្នួល ឬអវត្តមានដោយមានច្បាប់ ប្រាក់ឈ្នួលមូលដ្ឋានប្រចាំឆ្នាំ ត្រូវស្មើនឹងប្រាក់ឈ្នួលមធ្យមក្នុងរយៈ-ពេលដប់ពីរខែ គិតមកទល់ថ្ងៃដែលអាក់ខានធ្វើការដោយគ្រោះថ្នាក់ការងារ ។

ក្នុងករណីដែលមានការបាត់បង់សមត្ថភាពការងាររហូតដល់អត្រា៥០% អ្នករងគ្រោះមានសិទ្ធិទទួលបានធនលាភ ដែលត្រូវគណនាតាមរូបមន្តដូចខាងក្រោម:-

$R_1 = \frac{1}{2} S X_1$ *ដែលក្នុងនោះ*

$R_1$ - *ជាធនលាភប្រចាំឆ្នាំ*

S - *ជាប្រាក់ឈ្នួលមូលដ្ឋានប្រចាំឆ្នាំ*

X1 - *ជាអត្រាបាត់បង់សមត្ថភាពការងារចិរន្ត្រៃយ៍ពី២០% ដល់ ៥០% ។*

បើអត្រាបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍លើសពី ៥០% អ្នករងគ្រោះមានសិទ្ធិទទួលបាន ធនលាភដែលត្រូវគណនាតាមរូបមន្តដូចខាងក្រោមៈ-

$R_2 = S\,[½50\% + 1.5(X_2 - 50\%)]$ *ដែលក្នុងនោះ*

R2 - *ជាធនលាភប្រចាំឆ្នាំ*

S - *ជាប្រាក់ឈ្នួលមូលដ្ឋានប្រចាំឆ្នាំ*

$X_2$ - *ជាអត្រាបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ដែលលើសពី ៥០% ។*

នៅពេលដែលគ្រោះថ្នាក់ការងារ បណ្ដាលឱ្យបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ទាំងស្រុង និង តំរូវឱ្យមានមនុស្សនៅចាំថែរក្សា និយោជកត្រូវតម្លើងបន្ថែម ៤០% លើធនលាភដូចមានកំណត់ខាងលើ ។

នៅពេលដែលទទួលបានធនលាភ អ្នករងគ្រោះមានសិទ្ធិទទួលបានការងារដែលមានលក្ខខណ្ឌសមស្របនឹងកាយសម្បទារបស់ខ្លួន ។ ក្នុងករណីនេះ និយោជកត្រូវផ្ដល់ដល់ជនរងគ្រោះថ្នាក់ការងារ នូវការបង្រៀនវិជ្ជាជីវៈឡើងវិញ ដើម្បីឱ្យជននេះមានសមត្ថភាពគ្រប់គ្រាន់ក្នុងការបំពេញការងារថ្មីរបស់ខ្លួន។

ក្នុងករណីដែលភាគីទាំងពីរព្រមព្រៀងគ្នា និយោជកអាចផ្ដល់ប្រាក់ធនលាភផ្ដាច់តែម្ដង ។

**ប្រការ១០.-** និយោជកត្រូវចាត់ចែងបញ្ជូនជនរងគ្រោះមកទទួលការពិនិត្យកាយសម្បទាសារឡើងវិញ នៅនាយកដ្ឋានពេទ្យការងារបន្ទាប់ពីមុខរបួសបានជាសះស្បើយ។ កាតព្វកិច្ចនេះ អនុវត្តតែចំពោះអ្នករងគ្រោះណា ដែលអាក់ខានធ្វើការងារចាប់ពីប្រាំថ្ងៃឡើងទៅ ។

សោហ៊ុយចំណាយសំរាប់ការពិនិត្យកាយសម្បទាសារឡើងវិញ ត្រូវស្ថិតនៅក្នុងបន្ទុករបស់និយោជក ។ p

**ប្រការ១១.-** និយោជកត្រូវទទួលបន្ទុកដោយពេញច្បាប់ ក្នុងការផ្ដល់សោហ៊ុយសំរាប់បូជាសព និង ធនលាភសំរាប់អ្នកនៅក្នុងបន្ទុកនៃអ្នករងគ្រោះថ្នាក់ការងារដល់ស្លាប់ ។ ត្រូវចាត់ទុកជាអ្នកនៅក្នុងបន្ទុកនៃអ្នករងគ្រោះ គឺជនដែលមានលក្ខណៈសម្បត្តិដូចខាងក្រោមៈ-

- ភរិយា ឬប្ដីពេញច្បាប់ដោយមានលិខិតបញ្ជាក់អត្រានុកូលដ្ឋាន និង មិនមានការលែងលះគ្នា រហូតមកទល់ថ្ងៃមានគ្រោះថ្នាក់ ។
- កូនដែលនៅក្នុងបន្ទុករបស់ជនរងគ្រោះ ។ កូនដែលនៅក្នុងបន្ទុកជនរងគ្រោះ គឺកូនដែលមិនទាន់រៀបអាពាហ៍ពិពាហ៍ និង កូនដែលមានអាយុយ៉ាងច្រើន ១៦ ឆ្នាំ ។ ប៉ុន្តែការកំរិតនេះអាចបន្ថែមដល់អាយុ ១៨ ឆ្នាំ ចំពោះកូនដែលកំពុងដាក់ឱ្យរៀនធ្វើការ និង ២២ ឆ្នាំ ចំពោះកូនដែលកំពុងបន្តការសិក្សានៅក្នុងគ្រឹះស្ថានសាធារណៈមធ្យមសិក្សា ឬឧត្តមសិក្សា ឬក្នុងគ្រឹះស្ថានឯកជន មធ្យមសិក្សា ឬឧត្តមសិក្សា ហើយមិនបានទទួល

អាហារូបករណ៍ ដោយមានការអនុញ្ញាតិត្រឹមត្រូវ ព្រមទាំងកូនជាជនពិការ ឬមានជំងឺរ៉ាំរ៉ៃ មិនអាចព្យាបាលឱ្យជាសះស្បើយបាន។

ប្រាក់ឧបត្ថម្ភដែលជាសោហ៊ុយសំរាប់ចាត់ចែងបូជាសព ត្រូវកំណត់យ៉ាងតិចស្មើនឹង ៩០ ដងនៃប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ ឬត្រូវស្មើនឹងប្រាក់ឈ្នួលសំរាប់បីខែរបស់អ្នករងគ្រោះ ។

ធនលាភសំរាប់ផ្តល់ឱ្យអ្នកនៅក្នុងបន្ទុក ត្រូវកំណត់តាមអត្រាភាគរយនៃប្រាក់ឈ្នួលជាមូលដ្ឋានប្រចាំឆ្នាំនៃអ្នករងគ្រោះ ហើយអត្រានេះកំណត់ដូចតទៅ :-

- សាមសិបភាគរយ "៣០%" ចំពោះប្តី ឬប្រពន្ធអ្នករងគ្រោះ
- ដប់ប្រាំភាគរយ "១៥% " ចំពោះកូនទី១ និង ទី២ ដែលកំព្រាឪពុក ឬម្តាយ
- ដប់ភាគរយ "១០% " ចំពោះកូនទី៣ តទៅដែលកំព្រាឪពុក ឬម្តាយ

ប៉ុន្តែចំនួនសរុបនៃធនលាភសំរាប់អ្នកនៅក្នុងបន្ទុកមិនអាចលើស ៨៥% នៃចំនួនប្រាក់ឈ្នួលមូលដ្ឋានប្រចាំឆ្នាំនោះឡើយ ។

សិទ្ធិនៃការទទួលធនលាភនៃប្តី ឬប្រពន្ធ ដូចមានកំណត់តាមលក្ខខណ្ឌខាងលើ ត្រូវផុតរលត់ក្នុងករណីជនទាំងនោះរៀបអាពាហ៍ពិពាហ៍ម្តងទៀត ។

ប្រាក់ធនលាភនេះអាចបើកប្រចាំខែ ឬអាចបើកផ្តាច់តាមការព្រមព្រៀងគ្នា រវាងនិយោជកនិងសិទ្ធិវន្តនៃអ្នករងគ្រោះ។

**ប្រការ១២.-** ដោយអនុលោមតាមប្រភេទនៃមុខរបួស និង លក្ខណៈទូទៅផ្សេងទៀត ដូចជា អាយុ កំលាំងកាយ ស្មារតី សម្បទា និង លក្ខណៈសម្បត្តិនៃវិជ្ជាជីវៈ អត្រានៃការបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ត្រូវកំណត់ក្នុងឧបសម្ព័ន្ធទី៥ នៃប្រកាសនេះ ។

**ប្រការ១៣.-** នាយកដ្ឋានពេទ្យការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវធ្វើការសិក្សាស្រាវជ្រាវ និង លើកសំណើប្រភេទជំងឺវិជ្ជាជីវៈ ។

**ប្រការ១៤.-** ការប្រព្រឹត្តិល្មើសនឹងបទបញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវទទួលពិន័យ ឬទទួលទោសដូចមានចែងក្នុងជំពូកទី ១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ១៥.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន លេខ ៥៨ សកអ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ ១៩៩៨ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ១៦.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និងត្រា**

**អ៊ិត សំហេង**

ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ ២៤៣ សកបយ
ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០០២

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ការប្រកាសជូនដំណឹងអំពីគ្រោះថ្នាក់ការងារ

លោក/លោកស្រី ............................................................................................................

ម្ចាស់ ឬ នាយកសហគ្រាស ឬក្រុមហ៊ុន ..........................................................................

អាសយដ្ឋាន ...................................................................................................................

## គោរពជូន

លោកប្រធាន

☐ នាយកដ្ឋានសន្តិសុខសង្គម [១]

☐ មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត ឬក្រុង ρ

**កម្មវត្ថុ** : ប្រកាសជូនដំណឹងអំពីគ្រោះថ្នាក់ការងារ

១-កាលបរិច្ឆេទនៃគ្រោះថ្នាក់ការងារ

ម៉ោង...................ថ្ងៃ.............ខែ .....................ឆ្នាំ..................... ទីកន្លែង..............................

២-ប្រភេទគ្រោះថ្នាក់ការងារ.........................................................................................

.....................................................................................................................................

.....................................................................................................................................

៣-ចំនួនអ្នករងគ្រោះ :

- ស្លាប់ ..........................................................................................................

- របួសធ្ងន់ .....................................................................................................

- របួសស្រាល ..................................................................................................

[១] គូសក្នុងចតុកោណដែលត្រូវធ្វើ

៤-មូលហេតុនៃគ្រោះថ្នាក់ "បរិយាយលំអិត" ............................................................................................................
........................................................................................................................................................................
........................................................................................................................................................................
........................................................................................................................................................................
........................................................................................................................................................................
........................................................................................................................................................................
........................................................................................................................................................................
........................................................................................................................................................................
........................................................................................................................................................................
........................................................................................................................................................................
........................................................................................................................................................................
........................................................................................................................................................................
........................................................................................................................................................................
........................................................................................................................................................................
........................................................................................................................................................................
........................................................................................................................................................................
........................................................................................................................................................................
........................................................................................................................................................................
p
........................................................................................................................................................................
........................................................................................................................................................................
........................................................................................................................................................................
........................................................................................................................................................................
........................................................................................................................................................................
........................................................................................................................................................................
........................................................................................................................................................................
........................................................................................................................................................................

ធ្វើនៅ ........................ថ្ងៃទី ខែ ឆ្នាំ២០០..

ហត្ថលេខានិយោជក ឬម្ចាស់សហគ្រាស

ឧបសម្ព័ន្ធទី ២ នៃប្រកាសលេខ: ២៤៣ សកបយ
ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០០២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

## កំណត់ហេតុ
## អង្កេតគ្រោះថ្នាក់ការងារ

ឆ្នាំ......................ខែ....................ថ្ងៃទី....................ម៉ោង......................គណៈកម្មការអង្កេតគ្រោះថ្នាក់ការងាររបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានចុះអង្កេតករណីគ្រោះថ្នាក់ដែលបានកើតឡើងនៅ : សហគ្រាស/ក្រុមហ៊ុន..........................................................................................

អាសយដ្ឋាន.....................................................................................................................

១-កំរិតគ្រោះថ្នាក់

☐ ស្លាប់

p

☐ របួសធ្ងន់

☐របួសស្រាល

២- កំរិតគ្រោះថ្នាក់:

☐.........................................................................................................

☐.........................................................................................................

☐.........................................................................................................

☐.........................................................................................................

៣-សមាសភាពគណៈកម្មការអង្កេត

☐.........................................................................................................

☐.........................................................................................................

☐.........................................................................................................

☐.........................................................................................................

៤- ជីវប្រវត្តិជនរងគ្រោះ

☐ឈ្មោះ..........................................ភេទ.....................អាយុ..............................................

☐មុខជំនាញ....................................................................................................................

☐អតីតភាពការងារ..........................................................................................................

☐រូបភាពផ្តល់បៀវត្ស.........................................................................................................

☐សញ្ជាតិ........................................................................................................................

☐ធ្លាប់ទទួលការបណ្តុះបណ្តាលបច្ចេកទេសសន្តិសុខការងារឬទេ.............................................

☐ធ្លាប់ ☐មិនធ្លាប់

☐ស្ថានភាពគ្រួសារ( អ្នកនៅក្នុងបន្ទុក ,ការិតជីវភាព)...........................................................

☐ ឈ្មោះ..................................ភេទ...................អាយុ..................សញ្ជាតិ...........................

☐ មុខជំនាញ...............................អតីតមុខជំនាញ..............................អតីតភាពការងារ................

☐ រូបភាពផ្តល់បៀវត្ស...........................................បៀវត្ស...............................................

☐ ធ្លាប់ទទួលការបណ្តុះបណ្តាលបច្ចេកទេសសន្តិសុខការងារឬទេ? ☐ ធ្លាប់. ☐មិនធ្លាប់

☐ ស្ថានភាពគ្រួសារ ( អ្នកនៅក្នុងបន្ទុក, ការិតជីវភាព).......................................................

☐ ឈ្មោះ.................................................ភេទ.........................អាយុ.......................................

☐ មុខជំនាញ...................................................................................................................

☐ អតីតភាពការងារ..........................................................................................................

☐ រូបភាពផ្តល់បៀវត្ស.......................................................................................................

☐ សញ្ជាតិ........................................................................................................................

☐ ធ្លាប់ទទួលការបណ្តុះបណ្តាលបច្ចេកទេសសន្តិសុខការងារឬទេ............................................

☐ ធ្លាប់ ☐មិនធ្លាប់

☐ស្ថានភាពគ្រួសារ( អ្នកនៅក្នុងបន្ទុក ,ការិតជីវភាព)...........................................................

៥-ទិដ្ឋភាពនៃគ្រោះថ្នាក់( អនុលោមតាមរបាយការណ៍របស់គ្រូពេទ្យប្រចាំសហគ្រាស និង ឬមន្ត្រីអង្កេត)

☐ថ្ងៃ..........................ខែ.......................ឆ្នាំ.........................ម៉ោង...........................................

☐ មុន ឬ ក្រោយពេលធ្វើការ

☐ពេលម៉ោងបន្ថែម

☐.............................................................................................................................

☐.............................................................................................................................

☐.............................................................................................................................

☐.............................................................................................................................

☐.............................................................................................................................

☐..............................................................................................................................
☐..............................................................................................................................
☐..............................................................................................................................
☐..............................................................................................................................
☐..............................................................................................................................
☐..............................................................................................................................
☐..............................................................................................................................
☐..............................................................................................................................
☐..............................................................................................................................
☐..............................................................................................................................

៦- សាក្សី

☐..............................................................................................................................
☐..............................................................................................................................
☐..............................................................................................................................
☐..............................................................................................................................
☐..............................................................................................................................
☐..............................................................................................................................
☐..............................................................................................................................

៧-មតិនិយោជក

☐..............................................................p..............................................................
☐..............................................................................................................................
☐..............................................................................................................................
☐..............................................................................................................................
☐..............................................................................................................................
☐..............................................................................................................................

៨- មតិប្រតិភូបុគ្គលិក ឬ សហជីព

☐..............................................................................................................................
☐..............................................................................................................................
☐..............................................................................................................................
☐..............................................................................................................................
☐..............................................................................................................................

☐ ..........................................................................................................

៩- មូលហេតុនៃគ្រោះថ្នាក់

☐..........................................................................................................

☐..........................................................................................................

☐..........................................................................................................

☐ ..........................................................................................................

☐ ..........................................................................................................

☐ ..........................................................................................................

☐ ..........................................................................................................

១០-វិធានការទប់ស្កាត់

☐ ..........................................................................................................

☐ ..........................................................................................................

☐ ..........................................................................................................

☐..........................................................................................................

☐..........................................................................................................

☐..........................................................................................................

១១-សេចក្ដីសន្និដ្ឋានរបស់គណៈកម្មការអង្កេត

☐ ..........................................................................................................

☐ ..........................................................................................................

☐ ...................................................p.......................................................

☐..........................................................................................................

☐..........................................................................................................

☐..........................................................................................................

☐ ..........................................................................................................

នាយកសហគ្រាស ឬ តំណាង សាក្សី គណៈកម្មការអង្កេត

១-..........................ឈ្មោះ..........................

២-..........................ឈ្មោះ..........................

៣-..........................ឈ្មោះ..........................

ឧបសម្ព័ន្ធទី ៣ នៃប្រកាសលេខ ២៤៣ សកបយ.

ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០០២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ឈ្មោះក្រុមហ៊ុន : ..................................

អាសយដ្ឋាន : .......................................

**បញ្ជីគ្រោះថ្នាក់ការងារ**

| លរ/No. | | | | | អាយុ Age | | | | អតីតភាពមុខជំនាញ Skilled seniority | | | គំរិតគ្រោះថ្នាក់ Accident severity | | | | | | មូលហេតុ CAUSES | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| គ្រោះថ្នាក់ការងារ Labour accident | ជនរងគ្រោះថ្នាក់ victim | ឈ្មោះ NAME | មុខរបរ JOB | ភេទ SEX | តិចជាង ៣០ <30 years old | ពី ៣០ ទៅ ៤០ From 30 to 40 years old | ៤០ឡើង >40 years old | អតីតភាពការងារ Employment age | តិចជាង ៥ <5 years old | ពី ៥ ទៅ ១០ From 5 to 10 years old | ១០ឡើង >10 years old | ស្លាប់ Death | ចាប់ពី២០%ឡើង <20%of pert.incapacity | តិចជាង ២០% >20% Pert. Incapacity | ចំនួនថ្ងៃឈប់ធ្វើការ Employment age | **គាទិកាលិក** Benefits (x 1000 Riels) | ប្រភេទគ្រោះថ្នាក់ការងារ Type of the accident | ឧបករណ៍ផលិតកម្ម Productive Agencies | អនាម័យការងារ Labor hygine | សំភារៈការពារបុគ្គល Per.Prot Equi\pment | ល្មើសបទបញ្ជា RULE VILATION | ប្រភេទគ្រោះថ្នាក់ការងារ Type of the accident |
| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | ២៣ |
| | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | |

ឧបសម្ព័ន្ធទី ៤ នៃប្រកាសលេខ ២៤៣ សកបយ.
ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០០២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ឈ្មោះក្រុមហ៊ុន : ..................................
អាសយដ្ឋាន : ......................................

## របាយការណ៍សរុបគ្រោះថ្នាក់ការងារ

| ប្រភេទគ្រោះថ្នាក់ Type of Accident | ចំនួនគ្រោះថ្នាក់ការងារ (ដង) Number of accident (time): សរុប Total | ស្លាប់ Death | ច្រើននាក់ Many People | ចំនួនមនុស្សគ្រោះថ្នាក់ការងារ (នាក់) Number people accident (person): សរុប total | ស្រី femal | ស្លាប់ Death: សរុប total | ស្រី total | >20%: សរុប total | ស្រី femal | <20% d | អាយុ Age: តិចជាង ៣០ <30year old | ពី ៣០ ទៅ ៤០ from30 to40years old | ៤០ឡើង >40yearsold | អតីតភាពមុខជំនាញ Skilled seniority: តិចជាង ៥ឆ្នាំ <5 year old | ពី ៥ ដល់ ១០ឆ្នាំ from 5 to 10years old | ១០ឡើង >10 years old | ចំនួនថ្ងៃឈប់ធ្វើការ Working day off | សោធននិវត្តន៍ Benefits (x 1000 Riels) | មូលហេតុ Caues: ឧបករណ៍ផលិតកម្ម Productive Agencies | អនាម័យការងារ Labor hygine | សំភារៈការពារបុគ្គល Per.Prot Equi\lipment | ល្មើសបទបញ្ជា RULE VILATION: អ្នកគ្រប់គ្រង Manager | កម្មករនិយោជិត Workers | អប់រំបច្ចេកទេសសុវត្ថិភាព Saf Training (yes / no) |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | ២៣ | ២៤ | ២៥ |
| | | | | | | | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | | | | | | | |

ឧបសម្ព័ន្ធទី ៥ នៃប្រកាស លេខ: ២៤៣ សកបយ
ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០០២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លក្ខណៈវិនិច្ឆ័យសំរាប់ការចាត់ថ្នាក់នៃ
# ការបាត់បង់សមត្ថភាពការងារ

------

ការបាត់បង់សមត្ថភាពបំរើការងារត្រូវចាត់ថ្នាក់ជា ៤ ប្រភេទ :

ប្រភេទទី ១ : ប្រើប្រាស់សំរាប់ចំណាត់ថ្នាក់សាមីជនដែលមានការទ្រុឌទ្រោមទាំងស្រុងនៃមុខងារសំខាន់ៗ និង ជាសារវន្តចំនួនមួយ ឬច្រើនរបស់សរីរាង្គកាយ ។ ជនពិការពុំអាចធ្វើការងារបំរើខ្លួនឯងបាន និងតម្រូវឱ្យមានអ្នកដទៃជួយជាអចិន្ត្រៃយ៍ ។

ប្រភេទទី ២ : ប្រើប្រាស់សំរាប់ចំណាត់ថ្នាក់ក្នុងករណីដែលមានការទ្រុឌទ្រោមធ្ងន់ ឬស្រាល នៃមុខងារសំខាន់ៗរបស់សរីរាង្គកាយ ។ ជនពិការអាចប្រកបការងារបាននៅក្នុងករណីពិសេស ។ សាមីជននេះអាចធានាបានដោយខ្លួនឯងនូវសេចក្តីត្រូវការរបស់ខ្លួនមួយផ្នែកក្នុងជីវភាពប្រចាំថ្ងៃ ដោយមិនចាំបាច់ពឹងផ្អែកជំនួយជាអចិន្ត្រៃយ៍ពីអ្នកដទៃឡើយ ។

ប្រភេទទី ៣ : ប្រើប្រាស់សំរាប់ចំណាត់ថ្នាក់ក្នុងករណីដែលមានការចុះថយនៃសមត្ថភាពធ្វើការងារ ។ ជនពិការអាចបំរើការងារបាននៅក្នុងករណីដែលបានកំណត់ ហើយមិនទាមទារឱ្យមានអ្នកដទៃជួយក្នុងជីវភាពប្រចាំថ្ងៃឡើយ ។

ប្រភេទទី ៤ : ប្រើប្រាស់សំរាប់ចំណាត់ថ្នាក់ក្នុងករណីដែលសមត្ថភាពការងារត្រូវថយចុះ និង សភាពសុខភាពតម្រូវឱ្យផ្លាស់ប្តូរវិជ្ជាជីវៈ ឬតម្រូវឱ្យផ្លាស់ប្តូរលក្ខណៈការងារ ។

## ប្រភេទទី ១

| សំណល់នៃអាហ្វិចស្បុង "ជំងឺត្រូម៉ា" ការប៉ះទង្គិច " បណ្តាលពីគ្រោះថ្នាក់នៃការងារ | : អត្រាបាត់បង់សមត្ថភាពការងារ( % ) |
|---|---|
| **ក-ក្បាល មុខ ក :** | |
| ១-ការប៉ះទង្គិចលលាដ៏: | |
| -ខ្វិនមួយចំហៀងខ្លួនមិនពេញលេញ វិបត្តិនៃពាក្យសំដី | : ៧០-៨០ |
| -ខ្វិនមួយចំហៀងខ្លួនមិនពេញលេញ វិបត្តិសាច់ដុំ | : ៧០-៨០ |
| -ឆ្កួតជ្រូកញឹកញាប់ "កើតមានច្រើនដងក្នុងមួយសប្តាហ៍" | : ៧៥-១០០ |
| -វិលមុខ ភ្លេចភ្លាំង "ឆ្កួតជ្រូកស្រាល " កើតឡើងដោយធ្ងន់ធ្ងរ | : ៤០-៨០ |
| -មានសឹក "ប្រាជ្ញាស្មារតី " ខូចខាត" ភាពវិកលចរិត ភាពលីលា " ធ្ងន់ធ្ងរ | : ៦១-១០០ |
| ២-អន្ធការភ្នែកទាំងពីរ,ការគំហើញ សរុប ១/២០ | : ៨០ |

៣-អន្ទការទាំងស្រុងនៃភ្នែកទាំងពីរ "ខ្វាក់" : ៩០
៤-បាត់បង់ឆ្អឹងថ្គាមខាងក្រោម : ៦០-៧០
៥-ដំបៅបំពង់សំលេង ដើមក ហត់ដង្ហើមមិនធូរស្រាល : ៥០-៦០

**ខ.ទ្រូង និង សរីរាង្គក្នុងទ្រូង**

១-វះកាត់សួត សមត្ថភាពដកដង្ហើមថយចុះជាង៥០ភាគរយ សុខភាពទូទៅ ត្រូវរងគ្រោះ "ថយចុះ" : ៥៥-៧៥
២-ប៉ះពាល់ដល់ស្រោមបេះដូង "ហឫទ័យកោស បេរីការដ" សាច់បេះដូង "មីយូការដ"
ប្រើសបេះដូងបង្កឱ្យមានវិបត្តិសង្វាក់បេះដូង : ៥៥-៧០

**គ.ឆ្អឹងខ្នង : ជំងឺឆ្អឹងខ្នងជាមួយនឹងការកៀបសរសៃខួរឆ្អឹងខ្នង** :

១-ខ្វិនសងខាងមិនពេញលេញនៃអវៈយវៈក្រោម លំបាកលំបិនទូវដំណើរ និងវិបត្តិសាច់ដុំរលីង និង ស : ៤០-៧០
២-ខ្វិនសងខាងទាំងស្រុងនៃអវៈយវៈក្រោម : ៧០-៨០
៣-ខ្វិនទាំងបួន "ដៃពីរ ជើងពីរ" មិនពេញលេញ : ៨០-៩០
៤-ខ្វិនបួនទាំងស្រុង "ងាប់ទាំងជើង ទាំងដៃ" : ១០០
៥-អាការៈរោគនៃកន្ទុយសេះ "គីស្តីវ៉ាស" ខ្វិនសងខាង វិកលភាព សាច់ដុំរលីង និង ស
បាត់បង់អស់រេផ្លិចអាគីល : ១០០

**ឃ.ពោះ និង សរីរាង្គក្នុងពោះ** :

-ដំបៅពោះវៀនធំ ទ្វារលាមកសិប្បនិម្មិត : ៤០-៧០

**ង.អវៈយវៈ** :

១-កាត់ដៃទាំងពីរ "មិនចំពោះកាត់ត្រឹមណា" : ៧៥-៨៥
២-កាត់ប្រអប់ជើងទាំងពីរ : ៧០-៨០
៣-កាត់ជើងទាំងពីរ "មិនចំពោះកាត់ត្រឹមណា" : ៧០-៨០
p
៤-កាត់ដើមដៃម្ខាង និង ប្រអប់ជើងម្ខាង
-មានជើងដាក់ជំនួសបាន "ជើងសិប្បនិម្មិត" : ៧៥-៨០
-គ្មានជើងដាក់ជំនួសបាន : ៨០-៩០
៥-បាត់បង់អវៈយវៈបី "ដៃពីរជើងមួយ ឬ ផ្ទុយ" : ១០០
៦-ខ្វិនទាំងស្រុងនៃអវៈយវៈពីរ ឬច្រើនជាងនេះ "ឬមួយអវៈយវៈលើ ២ ឬមួយអវៈយវៈ
ក្រោម២ ឬមួយអវៈយវៈលើមួយក្រោមមួយ : ៧០-៨៥

## ប្រភេទទី ២

**ក.ក្បាល មុខ ក** :

១-ខ្វិនមួយចំហៀងខ្លួនមិនពេញលេញ លំបាកលំបិននៅដំណើរ : ៤០-៧០
២-ថ្លង់ និង ភាពគ : ៤០-៦០
៣-ឆ្កួតជ្រូកច្រំដែល : ៣០-៤៥
៤-វិលមុខឆ្កួតជ្រូកស្រាល "បីដងក្នុងមួយសប្តាហ៍" : ៣០-៤០

៥-ឆ្អឹងជ្រូកដោយអន្ទើ កើតវិបត្តិជាប់ៗគ្នា : ៣០-៥០
៦-អាហ្វាស៊ី - និយាយមិនឮ : ២០-៥០
៧-វិបត្តិណើរ៉ូ បន្ទាប់ពីការប៉ះទង្គិច ឬអាការៈរោយបន្ទាប់ពីការប៉ះទង្គិច : ៣០-៤០
៨-ភាពល្ងិតល្ងៃ " អារម្មណ៍ " បន្ទាប់ពីការប៉ះទង្គិច : ៣០-៤០
៩-ហ៊ីពែរអេម៉ូស្យុង "ឆាប់រំភើបចិត្តខ្លាំងពេក " : ៣០-៤០
១០-ផ្ដោកនោមស្វ័យប្រវត្តិ " អាការៈរោគក៏ស្ពឺវ៉ាល់ " : ២០-៤០
១១-មានសឹក ( សតិបញ្ញា ) ទន់ខ្សោយ : ៤៥-៦០
១២-មានសឹកស្រុតចុះ : ៤០
១៣-ថ្លង់សងខាងទាំងស្រុង : ៤៥
១៤-ដំបៅបំពង់សំឡេង-វះចោះបំពង់ខ្យល់ : ៥០-៦០
១៥-បំពង់អាហាររួមតូច តម្រូវឱ្យអវ:យវ:ក្រពះ : ៤០-៦០
១៦-គំហើញនៃភ្នែកទាំងពីរថយចុះ
-ការតគំហើញ ( អាគ្គីតេ ) ២/១០ : ៦០
-ការតគំហើញ ( អាគ្គីតេ ) ១/១០ : ៧០
១៧-បាត់បង់ឆ្អឹងថ្គាមខាងលើ : ៥០-៦០
១៨-ភ្ជាត់ឆ្អឹងថ្គាមមានសមត្ថភាពលេបតែសារជាតិរាវ : ៤០-៦០
១៩-ខ្វិនសាច់ដុំអណ្ដាតទាំងស្រុង " ងាប់អណ្ដាត " : ៥០
២០-អណ្ដាតដាច់ដោចដោយសារប៉ះទង្គិច : ៥០

**ខ_ទ្រូង និង សរីរាង្គក្នុងទ្រូង :**

១-វះកាត់សួត " ពូម៉ុងអឺចតូមី " សមត្ថភាពដកដង្ហើមថយចុះតិចជាង៥០% : ៣៥-៤៥
២-កើតជំងឺនៅស្រោមបេះដូង " ហបូម័យកោស បើរីការដ មីញ៉ូការដ សាច់បេះដូង " ប្រើស "វ៉ាល់វ " មិនបណ្ដាលឱ្យមានវិបត្តិដល់មុខងារសំខាន់ៗរបស់បេះដូង " : ៣០-៥០

p

**គ_ឆ្អឹងខ្នង :**

១-ខ្វិនសងខាងមិនពេញលេញ មានសមត្ថភាពអាចរំកិលខ្លួនបាន : ២៥-៤០
២-ខ្វិនថាសឆ្អឹងខ្នងសងខាង : ២៤-៤០
៣-បាក់ឆ្អឹងតូច គួបផ្សំវិបត្តិនៃសាច់ដុំរលីង និង ស : ២៥-៣៥

**ឃ_ពោះ និង សរីរាង្គក្នុងពោះ :**

១-ការប៉ះទង្គិចផ្ទៃពោះ ប៉ះពាល់ដល់ក្រពះជាមួយនឹងផលវិបាក : ដំបៅរលួយ ខ្វះឈាម ស្លេកស្លាំង ( anémie ) ស្គមស្គាំង : ៣៥-៤៥
២-វះកាត់ក្រពះ : ៤០ -៦០
៣-វះកាត់ពោះវៀនតូចលើសពីមួយម៉ែត្រ ជាមួយនឹងវិបត្តិនៃការរំលាយអាហារ : ៣៥-៦០
៤-ដំបៅពោះវៀនតូច និងផ្លាយរន្ធចំនៅភាគខាងលើ : ២៥-៤០
៥-រន្ធផ្លាយចំនៃពោះវៀនធំជាមួយនឹងការហូរលាមក : ៣០-៤០
៦-ចោះផ្ដោកនោមនៅផ្ទៃពោះ " រន្ធនោមសិប្បនិម្មិត " : ៣០-៤០
៧-កាត់តម្រងនោមម្ខាងចោល : អ៊ុយរេឈាម ០,៦ - ១ក្រាមក្នុងមួយលីត្រ : ៣៥-៤៥
អ៊ុយរេឈាមច្រើនជាងមួយក្រាមក្នុងមួយលីត្រ : ៤៥-៦៥

**ខ. ត្រគាក សរីរាង្គនៃត្រគាក ប្រដាប់បន្តពូជ "អង្គជាតិ" :**

១-បាក់ឆ្អឹងត្រគាកជាមួយនឹងការខូចទ្រង់ទ្រាយត្រគាករបស់ស្ត្រីក្នុងអាយុកាលអាចឱ្យកំណើតកូនបាន : ៣០-៤០
២-វះកាត់ស្បូននៃស្ត្រីមិនដែលមានកូន : ៣៥-៤៥
៣-កាត់សុដនចោលនូវនារីវ័យក្មេង : ៣៥-៤៥
៤-កាត់លិង្គបុរសនៅមិនទាន់មានកូន : ៣៥-៤៥
៥-បាត់បង់ពងស្វាសទាំងពីរនៅបុរសមិនដែលមានកូន : ២៥-៤០

**គ. អវយវៈ :**

១-បាត់បង់ប្រអប់ដៃម្ខាង : ៣៥-៤០
២-កាត់ត្រង់សន្លាក់ឆ្អឹងកដៃ : ៣៥-៤០
៣-កាត់កំភួនដៃ : ៤០-៤៥
៤-កាត់ត្រង់សន្លាក់ឆ្អឹងកែងដៃ : ៤០-៤៥
៥-កាត់ឆ្អឹងដើមដៃ
-ពាក់កណ្ដាលខាងក្រោម : ៤៥-៥០
-ពាក់កណ្ដាលខាងលើ : ៥០-៥៥
៦-កាត់ត្រង់សន្លាក់ឆ្អឹងស្មា : ៥៥-៦០
៧-ខ្វិនទាំងស្រុង "ងាប់" នៃដៃម្ខាង : ៤៥-៥០
៨-អាការៈរោគនៃការឈឺចាប់កូសាល់ "កូសាល់ឈឺ" ខូចខាតទាំងស្រុងនៃដើមដៃម្ខាង : ៤៥-៥០
៩-កាត់ស្មងម្ខាង : ៣៥-៥០
១០-កាត់ត្រង់សន្លាក់ជង្គង់ : ៣៥-៤០
១១-កាត់ភ្លៅ : ៣៥-៤០
១២-ខ្វិនទាំងស្រុង "ងាប់" នៃជើងម្ខាង : ៤៥
១៣-ភ្លាត់ឆ្អឹងចង្កេះជាមួយនឹងរួញសាច់ភ្លៅ : ៤៥
p
១៤-កាត់សន្លាក់ឆ្អឹងចង្កេះ "គ្មានសន្លាក់ឆ្អឹងចង្កេះ" : ៥០-៧០

**ប្រភេទទី ៣**

**ក. ក្បាល មុខ ក :**

១-របោត់ស្បែកលលាដ៍ : ១៥-៣០
២-កាត់ឆ្អឹងលលាដ៍ចោលមួយចំណែក :
-វិជ្ជមាត្រលើសពី ៦ ស.ម : ២០-៣០
-វិជ្ជមាត្រលើសពី ១០ ស.ម : ៣០-៤០
៣-អង្គធាតុដទៃនៅក្នុងប្រអប់លលាដ៍ : ២០-៣០
៤-ហេមីប៉ារេស៊ី : ២០-៤០
៥-និយាយមិនឮស្មើតែទាំងស្រុង : ២០-៣០
៦-ឆ្កួតជ្រូកទូទៅ :
-រម្មើល "ម្ដងទៅពីរដងក្នុងមួយខែ" : ១៥-៣៥
-កម្រ " ៣ដងទៅ ៤ដងក្នុងមួយឆ្នាំ " : ១០-១៥

៧-វិលមុខ ភ្លេចភ្លាំង "ឆ្កួតជ្រូកស្រាល" "សណ្ឋានស្រាល" : ២០-៣០

៨-ឆ្កួតជ្រូកតិចតួច "មិនជាឆ្កួតជ្រូក" យាកសួន " ម្តងក្នុងមួយសប្តាហ៍ : ២០-៣០

៩-ចលនាមិនធម្មតា "ញ័រទទ្រើកប្រកាច់... លំបាកលំបិនក្នុងការងារនៃភាពឥតល្បឿង "ជាក់លាក់ " : ១០-៤០

១០-អាការៈរោគផ្ទាល់ខ្លួន "ស៊ូបហ្សិកទីហ្វ " ជាប់បន្តពីការរញ្ជួយខួរក្បាលស្បុងខួរ " : ២០-៣០

១១-អាស្តេនីបន្ទាប់ពីការប៉ះទង្គិច "សណ្ឋានមធ្យម .កណ្តាល" : ២០-៣០

១២-ហ៊ីពែរអេម៉ូទីវីតេ "ភាពឆាប់រំភើបចិត្តខ្លាំងពេក" ចរម្ក. មរៃគិត "សណ្ឋានមធ្យម" : ២០-៣០

១៣-សភាពស្រុតចុះនៃណឺរ៉ូ "មធ្យម ល្មម " : ១០-៣០

១៤-សណ្ឋានឆ្កួតជ្រូកនាពេលព្រលប់ "សន្និប្រកាស " : ២៥-៣០

១៥-ថ្លង់ទាំងសងខាងមិនពេញលេញ : ៣០-៤០

១៦-បំពង់ច្រមុះរួមតូច " កុងង៉ីណាសាល់ " ដកដង្ហើមតាមមាត់ : ២០-៣០

១៧-អន្ធការភ្នែកម្ខាង ខូចទ្រង់ទ្រាយគ្រាប់ភ្នែកម្ខាងទៀត : ២៥-៣០

១៨-កាត់គ្រាប់ភ្នែកម្ខាងចោល

-មានលទ្ធភាបដាក់កែវភ្នែកជំនួសបាន"កែវភ្នែកសិប្បនិម្មិត" : ២៥-៣០

-គ្មានលទ្ធភាពដាក់កែវភ្នែកជំនួសបាន : ៣០-៣៥

១៩-បាក់ឆ្អឹងថ្គាមខាងលើជាមួយនឹងផ្ទៃឆ្អឹងមានគុណវិបត្តិ និង ភ្ជាត់

សៀតផ្កា ថ្គាម អសមត្ថភាពនៃការរំលាយអាហារ : ៣០-៤០

២០-បាក់ឆ្អឹងថ្គាមក្រោម ផ្ទៃឆ្អឹងមានគុណវិបត្តិ ការវៀចខុសកន្លែងនៃសន្ទាក់ធ្មេញ

"កន្លែងដែលធ្មេញលើនិងក្រោមប៉ះគ្នា " : ២០-៣០

២១-សន្ទាក់ថ្គាមជាប់រឹងអសមត្ថភាពញែកច្រានឆ្អឹងថ្គាមទាំងពីរច្រើនជាង ១០ស.ម : ១៥-៤០

២២-បាត់បង់អណ្តាតមួយភាគ វិបត្តិនៃពាក្យសំដី : ២០-៣០

២៣-ថ្លង់ ត បណ្តាលមកពីអនុភាព សន្ទុះខ្យល់ធាក់នៃការផ្ទុះ

-ភាពធ្ងន់ធ្ងរ : ៤០-៦០

-ធ្ងន់ធ្ងរមធ្យម : ២០-៤០

p

**ខ-ទ្រូង និង សរីរាង្គក្នុងទ្រូង :**

១-បាក់ឆ្អឹងជំនី ខូចទ្រង់ទ្រាយឱកា "ប្រអប់ទ្រូង" ជាមួយនឹងកំរែលនៃដំបៅធ្លុះធ្លាយស្រោមសួត : ២៥-៣៥

២-វិប្បរិត និង កំរែលដទៃទៀតនៃដំបៅស្រោមសួត "ឈាមក្នុងស្រោមសួត ខ្យល់ក្នុងស្រោមសួត

ស្រោមសួតស្អិតជាប់គ្នា ហត់ដង្ហក់ "ហេម៉ូថូរ៉ាក់ " ផឺប៉ូថូរ៉ាក់ បាជីផ្សីត " : ២០-៣០

៣-វះកាត់សួត " ធីម៉ូណេតូមី" សមត្ថភាពដកដង្ហើមថយចុះតិចជាង ៥០ភាគរយ : ២៥-៣៥

៤-ការរួមតូចនៃបំពង់អាហារ មកពីការប៉ះទង្គិច ឬមកពីការលេបដោយគ្រោះថ្នាក់នៃរូបធាតុ

ឱ្យរលាក "ស៊ូដកូស៊ីប" : ២០-៤០

**គ-ឆ្អឹងខ្នង :**

១-រឹងឆ្អឹងខ្នង ចលនានៃបំណត់ និង បង្វិលមានលក្ខខណ្ឌបន្ថយចុះ និង ឈឺចាប់ : ២៥-៤០

២-អាការៈរោគនៃកន្ទុយសេះ ទល់នោមមិនពេញលេញ : ១០-៣០

**ឃ-ពោះ និង សរីរាង្គក្នុងពោះ :**

១-វះកាត់ក្រពះ :

-គ្មានវិបត្តិ : ២០-២៥

-មានវិប្បរិតជាប់ស្អិត វិបត្តិនៃការរំលាយអាហារ សុខភាពទូទៅថយចុះ : ២៥-៣៥

២-វះកាត់ពោះវៀនតូច លើសពីមួយម៉ែត្រ គ្មានវិប្បរិត និង គ្មានវិបត្តិដល់ការរំលាយអាហារ : ២៥-៣០

៣-ដំបៅធ្លាយនៃពោះវៀន :

-រន្ធធ្លាយធំនៅភាគខាងលើ : ២៥-៤០

-រន្ធធ្លាយធំនៅភាគខាងក្រោម : ២០-៣០

៤-រន្ធធ្លាយតូចបណ្តាលឱ្យចូលនូវឧស្ម័ន និងទឹកលាមក "លាមកវាវ" : ២០-៣០

៥-ការប៉ះពាល់ដល់ស្ពិនក្ទែរទ្វារលាមក ជាមួយនឹងការបន្ទោបង់ " ជុះទប់មិនឈ្នះ " : ២៥-៣០

៦-ដាំថ្លើមជាមួយនឹងវិបត្តិនៃមុខងារថ្លើម : ១៥-៣០

៧-វះកាត់តម្រងនោមម្ខាង ម្ខាងទៀតធម្មតា : ២៥

## ខ. ត្រគាក សរីរាង្គនៃត្រគាក អង្គជាតិ :

១-រន្ធរហែកធ្លាយ "អ៊ុនជិចតេ" នៃរបេរីណេ" : ២០-៤០

២-ការរួមតូចនៃទ្វារនោម "អ៊ូរ៉េត្រ"

-តម្រូវឱ្យព្យាបាលដោយពង្រីកជារៀងរាល់ខែ : ១០-៣០

-ជាមួយនឹងរន្ធរហែកក្លាយ : ២៥-៤០

៣-កាត់លិង្គបុរសមានកូនរួចហើយ : ២៥-៣៥

៤-វះកាត់ស្បូនស្ត្រីអាយុតិចជាង៤៥ឆ្នាំ ដែលមានកូនរួចហើយ : ២៥-៣៥

៥-កាត់សុដន់ទាំងពីរចោលនៅពេលស្ត្រីដែលមានកូនរួចហើយ : ២៥-៤០

៦-រន្ធធ្លាយពីថ្លោកនោមទៅទ្វារមាស "ថ្លោកនោម ទ្វារមាស" : ២០-៣០

## ច. អវយវៈ :

១-បាត់បង់មេដៃ និង ចង្អុលដៃ : ២៥-៣០

២-បាត់បង់ម្រាមដៃបួន មិនចំពោះម្រាមណា : ២៥-៣០

៣-បាត់បង់ម្រាមដៃទាំងប្រាំ : ៣០-៣៥

p

៤-ម្រាមទាំងប្រាំរឹងក្រញង់ : ២៥-៣០

៥-សន្លាក់ក្លែងក្លាយ ខុសកន្លែង នៃឆ្អឹងកំភួនដៃទាំងពីរ : ២០-៣០

៦-កែងដៃរឹងក្រញង់ តំរិយាបថសន្ទឹងពី ១១០-១៨០អង្សា : ២៥-៤០

៧-បាត់ឆ្អឹងដើមដៃជាមួយនឹងសន្លាក់ក្លែងក្លាយ : ២៥-៣៥

៨-បាក់កលល្បៈនៃឆ្អឹងដើមដៃ ផ្លែឆ្អឹងមានគុណវិបត្តិជាមួយនឹងលក្ខខណ្ឌបន្ថយចុះនៃចលនារបស់ស្មា : ២៥-៣០

៩-ស្មារឹងក្រញង់ :

-កន្ទែកចេញ " អាប់ឌុលស្យុង " ពី ៤៥ អង្សា : ២៥-៣០

-កន្ទែកចេញពី ១០ អង្សា : ៣០-៣៥

១០-ខ្ទិនឈើរ៉ូ ម៉េដ្យង់ : ២៥-៣០

១១-ខ្ទិនឈើរ៉ូ រ៉ាដ្យាល់នៅភាគខាងលើនៃទ្រីសិបស ប្រអប់ដៃធ្លាក់ចុះរវិករវក់ : ២៥-៣០

១២-ខ្ទិនឫសឈើរ៉ូខាងលើ " រ៉ាឌីគុយឡែរ " ធុនឌុចចេនន៍អេរ៉ុស " ខ្ទិនសាច់ដុំ ដែលតួអឹង
ប៊ីសិបស ប្រាចាល់មុខ និងឡុងស៊ូឌីណាទ័រ " : ២៥-៣០

១៣-ខ្ទិនឫសឈើរ៉ូខាងក្រោម ខ្ទិនសាច់ដុំផ្ទៃជីសប៉ះម្រាមដៃ : ២៥-៣៥

១៤-អាការៈរោគវូលក្មេន " វូញ ឡុងផ្ទៃជីសស័រម្រាមដៃដោយហ៊ីប៉ូរ៉ាស្ដយឡារីសាស្សុនប្រភពនៃការប៉ះទង្គិច : ២០-៣៥

១៥-បាត់បង់ម្រាមជើងទាំងប្រាំ និង ឆ្អឹងបាតជើង : ២០-២៥

១៦-បាត់បង់ប្រអប់ជើង សល់តែការណោអូម " ឆ្អឹងកែងជើង " ឬកាត់សន្លាក់តាមរបៀបចូប៉ារតិ : ២៥-៣០

១៧-ការវះកាត់តាមរបៀបលីសហ្វ្រង់គិរីការជិ ពីរ៉ូគូលហ្វិ : ២៥-៣០

១៨-កាត់សន្លាក់កជើង : ៣៥

១៩-បាក់ថាសឆ្អឹង ផ្កាតូទីប៊ីយ៉ា ជង្គង់រឹងក្រញង់ : ២០-៣០

២០-បាក់ឆ្អឹងស្មងទាំងពីរ ផ្ទៃឆ្អឹងមានគុណវិបត្តិ ស្មងវៀចជាមួយនឹងការរួញខ្លីលើសពី ៥ ស.ម : ២០-២៥

២១-សន្លាក់ក្លែងក្លាយនៃស្មង : ៣៥-៥០

២២-បាក់ ឬកាត់ត្រង់សន្លាក់អង្កុញ ជង្គង់រឹងក្រញង់ បស្រ្តិត ត្វាឡិសេបសិ : ១៥-២៥

២៣-កំអែល លេស្បុងនៃការប៉ះទង្គិចប៉ះពាល់ដល់សន្លាក់ជង្គង់ ស្មងបត់បានពី ១៥០-១៣៥អង្សា : ២០-៣០

២៤-បាក់មួយភាគបី កណ្តាលឬខាងក្រោម នៃឆ្អឹងភ្លៅ ផ្ទៃឆ្អឹងមានគុណវិបត្តិ អក្ស័វៀចរួញខ្លីលើសពី ៤ ស.ម : ២០-៣០

២៥-បាក់មួយភាគបីខាងលើ ឬក៏ឆ្អឹងភ្លៅ ផ្ទៃឆ្អឹងមានគុណវិបត្តិ បង្ខៀចនៃអ័ក្សឈឺចាប់នៅដំណើរ : ២៥-៣០

២៦-ចង្កេះរឹងក្រញង់ គ្មានវៀចឆ្អឹងភ្លៅ : ២៥-៣០

២៧-ចង្កេះរឹងក្រញង់វៀចឆ្អឹងភ្លៅ : ៣០-៣៥

២៨-សម្លាកមានគុណវិបត្តិនៃការរលាកនៅសន្លាក់ជង្គង់ "កន្លាក់អាចម៍ " ឬនៅជង្គង់
លក្ខខណ្ឌបន្ថយចុះដែលចលនាបត់និងលាស្មងជើងតិចជាង ៩០ អង្សា : ៣០-៣៥

២៩-ជំងឺរលាកឆ្អឹង និងខួរឆ្អឹង "អូស្តេអូម្មេលីក " រទ្ធធ្លាយឆ្អឹងច្រើនកន្លែង និងសារជាតិ" រឹងក្បាល : ២០-៥០

## <u>ប្រភេទទី ៤</u>

<u>ក-ក្បាល មុខ ក :</u>

១-បាត់បង់មួយភាគនៃឆ្អឹងលលាដ៍វិជ្ជមាត្រ ២ ស.ម : ១៥-២០

២-អន្ធការភ្នែកម្ខាង ម្ខាងទៀតធម្មតា : ២៥

៣-ឆ្អឹងថ្គាមខាងលើ :

-បាត់បង់ធ្មេញភាគច្រើន គ្មានលទ្ធភាពដាក់ធ្មេញបាន : ២០

-បាក់មិនពង្រឹងពង្រួមបាននៃឆ្អឹងថ្គាមខាងលើ សមត្ថភាពទំពារថយចុះ p : ២០-២៥

-សន្លាក់ធ្មេញវៀចតិចតួច : ១៥-២០

-ធ្លុះធ្លាយក្រអូមមាត់ ធ្លាយពីម្ខាងទៅម្ខាងរវាងមាត់ច្រមុះ : ២០-៣០

៤-ឆ្អឹងថ្គាមខាងក្រោម :

-បាក់មិនពង្រឹងពង្រួមបាននៃមែក "ប្រង់ចិ " ទទឹង" ចាត់ថ្នាក់ទៅតាមសមត្ថភាពទំពារ : ២០-២៥

៥-ភ្ជាត់ឆ្អឹងថ្គាមសារជាតិ : ១០-២០

៦-កាត់អណ្តាតមួយភាគ រអាក់រអួលដល់ការនិយាយស្តី ការទំពារអាហារ និងការលេបអាហារ : ១០-២០

៧-ថ្ពង់ទាំងសងខាង កិរិតមធ្យម : ២០-២៥

៨-កាត់ច្រមុះចោល តម្រូវឱ្យផ្លាស់ប្តូរមុខវិជ្ជាជីវៈ : ១០-២៥

៩-ជំងឺរលាកស៊ីនូសនៃថ្គាម "ស៊ីនូសអ៊ីត " ថ្វាស អេថ្មអ៊ីត ចាត់ថ្នាក់ទៅតាមការធ្ងន់ធ្ងរនៃជំងឺ
និងចំនួនស៊ីនូសដែលរងគ្រោះមានជំងឺ : ១០-៣០

១០-វិបត្តិពាក្យសំដី និងវិបត្តិដកដង្ហើមមានប្រភពពីរ :

-ខ្ទិនឈើរ៉ូវ៉េក្ខុវេទតិ

-សម្លាកនៅបំពង់សំលេង ដើមក

-ជំងឺរលាកសន្លាក់ត្រីកូ -អារីថេន៍រអ៊ីដ :

និយាយមិនច្បាស់ : ២០-៣០

ហត់ដង្ហក់មធ្យម : ១៥-២០

១១-កំអែលប៉ះទង្គិចមកពីសន្ទុះខ្យល់ធាក់នៃការផ្ទុះ

-អាការៈរោគផ្ទាល់ខ្លួនជាប់បន្តពីការរញ្ជួយខួរ "សណ្ឋានស្រាល" : ២០

-វិបត្តិនៃពាក្យសំដីនិងកិរិតស្តាប់សូរសំលេងអាត្ថិតេត្រចៀកធ្លាក់ចុះ : ១១-២០

-ជំងឺប៉ាស៊ីដូវ "ពពក" កើតឡើងនៅរវាងខែដំបូងក្រោមការប៉ះទង្គិច : ៥-២០

-យ៉ាបែតផ្អែម "ទឹកនោមផ្អែម " ជាប់បន្តពីការប៉ះទង្គិចលលាដ៏ ឬការបុកទង្គិច : ២៥

១២-ដំបៅរបួសផ្នែកទន់ " សាច់ដុំ " នៅស្មា ជាមួយនឹងស្នាមដុំនៃសាច់ដុំក និងមុខ : ១៥-២០

<u>**ខ.ទ្រូង និង សរីរាង្គក្នុងទ្រូង**</u> :

១-វះកាត់ក្លែបសួត "ឡូបេកតូមី " ជាមួយនឹងសមត្ថភាពដកដង្ហើមថយចុះតិចតួច : ១៥-២០

<u>**គ.ពោះ និង សរីរាង្គក្នុងពោះ**</u> :

១-តំណ "កាត់តភ្ជាប់ ក្រពះ ពោះវៀន " : ១៥-២០

២-ស្នះពោះវៀន វះកាត់ឡើងវិញ មកពីវិបត្តិនៃអន្តរាគមន៍វះកាត់ចាស់នៃពោះវៀន : ១៥-២៥

៣-វះកាត់ពោះវៀនតូច "តិចជាងមួយម៉ែត្រ " : ២០-២៥

៤-កាត់ថ្លើមចោលមួយក្លែប : ២០-២៥

៥-វះកាត់ផាល " អណ្តើក " អនៈហេមីមធ្យម : ១៥-៣៥

<u>**ឃ.ត្រគាក សរីរាង្គនៃត្រគាក អង្គជាតិ**</u> :

១-កាត់ពងស្វាសចោលទាំងពីរ លើបុរសអាយុលើសពី ៥០ ឆ្នាំ : ១០-២០

២-វះកាត់ស្បូនចំពោះស្ត្រីអាយុលើសពី ៤៥ ឆ្នាំដែលមានកូន : ២០-២៥

៣-សម្លាកច្រើនអន្លើនៃទ្វារមាស និងយោនី : ១០-២៥

៤-កាត់សុដនចោលម្ខាងនៅស្ត្រី ឬក្មេងស្រី : ១០-២០

៥-បាក់ឆ្អឹងគូថ ជាមួយនឹងវិបត្តិសាច់ដុំរលីង និងស : ២០-២៥

p

<u>**ខ.អវៈយវៈ**</u> :

១-បាត់បង់មេដៃ និង ឆ្អឹងបាតដៃ : ១៨-២១

២-ចង្អុល និង ម្រាមដៃពីរទៀត ក្រៅពីមេដៃ : ២០-២២

៣-បាត់បង់មេដៃ និង ម្រាមដៃមួយទៀត ក្រៅពីចង្អុលដៃ : ២០-២២

៤-បាត់បង់មេដៃ និង ម្រាមដៃពីរទៀត ក្រៅពីចង្អុលដៃ : ២០-២៥

៥-សម្លាកធំនៃការរលាកប្រអប់ដៃ. ម្រាមដៃរឹង និងក្រញាង ឬមិនលា បត់បាន :

-ម្រាមដៃទាំងប្រាំ : ២៥-៣០

-មេ និង ចង្អុលដៃ : ២០-២៥

-មេ និង ម្រាមដៃមួយទៀត : ១៥-២០

៦-សម្លាកមានគុណវិបត្តិនៅកែងដៃ ដែលកំណត់ចលនាកំភួនដៃ :

-លាតសន្ធឹងពី ១៨០ មក ១១០ អង្សា : ២០-២៥

-បំណត់ពី ១១០ មក ៧៥ អង្សា : ១៥-២០

-បំណត់ពី ៧៥ មក ៣៥ អង្សា : ១០-១៥

៧-សម្លាកមានគុណវិបត្តិនៅក្លៀក ដែលកំណត់នៅចលនាស្មា :

-ដើមដៃ កន្ទែកចេញពី ៤៥ អង្សា ៖ ១០-២៥

-ដើមដៃកន្ទែកចេញពី ១០ អង្សា ៖ ២៥-៣០

៨-សន្ទាក់ដើរឹងក្រញង់ ជាមួយនឹងចលនាចម្លតានៃម្រាមដៃ :

-ឥរិយាបថនៃមុខងារ "ធ្វើការងារ" ៖ ១៥-២០

-ឥរិយាបថកោង ៖ ២០-២៥

៩-បាក់ឆ្អឹងកំភួនដៃទាំងពីរ ផ្លែឆ្អឹងមានគុណវិបត្តិ អ័ក្សវៀច រួញខ្លី ៖ ១៥-២៥

១០-កែងដើរឹងក្រញង់ជាមួយនឹងបំនត់ដើមកំភួនដៃពី ៦០ ទៅ ១១០ អង្សា ៖ ១៥-២៥

១១-ស្មារឹងក្រញង់ ដើមដៃកន្ទែកចេញពី ៩០ អង្សា ៖ ១០-២៥

១២-ខ្ទិនណឺរ៉ូ មេដ្យង់ នៅកន្លែងកដៃ ៖ ២០-២៥

១៣-ខ្ទិនណឺរ៉ូ កូប៊ីតាល់ ៖ ១៥-២៥

១៤-ខ្ទិន រ៉ាដ្យាលនៅខាងក្រោមទ្រីសបស៍ ៖ ២០-២៥

១៥-បាក់ឆ្អឹងដងកាំបិត ផ្លែឆ្អឹងមានគុណវិបត្តិជាមួយនឹងសញ្ញាតៀបត្បៀតណឺរ៉ូ ៖ ១៥-២៥

១៦-បាក់ឆ្អឹងស្លាបប្រចៀវ ៖ ១០-៣០

១៧-បាត់បង់ម្រាមជើងប្រាំ ៖ ៥-១០

១៨-បាត់បង់ឆ្អឹងអាំស្ត្រាគ្គាល ៖ ២៥

១៩-បាត់បងឆ្អឹងកែងជើង ៖ ២៥-៣០

២០-សន្ទាក់ឆ្អឹងកជើងរឹងក្រញង់ ៖ ១៥-២០

២១-បាត់បង់ភ្នែកគោលទាំងពីរ ស្មងវៀច ៖ ១៥-២០

២២-បាក់ឆ្អឹងស្មងទាំងពីរ " ទីប៊្យា និងប៉េរ៉ូណេ " ផ្លែឆ្អឹងមានគុណវិបត្តិ ស្មងវៀច រួញខ្លីតិចជាង ៥ ស.ម ៖ ១៥-២០

២៣-លេស្យុង ជង្គង់ ឥរិយាបថអនុគ្រោះដល់ស្មង "១៣៥-១៨០ អង្សា" ៖ ១៥-២០

២៤-អង្គធាតុដទៃនៅក្នុងសន្ទាក់ជង្គង់ ៖ ១០-២៥

២៥-ជង្គង់រឹងក្រញង់ ឥរិយាបថស្តាំនៃស្មង " ១៨០ អង្សា " ៖ ១៥-២៥

២៦-សម្លាកមានគុណវិបត្តិនៃការរលាកនៅសន្ទាក់ជង្គង់ " កន្ទាក់អាចម៍ " ឬនៅជង្គង់កំណត់
ចលនាបត់ និងលាពី ៩០ - ១៣៤ អង្សា ៖ ១០-៣០

២៧-ដំបៅស្មង សម្លាកមានគុណវិបត្តិជាមួយនឹងការរួញខ្លីនៃសសៃកែង "តង់ដុងអាគ្ជីល" ៖ ១៥-២៥

២៨-បាក់មួយភាគបីខាងលើនៃឆ្អឹងភ្លៅ ឬក៏ឆ្អឹងភ្លៅ ផ្លែឆ្អឹងមានវិបត្តិសាច់ដុំខាងក្រោមវៀច ឈឺចាប់នៅដំណើរ ៖ ២៥-៣០

២៩-ខ្ទិនណឺរ៉ូស្យាទីគ ៖ ២៥

៣០-ឈឺចាប់នៃណឺរ៉ូស្យាទីគ ចាត់ថ្នាក់ទៅតាមកំរិតនៃការឈឺចាប់ និងកំរិតនៃការលំបាកលំបិននៅដំណើរ ៖ ១០-២៥

៣១-ភ្ជាត់ឆ្អឹងចង្កេះ និង រឹងក្រញង់ ៖ ២០-២៥

៣២-ជំងឺរលាកឆ្អឹង និងខួរ ជាមួយនឹងរន្ធធ្លាយច្រើនអន្លើ និងសារជាតិ ៖ ២០-៣០

៣៣-ស្វិតសាច់ដុំ ឈឺចាប់ ប៉ារ៉េស៊ីអវៈយវៈមកពីការព្យាបាលដោយសេរ៉ូមអង់ទីតេតានិច ៖ ២០

៣៤-អាណោប្រីស្មអារទែរ វ៉ែន នៃអវៈយវៈ ចាត់ថ្នាក់ទៅតាមវិប្បរិតនៃរបត់ឈាម និង
វិបត្តិនៃមុខងារផ្លាស់ប្តូរកន្លែង ៖ ៥-២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ: ០៩៦ សកបយ.

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០០៣

# ប្រកាស
# ស្តីពី
# ការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។
-បានឃើញប្រកាសលេខ ១៤១ សកបយ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈកម្មការប្រឹក្សា គម្រោងដោះស្រាយវិវាទការងារនៅកម្ពុជា
-បានឃើញប្រកាសលេខ ៣៣៨ សកបយ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០២ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល
-បានឃើញលិខិត ចុះថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០០៤ របស់ប្រធានទីប្រឹក្សាបច្ចេកទេសនៃគម្រោងដោះស្រាយវិវាទការងារនៅកម្ពុជា ស្តីពីសំណើសុំតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល

# សម្រេច

**ប្រការ១.-** តែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលមានសមាសភាពដូចខាងក្រោម :

**I-សមាជិកដែលស្នើឡើងដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា:**

១- លោក អាំង អេងថុង

២- លោកជំទាវ គីម សត្ថាវី

៣- លោក គីម យ៉ាតដារ៉ារិទ្ធ

៤- លោក គង់ ផល្លះ

៥- Mr.Rendall, Matthew

៦- លោក សុខ ម៉ាធឿង

៧- លោក ស សូវ៉ាន

**II-សមាជិកដែលស្នើឡើងដោយសមាគមនិយោជក:**

១- លោក Gui Anvanith

២- លោក ហេង ជី

៣- លោក ម៉ារ សំបូរណា

៤- លោក អ៊ុក រី

៥- លោក Wong Chiv

៦- កញ្ញា យូ ស៊ុនទី

៧- លោក Kim Leong Lee

**III-សមាជិកដែលស្នើឡើងដោយសហជីព កម្មករនិយោជិត(សហព័ន្ធសហជីព):**

១- លោក អន ណន

២- លោក គុយ នាម

៣- លោក លីវ សុវណ្ណា

៤- លោកស្រី ស៊ុន គីមស៊ាន

៥- លោក សុង វណ្ណស៊ីន

៦- លោក ទូន ស៊ីផាន់

៧- លោក វង្ស វណ្ណា

**ប្រការ២.-** យោងតាមមាត្រា១២ នៃច្បាប់ស្តីពីការងារ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានភារកិច្ចដូចតទៅ:

ក្រុមប្រឹក្សាអាជ្ញាកណ្តាល គ្មានភារកិច្ចពិនិត្យបញ្ហាដទៃ ក្រៅពីបញ្ហាដែលមានបញ្ជាក់ក្នុងកំណត់ហេតុមិនព្រមសះជា ឬបញ្ហាដែលកើតក្រោយការធ្វើកំណត់ហេតុ ជាផលវិបាកផ្ទាល់នៃការវិវាទនេះប៉ុណ្ណោះ ។

ក្រុមប្រឹក្សានេះដោះស្រាយជាផ្លូវច្បាប់ចំពោះការវិវាទដែលទាក់ទងនឹងការបកស្រាយ និងការអនុវត្តបញ្ញត្តិច្បាប់ ឬ អនុសញ្ញាណាមួយ ។ ក្រុមប្រឹក្សានេះដោះស្រាយដោយសមធម៌ចំពោះការវិវាទឯទៀតទាំងអស់ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាល មានអំណាចធំទូលាយ ដើម្បីស៊ើបអំពីស្ថានភាពសេដ្ឋកិច្ចនៃសហគ្រាស និងស្ថានភាពខាងសង្គមកិច្ចនៃកម្មករនិយោជិតដែលជាសាមីខ្លួនក្នុងការវិវាទ ។

ក្រុមប្រឹក្សានេះ មានអំណាចអង្កេតគ្រប់បែបយ៉ាងនៅទីកន្លែងសហគ្រាស ឬ អង្គការវិជ្ជាជីវៈផ្សេងៗ ព្រមទាំងមានអំណាចចាត់ឱ្យភាគីជូនឯកសារ ឬ ពត៌មានខាងសេដ្ឋកិច្ច គណនេយ្យ ស្ថិតិហិរញ្ញវត្ថុ ឬ រដ្ឋបាលដែលមានប្រយោជន៍ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ។ ក្រុមប្រឹក្សានេះ អាចសុំអ្នកជំនាញការជួយបានទៀតផង ។

សមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវលាក់អាថ៌កំបាំងវិជ្ជាជីវៈចំពោះពត៌មាន និងឯកសារទាំងឡាយដែលគេបានជូនមកឱ្យខ្លួនពិនិត្យ និងចំពោះហេតុការណ៍ទាំងអស់ ដែលខ្លួនបានដឹងក្នុងការបំពេញបេសកកម្មរបស់ខ្លួន ។

ការប្រជុំនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវប្រព្រឹត្តទៅដោយបិទទ្វារ ។

**ប្រការ៣.-** កិច្ចដំណើរការ អំណាចយុត្តាធិការ ការចេញសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវអនុវត្តតាមបទប្បញ្ញត្តិ នៃប្រកាសលេខ ៣៣៨សកបយ. ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០២ ព្រមទាំងវិធាននៃនីតិវិធីដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ៣៣៨ នេះផង ។

**ប្រការ៤.-** សមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអាណត្តិមួយឆ្នាំ ដោយគិតចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០០៣ ។ p

**ប្រការ៥.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ   សាសនា   ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច  ការងារ  បណ្តុះបណ្តាលវិជ្ជាជីវៈ

និងយុវនីតិសម្បទា

លេខ: ១៣៨ សកបយ.

រាជធានីភ្នំពេញ ,ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៣

# ប្រកាស

## ស្តីពី

## សំឡេងក្នុងទីកន្លែងធ្វើការ

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច  ការងារ  បណ្តុះបណ្តាលវិជ្ជាជីវៈ  និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## <u>សំរេច</u>

**ប្រការ១.-** និយោជកនៃសហគ្រាស គ្រឹះស្ថានដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវរៀបចំយ៉ាងណាឱ្យប្រពលភាពសំឡេងក្នុងទីកន្លែងធ្វើការស្ថិតនៅទាបបំផុត ហើយប្រពលភាពសំឡេងនេះត្រូវស្ថិតនៅក្នុងព្រំដែនមួយដែលមិនធ្វើឱ្យខូចសុខភាពកម្មករនិយោជិត ពិសេសគឺមិនធ្វើឱ្យខូចសោតវិញ្ញាណរបស់គេទាំងពួង ។

**ប្រការ២.-** ដើម្បីទទួលបានលទ្ធផលដូចមានចែងក្នុងប្រការ១ ខាងលើ និយោជកត្រូវ :-

- ឱ្យឯកសិទ្ធិរបៀបផលិតណាដែលបញ្ចេញសំឡេងតិច
- បន្ថយនៅដើមប្រភពនៃប្រពលភាពសំឡេង ដែលបញ្ចេញដោយបរិក្ខារការងារពិសេស សំឡេងម៉ាស៊ីន និងគ្រឿងចក្រ

- ដាក់ឱ្យនៅដាច់ឆ្ងាយពីគេ នូវបរិក្ខាការងារណាដែលមានប្រភពសំឡេងខ្លាំង នៅពេលដំណើរការ និងត្រូវការវត្តមានកម្មករនិយោជិតតិចបំផុត ។
- ជៀសវាងការសាយភាយសំឡេងពីរោងជាងមួយ ទៅរោងជាងមួយទៀត
- ចាត់ចែងការងារនៅតាមរបៀបដែលកម្មករនិយោជិតនៅឆ្ងាយពីប្រភពសំឡេង
- រៀបចំអគារយ៉ាងណាឱ្យសំឡេងខ្ទរត្រូវបានកាត់បន្ថយ(Reverberation du bruit) ។

**ប្រការ៣.-** កំរិតទទួលរងសំឡេងប្រចាំថ្ងៃ ឬកំរិតសំឡេងជាមធ្យម ដែលកម្មករនិយោជិតម្នាក់ៗទទួលរង ក្នុងរយៈពេលធ្វើការពេញមួយថ្ងៃ មិនត្រូវឱ្យលើសពី ៨៥ ដេស៊ីបែលអា ។

**ប្រការ៤.-** ក្នុងករណីចាំបាច់ និង នៅគ្រប់កាលៈទេសៈ ប្រសិនបើតាមលក្ខណៈបច្ចេកទេស គេមិនអាចបន្ថយប្រពលភាពសំឡេងឱ្យនៅក្រោម ៨៥ ដេស៊ីបែលអា បានទេ និយោជិកត្រូវដាក់ឱ្យកម្មករនិយោជិតនូវបរិក្ខាការពារបុគ្គលិកដ៏ត្រឹមត្រូវ និងធានាថា បរិក្ខាទាំងនោះត្រូវបានប្រើប្រាស់ពិតប្រាកដ ។

**ប្រការ៥.-** ការមិនអនុវត្តតាមបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោសដូចមានចែងក្នុងជំពូកទី ១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៦.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

p

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខ: ១៣៩ សកបយ.

រាជធានីភ្នំពេញ ,ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០០៣

# ប្រកាស
## ស្តីពី
## ការងារក្នុងមណ្ឌលហាប់

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## សំរេច

**ប្រការ១.-** មណ្ឌលហាប់គឺលំហរអាកាសនៅក្នុងធុងធំ ស៊ីទែន អន្លង់ បាតនាវា ប្រឡាយបង្ហូរក្នុងដីបំពង់ លូ អណ្តូង ផ្លូវក្នុងអណ្តូងរ៉ែ បន្ទប់ក្រោមដី ផលារាជ ។ល។ ដែលមានមាត់រន្ធ ឬច្រកចូលតូច មិនអាចឱ្យមានការផ្លាស់ប្តូរខ្យល់អាកាសបានគ្រប់គ្រាន់សំរាប់ការដកដង្ហើម ។ មណ្ឌលហាប់អាចខ្វះខ្យល់អុកស៊ីហ្សែន ហើយមាន ឬអាចនឹងមានសារធាតុពុល ឬសារធាតុងាយឆាបឆេះ ។ មាត់រន្ធ ឬច្រកចូលនៃមណ្ឌលហាប់ ត្រូវឱ្យមានទំហំសមស្របសំរាប់ឱ្យកម្មករនិយោជិតអាចចូល ឬ ចេញ ឬត្រូវបានជួយសង្គ្រោះដោយគ្មានការលំបាក ។

**ប្រការ២.-** មុននឹងអនុញ្ញាតឱ្យកម្មករនិយោជិតម្នាក់ចូលក្នុងមណ្ឌលហាប់ និយោជកត្រូវមានវិធានការចាំបាច់ដើម្បីធានាសុវត្ថិភាពកម្មករនិយោជិត ជាពិសេសការពារ :-

-កុំឱ្យមានអគ្គីភ័យ ឬការផ្ទុះ

-កុំឱ្យមានការថប់ដង្ហើមដោយសារខ្វះអុកស៊ីហ្សែន

-កុំឱ្យពុលដោយសារឧស្ម័ន ចំហាយ ឬធូលីមានជាតិពុល

-កុំឱ្យបរិយាកាសឡើងកំដៅហួសកំណត់

-កុំឱ្យមានការធ្លាក់ពីទីខ្ពស់ ។

**ប្រការ៣.-** នៅក្នុងការដ្ឋានមណ្ឌលហប់ ការបក់បញ្ចេញបញ្ចូលខ្យល់ដោយធម្មជាតិ ឬដោយសិប្បនិម្មិត ត្រូវមានលទ្ធភាពបក់បញ្ចូលខ្យល់ថ្មីយ៉ាងតិច ៣០ ម៉ែត្រគ្រីគុណសំរាប់មនុស្សម្នាក់ក្នុង ១ម៉ោងពេញរយៈពេលនៃការអនុវត្តការងារ ។

**ប្រការ៤.-** ការសាយភាយសារធាតុមានគ្រោះថ្នាក់ ដោយសារការអនុវត្តន៍ការងារក្នុងមណ្ឌលហប់ ដូចជាការផ្សារ ការលាបថ្នាំ ត្រូវបានបឺតចេញតាំងពីដើមប្រភពជាបណ្តើរៗ ឱ្យស្របតាមប្រកាសស្តីពីការបញ្ចេញបញ្ចូលខ្យល់ និងការសំអាតបរិយាកាស ។ បរិមាណខ្យល់ដែលត្រូវបក់បញ្ចូល ត្រូវគិតឱ្យបានសមស្របទៅនឹងខ្យល់ដែលបានបឺតចេញ ។ គុណភាពខ្យល់ក្នុងមណ្ឌលហប់ ត្រូវបានត្រួតពិនិត្យជាទៀងទាត់ពេញរយៈពេលអនុវត្តការងារ ។

**ប្រការ៥.-** ប្រសិនបើបរិយាកាសនៃមណ្ឌលហប់មិនអាចសំអាតបានត្រឹមត្រូវទេ កម្មករនិយោជិតដែលបំពេញការងារនៅទីនោះ ត្រូវពាក់ម៉ាស់ការពារមានស្វ័យភាពដែលមិនមានប្រើខ្យល់ក្នុងមណ្ឌលហប់សំរាប់ការដកដង្ហើម ។

**ប្រការ៦.-** នៅក្នុងមណ្ឌលហប់ និយោជកត្រូវផ្តល់សំភារៈការពារបុគ្គលចាំបាច់មួយចំនួនដូចជា :- មួកកាសការពារក្បាល និងមុខ សំលៀកបំពាក់ ស្បែកជើងក្រាស ស្រោមដៃ វ៉ែនតា ជាដើម ។

**ប្រការ៧.-** ប្រសិនបើមណ្ឌលហប់ជាកន្លែងតូចចង្អៀត ឬងាយឆេះ និងផ្ទុះ សំភារៈអគ្គិសនីទាំងឡាយព្រមទាំងសំភារៈសំរាប់បំភ្លឺ ដែលប្រើប្រាស់នៅទីនោះ ត្រូវធានាថាមានគុណភាពសមស្របល្អ ។

**ប្រការ៨.-** កាលណាមានកម្មករនិយោជិតណាម្នាក់ចូលទៅធ្វើការនៅក្នុងមណ្ឌលហប់ និយោជកត្រូវចាត់តាំងឱ្យមានឆ្មាំចាំឃ្លាំមើលជាប្រចាំ ហើយត្រូវរក្សាទំនាក់ទំនងជាប់ជានិច្ចដោយភ្នែក ឬដោយសំឡេង ។ កម្មករនិយោជិតដែលធ្វើការក្នុងមណ្ឌលហប់ ត្រូវមានខ្សែព្រយុងសំរាប់ទាញយកចេញក្រៅនៅពេលចាំបាច់ ។

**ប្រការ៩.-** ឆ្មាំដែលចាំឃ្លាំមើលអ្នកធ្វើការក្នុងមណ្ឌលហប់ ត្រូវមានសំភារៈជួយសង្គ្រោះគ្រប់គ្រាន់ នឹងត្រូវបានរៀនសូត្រអំពី :-

-វិន័យការងារក្នុងមណ្ឌលហប់

-ប្រតិកម្ម និង សកម្មភាពនៅពេលមានអាសន្ន

-បច្ចេកទេសជួយសង្គ្រោះ ។

**ប្រការ១០.-** កម្មករនិយោជិតម្នាក់ មុននឹងត្រូវបានចាត់តាំងឱ្យបំពេញភារកិច្ចក្នុងមណ្ឌលហាប់ ត្រូវបានរៀនសូត្រអំពីវិធានសន្តិសុខសំខាន់ៗ ដែលត្រូវគោរព និង ត្រូវមានលិខិតបង្គាប់ការឱ្យធ្វើប្រតិបត្តិការក្នុងមណ្ឌលហាប់ ចេញឱ្យដោយតំណាងសហគ្រាសពេញសមត្ថភាព ។ លិខិតបង្គាប់ការឱ្យធ្វើប្រតិបត្តិការក្នុងមណ្ឌលហាប់ ត្រូវមានបញ្ជាក់អំពី :-

-ប្រតិបត្តិការដែលត្រូវធ្វើ

-ឈ្មោះកម្មករនិយោជិតដែលត្រូវធ្វើប្រតិបត្តិការ

-ឈ្មោះ និង ឋានៈអ្នកចេញលិខិតបង្គាប់ការ

-ឈ្មោះ និង ឋានៈអ្នកចាំឃ្លាំមើល

-វិធានសន្តិសុខសំខាន់ៗ ដែលត្រូវគោរព ។

**ប្រការ១១.-** ការមិនអនុវត្តតាមបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោសដូចមានចែងក្នុងជំពូកទី ១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ១២.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

p

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខៈ ១៧៤ សកបយ. រាជធានីភ្នំពេញ , ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ
ស២០០៣

# ប្រកាស
## ស្តីពី
## ការបង្កើតលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២ / នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។
-បានឃើញប្រកាសលេខ ១៤១ សកបយ ចុះថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈកម្មការប្រឹក្សាគម្រោងដោះស្រាយវិវាទការងារនៅកម្ពុជា
-បានឃើញប្រកាសលេខ ៣៣៨ សកបយ ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០០២ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល
-បានឃើញប្រកាសលេខ ០៩៦ សកបយ ចុះថ្ងៃទិ ១២ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល

## សំរេច

**ប្រការ១.-** បង្កើតលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលសំរាប់គ្រប់គ្រង និង សំរបសំរួលដល់ការដោះស្រាយវិវាទការងាររួមដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ លេខាធិការដ្ឋាននេះមានមន្ត្រីទទួលខុសត្រូវដូចតទៅ :-

១- លោក ថូ ប៊ុនថន ជាប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

២-លោក ឃាំ ភា ជាមន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

៣-លោក ជួប ណារ៉ាត់ ជាមន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

**ប្រការ២.-** ការរៀបចំ និង ការប្រព្រឹត្តិទៅរបស់លេខាធិការដ្ឋាន ដែលមានចែងក្នុងប្រការ ១ ខាងលើត្រូវស្ថិតក្រោមការទទួលបន្ទុករបស់នាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

**ប្រការ៣.-** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ**
**និងយុវនីតិសម្បទា**

លេខៈ ៤៣៧ សកបយ. រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៣

# ប្រកាស
## ស្តីពី
## ការផ្លាស់ប្តូរសមាសភាពសមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ក្បរងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។
-បានឃើញប្រកាសលេខ ១៤១ សកបយ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈកម្មការប្រឹក្សាគម្រោងដោះស្រាយវិវាទការងារនៅកម្ពុជា
-បានឃើញប្រកាសលេខ ៣៣៨ សកបយ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០២ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល
-បានឃើញលិខិត ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៣ របស់ប្រធានទីប្រឹក្សាបច្ចេកទេសនៃគម្រោងដោះស្រាយវិវាទការងារនៅកម្ពុជា ស្តីពីសំណើសុំតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល

## សំរេច

**ប្រការ១.-** ផ្លាស់ប្តូរសមាសភាពសមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលមានសមាសភាពដូចខាងក្រោមៈ

**I-សមាជិកបំរុងដែលគណៈកម្មការប្រឹក្សាគម្រោងបានអនុម័តរួចហើយៈ**

- លោក **កៅ ថាច (Kao Tach)** ជំនួសលោក **Gui Anvanith**

II- សមាជិកដែលស្នើឡើងដោយសមាគមនិយោជក:

- លោក ហែម ណារិទ្ធ (Naryth H. HEM) ជំនួសលោក KIM Leong Lee

**ប្រការ២.-** លោក កៅ ថាច និង លោក ហែម ណារិទ្ធ ជាសមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល មានអាណត្តិដោយគិតចាប់ពីថ្ងៃចេញប្រកាសនេះ រហូតដល់ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៤ ។

**ប្រការ៣.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

លេខ: ៤៨៤ សគបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៣

# ប្រកាស
# ស្តីពី
# ពន្លឺ និង ការបំភ្លឺ

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## សំរេច

**ប្រការ១.-** និយោជកនៃសហគ្រាស គ្រឹះស្ថានដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ត្រូវរៀបចំយ៉ាងណាឱ្យអគាររោងជាង ទីកន្លែងធ្វើការ មានពន្លឺធម្មជាតិ និង ពន្លឺសិប្បនិម្មិត សមស្របទៅនឹងការងារ គឺលៃលកយ៉ាងណាធានាឱ្យកម្មករនិយោជិតសំឡឹងមើលឃើញបានច្បាស់ និង មិនរោយភ្នែក ។ ការបំភ្លឺជាទូទៅត្រូវបានបន្ថែមដោយការបំភ្លឺជាលក្ខណៈដោយឡែក នៅតាមមណ្ឌលធ្វើការ ឬប៉ុស្តិ៍ការងារ ។

ពាក្យបច្ចេកទេសទាំងឡាយមានពន្យល់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ២.-** ការផ្តល់ពន្លឺសំរាប់ការងារប្រណិត ឬការងារផ្ចិតផ្ចង់ ត្រូវធ្វើយ៉ាងណាឱ្យការសំឡឹងមើលមិននឿយហត់ និង មិនបង្កឱ្យមានបច្ច័យមិនល្អទៅអនាគត ពិសេសគឺ :

- ពន្លឺដែលបំភ្លឺមណ្ឌលធ្វើការត្រូវឱ្យមានកំរិតប្រហាក់ប្រហែលនឹងមណ្ឌលជិតខាងនោះ
- ការបំភ្លឺជាទូទៅនៅទីកន្លែងធ្វើការតែមួយត្រូវយ៉ាងហោចណាស់ស្មើនឹងមួយភាគប្រាំនៃការបំភ្លឺមណ្ឌលធ្វើការ ឬប៉ុស្តិ៍ការងារ
- ការបំភ្លឺត្រូវមានគុណភាព អាចមើលឃើញពណ៌បានត្រឹមត្រូវ សមស្របជាមួយនឹងសកម្មភាពនៃការងារ
- កម្មករនិយោជិតត្រូវបានការពារទប់ទល់នឹងប្រភពពន្លឺដែលចាំងខ្លាំង ទោះដោយត្រង់ ឬដោយប្រយោលក្តី
- បាតុភូតនៃពន្លឺភ្លឺបភ្លែតត្រូវលុបបំបាត់
- ប៉ុស្តិ៍ការងារមិនត្រូវទទួលកាំរស្មីព្រះអាទិត្យដោយផ្ទាល់ឡើយ ។

**ប្រការ៣.-** កំរិតបំភ្លឺជាមធ្យមនៅមណ្ឌលធ្វើការ ឬនៅប៉ុស្តិ៍ការងារ ត្រូវបានកំណត់ក្នុងតារាងជាបន្តបន្ទាប់ដូចខាងក្រោមនេះ :

| មណ្ឌលធ្វើចរាចរ និងសន្និធិ | ការបំភ្លឺជាមធ្យមគិតជាលុច (Lux) |
|---|---|
| មណ្ឌលធ្វើចរាចរ | 100 – 150 |
| ជណ្តើរ | 150 |
| គីរឃ៉ានផ្ទុកទំនិញ | 150 |
| ឃ្លាំងសន្និធិ | 100 |

| ទីកន្លែងបំរុងសំរាប់កម្មករនិយោជិត | ការបំភ្លឺជាមធ្យមគិតជាលុច (Lux) |
|---|---|
| អាហារដ្ឋាន | 200 |
| កន្លែងទុកសំលៀកបំពាក់ | 100 |
| បង្គន់ - បន្ទប់ទឹក | 100 |
| គិលានដ្ឋាន | 500 |

| ឧស្សាហកម្មម្ហូបអាហារ | ការបំភ្លឺជាមធ្យមគិតជាលុច (Lux) |
|---|---|
| ការដុសលាង និងបំពេញធុង | 200 |
| ការជ្រើសរើស និងវេចខ្ចប់ | 200 |
| ការបញ្ចូលក្នុងកំប៉ុង ឬដប | 500 |
| ការពិនិត្យបញ្ចាក់លើកែវ ឬដប | 500 |
| ការត្រួតពិនិត្យផលិតផល | 500 |

| | |
|---|---|
| ការត្រួតពិនិត្យពណ៌ | 1000 |

| ឧស្សាហកម្មថ្នាំជក់ | ការបំភ្លឺជាមធ្យមគិតជាលុច (Lux) |
|---|---|
| ការងារសំងួត | 200 |
| ការងារជ្រើសរើស | 1000 |
| ផលិតកម្មបារី | 500 |

| ឧស្សាហកម្មឈើ | ការបំភ្លឺជាមធ្យមគិតជាលុច (Lux) |
|---|---|
| ការថ្លែងភាពជាស្វ័យប្រវត្តិ | 100 |
| ការងារនៅរណ្តៅចំហាយ | 150 |
| ការងារជាងឈើ ( កាត់ ជ្រៀក ឈូស...) | 500 |
| ការខាត់ លាប កោសសំអាត | 500 |
| ការងារជ្រើសរើស | 750 |
| ការងារចម្លាក់ | 750 |
| ការត្រួតពិនិត្យគុណភាព | 750 |

| ឧស្សាហកម្មកញ្ចក់ ចាន ត្រីស្ពាល់ | ការបំភ្លឺជាមធ្យមគិតជាលុច (Lux) |
|---|---|
| ការងារសំងួត | 100 |
| ការត្រៀមឃ្លាំមើលគ្រឿងចក្រ | 300 |
| ការវាយថ្នាំភ្លឺ ការកិនសំប៉ែត ចាក់ពុម្ព... p | 750 |
| ការងារសំល្បេង ឆ្លាក់ ដោយដៃ | 750 |
| ការងាររចនាគំនូរ | 750 |
| ការផលិតត្រីស្ពាល់ | 1500 |

| ឧស្សាហកម្មគីមី | ការបំភ្លឺជាមធ្យមគិតជាលុច (Lux) |
|---|---|
| ការកិនកំទេច លាយ | 300 |
| ការកិនសំប៉ែត ម៉ាស៊ីនបាញ់ខ្យល់ | 500 |
| ការងារផលិតកៅស៊ូកង់ | 500 |
| បន្ទប់បញ្ជា | 500 |
| មន្ទីរពិសោធន៍ | 500 |
| ការត្រួតពិនិត្យពណ៌ | 1000 |

| ឧស្សាហកម្មផលិតបរិក្ខារអគ្គិសនី | ការបំភ្លឺជាមធ្យមគិតជាលុច (Lux) |
|---|---|
| ការផលិតខ្សែកាប និងខ្សែភ្លើង | 300 |
| ការរុំបូប៊ីនធំ | 300 |
| ការរុំបូប៊ីនមធ្យម | 500 |
| ការរុំបូប៊ីនតូច | 750 |
| ការលាបថ្នាំលើបូប៊ីន | 300 |
| ការពាសសំណប៉ាហាំង | 300 |
| ការងារផ្គុំបរិក្ខារ ធំ មធ្យម តូច | 300 – 500 – 750 |
| ការផលិតបរិក្ខារតូចៗសំរាប់វាស់វែង | 1000 |
| រោងជាងអេឡិចត្រូនិច | 1500 |

| បោះពុម្ព | ការបំភ្លឺជាមធ្យមគិតជាលុច (Lux) |
|---|---|
| ការកាត់ក្រដាស់ លាបទឹកមាស ធ្វើឃ្លីសេ ធ្វើពុម្ព | 500 |
| ការរៀបអក្សរ | 500 |
| ការផ្គុំចំរុះ ជួសកែសំរួល | 1000 |
| សិលាលេខ | 1000 |
| ការត្រួតពិនិត្យពណ៌ | 1500 |
| ការចងសៀវភៅ | 500 |

| វាយនភណ្ឌ | ការបំភ្លឺជាមធ្យមគិតជាលុច (Lux) |
|---|---|
| ការសិត ហូត ទាញអំបោះ | 300 |
| ការវៃអំបោះ ស្រាវអំបោះ ការហុងអំបោះ | 500 |
| ការអន្ទង ត្បាញ ប៉ាក់ | 750 |
| ការបង្ហើយ ជ្រលក់ពណ៌ | 500 |
| បន្ទប់សំងួត | 100 |
| ការបោះពុម្ពជាស្វ័យប្រវត្តិ | 500 |
| ការត្រួតពិនិត្យពណ៌ | 1000 |

| ឧស្សាហកម្មសម្លៀកបំពាក់ | ការបំភ្លឺជាមធ្យមគិតជាលុច (Lux) |
|---|---|
| ការប៉ាក់ តំឡើងគ្រឿងប៉ាក់ | 750 |
| ការតំឡើងពុម្ពកាត់ និងកាត់ | 750 |
| ការស្រេះ | 1500 |
| ការដេរ | 1000 |
| ការអ៊ុត | 300 |
| ការត្រួតពិនិត្យចុងក្រោយ | 1000 |

| ផលិតគ្រឿងអលង្ការ | ការបំភ្លឺជាមធ្យមគិតជាលុច (Lux) |
|---|---|
| ការងារច្នៃត្បូង | 1500 |
| ការធ្វើ និងតំឡើងគ្រឿងអលង្ការ | 1000 |
| ការធ្វើ និងតំឡើងនាឡិកាដៃ | 1500 |

| សណ្ឋាគារ ភោជនីយដ្ឋាន | ការបំភ្លឺជាមធ្យមគិតជាលុច (Lux) |
|---|---|
| កន្លែងបដិសណ្ឋារកិច្ច បេឡា គេហបាល | 300 |
| ផ្ទះបាយ | 500 |
| បន្ទប់បាយ ភោជនីយដ្ឋាន | 200 |
| របៀង p | 100 |

| អគាររដ្ឋបាល ការិយាល័យ | ការបំភ្លឺជាមធ្យមគិតជាលុច (Lux) |
|---|---|
| កន្លែងរៀបចំទុកដាក់ | 300 |
| កន្លែងសរសេរ អង្គុលីលេខ អាន វិភាគទិន្នន័យ | 500 |
| បន្ទប់កុំព្យូទ័រ | 500 |
| កន្លែងគូរគំនូរឧស្សាហកម្ម | 1000 |
| បន្ទប់ប្រជុំ | 500 |
| កន្លែងបដិសណ្ឋារកិច្ច | 300 |
| កន្លែងទុកដាក់ឯកសារ | 200 |

| ភណ្ឌាគារ ឃ្លាំង ហាងលក់រាយ | ការបំភ្លឺជាមធ្យមគិតជាលុច (Lux) |
|---|---|
| កន្លែងដាក់លក់ | 300 |
| កន្លែងបេឡា | 300 |
| កន្លែងវេចខ្ចប់ | 500 |

**ប្រការ៤.-** និយោជកត្រូវរៀបចំយ៉ាងណា កុំឱ្យកម្មករនិយោជិតមានការរំខានដោយសារកំដៅដែលសាយភាយចេញពីប្រភពបញ្ចេញពន្លឺ ឬបណ្ដាលឱ្យមានការរលាកដោយសារប្រភពកំដៅនោះ ។ ទីបិទបើកសំរាប់ការបំភ្លឺ ត្រូវមានភាពងាយស្រួល ទោះបន្ទប់ស្ថិតក្នុងភាពងងឹតក៏ដោយ ។ ប្រព័ន្ធរួមនៃការបំភ្លឺ (ខ្សែភ្លើង ជើងចាប់អំពូល កុងតាក់) ត្រូវរៀបចំឱ្យបានរឹងមាំតាមលក្ខណៈបច្ចេកទេស ដើម្បីជៀសវាងកុំឱ្យឆក់ ។

**ប្រការ៥.-** ម៉ាស៊ីនភ្លើងត្រូវដាក់ឱ្យនៅឆ្ងាយពីទីកន្លែងធ្វើការ ឬអគារដទៃទៀតសំរាប់កម្មករនិយោជិតប្រើប្រាស់ ដើម្បីជៀសវាងប្រភពសំឡេងខ្លាំង ឬការបំពុលបរិយាកាស ។

**ប្រការ៦.-** និយោជកត្រូវរៀបចំដាក់ឱ្យមានភ្លើងបំភ្លឺជំនួយបំរុង សំរាប់បំភ្លឺពេលដាច់ចរន្តធម្មតា ។ ភ្លើងបំភ្លឺជំនួយបំរុងនេះ ត្រូវឱ្យមានកំរិតយ៉ាងតិច ៥ លុច ។

**ប្រការ៧.-** ការមិនអនុវត្តតាមបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះត្រូវពិន័យ ឬទទួលទោសដូចមានចែងក្នុងជំពូកទី ១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៨.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

p

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

ឧបសម្ព័ន្ធនៃប្រកាសលេខ ៤៨៤ សកបយ.

ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីពន្យល់ពាក្យបច្ចេកទេស

| ពាក្យខ្មែរ | ជាភាសាបារាំង | សេចក្តីពន្យល់ |
|---|---|---|
| មណ្ឌល | Zone | ទីកន្លែង ចំណុច |
| មណ្ឌលធ្វើការ | Zone de travail | ចំណុចបុស្តិ៍ការងារ |
| មណ្ឌលជិតខាង | Zone Contiguë | ទីកន្លែងដែលនៅជុំវិញមណ្ឌលធ្វើការ |
| លុច | Lux | បរិមាណប្រើយកជាខ្នាតសំរាប់វាស់ពន្លឺ |
| បាតុភូតនៃពន្លឺភ្លឺបភ្លែត | Phénomènes de fluctuation (Effets stroboscopiques) | ភ្លើងដែលឆេះរលត់ៗ |
| ឃ្លាំងសន្និធិ | Magasins de stockage | ឃ្លាំងទុកដាក់ទំនិញបំរុង |
| តំរង្គានផ្ទុកទំនិញ | Quais de chargement | ចន្លោះផ្លូវដែលមានគំនរទំនិញនៅសងខាង |
| ការប្លែងភាពជាស្វ័យប្រវត្តិ | Transformation automatique | ជាខ្សែសង្វាក់ផលិតកម្មស្វ័យប្រវត្តិ |
| គ្រីស្តាល់ | Cristal | វត្ថុធ្វើពីកែវចរណៃ |
| ការវាយថ្នាំភ្លឺ | Emaillage | ការលាបថ្នាំជាតិ Email |
| ធ្វើឃ្លីសេ | Gravure des clichés | ធ្វើពុម្ពដែលឆ្លាក់ភ្ជាប់នឹងក្តារបន្ទះ |
| សិលាលេខ | Lithographie | សិល្បៈខាងការផ្តិតដោយប្រើពុម្ពថ្ម |
| គេហបាល | Concierge | អ្នកស៊ីឈ្នួលយាមផ្ទះ ឬសណ្ឋាគារ |
| របៀង | Couloirs | ល្វែងតូចនៅពីក្រៅជញ្ជាំងផ្ទះធំ |
| ភ្លើងបំភ្លឺជំនួយបំរុង | Eclairage de sécurité | ភ្លើងបំភ្លឺនៅពេលចរន្តធម្មតាត្រូវកាត់ផ្តាច់ |

រាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ២០០៣

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខៈ ០២៩ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០០៤

# ប្រកាស
## ស្តីពី
## ការផ្លាស់ប្តូរសមាសភាពសមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។
-បានឃើញប្រកាសលេខ ១៤១ សកបយ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈកម្មការប្រឹក្សាគម្រោងដោះស្រាយវិវាទការងារនៅកម្ពុជា
-បានឃើញប្រកាសលេខ ៣៣៨ សកបយ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០០២ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល
-បានឃើញលិខិត ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៤ របស់ប្រធានទីប្រឹក្សាបច្ចេកទេសនៃគម្រោងដោះស្រាយវិវាទការងារនៅកម្ពុជា ស្តីពីសំណើសុំតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល

## សំរេច

**ប្រការ១.-** ផ្លាស់ប្តូរសមាសភាពសមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលមានសមាសភាពដូចខាងក្រោមៈ

**I-សមាជិកពេញសិទ្ធិតំណាងនិយោជក ដែលស្នើឡើងដោយប្រធានទីប្រឹក្សាបច្ចេកទេសគម្រោងៈ**

- លោក **លី តៃសេង (Ly Tay Seng)** ជំនួសលោក **Wong Chiv**

**ប្រការ២.-** លោក **លី តៃសេង** ជាសមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល មានអាណត្តិដោយគិតចាប់ពីថ្ងៃចេញប្រកាសនេះ រហូតដល់ថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ២០០៤ ។

**ប្រការ៣.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខៈ ០៩៩ សកបយ.

រាជធានីភ្នំពេញ , ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤

# ប្រកាស
# ស្តីពី
# ក្រុមប្រឹក្សាអាជ្ញាកណ្តាល

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

## ស ម្រេ ច

## ជំពូក ១
## សមាសភាពក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ប្រការ១.-** ប្រកាសនេះ កំណត់ការបង្កើតក្រុមប្រឹក្សាអាជ្ញាកណ្តាលមួយ ដែលមានសមាជិកយ៉ាងតិច ១៥ រូប ដោយអនុលោមតាមមាត្រា៣១៧ នៃច្បាប់ស្តីពីការងារ ។ ក្រសួងសង្គមកិច្ច ការងារ បណ្តុះ-បណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវចេញប្រកាសតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលជារៀងរាល់ឆ្នាំ ។ ប្រកាសតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលរៀងរាល់ឆ្នាំ ត្រូវចេញយ៉ាងតិច ១៤ថ្ងៃ មុនពេលបញ្ចប់អាណត្តិ ។

**ប្រការ២.-** អាណត្តិនៃសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល មានរយៈពេលមួយឆ្នាំ ។ សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលម្នាក់ៗ ត្រូវបានតែងតាំងដោយប្រកាសរៀងរាល់ឆ្នាំលើកលែងតែ :

ក-សមាជិកនោះស្លាប់ លាលែងពីតំណែង ឬក្លាយជាជនអសមត្ថភាព មិនអាចបំពេញភារកិច្ចរបស់ខ្លួនជាអាជ្ញាកណ្តាល ឬ

ខ-សមាជិកនោះត្រូវបានជាប់ពិរុទ្ធពីបទព្រហ្មទណ្ឌ ឬបានប្រព្រឹត្តកំហុស ដែលបណ្តាលឱ្យសមាជិករូបនោះលែងមានសិទ្ធិជាសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្របតាមប្រការ ៦ នៃប្រកាសនេះ ឬ

គ-សមាជិកនោះកាន់កាប់មុខងារដែលមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ ។

**ប្រការ៣.-** សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលមានសមាសភាពដូចតទៅ:-

ក-មួយភាគបីស្នើឡើងដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

ខ-មួយភាគបីស្នើឡើងដោយសមាគមនិយោជក ដែលជាសមាជិកពេញសិទ្ធិនៃគណៈកម្មការប្រឹក្សាការងារ ។

គ-មួយភាគបីស្នើឡើងដោយសហជីពកម្មករនិយោជិត (សហព័ន្ធសហជីព) ដែលជាសមាជិកពេញសិទ្ធិនៃគណៈកម្មការប្រឹក្សាការងារ ។ សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបានតែងតាំងឡើង ដោយផ្អែកតាមសំណើឈ្មោះខាងលើ ។

**ប្រការ៤.-** ករណីដែលតំណាងសមាគមនិយោជកនៅក្នុងគណៈកម្មការប្រឹក្សាការងារ មិនអាចឯកភាពគ្នាលើសំណើឈ្មោះសំរាប់សមាជិកភាពក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ សមាគមនិយោជកនីមួយៗ ដែលមានតំណាងពេញសិទ្ធិនៅក្នុងគណៈកម្មការប្រឹក្សាការងារ មានសិទ្ធិដាក់សំណើឈ្មោះ ក្នុងចំនួនស្មើៗគ្នា ។

**ប្រការ៥.-** ករណីដែលតំណាងសហជីពកម្មករនិយោជិត (សហព័ន្ធ) នៅក្នុងគណៈកម្មការប្រឹក្សាការងារ មិនអាចឯកភាពគ្នាលើសំណើឈ្មោះសំរាប់សមាជិកភាពក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ សហជីពកម្មករនិយោជិតនីមួយៗ (សហព័ន្ធ) ដែលមានតំណាងពេញសិទ្ធិនៅក្នុងគណៈកម្មការប្រឹក្សាការងារ មានសិទ្ធិដាក់សំណើឈ្មោះក្នុងចំនួនស្មើៗគ្នា ។

**ប្រការ៦.-** សមាជិករបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវមានលក្ខណៈសម្បត្តិដូចតទៅ :-

ក-គ្រប់សមាជិកទាំងអស់ត្រូវមាន :-

- អាយុយ៉ាងតិច២៥ឆ្នាំ
- ការទទួលស្គាល់អំពីលក្ខណៈសម្បត្តិផ្នែកសីលធម៌

- បទពិសោធន៍ពាក់ពន្ធ័នឹងការងារយ៉ាងហោចបីឆ្នាំ ។

ខ-សមាជិកដែលត្រូវបានតែងតាំងតាមប្រការ ៣ ចំណុច ក ខាងលើ ត្រូវមាន :-

- បរិញ្ញាបត្រផ្នែកច្បាប់ ឬមានគុណសម្បត្តិផ្នែកច្បាប់ដែលប្រហាក់ប្រហែលដទៃទៀត
- ចំណេះដឹងសមរម្យអំពីច្បាប់ស្តីពីការងារ និង បទបញ្ញាផ្សេងៗទៀត សំរាប់ប្រតិបត្តិច្បាប់នេះ ។

គ-សមាជិកដែលបានតែងតាំងតាមប្រការ ៣ ចំណុច ខ និង ចំណុច គ ខាងលើ ត្រូវមាន :-

- ចំណេះដឹងសមរម្យអំពីច្បាប់ស្តីពីការងារ និង បទបញ្ញាផ្សេងៗទៀត សំរាប់ប្រតិបត្តិច្បាប់នេះ ។
- បទពិសោធន៍យ៉ាងតិចមួយឆ្នាំក្នុងវិស័យការងារ ឬការដោះស្រាយវិវាទការងារ ។

**ប្រការ៧.-** បុគ្គលិកដែលមិនអាចត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល មានដូចតទៅ:-

ក-បុគ្គលិកមន្ត្រីរាជការនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

ខ-ម្ចាស់ ឬអ្នកគ្រប់គ្រងនៃសហគ្រាសណាមួយដែលជាសមាជិកនៃអង្គការនិយោជក ឬអ្នកដែលកាន់តំណែងផ្លូវការរបស់អង្គការនិយោជកណាមួយ ឬអ្នកដែលធ្លាប់កាន់កាប់តំណែងទាំងនេះក្នុងរយះពេល១២ ខែមុន។

គ-សមាជិកសហជីព ឬអ្នកដែលកាន់តំណែងផ្លូវការរបស់សហជីពណាមួយ ឬអ្នកដែលធ្លាប់កាន់កាប់តំណែងទាំងនេះក្នុងរយះពេល ១២ខែមុន ។

**ប្រការ៨.-** សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវបានទទួលការតែងតាំងដោយមិនប្រកាន់រើសអើងដោយមូលហេតុសញ្ជាតិ ឬដោយមូលហេតុផ្សេងៗ ដូចមានចែងក្នុងមាត្រា៣១ កថាខណ្ឌ័២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៩.-** ទោះបីអាណត្តិរបស់សមាជិកណាម្នាក់ បានចប់ហើយក៏ដោយ ក៏សមាជិករូបនោះត្រូវបន្តការងាររបស់ខ្លួននៅក្នុងក្រុមអាជ្ញាកណ្តាល ដែលខ្លួនត្រូវបានជ្រើសរើសឱ្យចូល កាលពីមុនពេលផុតអាណត្តិរបស់ខ្លួន រហូតដល់សេចក្តីបង្គាប់អាជ្ញាកណ្តាលត្រូវបានធ្វើឡើង ឬដំណើរការសំរេចសេចក្តីនៃអាជ្ញាកណ្តាលត្រូវបានបញ្ចប់ ។

**ប្រការ១០.-** សមាជិកណាម្នាក់នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលទទួលមរណភាព ឬក្លាយជាជនអសមត្ថភាព ឬលាលែងពីតំណែងជាក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងអំឡុងពេលនៃអាណត្តិរបស់ខ្លួន ឬសមាជិកនោះត្រូវជាប់ពិរុទ្ធពីបទព្រហ្មទណ្ឌ ឬបានប្រព្រឹត្តកំហុសដែលបណ្តាលឱ្យសមាជិករូបនោះលែងមានសិទ្ធិជាសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលស្របតាមប្រការ ៦ នៃប្រកាសនេះ ឬសមាជិក

នោះកាន់កាប់មុខងារណាមួយ ដែលមានចែងក្នុងប្រការ ៧ នៃប្រកាសនេះ នឹងត្រូវជំនួសដោយសមាជិកថ្មីសំរាប់រយៈពេលដែលនៅសល់ក្នុងអាណត្តិនោះ ។ សមាជិកថ្មីនោះត្រូវបានស្នើឈ្មោះដោយស្ថាប័ន ឬអង្គការវិជ្ជាជីវៈ ដែលបានបញ្ជូនឈ្មោះសមាជិកដែលចាកចេញនោះហើយ ត្រូវបានតែងតាំងស្របតាមនីតិវិធីដែលមានចែងក្នុងប្រកាសនេះ ។

**ប្រការ១១.-** សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបំពេញមុខងារដោយឯករាជ្យទាំងស្រុង និងនៅក្នុងរង្វង់នៃអំណាចរបស់ខ្លួន ដូចដែលមានចែងក្នុងមាត្រា៣១២ នៃច្បាប់ស្តីពីការងារ ។ គ្មានបុគ្គលណាម្នាក់ត្រូវផ្តល់ការណែនាំដល់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ឬដល់សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលទាក់ទងនឹងការដោះស្រាយវិវាទឡើយ ។ សមាជិកនៃក្រុមអាជ្ញាកណ្តាលត្រូវតែមានភាពមិនលំអៀង ។

## ជំពូក ២
## សមាសភាពក្រុមអាជ្ញាកណ្តាល

**ប្រការ១២.-** វិវាទការងាររួមទាំងឡាយ ដែលដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលស្របតាមមាត្រា ៣០៩ នៃច្បាប់ស្តីពីការងារ ត្រូវដោះស្រាយដោយក្រុមអាជ្ញាកណ្តាលមួយ ដែលត្រូវបង្កើតឡើងសំរាប់តែការដោះស្រាយវិវាទនោះ ។ សេចក្តីបង្គាប់ដែលចេញដោយក្រុមអាជ្ញាកណ្តាលណាមួយ ត្រូវចាត់ទុកជាសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ក្រុមអាជ្ញាកណ្តាលនីមួយៗ ត្រូវមានសមាជិកបីរូប ដែលជ្រើសចេញពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដូចខាងក្រោម :-

ក-សមាជិកមួយរូបមកពីសមាសភាពដូចមានចែងក្នុងប្រការ ៣ ចំណុច ខ ខាងលើ ហើយត្រូវបានជ្រើសរើសដោយសហគ្រាសដែលជាភាគីវិវាទ

ខ-សមាជិកមួយរូបមកពីសមាសភាពដូចមានចែងក្នុងប្រការ ៣ ចំណុច គ ខាងលើ ហើយត្រូវបានជ្រើសរើសដោយសហជីព ឬក្រុមកម្មករនិយោជិតដែលជាភាគីនៃវិវាទ

គ-សមាជិកមួយរូបដែលត្រូវធ្វើជាប្រធានក្រុមអាជ្ញាកណ្តាល និងដែលត្រូវបានជ្រើសរើសចេញពីសមាសភាពដូចមានចែងក្នុងប្រការ ៣ ចំណុច ក ខាងលើ ដោយមានការឯកភាពពីសមាជិកទាំងពីរខាងលើ។ នៅក្នុងករណីដែលសមាជិកទាំងពីររូបនេះ មិនឯកភាពគ្នាក្នុងការជ្រើសរើសសមាជិកទីបីនៃក្រុមអាជ្ញាកណ្តាល ការជ្រើសរើសនេះត្រូវធ្វើតាមការចាប់ឆ្នោត ក្នុងចំណោមសមាសភាពដូចមានចែងក្នុងប្រការ៣ ចំណុចក ។

**ប្រការ១៣.-** ក្នុងករណីដែលសហគ្រាសពីរ ឬច្រើនជាភាគីនៃវិវាទ ហើយពួកគេមិនអាចឈានទៅដល់ការព្រមព្រៀងក្នុងការជ្រើសរើសសមាជិកណាមួយ សមាជិកនេះនឹងត្រូវជ្រើសរើសដោយការចាប់

ឆ្នោត ។ ដូចគ្នានឹងនេះដែរ ក្នុងករណីដែលសហជីព ឬក្រុមកម្មករពីរ ឬច្រើនជាភាគីវិវាទ ហើយគេមិនមានការឯកភាពគ្នាក្នុងការជ្រើសរើសសមាជិកណាម្នាក់នោះ សមាជិកមួយនោះនឹងត្រូវជ្រើសរើសតាមការចាប់ឆ្នោត ។

**ប្រការ១៤.-** ក្នុងករណីដែលកម្មករនិយោជិតណាម្នាក់ត្រូវបានគេតំរូវឱ្យចូលរួមក្នុងសវនាការជំនុំជំរះរបស់ក្រុមអាជ្ញាកណ្តាលក្នុងពេលម៉ោងធ្វើការ និយោជករបស់កម្មករនិយោជិតនោះត្រូវតែអនុញ្ញាតឱ្យកម្មករនិយោជិតនោះចូលរួមដោយមិនឱ្យទទួលផលប៉ះពាល់ជាអវិជ្ជមានដល់សិទ្ធិការងារទាំងឡាយដែលកម្មករនិយោជិតនោះមានឡើយ ។

**ប្រការ១៥.-** សមាជិកម្នាក់ៗនៃក្រុមអាជ្ញាកណ្តាលត្រូវបដិសេធខ្លួនឯងពីក្រុមអាជ្ញាកណ្តាល ដែលខ្លួនត្រូវបានគេជ្រើសរើស ប្រសិនកាលៈទេសៈដែលកើតមានឡើងចោទជាមន្ទិលសង្ស័យសមស្រប អំពីភាពមិនលំអៀង ឬឯករាជ្យភាពរបស់ខ្លួន រួមមានទំនាក់ទំនងជិតស្និទ្ធជាលក្ខណៈបុគ្គល ឬអាជីពជាមួយសមាជិកដទៃទៀតនៃក្រុមអាជ្ញាកណ្តាល ឬជាមួយភាគីណាមួយ ឬដោយមានផលប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍អាជីពផ្ទាល់ ពីលទ្ធផលនៃរឿងក្តីនោះ ។

**ប្រការ១៦.-** ការដែលសមាជិកនៃក្រុមអាជ្ញាកណ្តាលណា ដែលពុំបដិសេធខ្លួនឯងតាមបទប្បញ្ញត្តិដែលមានចែងក្នុងប្រការ ១៥ ខាងលើ អាចត្រូវបានយកធ្វើជាហេតុផលសំរាប់អនុវត្តបញ្ញត្តិ ដែលមានចែងក្នុងប្រការ ៤៧ នៃប្រកាសនេះ ដែលទាក់ទងនឹងការពុំទទួលស្គាល់សេចក្តីបង្គាប់ ។

**ប្រការ១៧.-** ក្នុងករណីដែលសមាជិកណាម្នាក់ក្នុងក្រុមអាជ្ញាកណ្តាលមិនអាចបំពេញមុខងាររបស់ខ្លួនបានដោយសារហេតុផលស្របច្បាប់ ឬដោយហេតុផលជាក់ស្តែងណាមួយ ត្រូវជ្រើសរើសអាជ្ញាកណ្តាលថ្មីមកជំនួសដោយផ្អែកតាមប្រការ ១២ និង ១៣ ខាងលើ ។

## ជំពូក ៣

## ដំណើរការអាជ្ញាកណ្តាល

**ប្រការ១៨.-** ក្រុមអាជ្ញាកណ្តាលត្រូវអញ្ជើញភាគីវិវាទមកបកស្រាយបង្ហាញដោយផ្ទាល់មាត់នូវការអះអាងរបស់ខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល និងដាក់ជូននូវឯកសារ និងពត៌មានចាំបាច់ផ្សេងៗទៀត ។

**ប្រការ១៩.-** ភាគីវិវាទអាចមកបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬតំណាងដោយមេធាវីដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ ។

**ប្រការ២០.-** ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទដូចជា កូដកម្ម ឬឡុកអៅ ( ដូចមានចែងក្នុងមាត្រា៣១៨ នៃច្បាប់ស្តីពីការងារ ) ឬវិធាន-

ការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយដែលក្រុមអាជ្ញាកណ្ដាលបានអញ្ជើញឱ្យចូលរួម ។

**ប្រការ២១.-** ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្ដាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្ដាលអាចបន្តដំណើរការរបស់ខ្លួន ក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្ដាលដោយចេញជាសេចក្ដីបង្គាប់ ។

**ប្រការ២២.-** ទីស្នាក់ការនៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលគឺ នៅភ្នំពេញ ។ តែទោះជាយ៉ាងណាក៏ដោយ ក្រុមអាជ្ញាកណ្ដាលអាចជួបប្រជុំនៅកន្លែងណាផ្សេងទៀតក៏បាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលខ្លួនគិតថាសមរម្យ សំរាប់ពិគ្រោះយោបល់នៅក្នុងចំណោមសមាជិករបស់ខ្លួន សំរាប់ជួបជាមួយភាគីសាក្សី ឬអ្នកជំនាញការសំរាប់ត្រួតពិនិត្យវត្ថុ ទ្រព្យសម្បត្តិដទៃទៀត ឬឯកសារ ឬការចុះពិនិត្យដល់ទីកន្លែងផ្ទាល់។ នៅក្នុងករណីបែបនេះ ក្រុមអាជ្ញាកណ្ដាលត្រូវជូនដំណឹងដល់ភាគីពាក់ព័ន្ធអំពីទីកន្លែងថ្មីដែលបានជ្រើសរើសសំរាប់សកម្មភាពរបស់ខ្លួននេះ ។

**ប្រការ២៣.-** ភាសាដែលត្រូវប្រើក្នុងដំណើរការរបស់ក្រុមអាជ្ញាកណ្ដាលគឺ ភាសាខ្មែរ ។ ភាគីណាមួយដែលមានបំណងនិយាយភាសាផ្សេងក្រៅពីភាសាខ្មែរទៅក្រុមអាជ្ញាកណ្ដាល ឬមានសាក្សីដែលមិនចេះនិយាយភាសាខ្មែរ ភាគីនោះត្រូវនាំមកជាមួយខ្លួននូវអ្នកជំនាញបកប្រែម្នាក់ ចូលរួមក្នុងដំណើរការអាជ្ញាកណ្ដាល ។

**ប្រការ២៤.-** ក្រុមអាជ្ញាកណ្ដាលមានអំណាចក្នុងការស៊ើបពត៌មាន អំពីស្ថានភាពសេដ្ឋកិច្ចនៃសហគ្រាស និងស្ថានភាពសង្គមនៃកម្មករនិយោជិតដែលពាក់ព័ន្ធនៅក្នុងវិវាទ ។ ក្រុមនេះអាចដឹកនាំការស៊ើបអង្កេតណាមួយដែលមានការទាក់ទងនឹងសហគ្រាស ឬអង្គការវិជ្ជាជីវៈផ្សេងៗ ព្រមទាំងអាចតម្រូវឱ្យភាគីប្រគល់ជូននូវឯកសារ ឬពត៌មានខាងសេដ្ឋកិច្ច គណនេយ្យ ស្ថិតិ ហិរញ្ញវត្ថុ ឬរដ្ឋបាល ដែលអាចមានប្រយោជន៍ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ។ ក្រុមអាជ្ញាកណ្ដាលនេះ អាចសុំឱ្យអ្នកជំនាញការជួយបានទៀតផង ។

**ប្រការ២៥.-** ក្រុមអាជ្ញាកណ្ដាលត្រូវមានសេរីភាពក្នុងការកំណត់អំពីភាពដែលអាចទទួលយកបានភាពពាក់ព័ន្ធ ភាពសំខាន់ និង ទំងន់នៃភស្តុតាង និង មានសេរីភាពក្នុងការកំណត់ឱ្យភាគីណាមួយ លើកភស្តុតាងមកបញ្ជាក់ទៀតផង ។

**ប្រការ២៦.-** ក្រុមអាជ្ញាកណ្ដាលមានអំណាចក្នុងការសាកសួរសាក្សី បើសិនជាយល់ឃើញថាសមស្រប។ ក្រុមអាជ្ញាកណ្ដាលត្រូវកំណត់អំពីថ្ងៃ ពេលវេលា និង ទីកន្លែងសំរាប់សាកសួរសាក្សី ។ ភាគីវិវាទទាំងអស់មានសិទ្ធិក្នុងការសាកសួរសាក្សី នៅចំពោះមុខក្រុមអាជ្ញាកណ្ដាល ។

**ប្រការ២៧.-** គ្រប់សេចក្តីថ្លែង ឯកសារ ឬពត៌មានផ្សេងទៀត ដែលប្រគល់ជូនក្រុមអាជ្ញាកណ្តាលដោយភាគីមួយត្រូវតែបញ្ជូនទៅភាគីមួយទៀត ។ ទន្ទឹមនឹងនេះដែរ គ្រប់របាយការណ៍របស់អ្នកជំនាញការ ឬឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយោងដើម្បីធ្វើសេចក្តីសំរេច ត្រូវតែបញ្ជូនទៅភាគីវិវាទផងដែរ ។ ក្រុមអាជ្ញាកណ្តាលមានអំណាចក្នុងការចេញសេចក្តីសំរេចសមស្រប ដើម្បីការពារដល់ភាពអាថិកំបាំងនៃពត៌មាននេះ ។

**ប្រការ២៨.-** លើកលែងករណីដូចមានចែងក្នុងប្រការ ២៧ ខាងលើ សមាជិកទាំងអស់នៃក្រុមអាជ្ញាកណ្តាលត្រូវតែរក្សាជាអាថិកំបាំងនូវរាល់ពត៌មាន និង ឯកសារដែលខ្លួនបានទទួល ព្រមទាំងអង្គហេតុណាមួយដែលខ្លួនបានដឹងក្នុងពេលបំពេញភារកិច្ច ។

**ប្រការ២៩.-** ការប្រជុំទាំងឡាយរបស់ក្រុមអាជ្ញាកណ្តាលត្រូវធ្វើឡើងជាសម្ងាត់ ។

**ប្រការ៣០.-** ក្រុមអាជ្ញាកណ្តាលអាចអញ្ជើញភាគីវិវាទទាំងអស់ជាលើកចុងក្រោយ ដើម្បីជួយឱ្យពួកគេឈានទៅដល់ដំណោះស្រាយមួយ ។ ប្រការនេះមិនអាចនាំឱ្យមានការពន្យាពេលហួសពីរយៈពេលកំណត់ ដែលមានចែងក្នុងមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារឡើយ លើកលែងតែភាគីទាំងពីរព្រមព្រៀងចំពោះការពន្យាពេលនោះ ។ ការព្រមព្រៀងគ្នារវាងភាគីវិវាទក្នុងអំឡុងពេលនៃដំណើរការក្រុមអាជ្ញាកណ្តាលអាចធ្វើជាកម្មវត្ថុនៃសេចក្តីបង្គាប់អាជ្ញាកណ្តាលបាន ។

**ប្រការ៣១.-** ដំណើរការរបស់អាជ្ញាកណ្តាលត្រូវអនុវត្តតាមវិធាននៃនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចចេញសេចក្តីណែនាំ ដើម្បីសំរបសំរួលដំណើរការអាជ្ញាកណ្តាល ។ សេចក្តីណែនាំមិនត្រូវផ្ទុយពីច្បាប់ស្តីពីការងារ ប្រកាសនេះ ឬវិធាននីតិវិធីនានាឡើយ ។ សេចក្តីណែនាំ ត្រូវមានការយល់ព្រមពីសមាជិកទាំងអស់នៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ ប្រសិនបើសមាជិកទាំងអស់មិនមានការព្រមព្រៀងគ្នាទេ សេចក្តីណែនាំត្រូវធ្វើឡើងតាមមតិភាគច្រើនដាច់ខាតនៃសមាជិកទាំងអស់ក្នុងប្រភេទនីមួយៗនៃប្រភេទទាំងបី ដែលមានចែងក្នុងប្រការ ៣ ខាងលើ ។

## ជំពូក ៤
## អំណាចយុត្តាធិការ និង សំណង

**ប្រការ៣២.-** ក្រុមអាជ្ញាកណ្តាលត្រូវសំរេចសេចក្តីលើវិវាទការងាររួមដែលដាក់មកខ្លួន ដោយយោងទៅតាមមាត្រា ៣០៩ កថាខ័ណ្ឌ ត នៃច្បាប់ស្តីពីការងារ ។

**ប្រការ៣៣.-** អំណាចរបស់ក្រុមអាជ្ញាកណ្តាលក្នុងការពិចារណាទៅលើវិវាទមួយ ត្រូវកំរិតត្រឹមតែបញ្ហាទាំងឡាយណាដែលមានក្នុងកំណត់ហេតុនៃការផ្សះផ្សាមិនបានសះជា រួមទាំងបញ្ហាជាផលវិបាកផ្ទាល់នៃវិវាទនោះ ដែលកើតឡើងក្រោយការធ្វើកំណត់ហេតុ ។

**ប្រការ៣៤.-** ចំពោះបញ្ហាដែលបានដាក់ជូនក្រុមអាជ្ញាកណ្តាល ក្រុមនេះមានសិទ្ធ និង អំណាចក្នុងការសំរេចឱ្យភាគីវិវាទផ្តល់សំណងយ៉ាងពេញលេញ ចំពោះរាល់ការបំពានបទប្បញ្ញត្តិ ដែលមាននៅក្នុងច្បាប់ស្តីពីការងារ បទប្បញ្ញត្តិអនុវត្តច្បាប់ស្តីពីការងារ អនុសញ្ញារួម ឬក្នុងកាតព្វកិច្ចផ្សេងទៀតដែលកើតចេញពីទំនាក់ទំនងវិជ្ជាជីវៈរវាងនិយោជក និងកម្មករនិយោជិត។ ក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារ និង ប្រកាសនេះ ក្រុមអាជ្ញាកណ្តាលមានសិទ្ធិ និង អំណាចក្នុងការសំរេចឱ្យភាគីវិវាទផ្តល់នូវសំណងរដ្ឋប្បវេណី ឬសំណងខូចខាតដែលមានលក្ខណៈត្រឹមត្រូវ និង យុត្តិធម៌ ដោយរួមទាំងការ :-

ក-បញ្ជាឱ្យទទួលយកកម្មករនិយោជិតដែលបានបណ្តេញចេញ ឱ្យចូលមកធ្វើការវិញនៅក្នុងតំណែងចាស់ ឬតំណែងសមរម្យណាមួយ

ខ-បញ្ជាឱ្យបង់ប្រាក់ជាបន្ទាន់នូវប្រាក់ដែលត្រូវបង់

គ-បញ្ជាឱ្យបញ្ឈប់ជាបន្ទាន់នូវកូដកម្ម ឬឡុកអៅដែលកំពុងធ្វើឡើងដោយភាគីវិវាទ

ឃ-បញ្ជាឱ្យបញ្ឈប់ជាបន្ទាន់នូវរាល់ការប្រព្រឹត្តិទាំងឡាយណា ដែលមិនស្របច្បាប់ ឬដែលត្រូវហាមឃាត់ ដោយរួមទាំងអំពើសងសឹក និងអំពើផ្សេងៗទៀតក្រៅពីអំពើសងសឹក

ង-បញ្ជាឱ្យធ្វើការចរចា

ច-បញ្ជាឱ្យអនុវត្តតាមដំណោះស្រាយក្រោមប្រការ៣០ នៃប្រកាសនេះ

ឆ-បង្កើតលក្ខខណ្ឌទាំងឡាយសំរាប់អនុសញ្ញារួម

ជ-សងការខូចខាតផ្សេងៗទៀតតាមការសមស្រប ។

**ប្រការ៣៥.-** ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចជូនដំណឹងអំពីសេចក្តីបង្គាប់របស់ខ្លួន ទៅនាយកដ្ឋានអធិការកិច្ចការងារ ឬមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត-ក្រុង ដើម្បីជួយចាត់វិធានការក្នុងការអនុវត្តសេចក្តីបង្គាប់នោះ ។

## ជំពូក ៥
## សេចក្តីបង្គាប់អាជ្ញាកណ្តាល

**ប្រការ៣៦.-** ក្រុមអាជ្ញាកណ្តាលត្រូវព្យាយាមឱ្យបានសម្លេងឯកឆន្ទក្នុងការសំរេចសេចក្តីរបស់ខ្លួន ។ ប្រសិនបើសម្លេងឯកឆន្ទមិនអាចរកបានទេ ក្រុមអាជ្ញាកណ្តាលត្រូវធ្វើសេចក្តីសំរេចរបស់ខ្លួនតាមសម្លេងភាគច្រើន។

**ប្រការ៣៧.-** ក្រុមអាជ្ញាកណ្តាលត្រូវកត់ត្រារាល់សេចក្តីសំរេចរបស់ខ្លួន ក្នុងសេចក្តីបង្គាប់មួយដែលត្រូវចុះហត្ថលេខារបស់អាជ្ញាកណ្តាលទាំង ០៣ រូប ។ ក្នុងករណីដែលអាជ្ញាកណ្តាលណាម្នាក់មិនឯកភាពនឹង

សេចក្ដីសំរេចតាមមតិភាគច្រើននោះ គាត់អាចកត់ត្រាយោបល់ជំទាស់របស់គាត់ធ្វើជាឧបសម្ព័ន្ធមួយក្នុងសេចក្ដីបង្គាប់នោះ ។

**ប្រការ៣៨.-** សេចក្ដីបង្គាប់អាជ្ញាកណ្ដាលត្រូវចែងអំពី :-

ក-ឈ្មោះរបស់អាជ្ញាកណ្ដាលទាំង ០៣ រូប

ខ-ឈ្មោះ អាសយដ្ឋាន និង ទីកន្លែងធ្វើការ ឬកន្លែងស្នាក់នៅពិតប្រាកដរបស់ភាគី

គ-សេចក្ដីសង្ខេបស្ដីពីនីតិវិធី

ឃ-សេចក្ដីពិពណ៌នាអំពីបណ្ដឹង និង បណ្ដឹងតប ប្រសិនជាមាន

ង-ហេតុផលនៃការសំរេចដែលចែងនៅក្នុងសេចក្ដីបង្គាប់ ព្រមទាំងសេចក្ដីយោងទៅនឹងបញ្ញត្តិពាក់ព័ន្ធទាំងឡាយដែលមានចែងក្នុងច្បាប់ស្ដីពីការងារ បទប្បញ្ញត្តិសំរាប់អនុវត្តច្បាប់ស្ដីពីការងារ ឬអនុសញ្ញារួម ឬកិច្ចសន្យាការងារនីមួយៗ បើសិនជាមាន

ច-រាល់សេចក្ដីសំរេចរបស់ក្រុមអាជ្ញាកណ្ដាល

ឆ-កាលបរិច្ឆេទនៃការធ្វើសេចក្ដីបង្គាប់ ។

**ប្រការ៣៩.-** ក្នុងរយៈពេល ១៥ថ្ងៃ ចាប់ពីថ្ងៃដែលខ្លួនបានទទួលសំណុំរឿង ក្រុមអាជ្ញាកណ្ដាលត្រូវរាយការណ៍ អំពីសេចក្ដីបង្គាប់របស់ខ្លួនជាលាយលក្ខណ៍អក្សរ ជូនទៅរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ហើយរដ្ឋមន្ត្រីចាត់ការផ្ដល់ដំណឹងទៅភាគីវិវាទភ្លាមអំពីសេចក្ដីបង្គាប់នោះ ដោយផ្ដល់ជូនភាគីទាំងនោះនូវច្បាប់ចម្លងសេចក្ដីបង្គាប់ដែលបានបញ្ជាក់ថាត្រឹម-ត្រូវចំនួន ០១ ច្បាប់ម្នាក់ ។ ក្នុងករណីដែលដំណើរការសំណុំរឿងត្រូវបានបញ្ចប់ ដោយមិនមានសេចក្ដីបង្គាប់នោះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលត្រូវជូនដំណឹងទៅរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អំពីការបញ្ចប់នៃដំណើរការនេះ។

**ប្រការ៤០.-** ភាគីនីមួយៗ អាចជំទាស់ទៅនឹងសេចក្ដីបង្គាប់អាជ្ញាកណ្ដាល ដោយជូនពត៌មានទៅរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា តាមសំបុត្រអនុសិដ្ឋ ឬតាមមធ្យោបាយដែលទុកជាបានការក្នុងរយៈពេល ៨ ថ្ងៃប្រតិទិន បន្ទាប់ពីបានទទួលដំណឹង ។ ប្រសិនបើថ្ងៃចុងក្រោយនៃរយៈពេលនេះ មិនមែនជាថ្ងៃធ្វើការសំរាប់មន្ត្រីរាជការស៊ីវិល រយៈពេលនេះត្រូវពន្យាបន្ថែមទៅថ្ងៃធ្វើការបន្ទាប់ ។ ប្រសិនភាគីណាមួយនៃវិវាទបានដាក់ពាក្យជំទាស់របស់ខ្លួនក្នុងអំឡុងពេលនេះ សេចក្ដីបង្គាប់នោះមិនអាចអនុវត្តបានឡើយ ។ ក្នុងករណីនេះបើវិវាទជាវិវាទអំពីសិទ្ធិដែលពាក់ព័ន្ធនឹងការអនុវត្តបទប្បញ្ញត្តិនៃច្បាប់ (ឧទាហរណ៍ៈ បញ្ញត្តិណាមួយនៅក្នុងច្បាប់ស្ដីពីការងារ អនុសញ្ញារួម ឬសេចក្ដីបង្គាប់អាជ្ញាកណ្ដាល ដែលជំនួសអនុសញ្ញារួម) ភាគីវិវាទអាចប្ដឹងពីករណីនេះ ទៅតុលាការមានសមត្ថកិច្ចសំរាប់ការដោះស្រាយចុងក្រោយ ។

**ប្រការ៤១.-** សេចក្តីបង្គាប់អាជ្ញាកណ្តាលត្រូវក្លាយជាស្ថាពរ ហើយភាគីវិវាទមានកាតព្វកិច្ចត្រូវអនុវត្តតាម ប្រសិនបើមិនមានភាគីវិវាទណាមួយ ដាក់ពាក្យជំទាស់ក្នុងរយៈពេលដែលបានកំណត់ក្នុងប្រការ ៤០ ខាងលើ ។

**ប្រការ៤២.-** ប្រការ ៤០ នៃប្រកាសនេះមិនអាចយកមកអនុវត្តបានទេ ក្នុងករណីដែលភាគីទាំងឡាយនៃវិវាទ បានឯកភាពគ្នាជាលាយលក្ខណ៍អក្សរមុនពេលជូនដំណឹងអំពីសេចក្តីបង្គាប់អាជ្ញាកណ្តាល ឬក្នុងករណីដែលភាគីវិវាទបានជាប់កាតព្វកិច្ចអនុវត្តតាមអនុសញ្ញារួម ដែលចែងអំពីការមិនជំទាស់ទៅនឹងសេចក្តីបង្គាប់អាជ្ញាកណ្តាលណាមួយ ។ ក្នុងករណីនេះសេចក្តីបង្គាប់អាជ្ញាកណ្តាលត្រូវក្លាយជាស្ថាពរ ហើយត្រូវយកមកអនុវត្តភ្លាម បន្ទាប់ពីការជូនដំណឹង ។

## ជំពូក ៦

## សេចក្តីបង្គាប់ទាក់ទងនឹងវិវាទផលប្រយោជន៍

**ប្រការ៤៣.-** សេចក្តីបង្គាប់អាជ្ញាកណ្តាល ដែលដោះស្រាយវិវាទផលប្រយោជន៍នឹងត្រូវមកជំនួសអនុសញ្ញារួម និង មានប្រសិទ្ធិភាពអនុវត្តរយៈពេលមួយឆ្នាំចាប់តាំងពីថ្ងៃចូលជាស្ថាពរ លើកលែងតែភាគីវិវាទបានព្រមព្រៀងគ្នាលើការធ្វើអនុសញ្ញារួមថ្មីមួយ ដើម្បីដាក់ជំនួសសេចក្តីបង្គាប់នោះ ។

**ប្រការ៤៤.-** សេចក្តីបង្គាប់នេះនៅតែមានប្រសិទ្ធិភាពអនុវត្តដដែល បន្ទាប់ពីរយៈពេល ១ ឆ្នាំនេះ បើភាគីណាមួយមិនបានជូនដំណឹង ៣ ខែមុនទៅភាគីម្ខាងទៀតថា ខ្លួនមិនចង់អនុវត្តតាមសេចក្តីបង្គាប់នោះទៀតទេ ។ p

**ប្រការ៤៥.-** នៅពេលដែលសេចក្តីបង្គាប់អាជ្ញាកណ្តាល ដែលជំនួសអនុសញ្ញារួមក្លាយជាស្ថាពរ សេចក្តីបង្គាប់នេះត្រូវរក្សាទុកជាឯកសារ និង ចុះបញ្ជិកាស្របទៅតាមនីតិវិធីស្តីពីអនុសញ្ញារួម ។

## ជំពូក ៧

## ការអនុវត្ត

**ប្រការ៤៦.-** ប្រសិនបើរយៈពេលជំទាស់បានផុត ហើយភាគីមួយបដិសេធការអនុវត្តតាមសេចក្តីបង្គាប់ ភាគីម្ខាងទៀតអាចស្នើឱ្យតុលាការមានសមត្ថកិច្ចទទួលស្គាល់ និង អនុវត្តសេចក្តីបង្គាប់នោះបាន ។ ភាគីដែលបានស្នើសុំឱ្យទទួលស្គាល់ និង ដែលស្នើសុំឱ្យមានការអនុវត្តសេចក្តីបង្គាប់ ត្រូវផ្តល់ជូនតុលាការនូវសេចក្តីបង្គាប់ច្បាប់ចំលងដែលបានបញ្ជាក់ថាត្រឹមត្រូវចំនួន ០១ ច្បាប់ ។

**ប្រការ៤៧.-** ភាគីមួយអាចជៀសវាងការទទួលស្គាល់ និង ការដាក់ឱ្យអនុវត្តសេចក្តីបង្គាប់ជាស្ថាពរ និង ដែលចងកាតព្វកិច្ច តែក្នុងករណីភាគីនោះផ្តល់ជូនតុលាការនូវភស្តុតាងបញ្ជាក់ថា សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនមានភាពត្រឹមត្រូវដោយសារ :-

ក-ភាគីវិវាទនោះមិនបានចូលរួមត្រឹមត្រូវក្នុងការជ្រើសរើសអាជ្ញាកណ្តាល ឬមិនបានទទួលនូវការជូនដំណឹងត្រឹមត្រូវអំពីដំណើរការអាជ្ញាកណ្តាល ឬត្រូវបានរារាំងយ៉ាងអយុត្តិធម៌មិនឱ្យធ្វើការបកស្រាយឱ្យបានក្បោះក្បាយអំពីរឿងក្តីរបស់ខ្លួន ។

ខ-ការមិនអនុវត្តតាមនីតិវិធីដូចមានចែងក្នុងច្បាប់ស្តីពីការងារ ឬប្រកាសនេះទាក់ទងនឹងការចេញសេចក្តីបង្គាប់ ។

គ-ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបង្គាប់ ដែលហួសពីអំណាច ដែលច្បាប់ស្តីពីការ-ងារ និង ប្រកាសនេះ ប្រគល់ឱ្យ ។

## ជំពូក ៨
## លេខាធិការដ្ឋាន និង ការចំណាយ

**ប្រការ៤៨.-** នាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវ-នីតិសម្បទា ត្រូវទទួលបន្ទុកលើការរៀបចំ និង ការប្រព្រឹត្តិទៅនៃលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

**ប្រការ៤៩.-** ក្នុងករណីដែលអាជ្ញាកណ្តាលមិនអាចនិយាយភាសាខ្មែរ ស្ថាប័ន ឬអង្គការវិជ្ជាជីវៈដែលស្នើឈ្មោះអាជ្ញាកណ្តាលរូបនោះ ជាអ្នកទទួលខុសត្រូវចំពោះការចំណាយសមស្របទៅលើការបកប្រែឯកសារ និង បកប្រែផ្ទាល់មាត់ ។

## ជំពូក ៩
## ការរាប់ចំនួន " ថ្ងៃ "

**ប្រការ៥០.-** លើកលែងតែមានការចែងផ្សេងពីនេះ ពាក្យថា " ថ្ងៃ " នៅក្នុងប្រការទាំងអស់នៃប្រកាសនេះមានន័យថា ថ្ងៃធ្វើការសំរាប់មន្ត្រីរាជការស៊ីវិល ។

## ជំពូក ១០
## អន្តរប្បញ្ញត្តិ

**ប្រការ៥១.-** អញ្ញត្រកម្មទៅនឹងប្រការ ២ នៅក្នុងរយៈពេលអន្តរកាលក្នុងអណត្តិទី១ អាណត្តិទី២ និង អាណត្តិទី៣ នៃក្រុមប្រឹក្សាអាជ្ញាកណ្តាល រាល់សមាជិកទាំងអស់នៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវបានតែងតាំងដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាផ្អែកតាមសំណើឈ្មោះនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បន្ទាប់ពីមានការប្រឹក្សាយោបល់ជាមួយគម្រោងដោះស្រាយវិវាទការងារនៃអង្គការពលកម្មអន្តរជាតិ (ILO) ។

## ជំពូក ១១
## ការចូលជាធរមាន និង ការទុកប្រកាសលេខ ៣៣៨ ជានិរាករណ៍

**ប្រការ៥២.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា លេខ ៣៣៨ សកបយ. ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០២ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥៣.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

p

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

ឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ.
ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ២០០៤

## វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល
## យោងតាមប្រការ ៣១ នៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល

**វិធាន១: លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១.១ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល(លេខាធិការដ្ឋាន)ជាអង្គការ ដែលត្រូវបានបង្កើតឡើង យោងតាមជំពូក ៨ នៃប្រកាសលេខ ០៩៩ សកបយ. ដើម្បីគ្រប់គ្រង និងសម្របសម្រួលដល់ការដោះស្រាយវិវាទដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

១.២ អាសយដ្ឋានលេខាធិការដ្ឋានគឺ :-

លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល
មជ្ឈមណ្ឌលភ្នំពេញ អគារ (A)
វិថីសុធារស
សង្កាត់ ទន្លេបាសាក់
ខណ្ឌ ចំការមន
រាជធានីភ្នំពេញ

ការផ្លាស់ប្តូរអាសយដ្ឋាននៃលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវជូនដំណឹងជាសាធារណៈ ។

១.៣ ភាគីវិវាទដែលដាក់បណ្តឹងមកក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវសហប្រតិបត្តិការជាមួយលេខាធិការដ្ឋាន ដើម្បីជួយលេខាធិការដ្ឋានក្នុងការបំពេញមុខងាររបស់ខ្លួន និងត្រូវដោះស្រាយអោយបានឆាប់រហ័ស និង ប្រកបដោយស្ថាបនាទូវសំណូមពរណាមួយ ដែលលេខាធិការដ្ឋានបានស្នើសុំឱ្យភាគីវិវាទជួយ ។

១.៤ សមាជិកក្រុមអាជ្ញាកណ្តាល និងភាគីត្រូវប្រាស្រ័យទាក់ទងគ្នាដោយផ្ទាល់បាន តែក្នុងកំឡុងពេលជំនុំជំរះផ្លូវការនៃក្រុមអាជ្ញាកណ្តាលប៉ុណ្ណោះ ។ រាល់ការប្រាស្រ័យទាក់ទងគ្នារវាងក្រុមអាជ្ញាកណ្តាល និង ភាគី ក្រៅពីពេលជំនុំជំរះត្រូវប្រព្រឹត្តទៅតាមរយៈលេខាធិការដ្ឋាន ។ លេខាធិការដ្ឋានត្រូវចាត់វិធានការសមរម្យគ្រប់បែបយ៉ាងដើម្បីឱ្យធានាថា ការប្រាស្រ័យទាក់ទងទាំងនេះបានទៅដល់គោលដៅ ។

១.៥ លេខាធិការដ្ឋានត្រូវមានវត្តមានក្នុងការជួយភាគី ដែលមានសំណួរពាក់ព័ន្ធនឹងទិដ្ឋភាពនៃនីតិវិធីដោះស្រាយវិវាទ និង ជួយក្នុងការបំភ្លឺបញ្ហាដែលកើតចេញពីប្រកាស ឬពីវិធាននៃនីតិវិធីនេះ ។

**វិធាន២: ការចាប់ផ្តើមអាជ្ញាកណ្តាល**

២.១ កាលណាការដោះស្រាយវិវាទតាមអាជ្ញាកណ្តាលត្រូវបានគេតំរូវឱ្យមានតាមមាត្រា ៣០៩ (គ) នៃច្បាប់ស្តីពីការងារ ក្នុងរយៈពេល ៤៨ ម៉ោងបន្ទាប់ពីការបញ្ចប់ការផ្សះផ្សាមិនសះជា ភាគីនីមួយៗត្រូវជូនយោបល់ទៅលេខាធិការដ្ឋានអំពីអាជ្ញាកណ្តាល ដែលខ្លួនបានជ្រើសរើសពីក្រុមប្រឹក្សាអាជ្ញា-កណ្តាល ដើម្បីធ្វើជាសមាជិកនៃក្រុមអាជ្ញាកណ្តាល ដែលបង្កើតឡើងផ្អែកតាមប្រការ ១២ នៃប្រកាស ។

២.២ ក្នុងការបំពេញតាមលក្ខខណ្ឌតម្រូវនៃវិធាន២.១ ភាគីអាចជូនយោបល់អ្នកផ្សះផ្សានៅពេលបញ្ចប់ការផ្សះផ្សាមិនសះជា អំពីអាជ្ញាកណ្តាលដែលខ្លួនបានជ្រើសរើស ។ នៅពេលដែលភាគីបានជូនយោបល់អ្នកផ្សះផ្សាអំពីអាជ្ញាកណ្តាល ដែលខ្លួនបានជ្រើសរើសសម្រាប់ធ្វើសមាជិកក្រុមអាជ្ញា-កណ្តាល ការជ្រើសរើសអាជ្ញាកណ្តាលនេះ ត្រូវបញ្ចូលទៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជាហើយបញ្ជូនឱ្យរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា យោងតាមមាត្រា ៣០៨ នៃច្បាប់ស្តីពីការងារ ។

២.៣ ភាគីដែលពាក់ព័ន្ធដំណើរការអាជ្ញាកណ្តាលត្រូវធ្វើធានាថា លេខាធិការដ្ឋានបានទទួលនូវការជូនដំណឹងអំពីអាសយដ្ឋានរបស់ខ្លួន ដែលជាទីកន្លែងដែលភាគីទទួលសេចក្តីជូនដំណឹង និង សេវាផ្តល់ជូនឯកសារផ្សេងៗក្នុងដំណើរការជំនុំជំរះ ហើយបើជាអាចទៅរួចប្រគល់លេខទូរស័ព្ទដែលអាចទាក់ទង។ ពត៌មានដូចនេះ ត្រូវប្រគល់ឱ្យក្នុងឱកាសមុនដំបូងបង្អស់ ហើយបើអាចទៅរួចត្រូវប្រគល់ឱ្យទៅអ្នកផ្សះផ្សានៅពេលបញ្ចប់ការផ្សះផ្សាមិនសះជា ។

p

**វិធាន៣: ការជ្រើសរើសអាជ្ញាកណ្តាល**

៣.១ លេខាធិការដ្ឋានត្រូវខិតខំខ្នែងដើម្បីអោយអាជ្ញាកណ្តាលទាំងបី បង្កើតជាក្រុមអាជ្ញាកណ្តាលមួយដែលត្រូវបានជ្រើសរើសឡើងក្នុងរយៈពេលបីថ្ងៃប្រតិទិន បន្ទាប់ពីលេខាធិការដ្ឋានបានទទួលរបាយការណ៍ផ្សះផ្សាមិនសះជា ។ លេខាធិការដ្ឋានត្រូវប្រើគ្រប់វិធានការដើម្បីសម្របសម្រួលដល់ការជ្រើសរើសអាជ្ញាកណ្តាលអោយបានស្របតាមវិធាននេះ ។

៣.២ កាលណាលេខាធិការដ្ឋានទទួលរបាយការណ៍ផ្សះផ្សាមិនសះជា យោងតាមមាត្រា ៣០៨ នៃច្បាប់ស្តីពីការងារ លេខាធិការដ្ឋានត្រូវចុះលេខរៀងសំណុំរឿងនៃវិវាទភ្លាមៗ ហើយពិនិត្យមើលថាតើភាគីបានជ្រើសរើសអាជ្ញាកណ្តាលស្របតាមប្រការ ១២ នៃប្រកាសហើយ ឬនៅ ។

៣.៣ ប្រសិនបើភាគីមិនបានជ្រើសរើសអាជ្ញាកណ្តាល ឬអាជ្ញាកណ្តាល ដែលត្រូវបានជ្រើសរើសហើយ មិនអាចបំពេញមុខងាររបស់ខ្លួនបាន ពេលនោះលេខាធិការដ្ឋានត្រូវជួយធានាអោយបានថា ភាគីទាំងអស់បានជ្រើសរើសអាជ្ញាកណ្តាលស្របតាមជំពូក ២ នៃប្រកាស ។

៣.៤ ក្នុងការជួយដល់ដំណើរការជ្រើសរើសស្របតាមវិធាន៣.៣ លេខាធិការដ្ឋានត្រូវ :-

ក-ផ្តល់ឱ្យសហគ្រាស ដែលជាភាគីវិវាទនូវបញ្ជីនៃអាជ្ញាកណ្តាល ដែលត្រូវស្នើឈ្មោះឡើងដោយនិយោជកក្នុងក្រុមប្រឹក្សាអាជ្ញាកណ្តាលស្របតាមប្រការ៣.ខ នៃប្រកាស ដែលការជ្រើសរើសអាជ្ញាកណ្តាលនេះ ត្រូវផ្អែកតាមប្រការនេះ ។

ខ-ផ្តល់ឱ្យសហជីព ឬក្រុមកម្មករនិយោជិតដែលជាភាគីវិវាទ នូវបញ្ជីនៃអាជ្ញាកណ្តាលដែលត្រូវស្នើឈ្មោះឡើងដោយសហជីពក្នុងក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្របតាមប្រការ៣.គ នៃប្រកាសដែលការជ្រើសរើសអាជ្ញាកណ្តាលនេះ ត្រូវផ្អែកតាមប្រការនេះ ។

គ-ធ្វើការជ្រើសរើសអាជ្ញាកណ្តាលដោយការចាប់ឆ្នោត កាលណាមានការតម្រូវក្រោមប្រការ ១៣ នៃប្រកាសនេះ ។

៣.៥ បន្ទាប់ពីបានជ្រើសរើសអាជ្ញាកណ្តាលពីបញ្ជី ដូចមានចែងក្នុងប្រការ៣.ខ និង ៣.គ នៃប្រកាស "អាជ្ញាកណ្តាល០២រូប" លេខាធិការដ្ឋានត្រូវធ្វើការទាក់ទងជាមួយអាជ្ញាកណ្តាលទាំង ០២ រូបនោះ ដើម្បីសួរបញ្ជាក់អំពីភាពដែលគេអាចធ្វើជាអាជ្ញាកណ្តាលបាន ។ លេខាធិការដ្ឋានត្រូវជូនដំណឹងទៅអាជ្ញាកណ្តាលទាំង០២រូបនោះអំពីលេខរៀងសំណុំរឿង និង អំពីភាគីវិវាទ ។ អាជ្ញាកណ្តាលទាំង ០២ ត្រូវជូនដំណឹងទៅលេខាធិការដ្ឋាន បើសិនជាគេមិនអាចធ្វើជាអាជ្ញាកណ្តាលបាន ដោយសារមូលហេតុណាមួយរួមទាំងមូលហេតុនីត្យានុកូលភាព ដូចជាទំនាស់ផលប្រយោជន៍ជាដើម ។

៣.៦ នៅពេលអាជ្ញាកណ្តាលណាមួយ ដែលត្រូវបានគេជ្រើសរើសមិនអាចបំពេញមុខងារក្នុងក្រុមអាជ្ញា-កណ្តាលបាន លេខាធិការដ្ឋានត្រូវតំរូវអោយភាគីដែលបានជ្រើសរើសអាជ្ញាកណ្តាលនោះធ្វើការជ្រើសរើសអាជ្ញាកណ្តាលផ្សេងដោយយោងតាមវិធាននេះ ។

៣.៧ នៅពេលការជ្រើសរើសអាជ្ញាកណ្តាលទាំង០២នោះ ត្រូវបានធ្វើរួចរាល់ហើយអាជ្ញាកណ្តាលទាំង០២ ត្រូវពិភាក្សាគ្នា ដើម្បីជ្រើសរើសអាជ្ញាកណ្តាល០១រូបទៀតចេញពីបញ្ជីអាជ្ញាកណ្តាលដែលតែងតាំងដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដូចមានចែងក្នុងប្រការ ៣.ក នៃប្រកាសនេះ " អាជ្ញាកណ្តាលទី៣ " ។

៣.៨ បើសិនជាអាជ្ញាកណ្តាលទាំង០២ អាចឯកភាពគ្នាលើការជ្រើសរើសអាជ្ញាកណ្តាលទី ៣ អាជ្ញាកណ្តាលទាំង២ ត្រូវធ្វើការទាក់ទងជាមួយអាជ្ញាកណ្តាលទី៣ ដើម្បីសួរបញ្ជាក់អំពីភាពដែលគេអាចធ្វើជាអាជ្ញាកណ្តាលបាន។ អាជ្ញាកណ្តាលទាំង ២ ត្រូវជូនដំណឹងទៅអាជ្ញាកណ្តាលទី ៣ អំពីលេខរៀងសំណុំរឿង និង អំពីភាគីវិវាទ ។ អាជ្ញាកណ្តាលទី ៣ ត្រូវជូនដំណឹងទៅអាជ្ញាកណ្តាលទាំង ២ បើសិនជាគេមិនអាចធ្វើជាអាជ្ញាកណ្តាលបាន ដោយសារមូលហេតុណាមួយរួមទាំងមូលហេតុនីត្យានុកូលភាព ដូចជាទំនាស់ផលប្រយោជន៍ជាដើម ។

៣.៩ នៅពេលការជ្រើសរើសអាជ្ញាកណ្តាលទី៣ នោះ ត្រូវបានធ្វើរួចរាល់ហើយអាជ្ញាកណ្តាលទី៣ ត្រូវជូនដំណឹងអំពីសមាសភាពនៃក្រុមអាជ្ញាកណ្តាលទៅលេខាធិការដ្ឋាន ដោយរួមទាំងលេខរៀងសំណុំរឿង ភាគីវិវាទ និងកាលបរិច្ឆេទ ពេលវេលា ដែលអាជ្ញាកណ្តាលទី៣បានបញ្ជាក់ប្រាប់អំពីភាពដែលគេអាចធ្វើជាសមាជិកក្រុមអាជ្ញាកណ្តាលនោះ ។ លេខាធិការដ្ឋានត្រូវកត់ត្រាទុកនូវពត៌មានលំអិតទាំងនេះ ហើយចងក្រងទុកអោយបានសមស្រប ។

៣.១០ កាលណាមានការតំរូវដូចមានចែងក្នុងប្រការ១២.គ នៃប្រកាស ទាក់ទងនឹងការដែលអាជ្ញាកណ្តាលទាំង២ មិនអាចឯកភាពគ្នាលើអត្តសញ្ញាណនៃអាជ្ញាកណ្តាលទី៣ លេខាធិការដ្ឋានត្រូវធ្វើការជ្រើសរើសអាជ្ញាកណ្តាលទី៣ ដោយការចាប់ឆ្នោត ។ ក្នុងករណីនេះ លេខាធិការដ្ឋានត្រូវទទួលខុសត្រូវលើការស្នើរបញ្ជាក់អំពីភាពអាចធ្វើជាអាជ្ញាកណ្តាលរបស់អាជ្ញាកណ្តាលទី៣ ។

៣.១១ កាលណាមានការតំរូវអោយមាននីតិវិធីសំរាប់ការជ្រើសរើសដោយការចាប់ឆ្នោត ដោយផ្អែកតាមប្រកាស និង ដរាបណាភាគីទាំងអស់មិនមានការព្រមព្រៀងគ្នា លើនីតិវិធីចាប់ឆ្នោតផ្សេងពីនេះទេនោះ នីតិវិធីចាប់ឆ្នោតត្រូវអនុវត្តតាមដូចខាងក្រោម :-

(ក) មន្ត្រីនៃលេខាធិការដ្ឋានម្នាក់ដែលត្រូវបានចាត់តាំងឡើង ត្រូវសរសេរលើក្រដាស់សន្លឹកផ្សេងៗគ្នានូវឈ្មោះរបស់អាជ្ញាកណ្តាលនីមួយៗពីបញ្ជីដែលពាក់ពន្ធ័ ដូចមានចែងក្នុងប្រការ ៣.ក. ៣.ខ ឬ៣.គ នៃប្រកាស ។ បន្ទាប់មកទៀតមន្ត្រីនោះត្រូវប្រមូលក្រដាស់ទាំងនេះ ដាក់ក្នុងប្រអប់ស្រអាប់មួយ ហើយជ្រើសរើសក្រដាសមួយសន្លឹកដោយព្រៀវ ដើម្បីជ្រើសរើសយកអាជ្ញាកណ្តាលម្នាក់ ។

(ខ) ភាគីវិវាទ និងអាជ្ញាកណ្តាលណាមួយ ដែលត្រូវបានគេជ្រើសរើសអោយធ្វើជាសមាជិកក្រុមអាជ្ញាកណ្តាល និង ទទួលនូវសេចក្តីជូនដំណឹង អំពីការប្រព្រឹត្តិទៅនៃនីតិវិធីចាប់ឆ្នោត និងមានសិទ្ធិមានវត្តមានក្នុងពេលប្រព្រឹត្តទៅនៃនីតិវិធីនោះ ។

៣.១២ ក្នុងគោលបំណងនៃវិធាននេះ ការជ្រើសរើសអាជ្ញាកណ្តាលណាមួយគឺ ចប់រួចរាល់នៅពេលដែលអាជ្ញាកណ្តាលត្រូវបានគេជ្រើសរើសឡើងដោយផ្អែកតាមនីតិវិធីកំណត់ ហើយអាជ្ញាកណ្តាលបានបញ្ជាក់អំពីភាពដែលគាត់អាចធ្វើជាសមាជិកនៃក្រុមអាជ្ញាកណ្តាលសំរាប់វិវាទណាមួយនោះ ។

៣.១៣ កាលណាការជ្រើសរើសអាជ្ញាកណ្តាលទាំង ៣ ត្រូវបានធ្វើចប់រួចរាល់ហើយ ក្រុមអាជ្ញាកណ្តាលត្រូវបានគេចាត់ទុកថា ត្រូវបានបង្កើតឡើង ។ ក្នុងពេលទន្ទឹមនឹងនេះដែររយៈពេល ១៥ ថ្ងៃប្រតិទិន ដូចមានចែងក្នុងប្រការ ៣៩ នៃប្រកាស ចាប់ផ្តើមរាប់ដែលក្នុងរយៈពេលនេះក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវរាយការណ៍អំពីសេចក្តីបង្គាប់របស់ខ្លួន ។

៣.១៤ បន្ទាប់ពីក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង កាលណាសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលនេះមិនអាចបំពេញមុខងាររបស់ខ្លួនបានដោយសារមូលហេតុច្បាប់ ឬមូលហេតុជាក់ស្តែង លេខាធិការដ្ឋានត្រូវធានាអោយមានការជ្រើសរើសអាជ្ញាកណ្តាលថ្មីមកជំនួស ដោយផ្អែកតាមប្រការ១៧ នៃប្រកាសស្របតាមនីតិវិធីតែមួយ ដូចនីតិវិធីដែលបានចែងក្នុងវិធាននេះ ។

**វិធាន៤ : ដំណើរការអាជ្ញាកណ្តាល**

៤.១ សមាជិកក្រុមអាជ្ញាកណ្តាលត្រូវជួបប្រជុំក្នុងរយៈ ៣ ថ្ងៃប្រតិទិន បន្ទាប់ពីក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង ។ ការប្រជុំនេះអាចធ្វើតាមរយៈទូរស័ព្ទ ។ ក្រុមអាជ្ញាកណ្តាលត្រូវជូនដំណឹងទៅលេខាធិការដ្ឋានអំពីការប្រជុំនេះ និង អំពីសេចក្តីសំរេចផ្សេងៗ ដែលបានធ្វើក្នុងពេលប្រជុំ ។ បន្ទាប់ពីបានទទួលការណែនាំពីក្រុមអាជ្ញាកណ្តាល លេខាធិការដ្ឋានត្រូវជូនដំណឹងទៅភាគីអំពីកាលបរិច្ឆេទ និងទីកន្លែងដែលភាគីត្រូវមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ។

៤.២ ក្រៅពីការឡើងបង្ហាញដោយផ្ទាល់មាត់ ដូចមានចែងក្នុងប្រការ ១៨ នៃប្រកាស ក្រុមអាជ្ញាកណ្តាលអាចតំរូវឱ្យភាគីបញ្ជាក់អំពីការទាមទារ និង ចំលើយរបស់ខ្លួនជាលាយលក្ខណ៍អក្សរ ។

៤.៣ គឺជាការស្ថិតក្នុងដែនអំណាច និង សមត្ថកិច្ចទាំងស្រុងរបស់ក្រុមអាជ្ញាកណ្តាលក្នុងការសំរេចលើបញ្ហាផ្សេងៗ ដែលទាក់ទងនឹងការរៀបចំវិវាទអោយបានសមស្របសំរាប់ការជំនុំជំរះ និង ដែលទាក់ទងនឹងទិដ្ឋភាពណាមួយនៃការជំនុំជំរះ ។

៤.៤ ប្រធាននៃក្រុមអាជ្ញាកណ្តាលត្រូវចំលងទុកនូវរាល់សេចក្តីណែនាំការជូនដំណឹងយោបល់ ឬការប្រាស្រ័យទាក់ទង ដែលមានលក្ខណៈប្រហាក់ប្រហែល ដែលធ្វើឡើងដោយក្រុមអាជ្ញាកណ្តាលក្នុងពេលជំនុំជំរះ ហើយត្រូវផ្តល់ឱ្យលេខាធិការដ្ឋាននូវឯកសារទាំងនេះចំនួន ០១ ច្បាប់ ។

៤.៥ ក្រុមអាជ្ញាកណ្តាលអាចតំរូវអោយភាគីមួយផ្តល់ភស្តុតាងតាមរយៈសាក្សីវត្ថុតាង ឬឯកសារផ្សេងៗ។ បន្ថែមពីនេះទៀតក្រុមអាជ្ញាកណ្តាលអាចអញ្ជើញអ្នកឯកទេសមកផ្តល់ភស្តុតាងទាក់ទងនឹងវិវាទ ។

៤.៦ ភាគីទាំងអស់មានសិទ្ធិពិនិត្យភស្តុតាងណាមួយ ដែលបានបង្ហាញដល់ក្រុមអាជ្ញាកណ្តាល និងចោទសួរសាក្សីណាមួយ ដែលផ្តល់ភស្តុតាងដល់ក្រុមអាជ្ញាកណ្តាល ។

៤.៧ ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់ ។ ក្នុងករណីណាមួយក្រុមអាជ្ញាកណ្តាលត្រូវតែបំពេញតាមល័ក្ខខ័ណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវអំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរអាជ្ញាកណ្តាលមុនពេលធ្វើសេចក្តីសំរេចរបស់ខ្លួន ។

៤.៨ ក្នុងការធ្វើសេចក្ដីសំរេចទាក់ទងនឹងដំណើរការ រួមទាំងវិវាទលើនីតិវិធីក្រុមអាជ្ញាកណ្ដាល ត្រូវផ្អែកលើការពិចារណា លើភាពយុត្តិធម៌ ដំណោះស្រាយវិវាទប្រកបដោយប្រសិទ្ធិភាព និងតំរូវការក្នុងការដោះស្រាយវិវាទអោយបានលឿន ។

៤.៩ ការផ្អាកការជំនុំជំរះអាជ្ញាកណ្ដាលធ្វើអោយខាតបង់ថវិកាច្រើន និង គួរអោយជៀសវាង ។ ការផ្អាកនឹងធ្វើទៅបានដោយក្រុមអាជ្ញាកណ្ដាល កាលណាភាគីទាំងអស់ក្នុងដំណើរការអាជ្ញាកណ្ដាលឯកភាពគ្នាលើការផ្អាកនេះ ។

៤.១០ ការដោះស្រាយតាមរយៈការផ្សះផ្សា ជានិច្ចកាល ជាជំរើសគួរឱ្យចង់បាន ហើយភាគីមានសិទ្ធិក្នុងការដោះស្រាយវិវាទដោយខ្លួនឯងគ្រប់ពេលវេលារួមទាំងក្នុងពេលដំណើរការអាជ្ញាកណ្ដាលផងដែរ ។

៤.១១ ក្រុមអាជ្ញាកណ្ដាលត្រូវតំកល់ទុកនូវឯកសារ :-

ក- ភស្តុតាងណាមួយ ដែលបានផ្ដល់អោយក្នុងការជំនុំជំរះអាជ្ញាកណ្ដាល និង

ខ-សេចក្ដីបង្គាប់អាជ្ញាកណ្ដាល ឬសេចក្ដីសំរេច ដែលធ្វើឡើងដោយក្រុមអាជ្ញាកណ្ដាល ។ ឯកសារអាចត្រូវតំកល់ទុកក្នុងរូបភាពជាកំណត់ហេតុសរសេរ ឬក្នុងរូបភាពផ្សេងទៀត រួមទាំងការថតចម្លងដោយអេឡិចត្រូនិច ។

**វិធាន៥ : សេចក្ដីបង្គាប់**

៥.១ ក្រុមអាជ្ញាកណ្ដាលត្រូវជូនដំណឹងទៅលេខាធិការដ្ឋាន អំពីសេចក្ដីបង្គាប់អាជ្ញាកណ្ដាលរបស់ខ្លួនក្នុងរយៈពេល១៥ ថ្ងៃ ប្រតិទិន ចាប់រាប់ពីថ្ងៃបង្កើតក្រុមអាជ្ញាកណ្ដាលដំបូង លើកលែងតែភាគីបានព្រមព្រៀងគ្នាផ្សេងពីនេះ ដូចមានចែងក្នុងប្រការ ៣០ នៃប្រកាស និង វិធាន ៤.៩ ខាងលើ ។

៥.២ ក្រុមអាជ្ញាកណ្ដាលត្រូវបង្ហាញសេចក្ដីបង្គាប់របស់ខ្លួនជាលាយល័ក្ខណ៍អក្សរ ទៅលេខាធិការដ្ឋានក្នុងទំរង់គំរូដែលផ្ដល់អោយដោយលេខាធិការដ្ឋាន ។

៥.៣ បន្ទាប់ពីបានទទួលសេចក្ដីបង្គាប់ លេខាធិការដ្ឋានត្រូវជូនដំណឹងជាបន្ទាន់ទៅភាគីដោយផ្ដល់ឱ្យពួកគេ នូវសេចក្ដីបង្គាប់ដែលបានបញ្ជាក់ថាត្រឹមត្រូវចំនួន ០១ ច្បាប់ ។ ការជូនដំណឹងទៅភាគីអាចធ្វើឡើងតាមរយៈបញ្ជូនសេចក្ដីបង្គាប់ទៅភាគីតាមរយៈអាសយដ្ឋានរបស់គេ ដែលពួកគេបានផ្ដល់ឱ្យលេខាធិការដ្ឋាន ដោយផ្អែកតាមវិធាន ២.៣ ខាងលើ ឬតាមរយៈអាសយដ្ឋាននៃអ្នកតំណាងភាគី ។

**វិធាន៦ : ឯកសារ និង ការប្រាស្រ័យទាក់ទងផ្សេងៗទៀត ដែលទាក់ទងនឹងដំណើរការអាជ្ញាកណ្ដាល**

៦.១ ក្នុងគោលបំណងនៃដំណើរការអាជ្ញាកណ្ដាល ស្របតាមជំពូក ១២ ផ្នែក ២ នៃច្បាប់ស្ដីពីការងារ ឬស្របតាមប្រកាស នៅពេលដែលបុគ្គល ឬភាគីណាមួយ ត្រូវប្រគល់ឯកសារ ឬតំកល់ឯកសារជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សេវាកម្មដូចនេះ នឹង

ចាត់ថាបានសំរេចលទ្ធផល ដោយការបញ្ជូនយ៉ាងត្រឹមត្រូវនូវឯកសារទាំងនោះទៅលេខាធិការដ្ឋាន ។ វិធាននេះក៏អនុវត្តផងដែរ ចំពោះរបាយការណ៍ផ្សះផ្សាមិនសះជា ដូចមានចែងក្នុងមាត្រា ៣០៨ នៃច្បាប់ស្តីពីការងារ និង ចំពោះការជំទាស់ ដូចមានចែងក្នុងប្រការ ៤០ នៃប្រកាស ។

៦.២ ក្នុងគោលបំណងនៃដំណើរការអាជ្ញាកណ្តាល ស្របតាមជំពូក ១២ ផ្នែក ២ នៃច្បាប់ស្តីពីការងារ ឬស្របតាមប្រកាស នៅពេលដែលបុគ្គល ឬភាគីណាមួយត្រូវប្រគល់ ឬជូនឯកសារណាមួយភាគីនោះត្រូវតែអាចបង្ហាញជាភស្តុតាងថា សេវាកម្ម និងការបញ្ជូននោះបានកើតឡើង ។ វិធីដែលអាចទទួលយកបានសម្រាប់សេវាកម្ម ឬការបញ្ជូនឯកសារនេះ រួមមាន :-

ក-ការបញ្ជូនឯកសារតាមទូរសារ និងការរក្សាទុកកន្ទុយសន្លឹក

ខ-បញ្ជូនឯកសារតាមអ្នករត់សារ ហើយមានបង្កាន់ដៃបញ្ជាក់ថាបានទទួល និង

គ-ប្រគល់ដល់ដៃ ហើយមានបង្កាន់ដៃបញ្ជាក់ថាបានទទួល ។

វិធាននេះក៏អនុវត្តចំពោះការជំទាស់សេចក្តីបង្គាប់ផងដែរ ដូចមានចែងក្នុងប្រការ ៤០ នៃប្រកាស ។

៦.៣ ដោយសារពេលវេលាជាកត្តាសំខាន់ ក្នុងការអនុវត្តដំណើរការក្រុមប្រឹក្សាអាជ្ញាកណ្តាល ដូច្នេះការទាក់ទងគ្នាដោយប្រើទូរស័ព្ទ ត្រូវបានគេលើកទឹកចិត្តក្នុងចំណោមភាគីដែលពាក់ព័ន្ធ លើកលែងតែច្បាប់ស្តីពីការងារ ប្រកាស ឬវិធាននេះ តម្រូវឱ្យមានការទាក់ទងគ្នាជាលាយលក្ខណ៍អក្សរជាក់លាក់ ។ ក្នុងករណីណាក៏ដោយភស្តុតាងបញ្ជាក់អំពីការទាក់ទងគ្នានេះអាចតម្រូវឱ្យមាន ។

៦.៤ រាល់ល័ក្ខខ័ណ្ឌតម្រូវទាំងឡាយក្នុងប្រកាស ឬក្នុងវិធាននេះ ដែលលេខាធិការដ្ឋាន ឬអាជ្ញាកណ្តាលទាក់ទងជាមួយនឹងភាគីណាមួយនឹងយកជាការបាន បើសិនជាមានការទាក់ទងជាមួយតំណាងពេញសិទ្ធិរបស់ភាគីនោះ ។ p

**វិធាន៧ : ការកែប្រែវិសោធនកម្មលើវិធាននៃនីតិវិធីនេះ**

៧.១ នៅពេលមានការតំរូវឱ្យធ្វើវិសោធនកម្មលើវិធាននៃនីតិវិធីនេះ រដ្ឋមន្ត្រីនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អាចធ្វើវិសោធនកម្មដូចនេះ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

រាជធានីភ្នំពេញ ,ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខៈ ១០៣ សកបយ. រាជធានីភ្នំពេញ . ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៤

# ប្រកាស
# ស្តីពី
# ការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។
-បានឃើញប្រកាសលេខ ១៤១ សកបយ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈកម្មការប្រឹក្សាគម្រោងដោះស្រាយវិវាទការងារនៅកម្ពុជា
-បានឃើញប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល
-បានឃើញលិខិត ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៤ របស់ប្រធានទីប្រឹក្សាបច្ចេកទេសនៃគម្រោងដោះស្រាយវិវាទការងារនៅកម្ពុជា ស្តីពីសំណើសុំតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល

## <u>ស ម្រេ ច</u>

**ប្រការ១.-** តែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលមានសមាសភាពដូចខាងក្រោម :

**I-សមាជិកដែលស្នើឡើងដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

១- លោក អាំង អេងថុង

២- លោក គង់ ផល្លះ

៣- លោក ម៉ែន និម្មិត

៤- លោក កុយ នាម

៥- លោក រុន សារាយ

៦- លោក Rendall, Matthew

៧- លោក សុខ ម៉ាធឿង ។

**II-សមាជិកដែលស្នើឡើងដោយសមាគមនិយោជក:**

១- លោក កៅ ថាច

២- លោក គល់ វឌ្ឍនា

៣- លោក ម៉ារ សំបូរណា

៤- លោក ហែម ហ្វូណារិទ្ធ

៥- លោក លី តៃសេង

៦- លោក អ៊ុក រី

៧- កញ្ញា យូ ស៊ុនទី

**III-សមាជិកដែលស្នើឡើងដោយសមាជិក កម្មករនិយោជិត(សហព័ន្ធសហជីព):**

១- លោក លីវ សុវណ្ណា

២- លោក វ៉ែន ពៅ

៣- លោក សុង វណ្ណស៊ីន

៤- លោកស្រី ស៊ីន គីមស៊ាន

p

៥- លោក ទួន ស៊ីផាន់

៦- លោក វង្ស វណ្ណា

៧- លោក អន ណន

**ប្រការ២.** យោងតាមមាត្រា១២ នៃច្បាប់ស្តីពីការងារក្រុមប្រឹក្សាអាជ្ញាកណ្តាល មានភារកិច្ចដូចតទៅ:-

ក្រុមប្រឹក្សាអាជ្ញាកណ្តាលគ្មានភារកិច្ចពិនិត្យបញ្ហាដទៃ ក្រៅពីបញ្ហាដែលមានបញ្ជាក់ក្នុងកំណត់ហេតុមិនព្រមសះជា ឬបញ្ហាដែលកើតក្រោយការធ្វើកំណត់ហេតុជាផលវិបាកផ្ទាល់នៃការវិវាទនេះប៉ុណ្ណោះ ។

ក្រុមប្រឹក្សានេះដោះស្រាយជាផ្លូវច្បាប់ចំពោះការវិវាទ ដែលទាក់ទងនឹងការបកស្រាយ និងការអនុវត្តបញ្ញត្តិច្បាប់ ឬ អនុសញ្ញារួមណាមួយ ។ ក្រុមប្រឹក្សានេះដោះស្រាយដោយសមធមិចំពោះការវិវាទឯទៀតទាំងអស់ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអំណាចធំទូលាយ ដើម្បីស៊ើបអំពីស្ថានភាពសេដ្ឋកិច្ចនៃសហគ្រាស និងស្ថានភាពខាងសង្គមកិច្ចនៃកម្មករនិយោជិតដែលជាសាមីខ្លួនក្នុងការវិវាទ ។

ក្រុមប្រឹក្សានេះមានអំណាចអង្កេតគ្រប់បែបយ៉ាងនៅទីកន្លែងសហគ្រាស ឬ អង្គការវិជ្ជាជីវៈផ្សេងៗ ព្រមទាំងមានអំណាចចាត់ឱ្យភាគីជូនឯកសារ ឬ ពត៌មានខាងសេដ្ឋកិច្ច គណនេយ្យ ស្ថិតិ ហិរញ្ញវត្ថុ ឬ រដ្ឋបាលដែលមានប្រយោជន៍ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ។ ក្រុមប្រឹក្សានេះអាចសុំអ្នកជំនាញការជួយបានទៀតផង ។

សមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវលាក់អាថ៌កំបាំងវិជ្ជាជីវៈចំពោះពត៌មាន និងឯកសារទាំងឡាយដែលគេបានជូនមកឱ្យខ្លួនពិនិត្យ និងចំពោះហេតុការណ៍ទាំងអស់ ដែលខ្លួនបានដឹងក្នុងការបំពេញបេសកកម្មរបស់ខ្លួន ។

ការប្រជុំនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវប្រព្រឹត្តទៅដោយបិទទ្វារ ។

**ប្រការ៣.-** កិច្ចដំណើរការ អំណាចយុត្តាធិការ ការចេញសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ២០០៤ ព្រមទាំងវិធាននៃនីតិវិធីដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ នេះផង ។

**ប្រការ៤.-** សមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអាណត្តិមួយឆ្នាំ ដោយគិតចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ ២០០៤ ។

**ប្រការ៥.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

p **រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខៈ ១០៦ សកបយ.

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៤

# ប្រកាស
# ស្តីពី
# ការហាមឃាត់កុមារធ្វើការនៅកន្លែងការងារប្រកបដោយគ្រោះថ្នាក់

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

## សំរេច

**ប្រការ១.-** ហាមនិយោជកនៃសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារមិនឱ្យប្រើប្រាស់កុមារដែលមានអាយុក្រោម ១៨ ឆ្នាំ នៅក្នុងប្រភេទការងារដូចមានចែងក្នុងប្រការ២ នៃប្រកាសនេះ ។

ប្រសិនបើកុមារធ្វើការងារពុំមានឯកសារផ្លូវការណាមួយបញ្ជាក់ពីអាយុឱ្យបានត្រឹមត្រូវ ឬក៏អធិការការងារសង្ស័យថា ឯកសារមានការក្លែងបន្លំអាយុនោះ ត្រូវស្រាវជ្រាវករណីនេះនៅមូលដ្ឋានពាក់ព័ន្ធរបស់សាមីខ្លួននៃកុមារនេះ ។

ពាក្យបច្ចេកទេសទាំងឡាយមានពន្យល់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

ប្រការ២.- ការងារប្រកបដោយគ្រោះថ្នាក់គឺការងារដែលបណ្តាលឱ្យប៉ះពាល់សុខភាព សន្តិសុខ ឬសីល-ធម៌របស់កុមារ ជាអាទិ៍ :

១- ការរំលាយ ផ្លុំ ដំ (ស្មិត) មូរ ដំពង្រាប ឬផ្សារលោហធាតុ

២- ការនេសាទ (ក្នុងទឹក និងលើផ្ទៃទឹកជ្រៅ)

៣- ការមុជទឹកដើម្បីលាងជូត រកខ្ចងខ្ចៅ គុជ កើបខ្សាច់ និង ត្រួសអាចម៍ផ្កាយ

៤- ការកាប់ព្រៃឈើ

៥- ការដុតធ្យូង

៦- ការធ្វើការនៅកន្លែងម៉ាស៊ីនចំហាយ ម៉ាស៊ីនបូមខ្យល់ ម៉ាស៊ីនបញ្ចូលឧស្ម័នក្នុងបំពង់ ឬម៉ាស៊ីន ផលិតឧស្ម័ន(អាសេទីឡែន) ការដឹកជញ្ជូន និងការធ្វើការនៅក្នុងកន្លែងយកថ្ម ដូចជា ការខួង អុជ ធ្វើឱ្យផ្ទុះបំបែកថ្ម ឬកំទេចថ្ម

៧- ការបញ្ជាម៉ាស៊ីនកែច្នៃឈើ

៨- ការបញ្ជាម៉ាស៊ីនស្ទូច ម៉ាស៊ីនលើក កន្ត្រាក់ ម៉ាស៊ីនមានខ្សែសំរាប់លើកចុះឡើង ឬម៉ាស៊ីន សំរាប់លើកផ្សេងទៀត

៩- ការលើកដាក់ លីសែង យួរកាន់ និង ចលនារបស់ធ្ងន់ៗ (ដូចមានចែងក្នុងប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា លេខ ១២៤ សកបយ.ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០១ ស្តីពីការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្ម)

១០- ការពន្លត់អគ្គីភ័យ

១១- ការបើកបរ ឬ ជំនួយការបើកបរ (រួមមាន ការបញ្ឆេះម៉ាស៊ីន ការបញ្ជា ការតំរែតំរង់ ការថែទាំ ឬសកម្មភាពដទៃទៀត ដែលទាក់ទងនឹងការប៉ះទង្គិចរាងកាយ ដែលបណ្តាលមកពីការបើកបរ) គ្រឿងចក្រ ដូចជា ម៉ាស៊ីនឈូសដី ឬរុញដី រថយន្តសណ្តោងរ៉ឺម៉ក រ៉ូឡូកិនថ្ម ត្រាក់ទ័រសំរាប់លើកសម្ភារៈ ម៉ាស៊ីនជីកដី ម៉ាស៊ីនប្រមូលរបស់របរ ម៉ាស៊ីនផ្ទុកឥវ៉ាន់ រថយន្តដឹកទំនិញ រថយន្តក្រុង និង រថយន្តតាក់ស៊ី

១២- ការថែទាំជួសជុលម៉ាស៊ីនធុនធ្ងន់

១៣- ការធ្វើការនៅក្រោមដី ក្រោមទឹក គុហា ផ្លូវក្រោមដី អណ្តូងរ៉ែ និងការយករ៉ែ ឬយកថ្មក្នុងដី

១៤- ការធ្វើការពាក់ព័ន្ធនឹងវត្ថុដែលមានជាតិផ្ទុះ ជាតិអាស៊ីត កាំជ្រួច ឬវត្ថុដែលងាយឆេះ លើកលែងតែការងារផ្តល់សេវាកម្មនៅក្នុងស្ថានីយ៍ប្រេងឥន្ធនៈ

១៥- ការធ្វើការនៅការដ្ឋានសាងសង់ លើកលែងតែកន្លែងពិសេស ដែលអធិការការងារអាចអនុញ្ញាតឱ្យកុមារធ្វើបាន និងកន្លែងមានសុវត្ថិភាព

១៦- ការធ្វើការនៅកន្លែងរុះរើ និងរំលំរំលាយ

១៧- ការធ្វើការនៅលើជណ្តើរ ឬ រន្ទាដែលមានកំពស់លើសពី ២.៥០ ម៉ែត្រឡើងទៅ (ដូចជា ការលាបថ្នាំ ជូសជុល ឬសំណង់ កាត់មែកឈើ បេះផ្លែឈើ)

១៨- ការធ្វើការដែលពាក់ព័ន្ធទៅនឹងមេរោគសាស្ត្រ ដូចជា ការងារនៅមន្ទីរពិសោធន៍ ទឹកលូ សំអុយ និងគំនរសំរាម

១៩- ការធ្វើការដែលប៉ះពាល់វត្ថុដែលមានជាតិគីមី រូបសាស្ត្រ អេឡិចត្រូម៉ាញេទិច ឬ អ៊ីយ៉ុង ដូចជា :

- រូបធាតុដែលមិនឆេះ
- បង់ហ្សែន
- កាត់ម្ញូម
- បារត
- សំណ ស័ង្កសី ឧស្សាហកម្មលោហៈ សំណពណិស និងថ្នាំលាបមានជាតិសំណ
- សារធាតុវិទ្យុសកម្ម វត្ថុដែលបញ្ចេញពន្លឺ
- កាំរស្មីស្វាយអ៊ុលត្រា កាំរស្មីឡាស៊ែរ និងវិទ្យុបញ្ជូនប្រេកង់

២០- ការធ្វើការដែលពាក់ព័ន្ធទៅនឹងផ្សែង ធូលី ឧស្ម័ន និង សារធាតុដទៃទៀត ដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់សុខភាព

២១- ការបាញ់ថ្នាំសំលាប់សត្វល្អិត និង ថ្នាំសំលាប់ស្មៅរុក្ខជាតិផ្សេងៗ

២២- ការបញ្ជាក់លាំងម៉ាស៊ីនរវៃខារអំបោះ និងរុំអំបោះ

២៣- ការជ្រលក់ពណ៌ ការបង្ហើយវាយនភ័ណ្ឌ ការបោកគក់ ការអ៊ុត ដែលការងារទាំង៤ យ៉ាងនេះមានប្រើជាតិគីមី

២៤- ការតម្លើងបរិធានអគ្គិសនី រួមទាំងការងារអូស ដាក់ខ្សែភ្លើង និង តខ្សែកាប

២៥- ការធ្វើការនៅក្បែរឡដុតកំដៅ រ៉ែ ក្អម ឆ្នាំង ជាផ្នែកមួយនៃដំណើរការរោងចក្រផលិតកែវ កុលាលភាជន៍ និងផលិតឥដ្ឋ

២៦- ការផលិតភេសជ្ជៈដែលមានជាតិស្រវឹង ដូចជា ចំហុយស្រា ស្រាបៀរ និងស្រាទំពាំងបាយជូរ

២៧- ការធ្វើការមួយចំនួននៅកន្លែងកំសាន្ត ដូចជាការបំរើគ្រឿងស្រវឹង ការគក់ប្រចាច់ធ្វើសរសៃ ការបំរើនៅក្នុងក្លឹបរាត្រី ការរាំកំដរភ្ញៀវក្រៅពីការសំដែងសិល្បៈ ។ ចំពោះការបណ្តុះបណ្តាលវិជ្ជាជីវៈ និង ការធ្វើកម្មសិក្សា និយោជកអាចឱ្យកុមារធ្វើការទាំងនោះបាន ។

២៨- ការធ្វើការដែលទាក់ទងទៅនឹងល្បែង ដូចជា ការចែកសន្លឹកបៀ ការស៊ីសងនៅតាមតុល្បែង និង ការទទួលលុយភ្នាល់

២៩- ការធ្វើការដែលពាក់ព័ន្ធទៅនឹងការផលិតឬក៏ការដឹកជញ្ជូនថ្នាំញៀន ឬផលិតផលឱសថ

៣០- ការសំលាប់ស្បែក(កែច្នៃស្បែក)

៣១- ការធ្វើការជាឆ្មាំសង្គ្រោះនៅកន្លែងហែលទឹក និង ឆ្នេរងូតទឹកកំសាន្ត

៣២- ការធ្វើការនៅកន្លែងរោងជាងស្មិត

៣៣- ការធ្វើការនៅទីសត្តឃាត (កន្លែងសំលាប់សត្វ) និងជាអ្នកផ្គត់សាច់

៣៤- ការចំហៀវខ្លាញ់ ឬប្រេង

៣៥- ការធ្វើការជាបុគ្គលិកសន្តិសុខ

៣៦- ការធ្វើការនៅក្នុងផ្នែកកីឡាដែលប្រកបដោយគ្រោះថ្នាក់ ដូចជា ការបង្ហាត់សេះ ការបង្ហាត់បាញ់ស៊ីប ឬនៅក្នុងសាលាបាញ់ស៊ីប

៣៧- ការបូជាសព

៣៨- ការធ្វើការទាំងឡាយដែលស្ថិតក្នុងលក្ខខណ្ឌក្តៅ ត្រជាក់ ញ័រ សំលេង និង ពន្លឺភ្លើងមិនប្រក្រតី ដែលអាចបណ្តាលឱ្យមានគ្រោះថ្នាក់ ។

**ប្រការ៣.-** យោងតាមសំណើរបស់និយោជក ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អាចពិនិត្យ និង សំរេចចេញសេចក្តីអនុញ្ញាតឱ្យកុមារដែលមានអាយុចាប់ពី១៦ឆ្នាំឡើងធ្វើការងារប្រកបដោយគ្រោះថ្នាក់បានក្នុងលក្ខខណ្ឌ :

- កុមារត្រូវបានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈត្រឹមត្រូវ
- មិនត្រូវអនុញ្ញាតឱ្យធ្វើការនៅចន្លោះពេលពីម៉ោង ២២:០០ ដល់ម៉ោង ៥:០០ ភ្លឺ
- បានពិគ្រោះយោបល់ជាមួយគណៈកម្មការប្រឹក្សាការងារជាមុន ។

ចំពោះការងារនៅក្នុងអណ្តូងរ៉ែ ការយករ៉ែ ឬយកថ្មក្នុងដី ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មិនអនុញ្ញាតឱ្យក្មេងអាយុក្រោម ១៨ ឆ្នាំ ធ្វើការងារនៅទីនោះទេ ។

នៅមុនពេលចាប់ផ្តើមធ្វើការងារ និង យ៉ាងហោចណាស់មួយឆ្នាំម្តង រហូតដល់កុមារមានអាយុ ១៨ ឆ្នាំ កុមារត្រូវតែឱ្យមានការពិនិត្យសុខភាពនៅក្នុងបរិបទនៃការងារដែលអាចបង្កគ្រោះថ្នាក់ដល់កុមារ ដើម្បីបញ្ជាក់ថាមានសុខភាពល្អត្រឹមត្រូវ ។ ការពិនិត្យសុខភាពនេះត្រូវធ្វើឡើងដោយនាយកដ្ឋានពេទ្យការងារ ។

**ប្រការ៤.-** ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នឹងរៀបចំលិខិតបទដ្ឋានដោយឡែក ស្តីពីការចាត់តាំងគណៈកម្មការកែសំរួលបញ្ជីមុខរបរប្រកបដោយគ្រោះថ្នាក់ ។

**ប្រការ៥.-** អ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះត្រូវពិន័យ ឬទទួលទោស ដូចមានចែងក្នុងជំពូក ១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៦.-** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

ឧបសម្ព័ន្ធ នៃប្រកាសលេខ ១០៦ សកបយ.
ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៤

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## សេចក្តីពន្យល់ពាក្យបច្ចេកទេស (ការងារប្រកបដោយគ្រោះថ្នាក់)

| ពាក្យខ្មែរ | ភាសាអង់គ្លេស | សេចក្តីពន្យល់ |
|---|---|---|
| ម៉ាស៊ីនបញ្ចូលឧស្ម័នក្នុងបំពង់ | Gas cylinders | ម៉ាស៊ីនបញ្ចូលសារធាតុមានក្លិន រាវ ពុល វិទ្យុសកម្ម ស្រាលជាងខ្យល់ ដុតឆេះ តាមបំពង់បង្ហូរ |
| អាសេទីឡែន | Acetylene | សារធាតុមានក្លិន រាវ ពុល វិទ្យុសកម្ម ស្រាលជាងខ្យល់ដុតឆេះ ( វត្ថុងាយឆេះ ) |
| ម៉ាស៊ីនកែច្នៃឈើ | Powre-driven woodworking machine | ជាការកែច្នៃដោយកំលាំងម៉ាស៊ីនដែលប្រមូល និងកែច្នៃឈើមូល ឬ ឈើដែលបោះបង់ចោល ឬសំណល់ដើម្បីបំប្លែងទៅជាផលិតផលដែលអាចប្រើប្រាស់បាន |
| ម៉ាស៊ីនលើកកន្ត្រាក់ | Lifting machine | ជាការលើកកន្ត្រាក់ដោយកំលាំងម៉ាស៊ីន |
| ជាតិអាស៊ីត | Acid p | សារធាតុដែលរលាយក្នុងទឹកបំបែកជាអ៊ីយ៉ុងផ្តល់ជាសូលុយស្យុងអាស៊ីតដែលមានក្លិនឈ្ងក់អាចធ្វើឱ្យស្ទះដល់ប្រព័ន្ធដកដង្ហើម និងមានរសជាតិពុលខ្លាំង |
| គីមី | Chemistry | វិទ្យាសាស្ត្រដែលសិក្សាអំពីទំរង់លក្ខណៈសមាសភាព និងបំលែងនៃអង្គធាតុ |
| រូបសាស្ត្រ | Physical | សំណុំវិទ្យាសាស្ត្រដែលសិក្សាអំពីលក្ខណៈរូបនៃរូបធាតុ (រឹង រាវ ឧស្ម័ន) |
| អេឡិចត្រូម៉ាញ៉េទិច | Electromagnetic | មេដែកអគ្គិសនី |
| អ៊ីយ៉ុង | Ion | ភាគល្អិត ( អាតូម ឬ ក្រុមអាតូម )ដែលមានផ្ទុកបន្ទុកអគ្គិសនីបណ្តាលមកពីការបាត់បង់ ឬ ចំណេញអេឡិចត្រុង |

| | | |
|---|---|---|
| បង់ហ្សែន | Benzene | អ៊ីដ្រូកាបូប្រហើរ រាវ ទាញចេញពីធ្យូងថ្ម និង ប្រេងកាត ។ បង់សែនជាសារធាតុពុលខ្លាំងហើយអាចបណ្តាលឱ្យកើតជំងឺមហារីកឈាម |
| កាត់ម្ញ៉ូម | Cadmium | ជាលោហៈធន់ ទន់ ពណ៌ប្រាក់មាននិមិត្តសញ្ញា CD |
| បារត | Mercury | ជាសារធាតុពុលដែលអាចធ្វើឱ្យមានគ្រោះថ្នាក់ដល់សុខភាពមនុស្សយ៉ាងធ្ងន់ធ្ងរបណ្តាលមកពីការប៉ះពាល់ដល់សសៃប្រសាទ |
| ឧស្សាហកម្មលោហៈ | Metallurgy | ឧស្សាហកម្មដែលមានផ្នែកលោហៈចម្លងកំដៅ និង អគ្គិសនីបានល្អ និង ជាទូទៅអាចហូតជាលួសបាន |
| សារធាតុវិទ្យុសកម្ម | Radioactive substances | ប្រភេទរូបធាតុនៃបាតុភូតដែលអង្គធាតុអាចបញ្ចេញដោយខ្លួនឯងនូវភាគល្អិតរបស់អាតូម ដូចជា ភាគល្អិតរបស់អាល់ផា និង ភាគល្អិតបេតា ឬ កាំរស្មីអេឡិចត្រូម៉ាញេទិចដូចជា កាំរស្មីអ៊ិច និង កាំរស្មីកាម៉ាបណ្តាលមកពីការបំបែកណ្វៃយ៉ូ អាតូម ឬ ប្រតិកម្មនុយក្លេអ៊ែរ |
| កាំរស្មីស្វាយអ៊ុលត្រា | Ultraviolet ray | ជាកាំរស្មីដែលភ្នែកមនុស្សមើលពុំឃើញ |
| កាំរស្មីឡាស៊ែរ | Laser | វត្ថុធាតុម្យ៉ាងដែលមានអំពូលឈ្មោះថា Monocromatic មានពណ៌តែ ១ ហើយបញ្ចេញកាំរស្មី |
| វិទ្យុបញ្ជូនប្រេកង់ | Radio-frequency emission | ឧបករណ៍សំរាប់បញ្ជូនតាមរលកធាតុអាកាស |
| វាយនភ័ណ្ឌ | Textile | ផលិតផលសំរេចនៃកីតម្បាញ |
| កុលាលភាជន៍ | Ceramic | វត្ថុដែលធ្វើអំពី ដី ដូចជា ចាន ឆ្នាំង ក្អម |

រាជធានីភ្នំពេញ ,ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ
និងយុវនីតិសម្បទា

លេខៈ ២៦៥ សកបយ. រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤

# ប្រកាស
## ស្តីពី
## ការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។
-បានឃើញប្រកាសលេខ ១៤១សកបយ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈកម្មការប្រឹក្សាគម្រោងដោះស្រាយវិវាទការងារនៅកម្ពុជា
-បានឃើញប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល
-បានឃើញប្រកាសលេខ ១០៣ សកបយ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៤ ស្តីពីការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល
-បានឃើញលិខិត ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៤ របស់ប្រធានទីប្រឹក្សាបច្ចេកទេសនៃគម្រោងដោះស្រាយវិវាទការងារនៅកម្ពុជា ស្តីពីសំណើសុំតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល

## សំរេច

**ប្រការ១.-** តែងតាំងបន្ថែមក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលមានសមាជិកថ្មីដូចខាងក្រោម :-

**I-សមាជិកដែលស្នើឡើងដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

១- លោក គីមយាត ដារ៉ារិទ្ធ

២- លោក ប៉ែន ប៊ុនឈា

II-សមាជិកដែលស្នើឡើងដោយសមាគមនិយោជក:

១- លោក អ៊ឹង សុទ្ធី

២- លោកស្រី សេង វួចហ៊ិន

III- សមាជិកដែលស្នើឡើងដោយសហជីព កម្មករនិយោជិត (សហព័ន្ធសហជីព)

១- លោក ហួន ជុនឌី

២- លោក លី អ៊ុយម៉េង

**ប្រការ២.-** យោងតាមមាត្រា ១២ នៃច្បាប់ស្តីពីការងារក្រុមប្រឹក្សាអាជ្ញាកណ្តាល មានភារកិច្ចដូចតទៅ:

ក្រុមប្រឹក្សាអាជ្ញាកណ្តាលគ្មានភារកិច្ចពិនិត្យបញ្ហាដទៃ ក្រៅពីបញ្ហាដែលមានបញ្ជាក់ក្នុងកំណត់ហេតុមិនព្រមសះជា ឬបញ្ហាដែលកើតក្រោយការធ្វើកំណត់ហេតុ ជាផលវិបាកផ្ទាល់នៃការវិវាទនេះប៉ុណ្ណោះ ។

ក្រុមប្រឹក្សានេះដោះស្រាយជាផ្លូវច្បាប់ចំពោះការវិវាទដែលទាក់ទងនឹងការបកស្រាយ និងការអនុវត្តបញ្ញត្តិច្បាប់ ឬ អនុសញ្ញារួមណាមួយ ។ ក្រុមប្រឹក្សានេះដោះស្រាយដោយសមធម៌ចំពោះការវិវាទឯទៀតទាំងអស់ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអំណាចធំទូលាយ ដើម្បីស៊ើបអំពីស្ថានភាពសេដ្ឋកិច្ចនៃសហគ្រាស និងស្ថានភាពខាងសង្គមកិច្ចនៃកម្មករនិយោជិតដែលជាសាមីខ្លួនក្នុងការវិវាទ ។

ក្រុមប្រឹក្សានេះមានអំណាចអង្កេតគ្រប់បែបយ៉ាងនៅទីកន្លែងសហគ្រាស ឬ អង្គការវិជ្ជាជីវៈផ្សេងៗ ព្រមទាំងមានអំណាចចាត់ឱ្យភាគីជូនឯកសារ ឬ ពត៌មានខាងសេដ្ឋកិច្ច គណនេយ្យ ស្ថិតិ ហិរញ្ញវត្ថុ ឬ រដ្ឋបាល ដែលមានប្រយោជន៍ក្នុងគ្នារបំពេញបេសកកម្មរបស់ខ្លួន ។ ក្រុមប្រឹក្សានេះអាចសុំអ្នកជំនាញការជួយបានទៀតផង ។

សមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវលាក់អាថ៌កំបាំងវិជ្ជាជីវៈចំពោះពត៌មាន និង ឯកសារទាំងឡាយដែលគេបានជូនមកឱ្យខ្លួនពិនិត្យ និង ចំពោះហេតុការណ៍ទាំងអស់ដែលខ្លួនបានដឹងក្នុងការបំពេញបេសកកម្មរបស់ខ្លួន ។

ការប្រជុំនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវប្រព្រឹត្តទៅដោយបិទទ្វារ ។

**ប្រការ៣.-** កិច្ចដំណើរការ អំណាចយុត្តាធិការ ការចេញសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃប្រកាសលេខ ០៩៩ សកបយ.ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ២០០៤ ព្រមទាំងវិធាននៃនីតិវិធីដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ នេះផង ។

**ប្រការ៤.-** សមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលខាងលើ ត្រូវបានតែងតាំងសំរាប់រយៈពេលដែលនៅសល់ក្នុងអាណត្តិទីពីរនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

**ប្រការ៥.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ: ៤១៦ ក.ក.ប.វ. រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មការប្រឹក្សាគម្រោងតាមឃ្លាំមើលលក្ខខណ្ឌការងារ នៅក្នុងវិស័យវាយនភណ្ឌ និងសំលៀកបំពាក់នៅកម្ពុជា

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការ ជាប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-យោងសេចក្តីថ្លែងការណ៍អំពីបំណងប្រាថ្នាចង់ធ្វើអោយប្រាកដថាលក្ខខណ្ឌការងារនៅក្នុងវិស័យវាយនភណ្ឌ និងសំលៀកបំពាក់នៅកម្ពុជា ស្របតាមបទដ្ឋានការងារសំខាន់ៗ ដែលទទួលស្គាល់ជាអន្តរជាតិ និងច្បាប់ស្តីពីការងារកម្ពុជា ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០០

-យោងអនុស្សរណៈនៃការយោគយល់គ្នារវាង ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សមាគមរោងចក្រកាត់ដេរនៅកម្ពុជា និងអង្គការពលកម្មអន្តរជាតិ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៣

-យោងលិខិតលេខ ២១៤៩ ពណ/របៈ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៤ របស់ក្រសួងពាណិជ្ជកម្មស្តីពីការបញ្ជូនមន្ត្រីមួយរូប ដើម្បីតែងតាំងជាសមាជិកពេញសិទ្ធិនៃគណៈកម្មការប្រឹក្សាគម្រោងតាមឃ្លាំមើលលក្ខខណ្ឌការងារនៅក្នុងវិស័យវាយនភណ្ឌ និងសំលៀកបំពាក់នៅកម្ពុជា

-យោងលិខិតលេខ ១៦៦៥ ឧរថ/បឧ/លស ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពីការបញ្ជូនមន្ត្រី ដើម្បីតែងតាំងជាសមាជិកបំរុងនៃគណៈកម្មការប្រឹក្សាគម្រោងតាមឃ្លាំមើលលក្ខខណ្ឌការងារនៅក្នុងវិស័យវាយនភណ្ឌ និងសំលៀកបំពាក់នៅកម្ពុជា

-យោងលិខិតលេខ ១៤២/០៩/០៤ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៤ របស់សមាគមរោងចក្រកាត់ដេរនៅកម្ពុជា ស្តីពីសំណើសុំតែងតាំងសមាជិក ០៦ រូប នៃគណៈកម្មការប្រឹក្សាគម្រោង

-យោងលិខិតចុះថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៤ របស់ប្រធានគម្រោងអប់រំដល់ចលនាសហជីពកម្មករកម្ពុជា

ស្តីពីសំណើសុំតែងតាំងសមាជិក ០៦ រូប នៃគណៈកម្មការប្រឹក្សាគម្រោង

-យោងលិខិត ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៤ របស់ប្រធានទីប្រឹក្សាបច្ចេកទេសរបស់គម្រោង ដែលស្នើសុំតែងតាំងសមាជិកគណៈកម្មការប្រឹក្សាគម្រោង

## សម្រេច

**ប្រការ១.-** បង្កើតគណៈកម្មការប្រឹក្សាគម្រោងតាមឃ្លាំមើលលក្ខខណ្ឌការងារនៅក្នុងវិស័យវាយនភណ្ឌ និងសំលៀកបំពាក់នៅកម្ពុជា ដែលមានសមាសភាពដូចខាងក្រោមនេះ :-

I-**សមាជិកពេញសិទ្ធិ**

ក-តំណាងក្រសួង រាជរដ្ឋាភិបាល

| | |
|---|---|
| -លោកជំទាវ ប្រាក់ ចន្ថា | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| -លោកជំទាវ សៅ ស្រីពៅ | អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| -លោក ឱក តារារិទ្ធ | អនុប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ។ |

ខ-តំណាងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា

| | |
|---|---|
| -លោក វ៉ាន់ ស៊ូអៀង | ប្រធានសមាគមរោងចក្រកាត់ដេរនៅកម្ពុជា |
| -លោក គង់ សាង | សមាជិកប្រតិបត្តិនៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា |
| -លោក Ken Loo | លេខាធិការនៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា ។ |

គ-តំណាងចលនាសហជីពកម្ពុជា

| | |
|---|---|
| -លោក រស់ សុក | ប្រធានសហព័ន្ធសហជីពឯករាជ្យកម្ពុជា |
| -កញ្ញា ឆន សុខា | អនុប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| -កញ្ញា សំ ស្រីមុំ | អនុប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ។ |

II-**សមាជិកបម្រុង**

ក- តំណាងក្រសួង រាជរដ្ឋាភិបាល

| | |
|---|---|
| -លោក ហួត ចាន់ធី | ប្រធាននាយកដ្ឋានអធិការកិច្ចការងារ |
| -លោក សាត សមុទ្រ | ប្រធាននាយកដ្ឋានបច្ចេកទេសឧស្សាហកម្ម |
| -លោក កុយ ទេពដារ៉ាវុធ | អនុប្រធាននាយកដ្ឋានអធិការកិច្ចការងារ ។ |

ខ- តំណាងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា

| | |
|---|---|
| -លោក ជាតិ ខេមរា | មន្ត្រីទទួលបន្ទុកទំនាក់ការងារនៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា |
| -លោក Ray Chew | សមាជិកប្រតិបត្តិនៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា |
| -លោក John Lu | នាយកគ្រប់គ្រងនៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជា ។ |

គ-តំណាងចលនាសហជីពកម្ពុជា

-លោក សោម អូន ប្រធានសហព័ន្ធសហជីពកម្មករកម្ពុជា

-លោក វង្ស សុវណ្ណ ប្រធានសហព័ន្ធសហជីពការងារកម្មករកម្ពុជា

-លោក អាត់ ធន់ ប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា។

**ប្រការ២.-** សមាជិកគណៈកម្មការប្រឹក្សាគម្រោង ដែលតំណាងឱ្យក្រសួង រាជរដ្ឋាភិបាល និងតំណាងឱ្យសមាគមរោងចក្រកាត់ដេរនៅកម្ពុជា មានអាណត្តិពីរឆ្នាំ។ ដោយឡែកសមាជិកគណៈកម្មការប្រឹក្សាគម្រោង ដែលតំណាងឱ្យចលនាសហជីពកម្ពុជាមានអាណត្តិប្រាំមួយខែ។

**ប្រការ៣.-** គណៈកម្មការប្រឹក្សាគម្រោងមានសហប្រធានពីររូបគឺមួយរូបជាសហប្រធានអចិន្ត្រៃយ៍ និងមួយរូបទៀតជាសហប្រធានប្តូរវេន។

សហប្រធានអចិន្ត្រៃយ៍ត្រូវជ្រើសរើសក្នុងចំណោមសមាជិកពេញសិទ្ធិនៃគណៈកម្មការប្រឹក្សាគម្រោង ដែលតំណាងឱ្យក្រសួង រាជរដ្ឋាភិបាល ។ សហប្រធានប្តូរវេនត្រូវជ្រើសរើសក្នុងចំណោមសមាជិកពេញសិទ្ធិនៃគណៈកម្មការប្រឹក្សាគម្រោង ដែលតំណាងឱ្យសមាគមរោងចក្រកាត់ដេរនៅកម្ពុជា សំរាប់រយៈពេលប្រាំមួយខែដំបូង និងត្រូវជ្រើសរើសក្នុងចំណោមសមាជិកពេញសិទ្ធិនៃគណៈ-កម្មការប្រឹក្សាគម្រោង ដែលតំណាងឱ្យចលនាសហជីពកម្ពុជា សំរាប់រយៈពេលប្រាំមួយខែបន្ទាប់។ ការជ្រើសរើសសហប្រធានប្តូរវេនត្រូវអនុវត្តតាមនីតិវិធីនេះ សំរាប់រយៈពេលប្រាំមួយខែជាបន្តបន្ទាប់ទៀត។

**ប្រការ៤.-** លោកជំទាវ ប្រាក់ ចន្ថា ត្រូវបានតែងតាំងជាសហប្រធានអចិន្ត្រៃយ៍ ហើយលោក វ៉ាន់ ស៊ូអៀង តំណាងឱ្យសមាគមរោងចក្រកាត់ដេរនៅកម្ពុជា ត្រូវបានតែងតាំងជាសហប្រធានប្តូរវេនក្នុងរយៈពេលប្រាំមួយខែដំបូង ។

**ប្រការ៥ .-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ហត្ថលេខា និង ត្រា**

**ញ៉ែប ប៊ុនជិន**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ: ៤៥៣ ក.ក.ប.វ.

រាជធានីភ្នំពេញ , ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៤

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មការប្រឹក្សាគម្រោងដោះស្រាយវិវាទការងារនៅកម្ពុជា

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការ ជាប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-យោងសេចក្តីប្រកាសអំពីបំណងប្រាថ្នា ដើម្បីលើកកំពស់ទំនាក់ទំនងវិជ្ជាជីវៈ និងអនុវត្តច្បាប់ស្តីពីការងារ ដែលបានចុះហត្ថលេខា រវាងអង្គការអន្តរជាតិខាងការងារ និងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា កាលពីថ្ងៃទី ០២ ខែ មេសា ឆ្នាំ២០០២

-យោងលិខិត ១១៤៨ បបប.កយ/២០០៤ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៤ របស់ក្រសួងយុត្តិធម៌ ស្តីពីការចាត់តាំងមន្ត្រី ០២ រូប ដើម្បីធ្វើជាសមាជិកគណៈកម្មការប្រឹក្សាគម្រោង ស្តីពីការដោះស្រាយវិវាទការងារនៅកម្ពុជា

-យោងលិខិតរបស់លោក HUGO VAN NOORD ប្រធានទីប្រឹក្សាបច្ចេកទេសរបស់គម្រោង ស្តីពីការដោះស្រាយវិវាទការងារនៅកម្ពុជា ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ២០០៤ ស្តីពីសំណើសុំតែងតាំងសមាជិកគណៈកម្មការប្រឹក្សាគម្រោង ដែលតំណាងអោយសមាគមនិយោជក និងចលនាសហជីពកម្ពុជា

-យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

## សម្រេច

**ប្រការ១.-** បង្កើតគណៈកម្មការប្រឹក្សាគម្រោងស្តីពីការដោះស្រាយវិវាទការងារនៅកម្ពុជា ដែលមានសមាសភាព ដូចខាងក្រោមនេះ:-

I-**សមាជិកពេញសិទ្ធិ**

ក-<u>តំណាងក្រសួង រាជរដ្ឋាភិបាល</u>

| | |
|---|---|
| -លោកជំទាវ ប្រាក់ ចន្ថា | រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| -លោក សេង សក្តា | ប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម |
| -លោក នាងស៊ីណា វឌ្ឍនៈ | អនុប្រធាននាយកដ្ឋានបុគ្គលិក និងបណ្តុះបណ្តាលក្រសួងយុត្តិធម៌ ។ |

ខ-<u>តំណាងសមាគមនិយោជក</u>

| | |
|---|---|
| -លោក វ៉ាន់ ស៊ូអៀង | ប្រធានសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា |
| -អ្នកឧកញ៉ា សូ ងួន | ប្រធានក្រុមហ៊ុនផែស្ងួត និងដឹកជញ្ជូន សូ ងួន |
| -លោក Michel Horn | នាយកសណ្ឋាគារកាំបូឌីយ៉ាណា ។ |

គ-<u>តំណាងចលនាសហជីពកម្ពុជា</u>

| | |
|---|---|
| -លោក រស់ សុក | ប្រធានសហព័ន្ធសហជីពឯករាជ្យកម្ពុជា |
| -លោក សោម អួន | ប្រធានសហព័ន្ធសហជីពកម្មករកម្ពុជា |
| -លោក ឈុន សំអួន | សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ។ |

II-**សមាជិកបម្រុង**

ក- <u>តំណាងក្រសួង រាជរដ្ឋាភិបាល</u>

| | |
|---|---|
| -លោក អ៊ិន ខេមរា | អនុប្រធាននាយកដ្ឋានអធិការកិច្ចការងារ |
| -លោក តាន់ ម៉ារ៉ា | មន្ត្រីខុទ្ទកាល័យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| -លោក ម៉េង ជាហេង | មន្ត្រីគ្រប់គ្រងរដ្ឋបាលក្រសួងយុត្តិធម៌ ។ |

ខ- <u>តំណាងសមាគមនិយោជក</u>

| | |
|---|---|
| -លោក VANDARA SAY | នាយកក្រុមហ៊ុន Armstrong Engineering Co Ltd., |
| -លោក គង់ សាង | នាយកក្រុមហ៊ុន QMI Industrial |
| -លោកឧកញ៉ា LOCH SARETH | នាយកក្រុមហ៊ុន Wing Ly Import and Export Co Ltd |

គ-<u>តំណាងចលនាសហជីពកម្ពុជា</u>

| | |
|---|---|
| -លោក លាង ស៊ុនហ៊ាង | អនុប្រធានសហព័ន្ធសហជីពកម្មករកម្ពុជា |
| -លោកស្រី ទេព គីមវណ្ណារី | អនុប្រធានសហព័ន្ធសហជីពឯករាជ្យកម្ពុជា |
| -លោក អ៊ូ សុផាត | សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ។ |

**ប្រការ២.-** សមាជិកគណៈកម្មការប្រឹក្សាគម្រោង ដែលតំណាងឱ្យក្រសួង រាជរដ្ឋាភិបាល និងតំណាងឱ្យសមាគមនិយោជកមានអាណត្តិពីរឆ្នាំ ។ ដោយឡែកសមាជិកគណៈកម្មការប្រឹក្សាគម្រោងដែលតំណាងឱ្យចលនាសហជីពកម្ពុជាត្រូវបានផ្លាស់ប្តូរក្នុងអាណត្តិប្រាំមួយខែ ។

**ប្រការ៣.-** លោកជំទាវ ប្រាក់ ចន្ថា រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវបានតែងតាំងជាប្រធានគណៈកម្មការប្រឹក្សាគម្រោង ។

**ប្រការ៤.-** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ជ.រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋលេខាធិការ**

**ហត្ថលេខា និង ត្រា**

**សុខ សាន**

p

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខៈ ៤១៣ ក.ក.ប.វ.

រាជធានីភ្នំពេញ . ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៥

# ប្រកាស

## ស្តីពី

## ប័ណ្ណការងារ និងសៀវភៅការងារជនបរទេស

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៘

## ស ម្រេ ច

**ប្រការ១.-** ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងឡាយ ដូចមានចែងក្នុងមាត្រា១នៃច្បាប់ស្តីពីការងារ ដែលត្រូវការប្រើប្រាស់ជនបរទេស ឬជនបរទេស ដែលចូលមកប្រកបមុខរបរអ្វីមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញបែបបទស្នើសុំប័ណ្ណការងារ និងសៀវភៅការងារឱ្យបានត្រឹមត្រូវ ។

**ប្រការ២.-** សំណុំបែបបទសំរាប់ស្នើសុំប័ណ្ណការងារ និងសៀវភៅការងារជនបរទេសរួមមាន :-

១-ពាក្យស្នើសុំប័ណ្ណការងារ និងសៀវភៅការងារបិទតែមប្រើយ៍

១.០០០ រៀល ដោយមានភ្ជាប់មកជាមួយនូវរូបថតចំពីមុខ

ទំហំ ៣ សម x ៤ សម ចំនួន ០៤ សន្លឹក ចំនួន ០១ច្បាប់

២-សេចក្តីបញ្ជាក់របស់ម្ចាស់សហគ្រាស គ្រឹះស្ថានអំពីចំនួនកម្មករ

និយោជិតខ្មែរ និងចំនួនជនបរទេស ដែលមានបច្ចុប្បន្ន ចំនួន ០១ច្បាប់

៣-សេចក្តីថតចម្លងលិខិតឆ្លងដែនជនបរទេសម្នាក់ៗ ចំនួន ០១ច្បាប់

៤-អាករប្រចាំឆ្នាំដែលជនបរទេសម្នាក់ៗ ត្រូវបង់ ចំនួន ១០០ ដុល្លារអាមេរិក

(មួយរយដុល្លារអាមេរិក

៥-កិច្ចសន្យាការងារ ឬសេចក្តីប្រកាសជូនដំណឹងជាលាយលក្ខណ៍អក្សរ

ស្តីពីកិច្ចសន្យាការងាររបស់ជនបរទេស ចំនួន ០១ច្បាប់

៦-វិញ្ញាបនប័ត្របញ្ជាក់ថា មានកាយសម្បទាសមស្របនឹងមុខរបរ

ដែលចេញឱ្យដោយស្ថាប័នមានសមត្ថកិច្ចរបស់ប្រទេសដើម

នៃសាមីជនបរទេសក្នុងរយៈពេលមិនលើសពី ៦ ខែ ចំនួន ០១ច្បាប់

ចំពោះជនបរទេស ដែលចូលមកដល់ព្រះរាជាណាចក្រកម្ពុជារួចហើយ តែមិនទាន់មានវិញ្ញា-បនប័ត្រនេះ ត្រូវមានវិញ្ញាបនប័ត្របញ្ជាក់កាយសម្បទា ដែលមានសេចក្តីសន្និដ្ឋានថា អាចធ្វើការបាន ដែលចេញឱ្យដោយនាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ០១ ច្បាប់ ។

**ប្រការ៣.-** ចំពោះជនបរទេសដែលត្រូវពន្យាសុពលភាពប័ណ្ណការងារ និងសៀវភៅការងារ បែបបទនានាដែលត្រូវបំពេញ រួមមាន :-

១-ពាក្យស្នើសុំពន្យារសុពលភាពប័ណ្ណការងារ និងសៀវភៅការងារ

បិទតែមប្រិយ៍ ១.០០០រៀល ដោយមានភ្ជាប់មកជាមួយនូវរូបថតចំពីមុខ

ទំហំ ៣ សម x ៤ សម ចំនួន០២ សន្លឹក ចំនួន ០១ច្បាប់

២-សេចក្តីបញ្ជាក់របស់ម្ចាស់ ឬនិយោជក អំពីចំនួនកម្មករនិយោជិតខ្មែរ

និង បរទេសក្នុងក្រុមហ៊ុន សហគ្រាស គ្រឹះស្ថាន

ដែលជនបរទេសត្រូវធ្វើការជាមួយ ចំនួន ០១ច្បាប់

៣-សេចក្តីចម្លងលិខិតឆ្លងដែន ចំនួន ០១ច្បាប់

៤-អាករប្រចាំឆ្នាំសំរាប់ជនបរទេសម្នាក់ៗ ចំនួន ១០០ដុល្លារអាមេរិក

(មួយរយដុល្លារអាមេរិក)

៥-កិច្ចសន្យាការងារ ឬសេចក្តីប្រកាសជូនដំណឹងជាលាយលក្ខណ៍អក្សរ

ស្តីពីកិច្ចសន្យាការងាររបស់ជនបរទេស ចំនួន ០១ច្បាប់

៦-វិញ្ញាបនប័ត្របញ្ជាក់កាយសម្បទា ដែលមានសេចក្តីសន្និដ្ឋានថា

អាចធ្វើការបាន ដែលចេញឱ្យដោយនាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារ និង

បណ្ដុះបណ្ដាលវិជ្ជាជីវៈ ចំនួន ០១ច្បាប់ ។

**ប្រការ៤.-** ការបង់អាករពន្យារពេលសុពលភាពប័ណ្ណការងារ និងសៀវភៅការងារ ត្រូវធ្វើឱ្យបានហើយមុនដំណាច់ខែមីនា នៃឆ្នាំនីមួយៗ ។ ក្នុងករណីដែលរកឃើញមានការខកខានមិនបានពន្យារសុពលភាពទៅតាមការកំណត់ខាងលើនេះទេ សហគ្រាស គ្រឹះស្ថាន ដែលប្រើសាមីជនបរទេសត្រូវបានចាត់ទុកថា បានរក្សាទុក ឬប្រើប្រាស់ជនបរទេសដោយមិនមានប័ណ្ណការងារ និងសៀវភៅការងារ ។

ចំពោះអ្នកដែលបានបង់អាករប្រចាំឆ្នាំរួចហើយ តែសុពលភាពប័ណ្ណការងារ និងសៀវភៅការងារ មិនមានរហូតដល់ដំណាច់ឆ្នាំ កាលបរិច្ឆេទនៃការពន្យារសុពលភាពនេះ មិនកំណត់ដូចខាងលើទេ គឺ ត្រូវពន្យារសុពលភាពនៅពេលដែលអស់សុពលភាពប័ណ្ណការងារ និងសៀវភៅការងារដែលបានចេញជូនរួចហើយ ។

**ប្រការ៥.-** ចំពោះជនបរទេស ដែលត្រូវបានអនុញ្ញាតឱ្យស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជាប់កាតព្វកិច្ចបង់អាករ ដើម្បីទទួលបានប័ណ្ណការងារ និងសៀវភៅការងារ ។

បែបបទសំរាប់ស្នើសុំប័ណ្ណការងារ និងសៀវភៅការងារសំរាប់ជនបរទេសប្រភេទនេះរួមមានៈ

១-ពាក្យស្នើសុំប័ណ្ណការងារ និងសៀវភៅការងារបិទតែមប្រើយ៍
១.០០០រៀល ដោយមានភ្ជាប់មកជាមួយនូវរូបថតចំពីមុខ
ទំហំ ៣ សម x ៤ សម ចំនួន ០២សន្លឹក ចំនួន ០១ច្បាប់

២-អត្តសញ្ញាណប័ណ្ណ ឬលិខិតដែលមានតំលៃស្មើដែលក្រសួងមហាផ្ទៃបានអនុញ្ញាត
ឱ្យស្នាក់នៅអចិន្ត្រៃយ៍ត្រឹមត្រូវនៅក្នុងព្រះរាជាណាចក្រកម្ពុជា ចំនួន ០១ច្បាប់

៣-វិញ្ញាបនប័ត្របញ្ជាក់កាយសម្បទាដែលមានសេចក្ដីសន្និដ្ឋានថា
អាចធ្វើការបាន ដែលចេញឱ្យដោយនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និង
បណ្ដុះបណ្ដាលវិជ្ជាជីវៈ ចំនួន ០១ច្បាប់

៤-អាករប្រចាំឆ្នាំសំរាប់ជនបរទេសម្នាក់ៗ ចំនួន ៥០ដុល្លារអាមេរិក(ហាសិបដុល្លារអាមេរិក)

**ប្រការ៦.-** ចំពោះការពន្យារសុពលភាពប័ណ្ណការងារ និងសៀវភៅការងារជនបរទេស ដែលស្នាក់នៅអចិន្ត្រៃយ៍ ក៏មានបែបបទដូចគ្នានឹងការស្នើសុំធ្វើប័ណ្ណការងារ និងសៀវភៅការងារក្នុងប្រការ៥ ផងដែរ ។ ចំពោះការខកខានមិនបានធ្វើការពន្យារសុពលភាពឱ្យបានត្រឹមត្រូវមុនដំណាច់ខែមីនា នៃឆ្នាំនីមួយៗទេនោះ សាមីជនបរទេសត្រូវចាត់ទុកថា គ្មានប័ណ្ណការងារ និងសៀវភៅការងារ ។

**ប្រការ៧.-** អ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ នឹងត្រូវពិន័យ ឬទទួលទោស ដូចមានចែងនៅក្នុងជំពូក ១៦ នៃច្បាប់ស្ដីពីការងារ ។

**ប្រការ៨.-** ប្រកាសលេខ ១៦២ សកបយ ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីប័ណ្ណការងារ និងសៀវភៅការងារជនបរទេស របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវបានជំនួសដោយប្រកាសលេខ ៤១៣ ក.ក.ប.វ ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៥ ស្តីពីប័ណ្ណការងារ និងសៀវភៅការងារជនបរទេស របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**ប្រការ៩.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**ហត្ថលេខា និង ត្រា**

**ញៀប ប៊ុនជិន**

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខៈ ៤១៤ ក.ក.ប.វ.

រាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៥

# ប្រកាស
# ស្តីពី
# សៀវភៅការងារកម្មករនិយោជិតខ្មែរ

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែម សំដៅធានាដំណើរការ ជាប្រក្រតីនៃស្ថាប័នជាតិ
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-យោងអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# ស ម្រេ ច

**ប្រការ១.-** ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងឡាយ ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពី ការងារ មិនអាចប្រើកម្មករនិយោជិតខ្មែរ ដោយគ្មានសៀវភៅការងារឡើយ ហើយត្រូវបង្កលក្ខណៈងាយស្រួលឱ្យពួកគេមានលទ្ធភាពគ្រប់គ្រាន់ ដើម្បីទៅធ្វើសៀវភៅការងារនៅនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំពោះអ្នកនៅរាជធានីភ្នំពេញ និងនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត-ក្រុងនីមួយៗ ចំពោះអ្នកនៅខេត្ត-ក្រុង ។

**ប្រការ២.-** នៅពេលស្នើសុំសៀវភៅការងារ កម្មករនិយោជិតម្នាក់ៗ ត្រូវយកទៅជាមួយនូវៈ-

- ពាក្យស្នើសុំសៀវភៅការងារ បិទតែមប្រើយី ១.០០០ រៀល ដោយមានភ្ជាប់មកជា

មួយនូវ រូបថតចំពីមុខ ទំហំ ៣ គុណ ៤ សម ចំនួន ០៥ សន្លឹក ចំនួន ០១ច្បាប់

- អត្តសញ្ញាណប័ណ្ណជនជាតិខ្មែរ ឬលិខិតបញ្ជាក់សញ្ជាតិខ្មែរ ដែលចេញឱ្យដោយអាជ្ញាធរមានសមត្ថកិច្ច ឬលិខិតផ្ទាល់ខ្លួនថា ជាជនជាតិខ្មែរដោយមានការបញ្ជាក់របស់កម្មករដែលធ្វើការជាមួយគ្នាចំនួន ០២ នាក់ ដែលមានអត្តសញ្ញាណជាខ្មែរ ចំនួន ០១ច្បាប់

- លិខិតបញ្ជាក់មុខរបរដែលចេញឱ្យដោយម្ចាស់ ឬនាយកសហគ្រាសគ្រឹះស្ថានចំនួន ០១ច្បាប់

- អាករសៀវភៅការងារដែលកំណត់ឱ្យបង់តែម្តងគត់ ចំនួន ១.៥០០ រៀល ( មួយពាន់ប្រាំរយរៀល) ។

**ប្រការ៣.-** ពេលជាមួយគ្នានឹងការចេញសៀវភៅការងារ នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង នីមួយៗក៏មានចេញជូនសាមីជនកម្មករនិយោជិតផងដែរនូវ " ប័ណ្ណសំគាល់កម្មករនិយោជិតខ្មែរ " ។

**ប្រការ៤.-** នៅពេលដែលមានកម្មករនិយោជិតចូលធ្វើការ ឬឈប់ពីការងារសហគ្រាស គ្រឹះស្ថានណាមួយ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវយកសៀវភៅការងាររបស់កម្មករនិយោជិតនោះទៅចុះទិដ្ឋាការចូល ឬចេញ នៅនាយកដ្ឋានមុខរបរ និងហត្ថពលកម្មនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំពោះអ្នកនៅរាជធានីភ្នំពេញ ឬនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុងនីមួយៗ ចំពោះអ្នកនៅខេត្ត-ក្រុង ។

ការចុះទិដ្ឋាការនេះ ត្រូវធ្វើក្នុងរយៈពេលមិនលើសពី០៧ថ្ងៃ គិតចាប់ពីថ្ងៃដែលសាមីកម្មករនិយោជិតបានចូលធ្វើការ ឬឈប់ពីការងារ ។

នៅពេលដែលមានការផ្លាស់ប្តូរមុខងារ និងប្រាក់ឈ្នួលរបស់កម្មករនិយោជិតម្តងៗ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ក៏ត្រូវយកសៀវភៅការងារទៅចុះទិដ្ឋាការឱ្យបានត្រឹមត្រូវដូចពេលចូលធ្វើការងារ ឬឈប់ពីការងារផងដែរ ។

នៅពេលដែលកម្មករនិយោជិតឈប់ពីការងារ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ត្រូវប្រគល់សៀវភៅការងារជូនសាមីជនកម្មករនិយោជិតវិញ ។

**ប្រការ៥.-** ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន មិនត្រូវបានអនុញ្ញាតឱ្យយកសៀវភៅការងារកម្មករនិយោជិតទៅប្រើប្រាស់ខុសគោលដៅឡើយ ហើយក៏មិនអាចចារមូលវិចារអ្វីនៅលើសៀវភៅការងារនោះផងដែរ ។

**ប្រការ៦.-** អ្នកប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ នឹងត្រូវពិន័យ ឬទទួលទោស ដូចមានចែងនៅក្នុងជំពូក ១៦ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៧.-** ប្រកាសលេខ ១៤៧ សកបយ. ចុះថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីសៀវភៅការងារកម្មករនិយោជិតខ្មែរ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវបានជំនួសដោយប្រកាសលេខ ៤១៤ ក.ក.ប.វ ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៥ ស្តីពីសៀវភៅការងារកម្មករនិយោជិតខ្មែរ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

**ប្រការ៨.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ហត្ថលេខា និង ត្រា**

**ញ៉ែប ម៉ុនជីន**

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខៈ ៥១៣ ក.ក.ប.វ.

រាជធានីភ្នំពេញ ,ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៥

# ប្រកាស
## ស្តីពី
## ការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល

**រដ្ឋមន្ត្រីក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
-បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
-បានឃើញប្រកាសលេខ ៤៩៣ កកបវ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបង្កើតគណៈកម្មការប្រឹក្សាគម្រោងដោះស្រាយវិវាទការងារនៅកម្ពុជា
-បានឃើញប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល
-បានឃើញប្រកាសលេខ ១០៣ សកបយ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៤ ស្តីពីការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល
-បានឃើញប្រកាសលេខ ២៦៥ សកបយ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល
-បានឃើញលិខិត ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៥ របស់ប្រធានទីប្រឹក្សាបច្ចេកទេសនៃគម្រោងដោះស្រាយវិវាទការងារនៅកម្ពុជា ស្តីពីសំណើសុំតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល

## ស ម្រេ ច

**ប្រការ១.-** តែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលមានសមាសភាពដូចខាងក្រោម :-

**I-សមាជិកដែលស្នើឡើងដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

៨- លោក អាំង អេងថុង

៩- លោក គីម យាត ដារ៉ារិទ្ធ

១០- លោក គង់ ផល្លះ

១១- លោក កុយ នាម

១២- លោក ម៉ែន និម្មិត

១៣- លោក ញាន សុមុន្និទ្ធ

១៤- លោក ប៉ែន ប៊ុនឈា

១៥- លោក រុន សារ៉ាយ

១៦- លោក សុខ ម៉ាធឿង

១៧- លោក តាំង ទ្រី ។

**II-សមាជិកដែលស្នើឡើងដោយសមាគមនិយោជក:**

៨- លោកស្រី ឈីវ ភិរម្យ

៩- លោក ហែម ហួណរិទ្ធ

១០- លោក អ៊ុង សុទ្ធី

១១- លោក កៅ ថាច

១២- លោក គល់ វឌ្ឍនា

១៣- លោក លី តៃសេង

១៤- លោក ម៉ារ សំបូរណា

១៥- លោក អ៊ុក វី p

១៦- លោកស្រី សេង វ៉ូចហ៊ុន

១៧- កញ្ញា យូ សូនទី ។

**III-សមាជិកដែលស្នើឡើងដោយសហជីព កម្មករនិយោជិត(សហព័ន្ធសហជីព):**

៨- កញ្ញា អាន វីរៈ

៩- លោក អន ណន

១០- លោក ហួន ជុនឌី

១១- លោក លីវ សុវណ្ណា

១២- លោក សុង វណ្ណស៊ីន

១៣- លោកស្រី ស៊ីន គីមស៊ាន

១៤- លោក សួង សុផល

១៥- លោក ទូន ស៊ីផាន់

១៦- លោក វង្ស វណ្ណា

១៧- លោក វ៉ែន ពៅ ។

**ប្រការ២.-** យោងតាមមាត្រា១២ នៃច្បាប់ស្តីពីការងារក្រុមប្រឹក្សាអាជ្ញាកណ្តាល មានភារកិច្ចដូចតទៅ:-

ក្រុមប្រឹក្សាអាជ្ញាកណ្តាលគ្មានភារកិច្ចពិនិត្យបញ្ហាដទៃ ក្រៅពីបញ្ហាដែលមានបញ្ជាក់ក្នុងកំណត់ហេតុមិនព្រមសះជា ឬបញ្ហាដែលកើតក្រោយការធ្វើកំណត់ហេតុជាផលវិបាកផ្ទាល់នៃការវិវាទនេះប៉ុណ្ណោះ ។

ក្រុមប្រឹក្សានេះដោះស្រាយជាផ្លូវច្បាប់ចំពោះការវិវាទ ដែលទាក់ទងនឹងការបកស្រាយ និងការអនុវត្តបញ្ញត្តិច្បាប់ ឬ អនុសញ្ញារួមណាមួយ ។ ក្រុមប្រឹក្សានេះដោះស្រាយដោយសមធម៌ចំពោះការវិវាទឯទៀតទាំងអស់ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអំណាចធំទូលាយ ដើម្បីស៊ើបអំពីស្ថានភាពសេដ្ឋកិច្ចនៃសហគ្រាស និងស្ថានភាពខាងសង្គមកិច្ចនៃកម្មករនិយោជិតដែលជាសាមីខ្លួនក្នុងការវិវាទ ។

ក្រុមប្រឹក្សានេះមានអំណាចអង្កេតគ្រប់បែបយ៉ាងនៅទីកន្លែងសហគ្រាស ឬ អង្គការវិជ្ជាជីវៈផ្សេងៗ ព្រមទាំងមានអំណាចចាត់ឱ្យភាគីជូនឯកសារ ឬ ព័ត៌មានខាងសេដ្ឋកិច្ច គណនេយ្យ ស្ថិតិ ហិរញ្ញវត្ថុ ឬ រដ្ឋបាល ដែលមានប្រយោជន៍ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ។ ក្រុមប្រឹក្សានេះអាចសុំអ្នកជំនាញការជួយបានទៀតផង ។

សមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវលាក់អាថ៌កំបាំងវិជ្ជាជីវៈចំពោះព័ត៌មាន និងឯកសារទាំងឡាយដែលគេបានជូនមកឱ្យខ្លួនពិនិត្យ និងចំពោះហេតុការណ៍ទាំងអស់ ដែលខ្លួនបានដឹងក្នុងការបំពេញបេសកកម្មរបស់ខ្លួន ។

ការប្រជុំនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវប្រព្រឹត្តទៅដោយបិទទ្វារ ។

**ប្រការ៣.-** កិច្ចដំណើរការ អំណាចយុត្តាធិការ ការចេញសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ ព្រមទាំងវិធាននៃនីតិវិធីដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ នេះផង ។

**ប្រការ៤.-** សមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអាណត្តិមួយឆ្នាំ ដោយគិតចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ ២០០៥ ។

**ប្រការ៥.**~ ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**
**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**ហត្ថលេខា និងត្រា**

**ញ៉េប ម៉ុនជីន**

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខៈ ១៨៨៦ ក.ក.ប.វ.

រាជធានីភ្នំពេញ . ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៥

# ប្រកាស
# ស្តីពី
# ការឈប់បុណ្យដែលត្រូវមានប្រាក់ឈ្នួល ប្រចាំឆ្នាំ២០០៦

**រដ្ឋមន្ត្រីក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់រដ្ឋធម្មនុញ្ញ សំដៅធានាដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
-បានឃើញអនុក្រឹត្យ លេខ ១២១ អនក្រ.បក. ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៥ ស្តីពីប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ២០០៦

## <u>ស ម្រេ ច</u>

**ប្រការ១.-** ថ្ងៃបុណ្យដែលត្រូវឈប់ ហើយមានប្រាក់ឈ្នួលនៅឆ្នាំ២០០៦ ដោយត្រូវអនុញ្ញាតឱ្យកម្មករនិយោជិតនៃសហគ្រាស គ្រឹះស្ថានទាំងអស់ ដែលមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារ បានឈប់សម្រាកការងារ ដោយមានប្រាក់ឈ្នួលតាមការកំណត់ដូចតទៅៈ

-បុណ្យទិវាចូលឆ្នាំសកលចំនួនមួយថ្ងៃ គឺថ្ងៃទី ០២ ខែ មករា ជំនួសថ្ងៃទី ០១ ខែ មករា ដែលចំថ្ងៃអាទិត្យ

-បុណ្យទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ចំនួនមួយថ្ងៃ គឺថ្ងៃទី ០៧ ខែ មករា

-បុណ្យមាឃបូជាចំនួនមួយថ្ងៃ គឺថ្ងៃទី ១៣ ខែ កុម្ភៈ

-បុណ្យទិវានារីអន្តរជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី ០៨ ខែ មីនា

-បុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិចំនួនបីថ្ងៃ គឺថ្ងៃទី ១៤ ១៥ និងថ្ងៃទី ១៧ ខែ មេសា ជំនួសថ្ងៃទី ១៦ ខែ មេសា ដែលចំថ្ងៃអាទិត្យ

-បុណ្យទិវាពលកម្មអន្តរជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី០១ ខែ ឧសភា

-បុណ្យវិសាខបូជាចំនួនមួយថ្ងៃ គឺ ថ្ងៃទី ១២ ខែ ឧសភា

-ព្រះរាជពិធីបុណ្យចំរើនព្រះជន្ម ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចំនួនបីថ្ងៃ គឺថ្ងៃទី១៣ ១៥ និងថ្ងៃទី ១៦ ខែ ឧសភា ជំនួសថ្ងៃទី ១៤ ខែ ឧសភា ដែលចំថ្ងៃអាទិត្យ

-ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័លចំនួនមួយថ្ងៃ គឺថ្ងៃទី ១៧ ខែ ឧសភា ជំនួសថ្ងៃទី ១៦ ខែ ឧសភា

-ព្រះរាជពិធីបុណ្យចំរើនព្រះជន្មសម្តេចព្រះមហាក្សត្រីព្រះវររាជមាតា នរោត្តមមុនីនាថ សីហនុចំនួនមួយថ្ងៃ គឺថ្ងៃទី ១៩ ខែ មិថុនា ជំនួសថ្ងៃទី ១៨ ដែលចំថ្ងៃអាទិត្យ

-បុណ្យភ្ជុំបិណ្ឌចំនួនបីថ្ងៃ គឺថ្ងៃទី ២១ ២២ និងថ្ងៃទី ២៣ ខែ កញ្ញា

-បុណ្យទិវាប្រកាសរដ្ឋធម្មនុញ្ញចំនួនមួយថ្ងៃគឺថ្ងៃទី ២៥ ខែ កញ្ញា ជំនួសថ្ងៃទី ២៤ ខែ កញ្ញា ដែលចំថ្ងៃអាទិត្យ

-ព្រះរាជពិធីគ្រងរាជសម្បត្តិរបស់ព្រះករុណា ព្រះបាទសម្តេចបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចំនួនមួយថ្ងៃ គឺថ្ងៃទី ៣០ ខែ តុលា ជំនួសថ្ងៃទី ២៩ ខែ តុលា ដែលចំថ្ងៃអាទិត្យ

-ព្រះរាជពិធីបុណ្យចំរើនព្រះជន្ម ព្រះវររាជបិតា ព្រះបាទសម្តេច ព្រះនរោត្តមសីហនុ ចំនួនមួយថ្ងៃ គឺថ្ងៃទី ៣១ ខែ តុលា

-ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក ចំនួនបីថ្ងៃ គឺថ្ងៃទី ០៤ ០៦ និងថ្ងៃទី ០៧ ខែ វិច្ឆិកា ជំនួសថ្ងៃទី ០៥ ខែ វិច្ឆិកា ដែលចំថ្ងៃអាទិត្យ

-បុណ្យឯករាជ្យជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី ០៩ ខែ វិច្ឆិកា

-បុណ្យទិវាសិទ្ធិមនុស្សអន្តរជាតិចំនួនមួយថ្ងៃ គឺថ្ងៃទី ១១ ខែ ធ្នូ ជំនួសថ្ងៃទី ១០ ខែ ធ្នូ ដែលចំថ្ងៃអាទិត្យ ។

**ប្រការ២.-** ក្រៅពីថ្ងៃបុណ្យដូចមានចែងក្នុងប្រការ ១ ខាងលើ តាមគោលការណ៍ដែលមានចែងក្នុងមាត្រា ១៤៧ នៃច្បាប់ស្តីពីការងារ ត្រូវឱ្យឈប់នៅថ្ងៃអាទិត្យសំរាប់កម្មករនិយោជិតទាំងអស់ ។

**ប្រការ៣.-** ប្រកាសរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខ ៣៣៣ ក.ក.ប.វ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៥ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤.~** ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ហត្ថលេខា និងត្រា**

**ញ៉ៀប ប៊ុនជិន**

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ: ០២១ ក.ក.ប.វ/ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៦

# ប្រកាស
# ស្តីពី
# ការចុះបញ្ជិកានៃអង្គការវិជ្ជាជីវៈ

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

p

## សម្រេច

**ប្រការ១.-** ដើម្បីឱ្យអង្គការវិជ្ជាជីវៈទទួលបាននូវសិទ្ធិ និងផលប្រយោជន៍ទាំងឡាយ ដែលច្បាប់ស្តីពីការងារទទួលស្គាល់ស្ថាបនិកនៃអង្គការវិជ្ជាជីវៈទាំងនោះ ត្រូវយកលក្ខន្តិកៈ និងបញ្ជីរាយនាមនៃអ្នកទទួលខុសត្រូវក្នុងការដឹកនាំ និងកិច្ចការរដ្ឋបាលទៅតំកល់ទុកទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីសុំចុះបញ្ជិកា ។

**ប្រការ២.-** សំណុំលិខិតស្នើសុំចុះបញ្ជិកាមានដូចតទៅ :-

១-ពាក្យស្នើសុំចុះបញ្ជិកាដោយមានចុះហត្ថលេខា និងនាមរបស់ស្ថាបនិកនៃអង្គការវិជ្ជាជីវៈ
........................................................................................ ០១ ច្បាប់ ។

២-លក្ខន្តិកៈ " ច្បាប់ដើម " របស់អង្គការវិជ្ជាជីវៈ.................................០២ ច្បាប់ ។

៣-បញ្ជីរាយនាមអ្នកទទួលខុសត្រូវការងារគ្រប់គ្រង ដឹកនាំ និងការងាររដ្ឋបាល ដោយ

បញ្ជាក់អំពីភេទ សញ្ជាតិ ឆ្នាំកំណើត ករិតវប្បធម៌ជាតិ មុខងារ អតីតភាពក្នុងវិជ្ជាជីវៈ ឬមុខរបរ និងអាសយដ្ឋានច្បាស់លាស់ ។ ចំពោះអ្នកទទួលខុសត្រូវក្នុងការងារគ្រប់គ្រង ដឹកនាំ និងការងាររដ្ឋបាលដែលមានសញ្ជាតិខ្មែរត្រូវភ្ជាប់ទៅជាមួយនូវ " លិខិតប្រកាសផ្ទាល់ខ្លួន " ដែលមានចុះកាលបរិច្ឆេទច្បាស់លាស់ និងចុះហត្ថលេខា ឬផ្តិតមេដៃស្តាំទទួលខុសត្រូវផង ដោយប្រកាសបញ្ជាក់ដោយខ្លួនឯងថា មិនធ្លាប់ទទួលការផ្តន្ទាទោសពីបទព្រហ្មទណ្ឌណាមួយឡើយ ។ សេចក្តីប្រកាសផ្ទាល់ខ្លួននេះត្រូវមានសុពលភាពមិនលើសពី បី ខែគិតរហូតដល់ថ្ងៃទទួលសំណុំលិខិត ។ ក្រសួងការងារ និងបណ្តុះ-បណ្តាលវិជ្ជាជីវៈ នឹងធ្វើលិខិតជាផ្លូវការទៅក្រសួងមានសមត្ថកិច្ច ដើម្បីបញ្ជាក់ថា សាមីជនទាំងអស់ខាងលើពិតជាមិនធ្លាប់ទទួលការផ្តន្ទាទោសពីបទព្រហ្មទណ្ឌណាមួយទេ ។ ករណីក្រសួងមានសមត្ថ-កិច្ចចេញសេចក្តីបញ្ជាក់ជាផ្លូវការថា សាមីជនណាធ្លាប់ទទួលការផ្តន្ទាទោសពីបទព្រហ្មទណ្ឌណាមួយនោះ អង្គការវិជ្ជាជីវៈនោះ ត្រូវតែធ្វើការផ្លាស់ប្តូរសមាសភាពថ្មីមកជំនួសជននោះជាដាច់ខាត ដោយអនុវត្តតាមបែបបទដូចមានចែងខាងលើនេះដែរ ។

ចំពោះអ្នកទទួលខុសត្រូវក្នុងការងារគ្រប់គ្រង ដឹកនាំ និងការងាររដ្ឋបាលដែលមានសញ្ជាតិបរទេសត្រូវភ្ជាប់ទៅជាមួយនូវលិខិតជាច្បាប់ដើម ឬសេចក្តីថតចម្លងត្រឹមត្រូវតាមផ្លូវច្បាប់នូវលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច អំពីសិទ្ធិស្នាក់នៅជាអចិន្ត្រៃយ៍ត្រឹមត្រូវតាមច្បាប់អន្តោប្រវេសន៍ នៃព្រះរាជាណាចក្រកម្ពុជា ។

៤-កំណត់ហេតុនៃការបង្កើតអង្គការវិជ្ជាជីវៈ " ច្បាប់ដើម " ...................... ០១ ច្បាប់ ។

សំណុំលិខិតសុំចុះបញ្ជិកាខាងលើ ត្រូវផ្ញើទៅនាយកដ្ឋានវិវាទការងារ នៃក្រសួងការងារ និង បណ្តុះ-បណ្តាលវិជ្ជាជីវៈ ដែលមានអាសយដ្ឋានលេខ ២៨ វិថីសម្តេចព្រះធម្មលិខិតអ៊ុក " ផ្លូវ១៨៤ " សង្កាត់ជ័យជំនះ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ។

**ប្រការ៣.-** គ្រប់អង្គការវិជ្ជាជីវៈត្រូវយកលក្ខន្តិកៈ និងបញ្ជីរាយនាមអ្នកទទួលខុសត្រូវក្នុងការងារគ្រប់គ្រង ដឹកនាំ និងការងាររដ្ឋបាលចម្លងជូនទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃខេត្ត-ក្រុងមូលដ្ឋានខ្លួន ព្រមទាំងចម្លងជូនទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃផង។

**ប្រការ៤.-** រាល់ការផ្លាស់ប្តូរលក្ខន្តិកៈ ឬអ្នកគ្រប់គ្រងដឹកនាំអង្គការវិជ្ជាជីវៈ ក៏ដូចជាការរំលាយអង្គការវិជ្ជាជីវៈ ត្រូវតែរាយការណ៍ទៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងស្ថាប័នដទៃទៀត ដូចមានចែងក្នុងប្រការ ៣ ក្នុងរយៈពេលយ៉ាងយូរ ៣០ ថ្ងៃ បន្ទាប់ពីមានការផ្លាស់ប្តូរទាំងនោះ ឬក្រោយការរំលាយអង្គការវិជ្ជាជីវៈ ។

**ប្រការ៥.-** ដើម្បីឱ្យមានការងាយស្រួលក្នុងការពិនិត្យ មុនចុះបញ្ជិកាលក្ខន្តិកៈនៃអង្គការវិជ្ជាជីវៈ សូមបញ្ជាក់ឱ្យបានច្បាស់លាស់ទៅតាមលទ្ធភាពដែលអាចធ្វើទៅបាននូវចំណុចជាអាទិ៍ ដូចតទៅ :-

១- ឈ្មោះនៃអង្គការវិជ្ជាជីវៈ

២- ទីស្នាក់ការនៃអង្គការវិជ្ជាជីវៈ

៣- គោលបំណងរបស់អង្គការវិជ្ជាជីវៈ

៤- លក្ខខណ្ឌចូលជាសមាជិក និងបណ្តេញចេញពីសមាជិកអង្គការវិជ្ជាជីវៈ

៥- បែបបទបោះឆ្នោតជ្រើសរើស ឬបណ្តេញចេញអ្នកទទួលខុសត្រូវ ក្នុងការងារគ្រប់គ្រង ដឹកនាំ និងការងាររដ្ឋបាល និងគណៈកម្មការ ។ បែបបទបោះឆ្នោតកំណត់អាណត្តិ និងបែបបទបន្តអាណត្តិថ្មី នៃអង្គការវិជ្ជាជីវៈ

៦- បែបបទនៃការបោះឆ្នោតជាសម្ងាត់សំរាប់ការសំរេចធ្វើកូដកម្ម ឬឡុកអៅ

៧- សាមយិកភាព នៃមហាសន្និបាត និងនីតិវិធីនៃការពិភាក្សា

៨- អត្រានៃភាគទានគ្រាដំបូង របៀបបង់ភាគទាននៅពេលបន្ទាប់មកទៀត

៩- នីតិវិធីនៃការគ្រប់គ្រងគណនី

១០- នីតិវិធីគ្រោងទុកសំរាប់ការកែប្រែលក្ខន្តិកៈ

១១- នីតិវិធីនៃការរំលាយអង្គការវិជ្ជាជីវៈនិងការបែងចែកទ្រព្យសម្បត្តិរបស់អង្គការវិជ្ជាជីវៈ ។

ចំណុចទាំង១១ខាងលើនេះ គ្រាន់តែជាចំណុចជួយណែនាំដល់អ្នកតាក់តែងលក្ខន្តិកៈនៃអង្គការវិជ្ជាជីវៈតែប៉ុណ្ណោះ ។ អង្គការវិជ្ជាជីវៈ មានសិទ្ធិតាក់តែងលក្ខន្តិកៈរបស់ខ្លួនបានដោយសេរី កុំឱ្យតែលក្ខន្តិកៈនោះផ្ទុយជាមួយច្បាប់ជាធរមាន ឬផ្ទុយជាមួយសណ្តាប់ធ្នាប់សាធារណៈ ។

**ប្រការ៦.-** សហភាពអង្គការវិជ្ជាជីវៈទាំងឡាយ ក៏ត្រូវបំពេញសំណុំលិខិតស្នើសុំចុះបញ្ជិកា ដូចមានចែងក្នុងប្រការ២ នៃប្រកាសនេះផងដែរ ក្នុងលក្ខខណ្ឌដែលសហភាពទាំងនោះ ត្រូវផ្តល់ឱ្យបានដឹងនូវឈ្មោះ និងទីស្នាក់ការរបស់សហជីពដែលជាសមាជិករបស់ខ្លួន ។

សហភាពអង្គការវិជ្ជាជីវៈ ក៏ត្រូវអនុវត្តបទប្បញ្ញត្តិនៃប្រការ៣ នៃប្រកាសនេះផងដែរ ។

**ប្រការ៧.-** ប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា លេខ ២២១ សកបយ. ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០០ និងលេខ ២៧៧ សកបយ. ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ២០០០ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៨.-** ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ហត្ថលេខា និង ត្រា**

**ញៀម ម៉ុនីន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ: ០៩៩ ក.ក.ប.វ. រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៦

# ប្រកាស
## ស្តីពី
## ការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល

**រដ្ឋមន្ត្រីក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញប្រកាសលេខ ៤៥៣ កកបវ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបង្កើតគណៈកម្មការប្រឹក្សាគម្រោងដោះស្រាយវិវាទការងារនៅកម្ពុជា

-បានឃើញប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល

-បានឃើញប្រកាសលេខ ១០៣ សកបយ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០០៤ ស្តីពីការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល

-បានឃើញប្រកាសលេខ ២៦៥ សកបយ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល

-បានឃើញប្រកាសលេខ ៥១៣ ក.ក.ប.វ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៥ ស្តីពីការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល

-បានឃើញលិខិត ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៦ របស់ប្រធានទីប្រឹក្សាបច្ចេកទេសនៃគម្រោងដោះស្រាយវិវាទការងារនៅកម្ពុជា ស្តីពីសំណើសុំតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាល

## <u>ស ម្រេ ច</u>

**ប្រការ១.-** តែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលមានសមាសភាពដូចខាងក្រោម :

**I-សមាជិកដែលស្នើឡើងដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១៨- លោក អាំង អេងថុង

១៩- លោក គីម យាត ដារ៉ារិទ្ធ

២០- លោក គង់ ផល្លៈ

២១- លោក កុយ នាម

២២- លោក ម៉ែន និម្មិត

២៣- លោក ញាន សុមុន្និន

២៤- លោក ប៉ែន ប៊ុនឈា

២៥- លោក រុន សារ៉ាយ

២៦- លោក សុខ ម៉ាធឿង

២៧- លោក តាំង ទ្រី ។

**II-សមាជិកដែលស្នើឡើងដោយសមាគមនិយោជកៈ**

១៨- លោកស្រី ឈីវ ភិរម្យ

១៩- លោក ហែម ហួណារិទ្ធ

២០- លោក អ៊ុង សុទ្ធី

២១- លោក កៅ ថាច

២២- លោក គល់ វឌ្ឍនា

២៣- លោក លី តៃសេង p

២៤- លោក ម៉ារ សំបូរណា

២៥- លោក អ៊ុក រី

២៦- លោកស្រី សេង វួចហ៊ុន

២៧- កញ្ញា យូ សួនទី ។

**III-សមាជិកដែលស្នើឡើងដោយសហជីព កម្មករនិយោជិត(សហព័ន្ធសហជីព):**

១៨- កញ្ញា អាន វីរៈ

១៩- លោក អន ណន

២០- លោក ហួន ជុនឌី

២១- លោក លីវ សុវណ្ណ

២២- លោក សុង វណ្ណស៊ីន

២៣- លោកស្រី ស៊ីន គីមស៊ាន

២៤- លោក សួង សុផល

២៥- លោក ទូន ស៊ីផាន់

២៦- លោក វង្ស វណ្ណា

២៧- លោក វ៉ែន ពៅ ។

**ប្រការ២.-** យោងតាមមាត្រា ៣១២ នៃច្បាប់ស្តីពីការងារក្រុមប្រឹក្សាអាជ្ញាកណ្តាល មានភារកិច្ចដូចតទៅ:-

ក្រុមប្រឹក្សាអាជ្ញាកណ្តាលគ្មានភារកិច្ចពិនិត្យបញ្ហាដទៃ ក្រៅពីបញ្ហាដែលមានបញ្ជាក់ក្នុងកំណត់ហេតុមិនព្រមសះជា ឬបញ្ហាដែលកើតក្រោយការធ្វើកំណត់ហេតុជាផលវិបាកផ្ទាល់នៃការវិវាទនេះប៉ុណ្ណោះ ។

ក្រុមប្រឹក្សានេះដោះស្រាយជាផ្លូវច្បាប់ចំពោះការវិវាទ ដែលទាក់ទងនឹងការបកស្រាយ និងការអនុវត្តបញ្ញត្តិច្បាប់ ឬ អនុសញ្ញារួមណាមួយ ។ ក្រុមប្រឹក្សានេះដោះស្រាយដោយសមធម៌ចំពោះការវិវាទឯទៀតទាំងអស់ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអំណាចធំទូលាយ ដើម្បីស៊ើបអំពីស្ថានភាពសេដ្ឋកិច្ចនៃសហគ្រាស និងស្ថានភាពខាងសង្គមកិច្ចនៃកម្មករនិយោជិតដែលជាសាមីខ្លួនក្នុងការវិវាទ ។

ក្រុមប្រឹក្សានេះមានអំណាចអង្កេតគ្រប់បែបយ៉ាងនៅទីកន្លែងសហគ្រាស ឬ អង្គការវិជ្ជាជីវៈផ្សេងៗ ព្រមទាំងមានអំណាចចាត់ឱ្យភាគីជូនឯកសារ ឬ ព័ត៌មានខាងសេដ្ឋកិច្ច គណនេយ្យ ស្ថិតិ ហិរញ្ញវត្ថុ ឬ រដ្ឋបាល ដែលមានប្រយោជន៍ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ។ ក្រុមប្រឹក្សានេះអាចសុំអ្នកជំនាញការជួយបានទៀតផង ។

សមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវលាក់អាថ៌កំបាំងវិជ្ជាជីវៈចំពោះព័ត៌មាន និងឯកសារទាំងឡាយដែលគេបានជូនមកឱ្យខ្លួនពិនិត្យ និងចំពោះហេតុការណ៍ទាំងអស់ ដែលខ្លួនបានដឹងក្នុងការបំពេញបេសកកម្មរបស់ខ្លួន ។

ការប្រជុំនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវប្រព្រឹត្តទៅដោយបិទទ្វារ ។

**ប្រការ៣.-** កិច្ចដំណើរការ អំណាចយុត្តាធិការ ការចេញសេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ ព្រមទាំងវិធាននៃនីតិវិធីដែលជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ នេះផង ។

**ប្រការ៤.-** សមាជិកនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលមានអាណត្តិមួយឆ្នាំ ដោយគិតចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ ២០០៦ ។

**ប្រការ៥.-** ប្រកាសនេះ មានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**ហត្ថលេខា និងត្រា**

**ញៀប ប៊ុនជិន**

p

# សារាចរ

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន

លេខ : ០១ សគអ

# សារាចរ

## ជំរាបមក

## លោកនាយកក្រុមហ៊ុនកាត់ដេរ គ្រប់ក្រុមហ៊ុនទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា

**កម្មវត្ថុ** : ការអនុវត្តច្បាប់ការងារស្តីពីសន្តិសុខ និងអនាម័យការងារ ចំពោះកម្មករនិយោជិត ការគោរពសិទ្ធិ កិត្តិយសរបស់កម្មករនិយោជិត ។

ខ្ញុំសូមជំរាបដល់អស់លោកនាយកក្រុមហ៊ុនកាត់ដេរទាំងអស់បានជ្រាបថា កន្លងទៅក្រុមអធិការកិច្ចការងាររបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន បានចុះទៅធ្វើអធិការកិច្ចការងារនៅតាមរោងចក្រទាំងឡាយរបស់ក្រុមហ៊ុន ដើម្បីណែនាំឱ្យនិយោជកអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវច្បាប់ការងារ សំដៅជួយឱ្យក្រុមហ៊ុនប្រព្រឹត្តទៅបានស្របនឹងច្បាប់ផង និងរក្សាឱ្យបានល្អនូវល័ក្ខខ័ណ្ឌការងារដែលនិយោជក និងកម្មករនិយោជិតត្រូវតែគោរពគ្នាទៅវិញទៅមកផង ដូចជា ការកំណត់ប្រាក់ឈ្នួល ការបើកប្រាក់ឈ្នួល ការកាត់ប្រាក់ឈ្នួល ការឈប់សំរាកប្រចាំសប្តាហ៍ ការឈប់សំរាកថ្ងៃបុណ្យដោយមានប្រាក់ឈ្នួល ការឈប់សំរាកដោយជម្ងឺ ការឈប់សំរាកពេលសំរាលកូន ការឈប់ដោយគ្រោះថ្នាក់ការងារ ការឈប់សំរាកប្រចាំឆ្នាំ ការងារលើសម៉ោង ការងារពេលយប់ ការងារសំរាប់កុមារ ការងារសំរាប់ស្ត្រី ការបញ្ឈប់ពីការងារ ការពិនិត្យព្យាបាលពេលមានជម្ងឺ ឬពេលមានគ្រោះថ្នាក់ការងារ ព្រមទាំងសន្តិសុខ និងអនាម័យពលកម្មរបស់កម្មករនិយោជិតផង ។

ការណែនាំនេះ ក្រុមអធិការកិច្ចការងារបានធ្វើចំពោះក្រុមហ៊ុនទាំងអស់ជាង ៤០ ក្រុមហ៊ុនហើយ គិតទាំងក្រុមហ៊ុនដែលនៅក្នុងសមាគមនិយោជកផ្នែកកាត់ដេរ និងក្រុមហ៊ុនដែលមិននៅក្នុងសមាគមនេះផង ។ ក្រុមហ៊ុននីមួយៗ ក្រុមអធិការកិច្ចបានណែនាំយ៉ាងហោចណាស់ក៏ ៣ ដងដែរ ។

ការខិតខំរបស់មន្ត្រីក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនពុំទាន់ទទួលបានលទ្ធផលជាទីគាប់ចិត្តនៅឡើយទេ ។ ក្រុមហ៊ុនខ្លះអនុវត្តបានមួយចំនួន ក្រុមហ៊ុនខ្លះទៀតមិនទាន់អនុវត្តតាមនៅឡើយ ។

ដោយសារក្រុមហ៊ុនមិនព្រមអនុវត្តតាមច្បាប់ការងារនេះហើយ បានជាបញ្ហាមួយចំនួនបានកើតឡើងដោយមានការទាមទារពីកម្មករនិយោជិត សុំឱ្យនិយោជកអនុវត្តតាមច្បាប់ការងារ ។ ក្រុមហ៊ុនណាដែលមិន

បានអនុវត្តតាមការណែនាំរបស់មន្ត្រីអធិការកិច្ចការងារចាប់ពី ៤ ដង ឡើងទៅ ក្រសួងបានធ្វើការផាកពិន័យ ឬបញ្ជូនទៅតុលាការតាមច្បាប់ការងាររួចអស់ហើយ ។

ការធ្វើការផាកពិន័យរួចហើយ មិនមែនបានន័យថា មិនចាំបាច់អនុវត្តច្បាប់តទៅទៀតទេ ផ្ទុយទៅវិញ ក្រុមហ៊ុនត្រូវតែប្រញាប់ប្រញាល់អនុវត្តជាបន្ទាន់ នូវចំណុចណាដែលមិនទាន់បានអនុវត្តតទៅទៀត ។

ការយឺតយូរ ឬ ធ្វើព្រងើយកន្តើយមិនគោរពច្បាប់តទៅទៀត ក្រុមហ៊ុននឹងទទួលនូវកំហុសទ្វេរឡើងម្តងទៀតជាពុំខាន ។

ក្រៅពីល័ក្ខខ័ណ្ឌការងារខាងលើនេះ ក្រសួងក៏បានទទួលនូវពត៌មានមួយចំនួនទៀត ដែលក្រុមហ៊ុនកាត់ដេរអនុវត្តពុំទាន់បានល្អ ។ ការអនុវត្តទាំងឡាយនោះមានដូចតទៅ :-

ការឆែកឆេរកម្មករ-កម្មការិនី ការប្រើពាក្យសម្តីមិនសមរម្យ ដូចជាការជេរប្រមាថ វាយដំកម្មករកម្មការិនីជាដើម ។

**ក- ការឆែកឆេរកម្មករ កម្មការិនី :**

ការឆែកឆេរទាំងមុនពេលចូលធ្វើការ ទាំងក្រោយពេលចេញពីធ្វើការ ជាសិទ្ធិរបស់និយោជកក្នុងការថែរក្សាសុវត្ថិភាពសន្តិសុខរោងចក្រ ឬការពារទ្រព្យសម្បត្តិរបស់និយោជក ។ ប៉ុន្តែក្រសួងសូមឱ្យនាយកក្រុមហ៊ុនទាំងអស់ អនុវត្តនូវល័ក្ខខ័ណ្ឌដូចតទៅ :

ក-១ ការឆែកឆេរមុនពេលចូលធ្វើការ : បើការឆែកឆេរនេះនាំឱ្យខាតពេលម៉ោងធ្វើការ និយោជកមិនត្រូវកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតឡើយ ព្រោះកម្មករនិយោជិតមកទាន់ម៉ោង តែការយឺតយ៉ាវបណ្តាលមកពីវិធានការឆែកឆេរ ដែលនិយោជកបានរៀបចំឱ្យមានការយឺតយ៉ាវ ។

ក-២ ការឆែកឆេរក្រោយពេលចេញពីធ្វើការ : ត្រូវធ្វើយ៉ាងណាមិនឱ្យកម្មករខាតពេលវេលារបស់ខ្លួនហួសពី ៣០ នាទីឡើយ គិតពីក្រោយពេលម៉ោងដែលកម្មករត្រូវចេញពីរោងចក្រ ។

ក-៣ ដើម្បីអនុវត្តការឆែកឆេរបានឆាប់ និងទាន់ពេលវេលាផលិត ព្រមទាំងចំណេញពេលកម្មករនិយោជិតក្នុងការត្រឡប់ទៅកាន់លំនៅដ្ឋានខ្លួនវិញ និយោជកត្រូវបង្កើតបុគ្គលិកឆែកឆេរឱ្យបានច្រើន និងសមស្របទៅតាមបរិមាណកម្មករនិយោជិតរបស់ខ្លួនដែលមាន ។

-ត្រូវឱ្យមានបន្ទប់បិទជិត សំរាប់ការឆែកឆេរណាដែលនាំឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់កម្មករនិយោជិត ។

-ត្រូវចាត់តាំងបុគ្គលិកនារី សំរាប់ឆែកឆេរកម្មការិនី និងនិយោជិតនារី និងបុគ្គលិកបុរសសំរាប់ឆែកឆេរកម្មករ និងនិយោជិតបុរស ។

-ត្រូវគោរពប្រពៃណី ទំនៀមទំលាប់ខ្មែរ ឱ្យបានម៉ឺងម៉ាត់ និង ត្រូវគោរពសិទ្ធិមនុស្ស កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋខ្មែរ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**ខ- ការជេរប្រមាថ - វាយដំកម្មករនិយោជិត :**

និយោជកត្រូវអប់រំបុគ្គលដែលខ្លួនចាត់តាំងឱ្យមើលការងារនៅតាមគ្រឹះស្ថាន ការដ្ឋាន ឬផ្នែកនីមួយៗ ក្នុងក្រុមហ៊ុនឱ្យមានសីលធម៌ល្អ ពោលគឺត្រូវនិយាយស្ដីជាមួយកម្មករនិយោជិតដោយពាក្យសំដីថ្លៃថ្នូរ មិនត្រូវនិយាយពាក្យសំដីណាដែលមិនសមរម្យដល់កម្មករនិយោជិត ។ ក្នុងករណីកម្មករនិយោជិត មិនស្ដាប់តាមការណែនាំរបស់ខ្លួន និយោជកអាចអនុវត្តតាមបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថាន ឬក្រុមហ៊ុន ឬតាមមាត្រាទាំងឡាយនៃច្បាប់ការងារ ។

ការជេរប្រមាថ ការវាយដំ កម្មករ កម្មការិនី និងនិយោជិត ត្រូវហាមឃាត់ជាដាច់ខាត ។

**គ- សន្តិសុខ និងអនាម័យការងារ :**

ក្រសួងបានណែនាំគ្រប់ក្រុមហ៊ុនរួចហើយអំពីសន្តិសុខ និងអនាម័យការងាររបស់កម្មករនិយោជិត គិតទាំងពន្លឺ សម្លេង ធាតុអាកាស ធូលីក្នុងកន្លែងធ្វើការ ការរៀបចំប្រអប់សង្គ្រោះ គិលានដ្ឋាន ទារកដ្ឋាន បន្ទប់បំបៅកូន ទ្វារ និងច្រកចេញពេលមានអាសន្នដូចជាអគ្គីភ័យជាដើម បង្គន់សំរាប់នារី និងបង្គន់សំរាប់បុរស ការធ្វើដំណើរបន្ថែម ។ល។

ការចាក់សោរទ្វារ ឬដាក់គន្លឹះទ្វារនៅម៉ោងធ្វើការ ត្រូវហាមឃាត់ជាដាច់ខាត ព្រោះបើសិនជាមានអគ្គីភ័យ ឬគ្រោះអាសន្នផ្សេងៗទៀតកើតឡើង កម្មករនិយោជិតនឹងទទួលរងគ្រោះថ្នាក់ដល់អាយុជីវិតដោយចេញមិនរួចពីកន្លែងធ្វើការ ។

អាស្រ័យហេតុដូចបានជំរាបជូនខាងលើនេះ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន សូមឱ្យគ្រប់នាយកក្រុមហ៊ុនកាត់ដេរទាំងអស់អនុវត្តឱ្យបានខ្ជាប់ខ្ជួន និងជាបន្ទាន់នូវចំណុចណាដែលក្រុមហ៊ុនរបស់លោកមិនទាន់បានអនុវត្តតាមប្រកាសទាំងឡាយរបស់ក្រសួង ព្រមទាំងសេចក្ដីសំរេចដែលបានព្រមព្រៀងតាមការចរចាជាសមូហភាព និងតាមការណែនាំរបស់មន្ត្រីក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ដែលបានចុះធ្វើអធិការកិច្ច ។

មន្ត្រីអធិការកិច្ចការងាររបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ត្រៀមខ្លួនជាស្រេចនឹងផ្ដល់នូវការពន្យល់ ឬណែនាំបន្ថែមចំពោះចំណុចណាដែលក្រុមហ៊ុនមិនទាន់បានយល់ច្បាស់ ដើម្បីឈានទៅអនុវត្តឱ្យបានល្អតាមច្បាប់ស្ដីពីការងារ និងសារាចរណែនាំនេះ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ មករា ឆ្នាំ១៩៩៧

**រដ្ឋលេខាធិការ**

**ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន**

**ហត្ថលេខា និង ត្រា**

**ស៊ុយ សែម**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន
លេខៈ ៤០ សគអ.

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ តុលា ឆ្នាំ ១៩៩៨

# សារាចរ

## ស្តីពី

## ការមិនផ្សព្វផ្សាយលិខិតបទដ្ឋាននានា

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន សូមជំរាបលោក លោកស្រី ជាម្ចាស់ និងជានាយកសហគ្រាស គ្រឹះស្ថានទាំងអស់ថា កន្លងទៅក្នុងការចាត់តាំង និងផ្សព្វផ្សាយអនុវត្តច្បាប់ស្តីពីការងារ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន បានចេញប្រកាស និងសេចក្តីជូនដំណឹងជាបន្តបន្ទាប់ ។ ទន្ទឹមនឹងនេះ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន បានសង្កេតឃើញថា នៅតាមសហគ្រាស គ្រឹះស្ថានមួយចំនួនធំ កម្មករនិយោជិតបានធ្វើការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក ដើម្បីជាតំណាងរបស់ខ្លួនរួចហើយដែរ ហើយនៅតាមសហគ្រាសគ្រឹះស្ថានខ្លះទៀត កម្មករនិយោជិតបានបង្កើតអង្គការសហជីពទៀតផង ។ នៅតាមសហគ្រាស គ្រឹះស្ថានជាច្រើន បទបញ្ជាផ្ទៃក្នុងត្រូវបានក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ចុះទិដ្ឋាការឱ្យអនុវត្តជាផ្លូវការ ហើយអនុសញ្ញារួមត្រូវបានចុះហត្ថលេខារវាងនិយោជក និង ប្រតិភូបុគ្គលិក ឬ អង្គការសហជីព ។

ទន្ទឹមនឹងចំណុចជាវិជ្ជមានទាំងអស់នេះ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន បានពិនិត្យឃើញថា លិខិតបទដ្ឋាន និងទង្វើទាំងអស់ខាងលើ នៅមិនទាន់បានជ្រួតជ្រាបដល់កម្មករនិយោជិតទាំងអស់ឡើយ ហើយម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានមួយចំនួន នៅមិនទាន់បានបង្កលក្ខណៈងាយស្រួលឱ្យប្រតិភូបុគ្គលិក និងសហជីពបំពេញតួនាទី និងភារកិច្ចស្របច្បាប់របស់ខ្លួនឡើយ ។ កង្វះខាតក្នុងការផ្សព្វផ្សាយជាមូលហេតុសំខាន់នៃអំពើអសកម្មខាងលើ ហើយដែលបង្កើតឡើងជាបន្តបន្ទាប់នូវវិវាទការងារ ។

ក្នុងគោលបំណងជំរុញការអនុវត្តច្បាប់ស្តីពីការងារឱ្យបានល្អ ក្រសួងសូមធ្វើការណែនាំដូចខាងក្រោមនេះ :-

១-ម្ចាស់ និងនាយកគ្រប់សហគ្រាស គ្រឹះស្ថាន ត្រូវរៀបចំឱ្យមានកន្លែងសមស្រប ដើម្បីបិទផ្សព្វផ្សាយនូវប្រកាស និងសេចក្តីជូនដំណឹងនានារបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ពិសេស

ប្រកាសស្តីពីការឈប់សំរាកថ្ងៃបុណ្យដោយមានប្រាក់ឈ្នួល សេចក្តីជូនដំណឹងលេខ ០៦ សកអ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៧ ( ចំពោះសហគ្រាសកាត់ដេរ ) ។ល។ សេចក្តីជូនដំណឹង និងសេចក្តីសំរេចផ្សេងៗរបស់សហគ្រាសគ្រឹះស្ថានដែលទាក់ទងដល់កម្មករនិយោជិត អនុសញ្ញារួមរវាងម្ចាស់ ឬនាយកសហគ្រាសគ្រឹះស្ថាន និងប្រតិភូបុគ្គលិក ឬអង្គការសហជីពជាដើម ។

២-ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថាន ត្រូវផ្តល់កន្លែងសមស្របសំរាប់ប្រតិភូបុគ្គលិក និងអង្គការសហជីព បិទផ្សាយឈ្មោះ រូបថត មុខងាររបស់ប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំសហជីព ព្រមទាំងសកម្មភាពរបស់ខ្លួន ។

កន្លែងទាំងពីរខាងលើ ត្រូវស្ថិតក្នុងទីតាំងសមស្រប និង ងាយស្រួល សំរាប់ការអានរបស់កម្មករនិយោជិតទាំងអស់ ។

ការរៀបចំឱ្យមានកន្លែងទាំងពីរខាងលើនេះ រួមទាំងការបិទផ្សាយដូចមានរៀបរាប់ក្នុងចំណុច ០១ ខាងលើ ត្រូវអនុវត្តឱ្យហើយស្រេចក្នុងរយៈពេលយ៉ាងឆាប់បំផុត ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខាលើសារាចរនេះ។

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រី នឹងអនុវត្តបានល្អតាមសារាចរនេះ ។

**រដ្ឋលេខាធិការ**

**ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន**

**ហត្ថលេខា និង ត្រា**

p

**ស៊ុយ សែម**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច ការងារ**
**បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

លេខ : ០២១ សកបយ

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៩

# សារាចរ

## ស្តីពី

## ការចាត់តាំងបុគ្គលិកទំនាក់ទំនងនៅតាមរោងចក្រ សហគ្រាស កាត់ដេរ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជំរាបលោក លោកស្រីជាម្ចាស់ និងនាយករោងចក្រ សហគ្រាសកាត់ដេរទាំងអស់ថា ក្រសួងបាននឹងកំពុងសង្កេតឃើញមានវិវាទការងារមួយចំនួនកើតឡើងដោយសារខ្វះការយោគយល់អនុគ្រោះគ្នា និងខ្វះការប្រាស្រ័យទាក់ទងឱ្យបានយល់គ្នាទៅវិញទៅមករវាងនិយោជក ឬតំណាង និងកម្មករនិយោជិត ។

ក្នុងគោលបំណងសម្រួលឱ្យមានទំនាក់ទំនងគ្នាល្អ រវាងភាគីទាំងពីរនៅក្នុងរោងចក្រ សហគ្រាសនោះ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមកំណត់ឱ្យរោងចក្រ សហគ្រាសកាត់ដេរទាំងអស់ រៀបចំឱ្យមានបុគ្គលិកមួយរូបយ៉ាងតិចសំរាប់ទទួលខុសត្រូវដោះស្រាយសំណូមពរ ឬការតវ៉ាផ្សេងៗរបស់កម្មករនិយោជិត ។ បុគ្គលិករូបនេះត្រូវទទួលខុសត្រូវធ្វើការងារនេះជាអចិន្ត្រៃយ៍ ហើយទទួលប្រាក់ឈ្នួលពីនិយោជក ។ មុននឹងចាត់តាំងបុគ្គលិករូបនេះ ម្ចាស់ ឬនាយករោងចក្រ សហគ្រាស ត្រូវតែពិគ្រោះយោបល់ឱ្យបានឯកភាពគ្នាជាមួយតំណាងកម្មករនិយោជិតជាមុនសិន ដើម្បីជ្រើសរើសរកមនុស្សដែលមានជំនាញឯករាជ្យ និងអព្យាក្រឹត្យ ។ នៅពេលដែលបុគ្គលិករូបនេះអវត្តមាន ឬ ក៏មានការផ្លាស់ប្តូរនិយោជកត្រូវតែពិគ្រោះយោបល់ និងតំណាងកម្មករនិយោជិត និងផ្សព្វផ្សាយជូនកម្មករនិយោជិតបានជ្រាបអំពីអ្នកជំនួសជននោះផង ។ នៅពេលបានទទួលពាក្យតវ៉ា ឬសំណូមពរផ្សេងៗ ពីកម្មករនិយោជិតជាឯកជនក្តី តាមរយៈប្រតិភូបុគ្គលិកក្តី តាមរយៈសហជីពក្តី បុគ្គលិកនោះត្រូវតែយកពាក្យតវ៉ា ឬសំណូមពរទាំងនោះមកពិនិត្យពិចារណា ។ បើរឿងនោះជារឿងតូចតាច ហើយបានការប្រគល់សិទ្ធិពីនិយោជកនោះ បុគ្គលិករូបនោះ ត្រូវតែដោះស្រាយបញ្ហាឱ្យបានល្អកល្អើន ទាំងការប្រើអាកប្បកិរិយាសមរម្យទន់ភ្លន់ ទាំងការពន្យល់បកស្រាយឱ្យសាមីដើមចោទបានយល់ សំដៅទទួលបាននូវភាពសុខដុមរម្យនារវាងកម្មករ និយោជិត និង

និយោជក ។ បើពាក្យតវ៉ា ឬសំណូមពរជារឿងធំ ឬក៏ខ្លួនមិនអាចដោះស្រាយបាន បុគ្គលិកនោះត្រូវរាយការណ៍ជូននិយោជកជាបន្ទាន់ ដើម្បីកំណត់ពេលវេលាមួយសមស្រប ដែលនិយោជកត្រូវជួបដោះស្រាយជាមួយកម្មករនិយោជិត ឬតំណាងដោយផ្ទាល់ ។ ក្នុងការដោះស្រាយបញ្ហានេះ សាមីជនកម្មករនិយោជិតអាចពឹងពាក់ប្រតិភូបុគ្គលិក ឬពឹងពាក់សហជីពឱ្យជួយខ្លួនបាន ។ បើការដោះស្រាយនេះនៅតែមិនបានផលទៀតនោះ ទាំងសាមីជនកម្មករនិយោជិត ទាំងនិយោជកអាចផ្តល់ពតិមានជាផ្លូវការទៅមន្ត្រីអធិការកិច្ចការងារ ដើម្បីជួយដោះស្រាយបន្ត ។ ម្ចាស់ ឬនាយករោងចក្រ សហគ្រាសត្រូវជូនដំណឹងទៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ជាផ្លូវការ អំពីការចាត់តាំងបុគ្គលិកឱ្យទទួលបន្ទុកដោះស្រាយការតវ៉ា ឬសំណូមពរនានារបស់កម្មករនិយោជិត ហើយត្រូវតែបិទផ្សាយជូនកម្មករនិយោជិតទាំងអស់បានដឹងច្បាស់ទាំងឈ្មោះ មុខងារ និងទីកន្លែងដែលកម្មករនិយោជិតអាចទៅជួបទាក់ទងនឹងបុគ្គលិកនោះបានដោយងាយស្រួល ។ នៅពេលមានការផ្លាស់ប្តូរបុគ្គលិកនេះ ម្ចាស់ ឬនាយករោងចក្រ សហគ្រាសក៏ត្រូវជូនដំណឹងទៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាវិញដែរ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រីជាម្ចាស់ និងនាយករោងចក្រ សហគ្រាសកាត់ដេរទាំងអស់ ពិតជាយកចិត្តទុកដាក់បំពេញតាមការកំណត់ខាងលើរបស់ក្រសួងបានល្អប្រសើរជាមិនខាន ។ ការខកខានដោយប្រការណាមួយ អាចនាំឱ្យមានការចាត់វិធានការយ៉ាងតឹងរឹងពីក្រសួង ដោយផ្អែកតាមច្បាប់ និងបទបញ្ជាជាធរមាន ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ

បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ : ០២៤ សគបយ

រាជធានីភ្នំពេញថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៩

# សារាចរ

## ស្តីពី

## ប្រាក់ឈ្នួលនៃការងារពេលយប់

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជំរាបលោក លោកស្រី ជាម្ចាស់ និងជានាយករោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារជ្រាប ថា ផ្អែកតាមការកំណត់នៃច្បាប់ស្តីពីការងារ កម្មករនិយោជិតដែលធ្វើការនៅពេលយប់ចន្លោះពីម៉ោង ២២ ដល់ ម៉ោង ៥ ភ្លឺ ទោះបីធ្វើការដោយផ្លាស់ប្តូរវេនគ្នាក្តី ទោះបីធ្វើការជាអចិន្ត្រៃយ៍ក្តី កម្មករនិយោជិតទាំង នោះ ត្រូវបានប្រាក់ឈ្នួលស្មើនឹងពីរដងនៃប្រាក់ឈ្នួលធ្វើការពេលថ្ងៃធម្មតា ដូចគ្នានឹងករណីធ្វើការបន្ថែមម៉ោង នៅពេលយប់ដែរ ។

<u>ឧទាហរណ៍</u>: សហគ្រាសមួយមានកម្មករ ១៦ នាក់ ។ កម្មករទាំង ១៦ នាក់នេះ ចែកជាពីរផ្នែក គឺ មួយផ្នែកមានកម្មករ ១២ នាក់ ដែលចែកជា ៣ វេនការងារ ក្នុងមួយវេនមានគ្នា ៤ នាក់ ។ កម្មករផ្នែកទី១ នេះ ផ្លាស់ប្តូរវេនគ្នាធ្វើការ ជូនថ្ងៃជូនយប់ ។ ឯកម្មករមួយផ្នែកទៀតមានគ្នា ៤ នាក់ ចែកជាពីរក្រុម មួយ ក្រុមមានគ្នា ២ នាក់ ធ្វើការជាអចិន្ត្រៃយ៍ ៨ ម៉ោងនៅពេលថ្ងៃ ហើយមួយក្រុមទៀតមានគ្នា ២ នាក់ដែរ តែ ធ្វើការជាអចិន្ត្រៃយ៍នៅពេលយប់ ។ ចំពោះកម្មករផ្នែកទី ១ និងកម្មករផ្នែកទី ២ខាងលើ កម្មករណាធ្វើការ ចំពេលយប់ដែលមានថិរវេលាចន្លោះពីម៉ោង ២២ ដល់ម៉ោង ៥ ភ្លឺ គឺកម្មករនោះត្រូវបានប្រាក់ឈ្នួលស្មើនឹងពីរ ដងនៃប្រាក់ឈ្នួលធ្វើការពេលថ្ងៃធម្មតា សំរាប់ថិរវេលានៃការងារពេលយប់នោះ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានសេចក្តីសង្ឃឹមយ៉ាងមុត មាំថា លោក លោកស្រីជាម្ចាស់ និងជានាយករោងចក្រ សហគ្រាស គ្រឹះស្ថានទាំងអស់ ពិតជាយកចិត្តទុក

ដាក់អនុវត្តបានត្រឹមត្រូវតាមច្បាប់ស្ដីពីការងារជាមិនខាន ។ ការប្រព្រឹត្តិល្មើសនឹងការកំណត់ខាងលើនឹងត្រូវទទួលទោសដូចមានចែងក្នុងច្បាប់ស្ដីពីការងារ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ

បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ : ០០៥ សគបយ

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០០

# សារាចរ

## ស្តីពី

## សិទ្ធិធ្វើកូដកម្ម

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានសង្កេតឃើញថា នារយៈពេលចុងក្រោយនេះ មានសកម្មភាពមិនប្រក្រតីមួយចំនួនកើតឡើងជាបន្តបន្ទាប់ ក្រោមការដឹកនាំរបស់អ្នកដឹកនាំសហព័ន្ធសហជីព និងសហជីពខ្លះ ។ យោងតាមរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា និងជំពូកទី ១៣ នៃច្បាប់ស្តីពីការងារ កម្មករនិយោជិតមានសិទ្ធិធ្វើកូដកម្ម ប៉ុន្តែសិទ្ធិធ្វើកូដកម្មនេះ ត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់ ។ មាត្រា ៣១៨ កថាខ័ណ្ឌទី១នៃច្បាប់ស្តីពីការងារបានចែងថា " កូដកម្ម គឺជាការឈប់ធ្វើការដោយកម្មករនិយោជិត ០១ក្រុម ដែលមានការព្រមព្រៀងគ្នា ហើយបានធ្វើឡើងនៅក្នុងសហគ្រាសមួយ ឬគ្រឹះស្ថានមួយ ក្នុងគោលបំណងដើម្បីទទួលបាននូវដំណោះស្រាយជំយុត្តិធម៌ ចំពោះការទាមទាររបស់កម្មករនិយោជិតពីនិយោជក ហើយក៏ជាល័ក្ខខ័ណ្ឌដើម្បីចូលធ្វើការវិញ " ។ កូដកម្ម គឺជាការឈប់ធ្វើការងារ ដែលកម្មករនិយោជិត ត្រូវស្ថិតនៅក្នុងបរិវេណរោងចក្រ សហគ្រាស គ្រឹះស្ថាន ដើម្បីធ្វើការតវ៉ា ឬទាមទារអ្វីមួយពីនិយោជក ពោលគឺកូដកម្មមិនមែនជាការនាំគ្នាដង្ហែ ជាក្រុម ជាពួក ជាក្បួនទៅទីកន្លែងផ្សេងៗនោះឡើយ ។

មាត្រា ៣២៣ នៃច្បាប់ស្តីពីការងារចែងថា " កូដកម្មត្រូវប្រកាសធ្វើតាមនីតិវិធីដែលមានកំណត់ក្នុងលក្ខន្តិកៈសហជីព ។ លក្ខន្តិកៈនេះត្រូវកំណត់អំពីការអនុម័តដោយការបោះឆ្នោតជាសម្ងាត់ ស្តីពីការសម្រេចឱ្យធ្វើកូដកម្ម ពោលគឺមុននឹងសំរេចធ្វើកូដកម្ម អ្នកដឹកនាំសហជីព ត្រូវធ្វើការប្រជុំ និងស្នើសុំការអនុម័តពីកម្មករនិយោជិត ដែលជាសមាជិករបស់ខ្លួនអំពីការធ្វើកូដកម្មនេះ បើកម្មករនិយោជិតមិនយល់ព្រម មិនឯកភាពទេ កូដកម្មនឹងមិនត្រូវប្រព្រឹត្តឡើងទេ មិនមែនអ្នកដឹកនាំសហជីពសំរេចដោយចិត្តឯង ហើយទៅបំផុស ឬបង្ខិតបង្ខំបងប្អូនកម្មករនិយោជិត ឱ្យធ្វើកូដកម្មឡើយ ។

មាត្រា ៣២៤ នៃច្បាប់ស្តីពីការងារបានចែងអំពី "ការជូនដំណឹងមុន" ក្នុងរយៈពេលប្រាំពីរថ្ងៃយ៉ាងតិច គិតតែថ្ងៃធ្វើការ មុននឹងធ្វើកូដកម្ម ពោលគឺ បើសិនជាសមាជិកសហជីពអនុម័តឯកភាពធ្វើកូដកម្មនោះ មុនពេលធ្វើកូដកម្ម អ្នកដឹកនាំសហជីពត្រូវជូនដំណឹងទៅនិយោជករបស់ខ្លួន និងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រយៈពេលយ៉ាងតិច ៧ ថ្ងៃមុនធ្វើកូដកម្ម ។

មាត្រា ៣៣០ នៃច្បាប់ស្តីពីការងារបានចែងថា " កូដកម្មត្រូវប្រព្រឹត្តទៅដោយសន្តិវិធី " ។

មាត្រា ៣៣១ នៃច្បាប់ស្តីពីការងារបានចែងថា " សេរីភាពនៃការធ្វើការងាររបស់អ្នកមិនមែនជាកូដករ ត្រូវបានការពារទល់នឹងការបង្ខិតបង្ខំ ឬការគំរាមកំហែងផ្សេងៗ " ពោលគឺ កម្មករនិយោជិតដែលមិនចង់ចូលរួមធ្វើកូដកម្មអាចនៅធ្វើការជាធម្មតាបាន គ្មានអ្នកដឹកនាំសហជីពណា ឬជនណាអាចបង្ខិតបង្ខំ គំរាមកំហែងឱ្យលុះតាមអំពើចិត្តរបស់ខ្លួនឡើយ ។

ចំពោះការធ្វើសកម្មភាពមិនប្រក្រតីកន្លងទៅដែលមានទ្រង់ទ្រាយជាបាតុកម្ម ដែលដឹកនាំដោយអ្នកដឹកនាំសហព័ន្ធសហជីព និងសហជីពខ្លះនាអំឡុងពេលកន្លងមក គឺមិនបានអនុវត្តទៅតាមបទបញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីការងារទេ ។

ចាប់ពីពេលនេះតទៅ អ្នកដឹកនាំ ឬ អភិបាល នៃអង្គការសហជីព និងសហព័ន្ធសហជីព ត្រូវអនុវត្ត " សិទ្ធិធ្វើកូដកម្ម " ឱ្យបានត្រឹមត្រូវតាមច្បាប់ និងបទបញ្ជាស្តីពីការងារជាកំហិត ។ ជនប្រព្រឹត្តល្មើសនឹងមាត្រាទាំងឡាយនៃច្បាប់ស្តីពីការងារ ត្រូវទទួលទោសដូចមានចែងក្នុងជំពូកទី ១៦ នៃច្បាប់នេះ និងបទបញ្ញត្តិរបស់រដ្ឋជាធរមាន ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា អ្នកដឹកនាំសហជីព សហព័ន្ធសហជីព ព្រមទាំងបងប្អូនកម្មករនិយោជិត នឹងអនុវត្តបានត្រឹមត្រូវតាមច្បាប់ស្តីពីការងារជាពុំខាន ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ : ០១២ សកបយ

រាជធានីភ្នំពេញថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០០

# សារាចរ

## ស្តីពី

## ការអនុវត្តវិធានការអនាម័យ និងសន្តិសុខការងារ នៅតាមគ្រឹះស្ថានផលិតផល

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សង្កេតឃើញថា នៅតាមគ្រឹះស្ថានផលិតផលនានា ការអនុវត្តវិធានការអនាម័យ និងសន្តិសុខការងារនៅមានការខ្វះខាតគួរឱ្យព្រួយបារម្ភ។ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមផ្តល់នូវការណែនាំជាជំហានដំបូង សំដៅធ្វើឱ្យការអនុវត្តវិធានការអនាម័យ និងសន្តិសុខការងារទាំងនោះឱ្យបានប្រសើរឡើង ដើម្បីធានាផលប្រយោជន៍ស្របច្បាប់ដល់គ្រប់ភាគីដូចតទៅ :

១-ត្រូវរៀបចំកន្លែងពុះអុសឱ្យនៅឆ្ងាយពីច្រកចេញចូល និងឆ្ងាយពីកន្លែងធ្វើការផ្សេងទៀត ហើយត្រូវហាមមិនឱ្យក្មេងទៅក្បែរកន្លែងនោះទេ ។

២-ចំពោះគ្រឹះស្ថាន ដែលមានប្រើម៉ាស៊ីនអារអុស ត្រូវធ្វើគំរបខ្សែពានម៉ាស៊ីនអារអុសឱ្យបានរឹងមាំ ហើយត្រូវរៀបចំឱ្យកម្មករអារអុស ឈរខាងកន្ទុយអុស ពោលគឺ ហាមឈរទល់មុខផ្លែរណារ ។

៣-ចំពោះគ្រឹះស្ថានផលិតផលដែលប្រើអុស និងអង្កាមត្រូវសាងសង់រោងម៉ាស៊ីនផលិតផលឱ្យបានរឹងមាំ និងប្រក់ដំបូលឱ្យបានជិត ។

៤-ចំពោះការប្រើម៉ាស៊ីនកិនដីផលិតផលដោយប្រើធ្មើត្រូវសាងសង់ឱ្យបានរឹងមាំ ទាំងធ្មើ ទាំងសសរធ្មើ ។ ទំងន់ដីដែលដាក់លើធ្មើ ត្រូវឱ្យសមាមាត្រជាមួយនឹងធ្មើ ។ កម្មករដែលធ្វើការនៅទីនោះ មិនត្រូវឱ្យឡើងអង្គុយលើធ្មើដើម្បីកាប់ដីញាត់ចូលប្រហោងប្រដាប់កិនដីទេ ពោលគឺ កម្មករត្រូវឈរសងខាងធ្មើ ដើម្បីកាប់ដីញាត់ចូលប្រហោងកិនដីដោយមិនត្រូវប្រើដៃ ឬ ជើងលូកចូលក្នុងប្រហោងកិនដីទេ ។ ខ្សែពានម៉ាស៊ីនកិនដីត្រូវមានគំរបការពាររឹងមាំ ។

៥-ចំពោះការប្រើប្រាស់ម៉ាស៊ីនកិនដីដោយគ្មានប្រើធ្មឹ ត្រូវសាងសង់រោងឱ្យបានគត់មត់សំរាប់កម្មករបានធ្វើការក្នុងម្លប់ ។ គ្រឿងយន្តកិនដីផលិតឥដ្ឋឆៅ ត្រូវមានគំរបការពារ និងគំរបការពារខ្សែពានឱ្យបានរឹងមាំ ។ កម្មករដែលធ្វើការនៅទីនោះ មិនត្រូវលូកដៃចូលក្នុងប្រហោងប្រដាប់កិនដើម្បីសង្កត់ដីទេ ត្រូវប្រើឧបករណ៍ផ្សេងសំរាប់បុកដីបញ្ចូលក្នុងប្រហោងនោះវិញ ។

៦-ត្រូវរៀបចំបណ្តាញអគ្គិសនីឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសអគ្គីសនី ដោយរៀបចំឱ្យមានប្រអប់សំរាប់ដាក់កុងតាក់បិទបើកចរន្តអគ្គីសនី និងគំរបការពារកុងតាក់ឱ្យបានត្រឹមត្រូវ ។

៧-ចំពោះគ្រឹះស្ថានដែលមានប្រើម៉ាស៊ីនភ្លើង ត្រូវផ្លាស់ប្តូរបំពង់ផ្សែងម៉ាស៊ីន ដែលពុកធ្លុះធ្លាយចេញជាប្រចាំ ។ ត្រូវរៀបចំធុងទឹកម៉ាស៊ីនឱ្យនៅក្រៅជញ្ជាំងរោងម៉ាស៊ីនភ្លើង ហើយមិនត្រូវស្តុកទុកប្រេងម៉ាស៊ូត ឬប្រេងម៉ាស៊ីននៅក្នុងរោងម៉ាស៊ីនភ្លើងទេ ពោលគឺ ត្រូវទុកដាក់ប្រេងទាំងនេះនៅទីកន្លែងផ្សេង ។

៨-ចំពោះកម្មករដែលធ្វើការនៅឡដុតឥដ្ឋ ត្រូវមានសំភារៈការពារពលកម្មដូចជា សំលៀកបំពាក់ក្រាស់ ស្រោមដៃក្រណាត់ក្រាស់ ស្បែកជើងក្រណាត់ ឬស្បែក (កវែង) មួក និងវ៉ែនតាខ្មៅជាដើម ។

៩-ចំពោះការប្រើប្រាស់កម្មករ និយោជិត ដែលមានអាយុពី ១៥ ទៅក្រោម ១៨ ឆ្នាំ ត្រូវធានាថាការងារនោះ មិនបណ្តាលឱ្យប៉ះពាល់ដល់សុខភាព សន្តិសុខ ឬសីលធម៌របស់មនុស្សពេញជំទង់ ដោយសារតែលក្ខខណ្ឌ ឬប្រភេទរបស់មុខរបរ និងការងារទាំងនោះបង្កឡើង ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា អស់លោក លោកស្រីជាម្ចាស់ និងនាយកគ្រឹះស្ថានផលិតឥដ្ឋទាំងអស់ ច្បាស់ជាយកចិត្តទុកដាក់អនុវត្តតាមការណែនាំខាងលើបានល្អប្រសើរជាពុំខាន ។

p **រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ : ១២ សគបយ

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០២

# សារាចរ

## ស្តីពី

## ការដោះស្រាយវិវាទការងារ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជំរាបលោក លោកស្រីជាម្ចាស់ និងជានាយកសហគ្រាស គ្រឹះស្ថាន បងប្អូនកម្មករនិយោជិត និងអង្គការវិជ្ជាជីវៈនានា ដែលស្ថិតនៅក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារ ហើយមានទីតាំងធ្វើការនៅក្នុងរាជធានីភ្នំពេញបានជ្រាបថា ចាប់ពីពេលនេះតទៅនៅពេលមានវិវាទការងារកើតឡើង ទាំងវិវាទការងាររួម និងវិវាទការងារបុគ្គល សូមអស់លោក លោកស្រីជូនដំណឹង ឬដាក់ពាក្យបណ្តឹងទៅប៉ុស្តិ៍អធិការកិច្ចការងារនៅតាមខណ្ឌ ដែលសហគ្រាស គ្រឹះស្ថានរបស់ខ្លួនស្ថិតនៅ ដើម្បីមន្ត្រីអធិការកិច្ចការងារនៅតាមប៉ុស្តិ៍ពិនិត្យ និងដោះស្រាយវិវាទការងារនេះបានឆាប់រហ័សជាង ។ ប៉ុស្តិ៍អធិការកិច្ចការងារទាំងនោះ មានអាសយដ្ឋានដូចមាននៅក្នុងឧបសម្ព័ន្ធជូនជាប់ជាមួយ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា អស់លោក លោកស្រីជាម្ចាស់ និងជានាយកសហគ្រាស គ្រឹះស្ថាន បងប្អូនកម្មករនិយោជិត អង្គការវិជ្ជាជីវៈ ដែលស្ថិតនៅក្នុងខណ្ឌសីមានៃរាជធានីភ្នំពេញ ច្បាស់ជាយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារខាងលើបានល្អប្រសើរពុំខាន ។

រដ្ឋមន្ត្រី

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

ហត្ថលេខា និង ត្រា

អ៊ិត សំហេង

ឧបសម្ព័ន្ធ នៃសារាចរលេខ ១២ សកបយ.

ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០២

## អាសយដ្ឋានប៉ុស្តិ៍អធិការកិច្ចការងារ តាមខណ្ឌនៅរាជធានីភ្នំពេញ

១-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌ មានជ័យ : នៅសាលាខណ្ឌមានជ័យ ផ្ទះលេខ ០៣ ផ្លូវលេខ ៣៦១ ភូមិព្រែក សង្កាត់ច្បារអំពៅទី១ លេខទូរស័ព្ទទំនាក់ទំនង ០១៦ ៨៨៥ ៥៦៥- ០១២ ៨៤៥ ២១៤ ។

២-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌ ចំការមន : នៅសាលាខណ្ឌចំការមន ផ្ទះលេខ ១៦៩ ផ្លូវម៉ៅសេទុង ភូមិ ១ សង្កាត់បឹងកេងកងទី៣ លេខទូរស័ព្ទទំនាក់ទំនង ០១២ ៨៧២ ៥៦៥- ០១២ ៨៣៦ ១០៥ ។

៣-ប៉ុស្តិ៍អធិការកិច្ចការងារ ខណ្ឌ ដង្កោ : នៅនាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អគារលេខ ២៨ ផ្លូវលេខ ១៨៤ សង្កាត់ ជ័យជំនះ ខណ្ឌ ដូនពេញ លេខទូរស័ព្ទទំនាក់ទំនង ០១២ ៩៤៥ ០៥៥ - ០១១ ៨៧៣ ៧៨៧ ។

៤-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌ ឫស្សីកែវ : នៅនាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អគារលេខ ២៨ ផ្លូវលេខ ១៨៤ សង្កាត់ ជ័យជំនះ ខណ្ឌ ដូនពេញ លេខទូរស័ព្ទទំនាក់ទំនង ០១៦ ៨៨០ ២០៩ - ០១១ ៩៧៣ ២៩៥ ។

៥-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌ ទួលគោក : នៅនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អគារលេខ ២៨ ផ្លូវលេខ ១៨៤ សង្កាត់ ជ័យជំនះ ខណ្ឌ ដូនពេញ លេខទូរស័ព្ទទំនាក់ទំនង ០១២ ៩២០ ៤៤៩ - ០១១ ៨៧២ ៩៧២ ។

៦-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌ ដូនពេញ : នៅនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អគារលេខ ២៨ ផ្លូវលេខ ១៨៤ សង្កាត់ ជ័យជំនះ ខណ្ឌ ដូនពេញ លេខទូរស័ព្ទទំនាក់ទំនង ០១២ ៨៦៨ ៣៧៧ ។

៧-ប៉ុស្តិ៍អធិការកិច្ចការងារខណ្ឌ ៧មករា : នៅនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា អគារលេខ ២៨ ផ្លូវលេខ ១៨៤ សង្កាត់ ជ័យជំនះ ខណ្ឌ ដូនពេញ លេខទូរស័ព្ទទំនាក់ទំនង ០១៦ ៨៩៧ ៩៣៥ ។

# សេចក្តីជូនដំណឹង

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៦

# សេចក្តីជូនដំណឹងអន្តរក្រសួង

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន និង ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សូមជូនដំណឹងដល់កម្មករ និយោជិត នៅតាមរោងចក្រកាត់ដេរទាំងអស់ក្នុងរាជធានីភ្នំពេញថា ក្រសួងទាំងពីរ បានពិភាក្សាគ្នាអស់រយៈពេលជាង ២ ខែមកហើយ ដើម្បីរកគ្រប់ឯកសារមកពិនិត្យពិចារណារៀបចំប្រាក់ឈ្នួលកម្មករផ្នែកកាត់ដេរឱ្យបានសមរម្យតាមកម្លាំងពលកម្មរបស់បងប្អូន ។ នៅពេលរកបានឯកសារសមល្មមនឹងអាចយកមកពិនិត្យជាមួយនិយោជកផ្នែកកាត់ដេរ ហើយក្រសួងទាំងពីរក៏បានរួមគ្នាពិភាក្សាជាមួយនិយោជក ។

ក្នុងកំឡុងពេលដែលយើងកំពុងតែចាត់ការការងារនេះ ក៏កើតមានឡើងនូវការទាមទាររបស់កម្មកររោងចក្រកាត់ដេរនៅក្រុមហ៊ុនកម្ពុជាកាត់ដេរលីមីតធីត ។ នៅថ្ងៃ ១៩ ខែ ធ្នូ ឆ្នាំ១៩៩៦ វេលាម៉ោង ១០ ដល់ម៉ោង ១ រសៀល ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន បានពិភាក្សាជាមួយនិយោជកនៃក្រុមហ៊ុននេះហើយបានសំរេចនូវសំណូមពររបស់កម្មករដូចតទៅ :

១-ចំពោះការទាមទាឱ្យធ្វើការតែមួយវេនដែលមានរយៈពេល ០៨ ម៉ោងនោះ និយោជកបានយល់ព្រមអនុវត្តតាមទាំងអស់ លើកលែងតែផ្នែកប៉ាក់ដែលនៅរក្សាធ្វើការ ៣ វេនដដែល ។ ការធ្វើការបន្ថែមម៉ោងអាចអនុវត្តបាន តែចំពោះផ្នែកដែលធ្វើការតែមួយវេន និងដោយមានការស្ម័គ្រចិត្តពីកម្មករនិយោជិត និងមានប្រាក់ឧបត្ថម្ភបន្ថែម ។

២-ចំពោះការឧបត្ថម្ភពេលឈឺថ្កាត់ កម្មករណាដែលមានជម្ងឺហើយមានបំណងចង់ទៅពិនិត្យសុខភាព ត្រូវជូនដំណឹងឱ្យគណៈគ្រប់គ្រងរោងចក្របានដឹងពីមន្ទីរពេទ្យដែលបងប្អូនមានបំណងចង់ទៅ ។ មន្ទីរពេទ្យនេះជាមន្ទីរពេទ្យរបស់រដ្ឋ ។ បើវេជ្ជបណ្ឌិតចេញវេជ្ជបញ្ជាឱ្យឈប់សំរាក ក្រុមហ៊ុននឹងអនុវត្តតាមវេជ្ជបញ្ជាដោយគ្មានការកាត់ប្រាក់ឈ្នួលឡើយព្រមទាំងចេញសោហ៊ុយទិញថ្នាំព្យាបាលទៀត ។ ករណីនេះអនុវត្តចំពោះតែការឈប់សំរាករយៈពេលខ្លី និងថ្លៃថ្នាំព្យាបាលមានតម្លៃតិចតួច ។

ការឈប់សំរាករយៈពេលវែង និង ថ្លៃថ្នាំព្យាបាលមានតម្លៃខ្ពស់ ត្រូវមានការពិភាក្សាបន្ថែមជាមួយនឹងក្រុមហ៊ុនថែមទៀត ។

៣-ការឈប់សម្រាកមាតុភាព ក្រុមហ៊ុននឹងអនុវត្តឱ្យឈប់ទៅតាមច្បាប់ការងារពេលគឺ ០៣ ខែ ដោយទទួលប្រាក់ឈ្នួលពាក់កណ្តាល ។ កម្មការិនីណាដែលមានជំងឺចាញ់កូនត្រូវចាត់ទុក និងទទួលការព្យាបាលដូចអ្នកជំងឺធម្មតាដែរ ។

៤-ក្នុងការបញ្ឈប់កម្មករបុគ្គលិកពីការងារក្រុមហ៊ុននឹងអនុវត្តតាមច្បាប់ការងារ ពោលគឺមានការជូនដំណឹងមុន និងការផ្តល់ប្រាក់បំណាច់បណ្តេញចេញ សមស្របតាមច្បាប់ការងារលើកលែងតែកម្មករនិយោជិតដែលមានកំហុសធ្ងន់ ។

៥-ក្រុមហ៊ុននឹងណែនាំឱ្យអ្នកទទួលខុសត្រូវ តាមលំដាប់ថ្នាក់របស់ក្រុមហ៊ុនឱ្យប្រើពាក្យសំដី និងមានអាកប្បកិរិយាសមរម្យចំពោះកម្មករនិយោជិត ។

ចំណុចទាំង ០៥ ខាងលើនេះ គឺជាករណីដោយឡែករបស់ក្រុមហ៊ុនកម្ពុជាកាត់ដេរ លីមីតធីត តែប៉ុណ្ណោះ ។ ប៉ុន្តែចំណុចខាងលើនេះសុទ្ធតែមានចែងក្នុងច្បាប់ការងារទាំងអស់ ហើយដែលគ្រប់ក្រុមហ៊ុនត្រូវតែអនុវត្ត ។

នៅថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ១៩៩៦ នេះចាប់ពីម៉ោង ១៤:៣០ ដល់ម៉ោង ១៧:៣០ តំណាងក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន និងតំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានបន្តការពិភាក្សាលើប្រាក់ឈ្នួលរបស់កម្មករផ្នែកកាត់ដេរទាំង ៣៦ ក្រុមហ៊ុនក្នុងរាជធានីភ្នំពេញតទៅទៀត ។ ក្នុងឱកាសនោះមាននិយោជក ឬតំណាងរបស់គេចំនួន ៣៦ ក្រុមហ៊ុនបានមកចូលរួម ដូចមានបញ្ជីរាយនាមក្រុមហ៊ុនភ្ជាប់មកជាមួយនេះ ។ ឯលទ្ធផលដែលទទួលបានគឺ :

សមាគមនិយោជកផ្នែកកាត់ដេរនៅរាជធានីភ្នំពេញទាំង ៣៦ ក្រុមហ៊ុន យល់ព្រមតាមសំណើរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន និង ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល នូវការផ្តល់ប្រាក់ឈ្នួលសុទ្ធសាធអប្បបរមាចំនួន ៤០ ដុល្លារ ( សែសិបដុល្លារអាមេរិក ) ក្នុង០១ខែ សំរាប់កម្មករនិយោជិតម្នាក់ៗ គិតចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ១៩៩៧ តទៅ ។

ចំពោះប្រាក់ឈ្នួលបន្ទាប់បន្សំ ( Accessoire de salaire ) ដូចជា ប្រាក់ហូបបាយសំរាប់កម្មករធ្វើការបន្ថែមម៉ោងពេលល្ងាច ប្រាក់រង្វាន់ធ្វើការងារទៀងទាត់ ការដឹកជញ្ជូនកម្មករ សំលៀកបំពាក់ឯកសណ្ឋានសំរាប់ធ្វើការជាដើម ។ល។ និយោជកឯកភាពជាគោលការណ៍ថា ត្រូវគិតគូរជូនកម្មករនិយោជិត ប៉ុន្តែសូមឱ្យក្រសួងទុកពេលវេលាឱ្យក្រុមហ៊ុននីមួយៗពិភាក្សាផ្ទាល់ជាក់ស្តែងជាមួយកម្មករនិយោជិត ឬ តំណាងរបស់គេ រួចក្រុមហ៊ុននឹងផ្តល់ពត៌មានមកក្រសួងឱ្យបានដឹងនៅពេលក្រោយ ។

ចំពោះម៉ោងធ្វើការ ក្រុមហ៊ុនទាំងអស់សូមរក្សារយៈពេលធ្វើការចំនួន ៤៨ ម៉ោង ក្នុងមួយសប្តាហ៍ ដូចមានចែងក្នុងច្បាប់ការងារ ។

ចំពោះកិច្ចការអនុវត្តលក្ខខណ្ឌការងារ និងជ្រើសរើសប្រតិភូបុគ្គលិក នៅតាមរោងចក្រទាំងអស់ ក្រសួងទាំងពីរ នឹងបន្តចុះធ្វើការកែលំអជាបន្តទៅទៀត លុះត្រាបានសំរេចតាមច្បាប់ការងាររបស់យើង ។

អាស្រ័យហេតុនេះ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន និង ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល សូមឱ្យបងប្អូនកម្មករ កម្មការិនី និងនិយោជិតទាំងអស់មេត្តាជ្រាប ហើយសូមរក្សានូវរបៀបរៀបរយ សក្តិសមជាពលរដ្ឋដ៏ថ្លៃថ្នូរ នៃព្រះរាជាណាចក្រកម្ពុជាដ៏រុងរឿងនៃយើង ។

សូមបងប្អូនមានជំនឿជឿជាក់លើរាជរដ្ឋាភិបាលរបស់យើង ដែលមានសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ ជាព្រះប្រមុខ និងជាប្រមុខដឹកនាំក្រោមព្រះរាជតិរះបង្រួបបង្រួមជាតិ នៃព្រះករុណាជាអម្ចាស់ជីវិតតំកល់លើត្បូង ។

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល**
**រដ្ឋលេខាធិការ**
**ហត្ថលេខា និង ត្រា**

**អ៊ិត ប្រាំង**

**រដ្ឋលេខាធិការ**
**ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន**
**ហត្ថលេខា និង ត្រា**

**ស៊ុយ សែម**

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន
លេខ ០៦ សករអ

រាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៧

# សេចក្តីជូនដំណឹង

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន សូមជូនដំណឹងដល់កម្មករនិយោជិត នៅតាមរោងចក្រកាត់ដេរទូទាំងរាជធានីភ្នំពេញថា នៅថ្ងៃទី ១៧ ខែ មករា ឆ្នាំ ១៩៩៧ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន បានបន្តធ្វើការពិភាក្សាជាមួយសមាគមអ្នកផលិតសំលៀកបំពាក់ ដើម្បីកំណត់អំពីលក្ខខណ្ឌការងាររបស់កម្មករនិយោជិតនៃរោងចក្រកាត់ដេរនៅរាជធានីភ្នំពេញ ។

ឆ្លងតាមការប្រជុំ សមាគមបានយល់ព្រមដូចតទៅនេះ :

១-ប្រាក់ឈ្នួលសុទ្ធសាធអប្បបរមា សំរាប់កូនជាងដែលមកសុំរៀនកាត់ដេរ ត្រូវបានកំណត់ ៣០ ដុល្លារក្នុងមួយខែ ។ ការហ្វឹកហ្វឺនកូនជាងនេះមានថិរវេលាអតិបរមា២ ខែ ។ ចប់រយៈពេលហ្វឹកហ្វឺន កូនជាងត្រូវបានធ្វើតេស្តវាស់កំរិតជំនាញ ។ បើជាប់ជំនាញហើយកូនជាងត្រូវបញ្ជូនអោយសាកល្បងថែមទៀត ។

២-មុនក្លាយទៅជាជាងកាត់ដេរ កូនជាងដែលបានបញ្ចប់ការហ្វឹកហ្វឺនប្រកបដោយជោគជ័យ ត្រូវឆ្លងកាត់ការសាកល្បងដែលមានថិរវេលាអតិបរមា៣ ខែ ។ ក្នុងថិរវេលាសាកល្បង អ្នកសាកល្បងបានទទួលប្រាក់ឈ្នួលសុទ្ធសាធអប្បបរមា ៤០ ដុល្លារ ក្នុងមួយខែ ។

៣-កម្មករនិយោជិតដែលបាន ឆ្លងកាត់ការសាកល្បងប្រកបដោយជោគជ័យ ក្លាយទៅជាជាងដេរ ដែលបានទទួលប្រាក់ឈ្នួលសុទ្ធសាធអប្បបរមា ៤០ ដុល្លារ ក្នុងមួយខែ ។

៤-កម្មករនិយោជិតចាស់ដែលមានសៀវភៅការងារហើយ ត្រូវឆ្លងកាត់ថិរវេលាសាកល្បង ៣ ខែទៀត បើសិនជាគេផ្លាស់មកធ្វើការនៅក្នុងក្រុមហ៊ុនថ្មី ។ ក្នុងថិរវេលាសាកល្បងនេះកម្មករនិយោជិត បានទទួលប្រាក់ឈ្នួលសុទ្ធសាធអប្បបរមា ៤០ ដុល្លារ ក្នុងមួយខែ ។

៥-មុននឹងបញ្ឈប់កូនជាងអ្នកសាកល្បង ឬកម្មករនិយោជិតពីការងារ និយោជកត្រូវជូនដំណឹងមុនតាមថិរវេលាដូចខាងក្រោមនេះ លើកលែងតែករណីមានកំហុសធ្ងន់ :

- មួយថ្ងៃមុនចំពោះកូនជាង
- មួយសប្តាហ៍មុនចំពោះអ្នកសាកល្បង

- ថិរវេលាដូចមានចែងក្នុងច្បាប់ការងារ ចំពោះកម្មករនិយោជិត ។

៦-ថិរវេលាធ្វើការអតិបរមាគឺ ៤៨ ម៉ោងក្នុងមួយសប្ដាហ៍ ។ ថិរវេលានេះអាចតិចជាងនេះអាស្រ័យលើការព្រមព្រៀងគ្នារវាងនិយោជក និងកម្មករនិយោជិត ។

៧-និយោជកអ្នកសំណូមពរអោយកម្មករ និយោជិត ធ្វើការថែមម៉ោងម្ដងម្កាលក្នុងលក្ខខណ្ឌដូចខាងក្រោមនេះ :-

- ការធ្វើការបន្ថែមម៉ោងត្រូវមានការស្ម័គ្រចិត្តពីកម្មករនិយោជិត
- អត្រាប្រាក់បន្ថែមម៉ោងក្នុងថ្ងៃធ្វើការធម្មតា ស្មើនឹង ១.៥ ដង នៃប្រាក់ឈ្នួលថ្ងៃធម្មតា ឬបន្ថែម ៥០ % លើប្រាក់ឈ្នួលធម្មតា
- ប្រាក់ធ្វើការថ្ងៃឈប់សំរាកប្រចាំសប្ដាហ៍ និងថ្ងៃបុណ្យ ត្រូវផ្ដល់ស្មើនឹង ២ ដង នៃប្រាក់ឈ្នួលថ្ងៃធម្មតា ឬបន្ថែម ១០០ % លើប្រាក់ឈ្នួលធម្មតា ។

៨-និយោជកឯកភាពផ្ដល់ការចំណាយទាំងអស់ផ្នែកពេទ្យដល់កម្មករនិយោជិត ដែលមានគ្រោះថ្នាក់ការងារ ។ និយោជកផ្ដល់ការព្យាបាល និងប្រាក់ថ្លៃថ្នាំពេទ្យរបស់កម្មករ និយោជិតដែលមានជម្ងឺតាម លទ្ធភាពរបស់ខ្លួន ។ និយោជកត្រូវបង្កើតគិលានដ្ឋាន ដើម្បីព្យាបាលជម្ងឺស្រាលៗរបស់កម្មករ និយោជិត សមស្របតាមការកំណត់របស់ច្បាប់ការងារ ។

៩-និយោជកអនុញ្ញាតអោយ កម្មករនិយោជិតជាស្ត្រីភេទ បានឈប់សំរាកលំហែមាតុភាពចំនួន ៩០ ថ្ងៃជាអតិបរមាដោយបានទទួលប្រាក់ឈ្នួលពាក់កណ្ដាល ។

១០-និយោជក នឹងបណ្ដេញពីការងារនូវកម្មករនិយោជិតណា ដែលមានកំហុសធ្ងន់ដូចមានចែងក្នុងច្បាប់ការងារ ។ ករណីមានកំហុសធ្ងន់ធ្ងរខ្លាំង និយោជកនឹងបញ្ជូនសាមីខ្លួន និងភស្តុតាងទៅស្ថាប័នមានសមត្ថកិច្ច ដើម្បីដោះស្រាយតាមផ្លូវច្បាប់ ។ ក្នុងករណីទាំងពីរនេះ កម្មករនិយោជិតដែលមានកំហុសនៅទទួលបានប្រាក់ឈ្នួលចំពោះការងារដែលខ្លួនបានធ្វើកន្លងមកហើយមិនទាន់បានបើក ។

១១-ក្នុងការបញ្ឈប់កម្មករ និយោជិតក្រៅពីកំហុសធ្ងន់ និយោជកត្រូវផ្ដល់ប្រាក់បំណាច់បណ្ដេញចេញ មិនតិចជាងការកំណត់របស់ច្បាប់ការងារឡើយ ។

១២-ប្រតិភូបុគ្គលិកត្រូវបានជ្រើសរើសក្នុងចំណោមបេក្ខជន ដែលឧទ្ទេសនាមដោយអង្គការសហជីព ។ ក្នុងសភាពការណ៍បច្ចុប្បន្នដែលនៅមិនទាន់មានអង្គការសហជីព បេក្ខជនប្រតិភូបុគ្គលិកត្រូវជ្រើសរើសដោយកម្មករនិយោជិតផ្ទាល់ ។

១៣-និយោជកឯកភាព ផ្ដល់ឱ្យដល់កម្មករ និយោជិតនូវប្រាក់ឈ្នួលបន្ទាប់បន្សំដូចខាងក្រោមនេះ :

ក- ប្រាក់រង្វាន់លើកទឹកចិត្តចំពោះការងារទៀងទាត់ ។ និយោជកនឹងពិភាក្សាជាមួយកម្មករនិយោជិតផ្ទាល់ដើម្បីកំណត់បរិមាណប្រាក់រង្វាន់នេះ ។

ខ- មធ្យោបាយដឹកជញ្ជូននៅពេលដែលក្រុមហ៊ុនមានលទ្ធភាព ។ ចំពោះមុខនិយោជក ឯកភាពផ្តល់ជាប្រាក់ជំនួសសិន ។ និយោជកនឹងពិភាក្សាជាមួយកម្មករនិយោជិត អំពីចំនួនប្រាក់ដែលត្រូវផ្តល់អោយកម្មករនិយោជិត ។

គ- ប្រាក់រង្វាន់ប្រចាំឆ្នាំ ករណីដែលរោងចក្រចំណេញ និងអនុវត្តចំពោះកម្មករនិយោជិតដែលធ្វើការបានមួយឆ្នាំពេញ ។

ឃ- សំលៀកបំពាក់ពលកម្ម ២ សំរាប់ម្នាក់ក្នុងមួយឆ្នាំដោយឥតគិតថ្លៃ ចំពោះកម្មករនិយោជិតណា ដែលធ្វើការចាប់ពី ៦ ខែ ឡើងទៅដោយគិតទាំងរយៈពេលសាកល្បងផង ។

ង- ក្រុមហ៊ុនឯកភាពផ្តល់នូវបាយមួយពេលដោយឥតគិតថ្លៃ ចំពោះកម្មករ និយោជិត ណាដែលធ្វើការបន្ថែមម៉ោង ។

១៤-ក្រុមហ៊ុនសន្យាថា នឹងអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ការងារ ឬ សេចក្តីសំរេចណារបស់រដ្ឋាភិបាលដែលផ្តល់លក្ខខណ្ឌប្រសើរជាងសំរាប់កម្មករ និយោជិត ។

១៥-ក្រុមហ៊ុនសន្យាថា នឹងដោះស្រាយជាមួយកម្មករនិយោជិតនូវវិវាទ ដែលកើតមានឡើងដោយសន្តិវិធី ។ បើដោះស្រាយមិនបានសំរេច ក្រុមហ៊ុននឹងស្នើឱ្យក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនដោះស្រាយបន្ត ។

ចំពោះបញ្ហាដែលនៅសេសសល់ក្រសួងនឹងបន្តពិភាក្សាជាមួយសមាគមថែមទៀត ហើយក្រសួងនឹងជូនដំណឹងជាបន្តបន្ទាប់ ។

អាស្រ័យហេតុនេះ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន សូមអោយបងប្អូនកម្មករ កម្មការិនី និងនិយោជិតទាំងអស់មេត្តាជ្រាប ។

**រដ្ឋលេខាធិការ**

**ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន**

**ហត្ថលេខា និង ត្រា**

**ស៊ុយ សែម**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន
លេខ ១២ សករ

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៧

# សេចក្តីជូនដំណឹង
# ស្តីពី
# បណ្ណការងារ និងសៀវភៅការងារជនបរទេស

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន សូមជូនដំណឹងដល់ជនបរទេសទាំងអស់ ដែលចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា យោងតាមមាត្រា ២៦១ នៃច្បាប់ស្តីពីការងារ ដើម្បីប្រកបមុខរបរអ្វីមួយ ឬមកធ្វើការបំរើអោយក្រុមហ៊ុន រោងចក្រ ឬសហគ្រាស ណាមួយជាបណ្តោះអាសន្ន ត្រូវមានប័ណ្ណការងារ និងសៀវភៅការងារ ដែលចេញអោយដោយ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ។

សំណុំលិខិតដែលត្រូវបំពេញរួមមានៈ-

| | | |
|---|---|---|
| ១-ពាក្យសុំធ្វើប័ណ្ណការងារ និងសៀវភៅការងារបិទតែមប្រី ១.០០០ រៀល | ០១ | ច្បាប់ |
| ២-សេចក្តីថតចម្លងលិខិតឆ្លងដែន | ០១ | ច្បាប់ |
| ៣-ប័ណ្ណស្នាក់នៅត្រឹមត្រូវ p | ០១ | ច្បាប់ |
| ៤-លិខិតបញ្ជាក់កាយសម្បទាល្អ ចេញដោយនាយកដ្ឋានពេទ្យការងារ នៃក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន | ០១ | ច្បាប់ |
| ៥-បង់អាករប្រចាំឆ្នាំ ១០០ ដុល្លារ អាមេរិក | | |
| ៦-រូបថតចំពីមុខ ៤ X ៦ ស.ម | ០៤ | សន្លឹក |

អាស្រ័យហេតុនេះ សូមជនបរទេសទាំងអស់ ដែលរស់នៅរាជធានីភ្នំពេញ អញ្ជើញទៅធ្វើប័ណ្ណការងារ និងសៀវភៅការងារឱ្យបានគ្រប់ៗគ្នា នៅនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ស្ថិតនៅអគារលេខ ២៨ វិថីព្រះធម្មលិខិតអ៊ុក អតីតផ្លូវលេខ ១៨៤ សង្កាត់ជ័យជំនះ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ។ ចំពោះអ្នកនៅតាមខេត្ត-ក្រុងនានា សូមអញ្ជើញទៅធ្វើប័ណ្ណការងារ និងសៀវភៅការងារ នៅអធិការដ្ឋានសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ខេត្ត-ក្រុង រៀងៗខ្លួន ។

ក្រុមហ៊ុន សហគ្រាស ទាំងឡាយណាដែលទទួលឱ្យធ្វើការ ឬរក្សាទុកឱ្យធ្វើការនូវជនបរទេស ដែលគ្មានប័ណ្ណការងារ និងសៀវភៅការងារ ត្រូវទទួលទោសពិន័យទៅតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនសង្ឃឹមថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានរោងចក្រ ឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សិប្បកម្ម សេវា ទាំងអស់នឹងអនុវត្តតាមសេចក្ដីជូនដំណឹងនេះឱ្យបានរួសរាន់ និងមានប្រសិទ្ធិភាពខ្ពស់ជាពុំខាន ។

**រដ្ឋលេខាធិការ**
**ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន**
**ហត្ថលេខា និង ត្រា**

**ស៊ុយ សែម**

p

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន**
**លេខ ១៣ សកអ**

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៧

# សេចក្តីជូនដំណឹង
## ស្តីពី
## សៀវភៅការងាររបស់និយោជិត_កម្មករខ្មែរ

ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន សូមជំរាបជូនដល់ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថាន ឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សេវា កសិកម្ម ទាំងអស់ដែលមានចែងក្នុងមាត្រា ១ នៅក្នុងច្បាប់ការងារបានជ្រាបថា យោងតាមមាត្រា ៣២ នៃច្បាប់ការងារ និយោជិតកម្មករ សញ្ជាតិខ្មែរ ដែលបំរើការងារនៅក្នុងរោងចក្រ សហគ្រាសរបស់ឯកជន ត្រូវតែមានសៀវភៅការងារ ដែលចេញដោយក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ។

ចំពោះអ្នកនៅរាជធានីភ្នំពេញ សូមអញ្ជើញទៅធ្វើសៀវភៅការងារនៅនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ស្ថិតនៅអគារលេខ ២៨ ផ្លូវ ១៨៤ សង្កាត់ ជ័យជំនះ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ។

ចំពោះអ្នកនៅតាមខេត្ត-ក្រុងនានា សូមអញ្ជើញទៅធ្វើសៀវភៅការងារនៅគ្រប់អធិការដ្ឋានខេត្ត-ក្រុងរៀង១ខ្លួន ។

សំណុំលិខិតដែលត្រូវបំពេញមានដូចតទៅ :

| | |
|---|---|
| ១-ពាក្យសុំធ្វើសៀវភៅការងារបិទតែមប្រិ៍ ១.០០០ រៀល | ០១ ច្បាប់ |
| ២-អត្តសញ្ញាណប័ណ្ណ ឬលិខិតបញ្ជាក់ទីលំនៅ | ០១ ច្បាប់ |
| ៣-លិខិតបញ្ជាក់ពីមុខរបរចេញដោយនិយោជក | ០១ ច្បាប់ |
| ៤-អាករចំនួន | ១.៥០០ រៀល |
| ៥-រូបថត ៤ x ៦ ស.ម | ០៤ សន្លឹក |

អាស្រ័យហេតុនេះ សូមនាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន រោងចក្រ ទាំងអស់រៀបចំកម្មវិធីដើម្បីបង្កលក្ខណៈងាយស្រួលឱ្យនិយោជិត កម្មករ ក្រោមឱវាទ ទៅធ្វើសៀវភៅការងារឱ្យបានគ្រប់១គ្នា ។

ក្រសួងសង្គមកិច្ច ភារងារ និងអតីតយុទ្ធជនសង្ឃឹមថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន រោងចក្រ ឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សិប្បកម្ម សេវា ទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះឱ្យបានរួសរាន់ និងមានប្រសិទ្ធិភាពខ្ពស់ជាពុំខាន ។

**រដ្ឋលេខាធិការ**

**ក្រសួងសង្គមកិច្ច ភារងារ និងអតីតយុទ្ធជន**

**ហត្ថលេខា និង ត្រា**

**ស៊ុយ សែម**

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ : ០១៤ សកបយ

រាជធានីភ្នំពេញ . ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៩

## សេចក្តីជូនដំណឹង

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជំរាបដល់ម្ចាស់ និងនាយករោងចក្រសហគ្រាសកាត់ដេរទាំងអស់បានជ្រាបថា កន្លងទៅថ្មីៗនេះដោយសារការដាក់អោយកម្មករនិយោជិត ធ្វើការបន្ថែមម៉ោងច្រើនពេកនោះ បានបណ្តាលអោយមានគ្រោះថ្នាក់ការងារកើតឡើង ជាបន្តបន្ទាប់ ។ ដើម្បីអនុវត្តមាត្រា ១៣៧ មាត្រា ១៣៩ និង មាត្រា ១៤១ នៃច្បាប់ស្តីពីការងារ ព្រមទាំងប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា លេខ: ៨០ សកបយ. ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីការធ្វើការបន្ថែមម៉ោងក្រៅពីថិរវេលាធ្វើការធម្មតា ឱ្យបានត្រឹមត្រូវ និងទទួលបានលទ្ធផលល្អប្រសើរ សំដៅធានាបាននូវផលប្រយោជន៍របស់កម្មករនិយោជិត និងនិយោជកនោះ សូមម្ចាស់ និងនាយករោងចក្រ សហគ្រាស កាត់ដេរ ទាំងអស់អនុវត្តដូចតទៅ :

១- ក្នុងករណីដែលរោងចក្រ សហគ្រាស មានការងារច្រើនខុសធម្មតាដែលតំរូវអោយមានការធ្វើការបន្ថែមម៉ោងក្រៅពីថិរវេលាធ្វើការធម្មតា ម្ចាស់ ឬនាយករោងចក្រសហគ្រាសត្រូវ ស្នើសុំការអនុញ្ញាតពីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាជាមុនសិន ។ នៅពេលទទួលបានការអនុញ្ញាតទើបរោងចក្រ សហគ្រាស អាចរៀបចំធ្វើការបន្ថែមម៉ោងនេះបាន ។

២- ការរៀបចំធ្វើការបន្ថែមម៉ោងនេះ ត្រូវផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត ពោលគឺម្ចាស់ ឬ នាយករោងចក្រ សហគ្រាសមិនត្រូវបង្ខិតបង្ខំ ឬ ដាក់វិន័យផ្សេងៗ ចំពោះកម្មករ និយោជិត ដែលមិនស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោងឡើយ ។

៣- ម្ចាស់ ឬនាយករោងចក្រ សហគ្រាសត្រូវផ្តល់ប្រាក់ឈ្នួលធ្វើការបន្ថែមម៉ោងជូនកម្មករនិយោជិតដូចតទៅ :

ក- ស្មើនឹង ១៥០ ភាគរយ( ឬ ១ ដងកន្លះ ) នៃប្រាក់ឈ្នួលធ្វើការធម្មតា ចំពោះការធ្វើការ

បន្ថែមម៉ោងនៅពេលថ្ងៃ នៃថ្ងៃធ្វើការធម្មតា ។

ខ- ស្មើនឹង ២០០ ភាគរយ (ឬ ២ ដង) នៃប្រាក់ឈ្នួលពេលធ្វើការធម្មតា ចំពោះការធ្វើការបន្ថែមម៉ោងនៅពេលយប់ (ពីម៉ោង ២២:០០ ទៅម៉ោង ៥:០០ព្រឹក) ។

៤- ចំពោះរោងចក្រ សហគ្រាស ដែលមានកម្មករនិយោជិតធ្វើការពេលយប់ ម្ចាស់ ឬ នាយកសហគ្រាស គ្រឹះស្ថាន ត្រូវផ្តល់ទីកន្លែងសំរាកទទួលទានដំណេក អោយបានសមរម្យដល់កម្មករនិយោជិតដែលចេញពីធ្វើការនៅពេលយប់ពុំនោះសោតទេ ត្រូវផ្តល់មធ្យោបាយសំរាប់ដឹកជញ្ជូនកម្មករនិយោជិតទៅដល់លំនៅដ្ឋានរៀងៗខ្លួនវិញប្រកបដោយសុវត្ថិភាព នៅពេលចប់ម៉ោងធ្វើការពេលយប់ ។

៥- ម្ចាស់រោងចក្រ សហគ្រាស ត្រូវយកចិត្តទុកដាក់រៀបចំកន្លែងធ្វើការរបស់កម្មករនិយោជិតឱ្យមានខ្យល់អាកាសបរិបូរណ៍ រៀបចំសំភារៈវត្ថុធាតុដើមដែលមានឥទ្ធិពលប៉ះពាល់សុខភាពតាមឃ្លាំងទុកដាក់ត្រឹមត្រូវ និងមានគិលានដ្ឋានប្រចាំរោងចក្រ សហគ្រាស សំរាប់ការព្យាបាលបឋមដល់ កម្មករនិយោជិត ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងចាត់វិធានការតឹងរឹងបំផុតទៅតាមច្បាប់ ចំពោះម្ចាស់ ឬ នាយករោងចក្រ សហគ្រាសកាត់ដេរណា ដែលប្រព្រឹត្តល្មើសលើចំណុចដែលបានរៀបរាប់ខាងលើនៃសេចក្តីជូនដំណឹងនេះ ព្រមទាំងប្រកាសនានារបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះ-បណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា កន្លងមក ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានក្តីសង្ឃឹមយ៉ាងមុតមាំថាម្ចាស់ និងនាយករោងចក្រ សហគ្រាសកាត់ដេរទាំងអស់ និងអនុវត្តតាមសេចក្តីជូនដំណឹងនេះ បានល្អប្រសើរពុំខាន ។

p **រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ

បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ : ១៥ សកបយ

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០០

## សេចក្តីជូនដំណឹង

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជូនដំណឹងដល់សហព័ន្ធ សហជីព សហជីពកម្មករនិយោជិត សមាគមនិយោជក និយោជកនៃរោងចក្រ សហគ្រាស ផ្នែកវាយនភ័ណ្ឌកាត់ដេរ និងដេរស្បែកជើងទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាជ្រាបថា នៅថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០០ គណៈកម្មការប្រឹក្សាការងារដែលមាន តំណាងមកពីខាងរាជរដ្ឋាភិបាល តំណាងមកពីខាងសហព័ន្ធ សហជីព កម្មករ និយោជិត តំណាងមកពីខាងសមាគមនិយោជក បានធ្វើការប្រជុំពិភាក្សាគ្នា អំពីប្រាក់ឈ្នួលអប្បបរមារបស់ កម្មករនិយោជិត ផ្នែកវាយនភ័ណ្ឌកាត់ដេរ និង ដេរស្បែកជើង ។ ការប្រជុំនោះបានប្រព្រឹត្តទៅដោយការពិភាក្សាគ្នាយ៉ាងតឹងតែង ដែលភាគីទាំងអស់បានលើកឡើងនូវទឡ្ហីករណ៍ បញ្ជាក់រៀងៗខ្លួន ។

ចំពោះភាគីខាងសមាគមនិយោជក បន្ទាប់ពីលើកហេតុផលសព្វគ្រប់បញ្ជាក់ពីការលំបាករបស់ខ្លួននាពេលបច្ចុប្បន្ន បានស្នើឡើងនូវដំណោះស្រាយដូចតទៅ:-

- ស្នើរក្សាប្រាក់ឈ្នួលអប្បបរមាត្រឹម ៤០ ដុល្លារ ក្នុង ១ ខែ នេះមួយរយៈពេលទៀតសិន
- ផ្តល់ប្រាក់រង្វាន់សំរាប់ការងារទៀងទាត់ចំនួនយ៉ាងតិច ៥ ដុល្លារ ក្នុង ១ ខែ
- តម្លើងប្រាក់ឈ្នួលស្មើនឹង ៥ % នៃប្រាក់ឈ្នួលមូលដ្ឋានចំពោះកម្មករ និយោជិត ដែលមានអតីតភាពការងារ ២ ឆ្នាំ ៦ % ចំពោះកម្មករដែលមានអតីតភាពការងារលើសពី ៤ ឆ្នាំ និង ៧ % ចំពោះកម្មករដែលមានអតីតភាពការងារលើសពី ៦ ឆ្នាំ ។ល ។

លោក ជា វិជ្ជា ប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា មិនឯកភាពទទួលយកដំណោះស្រាយ របស់សមាគមនិយោជកដូចខាងលើនេះទេ ។ លោកប្រធាន សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាស្នើសុំតម្លើងប្រាក់ឈ្នួលកម្មករ និយោជិតអោយបាន ៦០ ដុល្លារក្នុងមួយខែ។ សហព័ន្ធសហជីពដទៃទៀតរបស់កម្មករនិយោជិតមិនទាន់បានឯកភាពគ្នាលើទឡ្ហីករណ៍ ដែលលើកឡើងដោយតំណាងសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជាទេ ព្រោះគ្មានឯកសារ និងមូលដ្ឋានច្បាស់លាស់ ។ ហើយតំណាងសហ-

ព័ន្ធសហជីពចំនួន ០៣ ដែលបានចូលរួមប្រជុំក្នុងឱកាសនោះបានលើកសំណើសុំពន្យាពេលនៃការប្រជុំនេះទៅថ្ងៃក្រោយទៀត ដើម្បីទុកពេលអោយសហជីពទាំងអស់ពិគ្រោះគ្នាឡើងវិញអំពីបញ្ហានេះ ឱ្យឯកសារ និងមូលដ្ឋានច្បាស់លាស់ទើបដាក់ជូនអង្គប្រជុំនៃគណៈកម្មការប្រឹក្សាការងារពិនិត្យម្តងទៀត ។ ដោយមានសំណើបីខុសៗគ្នាយ៉ាងនេះ គណៈកម្មការប្រឹក្សាការងារបានធ្វើការអនុម័តលើសំណើទាំងនោះមួយម្តងៗ ដើម្បីសំរេចថា ត្រូវយកតាមសំណើណា ។ លទ្ធផលនៃការអនុម័តមានដូចតទៅ :-

១- អនុម័ត ១១ សំលេង លើ ១៨ ដែលបានចូលរួមប្រជុំ ចំពោះសំណើពន្យាពេលប្រជុំរបស់គណៈ-កម្មការដើម្បីទុកពេលអោយសហព័ន្ធសហជីពទាំងអស់ពិភាក្សាគ្នាអោយបានឯកភាព ព្រមទាំងមានឯកសារនិងមូលដ្ឋានច្បាស់លាស់ ។

២- អនុម័ត ៦ សំលេងលើ ១៨ សំលេងដែលបានចូលរួមប្រជុំ ចំពោះសំណើរបស់តំណាងសមាគមនិយោជក ។

៣- អនុម័ត ០១ សំលេងលើ ១៨ សំលេង ដែលបានចូលរួមប្រជុំ ចំពោះសំណើរបស់តំណាងសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ។

ផ្អែកតាមលទ្ធផលខាងលើគឺ គណៈកម្មការប្រឹក្សាការងារបានសំរេចពន្យាពេលនៃការប្រជុំរបស់ខ្លួនលើបញ្ហាប្រាក់ឈ្នួលអប្បបរមានេះ លុះដល់ពេលដែលសហព័ន្ធ សហជីពទាំងអស់ពិគ្រោះពិភាក្សាគ្នាបានឯក-ភាពហើយលើកសំណើជាថ្មីជូនគណៈកម្មការ ។ អាស្រ័យហេតុនេះគោលការណ៍ដែល កំពុងអនុវត្តជាធរមានសព្វថ្ងៃត្រូវបន្តអនុវត្តទៅមួយរយៈពេលទៀត ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងគណៈកម្មការប្រឹក្សាការ-ងារ និងបន្តខិតខំបំពេញនូវភារៈកិច្ចរបស់ខ្លួនអោយស្របតាមតួនាទី ដូចដែលមានចែងក្នុងច្បាប់របស់រដ្ឋពិសេសគឺ ច្បាប់ស្តីពីការងារ សំដៅថែរក្សាផលប្រយោជន៍សមស្របយុត្តិធម៌នៃរាល់ភាគីពាក់ព័ន្ធអោយកាន់តែល្អប្រសើរឡើងជាលំដាប់ ។

សូមបងប្អូនកម្មករនិយោជិត ទាំងអស់មេត្តាបន្តអនុវត្តការងាររបស់ខ្លួនជាធម្មតាក្នុងស្មារតីនឹងន និងទទួលខុសត្រូវអោយសមស្របជាពលរដ្ឋដ៏ល្អនៃព្រះរាជាណាចក្រកម្ពុជា ។ សូមបងប្អូនជៀសវាងការប្រព្រឹត្តអំពើមិនគប្បី ឬ អំពើផ្ទុយនឹងច្បាប់រដ្ឋនានា ដែលអាចនាំមកនូវផលវិបាកមិនល្អដល់ខ្លួនយើងផង និងដល់សង្គមជាតិរបស់យើងផង ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ : ០១៧ សគបយ

រាជធានីភ្នំពេញ . ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០០

## សេចក្តីជូនដំណឹង

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជូនដំណឹងដល់សហព័ន្ធសហជីព សហជីពកម្មករនិយោជិត សមាគមនិយោជក និងនិយោជកនៃរោងចក្រសហគ្រាស ផ្នែកវាយនភ័ណ្ឌកាត់ដេរ និងដេរស្បែកជើងទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាជ្រាបថា នៅថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០០ គណៈកម្មការប្រឹក្សាការងារដែលមានតំណាងមកពីរាជរដ្ឋាភិបាល តំណាងមកពីខាងសហព័ន្ធសហជីព កម្មករនិយោជិត និងតំណាងមកពីខាងសមាគមនិយោជក បានធ្វើការប្រជុំពិភាក្សាគ្នាអំពីប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌកាត់ដេរ និងដេរស្បែកជើង ។ ការប្រជុំនោះសំរេចបានលទ្ធផលដូចតទៅ :-

១- យោងសភាពការណ៍ជាក់ស្តែងចំពោះមុខហើយ និងយោងតាមទឡ្ហីករណ៍ដែលលើកឡើងដោយតំណាងកម្មករនិយោជិត និងតំណាងនិយោជក ប្រាក់ឈ្នួលអប្បបរមាសំរាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌកាត់ដេរ និង ដេរស្បែកជើង គឺកំណត់ស្មើនឹង ៤០ ដុល្លារអាមេរិកក្នុងមួយខែ ក្នុងរយៈពេលដែលកម្មករនិយោជិតធ្វើការសាកល្បងការងារពី ១ ខែទៅ ៣ ខែ ។ ចំពោះកម្មករនិយោជិតដែលទទួលប្រាក់ឈ្នួលតាមបរិមាណផលិតផល (ដេរស៊ីបុង) ត្រូវបានប្រាក់ឈ្នួលតាមផលិតផលជាក់ស្តែងដែលធ្វើបាន ។ បើទិន្នផលការងារទទួលបានប្រាក់ឈ្នួលលើសពី ៤០ ដុល្លារអាមេរិកក្នុង ១ខែ គឺត្រូវទទួលតាមការលើសនោះ ។ តែបើបានទាបជាង ៤០ ដុល្លារអាមេរិកក្នុងមួយខែ និយោជកត្រូវបន្ថែមអោយគ្រប់ ៤០ ដុល្លារអាមេរិក ក្នុងមួយខែ ។

២- ចប់រយៈពេលសាកល្បង កម្មករ និយោជិត ដែលពេញសិទ្ធិហើយ គឺ ត្រូវទទួលបានប្រាក់ឈ្នួលអប្បបរមា ៤៥ ដុល្លារអាមេរិកក្នុងមួយខែ ។ ចំពោះកម្មករនិយោជិត ដែលទទួលប្រាក់ឈ្នួលតាមបរិមាណផលិតផល( ដេរស៊ីបុង ) ត្រូវបានប្រាក់ឈ្នួលតាមលទ្ធផលជាក់ស្តែងដែលធ្វើបាន ។ បើទិន្នផលការងារទទួល

បានប្រាក់ឈ្នួលលើសពី ៤៥ ដុល្លារ អាមេរិកក្នុងមួយខែ គឺត្រូវទទួលតាមការលើសនោះ ។ តែបើបានទាបជាង ៤៥ ដុល្លារអាមេរិកក្នុងមួយខែ និយោជកត្រូវបន្ថែមអោយគ្រប់ ៤៥ ដុល្លារអាមេរិកក្នុងមួយខែ ។

៣- កម្មករនិយោជិត ដែលធ្វើការទៀងទាត់នៃចំនួនថ្ងៃដែលត្រូវធ្វើការក្នុងមួយខែៗនោះ ត្រូវបានប្រាក់រង្វាន់យ៉ាងតិចចំនួន ៥ ដុល្លារអាមេរិកក្នុងមួយខែ ។

៤- កម្មករនិយោជិត ដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោង តាមសំណូមពររបស់និយោជក ត្រូវទទួលបានប្រាក់ថ្លៃបាយចំនួន ១.០០០ រៀល ក្នុងមួយថ្ងៃ ឬទទួលបានការផ្តល់ជូនបាយមួយពេលដោយឥតគិតថ្លៃ ។

៥- កម្មករនិយោជិត ដែលធ្វើការបានយូរឆ្នាំនៅក្នុងរោងចក្រ សហគ្រាសណាមួយ ត្រូវបានប្រាក់រង្វាន់ការងារ ដូចតទៅ :-

៥.១- ធ្វើការបានចាប់ពីមួយឆ្នាំឡើងទៅ ត្រូវទទួលបានប្រាក់រង្វាន់អតីតភាពការងារចំនួន០២ ដុល្លារ អាមេរិកក្នុងមួយខែ ។

៥.២- ធ្វើការបានចាប់ពីពីរឆ្នាំឡើងទៅ ត្រូវទទួលប្រាក់រង្វាន់អតីតភាពការងារចំនួន ០៣ ដុល្លារអាមេរិកក្នុងមួយខែ ពោលគឺ ០២ ដុល្លារ នៃឆ្នាំទី ០១ បូកនិង ០១ ដុល្លារ នៃឆ្នាំទី ២ ។

៥.៣- ធ្វើការបានចាប់ពីបីឆ្នាំឡើងទៅ ត្រូវទទួលប្រាក់រង្វាន់អតីតភាពការងារចំនួន ០៤ ដុល្លារអាមេរិកក្នុងមួយខែ ពោលគឺ ០២ ដុល្លារ នៃឆ្នាំទី១ បូកនិង ១ដុល្លារ នៃឆ្នាំទី ២ បូកនិង ១ ដុល្លារ នៃឆ្នាំទី ៣ ។

៥.៤- ធ្វើការបានចាប់ពីបួនឆ្នាំឡើងទៅ ត្រូវទទួលប្រាក់រង្វាន់អតីតភាពការងារចំនួន ៥ ដុល្លារ អាមេរិកក្នុងមួយខែ ពោលគឺ ២ ដុល្លារនៃឆ្នាំទី ១ បូកនិង ១ ដុល្លារនៃឆ្នាំទី ២ បូកនិង ១ដុល្លារនៃឆ្នាំទី៣ បូក និង ១ ដុល្លារ នៃឆ្នាំទី ៤ ។

អតីតភាពសំរាប់គិតផ្តល់ប្រាក់រង្វាន់ខាងលើនេះត្រូវគិតចាប់ពីថ្ងៃទី០១ ខែ សីហា ឆ្នាំ ២០០០តទៅ។

៦- និយោជកត្រូវអនុញ្ញាតអោយកម្មករនិយោជិតឈប់សំរាកប្រចាំឆ្នាំអោយបានត្រឹមត្រូវតាមច្បាប់ស្តីពីការងារពោលគឺ កម្មករ និយោជិត ដែលធ្វើការបានទៀងទាត់ក្នុងរយះពេល ១២ ខែ ត្រូវបានឈប់សំរាកប្រចាំឆ្នាំចំនួន ១៨ ថ្ងៃ។

ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០០ តទៅ ប្រាក់ឈ្នួលអប្បបរមា ប្រាក់រង្វាន់ការងារទៀងទាត់ ប្រាក់ថ្លៃបាយ ឬការផ្តល់ជូនបាយមួយពេល សំរាប់កម្មករនិយោជិតធ្វើការបន្ថែមម៉ោង និងប្រាក់រង្វាន់ការងារយូរឆ្នាំរបស់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌកាត់ដេរ និងដេរស្បែកជើង ត្រូវអនុវត្តតាមខ្លឹមសារនៃចំណុចទាំងអស់ខាងលើ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងគណៈកម្មការប្រឹក្សាការងារនឹងបន្តខិតខំបំពេញនូវភារកិច្ចរបស់ខ្លួនអោយស្របតាមតួនាទី ដូចដែលមានចែងក្នុងច្បាប់របស់រដ្ឋពិសេសគឺ ច្បាប់ស្តីពីការងារ សំដៅថែរក្សាផលប្រយោជន៍សមស្រប យុត្តិធម៌នៃរាល់ភាគីពាក់ព័ន្ធ ឱ្យកាន់តែល្អប្រសើរឡើងជាលំដាប់ ។

**រដ្ឋមន្ត្រី**
**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**
**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ : ២០ សកបយ

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០០

# សេចក្តីជូនដំណឹង

អនុលោមតាមជំពូកទី ១៣ នៃច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា ។ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានចេញនូវសារាចរលេខ ០០៥ ចុះថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០០ ស្តីអំពីសិទ្ធិកូដកម្មរបស់កម្មករនិយោជិត ។ ការចេញសារាចរនេះ គឺមានបំណងណែនាំអំពីនីតិវិធីនៃការធ្វើកូដកម្មរបស់កម្មករនិយោជិត ដោយជៀសវាងអំពើហិង្សាតែប៉ុណ្ណោះ ។ ទន្ទឹមនឹងនេះកន្លងមក ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានទទួលមតិពីសហជីពកម្មករនិយោជិត និងកម្មករនិយោជិត និយោជក និងអង្គការនិយោជក ព្រមទាំងមតិពីសំណាក់អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលបានលើកឡើង និងធ្វើការបកស្រាយតាមជំហរផ្សេងៗពីគ្នាចំពោះករណីនេះ ។

ដើម្បីឆ្លើយតប ចំពោះករណីខាងលើនេះក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជូនដំណឹងដូចតទៅ :

១-ទន្ទឹមនឹងសិទ្ធិធ្វើកូដកម្ម ដូចមានចែងក្នុងច្បាប់ស្តីពីការងារ កម្មករនិយោជិត ក៏មានសិទ្ធិធ្វើបាតុកម្មដូចពលរដ្ឋទូទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

២-ការកំណត់គុណវឌ្ឍន៍នៃកូដកម្មថា ត្រឹមត្រូវតាមច្បាប់ ឬ ខុសច្បាប់ជាសមត្ថកិច្ចនៃតុលាការ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមអំពាវនាវដល់កម្មករនិយោជិត សហជីពកម្មករនិយោជិត និយោជក និងអង្គការនិយោជក អនុវត្តអោយបានត្រឹមត្រូវនូវសិទ្ធិសេរីភាពទាំងឡាយ ដែលមានចែងក្នុងច្បាប់ ។ មធ្យោបាយល្អបំផុតសំរាប់ដោះស្រាយបញ្ហាផ្សេងៗដែលចោទឡើង មានតែការចរចាជាសមូហភាពដោយសន្តិវិធីតែប៉ុណ្ណោះ ។ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា នឹងខិតខំប្រឹងប្រែងថែមទៀត ដើម្បីពង្រឹងការអនុវត្តច្បាប់ស្តីពីការងារឱ្យកាន់តែល្អប្រសើរ ។

រដ្ឋមន្ត្រី
ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
ហត្ថលេខា និង ត្រា
អ៊ិត សំហេង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ : ២៦ សកបយ

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០០

# សេចក្តីណែនាំ
# ស្តីពី
# ការផ្តល់ដំណឹងអំពីកន្លែងធ្វើការទំនេរ

ក្នុងគោលបំណងអនុវត្តឱ្យបានល្អបទបញ្ញត្តិ មាត្រា ២៥៨- ២៥៩ និង ២៦០ នៃច្បាប់ស្តីពីការងារ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមធ្វើការណែនាំដល់ម្ចាស់ និងនាយកក្រុមហ៊ុន សហគ្រាស គ្រឹះស្ថានទាំងអស់ ដែលស្ថិតក្រោមបទបញ្ញត្តិមាត្រា ១ នៃច្បាប់ស្តីពីការងារ អំពីការផ្តល់ដំណឹងស្តីពីទីកន្លែងធ្វើការទំនេរ ដូចតទៅ :

១-នៅពេលដែលត្រូវការជ្រើសរើសកម្មករ-និយោជិតចូលធ្វើការ ដំបូងបំផុតត្រូវពិនិត្យមើលឱ្យអស់លទ្ធភាព នូវពលរដ្ឋខ្មែរទាំងពីរភេទ ដើម្បីធ្វើការជ្រើសរើសចូលបំរើការងារ ។

២-ការជ្រើសរើសកម្មករ-និយោជិតចូលធ្វើការ អាចប្រព្រឹត្តទៅតាម ២ របៀប ។ របៀប ទី ១ គឺ ការជ្រើសរើសនៅនឹងមាត់ទ្វារសហគ្រាស មានន័យថា ការប្រកាសតាមបែបផ្សេងៗនៅមាត់ទ្វារក្រុមហ៊ុន សហគ្រាស គ្រឹះស្ថាន ហើយទុកឱ្យអ្នករកការងារធ្វើចូលមកដាក់ពាក្យសុំបំរើការងារនៅទីនោះ រួចហើយគេធ្វើការពិនិត្យ និងជ្រើសរើសទៅតាមវិធីផ្សេងៗដែលអាចធ្វើទៅបាន ។ របៀបទី ២ គឺ ជាការទទួលយកបេក្ខភាពពីនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ចំពោះអ្នកនៅភ្នំពេញ ឬ មន្ទីរសង្គមកិច្ច ការងារ បណ្តុះ-បណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង នីមួយៗ ចំពោះអ្នកនៅខេត្ត-ក្រុង យកទៅធ្វើការពិនិត្យ និងជ្រើសរើសចូលធ្វើការទៅតាមតម្រូវការជាក់ស្តែងនីមួយៗ ។

៣-ការជ្រើសរើសចូលធ្វើការថ្មីនេះ ទោះនៅក្នុងការជ្រើសរើសតាមរបៀបណាមួយក៏ដោយ ត្រូវជៀសវាងដាច់ខាត ការគាបសង្កត់ទារយកប្រាក់ពីអ្នកដាក់ពាក្យសុំបំរើការងារ និងត្រូវជូនដំណឹងដល់នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ចំពោះអ្នកនៅភ្នំពេញ ឬ មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង និងយុវនីតិសម្បទាខេត្ត-ក្រុង វិញដែរ អំពីលទ្ធផលនៃការជ្រើសរើសចូលធ្វើការថ្មីនេះ ។ ការជូនដំណឹងអំពីការជ្រើសរើសចូលធ្វើការថ្មី ត្រូវធ្វើឡើងមិនឱ្យយឺតជាង ១៥ ថ្ងៃឡើយ តែចំពោះសហគ្រាសកសិកម្ម ដែល

មានលក្ខណៈឆ្ងាយលំបាក រយៈពេលនេះអាចកំណត់ដល់ ៣០ ថ្ងៃ ដោយអនុវត្តតាមសេចក្តីប្រកាសជូនដំណឹងស្តីពី សេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិកចូល ។

៤-នៅពេលក្រុមហ៊ុន សហគ្រាស គ្រឹះស្ថាន មានសេចក្តីត្រូវការអ្នកធ្វើការថ្មី សូមជូនដំណឹងមកនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ចំពោះអ្នកនៅភ្នំពេញ ឬមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត-ក្រុង ចំពោះអ្នកនៅខេត្ត-ក្រុង តាមរយៈនៃការផ្ញើសេចក្តីត្រូវការ ដែលធ្វើឡើងតាមតារាងឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្តីណែនាំនេះក៏បាន ឬតាមរយៈនៃការប្រើទូរស័ព្ទក៏បានមកកាន់អាសយដ្ឋាន និងលេខទូរស័ព្ទដូចតទៅ:

**-ចំពោះអ្នកនៅរាជធានីភ្នំពេញ:**

-ការជូនដំណឹងតាមតារាងឧបសម្ព័ន្ធ ត្រូវជូនមក នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ដែលមានអាសយដ្ឋាន អគារលេខ ២៨ ផ្លូវសម្តេចព្រះធម្មលិខិតអ៊ុក សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ

-ការជូនដំណឹងតាមទូរស័ព្ទ ត្រូវទូរស័ព្ទមកកាន់លេខ : ០២៣ ៧២៣ ៩៩២

**-ចំពោះអ្នកនៅខេត្ត-ក្រុងនានា:**

ដំណឹងនេះត្រូវជូនទៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទានៃខេត្ត-ក្រុង នីមួយៗរៀងៗខ្លួន ទៅតាមមធ្យោបាយជាក់ស្តែងដែលអាចធ្វើទៅបាន ។

ចំពោះការដែលបានជ្រើសរើសចូលធ្វើការថ្មីរួចហើយ ហើយមិនបានជូនដំណឹងឱ្យបានត្រឹមត្រូវទៅតាមសេចក្តីណែនាំខាងលើនេះ ជាការប្រព្រឹត្តល្មើសទៅនឹងមាត្រា ២១ នៃច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ក្រុមហ៊ុន សហគ្រាស គ្រឹះស្ថាន នានានឹងអនុវត្តឱ្យបានល្អប្រសើរខ្លឹមសារនៃសេចក្តីណែនាំនេះ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កន្លែងទទួល : នាយកដ្ឋានមុខរបរ និងចាត់ពលកម្ម
ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

**តារាងស្តីពីទីកន្លែងធ្វើការទំនេរដែលត្រូវការពលកម្ម មិនហួសពីថ្ងៃទី .......... ខែ .......... ឆ្នាំ ២០០...**

គ្រឹះស្ថាន ..........................................................................................................

អាសយដ្ឋាន..........................................................................................................

ទូរស័ព្ទលេខ.............................................ទូរសារលេខ.........................................

| ល.រ | ឈ្មោះកន្លែងទំនេរដែលត្រូវការពលកម្ម | ភេទ | ក្រុមអាយុ | ចំនួនពលកម្ម | មុខជំនាញវិជ្ជាជីវៈដែលត្រូវការ | ម៉ោងធ្វើការ | ប្រាក់ឈ្នួល |
|---|---|---|---|---|---|---|---|
| | | | | | | | |

រាជធានីភ្នំពេញ . ថ្ងៃទី.................ខែ..................ឆ្នាំ២០០...

នាយកគ្រឹះស្ថាន /សហគ្រាស /ក្រុមហ៊ុន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ : ២៧ សកបយ

រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០០០

# សេចក្តីជូនដំណឹង
# ស្តីពី
# សេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក

(កម្មករនិយោជិត)

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជំរាបដល់ម្ចាស់ ឬនាយកក្រុមហ៊ុន គ្រឹះស្ថាន សហគ្រាស និងស្ថាប័នទាំងអស់ដែលស្ថិតក្រោមបទបញ្ញត្តិមាត្រា ១ នៃច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបអំពីការប្រតិបត្តិមាត្រា ២១ នៃច្បាប់នេះ ឱ្យបានជ្រាបដូច តទៅ:-

១-នៅពេលដែលមានជ្រើសរើសកម្មករនិយោជិតថ្មី ឬ មានទទួលយកកម្មករនិយោជិតដែលធ្លាប់បានធ្វើការងារនៅទីកន្លែងណាមួយ ឬនៅពេលដែលមានកម្មករ និយោជិតឈប់ពីការងារ ឬត្រូវផ្លាស់ឱ្យទៅធ្វើការងារនៅកន្លែងថ្មី ម្ចាស់ ឬនាយកក្រុមហ៊ុន សហគ្រាស គ្រឹះស្ថាន និងស្ថាប័ននីមួយៗ ត្រូវធ្វើសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិកជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលមិនលើសពី ១៥ ថ្ងៃ គិតចាប់ពីថ្ងៃដែលទទួលឱ្យធ្វើការងារ ឬបញ្ឈប់ ឬផ្លាស់ចេញពីការងារ ។ ចំពោះសហគ្រាស គ្រឹះស្ថាន ធ្វើការងារកសិកម្ម រយៈពេលនេះ ត្រូវបានកំណត់ ៣០ ថ្ងៃ ។

២- សេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិកនេះមិនអាចអនុវត្តទេ ចំពោះ:

-ការងារម្តងម្កាលដែលមានថិរវេលាជាប់គ្នាមិនលើសពី ៣០ ថ្ងៃ (សាមសិបថ្ងៃ)

-ការងារធ្វើឈប់ៗដែលថិរវេលាពិតប្រាកដសំរាប់ការងារនេះមិនលើស ៩០ ថ្ងៃ (កៅសិបថ្ងៃ) នៅក្នុងរយៈពេល ១២ ខែបន្តបន្ទាប់គ្នា ។

៣-នៅពេលដែលធ្វើបានជាសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិករួចហើយ ម្ចាស់ ឬនាយកក្រុមហ៊ុន សហគ្រាស គ្រឹះស្ថាន និងស្ថាប័ននីមួយៗ ត្រូវយកសេចក្តីប្រកាសជូនដំណឹងនេះទៅចុះបញ្ជិកានៅនាយកដ្ឋានមុខរបរ និងហត្ថពលកម្ម ចំពោះអ្នកនៅភ្នំពេញ និងនៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាល

វិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង ចំពោះអ្នកនៅខេត្ត-ក្រុង ក្នុងរយៈពេលមិនលើសពី ៧ ថ្ងៃ ក្រោយពេលដែលបានធ្វើសេចក្តីប្រកាសជូនដំណឹងនេះរួច ។

៤-នៅពេលដាក់ពាក្យស្នើសុំចុះទិដ្ឋាការលើសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិកចូល នៃជនបរទេស ឬដែលមានជនបរទេស និយោជក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ឬស្ថាប័ននីមួយៗត្រូវមានភ្ជាប់ជាមួយសំណើនូវសេចក្តីថតចម្លងលិខិតឆ្លងដែនរបស់សាមីជនបរទេស និង កិច្ចសន្យាការងាររវាងនិយោជក និងសាមីជនបរទេសម្នាក់ៗ ជាភាសាខ្មែរ ឬដែលមានអមជាភាសាខ្មែរ ។

៥-ចំពោះការប្រព្រឹត្តល្មើសទៅនឹងមាត្រា ២១ នៃច្បាប់ស្តីពីការងារ ដូចដែលបានណែនាំឱ្យអនុវត្តតាមសេចក្តីជូនដំណឹងនេះ នឹងត្រូវទទួលផ្តន្ទាទោសពិន័យ ដូចដែលបានកំណត់ក្នុងមាត្រា ៣៦៣ នៃច្បាប់ស្តីពីការងារ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយកក្រុមហ៊ុន គ្រឹះស្ថាន សហគ្រាស និង ស្ថាប័ន ដែលស្ថិតក្រោមបទប្បញ្ញត្តិមាត្រា ១ នៃច្បាប់ការងារ នឹងអនុវត្តឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ស្របទៅតាមខ្លឹមសារដែលបានកំណត់ក្នុងសេចក្តីជូនដំណឹងនេះ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

p

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ : ០០៣ សកបយ

រាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០១

# សេចក្តីណែនាំ
# ស្តីពី
# នីតិវិធីក្នុងការអនុវត្តប្រកាសលេខ ០០៤ សកបយ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០០ ស្តីពីការហ្វឹកហ្វឺនកូនជាង

យោងសេចក្តីជូនដំណឹងលេខ ០១០ សកបយ ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០០០ ស្តីពីការពន្យាពេលអនុវត្តប្រកាសលេខ ០០៤ សកបយ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០០០ ស្តីពីការហ្វឹកហ្វឺនកូនជាងបានកំណត់កាលបរិច្ឆេទចុងក្រោយ ដើម្បីចាប់ផ្តើមអនុវត្តប្រកាសអោយបានមុនថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០០១។ ក្នុងគោលបំណងបង្កលក្ខណៈឱ្យងាយក្នុងការអនុវត្តប្រកាស ដែលបានពោលខាងលើនេះ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមណែនាំស្តីពីនីតិវិធីក្នុងការអនុវត្តការហ្វឹកហ្វឺនកូនជាងដូចខាងក្រោមនេះ :- p

១-សហគ្រាស គ្រឹះស្ថាន រោងចក្រ ទាំងឡាយដែលបានកំពុងហ្វឹកហ្វឺនកូនជាង និងធ្វើបែបបទការអនុវត្តការហ្វឹកហ្វឺនកូនជាង តាមប្រកាសលេខ ០០៤ សកបយ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០០០ ត្រូវបន្តអនុវត្តរហូតដល់ចប់វគ្គ ហើយក៏អាចបើកវគ្គបន្តបន្ទាប់ទៀតបានអាស្រ័យលើ សហគ្រាស គ្រឹះស្ថាន រោងចក្រ ។

២-សហគ្រាស គ្រឹះស្ថាន រោងចក្រ ទាំងឡាយដែលបានធ្វើការហ្វឹកហ្វឺនកម្មករ មុនពេលចេញប្រកាសនោះ ក្រសួងយល់ព្រមទទួលស្គាល់ថា អង្គភាពនោះបានអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាងរួចហើយ តែសាមីអង្គភាពត្រូវផ្ញើបញ្ជីឈ្មោះកម្មករដែល សហគ្រាស គ្រឹះស្ថាន រោងចក្រ បានហ្វឹកហ្វឺនរួចហើយ ទៅនាយកដ្ឋានបច្ចេកទេសវិជ្ជាជីវៈ និងទីផ្សារការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា យ៉ាងយឺតបំផុតត្រឹមថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ២០០១ ។ ក្នុងករណីដែលពុំបានធ្វើទាន់ពេលវេលាកំណត់ ក្រសួងចាត់ទុកថា សហគ្រាស គ្រឹះស្ថាន រោងចក្រ គ្មានកម្មករដែលបានហ្វឹកហ្វឺនក្នុងឆ្នាំកន្លង:-

ក-បើសហគ្រាស គ្រឹះស្ថាន រោងចក្រ ទាំងឡាយណាមានកម្មករហ្វឹកហ្វឺនហើយតែពុំទាន់គ្រប់តាមអត្រាកំណត់របស់ប្រកាសលេខ ០០៤ សកបយ ត្រូវធ្វើបែបបទហ្វឹកហ្វឺនបន្ថែមឱ្យគ្រប់តាមអត្រាកំណត់ ។

ខ-សហគ្រាស គ្រឹះស្ថាន រោងចក្រ ទាំងឡាយណាធ្វើការហ្វឹកហ្វឺនកូនជាងបានគ្រប់ ឬលើសអត្រាកំណត់តាមប្រកាស ០០៤ សកបយ ត្រូវដាក់ពាក្យសុំធ្វើតេស្តបញ្ជាក់កិរិតមុខជំនាញវិជ្ជាជីវៈពីនាយកដ្ឋានបច្ចេកទេសវិជ្ជាជីវៈ និងទីផ្សារការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិ-សម្បទា ។

៣-នីតិវិធីក្នុងការធ្វើតេស្ត ចំពោះកម្មករដែលបានហ្វឹកហ្វឺនរួចហើយ មានដូចតទៅៈ-

ក-កម្មករដែលបានសំរេចលទ្ធផលថា (ជាប់) នឹងទទួលបាននូវវិញ្ញាបនប័ត្រ និង បណ្ណ័ទទួលស្គាល់កិរិតមុខជំនាញវិជ្ជាជីវៈ ដែលចុះហត្ថលេខា និងត្រាដោយនាយក ឬម្ចាស់សហគ្រាស គ្រឹះស្ថាន រោងចក្រ និងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

ខ-កម្មករណាដែលពុំបានសំរេចលទ្ធផលថាជាប់ (ធ្លាក់) គឺពុំបានផ្តល់វិញ្ញាបនប័ត្រ និងបណ្ណ័ទទួលស្គាល់កិរិតមុខជំនាញវិជ្ជាជីវៈទេ ។ ប៉ុន្តែកម្មករទាំងនោះអាចដាក់ពាក្យមកសុំធ្វើតេស្តម្តងទៀតក្រោយរយៈពេលពីរខែ បន្ទាប់ពីថ្ងៃធ្វើតេស្ត ។ ការធ្វើតេស្តមានការត្រួតពិនិត្យយ៉ាងហ្មត់ចត់ពីគណៈកម្មាធិការអព្យាក្រឹត្យដូចមានចែងក្នុងប្រការ ៦ នៃប្រកាសលេខ ០០៤ សកបយ ។

៤-វិញ្ញាបនប័ត្របញ្ជាក់កិរិតមុខជំនាញមានពីរប្រភេទតាមគំរូណែនាំរបស់ក្រសួងសង្គមកិច្ច ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា :-

ក-វិញ្ញាបនប័ត្រសំរាប់រក្សាទុកនៅគេហដ្ឋានដែលមានទំហំស្មើនឹង A4 (២១០mm X ២៩៧mm)

ខ-បណ្ណ័ទទួលស្គាល់កិរិតមុខជំនាញវិជ្ជាជីវៈដែលមានទំហំ (១០០ mm X ៦៥ mm) សំរាប់ប្រើជាផ្លូវការ ដែលចុះហត្ថលេខាដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

ក្នុងករណីអធិការការងារហ្វឹកហ្វឺនកូនជាងត្រួតពិនិត្យឃើញកម្មករណា ដែលមានបណ្ណ័ទទួលស្គាល់កិរិតមុខជំនាញវិជ្ជាជីវៈហើយ តែកម្មករនោះបានធ្វើការខុសជំនាញពីមុនចាំបាច់តម្រូវឱ្យសហគ្រាស គ្រឹះស្ថានរោងចក្រ ធ្វើការហ្វឹកហ្វឺន ឬ ធ្វើតេស្តបញ្ជាក់កិរិតមុខជំនាញវិជ្ជាជីវៈឡើងវិញ ទោះជាកម្មករទាំងនោះនៅរោងចក្រដើម ឬ ទៅរោងចក្រផ្សេងក៏ដោយ ។

៥-ចំពោះសហគ្រាស គ្រឹះស្ថាន រោងចក្រ ដែលទើបនឹងបង្កើតថ្មីត្រូវអនុវត្តទាំងស្រុងតាមប្រកាសលេខ ០០៤ សកបយ ពីព្រោះនោះជាតម្រូវការចាំបាច់របស់សហគ្រាស គ្រឹះស្ថាន រោងចក្រផង ហើយជាកាតព្វកិច្ចដែលបានចែងនៅក្នុងច្បាប់ស្តីពីការងារ ។

ចំពោះពត៌មានបន្ថែមស្តីពីបែបបទ សូមទំនាក់ទំនងជាមួយនាយកដ្ឋានបច្ចេកទេសវិជ្ជាជីវៈ និងទីផ្សារការងារ ដែលមានអាសយដ្ឋានអគារលេខ ៧៨៨ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខណ្ឌ ចំការមន

រាជធានីភ្នំពេញ និងទូរសព្ទ័លេខ (០២៣)២១៨ ៤៣៧ , (០១២) ៨៤៧ ២៦៤ និង (០១១) ៩៧៤ ៨១០ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា សង្ឃឹមថា នាយក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន រោងចក្រទាំងអស់ត្រូវរៀបចំដំណើរការអនុវត្តតាមសេចក្តីណែនាំនេះឱ្យបានទាន់ពេលវេលាកំណត់ និងធានានូវប្រសិទ្ធិភាពខ្ពស់ជាពុំខាន ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច ការងារ**
**បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**លេខ : ១៤ សគបយ**

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០១

# សេចក្តីជូនដំណឹង

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានកិត្តិយសជូនដំណឹងដល់គ្រប់រោងចក្រ សហគ្រាស គ្រឹះស្ថានទាំងអស់ថា យោងតាមសំណូមពររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតតាមលិខិតលេខ ០៧.៣៩៨/០១ គជប ចុះថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ ២០០១ លោកនាយក ឬ ម្ចាស់រោងចក្រ សហគ្រាស គ្រឹះស្ថានទាំងអស់ ត្រូវសំរួលអោយកម្មករនិយោជិតបានទៅចុះឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ ដែលនឹងប្រព្រឹត្តទៅចាប់ពី ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០១ ដល់ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០១ ទៅតាមលក្ខណៈជាក់ស្តែងនៃអាសយដ្ឋានពិតប្រាកដ និងកាលបរិច្ឆេទនៃការចុះឈ្មោះបោះឆ្នោតដូចខាងក្រោម :-

- ចំពោះកម្មករ និយោជិត ដែលមានអាសយដ្ឋាន ក្នុងរាជធានីភ្នំពេញ ហើយការិយាល័យចុះឈ្មោះនៅជិតៗ ទីតាំងរោងចក្រ សហគ្រាសនោះ និយោជកត្រូវអនុញ្ញាតច្បាប់ទៅចុះឈ្មោះដោយប្តូរវេនគ្នា ឬ ជាក្រុមៗទៅចុះឈ្មោះ ។ អវត្តមានពីការងាររបស់កម្មករនិយោជិត សំរាប់ការទៅចុះឈ្មោះបោះឆ្នោតនេះ ត្រូវចាត់ទុកដូចជាកម្មករនិយោជិតបានធ្វើការធម្មតា ។

- ចំពោះកម្មករនិយោជិត ដែលមានអាសយដ្ឋានឆ្ងាយ ឬ មានអាសយដ្ឋាននៅតាម ខេត្ត-ក្រុងផ្សេងៗ និយោជកត្រូវអនុញ្ញាតច្បាប់អោយទៅចុះឈ្មោះតាមតារាងខាងក្រោមនេះ ។ ការអនុញ្ញាតច្បាប់នេះត្រូវចាត់ទុកជាការអនុញ្ញាតច្បាប់ឈប់សំរាកពិសេសរបស់កម្មករនិយោជិត ។

## តារាងសំរាប់ការអនុញ្ញាតច្បាប់ជូនកម្មករ និយោជិត ទៅចុះឈ្មោះបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សា ឃុំ-សង្កាត់

| ល.រ | ទីតាំងរបស់រោងចក្រ សហគ្រាស គ្រឹះស្ថាន | ចំនួនថ្ងៃដែលត្រូវអនុញ្ញាតច្បាប់ | ផ្សេងៗ |
|---|---|---|---|
| ១ | រាជធានីភ្នំពេញ | ពីកន្លះថ្ងៃ ទៅមួយថ្ងៃ | |
| ២ | ពីរាជធានីភ្នំពេញទៅ ខេត្តកណ្ដាល ខេត្តកំពង់ស្ពឺ និង ខេត្តកំពង់ឆ្នាំង | ពីរថ្ងៃ | |
| ៣ | ពីរាជធានីភ្នំពេញទៅ ខេត្តពោធិសាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម ខេត្តក្រចេះ ខេត្តព្រៃវែង ខេត្តកំពង់ធំ ខេត្តស្វាយរៀង ខេត្តកំពត ខេត្តសៀមរាម ខេត្តតាកែវ និង ក្រុងព្រះសីហនុ | បីថ្ងៃ | |
| ៤ | ពីរាជធានីភ្នំពេញទៅ ខេត្ត-ក្រុង ដទៃទៀតក្រៅពី ខេត្ត-ក្រុង ទាំងអស់ខាងលើ | បួនថ្ងៃ | |

ចំពោះរោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលមានទីតាំងតាម ខេត្ត-ក្រុង ដទៃទៀតក្រៅពីរាជធានីភ្នំពេញ និយោជកត្រូវអនុញ្ញាតច្បាប់ជូនកម្មករនិយោជិត ទៅចុះឈ្មោះតាមចំនួនថ្ងៃដូចមានចែងក្នុងតារាងខាងលើដែរ ដោយយក ខេត្ត-ក្រុង នីមួយៗធ្វើជាមូលដ្ឋានដើមដូចគ្នានិងរាជធានីភ្នំពេញដែរ ។

ឧទាហរណ៍ : កម្មករនិយោជិត ធ្វើការនៅរោងចក្រ សហគ្រាស នៅក្នុងក្រុងព្រះសីហនុ ហើយត្រូវចុះឈ្មោះបោះឆ្នោតនៅក្រុងព្រះសីហនុ និយោជកត្រូវអនុញ្ញាតច្បាប់ជូនកម្មករនិយោជិត ពីកន្លះថ្ងៃទៅមួយថ្ងៃ ។ ប៉ុន្តែបើកម្មករនិយោជិតត្រូវទៅចុះឈ្មោះបោះឆ្នោតនៅភ្នំពេញ និយោជកត្រូវអនុញ្ញាតច្បាប់ជូនកម្មករនិយោជិតចំនួនបីថ្ងៃ ។

ចំពោះកម្មករនិយោជិតដែលអវត្តមានហួសពីច្បាប់អនុញ្ញាត ដូចមានចែងខាងលើត្រូវទទួលខុសត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់រោងចក្រ សហគ្រាស ។

ក្រសួងមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា អស់លោកជាម្ចាស់ និង នាយករោងចក្រ សហគ្រាស គ្រឹះស្ថានទាំងអស់ នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះ ប្រកបដោយប្រសិទ្ធិភាព ប្រកបដោយការយោគយល់ ជាពុំខាន ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ : ៣២ សកបយ

រាជធានីភ្នំពេញ , ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១

# សេចក្តីជូនដំណឹង

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានកិត្តិយសជូនដំណឹងដល់គ្រប់រោងចក្រ សហគ្រាស គ្រឹះស្ថានទាំងអស់ថា យោងតាមសំណូមពររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតតាមលិខិតលេខ ១២១១៥២/០១ គ.ជ.ប. ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០១ លោកនាយក ឬម្ចាស់រោងចក្រ សហគ្រាស គ្រឹះស្ថានទាំងអស់ត្រូវអនុញ្ញាតអោយកម្មករនិយោជិត ដែលមានប័ណ្ណបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ បានទៅចូលរួមការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ឃុំ-សង្កាត់ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០២ ខាងមុខនេះ ។

ចំនួនថ្ងៃត្រូវអនុញ្ញាតជូនកម្មករនិយោជិត ត្រូវស្របតាមលក្ខណៈជាក់ស្តែងនៃប័ណ្ណចុះឈ្មោះបោះឆ្នោតដូចមានកំណត់ខាងក្រោមនេះ :

១- ចំពោះកម្មករនិយោជិត នៃរោងចក្រ សហគ្រាស គ្រឹះស្ថាន នៅរាជធានីភ្នំពេញដែលមានប័ណ្ណចុះឈ្មោះបោះឆ្នោតនៅរាជធានីភ្នំពេញ និយោជកត្រូវអនុញ្ញាតច្បាប់អោយកម្មករ និយោជិតនោះឈប់សំរាក ០១ ថ្ងៃ គឺថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០២ ( ទោះសហគ្រាស គ្រឹះស្ថានដែលមានកម្មករនិយោជិត ធ្វើការថ្ងៃអាទិត្យក៏ដោយ ) ។

២-ចំពោះកម្មករនិយោជិត ដែលមានប័ណ្ណចុះឈ្មោះបោះឆ្នោតនៅតាមខេត្ត-ក្រុងផ្សេងៗ និយោជកត្រូវអនុញ្ញាតច្បាប់អោយកម្មករនិយោជិត ទៅបោះឆ្នោតតាមតារាងដូចខាងក្រោមនេះ :-

| ល.រ | ទីតាំងរបស់រោងចក្រ សហគ្រាស គ្រឹះស្ថាន | ចំនួនថ្ងៃដែលត្រូវអនុញ្ញាតច្បាប់ |
|---|---|---|
| ១ | ពីរាជធានីភ្នំពេញទៅខេត្តកណ្តាល-ខេត្តកំពង់ស្ពឺ-ខេត្តកំពង់ឆ្នាំង ខេត្តពោធិសាត់-ខេត្តកំពង់ចាម-ខេត្តព្រៃវែង-ខេត្តស្វាយរៀង ខេត្តកំពង់ធំ-ខេត្តតាកែវ-ខេត្តកំពត-ក្រុងកែប-និងក្រុងព្រះសីហនុ | បីថ្ងៃ គឺថ្ងៃទី ០២. ០៣. និង ០៤ ខែ កុម្ភៈ ឆ្នាំ ២០០២ |
| ២ | ពីរាជធានីភ្នំពេញទៅខេត្ត-ក្រុង ដទៃទៀតក្រៅពីខេត្ត-ក្រុង ទាំងអស់ខាងលើ | បួនថ្ងៃគឺថ្ងៃទី ០១. ០២. ០៣.និង ០៤ ខែ កុម្ភៈ ឆ្នាំ ២០០២ |

ចំពោះរោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលមានទីតាំងនៅ ខេត្ត-ក្រុង ដទៃទៀតក្រៅពីរាជធានី-ភ្នំពេញ និយោជកត្រូវអនុញ្ញាតច្បាប់ជូនកម្មករនិយោជិតទៅបោះឆ្នោតតាមចំនួនថ្ងៃដូចមានចែងក្នុងចំណុចទី១ និង ទី២ ខាងលើដែរ ដោយយកខេត្ត-ក្រុងនីមួយៗ ធ្វើជាមូលដ្ឋានដើមដូចគ្នា និងរាជធានីភ្នំពេញដែរ ។

ឧទាហរណ៍ : កម្មករនិយោជិតធ្វើការនៅរោងចក្រ សហគ្រាស គ្រឹះស្ថាន នៅក្នុងក្រុងព្រះសីហនុ ហើយត្រូវបោះឆ្នោតនៅក្រុងព្រះសីហនុ និយោជកត្រូវអនុញ្ញាតច្បាប់ជូនកម្មករនិយោជិតចំនួន ១ ថ្ងៃ ប៉ុន្តែបើកម្មករនិយោជិត ត្រូវទៅបោះឆ្នោតនៅរាជធានីភ្នំពេញ និយោជកត្រូវអនុញ្ញាតច្បាប់ជូនកម្មករនិយោជិតចំនួន ៣ ថ្ងៃ ។

រាល់ការអនុញ្ញាតច្បាប់ជូនកម្មករនិយោជិត ដូចមានចែងខាងលើ និយោជកត្រូវរក្សាទុកប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់ជូនកម្មករនិយោជិតនៅដដែល ។

ចំពោះកម្មករនិយោជិត ដែលអវត្តមានហួសពីច្បាប់អនុញ្ញាតដូចមានចែងខាងលើ ត្រូវទទួលខុសត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស ។

ក្រសួងមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា អស់លោកជាម្ចាស់ និងជានាយករោងចក្រ សហគ្រាស គ្រឹះស្ថាន ទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធិភាពពុំខាន ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច ការងារ**
**បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

លេខ : ០៣ សកបយ

រាជធានីភ្នំពេញ , ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០២

## <u>សេចក្តីជូនដំណឹង</u>

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានកិត្តិយសជូនដំណឹងដល់ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានទាំងអស់ដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារអោយបានជ្រាបថា ដើម្បីបង្កលក្ខណៈងាយស្រួលដល់បងប្អូនកម្មករនិយោជិត ក្នុងការចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ/សង្កាត់ នៅថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០០២ ខាងមុខនេះ សូមម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានអនុវត្តដូចតទៅ :

១-ផ្អាកដំណើរការផលិតកម្ម អាជីវកម្ម ដើម្បីជូនកម្មករនិយោជិតឈប់សំរាកថ្ងៃអាទិត្យ ទី០៣ ខែ កុម្ភៈ ឆ្នាំ២០០២ ទោះបីមានកិច្ចការមមាញឹក ឬចាំបាច់ក្នុងសហគ្រាស គ្រឹះស្ថានក៏ដោយ ។

២-អនុញ្ញាតច្បាប់ជូនកម្មករនិយោជិតទៅបោះឆ្នោតតាមខ្លឹមសារដូចមានកំណត់ក្នុងសេចក្តីជូនដំណឹងរបស់ក្រសួងលេខ ៣២ សកបយ. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០០១ ទោះកម្មករនិយោជិតពុំមានបណ្ណ័ចុះឈ្មោះបោះឆ្នោតបង្ហាញពេលសុំច្បាប់ក៏ដោយ ។ ប័ណ្ណនេះកម្មករនិយោជិត ត្រូវបង្ហាញនៅពេលត្រឡប់ពីចូលរួមបោះឆ្នោតវិញ ។

៣-ខិតខំរៀបចំបើកប្រាក់ឈ្នួលអោយកម្មករនិយោជិត អោយបានមុនថ្ងៃទៅបោះឆ្នោត ។ បើពុំមានលទ្ធភាពបើកប្រាក់ឈ្នួលទាន់ទេ សូមអនុញ្ញាតអោយកម្មករនិយោជិតខ្ចីប្រាក់ឈ្នួលមួយភាគ មុនពេលទៅបោះឆ្នោត ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាមានជំនឿជឿជាក់ថា ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថាន ទាំងអស់នឹងអនុវត្តបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធិភាពខ្ពស់តាមសេចក្តីជូនដំណឹងនេះ ។

**រដ្ឋមន្ត្រី**
**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**
**មន្ត្រលេខា និង ត្រា**

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ

បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ : ០៧ សកបយ

រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០២

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបន្តអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង និងការធ្វើតេស្តលើកម្មករចាស់ ចំពោះសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ដែលពុំទាន់បានចាប់ផ្តើមអនុវត្តក្នុងឆ្នាំ ២០០១

យោងប្រកាសលេខ ០០៤ សកបយ.ចុះថ្ងៃទី ០៥ ខែមករា ឆ្នាំ២០០០ ស្តីពីការហ្វឹកហ្វឺនកូនជាង សេចក្តីណែនាំលេខ ០០៣ សកបយ.ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០១ ស្តីពីនីតិវិធីក្នុងការអនុវត្តប្រកាសលេខ ០០៤ សេចក្តីជូនដំណឹងលេខ ៣៥ សកបយ.បទ ចុះថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ២០០១ ស្តីពីការសម្របសម្រួលថ្លៃផលិតសំណុំបែបបទការហ្វឹកហ្វឺនកូនជាង ការធ្វើតេស្តលើកូនជាង និងកម្មករចាស់ វិញ្ញាបនប័ត្រ និងប័ណ្ណទទួលស្គាល់ការគីតមុខជំនាញវិជ្ជាជីវៈ ។

ក្នុងគោលបំណងជំរុញការអនុវត្តប្រកាស និងបញ្ញត្តិដូចបានពោលខាងលើ ចប់សព្វគ្រប់សំរាប់កាតព្វកិច្ចឆ្នាំ ២០០១ បានជោគជ័យ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមធ្វើការក្រើនរំលឹកដល់បណ្តាសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនមួយចំនួន ដែលពុំទាន់បានបំពេញកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង និងធ្វើតេស្តលើកម្មករចាស់ ត្រូវចាប់ផ្តើម និងបន្តបំពេញកាតព្វកិច្ចនេះឱ្យពេញលេញ និងចប់សព្វគ្រប់តាមនីតិវិធីដូចតទៅ :

១- សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ដែលបានផ្ញើបញ្ជីឈ្មោះកម្មករចាស់ដែលសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនធ្លាប់បានហ្វឹកហ្វឺនមុនពេលចេញប្រកាសលេខ ០០៤ សកបយ.ចុះថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០០០ ស្តីពីការហ្វឹកហ្វឺនកូនជាង អាចមកទំនាក់ទំនងបំពេញកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង ឬធ្វើតេស្តលើកម្មករចាស់ អាស្រ័យទៅលើតម្រូវការចាំបាច់របស់សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ។

២- សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនដែលពុំធ្លាប់ធ្វើការហ្វឹកហ្វឺនកូនជាង មុនពេលចេញប្រកាសលេខ ០០៤ សកបយ.ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០០ ស្តីពីការហ្វឹកហ្វឺនកូនជាង ឬមិនបានផ្ញើបញ្ជីឈ្មោះកម្មករចាស់ដែលសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ធ្លាប់ធ្វើការហ្វឹកហ្វឺនមកនាយកដ្ឋាន

បច្ចេកទេសវិជ្ជាជីវៈ និងទីផ្សារការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មុនថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០១ តាមសេចក្តីជូនដំណឹងលេខ ០០៣ សកបយ. ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០១ ស្តីពីនីតិវិធីក្នុងការអនុវត្តប្រកាសលេខ ០០៤ សកបយ. ត្រូវមកទំនាក់ទំនងដើម្បីបំពេញកាតព្វកិច្ចហ្វឹកហ្វឺនកូនជាងជាកំហិត ។

៣- ចំពោះសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ដែលបោះទីតាំងនៅតាមខេត្ត-ក្រុងនានា ហើយពុំទាន់បានទទួល ឬ អនុវត្តសេចក្តីណែនាំលេខ ០០៣ សកបយ. ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០១ ស្តីពីនីតិវិធីក្នុងការអនុវត្តប្រកាសលេខ ០០៤ ក្នុងចំណុចទី ២ ក្រសួងអនុញ្ញាតឱ្យផ្ញើបញ្ជីឈ្មោះកម្មករចាស់ដែលសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ធ្លាប់បានហ្វឹកហ្វឺនមុនពេលចេញប្រកាសលេខ ០០៤ សកបយ. ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០០ ស្តីពីការហ្វឹកហ្វឺនកូនជាង ទៅនាយកដ្ឋានបច្ចេកទេសវិជ្ជាជីវៈ និងទីផ្សារការងារ ។

៤- សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ដូចមានចែងក្នុងចំណុចទី១ ចំណុចទី២ និងចំណុចទី៣ ខាងលើ ត្រូវប្រញាប់ប្រញាល់មកទំនាក់ទំនង ដើម្បីបំពេញកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង ឬធ្វើតេស្តលើកម្មករចាស់សំរាប់ឆ្នាំ ២០០១ នៅនាយកដ្ឋានបច្ចេកទេសវិជ្ជាជីវៈ និងទីផ្សារការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ឬនៅតាមមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត-ក្រុង យ៉ាងយូរបំផុតត្រឹមថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០២ ជាកំហិត ។

៥- ក្នុងករណីសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនណាពុំព្រមអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង ការធ្វើតេស្តលើកម្មករចាស់សំរាប់ឆ្នាំ ២០០១ ឬផ្ញើឈ្មោះកម្មករដែលសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ធ្លាប់បានហ្វឹកហ្វឺនកន្លងមកឱ្យបានទាន់ពេលវេលាកំណត់ដូចមានចែងក្នុងចំណុចទី ៤ នៃសេចក្តីជូនដំណឹងនេះ នឹងត្រូវទទួលការផាកពិន័យដូចមានចែងក្នុងមាត្រា ៣៦៣ នៃច្បាប់ស្តីពីការងារ និងត្រូវបង់ពន្ធអាករជំនួសការហ្វឹកហ្វឺនកូនជាងតាមចំនួនដូចមានចែងក្នុងប្រការ ៨ នៃប្រកាសលេខ ០០៤ សកបយ. ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០០ ស្តីពីការហ្វឹកហ្វឺនកូនជាង ។

ចំពោះពត៌មានបន្ថែម សូមទំនាក់ទំនងជាមួយនាយកដ្ឋានបច្ចេកទេសវិជ្ជាជីវៈ និងទីផ្សារការងារ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដែលមានអាសយដ្ឋាន អគារលេខ ២៨ ផ្លូវលេខ ១៨៤ សង្កាត់ ជ័យជំនះ ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ ឬ ទំនាក់ទំនងតាមទូរស័ព្ទលេខ ០២៣ ៧២២ ៩៩១ ០១២ ៨៤៧ ២៦៤ និង ០១១ ៩៧៤ ៨១០ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សង្ឃឹម និងជឿជាក់ថា នាយក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនទាំងអស់ នឹងរៀបចំដំណើរការអនុវត្តតាមសេចក្តីជូនដំណឹងនេះឱ្យបាន ទាន់ពេលវេលាកំណត់ និងមានប្រសិទ្ធិភាពខ្ពស់ជាពុំខានឡើយ ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច ការងារ**

**បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

លេខ : ១៤ សកបយ

រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០២

# សេចក្តីជូនដំណឹង

## ស្តីពី

## ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស គ្រឹះស្ថាន

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជំរាបដល់ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថាន ទាំងអស់ដែលមានចែងនៅក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារបានជ្រាបថា ដើម្បីអនុវត្តមាត្រា ២២ មាត្រា ២៣ មាត្រា ២៤ មាត្រា ២៥ មាត្រា ២៦ មាត្រា ២៧ មាត្រា ២៨ មាត្រា ២៩ មាត្រា ៣០ និងមាត្រា ៣១ នៃច្បាប់ស្តីពីការងារអោយបានត្រឹមត្រូវ និងទទួលលទ្ធផលល្អ ក្រសួងសូមម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងអស់ខាងលើអនុវត្តដូចតទៅ :-

១-ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ដូចពោលខាងលើដែលមានប្រើកម្មករនិយោជិតយ៉ាងតិចប្រាំបី នាក់ ឡើងទៅត្រូវតែរៀបចំអោយមានបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាសមួយជាដរាប ។

២-បទបញ្ជាផ្ទៃក្នុងត្រូវអនុវត្តបទប្បញ្ញត្តិទូទៅនៃច្បាប់ស្តីពីការងារតាមប្រភេទសហគ្រាសគ្រឹះស្ថាន អនុសញ្ញារួមនៃការងារ និងវិធានទូទៅនៃការងារដែលស្តីពីផ្នែកសកម្មភាពនៃសហគ្រាស គ្រឹះស្ថានជាអាទិ៍ គឺបទប្បញ្ញត្តិទាក់ទងនឹងលក្ខខណ្ឌទទួលធ្វើការ ការគិត និង ការបើកប្រាក់ឈ្នួលក៏រៃបន្ទាប់បន្សំទាក់ទងនឹងតាវ-កាលិកធម្មជាតិ ពេលម៉ោងធ្វើការ ពេលសំរាក និងការឈប់សំរាក ការអោយដំណឹងមុន បទបញ្ជា និងវិធានខាងអនាម័យ និងសន្តិសុខកម្មករនិយោជិត កាតព្វកិច្ចកម្មករនិយោជិត និងទណ្ឌកម្មដែលនឹងអាចតំរូវលើកម្មករនិយោជិត ដូចមានគំរូជាឧបសម្ព័ន្ធនៃសេចក្តីជូនដំណឹងនេះ ។

៣-បទបញ្ជាផ្ទៃក្នុងត្រូវរៀបចំឡើងដោយម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានក្រោយពីបានពិគ្រោះនឹងតំណាងកម្មករនិយោជិត ក្នុងរយៈពេលបីខែបន្ទាប់ពីថ្ងៃបើកសហគ្រាស គ្រឹះស្ថាន ។

ក្រោយពេលកសាងរួចហើយម្ចាស់ឬនាយកសហគ្រាស គ្រឹះស្ថានត្រូវបញ្ជូនបទបញ្ជាផ្ទៃក្នុងនោះចំនួនពីរច្បាប់ ដោយមានភ្ជាប់ទាំងមតិយោបល់ជាលាយលក្ខណ៍អក្សររបស់តំណាងកម្មករនិយោជិតផង ទៅសុំចុះទិដ្ឋាការ អំពីមន្ត្រីអធិការកិច្ចការងារមុននឹងដាក់អោយប្រើប្រាស់ជាផ្លូវការ ។

សហគ្រាស គ្រឹះស្ថានទាំងអស់នៅរាជធានីភ្នំពេញ ត្រូវបញ្ជូនបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនទៅស្នើសុំចុះទិដ្ឋាការ នៅនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដែលស្ថិតនៅផ្ទះលេខ ២៨ វិថីសម្តេចព្រះធម្មលិខិតអ៊ុក " ផ្លូវលេខ១៨៤ " សង្កាត់ ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។ ចំណែកសហគ្រាស គ្រឹះស្ថាននៅតាមខេត្ត-ក្រុងផ្សេងទៀត ត្រូវបញ្ជូនទៅមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត-ក្រុងនៃមូលដ្ឋានខ្លួនដើម្បី ស្នើសុំចុះទិដ្ឋាការ ។

៤-បើបទបញ្ជាផ្ទៃក្នុងមានការខ្វះចន្លោះ មន្ត្រីអធិការកិច្ចការងារ នឹងជូនដំណឹងឱ្យម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន យកទៅកែសំរួលអោយសមស្របឡើងវិញ ។ ក្រោយពីបានទទួលដំណឹងនេះម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានត្រូវធ្វើការកែសំរួលឡើងវិញភ្លាម ។

ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានមានសិទ្ធិប្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ពីការមិនសុខចិត្តរបស់ខ្លួនចំពោះការជូនដំណឹងរបស់មន្ត្រីអធិការកិច្ចការងារ ។ ការប្តឹងតវ៉ានេះ មិនជំទាស់នឹងមតិយោបល់របស់មន្ត្រីអធិការកិច្ចការងារ ដែលបានជូនដំណឹងដល់ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានឡើយ នៅពេលពុំទាន់មានសេចក្តីសំរេចជាផ្លូវការពីរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

៥-បទបញ្ជាផ្ទៃក្នុង ដែលបានចុះទិដ្ឋាការពីមន្ត្រីអធិការកិច្ចការងារ អោយប្រើប្រាស់ជាផ្លូវការហើយនោះ ត្រូវតែបិទផ្សាយនៅទីណាមួយដ៏សមរម្យ អាចចូលទៅមើលបានដោយងាយក្នុងកន្លែងធ្វើការហើយ និងនៅមាត់ទ្វារបន្ទប់សំរាប់ទទួលយកកម្មករនិយោជិតអោយធ្វើការ ។

បទបញ្ជាផ្ទៃក្នុងនេះ ត្រូវតែថែរក្សាទុកដាក់អោយបានល្អ អានបានច្បាស់ជាដរាប ។

៦-ការកែប្រែគ្រប់យ៉ាងនៃបទបញ្ជាផ្ទៃក្នុង ត្រូវតែអនុវត្តតាមបែបបទ និងនីតិវិធីដូចគ្នានឹងការរៀបចំកសាងបទបញ្ជាផ្ទៃក្នុងដែរ ។

៧-សេចក្តីជូនដំណឹងរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនលេខ ១២ សកអ. ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ១៩៩៦ និងលេខ ០៩ សកអ. ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ១៩៩៧ ត្រូវចាត់ទុកជានិរាករណ៍ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សង្ឃឹមថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះ អោយបានទាន់ពេលវេលា និងមានប្រសិទ្ធិភាពខ្ពស់ជាពុំខាន ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

**ឧបសម្ព័ន្ធ**

សេចក្តីជូនដំណឹងលេខ ១៤ សកបយ.

ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០០២

(គម្រោងបទបញ្ជាផ្ទៃក្នុង)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## បទបញ្ជាផ្ទៃក្នុង

**របស់សហគ្រាស**............................................................................

### I. បទបញ្ញត្តិស្តីពីវិន័យការងារ

**ប្រការ១** : - លក្ខខណ្ឌទទួលយកកម្មករនិយោជិតអោយធ្វើការ

- បែបបទផ្សេងៗដែលកម្មករនិយោជិតត្រូវបំពេញមុនចូលបំរើការងារ
- អាសយដ្ឋានរបស់កម្មករនិយោជិត ស្ថានភាពគ្រួសារ ការផ្លាស់ប្តូរផ្សេងៗ នៅពេលក្រោយមកទៀត
- ការហ្វឹកហ្វឺនកូនជាង
- ការសាកល្បងការងារ ។

**ប្រការ២** : - បែបបទនៃការអនុវត្តការងារក្នុងសហគ្រាស គ្រឹះស្ថាន

- របៀបរបប និងសណ្តាប់ធ្នាប់ល្អនៅក្នុងសហគ្រាស គ្រឹះស្ថាន ។

**ប្រការ៣** : - ការពិនិត្យកាយសម្បទានៅគ្រាដំបូង

- ការពិនិត្យសុខភាពជាកាលិក ។

**ប្រការ៤** : - ពេលម៉ោងធ្វើការ គិតទាំងការធ្វើការនៅពេលយប់ និងការប្តូរវេនធ្វើការ

- ការឈប់សំរាកប្រចាំសប្តាហ៍
- ការឈប់សំរាកប្រចាំឆ្នាំ ឈប់សំរាកពេលបុណ្យ ឈប់សំរាកពិសេស
- ការសំរាកសំរាលកូនរបស់កម្មករនិយោជិតជាស្ត្រី
- ការឈប់សំរាកដោយជម្ងឺ
- ការឈប់សំរាកដោយគ្រោះថ្នាក់ការងារ ។

**ប្រការ៥** : - ការកំណត់ប្រាក់ឈ្នួល ប្រាក់រង្វាន់ និងប្រាក់បន្ទាប់បន្សំផ្សេងៗ

- ការបើកប្រាក់ឈ្នួល
- ការកាត់ប្រាក់ឈ្នួល ។

**ប្រការ៦** : អវត្តមានរបស់កម្មករនិយោជិត :

- អវត្តមានមានច្បាប់អនុញ្ញាតត្រឹមត្រូវ
- អវត្តមានដោយអត់ច្បាប់អនុញ្ញាត ។

**ប្រការ៧** : ការប្រើប្រាស់សំភារៈ និងឧបករណ៍របស់សហគ្រាស គ្រឹះស្ថានក្នុងការបំពេញការងារ ។

**ប្រការ៨** : ការប្រើប្រាស់អគារ ឬមូលដ្ឋានរបស់សហគ្រាស គ្រឹះស្ថាន ។

**ប្រការ៩** : ការចេញ និងចូលសហគ្រាស គ្រឹះស្ថាន ។

## II. ការដាក់ទោសវិន័យ និងសិទ្ធិការពារខ្លួនរបស់កម្មករ និយោជិត

**ប្រការ១០** : ការកំណត់ទោសវិន័យផ្សេងៗដល់កម្មករនិយោជិត ដែលបានរំលោភលើបទបញ្ជាផ្ទៃក្នុង ឬដែលមានកំហុសធ្ងន់ ។

**ប្រការ១១** : សិទ្ធការពារខ្លួនរបស់កម្មករ និយោជិតនៅមុនពេលត្រូវទទួលទោសវិន័យ ។

## III. អនាម័យ និងសន្តិសុខការងារ

**ប្រការ១២** :

- បទបញ្ជា និងវិធានការនានានៃអនាម័យការងារ និងសន្តិសុខការងារ
- កាតព្វកិច្ចរបស់កម្មករនិយោជិត ក្នុងការគោរព និងអនុវត្តតាមបទបញ្ជា និងវិធានការខាងលើ
- ការបង្ការគ្រោះថ្នាក់ការងារ និងជម្ងឺវិជ្ជាជីវៈ ។

p

..........................ថ្ងៃទី.........ខែ..............ឆ្នាំ២០០....

(ហត្ថលេខារបស់នាយកសហគ្រាស)

**កន្លែងចុះនិដ្ឋការ**
**របស់មន្ត្រីអធិការកិច្ចការងារ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ

បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ : ១៦ សកបយ

រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០២

# សេចក្តីជូនដំណឹង

## ស្តីពី

## ការចុះបញ្ជិកាអង្គការវិជ្ជាជីវៈ និងការបញ្ជាក់ភាពជាតំណាង របស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត

ផ្អែកតាមច្បាប់ស្តីពីការងារ ប្រកាសលេខ ២៧៧ សកបយ. ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០០០ ស្តីពីការចុះបញ្ជិកាអង្គការវិជ្ជាជីវៈ និងប្រកាសលេខ ៣០៥ សកបយ. ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ២០០១ ស្តីពីភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិតនៅថ្នាក់សហគ្រាស គ្រឹះស្ថាន និងសិទ្ធិក្នុងការចរចាជាសមូហភាព ដើម្បីចុះអនុសញ្ញារួមនៅថ្នាក់សហគ្រាស គ្រឹះស្ថាន ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល-វិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជូនដំណឹងដល់សហពន្ធ័សហជីព សហជីពកម្មករនិយោជិត សមាគមនិយោជក និងនិយោជកទាំងអស់ ដែលស្ថិតនៅក្នុងដែនអនុវត្តន៍នៃច្បាប់ស្តីពីការងារ អោយបានជ្រាបថា :-

I-ក្រសួងទើបបានបង្កើតការិយាល័យទំនាក់ទំនងវិជ្ជាជីវៈ នៅចំណុះនាយកដ្ឋានអធិការកិច្ចការងារ កាលពីថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០០២ តាមប្រកាសលេខ ២២២ សកបយ. ។ ការិយាល័យនេះមានភារកិច្ចជាពិសេសក្នុងការទទួលសំណុំលិខិត និងចាត់ចែងការងារនៃការចុះបញ្ជិកាអង្គការវិជ្ជាជីវៈ ការបញ្ជាក់ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈ នៃកម្មករនិយោជិត ការចុះបញ្ជិកាកំណត់ហេតុបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក ។

ការបង្កើតការិយាល័យថ្មីនេះ គឺក្នុងគោលបំណងសម្រួលដល់ការចុះបញ្ជិកាអង្គការវិជ្ជាជីវៈ និងការបញ្ជាក់ភាពជាតំណាងរបស់សហជីព ឱ្យបានងាយស្រួល និងឆាប់រហ័ស ។

II-<u>បែបបទចុះបញ្ជិកាអង្គការវិជ្ជាជីវៈ និងការបញ្ជាក់ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត :</u>

១-<u>ការចុះបញ្ជិកាអង្គការវិជ្ជាជីវៈ</u>

ស្ថាបនិកនៃសហជីពកម្មករនិយោជិត និង សមាគមនិយោជក ត្រូវយកសំណុំលិខិតស្នើសុំចុះបញ្ជិកា

អង្គការវិជ្ជាជីវៈ(សហជីព ឬ សមាគមនិយោជក) ទៅដាក់ជូនការិយាល័យទំនាក់ទំនងវិជ្ជាជីវៈនៃនាយកដ្ឋានអធិការកិច្ចការងារ អាសយដ្ឋានលេខ ២៨ វិថី សម្ដេចព្រះធម្មលិខិតអ៊ុក(ផ្លូវលេខ១៨៤) សង្កាត់ ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។ សំណុំលិខិតស្នើសុំចុះបញ្ជិកាអង្គការវិជ្ជាជីវៈមានចែងលំអិតនៅក្នុងប្រកាសរបស់ក្រសួងលេខ ២៧៧ សកបយ. ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០០ ។

២-ការបញ្ជាក់អំពីភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត :

សហជីពដែលមានបំណងស្នើសុំការបញ្ជាក់អំពីភាពជាតំណាង ត្រូវដាក់ពាក្យស្នើសុំការបញ្ជាក់នេះចំនួន ១១ ច្បាប់ នៅការិយាល័យទំនាក់ទំនងវិជ្ជាជីវៈនៃនាយកដ្ឋានអធិការកិច្ចការងារ ដែលមានអាសយដ្ឋានដូចបានជំរាបខាងលើ ។ ពាក្យស្នើសុំនេះ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពី :-

-ឈ្មោះសហជីព

-ក្របខណ្ឌភូមិសាស្ត្រ ឬ វិជ្ជាជីវៈដែលមានបំណងស្នើសុំបញ្ជាក់ភាពជាតំណាង

-លេខ និងថ្ងៃ ខែ ឆ្នាំ វិញ្ញាបនប័ត្រចុះបញ្ជិកា និងការកែប្រែបន្ថែមទៀត

-ចំនួនសមាជិករបស់សហជីព និងចំនួនកម្មករនិយោជិតសរុប ក្នុងក្របខ័ណ្ឌភូមិសាស្ត្រ ឬវិជ្ជាជីវៈដែលស្នើសុំការបញ្ជាក់នេះ ព្រមទាំងធ្វើការប្រៀបធៀបជាភាគរយ

-ចំនួនសមាជិករបស់សហជីពដែលបានបង់ភាគទានសហជីព និងរូបភាពបង់ភាគទាននេះ (បង់ដោយផ្ទាល់ទៅសហជីព ឬតាមរយៈការកាត់ប្រាក់ឈ្នួលដោយនិយោជក)

-កម្មវិធីការងាររបស់សហជីព គំរូពាក្យស្នើសុំការបញ្ជាក់ភាពជាតំណាងមានជូនភ្ជាប់ជាឧបសម្ព័ន្ធនៃសេចក្ដីជូនដំណឹងនេះ ។

ទន្ទឹមនេះ សហជីពសាមីត្រូវផ្ដល់នូវភស្តុតាងភ្ជាប់ជាមួយពាក្យសុំការបញ្ជាក់ ដូចខាងក្រោម:-

-សេចក្ដីថតចម្លងវិញ្ញាបនប័ត្រចុះបញ្ជិកាសហជីព

-ភស្តុតាងនៃការកែប្រែបន្ថែមទៀត ។

III-ថិរវេលានៃការចុះបញ្ជិកាអង្គការវិជ្ជាជីវៈ និងការបញ្ជាក់ភាពជាតំណាងនៃអង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត :

ក្នុងរយៈពេល ៧ ថ្ងៃយ៉ាងយូរ ក្រោយថ្ងៃដែលស្ថាបនិកសហជីព ឬ សមាគមនិយោជកបានយកសំណុំលិខិតស្នើសុំចុះបញ្ជិកាអង្គការវិជ្ជាជីវៈ ឬ សំណើសុំបញ្ជាក់អំពីភាពជាតំណាងសហជីពទៅដាក់ជូនការិយាល័យទំនាក់ទំនងវិជ្ជាជីវៈ ស្ថាបនិកសហជីព ឬសមាគមនិយោជកសាមីត្រូវទៅជួបមន្ត្រីនៃការិយាល័យនេះ ដើម្បីទទួលដំណឹងអំពីភាពសមស្រប ឬ មិនសមស្របនៃសំណុំលិខិតស្នើសុំរបស់ខ្លួន ។ ក្នុងករណីដែលសំណុំលិខិតស្នើសុំនោះមានភាពមិនសមស្របត្រង់ចំណុចណាមួយ ស្ថាបនិកនៃសាមីអង្គការវិជ្ជាជីវៈ ត្រូវទទួលយកសំណុំលិខិតនោះទៅធ្វើការកែសម្រួល ឬ បំពេញបន្ថែមអោយបានត្រឹមត្រូវរួចហើយទើបយកទៅដាក់ជូនជាថ្មីទៀត

នៅការិយាល័យទំនាក់ទំនងវិជ្ជាជីវៈ ។ រយៈពេលនៃការទទួលយកសំណុំលិខិតរបស់ខ្លួនទៅកែសម្រួល ឬ បំពេញបន្ថែមនោះ មិនគិតចូលក្នុងរយៈពេលនៃការពិនិត្យពាក្យស្នើសុំ ទាំងឡាយខាងលើនោះឡើយ ។ ករណីដែលសំណុំលិខិតស្នើសុំត្រូវបានពិនិត្យឃើញមានភាពមិនសមស្រប ហើយម្ចាស់សំណុំលិខិតមិនបានទៅជួបមន្ត្រីនៃការិយាល័យទំនាក់ទំនងវិជ្ជាជីវៈទេ មន្ត្រីនោះត្រូវផ្ញើសំណុំលិខិតនោះត្រឡប់ទៅម្ចាស់ដើមវិញ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា កំណត់រយៈពេលអតិបរមា២ខែ សំរាប់រៀបចំដំណើរការការងារទាំងពីរនេះតាមនីតិវិធីច្បាប់ ។ រយៈពេល ២ ខែ នេះនឹងត្រូវពន្យាក្នុងករណីមានការប្តឹងជំទាស់តវ៉ា ឬហេតុផលចាំបាច់ណាមួយជាយថាហេតុ ដែលទាមទារអោយមានការងារបន្ត ។

IV-នីតិវិធីនៃការតវ៉ាចំពោះការយឺតយ៉ាវនៃការដោះស្រាយសំណុំរឿង :

ក្នុងករណីពិនិត្យឃើញថា មានការយឺតយ៉ាវក្នុងការចុះបញ្ជីកាអង្គការវិជ្ជាជីវៈ និងការចេញលិខិតបញ្ជាក់ពីភាពជាតំណាងអង្គការវិជ្ជាជីវៈនៃកម្មករនិយោជិតខុសពីរយៈពេលខាងលើម្ចាស់សំណុំរឿងអាចធ្វើការតវ៉ាជាលាយលក្ខណ៍អក្សរទៅនាយកដ្ឋានអធិការកិច្ចការងារ ។ ក្រោយពីដាក់ពាក្យតវ៉ានេះរយៈពេល ០២ សប្តាហ៍ បើគ្មានការបំភ្លឺសមស្របពីនាយកដ្ឋានអធិការកិច្ចការងារទេ ម្ចាស់សំណុំរឿងអាចធ្វើការតវ៉ាដោយផ្ទាល់ទៅអគ្គនាយកនៃអគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬ ទៅរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានសង្ឃឹមយ៉ាងមុតមាំថា សហពន្ធ័សហជីព សហជីពកម្មករនិយោជិត សមាគមនិយោជក និងនិយោជកទាំងអស់ នឹងខិតខំសហការជាមួយក្រសួង ដើម្បីអនុវត្តតាមសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធិភាពខ្ពស់ ។

p

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

**ឧបសម្ព័ន្ធ**

សេចក្តីជូនដំណឹងលេខ ១៦ សកបយ.

ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សហព័ន្ធសហជីព**.........................

**សហជីព**...................................    រាជធានីភ្នំពេញ ថ្ងៃទី        ខែ        ឆ្នាំ ២០០...

**ប្រធានសហជីព** ....................................................

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**កម្មវត្ថុ**: សំណើសុំភាពជាតំណាង☐ ភាពជាតំណាងបំផុត☐ របស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត

**យោង**: -ច្បាប់ស្តីពីការងារ

-ប្រកាសលេខ ៣០៥ សកបយ.ចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ ២០០១ ស្តីពីភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈ នៃកម្មករនិយោជិតនៅថ្នាក់សហគ្រាស គ្រឹះស្ថាន និងសិទ្ធិក្នុងការចរចាជាសមូហភាព ដើម្បីចុះអនុសញ្ញារួមនៅថ្នាក់សហគ្រាស គ្រឹះស្ថាន

-សេចក្តីជូនដំណឹងលេខ ............ សកបយ.ចុះថ្ងៃទី........ខែ........ឆ្នាំ២០០២ ស្តីពីការចុះបញ្ជិកាអង្គការវិជ្ជាជីវៈ និងការបញ្ជាក់ភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត ។

សេចក្តីដូចមានចែងនៅក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបជូនឯកឧត្តមរដ្ឋមន្ត្រីបានជ្រាបថា ដើម្បីបានភាពជាតំណាងក្នុងការចរចាជាសមូហភាព ការចុះអនុសញ្ញារួម និងការដោះស្រាយបញ្ហាផ្សេងៗជាមួយនិយោជក ខ្ញុំសូមគោរពស្នើសុំឯកឧត្តមរដ្ឋមន្ត្រីមេត្តាបញ្ជាក់ពី ភាពជាតំណាង ☐ ភាពជាតំណាងបំផុត ☐ របស់សហជីពខ្ញុំបាទ/នាងខ្ញុំ ។

ពត៌មានអំពីសហជីពមានដូចខាងក្រោម :

១-ឈ្មោះអង្គការវិជ្ជាជីវៈ.......................................................................................

២-បានចុះបញ្ជិកាលេខ............សកបយ. ចុះថ្ងៃទី..................................................

៣-ក្របខ័ណ្ឌភូមិសាស្ត្រ ឬវិជ្ជាជីវៈរបស់អង្គការវិជ្ជាជីវៈ និងវិជ្ជាជីវៈ

-ឈ្មោះសហគ្រាស គ្រឹះស្ថាន.............................................................................................

-ទូទាំងសហគ្រាស គ្រឹះស្ថាន ☐

-វិជ្ជាជីវៈខ្លះនៃសហគ្រាស គ្រឹះស្ថាន ☐ បរិយាយៈ.......................................................

.........................................................................................................................

៤-ចំនួនសមាជិកសហជីព...............នាក់ និងចំនួនកម្មករសរុប ............... នាក់( ក្នុងក្របខណ្ឌភូមិសាស្ត្រ ឬវិជ្ជាជីវៈរបស់អង្គការវិជ្ជាជីវៈ និងវិជ្ជាជីវៈ)

៥-ការបង់ភាគទានៈ

-បង់ដោយផ្ទាល់ដៃ ☐ ចំនួន .......... នាក់ ស្មើនឹង ....... ភាគរយនៃសមាជិក

-បង់តាមរយៈនិយោជក ☐ ចំនួន .......... នាក់ ស្មើនឹង ....... ភាគរយនៃសមាជិក

៦-កម្មវិធីការងាររបស់សហជីពៈ

.........................................................................................................................

.........................................................................................................................

.........................................................................................................................

៧-ជូនភ្ជាប់មកជាមួយនូវៈ

-ច្បាប់ចំលងចម្លងវិញ្ញាបនប័ត្រចុះបញ្ជិកា ចំនួន ០១ ច្បាប់

-.......................................................................................................................

-.......................................................................................................................។

អាស្រ័យដូចបានជំរាបជូនខាងលើ ខ្ញុំសូមស្នើសុំសេចក្ដីបញ្ជាក់ដ៏ខ្ពង់ខ្ពស់ ពីឯកឧត្ដមរដ្ឋមន្ត្រី ដើម្បីបានភាពស្របច្បាប់ក្នុងការអនុវត្តតទៅ ។

សូមឯកឧត្ដមមេត្តាទទួលនូវការគោរពដ៏ស្មោះស្ម័គ្រ អំពីខ្ញុំ ។

**ប្រធានសហជីព**

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០០...

បានឃើញ និង សូមស្នើសុំសេចក្ដីបញ្ជាក់ដ៏ខ្ពង់ខ្ពស់អំពីឯកឧត្ដមរដ្ឋមន្ត្រី

ប្រធានសហព័ន្ធសហជីព

( ករណីសហជីពនោះជាសមាជិករបស់សហព័ន្ធសហជីពណាមួយ)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ : ០១ សករបយ

រាជធានីភ្នំពេញ . ថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០៣

# សេចក្តីជូនដំណឹង

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានកិត្តិយសជូនដំណឹងដល់គ្រប់រោងចក្រ សហគ្រាស គ្រឹះស្ថានទាំងអស់ថា យោងតាមសំណូមពររបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតតាមលិខិតលេខ ១២.០៨៨/០២ គ.ជ.ប ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០២ លោកនាយក ឬ ម្ចាស់រោងចក្រ សហគ្រាស គ្រឹះស្ថានទាំងអស់ត្រូវបង្កលក្ខណៈ និង អនុញ្ញាតឱ្យកម្មករនិយោជិតទៅពិនិត្យផ្ទៀងឈ្មោះរបស់ខ្លួនជាមួយបញ្ជីបោះឆ្នោតឆ្នាំ ២០០២ ទៅចុះឈ្មោះបោះឆ្នោត ព្រមទាំងទៅចូលរួមការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ ដែលនឹងប្រព្រឹត្តទៅតាមកាលបរិច្ឆេទដូចខាងក្រោម :

- នៅថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០០៣ គ.ជ.ប នឹងធ្វើការបិទផ្សាយបញ្ជីបោះឆ្នោតឆ្នាំ ២០០២ នៅតាមសាលា ឃុំ-សង្កាត់ និងនៅតាមការិយាល័យបោះឆ្នោត ២០០២ ក្នុងគោលបំណងឱ្យប្រជាពលរដ្ឋមកពិនិត្យឈ្មោះរបស់ខ្លួន ។
- ការចុះឈ្មោះបោះឆ្នោតមានរយៈពេល ៣០ថ្ងៃ គឺចាប់តាំងពីថ្ងៃទី១៧ ខែមករា ដល់ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៣ នឹងត្រូវធ្វើនៅសាលាឃុំ-សង្កាត់ ឬនៅតាមការិយាល័យចុះឈ្មោះណាមួយក្នុងឃុំ-សង្កាត់ ។
- ការបោះឆ្នោតនឹងប្រព្រឹត្តទៅ នៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៣ ។ ប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៅការិយាល័យណា ត្រូវទៅបោះឆ្នោតនៅការិយាល័យនោះ ។

ក្នុងគោលបំណងបង្កលក្ខណៈឱ្យនិយោជិត កម្មករ-កម្មការិនី បានអនុវត្តសិទ្ធិរបស់ខ្លួនក្នុងការចូលរួមបោះឆ្នោតប្រកបដោយលក្ខណៈសេរី ត្រឹមត្រូវ យុត្តិធម៌ និងប្រជាធិបតេយ្យ ចំនួនថ្ងៃដែលត្រូវអនុញ្ញាតជូនកម្មករនិយោជិតសំរាប់សកម្មភាពខាងលើនេះ ត្រូវប្រព្រឹត្តតាមការកំណត់ដូចខាងក្រោមនេះ :-

| ល.រ | ទីតាំងរបស់រោងចក្រ សហគ្រាស គ្រឹះស្ថាន | ចំនួនថ្ងៃដែលត្រូវអនុញ្ញាតច្បាប់ | | ផ្សេងៗ |
|---|---|---|---|---|
| | | ការពិនិត្យបញ្ជីឈ្មោះ ឬ ការចុះឈ្មោះ | ការបោះឆ្នោត | |
| ១ | រាជធានីភ្នំពេញ | ១ថ្ងៃ គឺ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០៣ | ១ ថ្ងៃ គឺ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៣ | |
| ២ | ពីរាជធានីភ្នំពេញ ទៅ ខេត្តកណ្ដាល ខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តកំពង់ធំ ខេត្តកំពត ក្រុងកែប ខេត្តតាកែវ និងក្រុងព្រះសីហនុ | ៣ថ្ងៃ គឺ ថ្ងៃទី ៣១ ខែ មករា ថ្ងៃទី ០១-០២ ខែ កុម្ភៈ ឆ្នាំ ២០០៣ | ៣ថ្ងៃ គឺ ថ្ងៃទី ២៦-២៧-២៨ ខែ កក្កដា ឆ្នាំ ២០០៣ | |
| ៣ | ពីរាជធានីភ្នំពេញ ទៅ ខេត្ត-ក្រុង ដទៃទៀតក្រៅពី ខេត្ត-ក្រុង ទាំងអស់ខាងលើ | ៤ថ្ងៃ គឺ ថ្ងៃទី ៣១ ខែ មករា ថ្ងៃទី ០១-០២-០៣ ខែកុម្ភៈ ឆ្នាំ ២០០៣ | ៤ថ្ងៃ គឺថ្ងៃទី ២៥-២៦ ២៧-២៨ ខែ កក្កដា ឆ្នាំ ២០០៣ | |

ចំពោះរោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលមានទីតាំងនៅខេត្ត-ក្រុងដទៃទៀត ក្រៅពីរាជធានី-ភ្នំពេញ និយោជកត្រូវអនុញ្ញាតច្បាប់ជូនកម្មករនិយោជិតទៅបោះឆ្នោតតាមចំនួនថ្ងៃដូចមានចែងក្នុងចំណុចទី ១ ទី២ និងទី៣ ខាងលើដែរ ដោយយកខេត្ត-ក្រុងនីមួយៗធ្វើជាមូលដ្ឋានដើមដូចគ្នានឹងរាជធានីភ្នំពេញដែរ ។

ឧទាហរណ៍: កម្មករនិយោជិត ធ្វើការនៅរោងចក្រ សហគ្រាស គ្រឹះស្ថាននៅក្រុងព្រះសីហនុ ហើយត្រូវបោះឆ្នោតនៅក្រុងព្រះសីហនុ និយោជកត្រូវអនុញ្ញាត ច្បាប់ជូនកម្មករនិយោជិតចំនួន ០១ ថ្ងៃ ប៉ុន្តែបើកម្មករនិយោជិតត្រូវទៅបោះឆ្នោតនៅរាជធានីភ្នំពេញ និយោជកត្រូវអនុញ្ញាតច្បាប់ជូនកម្មករនិយោជិតចំនួន ០៣ ថ្ងៃ ។

ក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមគូសបញ្ជាក់ប្រការមួយចំនួនដែលគួរយកចិត្តទុកដាក់គឺ :

- រាល់ការអនុញ្ញាតច្បាប់ជូននិយោជិត កម្មករ-កម្មការិនី ដូចមានចែងខាងលើ និយោជកត្រូវរក្សាទុកប្រាក់ឈ្នួល និងប្រាក់រង្វាន់ធ្វើការទៀងទាត់ជូនកម្មករនិយោជិតនៅដដែល ។

- ចំពោះនិយោជិត កម្មករ-កម្មការិនី ដែលអវត្តមានហួសពីច្បាប់អនុញ្ញាតដូចមានចែងខាងលើត្រូវទទួលខុសត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់រោងចក្រ សហគ្រាស គ្រឹះស្ថាន ។

- និយោជកត្រូវខិតខំបើកប្រាក់ឈ្នួលឱ្យនិយោជិត កម្មករ-កម្មការិនី ឱ្យបានមុនថ្ងៃពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ព្រមទាំងថ្ងៃទៅបោះឆ្នោត ។ បើពុំមានលទ្ធភាពបើកប្រាក់ឈ្នួលទាន់ទេ សូមអនុញ្ញាតឱ្យនិយោជិត កម្មករ-កម្មការិនីខ្ចីប្រាក់ឈ្នួលមួយភាគ (បុរេប្រទាន) ជាមុនសិន។

ក្រសួងមានសេចក្ដីសង្ឃឹមយ៉ាងមុតមាំថា អស់លោកជាម្ចាស់ និងជានាយករោងចក្រ សហគ្រាស គ្រឹះស្ថានទាំងអស់ និយោជិត កម្មករ-កម្មការិនី នឹងអនុវត្តតាមសេចក្ដីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាព ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច ការងារ**
**បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**
**លេខ : ០៨ សគបយ**

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០៣

# សេចក្តីណែនាំ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមធ្វើការណែនាំដល់នាយកដ្ឋានអធិការកិច្ចការងារ មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង និងមន្ត្រីផ្សះផ្សាវិវាទការងាររួមថា នៅពេលបានទទួលដំណឹង ឬបានទទួលពាក្យប្តឹងអំពីវិវាទការងាររួម ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការដោះស្រាយវិវាទនោះ ។ ក្នុងរយៈពេល ១៥ ថ្ងៃយ៉ាងយូរ គិតចាប់ពីពេលបានទទួលសេចក្តីបង្គាប់ពីរដ្ឋមន្ត្រី បើការដោះស្រាយមិនបានលទ្ធផលសះជានឹងគ្នាទេ អ្នកផ្សះផ្សាត្រូវបញ្ជូនសំណុំរឿងស្តីពីការមិនសះជា ទៅជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា យ៉ាងយូរបំផុតក្នុងរយៈពេល ៤៨ ម៉ោង ក្រោយពីពេលបញ្ចប់ការផ្សះផ្សា ។ មន្ត្រីផ្សះផ្សាត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម :

## I. **ជំហានទី១: ការកសាងសំណុំរឿង**

១- ធ្វើរបាយការណ៍ក្នុងនាមអ្នកផ្សះផ្សា ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដោយកត់ត្រាឱ្យបានច្បាស់លាស់អំពីចំណុចដែលគូភាគីមិនយល់ព្រមសះជានឹងគ្នា ។ របាយការណ៍នេះ ត្រូវមានចំណារបញ្ជាក់របស់ប្រធានអង្គភាពនៃមន្ត្រីផ្សះផ្សាវិវាទនោះ ( ប្រធាននាយកដ្ឋានអធិការកិច្ចការងារ ឬប្រធានមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត-ក្រុង) ។

២- ព្រាងលិខិតក្នុងនាមក្រសួង ដើម្បីប្តឹងទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ( គំរូជូនភ្ជាប់ ) ។

## II- **ជំហានទី២: ការបញ្ជូនសំណុំរឿង**

ក- សំណុំរឿងផ្ញើជូនរដ្ឋមន្ត្រី:

១-របាយការណ៍របស់អ្នកផ្សះផ្សា ( ឯកសារចំណុច១ នៃជំហានទី១)

២-កំណត់ហេតុនៃការផ្សះផ្សាវិវាទ ( ឯកសារពេលផ្សះផ្សា)

៣-សេចក្តីព្រាងលិខិតប្តឹងទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល( ឯកសារចំណុចទី២ នៃជំហានទី១)

ខ- <u>សំណុំរឿងចម្លងផ្ញើជូនលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល</u> :

១-របាយការណ៍របស់អ្នកផ្សះផ្សា

២-កំណត់ហេតុនៃការផ្សះផ្សាវិវាទ

ការបញ្ជូនសំណុំរឿងក្នុងចំណុច "ក" និង "ខ" នេះត្រូវឱ្យអ្នកទទួលសំណុំរឿងចុះហត្ថលេខាថា បានទទួលព្រមទាំងសរសេរឈ្មោះ និងកាលបរិច្ឆេទឱ្យបានច្បាស់លាស់ ។ ដីកាអមនេះត្រូវទុកជាឯកសារក្នុងសំណុំរឿងវិវាទនីមួយៗ ។

III- **<u>ជំហានទី៣</u>:**

ពេលបានការឯកភាពពីរដ្ឋមន្ត្រីលើលិខិតប្តឹងទៅក្រុមប្រឹក្សាអាជ្ញាកណ្តាលហើយ ត្រូវផ្ញើលិខិតនោះទៅលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលមានអាសយដ្ឋានជាន់ទី ៣ អគារ " A " នៃមជ្ឈមណ្ឌលភ្នំពេញ កាច់ជ្រុងផ្លូវសុធារស និងមហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។ ការបញ្ជូនលិខិតនេះ ត្រូវមានដីកាអម និងអនុវត្តដូចចំណុច " ក " និង " ខ " នៃជំហានទី២ខាងលើ ។

នាយកដ្ឋានអធិការកិច្ចការងារ មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង និងមន្ត្រីអ្នកផ្សះផ្សាវិវាទការងាររួម ត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមការណែនាំនេះ ។

**ជ.រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**អនុរដ្ឋលេខាធិការ**

**ហត្ថលេខា និង ត្រា**

p **សយ ស៊ីផុន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ : ១១ សកបយ

រាជធានីភ្នំពេញ . ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៣

# សេចក្តីជូនដំណឹង

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជំរាបដល់ម្ចាស់ នាយក សហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតទាំងអស់បានជ្រាបថា កន្លងទៅក្រសួងសង្កេតឃើញថាភាគីទាំងពីរ គឺនិយោជក និងកម្មករនិយោជិត ច្រើនតែប្រើប្រាស់លិខិតបញ្ជាក់ទីលំនៅតែមួយមុខសំរាប់ជំនួសឯកសារអត្រានុកូលដ្ឋានភ្ជាប់ក្នុងពាក្យសុំចូលធ្វើការងារនៅតាមសហគ្រាស គ្រឹះស្ថាន ។

ការអនុវត្តរបៀបនេះ នាំអោយមានការលំបាកដល់ការពិនិត្យអំពីអាយុរបស់សាមីកម្មករនិយោជិតដែលសុំចូលបំរើការងារ ។

ក្នុងគោលបំណងបង្កភាពងាយស្រួលដល់ការត្រួតពិនិត្យអំពី អាយុពិតប្រាកដរបស់អ្នកសុំការងារធ្វើ ក្រសួងសូមភាគីទាំងពីរប្រើប្រាស់ឯកសារណាមួយក្នុងចំណោមឯកសារដែលរៀបរាប់ខាងក្រោមនេះ (ដោយផ្តល់ជាឯកសារ ដែលបានចម្លងត្រឹមត្រូវតាមច្បាប់) :- p

- អត្តសញ្ញាណប័ណ្ណប្រជាជន
- សំបុត្រកំណើត
- សំបុត្រអាពាហ៍ពិពាហ៍
- ប័ណ្ណគ្រួសារ
- សៀវភៅគ្រួសារ
- សញ្ញាប័ត្រ
- ប័ណ្ណបោះឆ្នោត
- ឯកសារដែលមានតម្លៃស្មើ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានសេចក្តីសង្ឃឹមជឿជាក់ថា ម្ចាស់ នាយកសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិតទាំងអស់ ប្រាកដជាអនុវត្តតាមសេចក្តីជូនដំណឹងនេះ បានល្អត្រឹមត្រូវជាពុំខាន ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ

បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ : ០១៦ សគបយ

# សេចក្តីជូនដំណឹង

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជូនដំណឹងដល់ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារ បងប្អូនកម្មករនិយោជិត សហជីព សហព័ន្ធសហជីពទាំងអស់ថា កាលពីថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៣ គណៈកម្មការប្រឹក្សាការងារបានបើកកិច្ចប្រជុំអាណត្តិទី ៤ លើកទី ៣ របស់ខ្លួន ហើយបានចេញសេចក្តីថ្លែងការណ៍អំពីការព្រមព្រៀងចំនួន ២ ចំណុច ។

ការព្រមព្រៀងគ្នាជាគោលការណ៍ចំពោះការបន្ថយប្រាក់ឈ្នួលធ្វើការពេលយប់មកត្រឹម ១៣០% នៃប្រាក់ឈ្នួលការងារពេលថ្ងៃ គឺជាការព្រមព្រៀងដើម្បីស្នើសុំធ្វើវិសោធនកម្មច្បាប់ស្តីពីការងារអំពីបញ្ហានេះ មានន័យថា បញ្ហានេះពុំទាន់មានឥទ្ធិពលផ្លូវច្បាប់សំរាប់អនុវត្តនៅឡើយទេ ។

អាស្រ័យហេតុនេះ សូមម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត សហជីព សហព័ន្ធសហជីពទាំងអស់មេត្តាជ្រាប និងបន្តអនុវត្តតាមគោលការណ៍ដែលមានជាធរមានសព្វថ្ងៃជាបន្តទៅទៀត រហូតមានការធ្វើវិសោធនកម្មច្បាប់ស្តីពីការងារ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានសេចក្តីសង្ឃឹមថា ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថាន កម្មករនិយោជិត សហជីព សហព័ន្ធសហជីពទាំងអស់ពិតជាអនុវត្តឱ្យបានត្រឹមត្រូវតាមការជូនដំណឹងនេះ ។

រាជធានីភ្នំពេញ . ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៣

រដ្ឋមន្ត្រី

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

ហត្ថលេខា និង ត្រា

អ៊ិត សំហេង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ : ០០៣ សកបយ.

រាជធានីភ្នំពេញ . ថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៤

## សេចក្តីជូនដំណឹង

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សង្កេតឃើញថា កន្លងមក រោងចក្រសហគ្រាសជាទូទៅ បានខិតខំអនុវត្តល្អពីលក្ខខណ្ឌការងារ ក៏ដូចជាវិធានអនាម័យ និងសុវត្ថិសុខការងារ ។ រយៈពេលកន្លងមកថ្មីៗនេះ មានបាតុភូតកម្មករវិលមុខ ដួលសន្លប់ ដែលជាហេតុបណ្តាលឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ និងការងាររោងចក្រមួយចំនួន ។ ដើម្បីជៀសវាងបាតុភូតមិនល្អទាំងនេះ និងដើម្បីរក្សាសុខ-ភាព សុវត្ថិភាព របស់កម្មករនិយោជិតផង ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិ-សម្បទា សូមធ្វើការណែនាំដល់ម្ចាស់ និងនាយករោងចក្រ សហគ្រាស ពិសេសរោងចក្រកាត់ដេរសំលៀកបំពាក់ និងដេរស្បែកជើង ដូចខាងក្រោមនេះ :

១-ត្រូវអនុវត្តឱ្យបានត្រឹមត្រូវនូវប្រកាស :

- លេខ ១២៥ សកបយ. ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការបញ្ចេញបញ្ចូលខ្យល់ និងការសំអាត បរិយាកាសជាអាទិ៍ "ការបញ្ចេញបញ្ចូលខ្យល់ក្នុងទីកន្លែងធ្វើការដែលគ្មាន បរិយាកាសក្រខ្វក់ ត្រូវធ្វើដោយការបក់បញ្ចូលខ្យល់តាមធម្មជាតិ ឬដោយសិប្បនិម្មិត" "ផ្ទៃក្រលានៃទ្វារ បង្អួច រន្ធខ្យល់ទាំងអស់សរុបគ្នា មិនត្រូវឱ្យទាបជាងមួយភាគបួននៃផ្ទៃក្រលារោងជាងឡើយ"

-លេខ ១៤៧ សកបយ. ចុះថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០០២ ស្តីពីបរិយាការណ៍កំដៅក្នុងទីកន្លែងធ្វើការជាអាទិ៍ "ក្នុងករណីដែលទីកន្លែងធ្វើការមានកំដៅឡើងខ្លាំង ធ្វើឱ្យប៉ះពាល់ដល់សុខភាព ឬធ្វើឱ្យទើសទាស់ដល់ការងាររបស់កម្មករនិយោជិត និយោជកត្រូវរកគ្រប់មធ្យោបាយ ដើម្បីធ្វើឱ្យទីកន្លែងធ្វើការបានត្រជាក់វិញដូចជា ដាក់កង្ហារ ម៉ាស៊ីនស្រូបខ្យល់ ឬម៉ាស៊ីនត្រជាក់ជាដើម"

-លេខ ០៥៤ សកបយ. ចុះថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ២០០០ ស្តីពីការផ្តល់ភេសជ្ជៈអនាម័យ ជាអាទិ៍ "និយោជកនៃសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា ១ នៃច្បាប់ស្តីពីការងារ ត្រូវផ្តល់ភេសជ្ជៈអនាម័យឱ្យបានគ្រប់គ្រាន់ដល់កម្មករនិយោជិតរបស់ខ្លួន" ។

២-ត្រូវប្រុងប្រយ័ត្នក្នុងការប្រើប្រាស់សារធាតុគីមីទាំងឡាយ ដូចជា Solvant Tricholéthylène, Perchloléthylène, ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ។

៣-មិនត្រូវរៀបចំឱ្យកម្មករនិយោជិតធ្វើការបន្ថែមម៉ោង លើសពីការអនុញ្ញាតរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

៤-នៅគ្រប់ពេលមានធ្វើការបន្ថែមម៉ោង ក្រៅពីប្រាក់ឈ្នួលបន្ថែមម៉ោង រោងចក្រ សហគ្រាស ត្រូវមានការបំប៉នកម្មករនិយោជិតបន្ថែមទៀត ជាចំណីអាហារដែលមានជាតិស្ករ ដូចជាភេសជ្ជៈដែលមានជាតិផ្អែម ។ល។

៥-ក្នុងករណីមានបាតុភូតកម្មករវិលមុខដួលសន្លប់កើតឡើង រោងចក្រ សហគ្រាស ត្រូវជូនដំណឹងភ្លាមទៅអគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ( អគារលេខ ២៩ ផ្លូវលេខ ១៨៤ សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ ទូរស័ព្ទ ០២៣ ៧២៤ ២៩១ - ០២៣ ៧២៥ ០៩២ - ០២៣ ៧២២ ៨៩១ ) ដើម្បីក្រសួងចាត់គណៈកម្មការអង្កេតចុះស្រាវជ្រាវរកមូលហេតុជាក់ស្តែង និងចាត់វិធានការកុំឱ្យបាតុភូតនេះកើតមានជាថ្មី ។

រោងចក្រ សហគ្រាស ត្រូវតែផ្តល់ឱកាស និងលទ្ធភាពដល់គណៈកម្មការអង្កេតរបស់ក្រសួងបានបំពេញមុខងាររបស់ខ្លួនអនុលោមតាមប្រកាសលេខ ២៤៣ សកបយ. ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ២០០២ ស្តីពីការជូនដំណឹងគ្រោះថ្នាក់ការងារ របៀបផ្តល់តាវកាលិក និងអត្រាបាត់បង់សមត្ថភាពការងារ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងចាត់វិធានការតឹងរឹងបំផុតទៅតាមច្បាប់ចំពោះម្ចាស់ ឬនាយក រោងចក្រ សហគ្រាសណាដែលប្រព្រឹត្តល្មើសលើចំណុចដែលបានរៀបរាប់ខាងលើនៃសេចក្តីជូនដំណឹងនេះ ព្រមទាំងប្រកាសនានារបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា កន្លងមក ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា មានក្តីសង្ឃឹមយ៉ាងមុតមាំថាម្ចាស់ និងនាយករោងចក្រ សហគ្រាសទាំងអស់ នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះបានល្អប្រសើរជាពុំខាន ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ
បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ : ០១៣ សកបយ.

រាជធានីភ្នំពេញ . ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៤

# សេចក្តីជូនដំណឹង
# ស្តីពី
# បទប្បញ្ញត្តិទូទៅ និងនីតិវិធីនៃការរៀបចំការបោះឆ្នោត សំរេចភាពជាតំណាងបំផុត របស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត នៅថ្នាក់សហគ្រាស គ្រឹះស្ថាន

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជំរាបជូនដំណឹងដល់កម្មករនិយោជិត សហជីព សហព័ន្ធសហជីពកម្មករនិយោជិត និងនិយោជកនៃសហគ្រាស គ្រឹះស្ថាន ទាំងអស់ឱ្យបានជ្រាបថា :

១. ផ្អែកតាមមាត្រា ២៧៧ នៃច្បាប់ស្តីពីការងារ និងប្រកាសលេខ ៣០៥ សកបយ.ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០១ ស្តីពីភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិតនៅថ្នាក់សហគ្រាស គ្រឹះស្ថាន និងសិទ្ធិក្នុងការចរចាជាសមូហភាព ដើម្បីចុះអនុសញ្ញារួមនៅថ្នាក់សហគ្រាស គ្រឹះស្ថាន ក្រសួងសំរេចមិនបញ្ជាក់ភាពជាតំណាងបំផុតរបស់សហជីព កាលណាមានការជំទាស់ពីសមាជិកគណៈកម្មការប្រឹក្សាការងារ ឬពីសហគ្រាស គ្រឹះស្ថាន ឬពីតតិយជនដែលមានការពាក់ព័ន្ធ ។

-សហព័ន្ធសហជីពណាដែលគ្មានសហជីពនៅក្នុង សហគ្រាស គ្រឹះស្ថាន ឬមានសហជីពដែលមិនទាន់បានចុះបញ្ជិកាជាផ្លូវការនៅក្នុងសហគ្រាស គ្រឹះស្ថាន ដែលមានសហជីពស្នើសុំភាពជាតំណាងបំផុតនោះមិនអាចធ្វើការជំទាស់បានទេ ។

-បន្ទាប់ពីទទួលបាននូវលិខិតជូនដំណឹងអំពីការមិនបញ្ជាក់ភាពជាតំណាងបំផុតជូនសហជីពតាមបណ្តាសហគ្រាស គ្រឹះស្ថាន ដែលចេញដោយនាយកដ្ឋានអធិការកិច្ចការងារនោះមក សហជីពសាមី ឬ សហព័ន្ធសហជីពតំណាង អាចដាក់ពាក្យស្នើសុំធ្វើការបោះឆ្នោតដើម្បីសំរេចភាពជាតំណាងបំផុត ទៅក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

២.ក្នុងរយៈពេល ២ សប្តាហ៍យ៉ាងយូរ បន្ទាប់ពីទទួលបានពាក្យស្នើសុំបោះឆ្នោតសំរេចភាពជាតំណាងបំផុត នាយកដ្ឋានអធិការកិច្ចការងារនឹងធ្វើការអញ្ជើញភាគីដែលពាក់ព័ន្ធ មានជាអាទិ៍ តំណាងគ្រប់ភាគីសហជីព ដែលមាននៅក្នុងសហគ្រាស គ្រឹះស្ថាន ព្រមទាំងតំណាងសហព័ន្ធសហជីព និងភាគីនិយោជកមកចូលរួមពិភាក្សាអំពីការរៀបចំបោះឆ្នោតនេះ ។

-ក្នុងករណីដែលដាក់ពាក្យសុំធ្វើការបោះឆ្នោតអវត្តមាន ដោយគ្មានការជូនដំណឹង និងគ្មានមូលហេតុសមស្របទេនោះ ត្រូវចាត់ទុកថាបានបោះបង់ការស្នើសុំធ្វើការបោះឆ្នោត និងការស្នើសុំភាពជាតំណាងបំផុត ។

-ក្នុងករណីភាគីដែលជំទាស់អវត្តមាន មិនបានចូលខ្លួនមកប្រជុំតាមការអញ្ជើញរបស់ក្រសួង ដោយគ្មានការជូនដំណឹងមុន និងគ្មានមូលហេតុសមស្រប ត្រូវចាត់ទុកថាឯកភាពតាមការសំរេចរបស់អង្គប្រជុំ ។

**៣.ដំណើរការនៃការរៀបចំ និងការត្រួតពិនិត្យការបោះឆ្នោត:**

ក.យោងតាមប្រកាសលេខ ៣០៥ សកបយ.ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០១ សហជីពទាំងអស់ដែលមានបំណងចូលរួមការបោះឆ្នោតនៅក្នុងសហគ្រាស គ្រឹះស្ថាន រួមទាំងភាគីនិយោជកផងដែរត្រូវអញ្ជើញចូលរួមដើម្បីពិគ្រោះអំពីនីតិវិធី ពេលវេលា និងទីកន្លែងនៃការបោះឆ្នោត ។ ការរៀបចំ និងការត្រួតពិនិត្យការបោះឆ្នោតនេះអាចប្រគល់ជូនតតីយជន ស្ថាប័នសាធារណៈដែលស្ម័គ្រចិត្តទទួលរៀបចំ និងត្រួតពិនិត្យការបោះឆ្នោត បើសិនមានការព្រមព្រៀងរបស់ភាគីដែលពាក់ព័ន្ធ ។ ក្នុងករណីដែលគ្មានអ្នកទទួលរ៉ាប់រងកិច្ចការនេះក្រសួងជាអ្នកទទួលបន្ទុករៀបចំការបោះឆ្នោត ដោយតំរូវឱ្យមានគណៈកម្មការមួយដែលរួមមាន :

-តំណាងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចំនួន ០១ រូប ជាប្រធាន ។

-តំណាងចំនួន ០១ រូប ពីសហព័ន្ធសហជីពនីមួយៗ និងតំណាងចំនួន ០៣ រូប ពីសហជីពនីមួយៗដែល ពាក់ព័ន្ធ ។

**ខ.តួនាទីរបស់គណៈកម្មការរៀបចំ និងត្រួតពិនិត្យការបោះឆ្នោតនេះមានដូចតទៅ:**

-ពិនិត្យ និងផ្ទៀងផ្ទាត់បញ្ជីឈ្មោះអ្នកបោះឆ្នោត

-រៀបចំទីកន្លែង កាលបរិច្ឆេទ នៃការបោះឆ្នោត និងសន្លឹកឆ្នោត

-សំរបសំរួលឱ្យការបោះឆ្នោតប្រព្រឹត្តទៅបានប្រកបដោយភាពត្រឹមត្រូវ

-ពន្យល់អំពីនីតិវិធីនៃការបោះឆ្នោត ពិនិត្យដំណើរការបោះឆ្នោត និងប្រកាសលទ្ធផលនៃការបោះឆ្នោត ។

**គ.អំពីនីតិវិធីបោះឆ្នោត:**

-ការបោះឆ្នោតនេះអាចធ្វើក្នុង ឬក្រៅសហគ្រាស គ្រឹះស្ថានដោយផ្ទាល់ អាស្រ័យតាមការឯកភាពនៃអង្គប្រជុំពិភាក្សា ហើយដែលអង្គការនានា អាចចូលរួមជាអ្នកសង្កេតការណ៍ ។

-សន្លឹកឆ្នោត : វាយដាក់ឈ្មោះសហជីពទាំងអស់ក្នុងសហគ្រាស គ្រឹះស្ថាន ព្រមទាំងបិទរូបថតថ្នាក់ដឹកនាំសហជីពនៅជាប់ប្រអប់គូស ( បាទ/ចាស ឬ ទេ) ។

-កាលបរិច្ឆេទ និងទីកន្លែងនៃការបោះឆ្នោតត្រូវជូនដំណឹងដល់កម្មករនិយោជិតយ៉ាងតិចប្រាំពីរថ្ងៃគត់មុនថ្ងៃបោះឆ្នោត ដោយពុំរាប់បញ្ចូលថ្ងៃបុណ្យ ឬថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ឡើយ ។

-ការបោះឆ្នោតត្រូវធ្វើក្នុងពេលម៉ោងធ្វើការ បើមានការយល់ព្រមពីនិយោជក ។

-ការបោះឆ្នោត ត្រូវធ្វើនៅមុន ឬក្រោយពេលម៉ោងធ្វើការ ប្រសិនបើមិនមានការយល់ព្រមពីនិយោជកឱ្យធ្វើការបោះឆ្នោតក្នុងម៉ោងធ្វើការទេ ។

-ការបោះឆ្នោត ត្រូវធ្វើនៅកន្លែងធ្វើការ បើមានការយល់ព្រមពីនិយោជក ឬនៅទីណាជិតកន្លែងធ្វើការប្រសិនបើគ្មានការយល់ព្រមពីនិយោជកទេ ។

-កម្មករនិយោជិតទាំងអស់ដែលធ្វើការនៅក្នុងសហគ្រាស គ្រឹះស្ថាននេះយ៉ាងតិច ០៣ ខែ ដោយគិតចាប់ពីថ្ងៃចូលសាកល្បងការងារ ទើបអាចមានសិទ្ធិចូលរួមការបោះឆ្នោត ។

-សហជីពទាំងអស់អាចធ្វើការផ្សព្វផ្សាយ ផ្តល់ព័ត៌មានសំរាប់ការបោះឆ្នោតដល់សមាជិករបស់ខ្លួននូវកាលបរិច្ឆេទ ទីកន្លែងទំរង់សន្លឹកឆ្នោត នីតិវិធីនៃការបោះឆ្នោតជាដើមនៅក្រៅម៉ោងធ្វើការ ។

-កម្មករនិយោជិតដែលមានសិទ្ធិបោះឆ្នោតត្រូវគូសលើសន្លឹកឆ្នោតនូវសញ្ញា " ✓ " ឬ សញ្ញា " + " នៅក្នុងប្រឡង់រាងបួនជ្រុងនៅជាប់ប្រអប់គូស ( បាទ/ចាស ឬ ទេ) ខាងមុខឈ្មោះសហជីពតែមួយគត់ដែលពេញចិត្ត រួចបត់សន្លឹកឆ្នោតឱ្យបានល្អ និងយកទៅដាក់ចូលក្នុងហិបឆ្នោតគ្រប់ៗគ្នាតាម លំដាប់លំដោយ ។

-សន្លឹកឆ្នោតទាំងឡាយណាដែលមិនបានគូស ឬគូសខុសពីការកំណត់ខាងលើ ឬការសរសេរ ការចុះហត្ថលេខា ការគូសវាសផ្សេងៗ ត្រូវចាត់ទុកសន្លឹកឆ្នោតនោះជាមោឃៈ ។

-តំណាងសហព័ន្ធសហជីព អង្គការជាតិ និងអន្តរជាតិដែលពាក់ព័ន្ធ មានសិទ្ធិចូលរួមសង្កេតការណ៍ ។

**ឃ-ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលៈ**

-ត្រូវធ្វើការរាប់សន្លឹកឆ្នោតជាសាធារណៈ បន្ទាប់ពីការបោះឆ្នោតត្រូវបានបញ្ចប់ភ្លាម ។ ក្នុងករណីការរាប់សន្លឹកឆ្នោតមិនអាចធ្វើទៅបានដោយសារមូលហេតុពេលវេលា ឬករណីផ្សេងទៀត នោះគណៈកម្មការបោះឆ្នោតត្រូវរក្សាទុកហិបឆ្នោតក្នុងទីកន្លែងសុវត្ថិភាព ចាក់សោរ និងផ្តិតបៃមានចុះហត្ថលេខា គណៈកម្មការរៀបចំការបោះឆ្នោត ។

-ហិបឆ្នោតត្រូវបានប្រមូលផ្តុំនៅកន្លែងមួយដែលកំណត់ដោយគណៈកម្មការបោះឆ្នោត ។

-ត្រូវបើកហិបឆ្នោត រួចយកសន្លឹកឆ្នោតមករាប់ ដោយធ្វើការផ្ទៀងផ្ទាត់សន្លឹកឆ្នោត ដែលបានចែកជូនអ្នកបោះឆ្នោត ។

-ត្រូវសរសេរឈ្មោះសហជីព ដែលបានចូលរួមប្រកួតប្រជែងនៅលើក្តារខៀន រួចបើកសន្លឹកឆ្នោតរាប់យកលទ្ធផលសន្លឹកឆ្នោតណាដែលបានការ ។

-លទ្ធផលត្រូវប្រកាសដោយប្រធានរៀបចំការបោះឆ្នោតភ្លាមៗ បន្ទាប់ពីការរាប់សន្លឹកឆ្នោតចប់ភ្លាម

-ក្រសួងនឹងចេញវិញ្ញាបនប័ត្របញ្ជាក់ភាពជាតំណាងបំផុត មិនឱ្យលើសពី ១៥ ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសលទ្ធផលឆ្នោត ។

-រាល់ការធ្វើការឧបាស្រ័យទាក់ទងដល់ភាពត្រឹមត្រូវនៃការបោះឆ្នោត ឬលទ្ធផលនៃការបោះឆ្នោតត្រូវតែដាក់ជូនតុលាការមានសមត្ថកិច្ចក្នុងរយៈពេល ៨ ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសលទ្ធផល ។ ការប្តឹងទៅតុលាការ ត្រូវចម្លងជូនមកនាយកដ្ឋានអធិការកិច្ច និងសហជីពដែលឈ្នះឆ្នោតជ្រាបជាពតិមាន ។

-ក្នុងពេលតុលាការមិនទាន់សំរេចថាយ៉ាងណានោះ សហជីពឈ្នះឆ្នោត នៅតែមានសិទ្ធិជាតំណាងបំផុតក្នុងការចរចាអនុសញ្ញារួមជានិច្ច ។

ក្រសួងសង្ឃឹម និងជឿជាក់លើការសហការរបស់គ្រប់ភាគីដែលពាក់ព័ន្ធ ដើម្បីធានាឱ្យការបោះឆ្នោតនេះ ប្រព្រឹត្តទៅដោយភាពត្រឹមត្រូវ សំដៅធានាដល់ភាពយុត្តិធម៌ ក្នុងការបញ្ជាក់ភាពជាតំណាងបំផុតជូនសហជីពតាមបណ្តាសហគ្រាស គ្រឹះស្ថាន ដើម្បីសហជីពទទួលបានផលប្រយោជន៍ និងសិទ្ធិស្របច្បាប់ក្នុងការងាររបស់ខ្លួន ។

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

p **អ៊ិត សំហេង**

# ប្រកាសថ្មី...

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ: ១៣៨ ក.ក.ប.វ/ប្រ.ក

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៦

# ប្រកាស

## ស្តីពី

## ការតែងតាំងគណៈកម្មការប្រឹក្សាការងារ

### រដ្ឋមន្ត្រីក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៤៧ អនុក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៦ ស្តីពីសមាសភាព និងការប្រព្រឹត្តទៅនៃគណៈកម្មការប្រឹក្សាការងារ

## ស ម្រេ ច

**ប្រការ១.-**

តែងតាំងសមាជិកពេញសិទ្ធិនៃគណៈកម្មការប្រឹក្សាការងារអាណត្តិទី៦ នៅអមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១-ឯកឧត្តម វង សូត | រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ជាប្រធាន |
| ២-លោក ប៊ុន ប៊ុណ្ណារិទ្ធ | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៣-លោក មាន សុភា | តំណាងក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| ៤-លោក គីម ទូច | តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ជាសមាជិក |

| | | |
|---|---|---|
| ៥-វេជ្ជ. សុខ ប៉ូ | តំណាងក្រសួងសុខាភិបាល | ជាសមាជិក |
| ៦-លោក ប៊ុន លី | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| ៧-លោកជំទាវ យូ អយ | តំណាងក្រសួងកិច្ចការនារី | ជាសមាជិក |
| ៨-លោក សំ ខាន់ឌី | តំណាងក្រសួងបរិស្ថាន | ជាសមាជិក |
| ៩-លោក មាស ម៉ូនីកា | តំណាងក្រសួងសាធារណៈការ និងដឹកជញ្ជូន | ជាសមាជិក |
| ១០-ឯកឧត្តម ប្រាក់ ចាន់ធឿន | តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា | ជាសមាជិក |
| ១១-ឧត្តមសេនីយ៍ត្រី គ្រី ទូច | តំណាងក្រសួងមហាផ្ទៃ | ជាសមាជិក |
| ១២-លោក ភួង វណ្ណៈ | តំណាងក្រសួងទេសចរណ៍ | ជាសមាជិក |
| ១៣-លោក នាង ស៊ីណាវឌ្ឍនៈ | តំណាងក្រសួងយុត្តិធម៌ | ជាសមាជិក |
| ១៤-លោក អន សុផាណារ៉ា | តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ជាសមាជិក |
| ១៥-លោក ជួន មុំថុល | តំណាងសហព័ន្ធសហជីពខ្មែរ | ជាសមាជិក |
| ១៦-លោក សោម អូន | តំណាងសហព័ន្ធសហជីពកម្មករកម្ពុជា | ជាសមាជិក |
| ១៧-អ្នកស្រី ទេព គីមវណ្ណារី | តំណាងសហព័ន្ធសហជីពឯករាជ្យកម្ពុជា | ជាសមាជិក |
| ១៨-លោក ហេង ប៊ុនឈុន | តំណាងសហព័ន្ធសហជីពឧស្សាហកម្មស្បៀងកម្ពុជា | ជាសមាជិក |
| ១៩-អ្នកស្រី ម៉ម ញឹម | តំណាងសហព័ន្ធសហជីពជាតិនៃឧស្សាហកម្មវាយនភ័ណ្ឌកាត់ដេរកម្ពុជា | ជាសមាជិក |
| ២០-លោក អាត់ ធន់ | តំណាងសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា p | ជាសមាជិក |
| ២១-លោក លី គាំ | តំណាងសម្ព័ន្ធសហជីពវិស័យទេសចរណ៍ និងសេវាកម្មកម្ពុជា | ជាសមាជិក |
| ២២-លោក វ៉ាន់ ស៊ូអៀង (Mr.Vann Sou Ieng) | តំណាងសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា | ជាសមាជិក |
| ២៣-លោក គង់ សាង | តំណាសមាគមរោងចក្រកាត់ដេរនៅកម្ពុជា | ជាសមាជិក |
| ២៤-លោក កែន លូ (Mr.Ken Loo) | តំណាងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា | ជាសមាជិក |
| ២៥-លោក ហូ វណ្ណី | តំណាងសមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា | ជាសមាជិក |
| ២៦-លោក លីវែវ វែន ឌឺ បឺត (Mr.Lievev Van Der Borght) | តំណាងក្លឹបពាណិជ្ជកម្មអន្តរជាតិ | ជាសមាជិក |
| ២៧-លោក ឡើប ឡេង | តំណាងសភាពាណិជ្ជកម្មកម្ពុជា | ជាសមាជិក |

២៨-លោក រ៉េ ជូ តំណាងក្រុមប្រឹក្សាពាណិជ្ជកម្មម៉ាឡេស៊ីកម្ពុជា ជាសមាជិក
(Mr.Ray Chu)

**ប្រការ២.-**

តែងតាំងសមាជិកបំរុងនៃគណៈកម្មការប្រឹក្សាការងារអាណត្តិទី៦ ដែលមានសមាសភាពដូចតទៅ :

១-លោក ចាប សុវណ្ណ តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក

២-លោក ឱក ដារាវិទ្ធិ តំណាងក្រសួងពាណិជ្ជកម្ម ជាសមាជិក

៣-លោក កែវ សុវត្ថិ តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ជាសមាជិក

៤-លោក ធូ យ៉ុន តំណាងក្រសួងសុខាភិបាល ជាសមាជិក

៥-លោក សុក ហ៊ាង តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាសមាជិក

៦-លោកជំទាវ ជូ ប៊ុនអេង តំណាងក្រសួងកិច្ចការនារី ជាសមាជិក

៧-លោក ប៉ាន់ បូណុច តំណាងក្រសួងបរិស្ថាន ជាសមាជិក

៨-លោក ដួង ពេជ្រ តំណាងក្រសួងសាធារណៈការ និងដឹកជញ្ជូន ជាសមាជិក

៩-លោក សឹង ម៉ុន តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាសមាជិក

១០-ឧត្តមសេនីយ៍ត្រី សួស អង្គារី តំណាងក្រសួងមហាផ្ទៃ ជាសមាជិក

១១-លោក អ៊ុំ ផល្លី តំណាងក្រសួងទេសចរណ៍ ជាសមាជិក

១២-លោក សរ ភូមរា តំណាងក្រសួងយុត្តិធម៌ ជាសមាជិក

១៣-លោក សារ សំបូរ តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាសមាជិក

១៤-លោក វង្ស សុវណ្ណ តំណាងសហព័ន្ធសហជីពការងារកម្មករកម្ពុជា ជាសមាជិក

១៥-លោក ចេន ណេន តំណាងសហព័ន្ធសហជីពលើកស្ទួយសិទ្ធិកម្មករ ជាសមាជិក

១៦-លោក គឹម ចាន់សំណាង តំណាងសហព័ន្ធសហជីពកម្មករប្រជាធិបតេយ្យជឿនលឿន ជាសមាជិក

១៧-លោក ណៃ សុខវាសនា តំណាងសហព័ន្ធសហជីពសាមគ្គីភាព ជាសមាជិក

១៨-លោកស្រី កេន ឆេងឡាង តំណាងសហព័ន្ធសហជីពកម្មករសំណង់កម្ពុជា ជាសមាជិក

១៩-លោក លូ សាក់ តំណាងសហព័ន្ធសហជីពឧស្សាហកម្មកម្ពុជា ជាសមាជិក

២០-លោក អ៊ិន តារា តំណាងសហព័ន្ធសហជីពសាមគ្គីឯករាជ្យ និងប្រជាធិបតេយ្យ ជាសមាជិក

២១-អ្នកស្រី សាន់ដ្រា ដាម៉ីកូ តំណាងសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា ជាសមាជិក
(Ms.Sandra D' Amico)

២២-លោក ជាតិ ខេមរា តំណាងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា ជាសមាជិក

២៣-លោកឧកញ៉ា សូ ងួន តំណាងសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា ជាសមាជិក

២៤- លោក ឱម ផារិន   តំណាងសមាគមទីភ្នាក់ងារទេសចរណ៍កម្ពុជា   ជាសមាជិក

២៥-លោក តាន់ បូរ័ត្ន   តំណាងសភាពាណិជ្ជកម្មកម្ពុជា   ជាសមាជិក

២៦-លោក ម៉ារ៉ា ស៊ីនតា   តំណាងសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា   ជាសមាជិក
(Mr. Marae Ciantar)

២៧-លោក យ៉ាំ ស៊ុយសាន   តំណាងសមាគមពាណិជ្ជកម្ម ចិន ហុងកុង ម៉ាកាវ កម្ពុជា   ជាសមាជិក
(Mr. Yong Sui San)

**ប្រការ៣.-**

ក្នុងករណីដែលឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អវត្តមាន ឬជាប់រវល់កិច្ចការមមាញឹក លោកអាចផ្ទេរសិទ្ធិជូនឯកឧត្តមរដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ឬឯកឧត្តមអគ្គនាយកការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទទួលភារកិច្ចជាប្រធានស្តីទីនៃគណៈកម្មការប្រឹក្សាការងារ ។

**ប្រការ៤.-**

គណៈកម្មការប្រឹក្សាការងារត្រូវរួមប្រជុំតាមការកំណត់ និងការអញ្ជើញរបស់ប្រធាន ។

**ប្រការ៥.-**

ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**ហត្ថលេខា និងត្រា**

**វង សូត**